# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃព្រះរាជទាន

ហ្គារី ឃីស៊ី

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃព្រះរាជទាន

ហ្គារី ឃីស៊ី

*បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃព្រះរាជទាន*
*រក្សាសិទ្ធិ© ២០២០ ដោយ ហ្គារីឃីស៊ី (Gary Keesee)*

សម្រាប់សម្រង់ខគម្ពីរគឺបានដកស្រង់ចេញពីព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន ឆ្នាំ២០០៥ ដោយ សមាគមព្រះគម្ពីរកម្ពុជា ©រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ២០០៥ - ដកស្រង់ដោយមានការអនុញ្ញាត។

សៀវភៅនេះ (ច្បាប់ដើមជាភាសាអង់គ្លេស) ត្រូវបានបោះពុម្ពនៅសហរដ្ឋអាមេរិក។ រក្សាសិទ្ធិគ្រប់យ៉ាងក្រោមច្បាប់ស្តីអំពីសិទ្ធិអ្នកនិពន្ធអន្តរជាតិ។ សម្រាប់មាតិកា និង/ឬក្របសៀវភៅនេះនឹងមិនត្រូវផលិតឡើងវិញទាំងស្រុង ឬតាមផ្នែកនៅក្នុងទម្រង់ណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគ្រឹះស្ថានបោះពុម្ពផ្សាយឡើយ។

លេខ ISBN: 978-1-945930-52-2
បោះពុម្ពផ្សាយដោយ Free Indeed Publishers ។
ធ្វើការចែកចាយដោយ Faith Life Now

Faith Life Now
P.O. Box 779
New Albany, OH 43054
1-(888)-391-LIFE

អ្នកអាចទំនាក់ទំនងទៅកាន់ព័ន្ធកិច្ច Faith Life Now តាមប្រព័ន្ធអ៊ីនធឺណិតតាមគេហទំព័រ www.faithlifenow.com

# បញ្ជីមាតិកា


បញ្ជីមាតិកា ..... v

សេចក្តីផ្តើម ..... 1

ជំពូក ១ ពន្លឺបំភ្លឺនៅក្នុងសេចក្តីងងឹត ..... 21

ជំពូក ២ ការគិតក្នុងរបៀបថ្មីមួយ ..... 45

ជំពូក ៣ បញ្ហាពាក់ព័ន្ធនឹងដែនអំណាចគ្រប់គ្រង ..... 73

ជំពូក ៤ តើអ្នកចាំឬទេ? ..... 113

ជំពូក ៥ ការផ្តល់អំណាចដល់ ព្រះរាជទានរបស់អ្នក ..... 139

ជំពូក ៦ ជំនឿគឺជាកូនសោ ..... 181

ជំពូក ៧ ការព្រមាន៖ ចូររក្សាជំនឿ ដែលអ្នកមាន! ..... 205

ជំពូក ៨ អ្នកត្រូវការផែនការមួយ! ..... 229

ជំពូក ៩ ដល់ពេលចេញទៅហើយ! ..... 251

# សេចក្ដីផ្ដើម

ចំណងជើងនៃសៀវភៅនេះអាចហាក់ដូចជាគ្មានគំនិត ជាអ្វីដែលជាការបញ្ជាក់ការពិតជាក់ស្ដែង។ ខ្ញុំចង់និយាយថា តើអ្នកណានឹងប្រកែកពីគុណសម្បត្តិរបស់វា? ខ្ញុំគិតថាយើងទាំងអស់គ្នានឹងយល់ស្របថាការមានព្រះរាជទាន (ការផ្គត់ផ្គង់) ការផ្គត់ផ្គង់សម្រាប់អ្វីដែលយើងត្រូវការក្នុងជីវិត គឺជាការចាំបាច់។ ប៉ុន្តែ មនុស្សជាច្រើនមិនមានការផ្គត់ផ្គង់ដែលពួកគេត្រូវការ។ តាមពិត មនុស្សជាច្រើនកំពុងតស៊ូដើម្បីឱ្យមានគ្រប់គ្រាន់ដើម្បីរស់នៅ។ ពួកគេរស់នៅក្នុងជីវិតទាសករចំពោះវិក្កយបត្រ និងបំណុលដែលហាក់ដូចជាគ្មានទីបញ្ចប់។ ជំនួសឱ្យការរស់នៅក្នុងក្ដីស្រមៃរបស់ពួកគេ ពួកគេត្រូវរស់នៅក្នុងស្ថានភាពអស់សង្ឃឹម ពោរពេញដោយភាពភ័យខ្លាចក្នុងការទៅធ្វើការដែលពួកគេស្អប់ ហើយអាក្រក់បំផុតគឺរស់នៅដោយគ្មានគោលបំណង។

ការសិក្សាថ្មីៗនេះនិយាយថា ៩៨% នៃជនជាតិអាមេរិករកចំណូលចូលផ្ទះចំនួន ៣១.៥៦១ដុល្លារ ក្នុងមួយឆ្នាំ ឬ ២.៦៣០ដុល្លារ ឬតិចជាងនេះក្នុងមួយខែ[1] ហើយ ៤០% នៃចំនួនប្រជាជនមិនអាចសរសេរមូលប្បទានបត្រសម្រាប់ $៤០០ ដោយមិនមានគម្រោងជាមុនសម្រាប់វា។[2]

តើអ្នកអាចស្រមៃគិតពីភាពតានតឹងនៃការមើលលុយរាប់កាក់រាប់សេនដែលអ្នកចំណាយ ដោយសង្ឃឹមថានឹងចាយដល់ថ្ងៃបើកប្រាក់ខែពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ មួយខែទៅមួយខែដោយមិនមើលឃើញពីទីបញ្ចប់នៃដំណើរនេះ? ជំនួសឱ្យ

---

1 https://howmuch.net/articles/how-much-americans-make-in-wages

2 https://www.cnbc.com/2018/05/22/fed-survey-40-percent-of-adults-cant-cover-400-emergency-expense.html

ការឆ្ពោះទៅមុខ អ្នកឃើញថាអ្នកកំពុងធ្លាក់ក្នុងបំណុលបន្ថែមទៀតដោយគ្មានច្រកចេញ។ ខ្ញុំអាចស្រមៃមើល ព្រោះនោះជារបៀបដែលខ្ញុំរស់នៅអស់រយៈពេលប្រាំបួនឆ្នាំ។ ហើយវាក៏មិនមែនជាការស្រមើស្រមៃរបស់ខ្ញុំដែរ។ វាជាការពិតណាស់។

## ភាពអាម៉ាស់នៃការខ្វះខាត

ភរិយាខ្ញុំ គ្រិនដា និងខ្ញុំបានរៀបការ ហើយសង្ឃឹមថានឹងចាប់ផ្តើមជីវិតដ៏អស្ចារ្យ ប៉ុន្តែយើងបានរកឃើញថាខ្លួនយើងនៅក្នុងបំណុល និងរស់នៅដោយភាពតានតឹងផ្នែកហិរញ្ញវត្ថុ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំដ៏ខ្លី យើងបានឃើញថាខ្លួនយើងមានកាតឥណទានចំនួន ១០ ដែលប្រើអស់ឥណទាន និងត្រូវបានលុបចោល កម្ចីក្រុមហ៊ុនហិរញ្ញវត្ថុចំនួនបីក្នុងអត្រាការប្រាក់ ២៨%; ការបង់ថ្លៃរថយន្តលើរថយន្តកញ្ចាស់ចំនួនពីរ ដែលមានចម្ងាយជាង ២០០.០០០ ម៉ាយលើរថយន្តទាំងនោះ; បំណុលពន្ធអាករ (IRS); និងបំណុលជាច្រើនទៀតដែលយើងមិនអាចសងបាន។ យើងជំពាក់ឪពុកម្តាយរាប់ពាន់ដុល្លាររហូតដល់គេឈប់ឱ្យយើងខ្ចីលុយ។

វាមិនដូចជាយើងកំណត់ដើម្បីបំផ្លាញជីវិតរបស់យើងដោយបំណុល យើងគ្រាន់តែព្យាយាមដើម្បីត្រដររស់។ ដូចស្តាប់ទៅដូចជាឆ្កួត ខ្ញុំស្ថិតនៅក្នុងផ្នែកហិរញ្ញវត្ថុជួយមនុស្សជាមួយនឹងតម្រូវការធានារ៉ាប់រង និងការវិនិយោគរបស់ពួកគេ។ ខ្ញុំកំពុងត្រូវបានបង់លើមូលដ្ឋានកម្រៃជើងសារ ១០០% ពីការលក់ដែលខ្ញុំនឹងធ្វើ ប៉ុន្តែកម្រៃជើងសារមិនគ្រប់គ្រាន់ទេ។ យើងបានបន្តសង្ឃឹមថាអាជីវកម្មនឹងកើនឡើង ប៉ុន្តែប៉ុន្មានសប្តាហ៍បានប្រែទៅជាឆ្នាំដោយគ្មានការផ្លាស់ប្តូរ។

នៅទីបំផុត បន្ទាប់ពីរយៈពេលប្រាំបួនឆ្នាំនៃការពឹងផ្អែកលើបំណុលដើម្បីទូទាត់វិក្កយបត្រ យើងបានអស់កម្លាំងនៅគ្រប់មធ្យោបាយនៃការខ្ចីប្រាក់ដែលយើងអាចគិតបាន។ យើងបានបញ្ចាំស្ទើរតែគ្រប់អ្វីៗទាំងអស់ដែលមានតម្លៃ ដែលយើងអាច

រកបាន ហើយភាពតានតឹងនៃការរស់នៅក្នុងភាពអាក់រអួលផ្នែកហិរញ្ញវត្ថុនោះបានចាប់ផ្ដើមធ្វើឱ្យប៉ះពាល់អារម្មណ៍ធ្ងន់ធ្ងរដល់ខ្ញុំ និងគ្រួសាររបស់ខ្ញុំ។

ខ្ញុំក៏មាននូវការវាយប្រហារភ័យស្លន់ស្លោ ហើយត្រូវបានគ្រូពេទ្យឱ្យដាក់ថ្នាំប្រឆាំងនឹងជំងឺធ្លាក់ទឹកចិត្ត ដែលពិតជាមិនបានជួយ និងបណ្ដាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងររបស់ពួកគេផ្ទាល់។ ខ្ញុំក៏ត្រូវបានគ្រូពេទ្យប្រាប់ថាខ្ញុំនឹងកើតជំងឺទឹកនោមផ្អែមដោយផ្អែកលើបញ្ហាជាតិស្ករក្នុងឈាមដែលខ្ញុំកំពុងមាន។

អាក្រក់ជាងបញ្ហាវេជ្ជសាស្ត្ររបស់ខ្ញុំ គឺការភ័យខ្លាចដែលហួសជីវិតរបស់ខ្ញុំរហូតដល់ខ្ញុំខ្លាចមិនហ៊ានចេញពីផ្ទះ។ ពិតពលោករបស់ខ្ញុំបានបិទជុំវិញខ្ញុំដោយភាពភ័យរន្ធត់ និងការឈឺចាប់ដែលកំពុងតែធ្វើឱ្យខ្ញុំខ្វិន! យើងបង់វិក្កយបត្ររបស់យើងទាំងអស់យឺតយ៉ាវ ហើយជារៀងរាល់ខែជាការពិបាកការគិតថា តើវិក្កយបត្រមួយណាដែលយើងត្រូវបង់ ហើយមួយណាដែលយើងអាចរំលងរហូតដល់ខែក្រោយ។

ខ្ញុំគិតថាទិដ្ឋភាពមួយដែលពិបាកចិត្តបំផុតនៅក្នុងភាពរញ៉េរញ៉ៃផ្នែកហិរញ្ញវត្ថុដែលយើងរស់នៅ គឺជាការអាម៉ាស់ដែលខ្ញុំមានអារម្មណ៍។ ការភ័យខ្លាចតែងរួបរឹតខ្ញុំរាល់ពេលដែលខ្ញុំប្រើកាតឥណទានដោយសង្ឃឹមថាវានឹងដំណើរការម្ដងទៀត។ ខ្ញុំបានរកឃើញថាខ្លួនខ្ញុំតែងតែបង្កើតលេស ការកុហកយ៉ាងពិតប្រាកដចំពោះអ្នកប្រមូលវិក្កយបត្រដែលទូរសព្ទមកស្ទើរតែរាល់ថ្ងៃ។ ប្រហែលជារឿងលំបាកបំផុតដែលត្រូវស៊ូទ្រាំគឺការឃើញគ្រួសារដ៏ស្រស់ស្អាតរបស់ខ្ញុំគ្មានរបស់ដែលពួកគេត្រូវការ ដែលធ្វើឱ្យខ្ញុំឈឺចាប់។ និយាយឱ្យត្រង់ទៅ ខ្ញុំមានអារម្មណ៍ថាដូចជាបរាជ័យស្ទើរតែរាល់ថ្ងៃ នៅពេលដែលខ្ញុំបានដោះស្រាយបញ្ហាមួយបន្ទាប់ពីមួយផ្សេងទៀត។

ភាពច្របូកច្របល់ផ្នែកហិរញ្ញវត្ថុនេះមិនមែនជាអ្វីដែលកើតឡើងក្នុងរយៈពេលមួយខ្លីទេ។ បញ្ហានេះបានបន្តអស់រយៈពេលប្រាំបួនឆ្នាំដ៏យូរ!

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ក្នុងករណីដែលអ្នកឆ្ងល់ មែនហើយ យើងទៅក្រុមជំនុំរៀងរាល់សប្តាហ៍។ ខ្ញុំមានសញ្ញាបត្រផ្នែកទេវវិទ្យា និងជំនួញ ហើយបានចូលរៀនសាលាព្រះគម្ពីរមួយឆ្នាំ។ ខ្ញុំបានទទួលពិធីជ្រមុជទឹកនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយខ្ញុំស្រលាញ់ព្រះជាម្ចាស់ ប៉ុន្តែមានអ្វីមួយខុសឆ្គងយ៉ាងខ្លាំង។ ខ្ញុំបានដឹងរឿងនោះ ប៉ុន្តែអ្វីទៅ? រឿងដែលខ្ញុំអានក្នុងព្រះគម្ពីរ គឺមិនមែនកើតឡើងក្នុងជីវិតពិតទេ។

យើងបានទៅក្រុមជំនុំដ៏អស្ចារ្យមួយដែលបង្រៀនយើងថា វាជាឆន្ទៈរបស់ព្រះជាម្ចាស់ដែលធ្វើឱ្យយើងចម្រុងចម្រើន ប៉ុន្តែខ្ញុំគ្រាន់តែមិនបានឃើញរឿងនោះកើតឡើង ហើយខ្ញុំក៏មិនដឹងសោះថាហេតុអ្វីបានជាវាដូច្នោះ។ និយាយឱ្យចំទៅ ខ្ញុំពិតជាមិនបានឃើញមិត្តភក្តិរបស់ខ្ញុំណាម្នាក់ចម្រុងចម្រើនដល់កម្រិតដ៏អស្ចារ្យនោះទេ។

## ការហៅឱ្យភ្ញាក់ខ្លួន

អ្វីគ្រប់យ៉ាងបានកើតឡើងនៅពេលដែលមេធាវីម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលទារប្រាក់ពីខ្ញុំបានទូរសព្ទមកទៀត។ លើកនេះគាត់ឆ្អែតឆ្អន់ហើយ៖ «លោកឃីស៊ី ខ្ញុំនឹងទុកពេលឱ្យលោកបីថ្ងៃដើម្បីផ្ញើឱ្យខ្ញុំនូវទឹកប្រាក់ ១.៦០០ដុល្លារ ដែលលោកជំពាក់អតិថិជនរបស់ខ្ញុំ បើមិនដូច្នោះទេខ្ញុំនឹងត្រូវបង្ខំចិត្តឱ្យដាក់ពាក្យប្តឹងលោកសម្រាប់ចំនួននោះ»។ បន្ទាប់មកគាត់គ្រាន់តែបិទទូរសព្ទ។

ខ្ញុំដឹងថាវាចប់ហើយ។ ខ្ញុំចប់ហើយ។ គ្មានកន្លែងណាដែលខ្ញុំមិនទាន់ហត់នោះទេ។ ខ្ញុំគ្មានលុយ ហើយក៏គ្មានអាហារដែរ។ ទូរទឹកកករបស់យើងមើលខ្សោះកក្រោះដូចគណនីធនាគាររបស់យើងអីចឹង។ ខ្ញុំបានសង្ឃឹមថា នឹងមានសប្តាហ៍មួយដែលមានអាជីវកម្មរឹងមាំ អាចទាញយើងចេញ ប៉ុន្តែវាមិនដែលកើតឡើងទេ។

ដោយក្តីអស់សង្ឃឹមយ៉ាងខ្លាំង ខ្ញុំបានឡើងទៅលើបន្ទប់គេងតូចរបស់ខ្ញុំនៅក្នុងផ្ទះចម្ការចាស់ ដែលយើងបានជួលក្នុងតម្លៃ ៣០០ ដុល្លារក្នុងមួយខែ។ ខ្ញុំបានដឹង

ថា វាមិនមែនជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលយើងរស់នៅក្នុងចំណងហិរញ្ញវត្ថុបែបនេះទេ ប៉ុន្តែយើងមិនចម្រុងចម្រើនទាល់តែសោះ ទោះបីជាយើងធ្វើអ្វីក៏ដោយ។

ពេលខ្ញុំបោះខ្លួនលើគ្រែទាំងទឹកភ្នែក ខ្ញុំស្រែកទៅកាន់ព្រះជាម្ចាស់។ អស្ចារ្យណាស់ ពេលខ្ញុំស្រែកឡើង ខ្ញុំស្រាប់តែឮទ្រង់ឆ្លើយតប។ ខ្ញុំបានឮបទគម្ពីរនេះដោយចេញពីវិញ្ញាណរបស់ខ្ញុំថា៖

> *ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។*
>
> — ភីលីព ៤:១៩

ខ្ញុំបាននិយាយខ្លាំងៗថា «ខ្ញុំស្គាល់អត្ថបទគម្ពីរនោះ ប៉ុន្តែខ្ញុំមិនឃើញរឿងនោះក្នុងជីវិតរបស់ខ្ញុំទេ»។ ពេលនោះ ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលថា៖

> «យើងមិនមានអ្វីពាក់ព័ន្ធនឹងភាពរញ៉េរញ៉ៃដែលអ្នកកំពុងជួបប្រទះនោះទេ។ មូលហេតុដែលអ្នកនៅក្នុងភាពរញ៉េរញ៉ៃនេះ គឺដោយសារតែអ្នកមិនដឹងថាតើព្រះរាជ្យរបស់យើងដំណើរការយ៉ាងដូចម្ដេច។» ទ្រង់បានបន្តប្រាប់ខ្ញុំថា ក្រុមជំនុំរបស់ទ្រង់កំពុងរស់នៅដូចអ៊ីស្រាអែលនៅសម័យស្ដេចផារ៉ោន ក្នុងនាមជាទាសករ។ ទ្រង់មានបន្ទូលថា «យើងចង់ឱ្យប្រជាជនរបស់យើងមានសេរីភាពខាងហិរញ្ញវត្ថុ!»

ទោះបីជាខ្ញុំពិតជាមិនដឹងថាទ្រង់មានន័យយ៉ាងណាអំពីព្រះរាជ្យក៏ដោយ ក៏ខ្ញុំយល់ថាការរស់នៅដោយជំពាក់បំណុលគេមិនដំណើរការទេ ហើយទ្រង់កំពុងតែបង្កប់ន័យថាមានវិធីប្រសើរជាងក្នុងការរស់នៅ ដែលខ្ញុំមិនបានរៀន។ តើនោះជាអ្វី ឬដោយរបៀបណានោះ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងថាខ្ញុំត្រូវតែស្វែងរកឱ្យឃើញ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

រឿងដំបូងដែលខ្ញុំបានធ្វើគឺចុះក្រោម ហើយចាប់ដៃខ្រិនដា។ ខ្ញុំបានប្រាប់នាងពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំ ហើយខ្ញុំអាចចាំថាបានឈរនៅទីនោះ កាន់ដៃនាង ហើយកែប្រែចិត្តគំនិតចំពោះព្រះជាម្ចាស់ និងចំពោះនាង ចំពោះភាពរញ៉េរញ៉ៃដែលខ្ញុំបានធ្វើឱ្យយើងចូល។ យើងបានប្ដេជ្ញាចិត្តនៅទីនោះថា ទោះបីជាយើងមិនយល់ថាព្រះជាម្ចាស់មានន័យយ៉ាងណាពេលទ្រង់មានបន្ទូលអំពីព្រះរាជ្យក៏ដោយ យើងនឹងស្វែងយល់។ យើងក៏បានប្ដេជ្ញាថានឹងមិនប្រើបំណុលជារបៀបរស់នៅទៀតទេ ប៉ុន្តែត្រូវទទួលស្គាល់ថាយើងមិនដឹងពីរបៀប។ ពេលយើងអធិស្ឋាន ខ្ញុំមានអារម្មណ៍អំពីសេចក្ដីសុខសាន្ត ហើយខ្ញុំដឹងថា ព្រះជាម្ចាស់នឹងបង្ហាញយើងពីរបៀបធ្វើតាមរបៀបរបស់ទ្រង់។

ប៉ុន្តែបើងាកទៅរកពាក្យថា ព្រះរាជ្យវិញ ខ្ញុំពិតជាមិនដឹងថាទ្រង់កំពុងតែនិយាយអ្វីទេ។ ខ្ញុំបានដឹងថាខ្ញុំនឹងទៅស្ថានសួគ៌ ហើយខ្ញុំបានទទួលការបណ្ដុះបណ្ដាលបន្តិចអំពីព្រះគម្ពីរ ប៉ុន្តែខ្ញុំនៅតែមិនដឹងថាទ្រង់មានន័យយ៉ាងណាទេ។ តាមពិត ពាក្យព្រះរាជ្យមិនមែនជាពាក្យដែលខ្ញុំដឹងច្រើនទេ។ ពេលវេលាតែមួយគត់ដែលខ្ញុំអាចចងចាំវាបាន គឺមានរៀបរាប់នៅក្នុងព្រះគម្ពីរ នៅក្នុងការអធិស្ឋានរបស់ព្រះអម្ចាស់។

> *សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដីដូចនៅស្ថានបរមសុខដែរ។*
>
> —ម៉ាថាយ ៦:១០

ខ្ញុំបានគិតនៅពេលនោះថា នេះគឺសំដៅទៅលើព្រះរាជ្យនាពេលអនាគតដែលព្រះយេស៊ូនឹងស្ថាបនានៅលើផែនដីនៅថ្ងៃណាមួយ ប៉ុន្តែខ្ញុំមិនដឹងថាវាសំដៅទៅលើអ្វីនោះទេ។ ប៉ុន្តែបន្ទាប់ពីពិនិត្យមើលអត្ថបទគម្ពីរ ខ្ញុំដឹងថាខ្ញុំខុស។ ព្រះយេស៊ូកំពុងប្រាប់យើងពីរបៀបអធិស្ឋាននៅទីនេះ ឥលូវនេះ។ យើងត្រូវអធិស្ឋានឱ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅលើផែនដីនេះ។ ប៉ុន្តែ តើព្រះរាជ្យរបស់ព្រះជាម្ចាស់ជាអ្វី?

## សេចក្ដីផ្ដើម

ប្រសិនបើអ្នកបានអានសៀវភៅមុនរបស់ខ្ញុំ អ្នកអាចរំលងទៅជំពូកទី ១ ប្រសិនបើអ្នកចង់បាន ប៉ុន្តែខ្ញុំជឿថានៅពេលដែលអ្នកហៀបនឹងធ្វើការប្រលង ការពិនិត្យឡើងវិញតែងតែមានប្រយោជន៍ដល់អ្នក។ ការប្រលងរបស់អ្នក ដែលជាហ្គេមនៃជីវិត បានចាប់ផ្ដើមរួចហើយ ប៉ុន្តែកុំបារម្ភ។ នៅមានពេលច្រើននៅឡើយ ដើម្បីទទួលបានចម្លើយត្រឹមត្រូវ និងជាប់ការប្រលង។ ប៉ុន្តែបើអ្នកអានជាលើកដំបូង អ្វីដែលមានខាងក្រោមនេះគឺសំខាន់!

## របៀបរស់នៅថ្មី

ពេលព្រះជាម្ចាស់ប្រាប់ខ្ញុំថា ខ្ញុំមិនដែលបានរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ នោះខ្ញុំយល់ច្រឡំ។ ខ្រិនដា និងខ្ញុំមិនបានយល់ថាទ្រង់ចង់មានន័យដូចម្ដេចទេ។ យើងបានអធិស្ឋាន ហើយសុំព្រះជាម្ចាស់ឱ្យបង្រៀនយើងពីអ្វីដែលទ្រង់ចង់មានន័យ ពេលទ្រង់មានបន្ទូលថា យើងមិនដឹងពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។

ដូច្នេះរឿងដំបូងដែលខ្ញុំត្រូវរៀនគឺថា តើព្រះរាជ្យជាអ្វីក្នុងន័យធម្មជាតិ។ ខ្ញុំគិតថា គំនិតនេះគឺពិបាកយល់សម្រាប់ចិត្តប្រជាជនលោកខាងលិចរបស់យើង ព្រោះយើងរស់នៅក្នុងគំនិតប្រជាធិបតេយ្យ និងការបញ្ចេញមតិដោយសេរីរបស់អាមេរិក។ ព្រះរាជ្យរបស់ព្រះជាម្ចាស់មិនមែនជាលទ្ធិប្រជាធិបតេយ្យទេ។ វាជានគរដែលមានស្ដេច។ សិទ្ធិអំណាចរបស់ព្រះមហាក្សត្រ បន្តជាលំដាប់លំដោយចុះមកក្នុងព្រះរាជ្យដោយមានសិទ្ធិអំណាចដែលត្រូវបានផ្ទេរតាមរយៈភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ និងមនុស្សដែលប្រតិបត្តិការនៅក្រោមអំណាចនោះ។ ការមានហ្វូងមនុស្សមិនមែនជានគរទេ។ អ្នកអាចមានហ្វូងមនុស្សមួយលាននាក់ វានៅតែមិនមែនជានគរទេ។ នគរមួយគឺជាក្រុមមនុស្សដែលប្រមូលផ្ដុំគ្នាដោយច្បាប់ ឬរដ្ឋាភិបាល។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

និយមន័យនៃនគរក្នុងវចនានុក្រមគឺ៖ «នគរ៖ រដ្ឋ ឬរដ្ឋាភិបាលដែលមានស្តេច ឬមហាក្សត្រិយានីជាប្រមុខ»។

ទោះបីជាយើងអបអរព្រះយេស៊ូយាងមកផែនដីនៅបុណ្យណូអែលក៏ដោយ ជាធម្មតា យើងមិនយល់ថាទ្រង់កំពុងនាំយករាជរដ្ឋាភិបាលមួយមកជាមួយទ្រង់ឡើយ។ ព្រះគម្ពីរចែងអំពីរាជរដ្ឋាភិបាលនេះនៅក្នុងអេសាយ ៩:៦-៧ ថា៖

> *ដ្បិតមានព្រះរាជបុត្រមួយអង្គប្រសូតមកសម្រាប់យើង ព្រះជាម្ចាស់បានប្រទានព្រះបុត្រាមួយព្រះអង្គមកយើងហើយ។ បុត្រនោះទទួលអំណាចគ្រប់គ្រង គេនឹងថ្វាយព្រះនាមថា៖ "ព្រះដ៏គួរស្ងើចសរសើរ ព្រះប្រកបដោយព្រះប្រាជ្ញាញាណ ព្រះដ៏មានឫទ្ធិចេស្ដា ព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គម្ចាស់នៃសេចក្ដីសុខសាន្ដ"។ ព្រះរាជបុត្រនោះនឹងលាតសន្ធឹងអំណាច ព្រះអង្គនឹងធ្វើឱ្យរាជបល្ល័ង្ករបស់ព្រះបាទដាវីឌ និងនគររបស់ព្រះអង្គមានសេចក្ដីសុខសាន្តរហូតតទៅ។ ព្រះអង្គយកសេចក្ដីសុចរិត និងយុត្តិធម៌មកពង្រឹងនគររបស់ព្រះអង្គឱ្យគង់វង្សចាប់ពីពេលនេះ រហូតអស់កល្បជាអង្វែងតរៀងទៅ ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូលសម្រេចដូច្នេះ មកពីព្រះអង្គមានព្រះហឫទ័យស្រលាញ់យ៉ាងខ្លាំងចំពោះយើង។*

ព្រះយេស៊ូគឺជាប្រមុខនៃរាជរដ្ឋាភិបាលនេះ ហើយនៅពេលដែលយើងទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់យើង យើងក្លាយជាអ្នកទទួលផលពីរាជរដ្ឋាភិបាលនោះ។ យើងក្លាយជាពលរដ្ឋ។ យើងមិនត្រឹមតែក្លាយជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ក្លាយជាផ្នែកនៃគ្រួសាររបស់ព្រះជាម្ចាស់ផ្ទាល់ក្នុងនាមជាកូនប្រុសកូនស្រីផងដែរ។

> *រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឱ្យគេអាចទៅជាបុត្ររបស់ព្រះជាម្ចាស់។ អ្នកទាំងនោះពុំមែន*

## សេចក្ដីផ្ដើម

*កើតពីលោហិត ពីចំណង់តណ្ហា ឬពីបំណងមនុស្សឡើយ គឺកើតពីព្រះជាម្ចាស់វិញ។*

—យ៉ូហាន ១:១២-១៣

*ហេតុនេះ បងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។*

—អេភេសូ ២:១៩

ក្នុងនាមជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់ យើងក្លាយជាផ្នែកនៃគ្រួសាររបស់ទ្រង់ ហើយដូច្នេះយើងជាម្ចាស់ ឬជាផ្នែកនៃអ្វីគ្រប់យ៉ាងដែលទ្រង់មាន។ ដូចគ្នានេះផងដែរ យើងក្លាយជាពលរដ្ឋនៃព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ជាមួយនឹងសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់។

### នគរថ្មី

ដើម្បីយល់ដឹងកាន់តែច្បាស់អំពីអ្វីដែលខ្ញុំកំពុងនិយាយ ខ្ញុំសូមនិយាយអំពីការក្លាយជាពលរដ្ឋនៃសហរដ្ឋអាមេរិកសិន។ ក្នុងនាមជាពលរដ្ឋនៃសហរដ្ឋអាមេរិកអ្នកមានសិទ្ធិស្របច្បាប់។ សិទ្ធិស្របច្បាប់របស់អ្នកត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង និងនៅក្នុងច្បាប់ដែលត្រូវបានអនុម័តនៅក្នុងរដ្ឋាភិបាលរបស់យើង។ ច្បាប់និងអត្ថប្រយោជន៍ទាំងនេះត្រូវបានប្រគល់ជូនប្រជាពលរដ្ឋគ្រប់រូប មិនថាពួកគេជានរណានោះទេ។ សិទ្ធិទាំងនោះមិនផ្អែកលើអារម្មណ៍ ឬភាពឆ្លាតវៃរបស់យើងទេ។ ទេ ទាំងនោះត្រូវបានបង្កើតឡើងដោយច្បាប់ និងស្របច្បាប់សម្រាប់ពលរដ្ឋគ្រប់រូបដែលហៅអាមេរិកថាមាតុភូមិរបស់ពួកគេ។ វាអាចទៅរួចដែលថាពលរដ្ឋម្នាក់ប្រហែលជាមិនស្គាល់សិទ្ធិស្របច្បាប់របស់ពួកគេ ប៉ុន្តែទោះជាយ៉ាងណា ពួកគេមានសិទ្ធិទាំងនោះដោយសារពួកគេជាពលរដ្ឋនៃសហរដ្ឋអាមេរិក។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ឥលូវនេះ នេះជាអ្វីដែលត្រូវគិត ហើយខ្ញុំសង្ឃឹមថាវានឹងផ្លាស់ប្តូរទស្សនៈរបស់អ្នកទាំងមូលចំពោះព្រះជាមច្ាស់ និងរបៀបដែលអ្នកទទួលបានពីទ្រង់។ នៅទីនេះនៅសហរដ្ឋអាមេរិក ប្រសិនបើយើងដឹងថាអ្វីមួយ ឬនរណាម្នាក់កំពុងព្យាយាមដកសិទ្ធិស្របច្បាប់របស់យើងចេញពីយើង ឬថាយើងត្រូវបានគេប្រព្រឹត្តដោយអយុត្តិធមិ នោះយើងមានសិទ្ធិទទួលបានយុត្តិធមិ (យុត្តិធមិមានន័យថាការអនុវត្ត ឬការគ្រប់គ្រងច្បាប់) ដំណើរការដែលអនុវត្តសិទ្ធិស្របច្បាប់របស់យើង។ យើងទៅតុលាការហើយចៅក្រមមិនខ្វល់ពីមុខមាត់យើង ឬថាយើងមាន ឬក្រប៉ុណ្ណាទេ។ គាត់មើលច្បាប់។ គាត់ត្រូវគ្រប់គ្រងតាមច្បាប់គ្រប់ពេល។ ច្បាប់ និងចៅក្រមនៅទីនោះក្នុងនាមជាសន្តិសុខរបស់យើង។

យើងមានសិទ្ធិស្របច្បាប់ ហើយរដ្ឋាភិបាលរបស់យើងនឹងធានា និងអនុវត្តសិទ្ធិស្របច្បាប់របស់យើង តាមរយៈដំណើរការយុត្តិធមិនៅក្នុងប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិក។ ដោយគិតក្នុងចិត្តនោះ សូមក្រឡេកមើលអេសាយ ជំពូក ៩ ដោយយកចិត្តទុកដាក់ នៅពេលដែលខនេះចែងអំពីរាជរដ្ឋាភិបាលថ្មីដែលព្រះយេស៊ូបាននាំមកផែនដីនេះ។

> *ព្រះរាជបុត្រនោះ (ព្រះយេស៊ូ) នឹងលាតសន្ធឹងអំណាច ព្រះអង្គនឹងធ្វើឱ្យរាជបល្ល័ង្ករបស់ព្រះបាទដាវីឌ និងនគររបស់ព្រះអង្គមានសេចក្តីសុខសាន្តរហូតតទៅ។ ព្រះអង្គយក<u>សេចក្តីសុចរិត និងយុត្តិធមិ</u>មកពង្រឹងនគររបស់ព្រះអង្គឱ្យគង់វង្ស...*
>
> —អេសាយ ៩:៧

បទគម្ពីរនេះចែងថាព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានបង្កើតឡើង និងទ្រទ្រង់ឡើងតាមរយៈយុត្តិធមិ ជាការគ្រប់គ្រងនៃច្បាប់របស់ព្រះជាម្ចាស់។ ការគ្រប់គ្រងមានន័យថា ដំណើរការនៃការអនុវត្ត ឬអនុវត្តសិទ្ធិស្របច្បាប់របស់អ្នក។

## សេចក្ដីផ្ដើម

សិទ្ធិស្របច្បាប់របស់អ្នកគឺជាអ្វីដែលព្រះជាម្ចាស់ហៅថាសុចរិត ឬអ្វីដែលទ្រង់មានបន្ទូលថាត្រឹមត្រូវ ជាច្បាប់របស់ទ្រង់។ ដើម្បីធានាថាអ្នកមានអ្វីដែលព្រះជាម្ចាស់មានបន្ទូលថាត្រឹមត្រូវនៅក្នុងព្រះរាជ្យរបស់ទ្រង់ អ្វីដែលជាកម្មសិទ្ធិស្របច្បាប់របស់អ្នកក្នុងនាមជាពលរដ្ឋនៅក្នុងព្រះរាជ្យនោះ ព្រះជាម្ចាស់បានផ្ដល់ឱ្យអ្នកនូវសិទ្ធិទទួលបានយុត្តិធម៌ ដំណើរការ ឬធានាថាអ្នកនឹងមានអ្វីដែលទ្រង់បានសន្យានឹងអ្នក។

ព្រះជាម្ចាស់បានធ្វើឱ្យយើងស្គាល់ព្រះហឫទ័យទ្រង់យើងតាមរយៈព្រះបន្ទូលទ្រង់ គឺព្រះគម្ពីរ ដូច្នេះយើងនឹងដឹងអំពីសិទ្ធិស្របច្បាប់របស់យើងក្នុងព្រះរាជ្យទ្រង់។ នេះជាដំណឹងល្អ! អ្វីគ្រប់យ៉ាងដែលអ្នកបានអាននៅក្នុងព្រះគម្ពីរទាក់ទងនឹងអ្វីដែលព្រះជាម្ចាស់បានសន្យាចំពោះអ្នក គឺជារបស់អ្នកស្របច្បាប់រួចទៅហើយក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យរបស់ទ្រង់!

២ កូរិនថូស ១:២០ បញ្ជាក់យ៉ាងច្បាស់ថា រាល់ព្រះបន្ទូលសន្យា **គឺរាល់ការសន្យា** គឺ «បាទ/ចាស៎» និង «អាម៉ែន»។ វាត្រូវបានសម្រេចរួចហើយ ព្រះបន្ទូលសន្យាទាំងនោះជារបស់អ្នកដោយស្របច្បាប់ហើយ។

> *ព្រះគ្រិស្តបានធ្វើឱ្យព្រះបន្ទូលសន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់បានសម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយបានជាយើងពោលពាក្យ «អាម៉ែន» ទៅកាន់ព្រះជាម្ចាស់ តាមរយៈព្រះគ្រិស្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។*
>
> —២ កូរិនថូស ១:២០

មូលដ្ឋានគ្រឹះនៃព្រះរាជ្យរបស់ព្រះជាម្ចាស់គឺយុត្តិធម៌ និងសេចក្ដីសុចរិត វាមិនអាចរង្គើឡើយ។ ដូច្នេះ ចូរគិតតាមរបៀបនេះ៖ ប្រសិនបើខ្ញុំដឹងពីច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ (ព្រះហឫទ័យរបស់ទ្រង់) ហើយខ្ញុំដឹងថា ខ្ញុំមានសិទ្ធិទទួលបានយុត្តិធម៌ ដំណើរការនៃការអនុវត្តដែលធានាខ្ញុំនូវអ្វីដែលច្បាប់ចែង នោះខ្ញុំមានទំនុកចិត្ត ហើយមិនខ្លាចនោះទេ។

*ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*

—១ យ៉ូហាន ៥:១៤-១៥

នៅពេលដែលខគម្ពីរនេះចែងថា ទ្រង់ស្ដាប់ឮយើង វាមិនមែននិយាយអំពីការស្ដាប់យើងដោយសំឡេង ដូចជាស្ដាប់ឮពាក្យសម្ដីរបស់យើងតាមរយៈរលកសំឡេងនោះទេ។ វានិយាយអំពីទ្រង់ទទួលយកករណីនេះ។

សូមគិតអំពីថៅក្រមដែលបើកសវនាការដើម្បីធានាថាមានយុត្តិធម៌។ បន្ទប់សវនាការ និងថៅក្រមនៅទីនោះ ដើម្បីធានាថាយុត្តិធម៌មានសម្រាប់ពលរដ្ឋគ្រប់រូប។ ការសម្រេចរបស់ថៅក្រមមិនផ្អែកលើអារម្មណ៍របស់គាត់ទេ ប៉ុន្តែផ្អែកលើច្បាប់ដែលគាត់ជាអធិបតីក្នុងការអនុវត្តសម្រាប់ពលរដ្ឋគ្រប់រូប។ ថៅក្រមនៅទីនោះដើម្បីធានាថាយុត្តិធម៌ (ការអនុវត្តច្បាប់) បានកើតឡើងស្របតាមច្បាប់ជាលាយលក្ខណ៍អក្សរ។

ក្នុងករណីរបស់ព្រះជាម្ចាស់ បល្ល័ង្ករបស់ទ្រង់ (កន្លែងនៃសិទ្ធិអំណាច) និងឫទ្ធានុភាពរបស់ទ្រង់នៅទីនោះ ដើម្បីធានានូវយុត្តិធម៌ (ការអនុវត្តតាមព្រះហឫទ័យរបស់ទ្រង់) ដល់មនុស្សទាំងអស់ដែលមកឯព្រះយេស៊ូ និងព្រះរាជ្យរបស់ទ្រង់។

សូមអានប្រយោគនោះម្ដងទៀតយឺតៗ ហើយអនុញ្ញាតឱ្យវាចេញពីទស្សនៈបច្ចុប្បន្នរបស់អ្នកចំពោះព្រះជាម្ចាស់។ មនុស្សភាគច្រើនមានអារម្មណ៍ថា ព្រះជាម្ចាស់ធ្វើការសម្រេចព្រះហឫទ័យរបស់ទ្រង់តាមករណីនីមួយៗ ប៉ុន្តែវាមិនពិតទេ។ ទ្រង់ជាស្ដេចនៃព្រះរាជ្យមួយដែលមានច្បាប់មិនប្រែប្រួល។ ទ្រង់មិនធ្វើ ហើយនឹងមិនធ្វើការសម្រេចចិត្តក្រៅច្បាប់របស់ទ្រង់ឡើយ។ យើងអាចដឹងពីចម្លើយរបស់ទ្រង់មុនពេល

យើងសួរ ហើយយើងអាចប្រាកដថាយើងមានអ្វីដែលច្បាប់របស់ទ្រង់មានបន្ទូលមុនពេលយើងឃើញវា ព្រោះទ្រង់មានអំណាចដើម្បីអនុវត្តការអនុវត្តច្បាប់របស់ទ្រង់។

## គ្មានការសុំទានទៀតទេ

នៅពេលដែល ឌ្រិនដា និងខ្ញុំចាប់ផ្ដើមរៀនអំពីសិទ្ធិស្របច្បាប់របស់យើងនៅក្នុងព្រះរាជ្យ វាបានផ្លាស់ប្ដូរយ៉ាងខ្លាំងពីរបៀបដែលយើងគិតអំពីព្រះជាម្ចាស់ និងព្រះគម្ពីរ។ លទ្ធផលនៃការយល់ដឹងថ្មីរបស់យើងបានផ្លាស់ប្ដូររបៀបដែលយើងរស់នៅ។ យើងលែងសុំទានទៀតហើយ។ គ្មានការអង្វរទៀតទេ។ យើងបានរៀនពីអ្វីដែលត្រូវបានផ្ដល់ឱ្យយើងដោយស្របច្បាប់ក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យរបស់ទ្រង់។ ហើយយើងបានបន្តរៀនពីរបៀបដាក់ការអះអាងចំពោះព្រះបន្ទូលសន្យាទាំងនោះ ហើយមើលឃើញព្រះបន្ទូលសន្យាត្រូវបានស្រោយនៅលើភពផែនដីនេះ។ វាពិតជាការបើកបង្ហាញមួយដើម្បីរៀនថា យើងជាម្ចាស់នៃអ្វីៗដែលស្ថានសួគ៌មាន។ ក្នុងនាមជាប្រជាពលរដ្ឋ យើងមានសិទ្ធិទទួលបាននូវច្បាប់នៃព្រះរាជ្យ។ ប៉ុន្តែក្នុងនាមជាសមាជិកនៃគ្រួសារខ្លួនឯង យើងជាម្ចាស់ ហើយមានការទាមទារផ្លូវច្បាប់លើការទទួលមតិកនៃអ្វីៗដែលស្ថានសួគ៌មាន។

> *ប្រសិនបើយើងពិតជាបុត្រមែន នោះយើងមុខជាទទួលមតិកពុំខាន។ យើងនឹងទទួលមតិកពីព្រះជាម្ចាស់ គឺ**ទទួលមតិករួម**ជាមួយព្រះគ្រិស្ត។*
>
> —រ៉ូម ៨:១៧

សូមកត់សម្គាល់អត្ថបទដែលចែងថា យើងជាអ្នកទទួលមតិករួមជាមួយព្រះគ្រិស្ត! នោះមានន័យថាអ្វីៗទាំងអស់ដែលព្រះគ្រិស្តមានក៏ជារបស់យើងដែរ!

នៅពេលដែលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅក្នុងផ្ទះចម្ការដ៏តូច និងខូចខ្ទេចខ្ទីនៅថ្ងៃនោះ ហើយបានប្រាប់ខ្ញុំថាខ្ញុំមិនដឹងថាតើព្រះរាជ្យរបស់ទ្រង់ដំណើរការដោយរបៀបណា ទ្រង់កំពុងសំដៅទៅលើច្បាប់ និងរចនាសម្ពន្ធច្បាប់នៃព្រះរាជ្យរបស់

ទ្រង់។ ទ្រង់មានបន្ទូលត្រូវ។ ខ្ញុំមិនដឹងថាព្រះរាជ្យជាអ្វី ឬវាដំណើរការដោយរបៀបណាទេ។ ប៉ុន្តែរឿងមួយដែលខ្ញុំបានចាប់យកមកទុកក្នុងចិត្តភ្លាមៗ ដែលជួយឱ្យការយល់ដឹងរបស់ខ្ញុំអំពីព្រះរាជ្យ គឺថា ព្រះរាជ្យដំណើរការដោយច្បាប់ដែលមិនអាចផ្លាស់ប្តូរបាន។ ច្បាប់មិនបង្ហាញការនិយម ឬបក្សពួកនិយមឡើយ។ ច្បាប់មិនប្តូរទៅអនុគ្រោះដល់បុគ្គលណាមួយឡើយ។ ទេ វាមិនអាចផ្លាស់ប្តូរបាន និងថេរ។

ខ្ញុំសូមផ្តល់ឧទាហរណ៍មួយដល់អ្នក។ សព្វថ្ងៃនេះយើងរីករាយនឹងអគ្គិសនី និងពន្លឺដែលវាផ្តល់នៅក្នុងផ្ទះរបស់យើង។ អ្នកនឹងយល់ស្រេបថាច្បាប់ដែលគ្រប់គ្រងអគ្គិសនីតែងតែនៅទីនេះចាប់តាំងពីផែនដីត្រូវបានបង្កើតឡើង។ ទោះជាយ៉ាងណា រាប់ពាន់ឆ្នាំមកហើយដែលគ្មានភ្លើង! ហេតុផល? គ្មាននរណាម្នាក់បានរកឃើញច្បាប់ដែលគ្រប់គ្រងអគ្គិសនី និងរបៀបប្រើប្រាស់វាដើម្បីបំភ្លឺអំពូលទេ។ ទោះបីជាផ្លេកបន្ទោរ និងអគ្គិសនីបិតិវន្តត្រូវបានគេសង្កេតឃើញថាជាផ្នែកធម្មតានៃជីវិតក៏ដោយ នោះជាការសង្កេត។ គ្មាននរណាម្នាក់គិតគូរពីការចម្លងអ្វីដែលពួកគេកំពុងឃើញនោះទេ ព្រោះពួកគេមិនបានដឹងថាអ្វីដែលពួកគេបានឃើញគឺផ្អែកលើច្បាប់ធម្មជាតិដែលអាចរៀនបាន។

កង្វះការយល់ដឹងដូចគ្នានេះ ជ្រៀតចូលក្រុមជំនុំសព្វថ្ងៃនេះ។ មនុស្សអានអំពីរឿងដ៏អស្ចារ្យដែលព្រះជាម្ចាស់បានធ្វើនៅក្នុងព្រះគម្ពីរ ប៉ុន្តែបានត្រឹមតែយល់ដឹងដោយសង្កេតអំពីអ្វីដែលពួកគេកំពុងអានប៉ុណ្ណោះ គឺមិនលើសពីហ្នឹងទេ។

មនុស្សជាច្រើនធ្លាប់បានឃើញព្រះជាម្ចាស់ធ្វើរឿងដ៏អស្ចារ្យមួយចំនួននៅក្នុងជីវិតរបស់ពួកគេ ប៉ុន្តែដូចជាការមើលផ្លេកបន្ទោរដ៏ភ្លឺឆ្វាចនៅក្នុងព្យុះរដូវក្តៅ ពួកគេឈរនៅទីនោះហើយនិយាយថា "អូហ៎ តើអ្នកបានឃើញវាទេ?" ប៉ុន្តែមិនទាន់អាចចម្លងបានទេ ព្រោះគេមិនយល់ពីច្បាប់ដែលគ្រប់គ្រងលើអ្វីដែលគេទើបតែឃើញ។ ជាឧទាហរណ៍ សព្វថ្ងៃនេះ យើងអាចដាក់ភ្លើងបានគ្រប់ទីកន្លែងក្នុងពិភពលោក គ្រប់ទីកន្លែងដែលយើងចង់បាន ព្រោះយើងយល់អំពីច្បាប់ដែលគ្រប់គ្រងអគ្គិសនី។

## សេចក្ដីផ្ដើម

ដូចគ្នាដែរសព្វថ្ងៃនេះ យើងក៏រីករាយនឹងសមត្ថភាពក្នុងការធ្វើដំណើររាប់ពាន់គីឡូម៉ែត្រក្នុងមួយថ្ងៃដោយយន្តហោះនៅគ្រប់ទីកន្លែងក្នុងពិភពលោក។ យន្តហោះទទួលបានសមត្ថភាពហោះហើរដោយការយល់ដឹងរបស់យើង និងប្រើប្រាស់ច្បាប់នៃការលើក។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នោះមាននៅក្នុងផែនដីតាំងពីផែនដីត្រូវបានបង្កើតឡើង ដូចដែលបានបង្ហាញដោយសត្វស្លាបដែលប្រើច្បាប់នោះជារៀងរាល់ថ្ងៃ។ ប៉ុន្តែគ្មាននរណាម្នាក់ជិះយន្តហោះឡើយ តាំងពីមានមនុស្សរស់នៅរាប់ពាន់ឆ្នាំមក ព្រោះគ្មាននរណាម្នាក់បានរកឃើញច្បាប់នៃការលើក និងរៀនពីរបៀបប្រើប្រាស់វា។

ជាថ្មីម្តងទៀត វាក៏ដូចគ្នានឹងព្រះរាជ្យរបស់ព្រះជាម្ចាស់។ មនុស្សភាគច្រើនអង្វរ យំ ហើយបន្តព្យាយាមបញ្ចុះបញ្ចូលព្រះជាម្ចាស់ឱ្យធ្វើអ្វីមួយជំនួសពួកគេ។ ប៉ុន្តែអ្វីដែលពួកគេមិនដឹងនោះគឺថា នៅពេលដែលពួកគេបានក្លាយជាអ្នកជឿ ច្បាប់ និងអត្ថប្រយោជន៍ទាំងអស់នៃព្រះរាជ្យបានក្លាយជារបស់ពួកគេសម្រាប់ប្រើប្រាស់ និងរីករាយដោយមិនចាំបាច់សុំទានឡើយ។

ឧបមាថា ខ្ញុំនឹងមកក្រុមជំនុំរបស់អ្នក។ តើអ្នកនឹងមានក្រុមអធិស្ឋានអធិស្ឋានហើយតមអាហារដើម្បីឱ្យមានភ្លើងបំភ្លឺនៅយប់ដែលខ្ញុំទៅដល់ដែរឬទេ? ជាការពិតណាស់ មិនមែនទេ! ប្រសិនបើថៃដន្យ ខ្ញុំបានទៅដល់ក្រុមជំនុំរបស់អ្នក ហើយភ្លើងមិនបើកទេ តើគ្រប់គ្នាចាប់ផ្តើមស្រែកអង្វរព្រះជាម្ចាស់ សុំអង្វរ ហើយយំព្យាយាមបញ្ចុះបញ្ចូលព្រះជាម្ចាស់ឱ្យបើកភ្លើងដែរឬទេ? ទេ ពួកគេនឹងស្វែងរកកុងតាក់ ដោយគ្រាន់តែបើកវាឡើង ហើយភ្លើងនឹងបើក។ គ្មានការភ័យខ្លាច គ្មានការភាន់ច្រឡំ គ្រាន់តែបើកវា!

ប៉ុន្តែដោយមូលហេតុខ្លះ គ្រិស្តបរិស័ទមិនដែលចូលទៅជិតព្រះរាជ្យ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមទស្សនៈនេះទេ។ ម្តងទៀត ពួកគេចំណាយពេលភាគច្រើនដើម្បីសុំទាន ដោយសង្ឃឹមថានឹងមានអ្វីកើតឡើង។ នៅពេលដែលវាមិនកើតឡើង ពួកគេបន្ទោសព្រះជាម្ចាស់ភ្លាមៗ ដោយជឿថាព្រះជាម្ចាស់បានជ្រើសរើសមិនព្រមនឹងការ

ស្នើសុំរបស់ពួកគេ។ ការខ្វះការយល់ដឹងនេះហើយជាមូលហេតុដែលគ្រិស្តបរិស័ទភាគច្រើនសព្វថ្ងៃនេះជឿថាព្រះជាម្ចាស់អនុញ្ញាតឱ្យមានរឿងអាក្រក់កើតឡើង ឬថាទ្រង់ដឹងច្បាស់បំផុតនៅពេលសោកនាដកម្មកើតឡើង។ មិត្តអើយ នេះមិនមែនជារបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការទេ!!!! ម្តងទៀត សូមក្រឡេកមើលបទគម្ពីររបស់យើងនៅក្នុង ១ យ៉ូហាន។

> *ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថាប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*
>
> —១ យ៉ូហាន ៥:១៤-១៥

ដោយសារយើងដឹងថាយើងកំពុងសួរតាមសិទ្ធិផ្លូវច្បាប់របស់យើង ហើយថាទ្រង់ទទួលយករឿងក្តី យើងមានទំនុកចិត្តថាយើងមានអ្វីដែលយើងបានសុំពីទ្រង់! គួរឱ្យស្តាយ ការពិតដែលត្រូវបានបង្ហាញក្នុងអត្ថបទនេះ មិនត្រូវបានយល់ដោយអ្នកជឿភាគច្រើននោះទេ។ តាមបទពិសោធរបស់ខ្ញុំ ខ្ញុំត្រូវតែនិយាយភាគច្រើន។ ប៉ុន្តែវាជាការយល់ដឹងនេះហើយដែលបានផ្លាស់ប្តូរជីវិតខ្ញុំយ៉ាងពិតប្រាកដ!

## ចក្ខុវិស័យធៀបនឹងការគ្រងរាស់

ខ្ញុំចាប់ផ្តើមអានរឿងក្នុងព្រះគម្ពីរដោយចំណាប់អារម្មណ៍ថ្មី។ ខ្ញុំបានដឹងថានៅក្នុងរឿងនីមួយៗមានច្បាប់ខាងវិញ្ញាណដែលត្រូវរកឃើញ។ ខ្ញុំបានក្លាយជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ។ ក្នុងរឿងនីមួយៗ ខ្ញុំនឹងសួរសំណួរ។ «ហេតុអីក៏វាកើតឡើង?» «តើច្បាប់អ្វីត្រូវបានបង្ហាញនៅក្នុងរឿងនេះ?» បន្តិចម្តងៗ ខ្ញុំបានចាប់ផ្តើមរៀនគោល

ការណ៍ និងច្បាប់ដែលជារបស់ខ្ញុំនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយវាបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំយ៉ាងពិតប្រាកដ។

នៅពេលដែលយើងចាប់ផ្ដើមអនុវត្តច្បាប់ទាំងនេះ យើងបានក្លាយជាអ្នកគ្មានបំណុលទាំងស្រុងក្នុងរយៈពេលពីរឆ្នាំកន្លះ។ យើងបានចាប់ផ្ដើមចំណាយប្រាក់សម្រាប់រថយន្តរបស់យើង សាងសង់ផ្ទះក្នុងក្ដីស្រមៃរបស់យើងលើផ្ទៃដី ២២ ហិចតា និងអ្វីៗជាច្រើនទៀត។ ផ្នែកដ៏ល្អបំផុតគឺ ឥលូវនេះមិនមានសម្ពាធផ្នែកហិរញ្ញវត្ថុទេ។ ផ្ទះរបស់យើងត្រូវបានបង់ថ្លៃទិញរួចរាល់ ហើយឥលូវនេះយើងអាចផ្ដោតលើកិច្ចការរបស់យើង គោលបំណងរបស់យើង ជំនួសឱ្យការត្រដររស់។

យើងពិតជារំភើបណាស់ចំពោះអ្វីដែលយើងកំពុងរៀន ហើយមិនទាន់ឃើញមិត្តភក្តិ និងអ្នកស្គាល់គ្នាភាគច្រើនរីករាយដូចអ្វីដែលយើងបានឃើញកើតឡើងនោះទេ។ ដោយសារបំណងប្រាថ្នារបស់យើងក្នុងការជួយមនុស្សឱ្យរៀនពីអ្វីដែលយើងបានរៀន យើងបានបើកក្រុមជំនុំជីវិត Faith Life នៅក្នុងឆ្នាំ ១៩៩៥។ យើងបានផ្ដោតលើការចែករំលែកច្បាប់ និងគោលការណ៍ដែលព្រះជាម្ចាស់បានបង្រៀនយើង ចែករំលែកជាមួយមនុស្សអំពីរបៀបដែលពួកគេអាចមានសេរីភាព និងរស់នៅក្នុងជីវិតដ៏ល្អនៅក្នុងព្រះរាជ្យ។

បន្ទាប់មកនៅឆ្នាំ ២០០៥ យើងបានចាប់ផ្ដើមកម្មវិធី Faith Life Now ដែលជាព័ន្ធកិច្ចប្រព័ន្ធផ្សព្វផ្សាយរបស់យើង។ Faith Life Now ចាក់ផ្សាយកម្មវិធីទូរទស្សន៍ប្រចាំថ្ងៃរបស់យើងពីររឿង *ដោះស្រាយរឿងលុយ* និង *ឌ្រីនដា* ទៅកាន់គ្រប់ល្វែងម៉ោងក្នុងពិភពលោកជាមួយនឹងដំណឹងល្អនៃព្រះរាជ្យ។

ថ្ងៃនេះ យើងមិនស្វែងរកកាក់ និងសេនដែលកប់នៅក្រោមកៅអីរថយន្តរបស់យើង ដោយសង្ឃឹមថានឹងអាចស្វែងរកការផ្លាស់ប្ដូរគ្រប់គ្រាន់ដើម្បីទិញអាហាររីករាយចែកកូនយើងទាំងបីនាក់ទៀតទេ។ យើងចំណាយប្រាក់រាប់លានដើម្បីធ្វើអ្វីដែលយើង

ធ្វើតលូវនេះ ហើយយើងមានចិត្តឆេះឆួលក្នុងការជួយមនុស្សឱ្យរៀនពីរបៀបដែលយើងបានធ្វើនោះ។

ភ្លាមៗនោះ យើងផ្លាស់ប្ដូរពីការគិតបែបត្រដររស់ ទៅជាការគិតផ្អែកលើចក្ខុវិស័យ ហើយចាប់ផ្ដើមស្រមៃអំពីអ្វីដែលយើងអាចបង្កើត និងធ្វើជាមួយជីវិតរបស់យើង។ យើងបានចេញពីភាពវឹកវរផ្នែកហិរញ្ញវត្ថុ និងទាសភាព ទៅជាសេរីភាពហិរញ្ញវត្ថុ។

នៅក្នុងថ្ងៃបែកបាក់ និងជាទាសកររបស់យើង រាល់បញ្ហាលំហូរសាច់ប្រាក់តូចតាចគឺជាគ្រាអាសន្នដ៏សំខាន់។ ក្រោមភាពតានតឹងខ្លាំង យើងនឹងព្យាយាមរកអ្នកខ្ចីលុយពីគេ ឬយើងនឹងទៅហាងបញ្ចាំក្នុងតំបន់របស់យើងម្តងទៀត! ប៉ុន្តែថ្ងៃនេះ យើងកំពុងរីករាយជាមួយអំណាចនៃព្រះរាជទាន។

អ្នកអាចសួរថា «លោកគ្រូ ហ្គារី តើអ្វីទៅជាអំណាចនៃព្រះរាជទាន?» អំណាចនៃព្រះរាជទាន គឺជាសមត្ថភាពក្នុងការរកឃើញគោលបំណងរបស់អ្នក និងគេចចេញពីជីវិតដែលត្រដររស់។ សូមចងចាំជានិច្ចថា ព្រះរាជទានគឺជាការគាំទ្រនឹងចក្ខុវិស័យ។ សូមអានយឺតម្តងទៀត វាជាការលេងពាក្យ ប៉ុន្តែអត្ថន័យគឺជាក់ស្តែង។

ការគ្មានព្រះរាជទាន (ការផ្គត់ផ្គង់) គឺធ្វើឱ្យយើងរស់នៅក្នុងជីវិតជាទាសករ ហើយទាសករមិនស្រមៃធំឡើយ! ហើយសូមចាំជានិច្ចថាអ្នកមិនមែនជាទាសករទេ! អ្នកជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់ ជាអ្នកទទួលមតិកជាមួយនឹងព្រះយេស៊ូនៃទ្រព្យទាំងមូល។ ដូច្នេះ សូមក្រឡេកមើលអនាគតថ្មី។ ខ្ញុំចង់ឱ្យអ្នកមានសេរីភាពនឹងស្រមៃ មានភាពសប្បាយរីករាយក្នុងការបង្កើតចក្ខុវិស័យរបស់អ្នក និងរស់នៅក្នុងជីវិតដ៏ល្អ។ ខ្ញុំជឿជាក់នៅពេលយើងឆ្លងកាត់សៀវភៅនេះ អ្នកនឹងត្រូវបានបំផុសគំនិត ប៉ុន្តែមិនត្រឹមតែត្រូវបានបំផុសគំនិតប៉ុណ្ណោះទេ អ្នកក៏នឹងមានទំនុកចិត្ត។ ច្បាប់ដូចគ្នានៃព្រះរាជ្យដែលបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំក៏ជារបស់អ្នកផងដែរ។

– ហ្គារី ឃីស៊ី

## សេចក្តីផ្តើម

តាមពិត នេះជាសៀវភៅទី ៩ នៅក្នុងសេរីសៀវភៅចំនួន ៥ ក្បាល ដែលមានចំណងជើងថា «បដិវត្តហិរញ្ញវត្ថុរបស់អ្នក»។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យអានសៀវភៅបីក្បាលមុនដើម្បីយល់ច្បាស់អំពីច្បាប់ដែលខ្ញុំកំពុងយោង និងបន្ថែមទៀតអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ។ សៀវភៅទាំងនោះគឺ៖ *បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃតក្កីភាព, បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃការសម្រាក និងបដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃយុទ្ធសាស្ត្រ។* អ្នកអាចស្វែងរកសៀវភៅទាំងនោះនៅគេហទំព័រ GaryKeesee.com ឬនៅ Amazon.com ។

# ជំពូក ១
# ពន្លឺបំភ្លឺនៅក្នុងសេចក្ដីងងឹត

ខ្ញុំបានប្រាប់អ្នករួចហើយនៅក្នុងសេចក្ដីផ្ដើមអំពីការកោះហៅរបស់មេធាវី ដែលបណ្ដាលឱ្យខ្ញុំប្រឈមមុខនឹងការពិតនៃស្ថានភាពរបស់យើង ហើយទីបំផុតខ្ញុំបានស្រែកទូលអង្វរទៅកាន់ព្រះជាម្ចាស់។ ខ្ញុំក៏បានប្រាប់អ្នកពីអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំនៅពេលខ្ញុំដេកឃំនៅលើគ្រែ ពេលនោះខ្ញុំមានអារម្មណ៍ក្ដុកក្ដួលក្នុងចិត្ត ដោយសារខ្ញុំមិនដែលបានដឹងពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការទេ។ ប៉ុន្តែតើវាមានដំណើរការយ៉ាងដូចម្ដេចទៅ? តើទ្រង់កំពុងព្យាយាមបង្ហាញអ្វីដល់ខ្ញុំ? ខ្ញុំគ្មានតម្រុយអ្វីសោះ ប៉ុន្តែខ្ញុំដូចជារៀនបានអ្វីមួយពីរឿងអស់ទាំងនេះ។

ប្រសិនបើអ្នកនៅចាំ ខ្ញុំត្រូវការប្រាក់ចំនួន ១.៦០០ ដុល្លារ ដើម្បីបង់ឱ្យមេធាវីក្នុងរយៈពេលបីថ្ងៃ ដើម្បីជៀសវាងការប្ដឹងផ្ដល់មួយ។ នៅពេលនោះ យើងគ្មានប្រាក់សោះ ហើយក៏គ្មានសង្ឃឹមថានឹងអាចរកប្រាក់បានពីអាជីវកម្មរបស់យើងឱ្យបានទាន់ពេលវេលាដើម្បីបង់ប្រាក់ចំនួន ១.៦០០ ដុល្លារនោះដែរ។ ខ្ញុំស្ថិតក្នុងស្ថានភាពមួយដែលមិនអាចដោះស្រាយបាន ឬបានដឹងខ្លួនថាបានដើរដល់ផ្លូវទាល់ហើយ។ ផ្ទុយទៅវិញ ខ្ញុំបានរៀនមេរៀនដំបូងរបស់ខ្ញុំទាក់ទងជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់។

ពេលនោះខ្ញុំមានឡានវ៉ែនមួយដែលមានម៉ាក Dodge Caravan ដែលមានផ្សែងហុយទ្រលោមពេលខ្ញុំជិះចុះផ្លូវចំណោត។ នៅយប់នោះ ខ្ញុំមានការណាត់ជួបជាមួយគ្រួសារមួយ ដើម្បីពិភាក្សាអំពីតម្រូវការធានារ៉ាប់រងរបស់ពួកគេ ហើយការ

ណាត់ជួបរបស់យើងគឺធ្វើនៅផ្ទះរបស់ពួកគេ ដែលត្រូវជិះរថយន្តប្រហែល១៥នាទីពីការិយាល័យរបស់ខ្ញុំ។

នៅថ្ងៃនោះ ខ្ញុំចង់ចតរថយន្តនៅមាត់ផ្លូវ ឬនៅកាច់ជ្រុងផ្ទះអតិថិជនរបស់ខ្ញុំ។ ហេតុផលគឺសាមញ្ញទេ។ រាល់ពេលដែលខ្ញុំបញ្ជោះរថយន្ត វាតែងតែហុយផ្សែងខ្លាំង ហើយខ្ញុំមិនគិតថាវាជួយជំរុញអាជីវកម្មរបស់ខ្ញុំឱ្យមានដំណើរការបានល្អទេ ដោយហេតុថាខ្ញុំត្រូវបានគេចាត់ទុកថាជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ ដែលផ្តល់ដំបូន្មានដល់អតិថិជនរបស់ខ្ញុំអំពីរបៀបវិនិយោគ និងទិញធានារ៉ាប់រងមក។

ពិតមែនហើយ នៅយប់ដ៏ពិសេសនោះ ក៏ដូចជាយប់រាល់ដងដែរ ខ្ញុំចតរថយន្តរបស់ខ្ញុំនៅកាច់ជ្រុងផ្ទះអតិថិជនខ្ញុំ។ ពួកយើងបានពិភាក្សាជាមួយគ្នាបានយ៉ាងល្អ ហើយខ្ញុំក៏បាននិយាយលាគ្នា ប៉ុន្តែខ្ញុំមានការព្រួយបារម្ភបន្តិច នៅពេលបុរសដ៏រាក់ទាក់ម្នាក់នោះបានដើរមកជាមួយខ្ញុំពេលខ្ញុំដើរឆ្ពោះទៅរករថយន្តរបស់ខ្ញុំ។ ថ្វីត្បិតតែមានការស្រងាកចិត្តបន្តិច ប៉ុន្តែខ្ញុំមិនមានបញ្ហាអ្វីទេ ដរាបណាគាត់មិននៅក្បែរខ្ញុំដើម្បីមើលខ្ញុំបញ្ឆេះរថយន្តរបស់ខ្ញុំ។ តែអ្វីដែលគួរឱ្យសោកស្តាយនោះ គឺថាគាត់នៅចាំទាល់តែខ្ញុំបញ្ឆេះរថយន្តរបស់ខ្ញុំ ទោះបីជាខ្ញុំបានចំណាយពេលក្នុងការរៀបចំកាតាបរបស់ខ្ញុំ និងរបស់របរផ្សេងទៀតនៅក្នុងរថយន្ត ដោយព្យាយាមទុកពេលឱ្យគាត់ចាកចេញក៏ដោយ ក៏គាត់នៅតែឈរនៅទីនោះដោយអត់ធ្មត់ រហូតទាល់តែខ្ញុំគិតថាខ្ញុំត្រូវទៅហើយ ហើយខ្ញុំក៏ចាប់ផ្តើមបញ្ឆេះរថយន្តខ្ញុំ។ ពិតណាស់ ដូចដែលបានរំពឹងទុកអ៊ីចឹង គឺហុយផ្សែងសពេញផ្លូវតែម្តង។

ពេលខ្ញុំហៀបនឹងបើករថយន្តរបស់ខ្ញុំចេញទៅហើយ គាត់បានធ្វើសញ្ញាឱ្យខ្ញុំពន្លត់រថយន្តខ្ញុំសិន ហើយបានដើរមកជិតបង្អួចរថយន្តខ្ញុំ។ បន្ទាប់មក គាត់បានប្រាប់ខ្ញុំថា គាត់ធ្លាប់ធ្វើការក្រៅម៉ោង ផ្នែកជួសជុលរថយន្តដើម្បីរកប្រាក់បន្ថែម ហើយគាត់ចង់ពិនិត្យមើលគម្របក្បាលឡានរ៉េនរបស់ខ្ញុំបន្តិចសិន។ ខ្ញុំបាននិយាយថាគាត់អាច

ពិនិត្យមើលបាន ហើយខ្ញុំបានបើកគម្របក្បាលឡានរបស់ខ្ញុំឱ្យគាត់ពិនិត្យមើល។ ខ្ញុំដឹងថាទោះបីគាត់រកឃើញអ្វីក៏មិនសំខាន់ដែរ។ ពេលនេះខ្ញុំមិនមានលុយដើម្បីជួសជុលរថយន្តចាស់នោះទេ។

មួយសន្ទុះក្រោមមក ពេលគាត់ពិនិត្យរួចហើយ គាត់បាននិយាយថា «ដូចអ្វីដែលខ្ញុំសង្ស័យមែន គឺវាបែករងមួយហើយ។ អ្នកត្រូវបើករថយន្តនេះទៅផ្ទះ ហើយត្រូវជួសជុលវា មុនពេលអ្នកបើកវាទៅកន្លែងណាឆ្ងាយផ្សេងទៀត។ វាគួរតែចំណាយអស់ប្រហែល៧០០ដុល្លារតែប៉ុណ្ណោះទេ»។

ខ្ញុំបានអរគុណសម្រាប់ការណែនាំរបស់គាត់ ហើយបានបរក្បាលរថយន្តរបស់ខ្ញុំទៅការិយាល័យរបស់ខ្ញុំវិញ។ អ្វីដែលខ្ញុំអាចឮនៅក្នុងខួរក្បាលរបស់ខ្ញុំគឺ «វាគួរតែចំណាយអស់ ៧០០ដុល្លារតែប៉ុណ្ណោះទេ!» ចំពោះខ្ញុំ ៧០០ដុល្លារនៅពេលនោះ ស្តាប់ទៅដូចជាមួយលានដុល្លារអ៊ីចឹង ហើយខ្ញុំនៅតែត្រូវការប្រាក់ ១.៦០០ដុល្លារដើម្បីផ្ញើទៅមេធាវី។ ក្រៅពីនោះ ខ្ញុំមានការចំណាយផ្សេងៗទៀតដែលខ្ញុំត្រូវបង់ឱ្យគេ។

ខ្ញុំគ្មានដំណោះស្រាយទេ ប៉ុន្តែខ្ញុំនឹកចាំពីសេចក្តីអធិស្ឋាន ដែលឌ្រិនដា និងខ្ញុំបានអធិស្ឋានពេលមុននេះ «ព្រះជាម្ចាស់អើយ សូមបង្រៀនយើងអំពីរបៀបដែលដែលព្រះរាជ្យរបស់ទ្រង់មានដំណើរការ ហើយសូមទ្រង់បង្ហាញយើងពីរបៀបរស់នៅដោយគ្មានបំណុលផង»។

ខណៈពេលដែលខ្ញុំបើករថយន្តត្រលប់ទៅការិយាល័យវិញ ខ្ញុំចាប់ផ្តើមនិយាយជាមួយព្រះអម្ចាស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្ញុំ។ «ព្រះអម្ចាស់អើយ ទ្រង់ជ្រាបគ្រប់យ៉ាងអំពីប្រាក់ដែលខ្ញុំត្រូវការ។ ទ្រង់បានជ្រាបដឹងហើយថា ខ្ញុំនៅជំពាក់ថ្លៃរថយន្តវ៉ែននេះនៅឡើយទេ ហើយឥលូវនេះ ខ្ញុំត្រូវការលុយ៧០០ដុល្លារទៀត ដើម្បីជួសជុលវា។ ព្រះជាម្ចាស់អើយ ខ្ញុំសូមនិយាយដោយត្រង់ទៅចុះ បើគិតពីចំនួនប្រាក់ដែលខ្ញុំជំពាក់ធនាគារសម្រាប់រថយន្តនេះ និងថ្លៃជួសជុលវា វាប្រហែលជាប្រសើរជាង

ប្រសិនបើរថយន្តនេះឆេះ ហើយក្រុមហ៊ុនធានារ៉ាប់រងនឹងសងថ្លៃគ្រប់យ៉ាងដល់ខ្ញុំ!» ខ្ញុំបាននិយាយខ្លាំងៗ ដោយមានអារម្មណ៍ខកចិត្ត តាមរបៀបមួយដែលបញ្ឈឺចិត្តខ្លួនឯង ។ វាមិនមែនជាការអធិស្ឋានដ៏ពិតប្រាកដនោះទេ។

បន្ទាប់ពីខ្ញុំបាននិយាយដូច្នេះមួយសម្ទុះក្រោយមក ស្រាប់តែដូចជាមានអ្វីមួយកើតឡើង ខ្ញុំមិនច្បាស់ថាមានអ្វីបានកើតឡើងនៅពេលនោះទេ។ ប៉ុន្តែវាហាក់ដូចជាមានកំពកប៉ោងតូចមួយនៅផ្នែកខាងលើនៃគម្របក្បាលឡានរបស់ខ្ញុំ។ ពេលដែលខ្ញុំសម្លឹងមើលទៅវា វាហាក់ដូចជាប៉ោងធំទៅៗ បន្តិចម្តងៗ។ ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងមែនទែន ខ្ញុំមិននិយាយបំផ្លើសទេ។ ខ្ញុំមិនដែលឃើញមានផ្សែងឯណា ច្រើនជាងផ្សែងពីក្រោយរថយន្តរបស់ខ្ញុំទេ ដូច្នេះខ្ញុំក៏នៅបន្តបើករថយន្តនោះទៅការិយាល័យរបស់ខ្ញុំ។

ពេលដែលខ្ញុំបើកចូលដល់ចំណតរថយន្ត ស្រាប់តែផ្នែកខាងមុខរថយន្តនោះបានឆេះយ៉ាងសន្ធោសន្ធៅ! មានអណ្តាតភ្លើងបានឆាបឆេះចេញពីកន្លែងម៉ាស៊ីន មានកម្ពស់ ១,៨០ម៉ែត្រ។ បន្ទាប់មក ខ្ញុំពិតជាបាននិយាយពាក្យទាំងនេះខ្លាំងៗថា «ព្រះជាម្ចាស់ តើទ្រង់ពិតជាបានឮពាក្យដែលខ្ញុំបាននិយាយ មែនទេ?»

នៅថ្ងៃបន្ទាប់ ក្រុមហ៊ុនធានារ៉ាប់រងបានទូទាត់ប្រាក់សម្រាប់ការខូចខាតនោះ ហើយខ្ញុំទទួលបានលុយ ១.៦០០ដុល្លារភ្លាមៗ ខ្ញុំបានទូទាត់ប្រាក់ដែលជំពាក់មេធាវី ព្រមទាំងសងថ្លៃទិញរថយន្តវ៉ែននោះ ហើយនៅមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញគ្រឿងទេសមួយចំនួនទៀតដែរ។ យើងសប្បាយចិត្តផង និងតក់ស្លុតផងនៅពេលនោះ ប៉ុន្តែការគ្មានរថយន្តវ៉ែន គឺជាបញ្ហាមួយដែលយើងទាំងប្រាំមួយនាក់ត្រូវដោះស្រាយ ។

**បន្ទាប់មក ខ្ញុំពិតជាបាននិយាយពាក្យទាំងនេះខ្លាំងៗថា «ព្រះជាម្ចាស់ តើទ្រង់ពិតជាបានឮពាក្យដែលខ្ញុំបាននិយាយ មែនទេ?»**

ខ្ញុំពិតជាមិនអាចពន្យល់ពីអ្វីដែលបានកើតឡើងនៅពេលនោះបានទេ ប៉ុន្តែការពិតដែលខ្ញុំបាននិយាយខ្លាំងៗថា វាប្រសើរជាងប្រសិនបើឡានវ៉ែនរបស់ខ្ញុំឆេះ បានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។ ខ្ញុំទទួលស្គាល់ថា ខ្ញុំមិនធ្លាប់មានរថយន្តដែលឆេះបែបនេះពីមុនមកទេ។ ម៉្យាងវិញទៀត ខ្ញុំក៏មិនដែលនិយាយខ្លាំងៗថាខ្ញុំចង់ឱ្យវាកើតឡើងបែបនោះដែរ។

តើរឿងនេះទាក់ទងជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរឬទេ? តើខ្ញុំបានធ្វើអ្វីមួយដើម្បីបង្កឱ្យរឿងនេះកើតឡើង ឬវាគ្រាន់តែជាការចៃដន្យ? យើងមិនប្រាកដទេ។ ថ្វីត្បិត តែយើងសប្បាយជាមួយជោគជ័យនៃការសងថ្លៃរថយន្តរបស់យើង ហើយបានសងថ្លៃម្ចាស់បំណុលក៏ដោយ ក៏យើងនៅតែត្រូវការរថយន្តមួយទៀត ប៉ុន្តែ ឥលូវនេះ តើត្រូវធ្វើដូចម្ដេចទៅ?

## ការរកទិញឡានវ៉ែនថ្មីមួយ

ឪពុករបស់ខ្ញុំបានទូរសព្ទសួរនាំអំពីរឿងរ៉ាវរថយន្តរបស់ខ្ញុំ ហើយបានផ្ដល់ជំនួយខ្លះក្នុងការជួសជុលរថយន្តដែលឆេះនោះ។ ប៉ារបស់ខ្ញុំមានលុយមួយចំនួន ហើយខ្ញុំសង្ឃឹមក្នុងចិត្តម្នាក់ឯងថា គាត់នឹងទិញឡានវ៉ែនឱ្យយើងមួយគ្រឿង។ គាត់បានផ្ដល់យោបល់ឱ្យយើង ទៅរកទិញតាមហាងលក់រថយន្តមួយចំនួននៅក្នុងតំបន់ ដើម្បីបានរថយន្តដែលនៅល្អប្រើ។ ជាការពិតណាស់ ខ្ញុំបានទទួលយកការផ្ដល់យោបល់នេះយ៉ាងអស់ពីចិត្ត។

យើងបានទៅហាងលក់រថយន្តពីរបីកន្លែង ហើយខ្ញុំបានឃើញឡានវ៉ែនម៉ាក Dodge Caravan ជារថយន្តនៅល្អស្អាតមែនទែន។ ប្រហែលវាជាស៊េរីក្រោមមួយឆ្នាំ ហើយស្ថិតក្នុងតម្លៃខ្ពស់។ ខ្ញុំបានប្រាប់ប៉ារបស់ខ្ញុំថា ខ្ញុំគិតថារថយន្តមួយគ្រឿងនេះហើយ ដែលគ្រិនដាចង់បាន វាមានពណ៌ក្រហមច្រាលស្អាត ហើយខ្ញុំសង្ឃឹមថាគាត់នឹងនិយាយអ្វីម៉្យាង ដូចជា «អស្ចារ្យណាស់! អីចឹងតោះយើងទៅបំពេញឯកសារទិញ

ឡាននោះ»។ ប៉ុន្តែនោះមិនមែនជាអ្វីដែលគាត់បាននិយាយទេ។ ផ្ទុយទៅវិញ គាត់បាននិយាយថា «ប៉ានឹងឱ្យប្រាក់កូន ៥.០០០ ដុល្លារ សម្រាប់ការទិញរថយន្តនេះ»។ មែនហើយ នោះគឺជាការផ្តល់ឱ្យដ៏សប្បុរសរបស់គាត់ ប៉ុន្តែគាត់ពិតជាផ្តល់ឱ្យសម្រាប់តែលុយកក់តែប៉ុណ្ណោះ លុយដែលនៅសល់គឺខ្ញុំជាអ្នកចេញ។

ភ្លាមៗនោះ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលជាមួយការពិតមួយនេះ។ ខ្ញុំមិនមានការវាយតម្លៃឥណទានល្អគ្រប់គ្រាន់ ដែលអាចឱ្យធនាគារណាមួយអនុញ្ញាតឱ្យខ្ញុំខ្ចីលុយពួកគេបានទេ។ ហើយរហូតមកដល់ពេលនេះ ខ្ញុំនៅតែអាចលាក់បាំងស្ថានភាពហិរញ្ញវត្ថុដ៏អាក្រក់របស់ខ្ញុំពីឪពុករបស់ខ្ញុំ។ ទីពីរ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនចង់បង្កើនបំណុលថែមទៀតទេ។

ទោះជាយ៉ាងណាក៏ដោយ ដោយគ្មានជម្រើសផ្សេងទៀត ខ្ញុំបានសម្រេចចិត្តយ៉ាងលឿន យ៉ាងហោចណាស់ក៏ខ្ញុំត្រូវបំពេញឯកសារឥណទានដែរ។ ទោះជាខ្ញុំដឹងពីរបៀបដែលត្រូវបំពេញវាក៏ដោយ ក៏ខ្ញុំត្រូវតែសារភាពស្ថានភាពពិតរបស់ខ្ញុំទៅកាន់ឪពុករបស់ខ្ញុំ ហើយគាត់នឹងត្រូវចុះហត្ថលេខារួមនៅលើឯកសារនោះ។ ខ្ញុំបានប្រាប់រឿងរ៉ាវទាំងអស់ដល់ឪពុករបស់ខ្ញុំដោយមានភាពស្មោះស្មើរ គាត់ក៏បានយល់ព្រមតាមសំណើរក្នុងការចុះហត្ថលេខាលើការកម្ចីរួមគ្នា ហើយយើងក៏បានប្រគល់វាឱ្យម្ចាស់ហាង។ អ្នកលក់បានប្រាប់ខ្ញុំថា ពួកគេនឹងជូនដំណឹងដល់ខ្ញុំនៅពេលព្រឹកស្អែក។

ជាការពិតណាស់ ខ្ញុំបានដឹងថា ធនាគារនឹងអនុម័តប្រាក់កម្ចីនោះ ដោយសារឪពុករបស់ខ្ញុំមានកាតឥណទានល្អ។ ការដែលធនាគារអនុម័តប្រាក់កម្ចីដល់ខ្ញុំ មិនមែនជាអ្វីដែលរំខានខ្ញុំនៅពេលខ្ញុំបើករថយន្តត្រលប់ទៅផ្ទះវិញទេ។ ខ្ញុំដឹងថាខ្ញុំមិនអាចខ្ចីប្រាក់នោះទេ ប៉ុន្តែខ្ញុំមានតម្រូវការដ៏ពិតប្រាកដមួយ ប៉ុន្តែខ្ញុំគ្មានប្រាក់សោះ។ តើខ្ញុំត្រូវធ្វើអ្វីទៅ? ខ្ញុំមានអារម្មណ៍ច្របូកច្របល់ និងតូចចិត្តបន្តិចបន្តួចដែរ។

ពេលដែលខ្ញុំទៅដល់ផ្ទះ ហើយប្រាប់ពីស្ថានភាពដែលបានកើតឡើងទៅគ្រិនដា នាងក៏ដឹងដែរថាយើងមិនអាចចុះហត្ថលេខាលើឯកសារបំណុលណាផ្សេងទៀតបានទេ ប៉ុន្តែតើយើងមានជម្រើសអ្វីទៀតទេ? ពេលយប់នោះយើងទាំងពីរនាក់គេងមិនបានស្រួលទេ ប៉ុន្តែពេលព្រឹកឡើង យើងដឹងច្បាស់ថាការខ្ចីលុយទិញរថយន្តនោះ មិនមែនជាអ្វីដែលយើងគួរធ្វើទេ។

ដូច្នេះ ខ្ញុំបានទូរសព្ទទៅឪពុករបស់ខ្ញុំ ហើយបានអរគុណគាត់សម្រាប់ការផ្តល់ឱ្យរបស់គាត់ ហើយបានប្រាប់គាត់ថា យើងមិនអាចមានបំណុលថែមទៀត ដើម្បីយកប្រាក់មកទិញរថយន្តនោះបានទេ។ បន្ទាប់មក ខ្ញុំបានទូរសព្ទទៅអ្នកលក់រថយន្តដោយប្រាប់ពួកគេថា យើងនឹងមិនទិញរថយន្តនោះទេ។ ពួកគេបានប្រាប់ខ្ញុំថា ប្រាក់កម្ចីសម្រាប់រថយន្តនោះត្រូវបានអនុម័តហើយ ហើយរថយន្តនោះបានលាងស្អាត និងត្រៀមជាស្រេចសម្រាប់ការដឹកយកទៅឱ្យពួកយើង។ ខ្ញុំបានអរគុណពួកគេ ប៉ុន្តែបានទទូចថា ខ្ញុំមិនអាចយករថយន្តនោះបានទេ។

ពេលដែលខ្ញុំដាក់ទូរសព្ទចុះ ខ្ញុំមានអារម្មណ៍សន្តិភាពនៅក្នុងចិត្ត ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ខ្ញុំក៏មិនដឹងថាតើយើងអាចទិញរថយន្តធំល្មមសម្រាប់គ្រួសារយើងដែលមានគ្នាប្រាំមួយនាក់បានដោយរបៀបណាទេ។ ខ្ញុំនៅមានរថយន្តមួយគ្រឿងទៀតដែលមានកៅអីប្រាំ ជារថយន្តដែលខ្ញុំបើកទៅធ្វើជំនួញ ហើយយើងត្រូវប្រើវា រហូតទាល់តែយើងទទួលបានគំនិតថ្មីណាមួយផ្សេងទៀត។ ប្រហែលពីរសប្តាហ៍បានកន្លងផុតទៅ យើងបានប្រើរថយន្តកៅអីប្រាំរបស់យើង ដោយត្រូវធ្វើដំណើរច្រើនដងពេលយើងត្រូវទៅកន្លែងណាមួយ។

បន្ទាប់មកនៅថ្ងៃមួយ ខ្ញុំបានទទួលទូរសព្ទពីបុរសម្នាក់ ដែលគ្រិនដាបានជួបកាលពីប៉ុន្មានខែមុន។ នាងកំពុងតែស្វែងរករបស់របរមួយចំនួន ដើម្បីលក់នៅក្នុងការដេញថ្លៃវត្ថុបុរាណរបស់ឪពុកម្តាយនាង ដែលការដេញថ្លៃនោះធ្វើឡើងជារៀងរាល់ខែ

នៅក្នុងរដ្ឋអាត្លង់តា ជាកន្លែងដែលឪពុកម្ដាយគ្រិនដារស់នៅ។ ពួកគាត់នឹងមករដ្ឋអូហៃយ៉ូមួយខែម្ដង ដើម្បីទិញរបស់របរសម្រាប់ការដេញថ្លៃ ហើយគ្រិនដាបានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់នូវអ្វីៗគ្រប់យ៉ាងដែលនាងគិតថាវាអាចមានប្រយោជន៍សម្រាប់ការដេញថ្លៃនោះ។ វាជាការរកប្រាក់បន្តិចបន្តួចបន្ថែមទៀតជារៀងរាល់ខែ ជាអ្វីដែលគ្រិនដាអាចរកបាន ដែលឪពុកម្ដាយគ្រិនដាឱ្យកម្រៃជើងសារដល់នាង។

ដូចជាចម្លែកបន្តិចដែរ គ្រិនដាបានជួបបុរសម្នាក់នេះដោយចៃដន់នៅកន្លែងមួយ ហើយពួកគេបានសន្ទនាជាមួយគ្នាអំពីអ្វីដែលនាងធ្វើ និងអ្វីដែលគាត់ធ្វើ។ នាងបានប្រាប់គាត់ថា ប្រសិនបើគាត់មានអ្វីត្រូវលក់ នាងប្រហែលជាចាប់អារម្មណ៍ចង់ទិញ។ ជាក់ស្តែង គាត់បានបើកមណ្ឌលថែទាំដ៏ធំមួយ ហើយយូរៗម្ដង អ្នកជំងឺនឹងដោះដូររបស់របរពេលពួកគេត្រលប់ទៅផ្ទះពួកគេវិញ។ ពេលដែលមិនមានគ្រួសារថែរក្សារបស់របរប្រើប្រាស់ក្នុងផ្ទះ ដែលពួកគេលែងត្រូវការ គាត់នឹងរក្សាទុកវានៅកន្លែងមួយសិន ហើយនៅទីបំផុតក៏ត្រូវលក់របស់ទាំងនោះចោល។

ខ្ញុំមិនបានស្គាល់គាត់ទេ ដូច្នេះពេលគាត់ទូរសព្ទមក ខ្ញុំក៏ចំណាំ ហើយបានប្រាប់គ្រិនដាថាគាត់បានទូរសព្ទមក។ និយាយរួមទៅ ពេលដែលនាងបានទូរសព្ទទៅគាត់វិញ គាត់បានប្រាប់នាងថា គាត់មានបន្ទប់បីដែលពេញទៅដោយគ្រឿងសង្ហារឹម ហើយមានរបស់របរប្រើប្រាស់ក្នុងផ្ទះមួយចំនួនទៀតផងដែរ ដែលគាត់ត្រូវការរើសម្អាត ហើយគាត់បានសួរនាងថា តើនាងចាប់អារម្មណ៍ដែរឬទេ។ គាត់បានលក់របស់ទាំងអស់នោះ ក្នុងតម្លៃមួយយ៉ាងទាបបំផុត។

គ្រិនដា និងខ្ញុំក៏បានទៅមើលបន្ទប់នោះ ហើយទោះបីជាយើងមិនអាចឃើញរបស់របរទាំងអស់នៅក្នុងបន្ទប់នោះក៏ដោយ ដោយសារបន្ទប់នោះបានបំពេញទៅដោយរបស់របរជាច្រើនពីកម្រាលតដ្ឋដល់ពិដាន ក៏យើងបានឃើញរបស់របរមួយចំនួនដែលយើងគិតថាអាចលក់បានតម្លៃលើសពីតម្លៃដែលគាត់បានសុំយើងដែរ។

យើងបានទូរសព្ទទៅឪពុកម្ដាយខ្រិនដា ហើយពួកគេបានផ្ទេរប្រាក់មកឱ្យយើង ពួកគេបានយករថយន្តដឹកទំនិញរបស់ពួកគេ ហើយដឹកយករបស់របរទាំងនោះត្រលប់ទៅរដ្ឋអាត្លង់តាវិញ សម្រាប់ការដាក់ដេញថ្លៃប្រចាំខែរបស់ពួកគេ។

ការដេញថ្លៃទទួលបានភាពជោគជ័យដ៏ធំធេង ហើយសម្រាប់កម្រៃជើងសាររបស់យើង ពួកគេបានយល់ព្រមផ្ដល់ឱ្យយើងនូវរថយន្តម៉ាក Peugeot station wagon ដែលជារថយន្តស៊េរីក្រោមពីរបីឆ្នាំតែប៉ុណ្ណោះ ហើយវានៅស្អាតល្អ។ ឥលូវនេះ ខ្ញុំដឹងថាមនុស្សភាគច្រើននៅពេលទទួលបានរថយន្ត ប្រហែលវាមិនមែនជាហេតុផលសម្រាប់ការអបអរដ៏រីករាយអីនោះទេ។ ប៉ុន្តែសម្រាប់យើងនៅពេលនោះវិញ វាជាលើកទីមួយហើយ ដែលយើងទទួលបានរថយន្តមួយដោយមិនចាំបាច់ចំណាយប្រាក់។ រថយន្តនេះទើបតែត្រូវបានគេបាញ់ពណ៌ថ្មីឡើងវិញ ហើយមើលទៅវាថ្មីស្រឡាងតែម្ដង។ យើងពិតជាសប្បាយចិត្តខ្លាំងណាស់។

រំពេចនោះ ខ្ញុំបានចាប់ផ្ដើមយល់អំពីវា ខ្ញុំបានទុកចិត្តព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់ខ្ញុំ ដោយមិនឱ្យជាប់បំណុលគេ។

## ការផ្លាស់ប្ដូរដ៏សំខាន់

មានព្រឹត្តិការណ៍មួយទៀត ដែលខ្ញុំបានមានបទពិសោធជាមួយព្រះអម្ចាស់កាលពីមួយឆ្នាំមុននេះ ខណៈពេលដែលយើងកំពុងរស់នៅក្នុងរដ្ឋអូក្លាហូម៉ា (Oklahoma) ឥលូវនេះ វាកាន់តែច្បាស់សម្រាប់ខ្ញុំហើយ។ ដោយសម្លឹងមើលពីអតីតកាល ខ្ញុំអាចមើលឃើញថាព្រះអម្ចាស់កំពុងព្យាយាមឱ្យខ្ញុំយកចិត្តទុកដាក់ចំពោះទ្រង់។ ប៉ុន្តែរហូតមកដល់ពេលនេះ យើងបានជំពាក់បំណុលគេវ័ណ្ឌក និងរងសម្ពាធដោយមិនដឹងខ្លួន យើងមិនបានឃើញអ្វីដែលព្រះជាម្ចាស់កំពុងព្យាយាមបង្រៀនយើងទេ។

ខ្ញុំចូលចិត្តការបរបាញ់ខ្លាំងណាស់ ហើយជាពិសេសការបរបាញ់សត្វក្ដាន់តែម្ដង។ ប៉ុន្តែខ្ញុំក៏ចូលចិត្តញ៉ាំសាច់វាផងដែរ ហើយក៏ត្រូវមានអ្វីបង្ហាញជាភស្តុតាង

សម្រាប់ការប្រឹងប្រែងបរបាញ់របស់ខ្ញុំដែរ។ ដូចជាកាលពីមុនអីចឹង ខ្ញុំបានទៅបរបាញ់ ប៉ុន្តែមិនបានទទួលអ្វីដើម្បីបង្ហាញជាភស្តុតាងអំពីការខិតខំប្រឹងប្រែងជាច្រើនឆ្នាំកន្លងមកនេះទេ។ ខ្ញុំបានចេញទៅក្រៅ អង្គុយយ៉ាងស្ងៀមស្ងាត់ ហើយចាំមើលពីមួយថ្ងៃទៅមួយថ្ងៃទៀត តែមិនឃើញសត្វក្តាន់ សូម្បីតែមួយក្បាល។ ការនេះធ្វើឱ្យខ្ញុំខកចិត្តបន្តិច ដោយសារខ្ញុំមានកូនដែលត្រូវចិញ្ចឹម ហើយពិតជាត្រូវការសាច់សត្វក្តាន់នោះខ្លាំងណាស់។ ថ្វីត្បិតតែខ្ញុំធ្លាប់ទទួលបានជោគជ័យក្នុងការបរបាញ់កាលពីមុនក៏ដោយ វាជារឿងយូរឆ្នាំមកហើយ ជាពេលដែលខ្ញុំទទួលបានជោគជ័យក្នុងការប្រមាញ់សត្វក្តាន់ ហើយបានយកសាច់វាត្រលប់មកផ្ទះវិញ។

មានថ្ងៃមួយ ពេលដែលខ្ញុំកំពុងគិតអំពីរដូវប្រមាញ់សត្វក្តាន់ពេលខាងមុខ ខ្ញុំបានឮសំឡេងរបស់ព្រះអម្ចាស់។ ទ្រង់បានមានបន្ទូលថា «ហេតុអ្វីបានជាអ្នកមិនអនុញ្ញាតឱ្យយើង បង្ហាញអ្នកពីរបៀបដើម្បីទទួលបានសត្វក្តាន់របស់អ្នកទៅ?» វាធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល។ «បង្ហាញខ្ញុំពីរបៀបដើម្បីទទួលបានសត្វក្តាន់របស់ខ្ញុំ?» តើការនេះមានន័យយ៉ាងដូចម្តេច?

ដោយអធិស្ឋាន សូមការពន្យល់បន្ថែមអំពីពាក្យទាំងនោះ ខ្ញុំមានអារម្មណ៍ថា ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញឱ្យខ្ញុំយល់ ក្នុងការសាបព្រោះគ្រាប់ពូជផ្នែកហិរញ្ញវត្ថុ ឬអំណោយទានសម្រាប់គោលបំណងដ៏ពិតប្រាកដក្នុងការប្រមូលផលពីសត្វក្តាន់នោះ។ ខ្ញុំមិនដែលធ្លាប់សាបព្រោះប្រាក់ដោយរំពឹងថានឹងប្រមូលផលសត្វក្តាន់ពីមុនមកទេ ហើយវាមានអារម្មណ៍ចម្លែកបន្តិចនៅពេលដំបូង។ ប៉ុន្តែខ្ញុំមានអារម្មណ៍យ៉ាងច្បាស់ថា ព្រះអម្ចាស់បានដឹកនាំខ្ញុំឱ្យសាបព្រោះគ្រាប់ពូជនោះ ដោយមានការណែនាំយ៉ាងលម្អិតមួយចំនួន ពេលខ្ញុំធ្វើដូច្នេះ។ ខ្ញុំបានសរសេរលើមូលប្បទានបត្រសម្រាប់ចំនួនដែលខ្ញុំមានអារម្មណ៍ថា ត្រូវបានដឹកនាំឱ្យសាបព្រោះសម្រាប់ការនោះ។ ខ្ញុំ និងឌ្រិនដា យើងទាំងពីរនាក់បានដាក់ដៃលើមូលប្បទានបត្រ ហើយប្រកាសថាយើងទទួលបានសត្វក្តាន់ឈ្មោលមួយក្បាលនៅឆ្នាំ១៩៨៧នោះហើយ ហើយយើងដឹងថាទទួលបានវានៅ

ពេលដែលយើងអធិស្ឋាន មិនមែនពេលក្រោយនោះទេ គឺយើងទទួលបានវានៅពេលដែលយើងអធិស្ឋាននោះឯង។

ទោះជាយ៉ាងណាក៏ដោយ ក្នុងនាមខ្ញុំជាគ្រិស្តបរិស័ទម្នាក់ ខ្ញុំតែងតែផ្តល់ឱ្យ និងផ្គត់ផ្គង់ក្រុមជំនុំរបស់ខ្ញុំ ដោយសាបព្រោះតាមរបៀបនេះ ដោយបានផ្ទង់ចិត្ត និងជឿជាក់ថាខ្ញុំទទួលបានអ្វីដែលខ្ញុំចង់បានរួចហើយ។ ពេលដែលខ្ញុំអធិស្ឋាន មានអ្វីកើតឡើងសម្រាប់ខ្ញុំ។

ដូច្នេះ ខ្ញុំបានយកមូលប្បទានបត្រមួយ ហើយសរសេរនៅក្នុងផ្នែកកិច្ចព្រមព្រៀង «សម្រាប់សត្វក្តាន់ឈ្មោលរបស់ខ្ញុំនៅឆ្នាំ១៩៨៧»។ ខ្ញុំ និងឌ្រិនដាបានដាក់ដៃលើមូលប្បទានបត្រនោះ រួចផ្ញើវាតាមប្រៃសណីយ៍ទៅព័ន្ធកិច្ចមួយដែលខ្ញុំទុកចិត្ត ហើយបានប្រកាសថាខ្ញុំបានទទួលសត្វក្តាន់ដូចដែលខ្ញុំចង់បានរួចហើយ។ ខ្ញុំបានយកក្រដាសមួយសន្លឹក ហើយសរសេរថ្ងៃ និងពេលវេលាដែលខ្ញុំជឿថាខ្ញុំទទួលបានសត្វក្តាន់នោះហើយ ហើយដាក់វាក្នុងហោប៉ៅអាវប្រមាញ់របស់ខ្ញុំ។

នៅពេលនោះ នៅក្នុងទីក្រុងធុលសា រដ្ឋអូក្លាហូម៉ា មានការកំណត់ទាក់ទងជាមួយការបរបាញ់ ខ្ញុំមិនមានកន្លែងសម្រាប់ការបរបាញ់នៅពេលនោះទេ ប៉ុន្តែមិត្តរបស់ខ្ញុំម្នាក់មកពីក្រុមជំនុំបានអញ្ជើញខ្ញុំឱ្យមកផ្ទះលោកយាយរបស់គាត់ សម្រាប់ពិធីបុណ្យដឹងគុណ។ ហើយគាត់បាននិយាយថា មានសត្វក្តាន់ពីរបីក្បាលនៅជុំវិញកសិដ្ឋាននៅទីនោះ។

ដូច្នេះ ក្រុមគ្រួសាររបស់ខ្ញុំបានទៅចូលរួមថ្ងៃបុណ្យដឹងគុណនាពេលព្រឹកនោះ ដើម្បីទៅបរិភោគអាហារ និងការប្រកបគ្នានៅក្នុងថ្ងៃដ៏សប្បាយរីករាយ ហើយបន្ទាប់មក ក៏ដល់ពេលចេញទៅបរបាញ់សត្វក្តាន់របស់ខ្ញុំ។ មិត្តរបស់ខ្ញុំពិតជាមិនដឹងថា ត្រូវប្រាប់ខ្ញុំឱ្យទៅបរបាញ់នៅទីណាទេ ប៉ុន្តែមានវាលស្មៅមួយកន្លែងដែលមានព្រៃប្រទល់

ជាប់ព្រៃឈើ ហើយគាត់បានផ្ដល់យោបល់ឱ្យខ្ញុំចេញទៅវាលស្មៅនោះ ហើយគាត់បានអង្គុយក្បែរដើមឈើដ៏ធំមួយនៅទីនោះ។

ឥលូវនេះ ខ្ញុំចង់ពន្យល់អ្នកឱ្យយល់ពីស្ថានភាពនៅពេលនោះបន្តិច។ នៅពេលព្រះអាទិត្យកំពុងបញ្ចេញពន្លឺនៅជុំវិញខ្លួនខ្ញុំ ខ្ញុំបានដឹងថាខ្ញុំកំពុងអង្គុយនៅកណ្ដាលវាលស្មៅដែលមានដើមឈើដ៏ធំមួយនៅចំកណ្ដាល។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំស្ថិតនៅទីតាំងមួយដែលខុសហើយ ដោយសារខ្ញុំដឹងថាគ្មានសត្វក្ដាន់ណាដែលល្ងង់ ហើយមកបង្ហាញខ្លួនពេលខ្ញុំកំពុងអង្គុយយ៉ាងច្រងោនៅកណ្ដាលវាលស្មៅនោះទេ។

ខ្ញុំហៀបនឹងក្រោកឡើងឆ្ពោះទៅរកព្រៃនៅពីមុខខ្ញុំ ដែលមានចំងាយប្រហែល ១២០ម៉ែត្រ ពេលដែលខ្ញុំឮសំឡេងរត់នៅក្នុងព្រៃតាមរបងខាងឆ្វេងដៃរបស់ខ្ញុំ។ ខ្ញុំអាចឮសំឡេងស្លឹកឈើពីចម្ងាយ ហើយខ្ញុំដឹងថាវាជាសត្វក្ដាន់។

រំពេចនោះ មានក្ដាន់បីក្បាលដើរចូលក្នុងព្រៃតាមរបងនោះ។ ខ្ញុំបានឃើញពួកវាតែមួយភ្លែតទេ ហើយពួកវាបានរត់ចូលទៅក្នុងព្រៃបាត់ទៅ។ សត្វក្ដាន់បានរត់ទៅឆ្ងាយហើយ ប៉ុន្តែខ្ញុំបានឈប់បន្តិច ហើយរង់ចាំពីរបីនាទី មុនពេលខ្ញុំផ្លាស់ទីទៅក្នុងព្រៃដែលជាកន្លែងដែលខ្ញុំមានអារម្មណ៍ថាសត្វក្ដាន់នឹងផ្លាស់ទីទៅកន្លែងនោះ។ បន្ទាប់មកការដែលមិននឹកស្មានដល់មួយបានកើតឡើង គឺមានក្ដាន់មួយក្បាល កំពុងរត់កាត់ទីវាលពីក្រោយខ្ញុំវាសំដៅមករកដើមឈើរបស់ខ្ញុំ។

ខ្ញុំស្ថិតនៅទីតាំងមួយដែលផ្ទុយពីទីតាំងកាលពីមុន ដែលសត្វក្ដាន់នោះបានធ្វើដំណើរឆ្លងកាត់វាលស្មៅឆ្ពោះទៅរកព្រៃនៅខាងមុខខ្ញុំ ហើយវាមិនបានឃើញខ្ញុំទេ។ ក្ដាន់នោះបានរត់ទៅរកដើមឈើ វាធុំក្លិនរបស់ខ្ញុំ ហើយបានឈប់ដោយសំឡេងស្រមុកជាខ្លាំង ដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល។ ពេលខ្ញុំក្រឡេកមើលទៅខាងស្ដាំ រំពេចនោះស្រាប់តែឮសំឡេង ខ្ញុំក៏ភ្ញាក់ផ្អើលជាខ្លាំង ពេលឃើញសត្វក្ដាន់ដែលមានពិន្ទុប្រាំមួយកំពុងរត់សំដៅមករកខ្ញុំ ដែលមានចម្ងាយពីខ្ញុំប្រហែល៤,៥០ម៉ែត្រប៉ុណ្ណោះ។ ភ្លាមៗនោះ ក្ដាន់

បានដឹងខ្លួនថានឹងមានអ្វីកើតឡើងហើយ ហើយវាបានរត់ពេញមួយទំហឹងសំដៅទៅរកព្រៃ ជាមួយនឹងជំហានផ្លោះវែងៗរបស់វា។

ឥលូវនេះ ខ្ញុំកំពុងតែព្យាយាមតម្រង់កាំភ្លើងបាញ់ក្ដាន់កន្ទុយសនោះ ដែលកំពុងតែរត់យ៉ាងលឿន។ ដោយសារតែវាយឺតពិបាកចាប់គោលដៅបានល្អ ហើយខ្ញុំបានដឹងថា ខ្ញុំមានឱកាសបាញ់តែមួយគ្រាប់តែប៉ុណ្ណោះទេ មុនពេលដែលវារត់ចូលទៅក្នុងព្រៃវិញ។ ខ្ញុំគ្មានវិធីណាដែលអាចតម្រង់ឱ្យចំគោលដៅទេ ខណៈដែលសត្វក្ដាន់នោះកំពុងផ្លោះដោយជំហានវែងៗបែបនេះនោះ។ គឺសល់ចម្ងាយត្រឹមតែ១៨ម៉ែត្រប៉ុណ្ណោះមុនពេលសត្វក្ដាន់នោះរត់ចូលទៅក្នុងព្រៃវិញ ហើយខ្ញុំក៏បានកេះកៃកាំភ្លើង។ នៅពេលបាញ់វា ក្ដាន់នោះក៏ដួល ហើយមិនបានរត់ទៀតទេ។ ខ្ញុំបានភ្ញាក់ផ្អើលជាខ្លាំង! តើខ្ញុំពិតជាបាញ់ត្រូវសត្វក្ដាន់នោះហើយមែនទេ? វាបានកើតឡើងលឿនណាស់! ខ្ញុំក្រោកឡើងយឺតៗ ហើយដើរទៅរកកន្លែងដែលក្ដាន់នោះដួលចុះ។ ខ្ញុំបានយកក្រដាសចេញពីហោប៉ៅយ៉ាងលឿន ហើយចាប់ផ្ដើមអរព្រះគុណព្រះជាម្ចាស់សម្រាប់ការបាញ់បានសត្វក្ដាន់មួយនោះ។

ដោយបានឮសូរសំឡេងកាំភ្លើង មិត្តរបស់ខ្ញុំបានចេញមកដើម្បីអបអរដល់ខ្ញុំសម្រាប់ការបាញ់របស់ខ្ញុំ។ គាត់បានឃើញសត្វក្ដាន់ដេកនៅទីនោះ។ ខ្ញុំមិនបានប្រាប់មិត្តខ្ញុំ អំពីអ្វីដែលព្រះអម្ចាស់បានប្រាប់ខ្ញុំទេ ប៉ុន្តែខ្ញុំមើលទៅគាត់ ហើយគាត់បាននិយាយថា «ខ្ញុំគិតថាខ្ញុំបាញ់បានសត្វក្ដាន់នេះ មិនមែនដោយសារសមត្ថភាពរបស់ខ្ញុំទេ»។ បន្ទាប់មក ខ្ញុំបានបង្ហាញគាត់នូវក្រដាសដែលខ្ញុំបានសរសេរនៅថ្ងៃ ដែលខ្ញុំ និងគ្រីនដាបានអធិស្ឋានសម្រាប់សត្វក្ដាន់នោះ។ ក្នុងក្រដាសនោះសរសេរយ៉ាងសាមញ្ញថា «ខ្ញុំជឿថាខ្ញុំទទួលបានសត្វក្ដាន់ឈ្មោលក្នុងឆ្នាំ១៩៨៧ នៅក្នុងកាលបរិច្ឆេទនេះ និងពេលវេលានេះ ខ្ញុំបានអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូ»។ ខ្ញុំលើកក្រដាសឱ្យមិត្តខ្ញុំមើលរួចចាប់ផ្ដើមប្រាប់គាត់អំពីអ្វីដែលព្រះអម្ចាស់បានប្រាប់ខ្ញុំឱ្យធ្វើ។




ព្រឹត្តិការណ៍នេះបានធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាខ្លាំង។ ខ្ញុំបានដឹងច្បាស់ដោយគ្មានការសង្ស័យបន្តិចសោះថា រឿងនោះគឺព្រះជាម្ចាស់ជាអ្នកធ្វើ។ ប៉ុន្តែមិនដឹងថាហេតុអ្វីទេ ខ្ញុំនៅមិនទាន់បានយល់ពីចំណុចទាំងអស់នោះនៅឡើយទេ។ នៅពេលនោះខ្ញុំមិនទាន់យល់ពីគោលគំនិតនៃច្បាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់ និងអ្វីដែលបានកើតឡើងជាមួយសត្វក្តាន់ អាចមានឥទ្ធិពលលើហិរញ្ញវត្ថុរបស់ខ្ញុំនៅឡើយទេ។ ការទទួលបានសត្វក្តាន់នោះពិតជាអស្ចារ្យខ្លាំងណាស់ ប៉ុន្តែតើវានឹងកើតឡើងម្តងទៀតដែរឬទេ? បើគ្មានគោលគំនិតនៃច្បាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់ទេ នោះខ្ញុំនឹងមិនអាចដឹងប្រាកដអំពីរបៀប ឬច្បាប់ដែលធ្វើឱ្យសត្វក្តាន់បង្ហាញខ្លួនបានទេ។ ប៉ុន្តែខ្ញុំមានចិត្តទន្ទឹងរងចាំសាកល្បងម្តងទៀត នៅរដូវប្រមាញ់ក្តាន់បន្ទាប់នេះ។

**ព្រឹត្តិការណ៍នេះបានធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាខ្លាំង។ ខ្ញុំបានដឹងច្បាស់ដោយគ្មានការសង្ស័យបន្តិចសោះថា រឿងនោះគឺព្រះជាម្ចាស់ជាអ្នកធ្វើ។**

## ជំនឿមានដំណើរការគ្រប់ពេល

រដូវកាលប្រមាញ់សត្វក្ដាន់បន្ទាប់បានធ្វើឱ្យមានការផ្លាស់ប្ដូរមួយកើតឡើង នៅពេលដែលយើងផ្លាស់ប្ដូរទីកន្លែងរស់នៅរបស់យើង ពីទីក្រុងធុលសាទៅនៅរដ្ឋអូហៃយ៉ូ។ គំនិតនៃការផ្លាស់ប្ដូរទីកន្លែងនេះបានកើតឡើងនៅពេលខ្ញុំកំពុងរត់ហាត់ប្រាណ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានមានបន្ទូលមកកាន់ខ្ញុំ ដោយប្រាប់ខ្ញុំថាដល់ពេលដែលត្រូវរើផ្ទះទៅរដ្ឋអូហៃយ៉ូហើយ ហើយនៅទីនោះខ្ញុំនឹងធ្វើការងារគ្រាចុងក្រោយរបស់ខ្ញុំ។

ខ្ញុំបានរស់នៅក្នុងទីក្រុងធុលសារហូតដល់ពេលនោះ គឺមានរយៈពេលដប់ឆ្នាំហើយ ហើយខ្ញុំចូលចិត្តរស់នៅទីក្រុងធុលសាខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនអាចសប្បាយចិត្តជាងការចាកចេញដែលធ្វើឱ្យអនាគតរបស់ខ្ញុំបានប្រសើរជាងនេះទេ។ កាលពីមួយឆ្នាំមុននេះ វិបត្តិប្រេងបានជះឥទ្ធិពលដល់ទីក្រុងធុលសាយ៉ាងខ្លាំង ព្រោះសេដ្ឋកិច្ចរបស់ទីក្រុងនោះពឹងផ្អែកលើវិស័យប្រេងជាចម្បង។ ហិរញ្ញវត្ថុរបស់យើងបានជួបវិបត្តិ ហើយយើងបានដឹងខ្លួនឯងថា ស្ទើរតែរកអ្វីផ្គត់ផ្គង់ខ្លួនឯងមិនបានទៅហើយទេ។ ការចាប់ផ្ដើមថ្មី គឺជាអ្វីដែលខ្ញុំរំភើបចិត្ត។ រឿងរ៉ាវផ្សេងទៀតដែលខ្ញុំបានដឹងគឺថា ប្រាំបួនឆ្នាំខាងមុខនេះ នឹងធ្វើឱ្យផ្នែកហិរញ្ញវត្ថុកាន់តែយ៉ាប់យ៉ឺនជាមុន ដែលអាក្រក់ជាងអ្វីដែលយើងបានឃើញនៅទីក្រុងធុលសានាពេលបច្ចុប្បន្ននេះទៅទៀត។

យើងបានផ្លាស់ទីលំនៅទៅរស់នៅរដ្ឋអូហៃយ៉ូនៅដើមរដូវក្ដៅ ហើយខ្ញុំបានទន្ទឹងរង់ចាំមើលថា យើងអាចធ្វើអ្វីបាននៅក្នុងរដ្ឋអូហៃយ៉ូនេះ។ យើងបានដឹងថាការចាប់ផ្ដើមអាជីវកម្មជាថ្មីឡើងវិញ រួមទាំងការយកបំណុលទាំងអស់របស់យើងទៅរដ្ឋអូហៃយ៉ូ គឺពិតជាតានតឹងខ្លាំងណាស់សម្រាប់ពួកយើង។

ពិតមែនហើយ រដូវប្រមាញ់ក្ដាន់បានឈានមកដល់ ចំនឹងថ្ងៃកំណើតកូនទីបីរបស់យើង ឈ្មោះថម (Tom) ។ ថម កើតនៅថ្ងៃទីពីរនៃរដូវប្រមាញ់ក្ដាន់ក្នុងរដ្ឋអូហៃយ៉ូដូច្នេះច្បាស់ណាស់ ខ្ញុំគ្មានពេលច្រើនដើម្បីស្វែងរកកន្លែងដើម្បីបរបាញ់ទេ ដោយសារ

មានទារកដែលត្រូវចាប់កំណើត ហើយត្រូវចាប់ផ្ដើមអាជីវកម្មជាថ្មីឡើងវិញ។ ខ្ញុំស្គាល់តែកន្លែងមួយតែប៉ុណ្ណោះនៅពេលនោះសម្រាប់ការបរបាញ់។

ឆ្លងផ្លូវម្ខាងពីផ្ទះដែលខ្ញុំបានធំធាត់ឡើង ខ្ញុំធ្លាប់ដាក់អន្ទាក់កាលពីខ្ញុំនៅរៀននៅវិទ្យាល័យ។ នៅស្រែចម្ការរបស់ឪពុកម្ដាយខ្ញុំ មានស្រះមួយនៅទីនោះ ដែលមានអូរតូចមួយហូរកាត់កសិដ្ឋានរបស់អ្នកជិតខាង ហើយបន្ទាប់មកហូរកាន់ស្រះរបស់យើង។ ខ្ញុំទទួលស្គាល់ថា ទោះបីជាខ្ញុំធ្លាប់បានដើរលេងតាមមាត់អូរនោះជាច្រើនឆ្នាំក៏ដោយ ក៏ខ្ញុំមិនធ្លាប់បានឃើញសត្វក្ដាន់ ឬសូម្បីតែដានជើងរបស់វានៅលើដីនៅទីនោះទេ។ ប៉ុន្តែខ្ញុំចាំបានថាកាលនៅរៀននៅមហាវិទ្យាល័យ ខ្ញុំបានទទួលទូរសព្ទពីបងប្រុសរបស់ខ្ញុំ ដែលបានប្រាប់ខ្ញុំថាគាត់មានការភ្ញាក់ផ្អើលជាខ្លាំង ដោយថ្ងៃមួយគាត់បានឃើញសត្វក្ដាន់មួយក្បាលនៅទីនោះ ហើយគាត់បានរៀបគម្រោងក្នុងការប្រមាញ់វានៅទីនោះនារដូវស្លឹកឈើជ្រុះខាងមុខនេះ។ យើងទាំងពីរនាក់ភ្ញាក់ផ្អើលមែនទែន។ ខ្ញុំចងចាំក្នុងចិត្តជានិច្ចអំពីការសន្ទនាពេលនោះ ដែលមកដល់ពេលនេះគឺបានប្រាំបួន ឬដប់ឆ្នាំហើយ។

ខ្ញុំបានចងចាំទីកន្លែងយ៉ាងច្បាស់ ពេលដែលគាត់និយាយថា បានឃើញសត្វក្ដាន់ ព្រោះខ្ញុំស្គាល់អូរនោះច្បាស់ណាស់។ គាត់បានបញ្ជាក់ថា គាត់បានឃើញសត្វក្ដាន់នៅកន្លែងផ្លូវទឹកហូរបែកជាពីរ ហើយមានដើមឈើម៉េផល (Maple) ធំមួយ។ បន្ទាប់មកគាត់បានប្រាប់ខ្ញុំទៀតថា មានដើមម៉េផលតូចមួយនៅក្បែរដើមម៉េផលដែលធំជាង ហើយគាត់ដឹងថាគាត់អាចឡើងតាមដើមឈើតូចឆ្លងទៅដើមឈើធំបាន គាត់គិតថាកន្លែងនោះគឺជាទីតាំងដ៏ល្អដើម្បីប្រមាញ់សត្វក្ដាន់។

ពិតមែនហើយ បងប្រុសរបស់ខ្ញុំមិនដែលបាញ់សត្វក្ដាន់នៅតាមអូរនោះទេ ទោះបីជាគាត់និយាយថាគាត់ធ្លាប់បាញ់ក្ដាន់ខុសម្ដងក៏ដោយ។ ប៉ុន្តែគាត់មិនបានត្រលប់មកទីនោះ អស់ពេលជាច្រើនឆ្នាំហើយ ដូច្នេះខ្ញុំមិនដឹងថា តើដើមឈើនោះនៅទី

នោះទៀតដែរឬទេ ឬក៏ខ្ញុំអាចរកដើមឈើនោះ នៅពេលព្រឹកទាបភ្លឺសម្រាប់ផែនការប្រមាញ់របស់ខ្ញុំបានដែរឬទេ។

រឿងដែលកាន់តែពិបាកមួយទៀតនោះគឺ រដ្ឋអូហៃយ៉ូអនុញ្ញាតឱ្យយើងប្រើប្រាស់តែកាំភ្លើងខ្លីតែប៉ុណ្ណោះទេ។ រដ្ឋនោះមិនអនុញ្ញាតឱ្យយើងប្រើប្រាស់កាំភ្លើងវែងក្នុងរដូវប្រមាញ់សត្វក្ដាន់ទេ សត្វក្ដាន់អាចឱ្យបាញ់បានតែពីកាំភ្លើងខ្លីតែប៉ុណ្ណោះ។ ខ្ញុំមានតែកាំភ្លើងម៉ាក double barreled 20-gauge ប៉ុណ្ណោះនៅពេលនោះ ហើយមិនមានទំនុកចិត្តថា ខ្ញុំអាចបាញ់ត្រូវសត្វក្ដាន់ទេ លើកលែងតែវាស្ថិតក្នុងចម្ងាយ ១៨ម៉ែត្រពីខ្ញុំ។ ប៉ុន្តែនោះជាអ្វីដែលខ្ញុំមានពេលនោះ ដូច្នេះវាជាផែនការរបស់ខ្ញុំ។

ខ្រិនដា និងខ្ញុំបានសាបព្រោះគ្រាប់ពូជរបស់យើង ដាក់ដៃលើមូលប្បទានបត្រដូចដែលយើងបានធ្វើកាលពីឆ្នាំមុន ហើយបានប្រកាសថា ខ្ញុំទទួលបានសត្វក្ដាន់យោងទៅតាមម៉ាកុស ១១:២៤ ។ និយាយឱ្យខ្លីទៅ នៅថ្ងៃទី៤ នៃរដូវកាលប្រមាញ់នៅរដ្ឋអូហៃយ៉ូ ដែលជាថ្ងៃដំបូងរបស់ខ្ញុំ ក្នុងរយៈ៤០នាទី ខ្ញុំបាញ់បានសត្វក្ដាន់ញីមួយក្បាល និងឈ្មោលមួយក្បាល ការបាញ់ទាំងពីរនេះមានចម្ងាយ ៧០ ម៉ែត្រ ដែលហួសពីសមត្ថភាពរបស់ខ្ញុំជាមួយនឹងកាំភ្លើងខ្លីដ៏រលោងស្អាតមួយនោះ។ រដ្ឋអូហៃយ៉ូកំណត់ឱ្យបាញ់សត្វក្ដាន់បានតែពីរទេនៅពេលនោះ នេះជាមូលហេតុដែលខ្ញុំបាញ់សត្វក្ដាន់ពីរនៅឆ្នាំនោះ។ ត្រូវហើយ ត្រឹមរយៈពេលតែ៤០នាទីតែប៉ុណ្ណោះ ខ្ញុំបាញ់បានសត្វក្ដាន់ពីរ។

ជាថ្មីម្ដងទៀត ខ្ញុំបានដឹងថាខ្ញុំជួបរឿងល្អៗជាច្រើន។ ប៉ុន្តែកំឡុងពេលដែលប្រមាញ់សត្វក្ដាន់នេះ ផ្នែកហិរញ្ញវត្ថុរបស់យើងមិនល្អទាល់តែសោះ ហើយមានភាពតានតឹងក្នុងអារម្មណ៍ជាខ្លាំង។ តាមពិត ពួកយើងមិនដែលអនុវត្តតាមគោលការណ៍ដូចគ្នានេះជាមួយហិរញ្ញវត្ថុរបស់យើងទេ។

## «ការមានភាពតាប់ជួន» ច្រើនពេក

វាពិតជាអាក្រក់ខ្លាំងណាស់ នៅដើមរដូវរងារនោះ និង១២ខែបន្ទាប់នៅក្នុងរដ្ឋអូហៃយ៉ូ។ ខ្ញុំមានបញ្ហាខាងផ្លូវអារម្មណ៍ ការខ្វល់ខ្វាយជ្រុល និងការបាក់ទឹកចិត្ត ដូចដែលខ្ញុំបានចែករំលែកនៅក្នុងសេចក្តីផ្តើមនៅក្នុងសៀវភៅនេះអ៊ីចឹង។

**និយាយឱ្យចំទៅ ព្រះជាម្ចាស់នឹងប្រើអ្វីៗគ្រប់យ៉ាង ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នក។**

វាកើតឡើងនៅខែវិច្ឆិកា ជិតដល់រដូវប្រមាញ់សត្វក្តាន់ ដែលរថយន្តរបស់យើងបានឆេះ។ ទោះបីជាពីដំបូងខ្ញុំបានប្រមាញ់សត្វក្តាន់បានជោគជ័យក៏ដោយ ដែលនៅពេលនោះខ្ញុំទទួលបានសត្វក្តាន់ពីរ ខ្ញុំនៅតែមិនទាន់ទទួលបានការបើសម្តែងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឡើយទេ។ ពេលរថយន្តរបស់យើងបានឆេះ ហើយព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំអំពីព្រះរាជ្យរបស់ទ្រង់ ខ្ញុំបានដឹងថា វាមានអត្ថន័យជាងរឿងរ៉ាវទាំងបី ដែលខ្ញុំបានគិតពីដំបូងទៅទៀត។ ខ្ញុំមានអារម្មណ៍ថាទទួលបានការលើកទឹកចិត្តយ៉ាងខ្លាំង ប៉ុន្តែមកដល់ពេលនេះ ខ្ញុំនៅមិនដឹងអំពីច្បាប់នៃព្រះរាជ្យរបស់ជាម្ចាស់នៅឡើយទេ។

រដូវប្រមាញ់សត្វក្តាន់បន្ទាប់ក៏បានមកដល់ ហើយខ្ញុំបាញ់បានសត្វក្តាន់មួយក្នុងរយៈពេលប្រហែល៤០នាទីម្តងទៀតហើយ ដូចជាបានកំណត់ម៉ោងអ៊ីចឹង។ យើងបានចាប់ផ្តើមឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ធ្វើការក្នុងផ្នែកហិរញ្ញវត្ថុរបស់យើងផងដែរ ដែលខ្ញុំនឹងរៀបរាប់រឿងនេះនៅក្នុងជំពូកទី២។ ប៉ុន្តែនៅឆ្នាំដំបូងនោះ ខ្ញុំបានយល់នូវរឿងដ៏អស្ចារ្យមួយចំនួន។

មែនហើយ វាហាក់បីដូចជាព្រះជាម្ចាស់បង្រៀនខ្ញុំនូវអ្វីមួយដែលថ្មី នៅពេលការប្រមាញ់សត្វក្តាន់របស់ខ្ញុំបានមកដល់។ ខ្ញុំគិតអំពីមូលហេតុនេះ ពីព្រោះរដូវប្រមាញ់

សត្វក្តាន់ជាពេលដែលប្រមូលផល ហើយវាកើតឡើងក្នុងពេលមួយដែលអាចគ្រប់គ្រងបាន ហើយក៏មានពេលកំណត់យ៉ាងច្បាស់លាស់ដែរ។ រដូវកាលនៃការប្រមាញ់នៅរដ្ឋអូហៃយ៉ូ ជាធម្មតាបើកឱ្យបរបាញ់ត្រឹមតែពីរសប្តាហ៍តែប៉ុណ្ណោះ។ វាដូចជារដូវដែលត្រូវតែផ្តោតអារម្មណ៍លើការប្រមូលផលអីចឹង អ្នកមិនចង់ខ្ជះខ្ជាយពេលវេលាទេ។ ផ្ទុយទៅវិញ អ្នកប្រមាញ់សត្វក្តាន់ភាគច្រើនផ្តោតអារម្មណ៍ និងតក់ក្រហល់ជាខ្លាំង ចំពោះរដូវកាលប្រមាញ់នេះ។ មនុស្សភាគច្រើននឹងចំណាយពេលជាច្រើនម៉ោងដើម្បីស្វែងរកទីតាំង និងរៀបចំខ្លួនសម្រាប់ឱកាសប្រមាញ់ក្នុងរយៈពេលពីរសប្តាហ៍នោះ។ ហេតុដូច្នេះហើយ ទើបធ្វើឱ្យខ្ញុំមានឱកាសក្នុងការដកពិសោធព្រះរាជ្យរបស់ព្រះជាម្ចាស់។

ដូច្នេះ ខ្ញុំសូមអភ័យទោសចំពោះការលើកឡើងអំពីការប្រមាញ់សត្វក្តាន់នេះ ប៉ុន្តែវាសំខាន់ណាស់សម្រាប់ខ្ញុំ។ រឿងរ៉ាវទាំងនេះ បានបើកសម្តែងពីច្បាប់ដ៏អាថ៌កំបាំង បើមិនដូច្នេះទេ ខ្ញុំនឹងមិនបានយល់ពីវាឡើយ។ និយាយដោយត្រង់ទៅ ព្រះជាម្ចាស់នឹងប្រើអ្វីៗគ្រប់យ៉ាងដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នក។ ទ្រង់បានប្រើការនេសាទត្រី ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់លោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហាន នៅក្នុងសៀវភៅលូកាជំពូកប្រាំ នៅពេលពួកគេចាប់បានត្រីជាច្រើនដែលធ្វើឱ្យទូករបស់ពួកគេហៀបនឹងលិចទៅហើយ។ វាបានកើតឡើងដូចគ្នានៅក្នុងករណីរបស់ខ្ញុំ គឺទ្រង់បានប្រើប្រាស់ការប្រមាញ់សត្វក្តាន់។

បន្ទាប់ពីព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំនៅក្នុងបន្ទប់គេងរបស់ខ្ញុំ អំពីព្រះរាជ្យរបស់ទ្រង់នៅថ្ងៃនោះមក ហើយបន្ទាប់ពីខ្ញុំបានឃើញរថយន្តរបស់ខ្ញុំបានឆេះហើយនឹកឃើញដល់ការប្រមាញ់សត្វក្តាន់ ហើយបន្ទាប់មកទៀតព្រះជាម្ចាស់បានបើកទ្វារឱ្យយើងទទួលបានរថយន្តមួយដ៏ល្អមួយគ្រឿងម៉ាក Station Wagon ដោយមិនត្រូវជាប់បំណុលគេមក ស្រាប់តែយើងបានយល់អំពីរឿងរ៉ាវទាំងអស់នោះ។ ឌ្រិនដា និងខ្ញុំពិតជាបានដាក់ចិត្តទាំងស្រុងក្នុងរឿងនេះ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ខ្ញុំបានចាប់ផ្ដើមសិក្សាគម្ពីរតាមរបៀបមួយថ្មីទាំងស្រុង។ ខ្ញុំបានហៅខ្លួនឯងថាជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ។ ខ្ញុំចាប់ផ្ដើមសួរសំណួរថា «ហេតុអ្វីបានជាវាកើតឡើងយ៉ាងដូច្នេះ?» «ហេតុអ្វីបានជាវាមិនកើតឡើងយ៉ាងដូច្នោះវិញ?»។ ពេលខ្ញុំអានព្រះគម្ពីរ ខ្ញុំបានស្វែងរកតម្រុយនៃច្បាប់ខាងវិញ្ញាណនៅពីក្រោយរឿងរ៉ាវទាំងនោះ។

ព្រះជាម្ចាស់នៅតែបន្តបង្ហាញរឿងរ៉ាវផ្សេងៗដល់ខ្ញុំទៀត ហើយទ្រង់បានប្រើការប្រមាញ់សត្វក្ដាន់ ដើម្បីបង្ហាញឱ្យខ្ញុំឃើញអំពីព្រះរាជ្យរបស់ទ្រង់បន្ថែមទៀត។ រឿងបន្ទាប់នេះ ពិតជាធ្វើឱ្យខ្ញុំយកចិត្តទុកដាក់ខ្លាំងមែនទែន។ វាគឺជារឿងមួយផ្សេងទៀតក្នុងចំណោមស្ថានភាពនៃរឿងរ៉ាវទាំងនោះ «តើអ្នកបានដឹងអំពីរឿងនោះដែរឬទេ?»

នៅពេលល្ងាចថ្ងៃបុណ្យហាឡូវីន ខ្ញុំមានពេលប្រហែល៩៥នាទីមុនពេលគ្រួសាររបស់យើងត្រូវទៅក្រុមជំនុំដើម្បីចូលរួមពិធីជប់លៀងមួយ ដែលយើងប្រារព្ធឡើងជំនួសឱ្យការប្រារព្ធបុណ្យនោះតាមប្រពៃណី។

ខ្រិនដា និងខ្ញុំបានសាបព្រោះគ្រាប់ពូជរបស់យើងសម្រាប់សត្វក្ដាន់មួយក្បាល បានដាក់ដៃលើមូលប្បទានបត្រ ផ្ញើវាទៅព័ន្ធកិច្ចមួយដែលយើងជឿថាព្រះជាម្ចាស់បានបង្ហាញដល់យើង ហើយយើងបានអធិស្ឋានឱ្យវាសម្រេចតាមម៉ាកុស ១១: ២៤ ពីរបីសប្ដាហ៍មុននេះ។ នេះជាលើកទីមួយរបស់ខ្ញុំនៅក្នុងរដូវកាលប្រមាញ់នេះ ហើយខ្ញុំកំពុងដើរបរបាញ់លើដីដែលយើងបានជួល។

ទោះបីជាខ្ញុំមានពេលវេលាតិចក៏ដោយ ដោយសារព្រះជាម្ចាស់បានប្រាប់ខ្ញុំពីរបៀបបរបាញ់ដោយជំនឿ ជាធម្មតាខ្ញុំបាញ់បានសត្វក្ដាន់ត្រឹមតែរយៈពេល៥០នាទីតែប៉ុណ្ណោះ ដូច្នេះខ្ញុំមានអារម្មណ៍ថាជិតអស់ពេលហើយ ប៉ុន្តែខ្ញុំមិនទាន់បាញ់បានសត្វក្ដាន់មួយនៅឡើយទេ។ នៅថ្ងៃដ៏ពិសេសនោះ ខ្ញុំបានទៅកន្លែងដើមឈើនៅពីក្រោយដើមស្រល់ ដែលនៅខាងក្រោយផ្ទះចម្ការចាស់របស់យើង ហើយខ្ញុំបានឡើងលើដើមឈើនោះ។ ខ្ញុំនៅទីនោះមិនដល់២០នាទីផង ពេលដែលខ្ញុំប្រទះឃើញសត្វក្ដាន់មួយ

នៅចម្ងាយប្រហែល១៨០ម៉ែត្រ កំពុងតែធ្វើដំណើរចេញនៅចំពោះមុខខ្ញុំ ចូលទៅក្នុងព្រៃអ្នកជិតខាង។ ខ្ញុំដឹងថាវាគឺជាសត្វក្តាន់របស់ខ្ញុំហើយ ប៉ុន្តែវាបានដើរខុសផ្លូវហើយ!

វាទើបតែជាឆ្នាំទីពីរដែលខ្ញុំដើរប្រមាញ់ ខ្ញុំពិតជាមិនទាន់បានដឹងពីរបៀបក្នុងការប្រមាញ់ច្រើនប៉ុន្មានទេនៅពេលនោះ។ ខ្ញុំមិនបានស្លៀកសម្លៀកបំពាក់បំបាំងកាយ មិនបានធ្វើសំឡេងហៅសត្វក្តាន់ និងមិនបានដឹងសូម្បីតែរបៀបប្រើក្លិនក្រអូបដើម្បីទាក់ទាញសត្វក្តាន់។ ជើងទម្រឈើរបស់ខ្ញុំគឺជាក្តារដែលខ្ញុំបានដំដែកគោលតភ្ជាប់គ្នាដែលមានចំងាយប្រហែល៩ម៉ែត្រពីដី ដែលប្រសិនបើអ្នកដឹងពីការបរបាញ់នៅលើដើមឈើ កម្ពស់នេះគឺមិនខ្ពស់ល្មមទេ។ ប៉ុន្តែកាលពីឆ្នាំមុន វាជាការបរបាញ់ឆ្នាំដំបូងរបស់ខ្ញុំ ខ្ញុំទៅបាញ់ពីរដង ហើយបានសត្វក្តាន់ចំនួនពីរដែរ។ ខ្ញុំបានចេញទៅក្រៅដោយប្រើជំនឿរបស់ខ្ញុំ ហើយខ្ញុំមិនរំពឹងថានឹងទទួលបានក្តាន់ច្រើននៅឆ្នាំនេះទេ។

ពេលខ្ញុំបានឃើញសត្វក្តាន់ដើរខុសផ្លូវ ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងណាទេ ដូច្នេះខ្ញុំចាប់ផ្តើមអធិស្ឋាន។ ភ្លាមៗនោះ ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់ខ្ញុំ។ ទ្រង់មានបន្ទូលថា «ចូរប្រាប់ឱ្យសត្វក្តាន់នោះដើរមករកអ្នកទៅ»។ ខ្ញុំមានការភ្ញាក់ផ្អើលបន្តិច នៅពេលដែលបានឮដូច្នេះ ។ ចូរប្រាប់សត្វក្តាន់ដើរមករកខ្ញុំ? ខ្ញុំដឹងថាខ្ញុំមិនអាចស្រែកខ្លាំងៗបានទេ ដូច្នេះខ្ញុំគ្រាន់តែនិយាយជាសំឡេងសន្ទនាថា «សត្វក្តាន់ ឈប់! ចូរដើរមកឈរនៅក្រោមដើមឈើរបស់ខ្ញុំ»។ ដូចឆ្កួតមែនទេ? វាមិនមែនជាការធ្វើសំឡេងហៅសត្វក្តាន់អីទេ។ ប៉ុន្តែលើកទីពីរ ដែលខ្ញុំនិយាយពាក្យនោះ សត្វក្តាន់ក៏ឈប់ ហើយបានមើលមកទិសដៅទាំងពីរ បន្ទាប់មកក៏ងាកមកក្រោយ ហើយចាប់ផ្តើមដើរចម្ងាយ១៨០ម៉ែត្រ ឆ្ពោះមករកខ្ញុំ។ ទោះបីជាព្រៃដែលខ្ញុំពួននោះមានទទឹងប្រហែល ៣៦៥ម៉ែត្រ) ក៏ដោយ ក៏ក្តាន់ដើរតម្រង់មកដើមឈើរបស់ខ្ញុំ ដើរសំដៅមកក្រោមដើម ហើយឈរស្ងៀមនៅទីនោះតែម្តង។

ជាការពិតណាស់ ខ្ញុំមិនអាចបាញ់ខុសនោះទេ។ វ៉ោ! តើខ្ញុំទើបតែបាញ់ត្រូវវាមែនទេ? សត្វក្ងាន់បានដួលចុះនៅពីក្រោមខ្ញុំ ដោយសារខ្ញុំបានបាញ់ចំគោលដៅ។ ខ្ញុំក្រឡេកមើលនាឡិការបស់ខ្ញុំ ហើយដឹងថាប្រសិនបើខ្ញុំចង់ទៅពិធីជប់លៀងឱ្យទាន់ពេល ខ្ញុំត្រូវទុកសត្វក្ងាន់នៅទីនេះសិន រហូតទាល់តែខ្ញុំត្រលប់មកវិញ ហើយយកវាទៅដាក់ក្នុងកន្លែងស្តុកទុក។ ខ្ញុំទទួលស្គាល់ថា ខ្ញុំបានចំណាយពេលគិតអំពីអ្វីដែលខ្ញុំបានឃើញជាច្រើនសប្តាហ៍បន្ទាប់ពីពេលនោះមក។ ប៉ុន្តែព្រះជាម្ចាស់មិនទាន់បញ្ចប់ការទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំនៅឡើយទេ។

កសិដ្ឋានដែលយើងជួលនោះមានព្រែកហូរកាត់ អមដោយគុម្ពោតព្រៃជាច្រើន។ ជាកន្លែងដ៏ល្អសម្រាប់ការបរបាញ់សត្វទន្សាយ។ នៅថ្ងៃដ៏ពិសេសនោះ មានព្រិលធ្លាក់នៅពេលយប់ ហើយព្រិលតែងតែធ្វើឱ្យងាយស្រួលក្នុងការមើលឃើញសត្វទន្សាយ។ ខ្ញុំទ្រាំមិនបានទេ ដូច្នេះកូនខ្ញុំ ធីម និងខ្ញុំបានចូលព្រៃចុះទៅក្រោមព្រែក ហើយពេលយើងយកជើងទាត់គុម្ពោតព្រៃ រំពេចនោះ មានមាន់ទោរមួយក្បាលហើរចេញពីគុម្ពោតព្រៃនោះ។

នៅក្នុងរដ្ឋអូហៃយ៉ូ មានរដូវកាលប្រមាញ់មាន់ទោរដែរ ប៉ុន្តែខ្ញុំមិនដែលឃើញមាន់ទោរនៅក្នុងកសិដ្ឋានទេ ប្រហែលមានតែម្តងក្នុងមួយឆ្នាំតែប៉ុណ្ណោះ។ ពិតណាស់ នៅពេលដែលសត្វមាន់ទោរនោះបានហើរចេញពីគុម្ពោតព្រៃ ខ្ញុំពិតជារំភើបក្នុងការបាញ់វា។ ពេលខ្ញុំបាញ់ចំបក្សីនោះ វាក៏ធ្លាក់ចុះមកប៉ះនឹងដី ហើយខ្ញុំក៏រត់ទៅរកវា។ ខ្ញុំដឹងភ្លាមៗថាខ្ញុំបានបាញ់វាត្រូវត្រង់ណាហើយ គឺចំស្លាបរបស់វា។ បក្សីនោះកំពុងរត់យ៉ាងពេញកម្លាំង ឡើងលើដីទួលដែលដុះចេញពីព្រែក ហើយមាន់ទោរអាចរត់បានរហូតដល់៣៥ម៉ាយ (៥៦ គីឡូម៉ែត្រ) ក្នុងមួយម៉ោង។ ជាការពិតណាស់ ដោយមានព្រិលវារត់មិនបានលឿនទេ ប៉ុន្តែវានៅតែរត់លឿនគ្រាន់បើដែរនៅពេលនោះ។

ដោយសារព្រៃកនោះស្ថិតនៅបាតជ្រោះដ៏វែង ខ្ញុំបានឃើញទិដ្ឋភាពគ្រប់ជ្រុងជ្រោយនៃដីទួលនោះ។ ដីទួលនេះត្រូវបានគេប្រើសម្រាប់ដាំស្មៅកាលពីឆ្នាំមុន ដូច្នេះវាមានលក្ខណៈរាបស្មើល្អ ដោយសារមានស្មៅដុះតែបន្តិចបន្តួចទេ។

នៅពេលដែលបក្សីកំពុងរត់ពេញលើដីទួលនោះ ខ្ញុំដឹងថាគ្មានវិធីណាដែលខ្ញុំអាចចាប់វាបានទេ ហើយវាហួសពីចម្ងាយដែលកាំភ្លើងខ្លីអាចបាញ់វាដល់។ ប៉ុន្តែភ្លាមៗនោះ ខ្ញុំនឹកចាំអំពីរឿងសត្វក្ដាន់ ដែលវាដើរមករកខ្ញុំពេលខ្ញុំនិយាយ។ ដូច្នេះ ខ្ញុំបានស្រែកខ្លាំងៗថា «បក្សីនៅឱ្យស្ងៀម!» នៅពេលដែលខ្ញុំនិយាយដូច្នេះ បក្សីក៏បាត់ទៅ។ ខ្ញុំបានឃើញទិដ្ឋភាពនៅលើទីទួលទាំងមូលយ៉ាងច្បាស់ ដែលគ្របដណ្ដប់ដោយព្រិល ហើយមានស្មៅដុះតិចតួចនៅពីលើព្រិល ប៉ុន្តែវាបានរត់បាត់ទៅហើយ។ ធីម បានស្រែកថា «ប៉ា តើបក្សីនោះរត់ទៅណាបាត់ហើយ?» ខ្ញុំបានឆ្លើយថា «ប៉ាក៏មិនដឹងដែរ»។

ដូច្នេះ យើងចាប់ផ្តើមដើរតាមផ្លូវឡើងលើទីទួលនោះ ហើយខ្ញុំក៏បានឃើញវាសំកុកនៅទីនោះ ដោយក្បាលដ៏តូចរបស់វាជាប់ក្នុងព្រិល។ ខ្ញុំគិតថា «មែនហើយ តើខ្ញុំបានបាញ់ត្រូវវា ហើយវារត់រហូតដល់ស្លាប់មែនទេ?» ខ្ញុំក៏លូកដៃទៅចាប់ក្សីនោះ ហើយវាក៏បានបម្រាស ស្រែកឡើង ហើយទទះស្លាបហើរ។ វាគឺជាបក្សីព្រៃ។ បក្សីនោះនៅមានកម្លាំងពេញនៅឡើយទេ! នៅយប់នោះពេលខ្ញុំកាប់បក្សីនោះធ្វើម្ហូប ខ្ញុំបានពិនិត្យមើលវា។ មិនមានស្នាមណាមួយនៅលើបក្សីនោះទេ ប៉ុន្តែខ្ញុំបានឃើញកន្លែងដែលខ្ញុំបាញ់ត្រូវវាបន្តិច នៅស្លាបខាងស្ដាំរបស់វាតែប៉ុណ្ណោះ។ ដូច្នេះ បក្សីនេះពិតជានៅមានកម្លាំងពេញនៅឡើយទេ ប៉ុន្តែវាបាននៅស្ងៀមភ្លាមៗពេលដែលខ្ញុំស្រែកថា «នៅឱ្យស្ងៀម!»។

ពិតមែនហើយ ព្រះជាម្ចាស់បានធ្វើឱ្យខ្ញុំយកចិត្តទុកដាក់ខ្លាំងចំពោះរឿងរ៉ាវទាំងអស់នេះ!

# ជំពូក ២
# ការគិតក្នុងរបៀបថ្មីមួយ

នៅពេលដែលឌ្រិនដា និងខ្ញុំបានចាប់ផ្តើមយល់ដឹងអំពីរបៀបព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការនៅក្នុងជីវិតរបស់យើង យើងមិនអាចឈប់ប្រាប់មនុស្សអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ។ យើងបានដឹងថាយើងស្ថិតនៅលើផ្លូវដ៏រំភើបរីករាយមួយនៃការរកឃើញ និងការរំដោះឱ្យមានសេរីភាព។ ខ្ញុំនៅតែលក់ធានារ៉ាប់រង និងមូលបត្រ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាមានអ្វីមួយកំពុងផ្លាស់ប្តូរ។ ខ្ញុំមិនដឹងថាវាជាការផ្លាស់ប្តូរអ្វីនោះទេ ប៉ុន្តែខ្ញុំដឹងថានៅទីនេះមានចម្លើយសម្រាប់ហិរញ្ញវត្ថុរបស់ខ្ញុំ ដូចដែលខ្ញុំបានឃើញនៅក្នុងការបរបាញ់សត្វក្តាន់របស់ខ្ញុំ និងដូចដែលខ្ញុំបានឃើញនៅក្នុងការទទួលបានរថយន្តម៉ាក station wagon ដែលល្អស្អាតផងដែរ។ ខ្ញុំដឹងថា ខ្ញុំត្រូវការអ្វីដែលល្អប្រសើរជាងរថយន្តម៉ាក station wagon ដ៏ល្អស្អាតនេះទៅទៀត ទោះបីខ្ញុំពិតជារំភើបរីករាយដែលខ្ញុំមានវាក៏ដោយ។

រហូតមកដល់ពេលនេះ ខ្ញុំនៅតែមានបំណុលជាច្រើនទៀតនៅក្នុងជីវិតរបស់យើងនៅឡើយទេ។ ខ្ញុំចង់រួចពីបំណុល ប៉ុន្តែមិនដឹងថាត្រូវកែប្រែវាយ៉ាងដូចម្តេចទេ។ ទោះបីជាខ្ញុំមិនដឹងថាត្រូវកែប្រែវាយ៉ាងដូចម្តេចក៏ដោយ តែខ្ញុំប្រាកដថាខ្ញុំនឹងស្វែងរកដំណោះស្រាយបាន។ ខ្ញុំដឹងថាខ្ញុំបានរកឃើញចម្លើយរបស់ខ្ញុំហើយ ប៉ុន្តែជាថ្មីម្តងទៀត ខ្ញុំត្រូវរៀនបន្ថែមទៀតក្នុងការយល់អំពីស្ថានភាពដែលខ្ញុំបានឃើញក្នុងព្រះគម្ពីរដើម្បីបង្ហាញឱ្យឃើញជាក់ស្តែងនៅក្នុងជីវិតរបស់ខ្ញុំ។ អាជីវកម្មរបស់ខ្ញុំដូចជាងើបឡើងវិញហើយនៅពេលនោះ ដែលគ្រាន់តែអាចផ្គត់ផ្គង់លើការចំណាយរស់នៅរបស់

យើងបាន។ ប៉ុន្តែវាក៏ប្រសើរជាងពេលដែលយើងជំពាក់បំណុលគេច្រើនទៅៗជារៀងរាល់ខែដែរ។

ខ្រិនដា និងខ្ញុំបានបន្តអានព្រះគម្ពីរ ហើយស្វែងរកតម្រុយបន្ថែមទៀតទាក់ទងនឹងមុខងាររបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់។ យើងបានសាបព្រោះប្រាក់របស់យើងសម្រាប់ហិរញ្ញវត្ថុដែលយើងត្រូវការផងដែរ។

នៅយប់មួយ ខ្ញុំបានយល់សប្តិ។ នៅក្នុងការយល់សប្តិនោះខ្ញុំបានឃើញសត្វដង្កូវមេអំបៅវារឃើតៗឡើងលើដើមរុក្ខជាតិ។ បន្ទាប់មកដង្កូវនោះក៏វារចេញពីមែកឈើ និងសម្បុកនាងរបស់វា។ នៅពេលដែលបានចេញពីសម្បុកនាងរួច រំពេចនោះវាបានក្លាយជាមេអំបៅដ៏ស្រស់ស្អាតមួយ ដែលអាចហោះហើរទៅក្រៅបាន។ បន្ទាប់មកស្រាប់តែមានសំឡេងមួយនិយាយថា «ដូច្នេះអាជីវកម្មរបស់អ្នក គួរតែមានការផ្លាស់ប្តូរល្អបែបនេះដែរ»។

ខ្ញុំបានភ្ញាក់ឡើង ហើយយល់ពីអត្ថន័យនៃសប្តិនោះ។ អ្វីដែលសត្វដង្កូវអាចធ្វើបានគឺមានតែវារទេ ហើយជីវិតរបស់វាមានកម្រិតខ្លាំងណាស់ ជាធម្មតាដង្កូវនោះរស់នៅលើរុក្ខជាតិពេញមួយជីវិតរបស់វា។ ប៉ុន្តែការបំប្លែងខ្លួនបានកើតឡើង ដែលធ្វើឱ្យមានការផ្លាស់ប្រែនៅក្នុងសក្តានុពលរបស់ដង្កូវនាងនោះពេញមួយជីវិតរបស់វា។ វាបំប្លែងខ្លួនទៅជាមេអំបៅ ដែលអាចហោះហើរគ្រប់ទីកន្លែងដែលវាចង់ទៅ។ មេអំបៅស្តេចខ្លះអាចហោះហើរបានរហូតដល់រាប់ពាន់គីឡូម៉ែត្រ ដើម្បីជៀសវាងខែរដូវរងានៅអឌ្ឍគោលខាងជើង។ ទោះបីជានៅពេលយល់សប្តិនោះ ខ្ញុំមិនដឹងថាការផ្លាស់ប្តូរនេះនឹងកើតឡើងដោយរបៀបណាក៏ដោយ ប៉ុន្តែខ្ញុំបានដឹងថាព្រះជាម្ចាស់កំពុងតែបង្ហាញខ្ញុំថា វានឹងកើតឡើង។ ខ្ញុំទទួលបានការលើកទឹកចិត្តតាមរយៈការយល់សប្តិមួយនោះ។

## ការរកឃើញដ៏អស្ចារ្យ

វាជាទម្លាប់របស់ខ្ញុំតាំងពីខ្ញុំត្រលប់ទៅរដ្ឋអូហៃយ៉ូវិញ ខ្ញុំត្រូវធ្វើការហៅទូរសព្ទទំនាក់ទំនងអតិថិជនចំនួន៩០ដងក្នុងមួយថ្ងៃនៅពេលព្រឹក។ ខ្ញុំចង់ប្រាប់អ្នកថាខ្ញុំ ខ្ញុំមានប្រព័ន្ធដ៏ល្អមួយដើម្បីធ្វើកិច្ចការទាំងនេះ ប៉ុន្តែនិយាយដោយត្រង់ទៅ ខ្ញុំបើកមើលសៀវភៅលេខទូរសព្ទជារៀងរាល់ថ្ងៃ (ពីមុនមិនមានបញ្ជីលេខទូរសព្ទទេ)។

ដោយសារខ្ញុំជាអនុប្រធានប្រចាំតំបន់សម្រាប់ក្រុមហ៊ុនដែលខ្ញុំបានធ្វើការ តួនាទីចម្បងរបស់ខ្ញុំគឺរើសបុគ្គលិក និងបណ្តុះបណ្តាលអ្នកតំណាងផ្នែកលក់ថ្មីៗ។ ខ្ញុំនឹងទូរសព្ទទៅអតិថិជន ហើយនិយាយថាក្រុមហ៊ុនរបស់ខ្ញុំកំពុងពង្រីកអាជីវកម្មរបស់យើងនៅរដ្ឋអូហៃយ៉ូនេះ ហើយខ្ញុំកំពុងធ្វើការហៅទូរសព្ទទៅតំបន់នោះ ដើម្បីដឹងថាតើពួកគេស្គាល់នរណាម្នាក់ដែលប្រហែលជាចាប់អារម្មណ៍ជាមួយក្រុមហ៊ុនរបស់យើងដែរឬទេ។ ភាគច្រើនខ្ញុំប្រើប្រាស់ទូរសព្ទលើតុ និងផ្ញើសារទៅកាន់អតិថិជន។ បើគេមានចំណាប់អារម្មណ៍ គេនឹងទូរសព្ទមកវិញ។ តាមរយៈការហៅទូរសព្ទចំនួន៩០ដងក្នុងមួយថ្ងៃ ខ្ញុំអាចរំពឹងថានឹងមានការសម្ភាសន៍ពី២ ទៅ៣នាក់ និងការលក់ដែលអាចធ្វើបានទៅតាមនោះដែរ។

តាមរយៈដំណើរការនេះ ហើយដែលខ្ញុំបានជួបដេវីឌ។ ពេលខ្ញុំនិយាយជាមួយគាត់តាមទូរសព្ទ គាត់បានប្រាប់ពីបំណងចង់ស្វែងរកការងារថ្មី ហើយគាត់ចាប់អារម្មណ៍ចង់ដឹងការងារដែលខ្ញុំអាចឱ្យគាត់ធ្វើបាន។ ខ្ញុំបានស្នើសុំទៅផ្ទះគាត់នៅល្ងាចនោះ ហើយគាត់ក៏យល់ព្រម ។ ពេលខ្ញុំអង្គុយជាមួយគាត់ និងប្រពន្ធរបស់គាត់ ខ្ញុំចាប់ផ្តើមសួរសំណួរធម្មតាទាំងអស់ អំពីកន្លែងដែលគាត់ធ្វើការពេលបច្ចុប្បន្ននេះ ហេតុអ្វីបានជាគាត់ចង់ផ្លាស់ប្តូរការងារ ហើយផ្នែកហិរញ្ញវត្ថុកន្លែងការងារដែលគាត់កំពុងធ្វើ វាល្អ ឬមិនល្អទេ។ ជាធម្មតាខ្ញុំតែងតែសួរបេក្ខជនដែលមានសក្តានុពលអំពីហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់ពួកគេ ព្រោះប្រសិនបើពួកគេមិនបានគិតថាពួកគេមានចំណាប់អារម្មណ៍ជាមួយក្រុមហ៊ុនយើងទេ នោះខ្ញុំនឹងបង្វែរការសន្ទនាតាមទូរសព្ទទៅជាការ

លក់ដ៏មានសក្តានុពលវិញ។ ដូច្នេះ ការប្រមូលទិន្នន័យហិរញ្ញវត្ថុជួយឱ្យខ្ញុំទទួលបានគំនិតអំពីចំនួនធានារ៉ាប់រងដែលពួកគេអាចទិញ និងដើម្បីមើលថាតើការធានារ៉ាប់រងអ្វីខ្លះដែលពួកគេមានរួចហើយ។

វាធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល ខណៈពេលដែលយើងកំពុងពិភាក្សាអំពីស្ថានភាពហិរញ្ញវត្ថុពេលបច្ចុប្បន្នរបស់ពួកគេ ប្រពន្ធរបស់គាត់ចាប់ផ្តើមយំដោយអស់សង្ឃឹម។ ផ្នែកហិរញ្ញវត្ថុរបស់ពួកគេធ្លាក់ចុះយ៉ាងខ្លាំង ហើយពួកគេមិនដឹងថាត្រូវធ្វើអ្វី ឬផ្លាស់ប្តូរអ្វីនោះទេ។ ខ្ញុំបានដឹងថាបញ្ហារបស់ពួកគេ គឺមិនទាក់ទងជាមួយការប្រើប្រាស់ការធានារ៉ាប់រងទេ។ ពួកគេត្រូវបង្កើនលំហូរសាច់ប្រាក់របស់ពួកគេ និងដោះបំណុល ដូច្នេះខ្ញុំក៏បានលើកឡើងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលគ្រិនដា និងខ្ញុំបានរៀនអំពីដំណើរការនេះ។ ខ្ញុំបានអះអាងជាមួយពួកគេថា ខ្ញុំនឹងធ្វើអ្វីៗគ្រប់យ៉ាងតាមតែខ្ញុំអាចធ្វើបានដើម្បីជួយពួកគេ ហើយនឹងជួបជាមួយពួកគេម្តងទៀតនៅសប្តាហ៍ក្រោយដើម្បីពិភាក្សាអំពីការផ្លាស់ប្តូរណាមួយដែលពួកគេត្រូវអនុវត្តតាម។

នៅតាមផ្លូវធ្វើដំណើរទៅការិយាល័យបន្ទាប់ពីការណាត់ជួបមួយនោះ ខ្ញុំមានអារម្មណ៍តប់ប្រមល់នៅក្នុងចិត្ត។ ខ្ញុំត្រូវតែធ្វើអ្វីមួយដើម្បីជួយពួកគេឱ្យបាន!

ពេលខ្ញុំត្រលប់ទៅការិយាល័យវិញ ខ្ញុំក៏អង្គុយនៅតុរបស់ខ្ញុំ ស្រាប់តែខ្ញុំនឹកឃើញគំនិតមួយ។ ខ្ញុំបានស្រាវជ្រាវរកជម្រើសសម្រាប់ផលិតផល ឬសេវាកម្មណាមួយដែលពួកគេកំពុងប្រើប្រាស់ ដោយសង្ឃឹមថាអាចស្វែងរកសេវាកម្មដូចគ្នាក្នុងតម្លៃដែលទាបជាង។ គោលដៅរបស់ខ្ញុំគឺដើម្បីដឹងថា តើខ្ញុំអាចជួយពួកគេដើម្បីកាត់បន្ថយបំណុលបានប៉ុន្មានដែរ។ កាលនោះគឺនៅសម័យដែលមិនទាន់មានអ៊ីនធឺណិតនៅឡើយទេ ដូច្នេះរាល់ការស្វែងរករបស់ខ្ញុំត្រូវតែចូលទៅកាន់សៀវភៅពណ៌លឿង (Yellow Pages) និងការហៅទូរសព្ទ។

មួយសប្តាហ៍ក្រោយមក ខ្ញុំបានពិនិត្យតម្លៃរាល់ផលិតផល ឬសេវាកម្មដែលពួកគេកំពុងប្រើប្រាស់ ហើយពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអ្វីដែលខ្ញុំបានរកឃើញ ។ តាមរយៈការរៀបចំឡើងវិញ ឬការប្តូរអ្នកលក់ពេលបច្ចុប្បន្នរបស់ពួកគេជាមួយនឹងអ្នកលក់ថ្មី ឬក្រុមហ៊ុនថ្មីដែលមានតម្លៃទាបជាង ខ្ញុំអាចជួយពួកគេឱ្យមានលំហូរសាច់ប្រាក់ជាង៦០០ដុល្លារក្នុងមួយខែ។ បន្ទាប់មកខ្ញុំបានយកម៉ាស៊ីនគិតលេខហិរញ្ញវត្ថុរបស់ខ្ញុំ ហើយដាក់បញ្ចូលលំហូរសាច់ប្រាក់ដែលសន្សំបាននោះទៅក្នុងរចនាសម្ពន្ធបំណុលបច្ចុប្បន្នរបស់ពួកគេ ហើយក៏ចុចប៊ូតុងគណនា។

នៅពេលដែលចំនួនលេខទាំងនោះបង្ហាញនៅលើអេក្រង់ ខ្ញុំអង្គុយនៅទីនោះទាំងស្រឡាំងកាំង។ ប្រាកដណាស់ ខ្ញុំពិតជាបានគណនាខុសនៅកន្លែងណាមួយហើយ ។ ការគណនារបស់ខ្ញុំបានបង្ហាញថាប្តីប្រពន្ធនេះអាចដោះបំណុលគ្រួចទាំងស្រុង ក្នុងរយៈពេលតិចជាងប្រាំពីរឆ្នាំ រួមទាំងប្រាក់កម្ចីទិញផ្ទះរបស់ពួកគេ ដោយមិនចាំបាច់ផ្លាស់ប្តូរប្រាក់ចំណូលពេលបច្ចុប្បន្នរបស់ពួកគេទេ។ ខ្ញុំគិតថា *វាមិនអាចទៅរួចទេ* ដូច្នេះខ្ញុំបានគណនាម្តងទៀត តែលទ្ធផលគឺនៅតែដដែលទេ។

បន្ទាប់មកខ្ញុំបានទៅកន្លែងផ្ទុកឯកសាររបស់ខ្ញុំ ហើយទាញឯកសារមួយចំនួនរបស់អតិថិជនផ្សេងទៀតរបស់ខ្ញុំចេញមក ហើយធ្វើការពិនិត្យឯកសារទាំងនោះនៅក្នុងសប្តាហ៍នោះ។ គ្រប់យ៉ាងដូចអតិថិជនបច្ចុប្បន្នរបស់ខ្ញុំដែរ ពួកគេម្នាក់ៗអាចរួចផុតពីបំណុលទាំងស្រុងក្នុងរយៈពេលពី៥ទៅ៧ឆ្នាំ រួមទាំងប្រាក់កម្ចីទិញផ្ទះរបស់ពួកគេ ដោយមិនចាំបាច់ផ្លាស់ប្តូរប្រាក់ចំណូលពេលបច្ចុប្បន្នរបស់ពួកគេទេ។ ប្រសិនបើរឿងនេះអាចទៅរួច ហើយតលូវនេះខ្ញុំដឹងថាវាមានដំណើរការយ៉ាងដូចម្តេចហើយ ចុះហេតុអ្វីបានជាមិនមានរណាម្នាក់ប្រកាសវាជាសាធារណៈទៅ? ខ្ញុំបានវាយបញ្ចូលទិន្នន័យមួយសន្លឹកសម្រាប់អតិថិជនរបស់ខ្ញុំ ដែលបង្ហាញពួកគេពីរបៀបដែលពួកគេអាចរួចផុតពីបំណុលទាំងស្រុងក្នុងរយៈពេលតិចជាងប្រាំពីរឆ្នាំ។ ខ្ញុំរំភើបរីករាយខ្លាំងណាស់ដែលបានរកឃើញរបៀបជួយពួកគេ ហើយបង្ហាញពួកគេពីអ្វីដែលខ្ញុំបានរក

ឃើញ ហើយចង់ឃើញពីរបៀបដែលពួកគេឆ្លើយតបពេលទទួលព័តិមាននោះពីខ្ញុំ តើពួកគេមានអារម្មណ៍យ៉ាងដូចម្ដេចដែរ?

ពេលខ្ញុំអង្គុយជាមួយដេវីឌ និងប្រពន្ធរបស់គាត់ ខ្ញុំបានរៀបរាប់អំពីចំនួនទឹកប្រាក់សម្រាប់មុខទំនិញនីមួយៗ ពេលដែលខ្ញុំកំពុងពន្យល់ពួកគេអំពីរបៀបដែលពួកគេអាចសន្សំប្រាក់ពួកគេបាន។ ខ្ញុំមានចេតនាលាក់បាំងលទ្ធផលចុងក្រោយ រហូតទាល់តែខ្ញុំបានរៀបរាប់គ្រប់មុខទំនិញទាំងអស់ ទើបខ្ញុំបង្ហាញពួកគេពីលំហូរសាច់ប្រាក់ដែលនៅសល់។ ការធ្វើបទបង្ហាញទាំងមូលរបស់ខ្ញុំ បានធ្វើឱ្យអតិថិជនដែលអង្គុយនៅទីនោះស្ទើរតែតក់ស្លុតទៅហើយ។ តាមទស្សនៈរបស់ពួកគេ គឺគ្មានប្រាក់នៅសល់ និងគ្មានផ្លូវណាដែលអាចរួចផុតពីបំណុលបានឡើយ គឺត្រូវនៅជាប់បំណុលគេរហូត! ពេលខ្ញុំបើកត្រលប់ទៅទំព័រចុងក្រោយ ដោយបង្ហាញថាពួកគេអាចរួចពីបំណុលក្នុងរយៈពេលតិចជាងប្រាំពីរឆ្នាំ រួមទាំងប្រាក់កម្ចីទិញផ្ទះរបស់ពួកគេផងដែរ រំពេចនោះស្រាប់តែប្ដីរបស់នាងស្ទុះលោតឡើង អរសប្បាយជាមួយទឹកភ្នែករលីងរលោង។ គាត់រំភើបរីករាយខ្លាំងណាស់។ ពេលនោះពួកគេទាំងពីរនាក់ស្រក់ទឹកភ្នែក ហើយអរគុណខ្ញុំម្ដងហើយម្ដងទៀត ដែលខ្ញុំបានជួយពួកគេ។ បន្ទាប់មកខ្ញុំបានចំណាយពេលខ្លះចែករំលែកជាមួយពួកគេអំពីអ្វីដែលព្រះជម្ចាស់បានបើកសម្ដែងដល់ខ្ញុំ និងអ្វីដែលខ្ញុំបានរៀនពីមុនមកទាក់ទងជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពួកគេបានផ្ចង់ចិត្តស្ដាប់យ៉ាងយកចិត្តទុកដាក់!

ខ្ញុំមិនបានយកប្រាក់មួយកាក់មួយសេនពីអតិថិជននោះទេ ប៉ុន្តែខ្ញុំមានអារម្មណ៍សប្បាយរីករាយជាខ្លាំងជាមួយអតិថិជនរបស់ខ្ញុំ។ ហើយតលូវនេះ ចិត្តរបស់ខ្ញុំពុះកញ្ជ្រោល។ ខ្ញុំចង់ធ្វើបែបនេះសម្រាប់អតិថិជនទាំងអស់ដែលខ្ញុំបានជួប ហើយខ្ញុំបានសុំប្រាជ្ញាពីព្រះអម្ចាស់អំពីរបៀបរកប្រាក់សម្រាប់ដំណើរការនេះ។ ខ្ញុំបានដឹងថាវានឹងក្លាយជាគំរូអាជីវកម្មថ្មីរបស់ខ្ញុំ ប្រសិនបើខ្ញុំអាចរកវិធីបង្កើតប្រាក់តាមរយៈការជួយដោះស្រាយបញ្ហាបំណុលអតិថិជន។ បន្ទាប់ពីមានការសាកល្បង និងជួបបញ្ហាមួយចំនួន

មក យើងបានរកឃើញវិធីមួយដើម្បីផ្តល់ជូនគម្រោងរបស់យើងដោយឥតគិតថ្លៃដល់អ្នកដែលបានស្នើសុំ ហើយថែមទាំងនាំមកនូវលំហូរសាច់ប្រាក់សម្រាប់អាជីវកម្មរបស់យើងផងដែរ តាមរយៈប្រព័ន្ធបញ្ជូនដែលយើងបានរៀបចំឡើង។ វាមានលក្ខណៈល្អពេកហើយ ដែលមិនគួរឱ្យជឿសោះ គ្រិនដា និងខ្ញុំមានចិត្តរំភើបជាខ្លាំង។

ខ្ញុំដឹងថានេះជាការផ្លាស់ប្តូរដែលខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំ។ ទោះបីជាខ្ញុំដឹងថាយើងទើបតែនៅក្នុងដំណាក់កាលសម្បុកដង្កូវនាងដូចក្នុងសុបិនក៏ដោយ តែខ្ញុំបានត្រៀមខ្លួនជាស្រេចដើម្បីហោះហើររួចហើយ! មានចំណុចជាច្រើនដែលខ្ញុំត្រូវរៀនដើម្បីហោះហើរឱ្យបានល្អ ប៉ុន្តែខ្ញុំដឹងថាខ្ញុំកំពុងដើរនៅលើផ្លូវត្រូវហើយ។

យើងបានចាប់ផ្តើមការសហប្រតិបត្តិការក្រុមហ៊ុនថ្មីរបស់យើង ហើយបានឱ្យឈ្មោះវាថា ហិរញ្ញវត្ថុគ្រួសារពោរពេញដោយជំនឿ (Faith-Full Family Finances) ដោយសារតែយើងដឹងថាដោយសារជំនឿ ហិរញ្ញវត្ថុរបស់អ្នកនឹងមានភាពពេញបរិបូរ។ ហើយនោះគឺដោយសារតែយើងពិតជាចង់បង្ហាញអតិថិជនយើងលើសពីចម្លើយហិរញ្ញវត្ថុ ដែលយើងផ្តល់ជូនដល់ពួកគេទៅទៀត។ យើងបានរក្សាឈ្មោះនោះអស់រយៈពេលជាង២០ឆ្នាំមកហើយ ប៉ុន្តែបានដឹងថាឈ្មោះក្រុមហ៊ុនដែលយើងបានដាក់កន្លងមកនេះ ជាឈ្មោះរបស់គ្រិស្តបរិស័ទខ្លាំងពេក ហើយយើងចង់ឈោងចាប់អ្នកដែលមិនទាន់ជឿបន្ថែមទៀត ដូច្នេះហើយយើងបានសម្រេចចិត្តប្តូរឈ្មោះរបស់យើងទៅជា ក្រុមហ៊ុនហិរញ្ញវត្ថុឆ្ពោះទៅមុខ (Forward Financial Group) ដែលជាឈ្មោះដូចសព្វថ្ងៃនេះ។ (និយាយអីចឹង គឺយើងនៅតែធ្វើផែនការដោះបំណុលដោយឥតគិតថ្លៃ ក៏ដូចជាជួយមនុស្សឱ្យជៀសវាងពីហានិភ័យទីផ្សារសម្រាប់គណនីចូលនិវត្តន៍របស់ពួកគេផងដែរ។ អ្នកអាចទាក់ទងក្រុមហ៊ុនហិរញ្ញវត្ថុឆ្ពោះទៅមុខរបស់យើង (Forward Financial Group) តាមរយៈលេខ ១-(៨០០)-៨១៥-០៨១៨ ឬតាមប្រព័ន្ធអនឡាញនៅ Forwardfinancialgroup.com។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ទោះបីជាយើងស្ថិតនៅក្នុងបំណុលវ័ណ្ឌក ពេលដែលយើងបង្កើតក្រុមហ៊ុនរបស់យើងក៏ដោយ យើងបានដឹងថាយើងបានដើរលើផ្លូវដ៏ត្រឹមត្រូវហើយ។ ក្រុមហ៊ុនរបស់យើងទទួលបានជោគជ័យដ៏ធំធេង ហើយឌ្រិនដា និងខ្ញុំបានរួចផុតពីបំណុលរយៈពេលប្រហែលតែពីរឆ្នាំកន្លះតែប៉ុណ្ណោះ។ ខ្ញុំមិនអាចពិពណ៌នាប្រាប់អ្នកថាខ្ញុំមានអារម្មណ៍រំភើបយ៉ាងណានោះទេ! ភ្លាមៗនោះ ជីវិតរបស់យើងមិនរស់ដើម្បីគ្រាន់តែរស់តែប៉ុណ្ណោះទេ ហើយនិមិត្តរបស់យើងបានចាប់ផ្ដើមលេចជារូបរាងឡើង។

ការយកប្រាក់ទៅទិញរថយន្តថ្មីពិតជាអស្ចារ្យខ្លាំងណាស់។ ការទិញ និងបង់ប្រាក់ជាសាច់ប្រាក់សម្រាប់ដី៥៥ហិចតា ដែលជាដីដ៏ស្រស់ស្អាតនៅក្នុងរដ្ឋអូហៃយ៉ូ ក៏ជារឿងមួយដែលរកអ្វីថ្លែងពុំបានផងដែរ។ ការសាងសង់ផ្ទះក្នុងក្ដីស្រមៃដែលមានទំហំ ៧១៥,៣៥ ម៉ែត្រការ៉េរបស់យើង ព្រមទាំងការបង់ថ្លៃសម្រាប់វា វាជារឿងដ៏មិនគួរឱ្យជឿ! ខ្ញុំមិនភ្លេចពេលដែលខ្ញុំបានឈរនៅទីនោះជាមួយឌ្រិនដា មើលបន្ទប់ក្រោមដីនៃផ្ទះថ្មីរបស់យើងដែលគេកំពុងជីក។ បន្ទប់ក្រោមដីរបស់យើងធំជាងផ្ទះចម្ការដ៏តូចរបស់យើង ដែលយើងកំពុងរស់នៅទៅទៀត។ យើងទាំងពីរនាក់ឈរនៅទីនោះទាំងទឹកភ្នែកស្រក់ចុះនៅលើមុខ។ ប្រាំបួនឆ្នាំហើយ ដែលយើងបានជួបការរងទុក្ខលំបាក។ ដោយដឹងថាអ្វីៗនឹងមិនលំបាកដូចពេលមុនទៀតទេ។ យើងបានរកឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយតលូវនេះយើងបានដឹងពីមូលហេតុដែលគេហៅថាដំណឹងល្អតាមរយៈព្យាការីអេសាយហើយ។

> *ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់សណ្ឋិតលើខ្ញុំ ដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ជួយថែទាំអ្នកដែលបាក់ទឹកចិត្តប្រកាសប្រាប់ជនជាប់ជាឈ្លើយថាពួកគេនឹងរួចខ្លួនហើយប្រាប់អ្នកជាប់ឃុំឃាំងថាពួកគេនឹងមានសេរីភាព។*
>
> — អេសាយ ៦១:១

និយាយឱ្យត្រង់ទៅ ឌ្រិនដា និងខ្ញុំបានលោតអោបគ្នាដោយក្ដីរីករាយម្ដងហើយម្ដងទៀត ព្រោះរឿងដ៏មិនគួរឱ្យជឿបែបនេះកំពុងតែកើតឡើង។ ការរួចផុតពីបំណុលទាំងស្រុង ដែលធ្លាប់ជាសុបិនដែលមិនអាចទៅរួចសម្រាប់ពួកយើង ប៉ុន្តែឥលូវនេះ វាក្លាយជាការពិតហើយ!

សូមស្ដាប់ ខ្ញុំដូចជាមិនពូកែអីទេ! អ្នកបានឃើញកំណត់ត្រារបស់ខ្ញុំ។ ខ្ញុំបានសាកល្បងវិធីរបស់ខ្ញុំអស់ជាច្រើនឆ្នាំ ហើយធ្វើការយ៉ាងលំបាកដោយគ្មានបានផលអ្វី ក្រៅពីការឈឺចិត្ត និងភាពតានតឹងចិត្ត។ ខ្ញុំកំពុងរៀនពីរបៀបធ្វើឱ្យជីវិតរបស់ខ្ញុំដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ហើយវាកំពុងមានដំណើរការល្អ។ នេះហើយជាមូលហេតុដែលអ្នកកំពុងអានសៀវភៅនេះ ដើម្បីស្វែងយល់ពីអ្វីដែលខ្ញុំបានរកឃើញ ហើយអ្នកនឹងទទួលបានការយល់ដឹង។ ប៉ុន្តែជាដំបូងអ្នកត្រូវតែដឹងថា ខ្ញុំបានចូលទៅក្នុងប្រព័ន្ធថ្មីមួយ គឺព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបរស់នៅថ្មីទាំងស្រុង។ នេះជាចម្លើយសម្រាប់អ្នកផងដែរ។ នេះគឺជាចម្លើយដែលអ្នកត្រូវការ។ នេះជាដំណឹងល្អដែលអ្នកទន្ទឹងរង់ចាំ។ ខ្ញុំដឹង ខ្ញុំដឹងថាក្រុមជំនុំរបស់អ្នកមិនបានបង្រៀនអ្នកអំពីរឿងនេះទេ។ ពិតមែនហើយ ក្នុងសៀវភៅរបស់ខ្ញុំក៏មិនបានបង្រៀនដែរ ប៉ុន្តែគ្រប់យ៉ាងគឺត្រឹមត្រូវ ព្រោះវាមាននៅក្នុងព្រះគម្ពីរ។

## ព្រះជាម្ចាស់តែងតែល្អជានិច្ច

ដូច្នេះ សូមអនុញ្ញាតឱ្យខ្ញុំប្រាប់អ្នកអំពីចំណុចគន្លឹះដ៏សំខាន់មួយ ដើម្បីយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ សូមបោះបង់ចោលសាសនាទៅ! រឿងនេះមិនមែនជាបញ្ហាសាសនាទេ។ រឿងនេះគឺនិយាយអំពីព្រះជាម្ចាស់ អ្វីដែលទ្រង់ចង់ឱ្យអ្នកទទួលបាន និងរបៀបដែលព្រះជាម្ចាស់បានបង់ថ្លៃតាមរយៈព្រះយេស៊ូ ដើម្បីផ្ដល់ឱ្យអ្នកនូវព្រះរាជ្យរបស់ទ្រង់។ ដូច្នេះ តោះយើងចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយស្វែងយល់ពីរបៀបដែលវាមានដំណើរការ។

ពេលដែលគ្រិនដា និងខ្ញុំចាប់ផ្ដើមឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការក្នុងជីវិតរបស់យើងជាច្រើនដង យើងមានការភ្ញាក់ផ្អើលចំពោះអ្វីដែលយើងបានឃើញ។ យើងបានដឹងថាអ្នកជឿភាគច្រើនមិនដឹងពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការទេ។

ជាឧទាហរណ៍ ខ្ញុំទើបតែអានព័ត៌មានដែលនិយាយអំពីក្មេងអាយុប្រាំពីរឆ្នាំដែលបានស្លាប់នៅលើតុវះកាត់ អំឡុងពេលការវះកាត់យកសាច់ដុះក្នុងបំពង់ករបស់នាង។ ទោះបីជាការវះកាត់នោះវាសាមញ្ញពិតមែន ហើយជាធម្មតាវាមានសុវត្ថិភាពខ្លាំងក៏ដោយ ប៉ុន្តែបេះដូងរបស់នាងបានឈប់លោតអំឡុងពេលនៃការវះកាត់នោះ ហើយនេះជាលទ្ធផលដ៏សោកសៅបំផុត។ ខ្ញុំគិតថាយើងអាចដកដង្ហើមធំបន្តិច ពេលបានឮរឿងមួយនេះ។ ទោះជាយ៉ាងណាក៏ដោយ នេះជាសោកនាដកម្មដ៏ក្រៀមក្រំ មានផ្នែកដែលខ្លោចផ្សាមួយទៀតនៃរឿងនេះដែលអាចប៉ះពាល់ដល់គ្រួសារនេះអស់មួយជីវិត។ ខ្ញុំសូមដកស្រង់នូវអ្វីដែលឪពុករបស់ក្មេងដែលស្លាប់នោះបាននិយាយ ទៅកាន់អ្នកយកព័ត៌មាន ហើយខ្ញុំយកការដកស្រង់នោះដាក់នៅទីនេះ។

> «អ្នកមិនអាចយល់ពីមូលហេតុដែលរឿងទាំងនេះបានកើតឡើងទេ ប៉ុន្តែយើងដឹងថាវាជាផែនការរបស់ព្រះជាម្ចាស់។ ហើយការដឹងយ៉ាងដូច្នេះ គឺជាអ្វីតែមួយគត់ ដែលធ្វើឱ្យយើងអាចមានអារម្មណ៍ធូរស្បើយបាន ពីព្រោះយើងដឹងថាវាជាកិច្ចការរបស់ទ្រង់»។[3]

[3] https://nypost.com/2020/02/26/7-year-old-south-carolina-girl-dies-during-tonsillectomy

ខ្ញុំសូមដកស្រង់ពាក្យពេចន៍របស់លោក អើរ៉ុន រ៉ូតជើ (Aaron Rodgers) ដែលជាខ្សែការពាររបស់ក្រុមបាល់អោប Green Bay Packers ដែលត្រូវបានចុះផ្សាយនៅក្នុងទស្សនាវដ្ដី *People* នៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០២០។[4]

> លោករ៉ូតជើបានពន្យល់ថា គាត់បានឆ្ងល់អំពីសាសនាតាំងពីក្មេងមកម្ល៉េះ ហើយចាប់តាំងពីពេលនោះមក គាត់ជាប់ទាក់ទងជាមួយ « វិញ្ញាណបែបផ្សេងៗ» ពេលគាត់កាន់តែកើនវ័យឡើង។ «មនុស្សភាគច្រើនដែលខ្ញុំស្គាល់ គិតថាក្រុមជំនុំគ្រាន់តែជាកន្លែង... ដែលអ្នកត្រូវទៅ»។ គាត់ក៏បាននិយាយទៀតថា «ខ្ញុំមិនដឹងថា អ្នកអាចជឿលើព្រះជាម្ចាស់បានដោយរបៀបណាទេ ដែលទ្រង់ចង់កាត់ទោសមនុស្សភាគច្រើននៅលើភពផែនដីនេះនៅក្នុងបឹងភ្លើង។ តើព្រះប្រភេទអីដែលមានសេចក្ដីស្រលាញ់ ដែលឆាប់ក្រោធខឹង មានវត្តមានគ្រប់ទីកន្លែង អាចជ្រាបដឹងរឿងរ៉ាវគ្រប់យ៉ាង ដែលចង់កាត់ទោសស្នាព្រះហស្ដដ៏អស្ចារ្យរបស់ទ្រង់ទៅក្នុងបឹងភ្លើងនៅថ្ងៃចុងក្រោយនោះ?»

ទាំងនេះជាមតិដែលមិនត្រឹមត្រូវទេ! ប៉ុន្តែប្រសិនបើនេះជាអ្វីដែលពួកគេមានជំនឿអំពីព្រះជាម្ចាស់នោះ អ្នកត្រូវតែយល់ស្របជាមួយពួកគេ ថាអ្នកណាអាចទុកចិត្តព្រះជាម្ចាស់ ឬមានបំណងចង់បម្រើព្រះជាម្ចាស់ដែលបានដកយកកូនស្រីអាយុប្រាំពីរឆ្នាំរបស់ពួកគេទៅ? គ្មាននរណាម្នាក់អាចទុកចិត្ត ឬមានបំណងចង់បម្រើទេ! ហើយតើនរណាចង់បម្រើព្រះជាម្ចាស់ដែល «ចង់» កាត់ទោសមនុស្សភាគច្រើននៅភពផែនដីនេះនៅក្នុងស្ថាននរក?! គ្មាននរណាម្នាក់ទេ! ប៉ុន្តែនេះជាអ្វីដែលគ្រិស្តបរិស័ទភាគច្រើនជឿ។ អ្នកអាចធ្លាប់ឮវាពេញមួយជីវិតរបស់អ្នកទៅហើយ៖ «ព្រះជាម្ចាស់បានអនុញ្ញាតវាឱ្យកើតឡើង» «ព្រះជាម្ចាស់បានធ្វើវា» «វាគឺជាផែនការរបស់ព្រះជាម្ចាស់» «វាដល់ពេលដែលពួកគេត្រូវទៅហើយ» និងមានការថ្លែងបែបនេះច្រើនទៀត។ តាមពិតទៅ ខ្ញុំ

[4] https://people.com/sports/aaron-rodgers-opens-up-about-religion-to-danica-patrick-i-dont-know-how-you-can-believe-in-a-god

ហ៊ានភ្នាល់ថា អ្នកប្រហែលជាគិតបែបនេះដែរ។ ដូច្នេះ ខ្ញុំសូមនិយាយត្រង់ៗតែម្តង ប្រសិនបើអ្នកពិតជាជឿថាព្រះជាម្ចាស់មានចេតនាសម្លាប់កូនក្មេង ឬធ្វើឱ្យនរណាម្នាក់មានជំងឺមហារីកនោះ យើងត្រូវតែនិយាយគ្នាឱ្យបានម៉ត់ចត់អំពីរឿងនេះ។ ខ្ញុំសូមនិយាយបែបនេះវិញ៖

## អ្នកនឹងមិនជឿនរណាដែលអ្នកមិនទុកចិត្តនោះទេ!

ប្រសិនបើអ្នកត្រូវបានបង្រៀនមិនឱ្យទុកចិត្តព្រះជាម្ចាស់ ដោយថាទ្រង់បានសម្លាប់មនុស្សស្លូតត្រង់ ហើយបើអ្នកយល់ស្របថា ទ្រង់មានអំណាចគ្រប់យ៉ាង ជាព្រះអទិករនៃសកលលោកនេះ ហើយយើងទាំងអស់គ្នាគ្រាន់តែព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីស្ថិតនៅកន្លែងមួយដ៏ល្អរបស់ទ្រង់តែប៉ុណ្ណោះ គឺគ្រប់គ្រាន់ហើយ។

នេះគឺជាអ្វីដែលមនុស្សបានជឿកាលពីអតីតកាលនៅក្នុងវប្បធម៌យុគ្គសម័យជាច្រើន។ ពួកគេបានរៀបចំតង្វាយគ្រប់ប្រភេទដើម្បីសម្រាលសេចក្តីក្រោធរបស់ព្រះជាម្ចាស់។ ពួកគេនឹងដាក់ខ្លួនពួកគេនៅក្រោមការរឹតត្បិតគ្រប់បែបយ៉ាង ទោះបីជាត្រូវទទួលរងការឈឺចាប់ជាច្រើនប្រភេទក៏ដោយ ដើម្បីបង្ហាញថាពួកគេពិតជាបានចុះចូលចំពោះទ្រង់ ហើយសង្ឃឹមថានឹងជៀសឱ្យផុតពីសេចក្តីក្រោធរបស់ទ្រង់។ ប៉ុន្តែ តើនេះពិតជាលក្ខណៈរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ មែនទេ? តើយើងត្រូវរស់នៅដោយមានការភ័យខ្លាចព្រះជាម្ចាស់ឬ? ទេ ពិតណាស់ វាមិនអ៊ីចឹងទេ។ គោលគំនិតដែលព្រះជាម្ចាស់ប្រឆាំងនឹងយើង ឬមិនគួរឱ្យទុកចិត្តគឺជាលទ្ធផលនៃការបង្រៀនដ៏អាក្រក់ដែលបានចាប់ផ្តើមនៅក្នុងសួនច្បារអេដែនជាមួយអដាំ និងអេវ៉ា។

> *ពស់ជាសត្វមួយមានកលល្បិចជាងគេ ក្នុងចំណោមសត្វព្រៃទាំងអស់ដែលព្រះជាអម្ចាស់បង្កើតមក។ វាពោលទៅកាន់ស្ត្រីថា៖ «តើព្រះជាម្ចាស់ពិតជាមានព្រះបន្ទូលថា អ្នកទាំងពីរមិនត្រូវបរិភោគផ្លែឈើទាំងប៉ុន្មាន ដែលនៅក្នុងសួនឧទ្យានមែនឬ?»។*

*ស្ត្រីពោលទៅកាន់ពស់ថា៖ «យើងអាចបរិភោគផ្លែឈើទាំងឡាយនៅក្នុងសួនឧទ្យានបាន រីឯដើមឈើដែលស្ថិតនៅកណ្ដាលសួនឧទ្យាននោះវិញ ព្រះជាម្ចាស់បានហាមថា "កុំបរិភោគផ្លែវាឡើយ ហើយក៏មិនត្រូវប៉ះពាល់ដែរ បើពុំនោះទេ អ្នកទាំងពីរនឹងស្លាប់ជាមិនខាន"»។*

*ពេលនោះ ពស់ប្រាប់ស្ត្រីថា៖ «ទេ! អ្នកទាំងពីរនឹងមិនស្លាប់ទេ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ជ្រាបថា ថ្ងៃណាអ្នកបរិភោគផ្លែឈើនោះ ភ្នែកអ្នកនឹងបានភ្លឺ ហើយអ្នកនឹងបានដូចព្រះ ដែលស្គាល់ល្អស្គាល់អាក្រក់ជាមិនខាន»។*

*ស្ត្រីមើលទៅដើមឈើ ឃើញថាមានរសជាតិឆ្ងាញ់ពិសា គួរឱ្យគយគន់ <u>ហើយថែមទាំងអាចធ្វើឱ្យមានប្រាជ្ញាទៀតផង</u> នាងក៏បេះផ្លែមកបរិភោគ ព្រមទាំងចែកឱ្យប្ដីដែលនៅជាមួយ ហើយប្ដីក៏បរិភោគដែរ។*

*— លោកុប្បត្តិ ៣:១-៦*

សាតាំងបានធ្វើឱ្យមានការសង្ស័យនៅក្នុងលក្ខណៈរបស់ព្រះជាម្ចាស់តាំងពីពេលចាប់ផ្ដើមមកម្ល៉េះ។ ចម្លែកណាស់ អេវ៉ាអាចមានប្រាជ្ញារួចទៅហើយ តែនាងប្រហែលជាមានអារម្មណ៍ថានាងខ្វះទំនាក់ទំនងជាមួយព្រះជាម្ចាស់ផ្ទាល់។ ហើយសាតាំងអាចបញ្ចុះបញ្ចូលនាងថាមានអ្វីមួយដែលនាងកំពុងបាត់បង់ ដោយសារព្រះជាម្ចាស់បានលាក់ទុកពីនាង។ អដាំ និងអេវ៉ាបានជឿការកុហកអំពីព្រះជាម្ចាស់ ហើយបានបោះបង់ចោលតំណែងពួកគេនៅក្នុងព្រះរាជ្យរបស់ទ្រង់ដើម្បីស្វែងរករាជ្យផ្សេងទៀត។ ពួកគេជឿថាការដើរតាមមារសាតាំងមានអនាគតល្អជាងការដើរតាមព្រះជាម្ចាស់។ ជាការពិតណាស់ ការសម្រេចចិត្តរបស់ពួកគេបានត្រឹមតែនាំមកនូវការឈឺចាប់ទុក្ខព្រួយ និងសេចក្ដីស្លាប់តែប៉ុណ្ណោះ។

ល្បិចកលរបស់សាតាំងមិនដែលផ្លាស់ប្ដូរទេ ហើយវាមិនគួរឱ្យភ្ញាក់ផ្អើលទេដែលគោលដៅដ៏ធំបំផុតរបស់វា គឺក្រុមជំនុំផ្ទាល់តែម្ដង។ ដោយសារក្រុមជំនុំមានសិទ្ធិអំណាចរួចហើយក្នុងការដាក់មារសាតាំងនៅក្រោមជើង និងយកឈ្នះលើវានៅគ្រប់ផ្លូវ

ទាំងអស់។ អាវុធតែមួយគត់របស់វាគឺដូចដែលវាធ្លាប់ប្រើកាលពីមុនអ៊ីចឹងដែរ គឺការបោកប្រាស់ និងការកុហក។

## អត្តចរិតរបស់ព្រះជាម្ចាស់

ប្រធានបទមួយដ៏សំខាន់បំផុតដែលយើងត្រូវដោះស្រាយមុនគេ ដែលទាក់ទងជាមួយអនាគត និងការផ្គត់ផ្គង់របស់អ្នក គឺលក្ខណៈរបស់ព្រះជាម្ចាស់។ ប្រសិនបើយើងមិនដោះស្រាយជាមួយបញ្ហានេះទេ នោះអ្នកអាចទុកសៀវភៅមួយក្បាលនេះនៅមួយកន្លែងដូចជាសៀវភៅជំនួយសម្រាប់ការមានបានដទៃទៀតដែរ។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថា អ្នកនឹងផ្តល់ពេលវេលាឱ្យខ្ញុំពន្យល់អ្នកអំពីរឿងនេះ។ ខ្ញុំសង្ឃឹមថាអ្នកពិតជាចង់មានសេរីភាពផ្នែកហិរញ្ញវត្ថុ ហើយចង់បានប្រាជ្ញា និងចំណេះដឹង។ ការបង្រៀននេះមិនមែនមកពីអ្នកកុហក ដែលជាមារសាតាំង ដែលបានបញ្ឆោតអដាំ និងអេវ៉ានោះទេ ប៉ុន្តែជាការបង្រៀនមកពីព្រះជាម្ចាស់ផ្ទាល់។

ជាដំបូង ខ្ញុំអាចយល់ពីមូលហេតុដែលអ្នកមានអារម្មណ៍ថា ព្រះជាម្ចាស់អនុញ្ញាតឱ្យមានរឿងអាក្រក់ជាច្រើនកើតឡើង។ ខ្ញុំចង់មានន័យថា ប្រសិនបើទ្រង់ជាព្រះពិតមែន នោះទ្រង់មានអំណាចអាចធ្វើអ្វីៗគ្រប់យ៉ាងបាន មិនថាអ៊ីចឹង? ដូច្នេះប្រសិនបើក្មេងអាយុប្រាំពីរឆ្នាំបានស្លាប់ ហើយព្រះជាម្ចាស់មានអំណាចអាចបញ្ឈប់ការនេះបាន តែទ្រង់បែរជាអនុញ្ញាតឱ្យការស្លាប់នេះកើតឡើងទៅវិញ។ ពិតណាស់ សេចក្តីថ្លែងទាំងនេះគ្រាន់តែជាផ្នែកមួយនៃការពិតតែប៉ុណ្ណោះទេ។ ទោះបីជាព្រះជាម្ចាស់មានអំណាចដើម្បីបញ្ឈប់វាមែនក៏ដោយ ក៏ទ្រង់មិនមានការគ្រប់គ្រងស្របច្បាប់ដើម្បីបញ្ឈប់វាដែរ។ ខ្ញុំនឹងនិយាយទាក់ទងជាមួយការគ្រប់គ្រងនេះនៅក្នុងជំពូកបន្ទាប់ ប៉ុន្តែខ្ញុំត្រូវតែដោះស្រាយជាមួយបញ្ហាដែលទាក់ទងជាមួយលក្ខណៈរបស់ព្រះជាម្ចាស់ជាមុនសិន។ បន្ទាប់មកទៀត អ្នកត្រូវប្រាកដថាអ្នកមានការយល់ដឹងដោយគ្មានការងឿងឆ្ងល់ ឬសង្ស័យថាព្រះជាម្ចាស់ល្អ ហើយព្រះបន្ទូលរបស់ទ្រង់គឺជាសេចក្តីពិត។

អ្នកប្រហែលជាឆ្ងល់ថាហេតុអ្វីបានជាវាសំខាន់ខ្លាំងម្ល៉េះ។ នៅពេលយើងបន្តអាននៅក្នុងសៀវភៅនេះ ខ្ញុំនឹងពិភាក្សាអំពីច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ មុខងាររបស់វា និងរបៀបដែលច្បាប់ទាំងនោះបានរំដោះខ្ញុំចេញពីការរស់នៅក្នុងហិរញ្ញវត្ថុដ៏អាក្រក់។ ប្រសិនបើអ្នកមិនទុកចិត្តលើស្តេច អង្គទ្រង់ផ្ទាល់ទេ នោះច្បាប់របស់ទ្រង់នឹងមិនមានន័យអ្វីសម្រាប់អ្នកទេ។

សូមចាំថា ការរកឃើញដំបូងរបស់ខ្ញុំក្នុងដំណើរនេះគឺថា ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាការគ្រប់គ្រងមួយ។ ការគ្រប់គ្រងនេះមានស្តេចមួយអង្គ ដែលបានកំណត់ច្បាប់នៃព្រះរាជ្យរបស់ទ្រង់។ ច្បាប់ទាំងនេះបានដាក់ចេញដើម្បីជាប្រយោជន៍ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងព្រះរាជ្យរបស់ទ្រង់។ ច្បាប់ទាំងនេះបានជួយការពារ និងធានាដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងព្រះរាជ្យរបស់ទ្រង់ ព្រមទាំងបំណងព្រះហឫទ័យរបស់ទ្រង់ សម្រាប់ជីវិតរស់នៅរបស់ពួកគេ។ ដើម្បីយល់ដឹងពីលក្ខណៈរបស់ស្តេច ចាំបាច់ត្រូវយល់ដឹងពីច្បាប់ជាមុនសិន។

ដូចដែលខ្ញុំបាននិយាយកាលពីមុនអីចឹង ពេលដែលខ្ញុំយល់ថាព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាការគ្រប់គ្រងមួយ ដែលមានច្បាប់ និងមានប្រយោជន៍ ដែលជាកម្មសិទ្ធិស្របច្បាប់សម្រាប់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងព្រះរាជ្យរបស់ទ្រង់ នោះខ្ញុំបានក្លាយជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ។ ដូច្នេះខ្ញុំបានដឹងថានៅពីក្រោយគ្រប់ទាំងសកម្មភាពនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ មានច្បាប់ខាងវិញ្ញាណដែលត្រូវបានបង្កើតឡើង។ ដូច្នេះខ្ញុំមានសង្ឃឹម។ ខ្ញុំអាចរៀនអំពីច្បាប់នោះបាន! អ្នកណាក៏អាចរៀនច្បាប់នោះបានដែរ! នេះជាអ្វីដែល ឃីត (Keith) និង ឃីធី (Kathy) បានរកឃើញ។

## រយៈពេលបួនឆ្នាំបានផ្លាស់ប្តូរជីវិតពួកគេ

ឃីត និងឃីធី គ្រាន់តែទទួលបានប្រាក់ខែពីការងារដ៏សាមញ្ញមួយ និងរស់នៅជីវិតយ៉ាងសាមញ្ញ។ ពួកគេទើបតែទិញផ្ទះថ្មី ពេលដែលឃីតបានបាត់បង់ការងារ។

ទោះជាយ៉ាងណាក៏ដោយ យីតបានឃើញនៅក្នុងកម្មវិធីទូរទស្សន៍ *ការដោះស្រាយរឿងរ៉ាវពាក់ព័ន្ធនឹងលុយកាក់*របស់យើងកាលពីជាងមួយឆ្នាំមុននេះ ហើយបានចំណាយពេលសិក្សា និងជញ្ជឹងគិតលើគំនិតមួយចំនួនរបស់ខ្ញុំ ដោយសិក្សាអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសិទ្ធិស្របច្បាប់របស់គាត់ក្នុងនាមជាពលរដ្ឋម្នាក់។

ពេលគាត់បានបាត់បង់ការងារ គាត់បានអធិស្ឋានអំពីរឿងនេះ ហើយសម្រេចចិត្តថាជំនួសឱ្យការស្វែងរកការងារធ្វើ គាត់ចង់ចាប់ផ្តើមក្រុមហ៊ុនដឹកទំនិញផ្ទាល់ខ្លួនរបស់គាត់វិញ។ គាត់បានទទួលស្គាល់ថា គាត់ពិតជាមិនចេះរបៀបធ្វើអាជីវកម្មនេះទេ ប៉ុន្តែគាត់មានអារម្មណ៍ថាគាត់អាចរៀនពីរបៀបធ្វើអាជីវកម្មនេះបាន។ គាត់បានចាប់ផ្តើមធ្វើអាជីវកម្មដឹកជញ្ជូនតាមរថយន្តដឹកទំនិញរបស់គាត់ ដោយមានរថយន្តដឹកទំនិញមួយ ហើយគាត់ដឹកជញ្ជូនរថយន្ត និងអ្វីផ្សេងទៀតឱ្យតែគាត់អាចដឹកបាន។ នៅពេលដែលយីត និង យីធីកំពុងតែបន្តរៀននោះ ក៏មានឱកាសថ្មីមួយក្នុងការចាប់ផ្តើមក្រុមហ៊ុនដឹកជញ្ជូនថ្នាក់ជាតិ។ នេះគឺជាជំហានដ៏ធំមួយសម្រាប់យីត ហើយក្រុមហ៊ុននោះតម្រូវឱ្យគាត់ធ្វើជាម្ចាស់ពាក់កណ្តាល និងរៀនច្បាប់ជាច្រើនទៀតទាក់ទងនឹងអាជីវកម្មដឹកជញ្ជូនតាមរថយន្តនេះ ហើយគាត់បានយកឱកាសនោះ និងទុកចិត្តថាព្រះជាម្ចាស់កំពុងដឹកនាំគាត់។

ពេលនោះ ក្រុមហ៊ុនរបស់គាត់បានបង្កើតឡើង។ ឥលូវនេះគាត់មានរថយន្តដឹកទំនិញចំនួនប្រាំបីដែលគាត់ជាម្ចាស់ពាក់កណ្តាល ហើយធ្វើការពេញពេលជារៀងរាល់ថ្ងៃ។ យីតបានប្រាប់ខ្ញុំអំពីប្រតិបត្តិការការងាររបស់គាត់ ដោយគាត់អាចរកលុយបានប្រមាណជា ១.៥០០ ដុល្លារ ក្នុងមួយសប្តាហ៍។ នៅឆ្នាំដំបូងនៃការធ្វើជាម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនផ្ទាល់ខ្លួននេះ យីត បាននិយាយថាគាត់រកបានជិត៥.០០០

**បើមានអ្វីមួយ ឬនរណាម្នាក់ប្រាប់អ្នកថាព្រះជាម្ចាស់គឺមិនល្អទេ នោះពួកគេកំពុងតែប្រាប់អ្នកអំពីការកុហកហើយ!**

ដុល្លារក្នុងមួយសប្តាហ៍។ នៅឆ្នាំទីពីរ ឃីតរកបានប្រាក់ចំណូលកើនឡើងដល់ជាង ១៥.០០០ដុល្លារក្នុងមួយសប្តាហ៍។ នៅឆ្នាំបន្ទាប់ប្រាក់ចំនូលរបស់គាត់បានឡើងដល់ ២៥.០០០ដុល្លារក្នុងមួយសប្តាហ៍ ហើយនៅឆ្នាំបន្ទាប់ទៀត វាកើតឡើងដល់ជាង ៣៨.០០០ដុល្លារក្នុងមួយសប្តាហ៍។ លោកឃីតរកបានប្រាក់ចាប់ពី៧៨.០០០ដុល្លារក្នុងមួយឆ្នាំ រហូតកើនដល់ពីរលានដុល្លារក្នុងមួយឆ្នាំ ក្នុងរយៈពេលតែបួនឆ្នាំ!

ខ្ញុំបានទទួលសារពីឃីត ខណៈពេលដែលខ្ញុំកំពុងសរសេរសៀវភៅជំពូកនេះ។ គាត់បាននិយាយថា គាត់ទើបតែបានជួលអ្នកបើករថយន្តបួននាក់បន្ថែមទៀត ហើយលំហូរសាច់ប្រាក់របស់គាត់ឥលូវមានចំនួន ៧០.០០០ ដុល្លារក្នុងមួយសប្តាហ៍។ គាត់ចាប់ផ្តើមទទួលបានប្រាក់ចំណូលពី ៧៨.០០០ ដុល្លារក្នុងមួយឆ្នាំ រហូតដល់ ៧០.០០០ ដុល្លារក្នុងមួយសប្តាហ៍ ក្នុងរយៈពេលតែ៥ឆ្នាំ! វាធ្វើឱ្យខ្ញុំចាប់អារម្មណ៍មែនទែន! ឃីត និងឃីធី កំពុងរំពឹងថានឹងមានរឿងអស្ចារ្យជាងនេះទៅទៀតកើតឡើង ខណៈពេលឥលូវនេះពួកគេកំពុងរៀបចំផែនការបង្កើតក្រុមហ៊ុនពីរបន្ថែមទៀត។

ប្រសិនបើអ្នកសួរឃីត និងឃីធីពីរបៀបដែលពួកគេបានធ្វើដំណើរការអាជីវកម្មរបស់ពួកគេ នោះពួកគេនឹងផ្តល់ក្រេឌីតគ្រប់យ៉ាងគឺមកពីការរៀនអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការ។

រឿងដំបូងដែលឃីត និងឃីធីនឹងប្រាប់អ្នកនោះគឺពួកគេបានបំភ្លេចរឿងសាសនាឥតប្រយោជន៍ជាច្រើន ដែលពួកគេត្រូវបានបង្រៀនពេញមួយជីវិតរបស់ពួកគេអំពីព្រះជាម្ចាស់ និងរបៀបដែលទ្រង់ធ្វើការ។ ចំណុចដ៏សំខាន់មួយដែលពួកគេត្រូវផ្តោតការយកចិត្តទុកដាក់លើនោះគឺ ព្រះជាម្ចាស់ល្អ ទ្រង់ល្អជានិច្ច ហើយព្រះអង្គមិនដែលកុហកទេ។ បើមានអ្វីមួយ ឬនរណាម្នាក់ប្រាប់អ្នកថាព្រះជាម្ចាស់គឺមិនល្អទេ នោះពួកគេកំពុងតែប្រាប់អ្នកអំពីការកុហកហើយ!

*បងប្អូនជាទីស្រលាញ់អើយ សូមកុំយល់ច្រឡំឡើយ។ គ្រប់អំណោយដ៏ល្អវិសេស និងអ្វីៗទាំងប៉ុន្មានដ៏គ្រប់លក្ខណៈដែលយើងបានទទួល សុទ្ធតែមកពីស្ថានលើទាំងអស់ គឺមកពីព្រះបិតាដែលបង្កើតពន្លឺ។ ព្រះអង្គមិនចេះប្រែក្រឡាស់ទេ ហើយនៅក្នុងព្រះអង្គ សូម្បីតែស្រមោលនៃការប្រែប្រួលក៏គ្មានផង។*

— យ៉ាកុប ១:១៦-១៧

ទីពីរ ពួកគេនឹងប្រាប់ថាពួកគេបានរៀនអំពីរបៀបធ្វើជាអ្នកឱ្យនៅក្នុងរបៀបថ្មីមួយទាំងស្រុង។ ការជួយគាំទ្រកិច្ចការរបស់ព្រះជាម្ចាស់ជាមួយនឹងប្រាក់ដែលពួកគេទទួលបានគឺជាចំណុចគន្លឹះដ៏សំខាន់មួយនៅក្នុងភាពជោគជ័យរបស់ពួកគេ។

នៅក្នុងព្រះគម្ពីរចែងយ៉ាងច្បាស់។ ការបន្ទោសព្រះជាម្ចាស់ពេលដែលមានរឿងអាក្រក់បានកើតឡើងចំពោះមនុស្ស គឺជារឿងមួយដែលមិនត្រឹមត្រូវទាល់តែសោះ។ ព្រះគម្ពីរចែងថា សាតាំងគឺជាម្នាក់ដែលមកដើម្បីតែសម្លាប់ លួចប្លន់ និងបំផ្លាញតែប៉ុណ្ណោះ។

*ចោរវាមក គិតតែពីលួចប្លន់ គិតតែពីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមក ដើម្បីឱ្យមនុស្សលោកមានជីវិត ហើយឱ្យគេមានជីវិតពេញបរិបូរ»។*

— យ៉ូហាន ១០:១០

សូមកត់ចំណាំអ្វីដែលព្រះយេស៊ូមានបន្ទូលបន្ទាប់ពីឃ្លាទីមួយ «ឯខ្ញុំវិញ ខ្ញុំមក ដើម្បីឱ្យមនុស្សលោកមានជីវិត ហើយឱ្យគេមានជីវិតពេញបរិបូរ» ឬច្បាប់ខ្លះអាចបកប្រែថា «ជីវិតកាន់តែពេញបរិបូរ»។ ព្រះជាម្ចាស់មិនមែនជាខ្មាំងសត្រូវរបស់អ្នកទេ។ ប៉ុន្តែប្រសិនបើអ្នកគិតថាទ្រង់ជាខ្មាំងសត្រូវ ដូច្នេះយោងតាមយ៉ាកុប ១:១៦ អ្នកត្រូវបានបញ្ឆោតដោយនរណាម្នាក់ហើយ។ អ្នកត្រូវសួរខ្លួនឯងថា អ្នកណាប្រាប់អ្នកថាព្រះជាម្ចាស់កុហក។ តើអ្នកណាប្រាប់អ្នកថាព្រះជាម្ចាស់បានសម្លាប់ក្មេងអាយុប្រាំពីរឆ្នាំនោះ? តើនរណាប្រាប់អ្នកថា ពេលខ្លះព្រះជាម្ចាស់ព្យាបាលឱ្យជាសះស្បើយ ហើយ

ពេលខ្លះទៀតទ្រង់ជ្រើសរើសមិនព្យាបាលឱ្យជាសះស្បើយ? ខ្ញុំប្រហែលជាអាចទាយបានថា មានគ្រូអធិប្បាយមួយចំនួនក៏មិនដឹងពីរឿងនេះច្បាស់ដែរ។ ប៉ុន្តែមានឃ្លាមួយដែលអ្នកត្រូវប្រកាន់ខ្ជាប់ ប្រសិនបើអ្នកចង់ទទួលបានការព្យាបាលឱ្យជាសះស្បើយពីព្រះជាម្ចាស់។ គឺថាព្រះជាម្ចាស់មិនកុហកទេ! តាមពិត ព្រះគម្ពីរចែងថា វាមិនអាចទៅរួចទេ ដែលថាព្រះជាម្ចាស់កុហកនោះ (ហេព្រើ ៦:១៨)។

ជាថ្មីម្តងទៀត ហេតុផលដែលមនុស្សជឿថាព្រះជាម្ចាស់ល្អជានិច្ចនោះ ដោយសារពួកគេមិនបានយល់អំពីប្រព័ន្ធស្របច្បាប់របស់ព្រះរាជ្យរបស់ព្រះជាម្ចាស់ នៅក្នុងអាណាចក្រផែនដីនេះ។ ដូចដែលខ្ញុំបានលើកឡើងពីខាងដើមអ៊ីចឹង យើងនឹងសិក្សាឱ្យស៊ីជម្រៅអំពីចំណុចនេះនៅជំពូកបន្ទាប់ វានឹងផ្តល់ចម្លើយយ៉ាងពេញលេញចំពោះសំណួររបស់អ្នក។ ប៉ុន្តែបើអ្នកចង់ដឹងពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការ នោះអ្នកត្រូវដឹងថាព្រះជាម្ចាស់ទ្រង់ល្អ ហើយទ្រង់មិនដែលកុហកទេ។

## ភាពស្ថិតស្ថេរនៃព្រះរាជ្យរបស់ព្រះជាម្ចាស់

គិតពីពេលដែលខ្ញុំរៀននៅវិទ្យាល័យ ខ្ញុំបានរៀនមេរៀនមួយដែលខ្ញុំគិតថាអាចអនុវត្តបាននៅទីនេះ។ គេបានបង្រៀនយើងថា ពេលអ្នកដោះស្រាយជាមួយសារធាតុរូបសាស្ត្រ មានលក្ខណៈមួយចំនួនដែលជាក់លាក់មិនដែលប្រែប្រួល និងស្ថិតស្ថេរហូត។ អ្នកបានដឹងពីវារួចហើយ! ច្បាប់ទាំងនេះត្រូវបានគេហៅថា ស្ថេរភាពនៅក្នុងរូបវិទ្យា។ ឧទាហរណ៍ សីតុណ្ហភាពដែលធ្វើឱ្យទឹកកក គឺ៣២អង្សារ។ នេះគឺជាស្ថេរភាព វាមិនដែរផ្លាស់ប្តូរទេ។ ដូចគ្នានេះដែរ ការដែលព្រះជាម្ចាស់ទ្រង់ល្អគឺស្ថិតស្ថេរជានិច្ច។ ដូច្នេះទាក់ទងនឹងទឹក អ្នកនឹងប្រើប្រាស់ស្ថេរភាពនៃសីតុណ្ហភាពកករបស់ទឹក នៅក្នុងសមីការទាំងអស់របស់អ្នកដែលទាក់ទងនឹងទឹក។

វាអាចអនុវត្តដូចគ្នាចំពោះការយល់ដឹងអំពីលក្ខណៈរបស់ព្រះជាម្ចាស់ដែរ។ ប្រសិនបើអ្នកដឹងថាព្រះជាម្ចាស់ទ្រង់ល្អ ហើយមិនដែលផ្លាស់ប្តូរ នោះអ្នកក៏អាចកាត់

ស្រាយបទគម្ពីរមួយតាមរបៀបរួមផងដែរ។ ជាឧទាហរណ៍ សូមក្រឡេកមើល និក្ខមនំ ៤:១១-១២។

> *ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកថា៖ «តើនរណាធ្វើឱ្យមនុស្សមានមាត់? តើនរណាធ្វើឱ្យមនុស្សទៅជា គ ឬថ្លង់ មើលឃើញ ឬខ្វាក់? តើមិនមែនយើងទេឬអី?*
>
> — និក្ខមនំ ៤:១១-១២

បើមើលមួយភ្លែតទៅ ខគម្ពីរនេះហាក់បីដូចជាបានចែងថា ព្រះជាម្ចាស់មានបំណងធ្វើឱ្យមនុស្សខ្វាក់ និងស្តាប់មិនឮអីចឹង។ ប៉ុន្តែយើងនឹកចាំអំពីគោលការណ៍នៃការមិនប្រែប្រួលគឺ ព្រះជាម្ចាស់តែងតែល្អជានិច្ច។ តោះសូមទៅមើលក្នុងបទគម្ពីរតែមួយ តែនៅក្នុងការបកប្រែផ្សេងវិញ។

> *នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងលោកថា តើអ្នកណាបានបង្កើតមាត់មនុស្ស តើអ្នកណាដែលធ្វើឱ្យគ ឬឱ្យថ្លង់ ឱ្យភ្លឺ ឬឱ្យខ្វាក់នោះ បើមិនមែនអញជាព្រះយេហូវ៉ាប៉ុណ្ណោះទេ។*
>
> — និក្ខមនំ ៤:១១ (ពគប)

នៅក្នុងបរិបទនៃបទគម្ពីរនេះ ព្រះជាម្ចាស់បានត្រាស់ហៅលោកម៉ូសេឱ្យទៅជួបរាស្ត្ររបស់ទ្រង់ដែលជាជនជាតិហេប្រឺ ហើយប្រាប់ពួកគេថាព្រះជាម្ចាស់បានត្រាស់ហៅគាត់ឱ្យទៅជួបស្តេចផារ៉ោនដើម្បីទាមទារឱ្យជនជាតិហេប្រឺមានសេរីភាពឡើងវិញ។ ប៉ុន្តែលោកម៉ូសេនិយាយទៅកាន់ព្រះជាម្ចាស់វិញថា៖ «ចុះបើពួកហេព្រើរទាំងនោះមិនជឿថាទ្រង់បានបង្ហាញអង្គទ្រង់ឱ្យទូលបង្គំឃើញនោះយ៉ាងម៉េចវិញ?»។ ព្រះជាម្ចាស់បានប្រាប់គាត់ពីរបៀបមួយចំនួនដើម្បីបញ្ជាក់ដល់ពួកគេ។ ប៉ុន្តែលោកម៉ូសេបានរកលេសផ្សេងទៀតប្រាប់ព្រះអម្ចាស់។

*«ម៉ូសេទូលទៅព្រះយេហូវ៉ាថា ឱព្រះអម្ចាស់អើយ ទូលបង្គំជាអ្នកមិនសូវមានវោហាររទេ គឺតាំងតែពីដើមរៀងមក ហើយឥលូវនេះដែលទ្រង់បានមានបន្ទូលនឹងទូលបង្គំជាអ្នកបម្រើទ្រង់ នោះក៏នៅតែគ្មានដដែល ដ្បិតទូលបង្គំមានមាត់រឹង ហើយអណ្តាតក៏ជំទ្បាន់ផង»*

*នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងលោកថា «តើអ្នកណាបានបង្កើតមាត់មនុស្ស តើអ្នកណាដែលធ្វើឱ្យគ ឬឱ្យថ្លង់ ឱ្យភ្លឺ ឬឱ្យខ្វាក់នោះ បើមិនមែនអញជាព្រះយេហូវ៉ាប៉ុណ្ណោះទេ»*

— និក្ខមនំ ៤:១០-១២ (ពគប)

សូមអនុញ្ញាតឱ្យខ្ញុំបកស្រាយបន្ថែមពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលទៅកាន់លោកម៉ូសេ។ តើអ្នកណាបានបង្កើតមាត់មនុស្ស តើអ្នកណាធ្វើឱ្យពួកគេគ ឬថ្លង់ ឬភ្លឺ ឬខ្វាក់នោះ បើមិនមែនអញជាព្រះយេហូវ៉ាទេនោះ ចម្លើយនេះគឺច្បាស់ណាស់។ មាត់ត្រូវបានបង្កើតឡើងដើម្បីនិយាយ ហើយភ្នែកត្រូវបានបង្កើតឡើងដើម្បីមើល។ នេះជាអ្វីដែលព្រះជាម្ចាស់កំពុងតែព្យាយាមប្រាប់ទៅលោកម៉ូសេ ព្រះជាម្ចាស់មានបន្ទូលថា « ប្រសិនបើយើងជាអ្នកបង្កើតមាត់ នោះយើងប្រាកដជាអាចជួយអ្នកបាន!» ព្រះជាម្ចាស់កំពុងតែព្យាយាមពន្យល់លោកម៉ូសេថាគាត់អាចទុកចិត្តទ្រង់បាន ដើម្បីជួយគាត់ក្នុងការនិយាយ ពេលគាត់ទៅជួបជនជាតិហេប្រឺ។

ប៉ុន្តែបើគ្មានទស្សនៈត្រឹមត្រូវអំពីព្រះជាម្ចាស់ទេ នោះយើងអាចបកស្រាយខុសពីគោលបំណងរបស់ទ្រង់នៅទីនេះ។ ខ្ញុំគិតថា យើងទាំងអស់គ្នាបានដឹងហើយថាលោកម៉ូសេនិយាយត្រដិត។ មនុស្សភាគច្រើននិយាយថាម៉ូសេពិតជាត្រដិតមែន ប៉ុន្តែតើវាជាការពិតដែរឬទេ? អ្នកនឹងឆ្លើយតបថា «ប្រាកដណាស់។ លោកម៉ូសេផ្ទាល់បាននិយាយថា គាត់និយាយថាគាត់មិនសូវមានវោហាររទេ»។ ខ្ញុំយល់ស្របចំពោះអ្វីដែលគាត់បាននិយាយដូច្នេះ ប៉ុន្តែតើយោងទៅលើអ្វី? ប្រសិនបើម៉ូសេមិនសូវមានវោហាររទេនោះ នោះយើងត្រូវពន្យល់នៅ កិច្ចការ ៧:២២។

*លោកបានរៀនសូត្រគ្រប់អស់ទាំងចំណេះវិជ្ជា នៃសាសន៍អេស៊ីព្ទ ហើយក៏មានពាក្យសម្ដី នឹងការធ្វើយ៉ាងចំណាន។*

— កិច្ចការ ៧:២២ (ពគប)

តាមពិតទៅ យើងឃើញថាលោកម៉ូសេត្រលប់ទៅជាមនុស្សផ្សេង ពេលជួបការលំបាកក្នុងការប្រើវោហារ។ គាត់ពូកែក្នុងការនិយាយ។ ដូច្នេះ តើម៉ូសេចង់មានន័យយ៉ាងដូចម្ដេច នៅពេលគាត់និយាយថា «ឱព្រះអម្ចាស់អើយ ទូលបង្គំជាអ្នកមិនសូវមានវោហារទេ គឺតាំងតែពីដើមរៀងមក ហើយឥលូវនេះដែលទ្រង់បានមានបន្ទូលនឹងទូលបង្គំជាអ្នកបម្រើទ្រង់ នោះក៏នៅតែគ្មានដដែល ដ្បិតទូលបង្គំមានមាត់រឹង ហើយអណ្ដាតក៏ជំទ្បាន់ផង»។

ពេលដែលនិក្ខមនំជំពូក៤ និយាយថាលោកម៉ូសេនិយាយយឺត គឺចង់សំដៅលើការពិតដែលថាម៉ូសេមិនអាចនិយាយភាសាហេប្រឺបានល្អទេ។ គាត់មិនត្រូវបានចិញ្ចឹមបីបាច់ជាជនជាតិហេប្រឺឡើយ។ គាត់ត្រូវបានចិញ្ចឹមបីបាច់ជាជនជាតិអេស៊ីប ហើយនិយាយភាសាអេស៊ីបជាគោល។ ព្រះជាម្ចាស់កំពុងតែធានាដល់ម៉ូសេថា តាំងពីទ្រង់បានបង្កើតមាត់មនុស្សមក ទ្រង់នឹងជួយគាត់និយាយទៅកាន់សាសន៍ហេប្រឺ។ ប៉ុន្តែជាថ្មីម្ដងទៀត ម៉ូសេបានរកលេសផ្សេងទៀតទៅវិញ។

*លោកម៉ូសេទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមព្រះអង្គចាត់នរណាម្នាក់ទៀតឱ្យទៅចុះ!»។*

*ពេលនោះ ព្រះអម្ចាស់ទ្រង់ព្រះពិរោធទាស់នឹងលោកម៉ូសេយ៉ាងខ្លាំង ហើយមានព្រះបន្ទូលថា៖ «អ្នកមានបងប្រុសម្នាក់ឈ្មោះអើរ៉ុន ជាកូនចៅលេវី។ យើងដឹងថា គាត់ជាមនុស្សពូកែវោហារ ហើយកំពុងតែមករកជួបអ្នកទៀតផង។ កាលណាគាត់ឃើញអ្នក នោះគាត់មុខជាសប្បាយរីករាយយ៉ាងខ្លាំង។ អ្នកនឹងប្រាប់គាត់ឱ្យនិយាយជំនួសនូវសេចក្ដីដែលអ្នកត្រូវនិយាយ។ រីឯយើងវិញ*

*យើងនឹងស្ថិតនៅជាមួយអ្នកទាំងពីរ ក្នុងពេលដែលអ្នកទាំងពីរនិយាយ ហើយប្រាប់អំពីអ្វីៗដែលអ្នកទាំងពីរត្រូវធ្វើ។ គាត់នឹងនិយាយទៅកាន់ប្រជាជនជំនួសអ្នក គាត់ជាអ្នកនាំពាក្យរបស់អ្នក ហើយអ្នកប្រៀបដូចជាព្រះសម្រាប់គាត់។*

— និក្ខមនំ ៤:១០-១២

**មានសេចក្តីសន្យាជាង ៧.០០០ នៅក្នុងព្រះគម្ពីរ ដែលកំណត់សិទ្ធិស្រប ច្បាប់របស់អ្នកក្នុងនាម ជាកូនរបស់ព្រះជាម្ចាស់។**

តាមការសន្និដ្ឋាន មូលហេតុដែលលោកអើរ៉ុនចេះភាសាហេប្រឺយ៉ាងស្ទាត់ ដោយសារគាត់ត្រូវបានចិញ្ចឹមបីបាច់ជាសាសន៍ហេប្រឺ ហើយអាចនិយាយជាមួយជនជាតិហេប្រឺជំនួសម៉ូសេបាន មិនមែនបានន័យថាម៉ូសេនិយាយត្រដិតនោះទេ។

ដូច្នេះ ឥលូវនេះអ្នកបានឃើញថាការមានទស្សនៈត្រឹមត្រូវ និងមិនផ្លាស់ប្តូរចំពោះលក្ខណៈរបស់ព្រះជាម្ចាស់មានសារៈសំខាន់ប៉ុនណាហើយ។ ការយល់ដឹងថាទ្រង់តែងតែល្អអនុញ្ញាតឱ្យយើងស្វះរកការសន្មតចំពោះអត្ថន័យក្នុងអត្ថបទគម្ពីរ និងដើម្បីជីកឱ្យកាន់តែស៊ីជម្រៅដើម្បីធ្វើការបកស្រាយឱ្យបានត្រឹមត្រូវ។ ដូច្នេះជាថ្មីម្តងទៀត មូលដ្ឋានគ្រឹះនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់របស់អ្នក គឺត្រូវស្គាល់លក្ខណៈរបស់ស្តេចផ្ទាល់។ ប្រសិនបើមិនស្គាល់ពីលក្ខណៈរបស់ទ្រង់ឱ្យបានច្បាស់ទេ នោះមារសាតាំងអាចបញ្ឆោតអ្នក ដូចជាវាបានធ្វើដាក់អេវ៉ាអ៊ីចឹងដែរ វាអាចធ្វើឱ្យអ្នកជឿថាព្រះជាម្ចាស់មិនបានប្រាប់ការពិតទាំងអស់ដល់អ្នក ឬទ្រង់ធ្វើអាក្រក់ជាងនេះទៅទៀត គឺទ្រង់បានកុហកអ្នកហើយ។

## ការយល់ដឹងអំពីសេចក្តីសន្យារបស់ព្រះជាម្ចាស់

មានសេចក្តីសន្យាជាង៧.០០០នៅក្នុងព្រះគម្ពីរដែលកំណត់សិទ្ធិស្របច្បាប់របស់អ្នកក្នុងនាមជាកូនរបស់ព្រះជាម្ចាស់។ សេចក្តីសន្យានីមួយៗត្រូវបានផ្តល់ឱ្យអ្នក

ដោយព្រះជាម្ចាស់ដោយផ្ទាល់ ហើយអ្នកអាចទុកចិត្តបាន។ តើអ្នកពិតជាអាចទុកចិត្តបានមែនឬ? ប្រសិនបើមានការសង្ស័យជាមួយភាពល្អរបស់ព្រះជាម្ចាស់ នោះក៏អាចមានការសង្ស័យជាមួយសេចក្តីសន្យារបស់ទ្រង់ផងដែរ។

សូមអនុញ្ញាតឱ្យខ្ញុំផ្តល់ឧទាហរណ៍មួយដល់អ្នក។ ឧបមាថា ខ្ញុំបានឱ្យមូលប្បទានបត្រ ១.០០០ដុល្លារដល់អ្នក។ អ្នកនឹងអរគុណខ្ញុំ ហើយក្នុងគំនិតអ្នក អ្នកនឹងមានគំនិតថា ខ្ញុំមាន ១.០០០ដុល្លារ។ អ្នកនឹងធ្វើដូចជាអ្នកមានប្រាក់១.០០០ដុល្លារពិតមែន ហើយនិយាយដូចជាអ្នកមានលុយ ១.០០០ដុល្លារដែរ ព្រមទាំងអរគុណខ្ញុំម្តងទៀតសម្រាប់លុយ១.០០០ដុល្លារនោះ។ ប៉ុន្តែការពិតនៃបញ្ហាគឺថា អ្នកមិនទាន់មានប្រាក់ ១.០០០ដុល្លារនៅឡើយទេ អ្នកមានតែលិខិតសន្យាតែប៉ុណ្ណោះ។ មូលប្បទានបត្រគឺគ្រាន់តែជាការសន្យាដែលខ្ញុំបានផ្តល់ឱ្យអ្នកដោយបញ្ជាក់ថា អ្នកមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានប្រាក់ ១.០០០ដុល្លារពីគណនីធនាគាររបស់ខ្ញុំ។ អ្នកត្រូវទៅដកសាច់ប្រាក់ពីមូលប្បទានបត្រនោះ ដើម្បីទទួលបានលុយពិតប្រាកដមែន! ប៉ុន្តែដោយសារអ្នកបានដឹងពីបំណងរបស់ខ្ញុំ ដូចដែលខ្ញុំបានយល់ព្រមឱ្យអ្នកនូវមូលប្បទានបត្រនេះ ហើយខ្ញុំបានចុះហត្ថលេខាលើវា ហើយដោយសារតែអ្នកជឿជាក់ថាខ្ញុំមានប្រាក់ ១.០០០ដុល្លារពិតមែន នោះអ្នកនឹងនិយាយថាអ្នកមានប្រាក់១.០០០ដុល្លារ ពេលអ្នកទទួលបានសេចក្តីសន្យាមួយនេះពីខ្ញុំ។

ព្រះជាម្ចាស់ពិតជាមានភាពស្មោះត្រង់ចំពោះសេចក្តីសន្យាច្រើនជាងខ្ញុំទៅទៀត។ ព្រះបន្ទូលរបស់ទ្រង់មិនកុហកទេ។ ទ្រង់ផ្តល់ឱ្យយើងនូវភាពអស្ចារ្យ និងសេចក្តីសន្យាដ៏មានតម្លៃរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់ប្រទានឱ្យអ្នកនូវសេចក្តីសន្យារបស់ទ្រង់ នោះទ្រង់នឹងសម្រេចតាមយ៉ាងល្អប្រសើរពិតប្រាកដមែន! រឿងតែមួយគត់ដែលសាតាំងអាចធ្វើ ដើម្បីបញ្ឈប់សេចក្តីសន្យាតាំងពីដើមនោះ គឺធ្វើឱ្យអ្នកមានការសង្ស័យចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាមូលហេតុសំខាន់មួយដែលអ្នកត្រូវដឹងថា ព្រះជាម្ចាស់ទ្រង់ល្អ ហើយទ្រង់មិនចេះកុហកទេ។

សូមអនុញ្ញាតឱ្យខ្ញុំផ្តល់ឧទាហរណ៍មួយទៀតដល់អ្នក។ ខ្ញុំបានឮពីមនុស្សជាច្រើនថាការអស្ចារ្យលែងមានទៀតហើយ ហើយព្រះជាម្ចាស់នឹងមិនធ្វើដូចអ្វីដែលព្រះយេស៊ូបានធ្វើ ពេលទ្រង់បានរស់នៅលើផែនដីនេះទេ។ ខ្ញុំធំឡើងនៅក្នុងក្រុមជំនុំបែបប្រពៃណីមួយ ហើយនិយាយដោយស្មោះត្រង់ទៅ ខ្ញុំមិនដែលឃើញអំណាចរបស់ព្រះជាម្ចាស់បានសម្តែងឡើងទេ យ៉ាងហោចណាស់បើខ្ញុំអាចជួបបានម្តងក៏អស់ចិត្តដែរ។ ដូច្នេះដោយសារតែខ្ញុំមិនបានឃើញមនុស្សជាសះស្បើយ តើមានន័យថាព្រះជាម្ចាស់ឈប់ធ្វើការប្រោសឱ្យជាទៀតហើយមែនទេ? ដំណោះស្រាយគឺថា យើងមិនអាចវាយតម្លៃតាមបទពិសោធរបស់យើងបានទេ។ យើងត្រូវស្វែងយល់ពីអ្វីដែលព្រះគម្ពីរបានចែង អ្វីដែលច្បាប់របស់ព្រះជាម្ចាស់និយាយអំពីការប្រោសឱ្យជា។

> *បងប្អូនបានជ្រាបថា ព្រះជាម្ចាស់**បានចាក់**ព្រះវិញ្ញាណដ៏វិសុទ្ធ និងឫទ្ធានុភាពអភិសេកព្រះយេស៊ូ ជាអ្នកភូមិណាសារ៉ែត។ បងប្អូនក៏ជ្រាបដែរថាព្រះយេស៊ូបានយាងពីកន្លែងមួយទៅកន្លែងមួយ ទាំងប្រព្រឹត្តអំពើល្អ និងប្រោសអស់អ្នកដែលត្រូវមារសង្កត់សង្កិនឱ្យជា **ដ្បិតព្រះជាម្ចាស់គង់ជាមួយព្រះអង្គ។***
>
> — កិច្ចការ ១០:៣៨

ដូចជាយើងបានឃើញហើយថា ការប្រោសឱ្យជាគឺជាកូនសោដ៏សំខាន់មួយនៃព័ន្ធកិច្ចរបស់ព្រះយេស៊ូគ្រិស្ត។

នៅក្នុងអត្ថបទនេះចែងថាព្រះយេស៊ូបានប្រោសមនុស្សទាំងអស់ដោយសារព្រះជាម្ចាស់គង់នៅជាមួយទ្រង់។ ឥលូវនេះ ចូលដល់ឃ្លាដែលនិយាយថា «ព្រះជាម្ចាស់គង់នៅជាមួយទ្រង់»។ អ្នកត្រូវតែយល់ប្រយោគនេះជាមុនសិន។ ការពិតណាស់ព្រះជាម្ចាស់គង់នៅជាមួយព្រះយេស៊ូពេញមួយជីវិតរបស់ទ្រង់នៅលើផែនដីនេះ។ ប៉ុន្តែឃ្លានេះ គឺចង់សំដៅលើពេលដែលព្រះយេស៊ូកំពុងទទួលពិធីជ្រមុជទឹក ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកសណ្ឋិតលើទ្រង់មានសណ្ឋានដូចជាសត្វព្រាប។ តាំង

ពីមុនរហូតដល់ពេលនេះ ព្រះយេស៊ូមិនទាន់បានធ្វើការអស្ចារ្យអីទេ។ យើងមិនមានកំណត់ត្រាអំពីពេលដែលព្រះយេស៊ូបានបង្កើតគ្រាប់ធញ្ញជាតិសម្រាប់អាហារពេលព្រឹករបស់ទ្រង់ ឬការព្យាបាលមនុស្សម្នាក់កាលពីទ្រង់នៅកុមារភាពទេ។ តែការអស្ចារ្យបានកើតឡើងបន្ទាប់ពីទ្រង់ត្រូវបានចាក់ប្រេងតាំងដោយព្រះវិញ្ញាណដ៏វិសុទ្ធប៉ុណ្ណោះ ដែលកិច្ចបម្រើរបស់ទ្រង់ពិតជាបានចាប់ផ្ដើម។ ព្រះជាម្ចាស់គង់នៅជាមួយទ្រង់ពេលទ្រង់ធ្វើកិច្ចការទាំងអស់នេះ។

ជាការប្រសើរណាស់ អ្នកអាចនិយាយថា «បាទ/ចាស៎ ព្រះយេស៊ូបានប្រោសមនុស្សឱ្យជាពិតមែន ប៉ុន្តែទ្រង់មិននៅទីនេះទេ»។ ជាការប្រសើរណាស់ ខ្ញុំយល់ស្របជាមួយអ្នក វាពិតជាត្រឹមត្រូវមែនហើយ ប៉ុន្តែទ្រង់បានផ្តល់កិច្ចការនេះដល់ក្រុមជំនុំ។ អ្នកឃើញទេថាអំណាចដូចគ្នាដែលបានយាងមកគង់នៅជាមួយព្រះយេស៊ូ ក៏ត្រូវបានប្រទានដល់ក្រុមជំនុំផងដែរ។ ពេលដែលព្រះយេស៊ូជិតនឹងចាកចេញពីផែនដីនេះទៅ ទ្រង់មានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ដូចខាងក្រោមនេះ។

> *ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។*
>
> — កិច្ចការ ១:៨

អំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធដដែល បានយាងមកសណ្ឋិតលើក្រុមជំនុំ ដើម្បីធ្វើការអស្ចារ្យដូចព្រះយេស៊ូបានធ្វើ។

អ្នកមិនអាចប្រាប់ខ្ញុំអ្វីផ្សេងក្រៅពីនេះបានទេ។ កូនស្រីរបស់ខ្ញុំឈ្មោះ អេមី (Amy) មានដុំសាច់ទម្ងន់ ៥,៨៩ គីឡូក្រាមនៅក្នុងពោះរបស់នាង។ យើងទាំងអស់គ្នាបានអធិស្ឋានសម្រាប់ការប្រោសឱ្យជា ដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់

ហើយនាងបានចូលគេង បន្ទាប់មកពេលភ្ញាក់ឡើងនៅពេលព្រឹក នាងបានជាសះស្បើយទាំងស្រុង។ ដុំសាច់ទម្ងន់៥,៨៩គីឡូក្រាមបានរលាយបាត់ទៅ ហើយខ្នងរបស់នាង (ដែលពក និងកោង) ត្រូវបានជាឡើងវិញទាំងស្រុងដែរ។ អ្នកអាចឃើញ និងអានអំពីសាច់រឿងរបស់នាងនៅក្នុងសៀវភៅដែលមានចំណងជើងថា បានជាសះស្បើយនៅក្នុងពេលមួយរាត្រី (Healed Overnight)។

កូនប្រសាស្រីរបស់ខ្ញុំមានដុំសាច់ពកប៉ុនផ្លែក្រូចនៅចំហៀងខ្លួនរបស់នាង ដោយគ្រូពេទ្យបាននិយាយថានឹងត្រូវវះយកដុំពកនោះចេញ។ គ្រូពេទ្យបាននិយាយទៀតថា នាងមានជំងឺមហារីកដ៏កម្រមួយ ហើយអាចរស់បានតែពីមួយខែទៅពីរខែទៀតប៉ុណ្ណោះ។ នាងក៏ជឿលើការសន្យារបស់ព្រះជាម្ចាស់ ហើយភ្ញាក់ពេលព្រឹកឡើងបានជាសះស្បើយទាំងស្រុងពិតមែន។ ដុំពកនោះបានរលាយបាត់ទៅ។

ប្រពន្ធរបស់ខ្ញុំឈ្មោះ ឌ្រិនដា ក៏មានដុំសាច់ធំដែលមានទំហំប៉ុនកាក់៥០សេន នៅលើខ្នងរបស់នាង។ នាងចាប់ផ្ដើមអធិស្ឋានបញ្ជាវាឱ្យចាកចេញពីរាងកាយរបស់នាង ហើយក្នុងរយៈពេលពីរសប្ដាហ៍ វាបានរលាយបាត់ទាំងស្រុងតែម្ដងដែរ។

តើព្រះជាម្ចាស់ជ្រើសរើសប្រោសស្ត្រីទាំងនេះឱ្យជាឬ? តើមានអ្វីធ្វើឱ្យព្រះជាម្ចាស់ជ្រើសរើសព្យាបាលពួកគេ? តើទ្រង់ចូលចិត្តនារីទាំងបីនាក់នេះជាងអ្នកឬ? ទេ មិនដូច្នេះទេ! ពួកគេយល់អំពីច្បាប់ និងអត្ថប្រយោជន៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយបានប្រកាសទទួលការជាសះស្បើយយ៉ាងសាមញ្ញបំផុត។ អ្នកអាចនឹងសួរថា «ល្អណាស់អ៊ីចឹង ចុះហេតុអ្វី» «បានជាមានមនុស្សឈឺច្រើនម្ល៉េះ? ហេតុអ្វីបានជាយើងមិនឃើញមនុស្សបានប្រោសឱ្យជាបន្ថែមទៀតនៅក្នុងក្រុមជំនុំរបស់យើងទៅ?»

ខ្ញុំរីករាយដែលអ្នកបានសួរសំណួរបែបនេះ។ ចូរយើងស្វែងយល់អំពីវានៅក្នុងជំពូកបន្ទាប់ទៀត។

# ជំពូក ៣

# បញ្ហាពាក់ព័ន្ធនឹងដែនអំណាចគ្រប់គ្រង

ដូចខ្ញុំបាននិយាយអីចឹង ខ្ញុំរស់នៅទីជនបទក្នុងទឹកដីដ៏ស្រស់ស្អាតដែលមានផ្ទៃដី២៤ហិចតានៅក្នុងរដ្ឋអូហៃយ៉ូ។ ដើមឡើយ ខ្ញុំមានដី២២ហិចតាទេ ប៉ុន្តែអ្នកជិតខាងរបស់ខ្ញុំបានលក់ដីដែលជាប់ព្រំប្រទល់ដីរបស់ខ្ញុំមកឱ្យខ្ញុំ នោះទើបខ្ញុំមានដីសរុបរហូតដល់២៤ហិចតា។ យើងពិតជារីករាយនឹងទឹកដីនេះណាស់ក្នុងពេល២២ឆ្នាំចុងក្រោយនេះ។ វាមានព្រៃឈើដើម្បីបរបាញ់សត្វក្តាន់ មានវាលតក់សម្រាប់បរបាញ់សត្វប្រវឹក និងមានវាលស្រែដើម្បីបរបាញ់ទន្សាយ និងសត្វស្លាប យព្រមទាំងមានការជិះម៉ូតូកង់បួនកម្សាន្តលេងជុំវិញនោះក៏ជាពរជ័យមួយដែរ។ ប៉ុន្តែបើអ្នកក្រឡេកមើលកន្លែងខ្ញុំឱ្យបានច្បាស់ អ្នកនឹងឃើញថានៅបរិវេណដីធ្លានេះគ្មានស្លាកសញ្ញា**ហាមឃាត់**ទេ។ ផ្លាកសញ្ញាមាននៅទីនោះ ដូចនេះមនុស្សគ្រប់គ្នានឹងដឹងថាកន្លែងណាដែលជាខ្សែបន្ទាត់ទ្រព្យសម្បត្តិរបស់ខ្ញុំ។

ច្បាប់នៅរដ្ឋអូហៃយ៉ូចែងថា អ្នកដែលចង់ចូលមកក្នុងដីខ្ញុំ ត្រូវមានទម្រង់បែបបទយល់ព្រមជាលាយលក្ខណ៍អក្សរនៅជាប់ខ្លួន នៅគ្រប់ពេលវេលានៅពេលពួកគេនៅលើទឹកដីនេះ។ បើពួកគេមិនមាន នោះគេហៅថាជាការបំពានចូល ហើយពួកគេអាចត្រូវបានបណ្តេញចេញ និងអាចប្រឈមនឹងការផាកពិន័យ និងការដាក់ទោសក្នុងដំណើរការនេះ។ បញ្ហាត្រង់ថា អ្នកណាជ្រើសរើសដើរមកក្នុងទឹកដីខ្ញុំដោយខ្ញុំមិនទទួលដឹងឮថាមានដែនអំណាចគ្រប់គ្រងផ្លូវច្បាប់ក្នុងការសម្រេចចិត្តនោះទេ ព្រោះវាមិនមែនជាដីរបស់ពួកគេទេ។ បើខ្ញុំប្រាប់គេឱ្យចាកចេញពីដីខ្ញុំ វាមិនមែនជាជម្រើសរបស់គេទេ!

ដូច្នេះ និយាយឱ្យខ្លី អ្នកមិនអាចកាន់កាប់អ្វីមួយដែលអ្នកមិនមានដែនអំណាចគ្រប់គ្រងស្របច្បាប់បានទេ។

រូបស្លាកសញ្ញាហាមឃាត់នេះនឹងឆ្លើយសំណួរជាច្រើនដែលមនុស្សចង់ដឹងទាក់ទងនឹងមូលហេតុដែលរឿងកើតឡើង ឬមិនកើតឡើងក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ការយល់ដឹងអំពីបញ្ហាដែនអំណាចគ្រប់គ្រងនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជាតម្រូវការជាមុនសម្រាប់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងព្រះរាជ្យ។

## ហេតុអ្វីបានជាពួកគេមិនបានជាសះស្បើយ?

ខ្ញុំប្រាកដថា អ្នកប្រហែលជាបានឮរឿងបែបនេះហើយ។ មនុស្សម្នាក់មានជំងឺដែលគេនោះមានអ្នកស្គាល់ច្រើន ហើយពួកគេសុំឱ្យមានការអធិស្ឋាន។ មនុស្សរាប់លាននាក់ចូលរួមក្នុងការអធិស្ឋានជំនួសឱ្យការប្រោសបុគ្គលម្នាក់នេះឱ្យជា ប៉ុន្តែបុគ្គលនេះនៅតែស្លាប់។ ហេតុអ្វី? ឬមានគេប្រាប់អ្នកថាជីដូនរបស់ពួកគេបានស្លាប់ ទោះបីជាពួកគេកំពុងអធិស្ឋានសម្រាប់គាត់ក៏ដោយ ហើយពួកគេចង់ដឹងពីមូលហេតុ។ ឬមាននរណាម្នាក់ប្រាប់អ្នកថាពួកគេបានសាបព្រោះលុយសម្រាប់តម្រូវការហិរញ្ញវត្ថុ ប៉ុន្តែពួកគេនៅតែបន្តដាច់លុយ។ តើមានចម្លើយសម្រាប់ប្រភេទសំណួរទាំងនេះដែរឬទេ?

មុនពេលខ្ញុំឆ្លើយតបនឹងចំណុចនេះ សូមយើងទទួលស្គាល់ថា យើងមិនដឹងអ្វីគ្រប់យ៉ាងដែលកំពុងកើតឡើងនៅក្នុងពិភពនៃព្រះវិញ្ញាណ ហើយខ្ញុំក៏មិនធ្វើពុតថាខ្ញុំបានដឹងឡើយ។ ទោះយ៉ាងណាក៏ដោយ ដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងដឹងថាប្រសិនបើនរណាម្នាក់ឈឺ នោះព្រះយេស៊ូបានបង់ថ្លៃសម្រាប់ការជាសះស្បើយរបស់ពួកគេរួចហើយ។ យើងដឹងថាប្រសិនបើយើងមានចិត្តទូលាយ និងធ្វើអំណោយដល់អ្នកដទៃ ព្រះគម្ពីរចែងថាយើងនឹងទទួលបានត្រលប់មកវិញ។ ប៉ុន្តែសម្រាប់ជីវភាពប្រចាំថ្ងៃ យើងឃើញនូវអ្វីដែលមើលទៅដូចជាការបរាជ័យជាក់ស្តែង

នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់កើតមានឡើង ដូចដែលវាត្រូវបានចារទុកនៅក្នុងជីវិតរបស់មនុស្សជាច្រើន។ តើគួរតែបន្ទោសព្រះជាម្ចាស់ឬ?

នៅពេលយើងក្រឡេកមើលអ្វីដែលយើងបានរៀននៅក្នុងជំពូកមុន ហើយនៅពេលយើងពិភាក្សាអំពីប្រធានបទនេះនៅក្នុងជំពូកនេះ អ្នកនឹងទទួលបានចម្លើយបន្លឺឡើងច្បាស់ៗថា ទេ។ បើចម្លើយនោះថា ទេ តើមានបញ្ហាអ្វីទៅ? នេះជាបញ្ហាចម្បង។ សម្រាប់មនុស្សភាគច្រើនដែលមិនមានការយល់ដឹងជាមូលដ្ឋានបំផុតដែលថាព្រះជាម្ចាស់ល្អជានិច្ច នៅពេលសួរថាតើព្រះជាម្ចាស់គួរតែត្រូវគេបន្ទោសចំពោះសោកនាដកម្មឬអត់នោះ ពួកគេសន្មតថាទ្រង់ជាអ្នកគួរទទួលរងការបន្ទោស។ ជាថ្មីម្តងទៀត ដោយសារពួកគេដឹងថាទ្រង់មានអំណាចក្នុងការបញ្ឈប់រឿងអាក្រក់កុំឱ្យកើតឡើង ហើយតាមជាក់ស្តែង ទ្រង់មិនបានធ្វើទេ ពួកគេក៏គិតថាទ្រង់ច្បាស់ជាបានអនុញ្ញាតឱ្យវាកើតឡើងហើយ។ ប៉ុន្តែប្រសិនបើអ្នកមានការយល់ដឹងថា ព្រះជាម្ចាស់ល្អ ហើយមិនអាចកុហកបាន នោះអ្នកនឹងដឹងថាបញ្ហានោះច្បាស់ជាមាននៅត្រង់កន្លែងណាមួយមិនខាន ហើយអ្នកនឹងចាប់ផ្តើមធ្វើការស្វែងរកចម្លើយ។

ពួកសិស្សបានបង្ហាញពីផ្នត់គំនិតនេះ នៅពេលដែលពួកគេមិនអាចដេញអារក្សចេញពីក្មេងប្រុសដែលមានអារក្សសណ្ឋិត។ ជំនួសឱ្យការសួរថា «ហេតុអ្វីបានជាព្រះជាម្ចាស់សម្រេចព្រះហឫទ័យទុកអារក្សនោះនៅទីនោះ?» ពួកគេសួរព្រះយេស៊ូថា «ហេតុអ្វីបានជាយើងមិនអាចដេញវាឱ្យចេញបាន?»

នេះគួរតែជាសំណួរភ្លាមៗរបស់យើង នៅពេលដែលកាលៈទេសៈហាក់ដូចជាផ្ទុយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះ ជាថ្មីម្តងទៀត ជាដំបូង វាជារឿងសំខាន់ណាស់ដែលយើងត្រូវតែដឹងថាព្រះជាម្ចាស់ល្អ ហើយទីពីរ ត្រូវដឹងថាទ្រង់មិនកុហកទេ។ នេះក៏ជាមូលហេតុដែលខ្ញុំបានចំណាយពេលច្រើនណាស់ក្នុងការដាក់ចេញនូវអ្វី

ដែលខ្ញុំមើលទៅដូចជាគ្មានគំនិត ប៉ុន្តែគួរឱ្យភ្ញាក់ផ្អើល វាជាពិតពអាចិកំបាំងមួយចំពោះពិតពក្រុមជំនុំតាគច្រើន។ ការសួរសំណួរទាំងនេះហើយ គឺជារបៀបដែលអ្នកត្រូវអានព្រះគម្ពីរ ប្រសិនបើអ្នកចង់រៀនពីរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់ដំណើរការ។

**ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជាអាណាចក្រមួយ ហើយដំណើរការដោយច្បាប់ និងគោលការណ៍ ដែលមិនដែលផ្លាស់ប្តូរ។**

សូមចាំថា រឿងដ៏អស្ចារ្យនានាក្នុងព្រះគម្ពីរមាននៅទីនោះដោយមានមូលហេតុរបស់វា។ ព្រះយេស៊ូកំពុងព្យាយាមបង្ហាញអ្នកនូវអ្វីមួយ។ ដូច្នេះ សូមបន្តស្វែងយល់ពីមូលហេតុដែលមនុស្សណាម្នាក់មិនបានទទួលអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែង។ ជាការពិតណាស់ វាអាចមានបញ្ហាច្រើនដែលកំពុងតែកាត់ផ្តាច់ដែនអំណាចគ្រប់គ្រងស្ថានសួគ៌។ បញ្ហាខ្លះមិនបង្ហាញឱ្យឃើញភ្លាមៗទេ ហើយខ្លះទៀតជារឿងផ្ទាល់ខ្លួន និងអាថ៌កំបាំង។

ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជាអាណាចក្រមួយ ហើយដំណើរការដោយច្បាប់ និងគោលការណ៍ដែលមិនដែលផ្លាស់ប្តូរ។ ដូចដែលខ្ញុំបាននិយាយអីចឹង គោលការណ៍ទាំងនោះ អាចត្រូវបានគេរៀន និងយកទៅប្រើប្រាស់បាន មិនខុសអីពីកសិករម្នាក់យល់អំពីច្បាប់នៃពេលវេលាគ្រាប់ពូជ និងការប្រមូលផលនៅក្នុងពិតពផែនដី ហើយប្រើប្រាស់ច្បាប់ទាំងនោះដើម្បីរីកចម្រើន។ ដោយសារតែព្រះរាជ្យនៃព្រះជាម្ចាស់ដំណើរការទៅដោយប្រើច្បាប់ ដែលត្រូវបានផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូបឱ្យបានយល់ និងប្រើប្រាស់ អ្នកណាក៏អាចរៀនសូត្របានដែរ។ ពេលខ្លះ ការដឹងពីរបៀបដែលច្បាប់ទាំងនេះដំណើរការ អាចជារឿងស្លាប់រស់។

## ការសម្រេចចិត្តដែលប៉ះពាល់ដល់ការស្លាប់-រស់

ម៉ាក និងហាណា បានមកក្រុមជំនុំរបស់យើង ហើយចង់មានកូន។ រហូតមកដល់ពេលនេះ គ្រូពេទ្យបានប្រាប់ហាណាថា ដោយសារតែបញ្ហាផ្សេងៗនៅក្នុងខ្លួនរបស់នាង វាស្ទើរតែមិនអាចទៅរួចទេដែលនាងអាចមានផ្ទៃពោះ ឬសម្រាលកូន។ ប៉ុន្តែពេលដែលបានឮអំពីភាពល្អនៃព្រះជាម្ចាស់ និងរៀនច្បាប់អំពីព្រះរាជ្យនៃព្រះជាម្ចាស់នៅក្រុមជំនុំ Faith Life នាងក៏បានដឹងថាខ្លួននាងមានផ្ទៃពោះ។ នាងរំភើបឥតឧបមា។ ប៉ុន្តែមិនយូរប៉ុន្មាន នាងចាប់ផ្តើមឈឺពោះយ៉ាងខ្លាំង។ មួយដងជាពីរដង នាងមានសភាពធ្ងន់ធ្ងររហូតដល់សន្លប់។

បន្ទាប់ពីរឿងក្នុងចំណោមរឿងរ៉ាវផ្សេងៗបានកើតឡើង នាងចង់ពិនិត្យមើលឱ្យច្បាស់ ហើយនាងក៏បានទៅកាន់ការិយាល័យវេជ្ជបណ្ឌិតរបស់នាង។ វេជ្ជបណ្ឌិតរបស់នាងមិនបាននៅឯការិយាល័យទេ ប៉ុន្តែវេជ្ជបណ្ឌិតប្រចាំការចង់ធ្វើការពិនិត្យដោយប្រើម៉ាស៊ីនថតតាមរយៈរលកសំឡេងដើម្បីមើលថាតើមានអ្វីកើតឡើង។ អ្វីដែលវេជ្ជបណ្ឌិតនោះបានឃើញគឺមានដុំឈាមធំមួយ ហើយគាត់បានប្រាប់ថា នាងបានរលូតកូនហើយ គឺកូននោះមិនមានចង្វាក់បេះដូងលោតទេ។ គ្រូពេទ្យបានស្នើឱ្យនាងមកនៅថ្ងៃបន្ទាប់ដើម្បីយកកូនដែលស្លាប់ចេញពីផ្ទៃនាង ប៉ុន្តែហាណាមិនព្រម។ ផ្ទុយទៅវិញ ម៉ាកដែលជាស្វាមីរបស់នាងបានលើកទឹកចិត្ត ហាណាដោយព្រះបន្ទូលព្រះជាម្ចាស់ និងការសន្យារបស់ព្រះជាម្ចាស់ ហើយបានលើកទឹកចិត្តនាងកុំឱ្យនាងបាត់បង់ទំនុកចិត្តរបស់ខ្លួនដោយសារតែនឹកគិតពីទារកនោះ។ នៅចុងសប្តាហ៍នោះ នាងបានទទួលការអធិស្ឋាននៅក្រុមជំនុំ ហើយជឿជាក់ថា នាងនឹងមានកូនដែលមានសុខភាពល្អ ផ្ទុយពីអ្វីដែលវេជ្ជបណ្ឌិតបានប្រាប់នាង។

នៅថ្ងៃចន្ទ នាងបានចូលទៅជួបគ្រូពេទ្យផ្ទាល់ខ្លួនរបស់នាង ព្រោះថាគ្រូពេទ្យរបស់នាងមិននៅក្នុងការិយាល័យកាលពីថ្ងៃដែលនាងបានឈៀងចូលនោះទេ។ គ្រូពេទ្យបានណែនាំឱ្យនាងធ្វើការពិនិត្យដោយម៉ាស៊ីនថតតាមរយៈរលកសំឡេងម្តងទៀត។ ហាណាបាននិយាយថា គ្រូពេទ្យបានមើលមុខរបស់នាងយ៉ាងភ្ញាក់ផ្អើល នៅពេល

ដែលនាងសម្លឹងមើលអេក្រង់ម៉ាស៊ីនថតរលកសំឡេងនោះ ហើយភ្លាមៗនោះគាត់បានក្រឡេកមកមើលការស្កេនដែលបានធ្វើឡើងកាលពីប៉ុន្មានថ្ងៃមុន។ បន្ទាប់មក នាងបាននិយាយពីពាក្យដែលគ្រូពេទ្យនិយាយមកកាន់នាង ៖ «ខ្ញុំធ្វើការងារនេះអស់៣០ឆ្នាំហើយ ហើយខ្ញុំមិនដែលឃើញរឿងនេះកើតឡើងពីមុនមកទេ។ ខ្ញុំអាចមើលឃើញកំណកឈាមធំនៅលើការស្កេនកាលពីសប្តាហ៍មុន និងអវត្តមាននៃចង្វាក់បេះដូង។ ពេលខ្ញុំមើលអ្នកថ្ងៃនេះ កំណកឈាមទាំងមូលបានរលត់ទៅ ហើយមានទារិកាដ៏ល្អឥតខ្ចោះម្នាក់នៅរស់ ហើយមានចង្វាក់បេះដូងដ៏ល្អឥតខ្ចោះ។» ប៉ុន្មានខែក្រោយមក ហាណាសម្រាលបានកូនស្រីដែលមានសុខភាពល្អម្នាក់ ដែលនាងដាក់ឈ្មោះថា អេវើលីន ។ ថ្ងៃមួយចង់ដឹងចង់ឃើញអត្ថន័យនៃឈ្មោះ អេវើលីន នាងបានឆែកមើល ហើយភ្ញាក់ផ្អើលដោយដឹងថាឈ្មោះនេះមានន័យថា ជីវិត!

រឿងដ៏អស្ចារ្យនេះច្បាស់ជាកិច្ចការរបស់ព្រះជាម្ចាស់ ប៉ុន្តែក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ពេលនេះអ្នកគួរតែគិតអំពីសំណួរមួយចំនួន។ ហេតុអ្វីបានជាវាកើតឡើង? តើហាណាជាមនុស្សសំណប់ទីពេញចិត្តរបស់ព្រះជាម្ចាស់ឬ? តើព្រះជាម្ចាស់គ្រាន់តែជ្រើសរើសដោយចៃដន្យដើម្បីប្រោសកូនរបស់នាងឱ្យបានជាទេ? ទាំងនេះគឺជាសំណួរដែលត្រូវតែឆ្លើយ។ ជាថ្មីម្តងទៀត ចំពោះគ្រិស្តបរិស័ទមួយចំនួនធំ មានកិច្ចការអស្ចារ្យមួយបានកើតឡើង។ ប៉ុន្តែខ្ញុំលើកទឹកចិត្តមនុស្សឱ្យគិតឡើងវិញនូវពាក្យកិច្ចការអស្ចារ្យ ព្រោះវាមានន័យខុសពីធម្មតា។ នៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់ នេះគ្រាន់តែជាមុខងារច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។

បើខ្ញុំទម្លាក់ដុំថ្ម ហើយវាធ្លាក់មកដី អ្នកនឹងគិតថាខ្ញុំឆ្កួត បើខ្ញុំស្រែកថា «វ៉ោ៎ អ្នកឃើញទេ? ថ្មទើបតែធ្លាក់ដល់ដី។ នោះជាការអស្ចារ្យ!» អ្នកនឹងមិនយល់ស្របថាវាជាការអស្ចារ្យទេ ព្រោះអ្នកដឹងថាសកម្មភាពគ្រាន់តែជាមុខងារនៃច្បាប់ទំនាញ ហើយវាដំណើរការដូចគ្នារាល់ពេលសម្រាប់មនុស្សគ្រប់គ្នា។ ថ្មនឹងធ្លាក់មកដីជានិច្ច។ ដូច្នេះក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ អ្នកត្រូវតែស្វែងរកតម្រុយអំពីអ្វីដែលបានកើត

ឡើង តម្រុយខាងវិញ្ញាណដែលនឹងបង្ហាញអំពីច្បាប់ ឬច្បាប់នៃព្រះរាជ្យនៃព្រះជាម្ចាស់ដែលកើតមាននៅក្នុងរឿងនោះ។

## គន្លឹះមួយត្រូវបានបើកបង្ហាញ

សូមបន្តទៅរឿងមួយទៀតដែលយើងអាចស្វែងយល់បន្ថែមអំពីមុខងាររបស់ព្រះរាជ្យនៃព្រះជាម្ចាស់ទាក់ទងនឹងសំណួរទាំងនេះ។ រឿងដ៏អស្ចារ្យបំផុតមួយនៅក្នុងព្រះគម្ពីរ ដែលនឹងជួយយើងស្វែងរកចម្លើយមួយចំនួន មាននៅក្នុងគម្ពីរលូកាជំពូកទីប្រាំបី។

*កាលព្រះយេស៊ូយាងទៅ នៅតាមផ្លូវ មានមហាជនប្រជ្រៀតគ្នាជុំវិញព្រះអង្គ។ ពេលនោះ មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ នាងបានចំណាយទ្រព្យសម្បត្តិដែលនាងមានទាំងប៉ុន្មាន ដើម្បីឱ្យគ្រូពេទ្យព្យាបាល តែគ្មានគ្រូពេទ្យណាអាចមើលនាងជាឡើយ។ នាងមកពីក្រោយព្រះយេស៊ូ ហើយពាល់ជាយព្រះពស្ត្រព្រះអង្គ ស្រាប់តែឈាមឈប់ធ្លាក់មួយរំពេច។ ព្រះយេស៊ូមានព្រះបន្ទូលសួរថា៖ «នរណាពាល់ខ្ញុំ?»។ គេប្រកែកគ្រប់គ្នាថា គេមិនបានពាល់ព្រះអង្គទេ។ លោកពេត្រុសទូលថា៖ «ព្រះគ្រូអើយ បណ្ដាជនប្រជ្រៀតគ្នានៅជុំវិញព្រះគ្រូ ហើយគេប៉ះព្រះគ្រូទាំងអស់គ្នា»។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានម្នាក់ពិតជាបានពាល់ខ្ញុំ ព្រោះខ្ញុំដឹងថាមានឫទ្ធានុភាពមួយចេញពីខ្លួនខ្ញុំទៅ»។ ស្ត្រីនោះមកក្រាបទៀបព្រះបាទាព្រះយេស៊ូ ទាំងញ័ររន្ធត់ ព្រោះដឹងថាខ្លួនលាក់រឿងនេះមិនជិត។ នាងទូលព្រះអង្គនៅចំពោះមុខប្រជាជនទាំងមូលអំពីហេតុ ដែលនាំឱ្យនាងពាល់ព្រះអង្គ ហើយនាងបានជាពីជំងឺភ្លាម។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «<u>កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ</u> សូមអញ្ជើញទៅដោយសុខសាន្តចុះ»។*

— លូកា ៨:៤២-៤៨ (គខប)

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ក្នុងរឿងនេះ យើងឃើញមានស្ត្រីម្នាក់ដែលមានជំងឺជាច្រើនឆ្នាំ ហើយមិនអាចជាសះស្បើយបាន។ គាត់បានតាមពីក្រោយព្រះយេស៊ូ គាត់បានពាល់ព្រះពស្ត្រទ្រង់ ហើយបានជាសះស្បើយភ្លាម។ ឥលូវនេះ មានតម្រុយដែលស៊ីជម្រៅមួយចំនួននៃប្រតិបត្តិការរបស់ព្រះរាជ្យនៃព្រះជាម្ចាស់នៅក្នុងរឿងនេះ ដែលយើងអាចរៀនបាន ហើយវានឹងបំភ្លឺនូវចម្លើយមួយចំនួនដែលយើងកំពុងស្វែងរក។

មុនដំបូង ហ្វូងមនុស្សដែលនៅជុំវិញព្រះយេស៊ូកំពុងតែប៉ះផ្ទាល់នឹងទ្រង់។ រឿងនេះចែងថា ទ្រង់ស្ទើរតែត្រូវបានកៀបសង្កត់សង្កិនដោយហ្វូងមនុស្សដែលប្រជ្រៀតគ្នាទៅរកទ្រង់។ ពេលព្រះយេស៊ូសួរថា៖ «អ្នកណាខ្លះបានប៉ះពាល់ខ្ញុំ?» ពេត្រុសភ្ញាក់ផ្អើលចំពោះសំណួរនេះ ព្រោះបើរំឭកម្តងទៀត អ្នករាល់គ្នាសុទ្ធតែកំពុងពាល់ទ្រង់។ ប៉ុន្តែព្រះយេស៊ូមានបន្ទូលថា បុគ្គលពិសេសម្នាក់នេះបានពាល់ទ្រង់ក្នុងវិធីផ្សេងពីគេ ព្រោះទ្រង់បានទទួលអារម្មណ៍ថាមានអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធហូរចេញពីទ្រង់។

បន្ទាប់ពីអានរឿងនេះរួច កណ្តឹង និងកញ្ចែគ្រប់ប្រភេទគួរតែបន្លឺឡើងនៅក្នុងស្មារតីរបស់អ្នកដោយធ្វើការដាស់តឿនអ្នកឱ្យឈប់ ហើយពិចារណាពីអ្វីដែលទើបតែកើតឡើង។ ចិត្តរបស់អ្នកគួរតែចាប់ផ្តើមចូលទៅក្នុងបែបផែនស៊ើបអង្កេតភ្លាមៗជាមួយនឹងសំណួរជាច្រើន។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងត្រូវដឹងថា ហេតុអ្វីបានជាស្ត្រីម្នាក់នេះបានជាសះស្បើយ ហើយគ្មាននរណាម្នាក់ទៀតជា។ ខ្ញុំអាចសន្មតថា មានអ្នកផ្សេងទៀតជាច្រើននៅទីនោះដោយមានជំងឺជាប់ខ្លួន ហើយបានពាល់ព្រះអង្គ ប៉ុន្តែនៅតែមិនទាន់បានជាសះស្បើយ។ ដូច្នេះ យើងត្រូវសួរថា៖ «ហេតុអ្វីបានជាការចាក់ប្រេងតាំងហូរមកតែស្ត្រីម្នាក់នេះ ហើយមិនហូរដល់អ្នកដទៃទៀតដែលពាល់ទ្រង់នៅកំឡុងពេលនោះ?»

ចម្លើយតាមបែបសាសនាប្រពៃណីគឺថា គាត់បានជាសះស្បើយដោយសារព្រះយេស៊ូបានប្រោសគាត់ឱ្យជាសះស្បើយ។ ប៉ុន្តែតើទ្រង់ពិតជាបានធ្វើមែនឬ? តើព្រះ

យេស៊ូកំពុងមានចេតនាធ្វើព័ន្ធកិច្ចចំពោះគាត់ពេលគាត់បានជាឬទេនៅពេលគាត់ត្រូវបានប្រោសឱ្យជា? តើទ្រង់បានដាក់ព្រះហស្តលើគាត់ទេ? តើទ្រង់បានបង្គាប់ឱ្យជំងឺនោះចាកចេញពីរូបកាយរបស់គាត់ឬទេ? ចម្លើយគឺ ទេ។ តាមពិត ព្រះយេស៊ូមិនបានដឹងថាគាត់នៅទីនោះទេ។ ព្រះអង្គត្រូវតែសួរថា អ្នកណាបានមកពាល់ទ្រង់។ ដូច្នេះ តើទ្រង់ពិតជាជ្រើសរើសប្រោសគាត់ឱ្យជានៅពេលនោះឬ? ជាថ្មីម្តងទៀត ទ្រង់មិនបានដឹងថាគាត់នៅទីនោះទេ។ ដូច្នេះ តើគាត់បានជាសះស្បើយដោយរបៀបណា? ហេតុអ្វីបានជាគាត់ជាសះស្បើយ?

ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងអាចដកចេញនូវគំនិតមួយគិតថា គាត់ជាកូនពិសេសម្នាក់របស់ព្រះជាម្ចាស់ ឬថាគាត់មានទំនាក់ទំនងពិសេសជាមួយនឹងព្រះយេស៊ូ ព្រោះគម្ពីរកិច្ចការ ១០:៣៤ ចែងថា ព្រះជាម្ចាស់រាប់រកមនុស្សទូទៅឥតរើសមុខឡើង។ យើងក៏អាចសន្មតថា ដោយសារព្រះយេស៊ូមិនទាំងដឹងថាគាត់នៅទីនោះ ទ្រង់មិនមានចំណែកក្នុងការសម្រេចចិត្តរបស់គាត់ដើម្បីប្រោសឱ្យជានៅថ្ងៃនោះឡើយ។ យើងយល់ស្របថាទ្រង់គឺជាអាងស្តុកទឹកនៃការចាក់ប្រេងតាំង ប៉ុន្តែទ្រង់មិនមែនជាផ្នែកនៃការសម្រេចចិត្តដែលគាត់បានធ្វើដើម្បីទទួលការប្រោសឱ្យជានៅពេលនោះទេ។

ព្រះយេស៊ូប្រាប់យើងយ៉ាងច្បាស់ពីរបៀបដែលគាត់ចូលទៅក្នុងសិទ្ធិ និងអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ គាត់បានមានបន្ទូលថា *«កូនស្រីអើយ ជំនឿរបស់នាងបានសង្គ្រោះនាងហើយ។ សូមអញ្ជើញទៅដោយសុខសាន្តចុះ។»* ប្រយោគនេះប្រាប់យើងនូវអ្វីគ្រប់យ៉ាងដែលយើងត្រូវដឹង ហើយឆ្លើយសំណួររបស់យើងអំពីមូលហេតុ និងរបៀបដែលគាត់បានទទួលនៅថ្ងៃនោះ។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ចូរយើងចាប់ផ្តើមពិនិត្យមើលរឿងនេះឱ្យបានជិតដល់ ហើយមើលថាតើយើងអាចរកឃើញតម្រុយណាមួយដែលថាហេតុអ្វីបានជាគាត់បានទទួល។

ជាដំបូង ព្រះយេស៊ូហៅគាត់ថាកូនស្រី នោះមានន័យថាគាត់ជាផ្នែកមួយនៃប្រជាជាតិអ៊ីស្រាអែល ដែលជាកូនចៅរបស់អប្រាហាំ។ ក្នុងនាមជាកូនរបស់អប្រាហាំ គាត់មានព្រះពរដែលបានប្រទានដល់អប្រាហាំ និងអត្ថប្រយោជន៍នៃសម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានធ្វើជាមួយអប្រាហាំ។

> *ព្រះអង្គមានព្រះបន្ទូលថា៖ «ប្រសិនបើអ្នករាល់គ្នាយកចិត្តទុកដាក់ស្ដាប់បង្គាប់យើង ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ហើយប្រព្រឹត្តតាមអ្វីៗដែលយើងយល់ថាត្រឹមត្រូវ ប្រសិនបើអ្នករាល់គ្នាត្រងត្រាប់ស្ដាប់បទបញ្ជា និងកាន់តាមច្បាប់ទាំងប៉ុន្មានរបស់យើង នោះយើងនឹងមិនធ្វើឱ្យអ្នករាល់គ្នាកើតជំងឺអ្វីមួយ ដូចយើងបានធ្វើចំពោះជនជាតិអេស៊ីបឡើយ ដ្បិតយើងជាព្រះអម្ចាស់ដែលប្រោសឱ្យអ្នករាល់គ្នាជា»។*
>
> — និក្ខមនំ ១៥:២៦ (គខប)

ដូច្នេះ នៅពេលព្រះយេស៊ូហៅគាត់ថាកូនស្រី នោះមានន័យថាគាត់មានសិទ្ធិស្របច្បាប់ចំពោះអ្វីៗទាំងអស់ដែលរួមបញ្ចូលក្នុងសម្ពន្ធមេត្រីរបស់អប្រាហាំ ដែលលោកបានធ្វើជាមួយនឹងព្រះជាម្ចាស់។ ទោះជាយ៉ាងណាក៏ដោយ ការពិតនេះតែម្យ៉ាងមិនអាចជាហេតុផលតែមួយគត់ដែលគាត់បានទទួលនោះទេ ខណៈដែលមនុស្សទាំងអស់នៅទីនោះនាថ្ងៃនោះដែលកំពុងតែប្រជ្រៀតគ្នាទៅលើព្រះយេស៊ូ មានភាពស្របច្បាប់ដូចគ្នានោះ។ វាត្រូវតែមានអ្វីផ្សេងទៀតដែលបណ្ដាលឱ្យអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ហូរមក។ បន្ទាប់មក ព្រះយេស៊ូប្រាប់យើងអំពីមូលហេតុមួយទៀតដែលគាត់បានទទួល។ តាមពិត ព្រះយេស៊ូបានមានបន្ទូលថា នេះជាមូលហេតុពិតប្រាកដដែលគាត់បានទទួលដោយផ្ទាល់។ ព្រះអង្គបានមានបន្ទូលថាជំនឿរបស់គាត់បានប្រោសគាត់ឱ្យជាហើយ។

**ជំនឿ គឺជាពាក្យដែលគ្រិស្តបរិស័ទតែងនិយាយប៉ប៉ាច់ប៉បោចទាំងមិនច្បាស់លាស់។**

ដូច្នេះ ពេលនេះយើងដឹងពីមូលហេតុដែលគាត់អាចទទួលបានហើយ។ វាជាសិទ្ធិស្របច្បាប់របស់គាត់ក្នុងការទទួលបាន ដោយសារតែគាត់ជាកូនស្រីរបស់លោកអប្រាហាំ ហើយទីពីរ ជំនឿរបស់គាត់គឺជាកុងតាក់បើកដែលអនុញ្ញាតឱ្យឫទ្ធានុភាពនោះហូរដោយផ្ទាល់ទៅក្នុងរូបកាយរបស់គាត់នៅពេលជាក់លាក់នោះ។ ការពិតដែលគាត់ជាកូនស្រី គឺអាចប្រៀបធៀបទៅនឹងក្រុមហ៊ុនអគ្គិសនីដែលបើកភ្លើង និងមានខ្សែភ្លើងចូលមកក្នុងផ្ទះរបស់អ្នក។ ភ្លើងមានឱ្យប្រើបានហើយ ប៉ុន្តែនេះមិនមានន័យថាអំពូលភ្លើងរបស់អ្នកនឹងភ្លឺនោះទេ។ អ្នកក៏ត្រូវបើកកុងតាក់មុនពេលអំពូលភ្លើងភ្លឺឡើង។

ដូច្នេះ ក្នុងនាមជាកូនចៅស្របច្បាប់របស់អប្រាហាំ ស្ត្រីម្នាក់នេះមានសិទ្ធិស្របច្បាប់ទទួលការប្រោសឱ្យជាសះស្បើយ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែគាត់មានដែនអំណាចគ្រប់គ្រងនៅលើផែនដី និងលើជីវិតផ្ទាល់ខ្លួនរបស់គាត់ គាត់ត្រូវបើកកុងតាក់ដោយខ្លួនឯងដើម្បីបញ្ចេញថាមពលនោះ។ ប៉ុន្តែតើកុងតាក់នៅឯណា? តើយើងបើកវាដោយរបៀបណា? ដើម្បីស្វែងយល់ឱ្យច្បាស់ យើងត្រូវកំណត់និយមន័យនៃពាក្យរបស់យើងសិន។

## អ្វីទៅជាជំនឿ?

ជំនឿ គឺជាពាក្យដែលគ្រិស្តបរិស័ទតែងនិយាយប៉ប៉ាច់ប៉បោចទាំងមិនច្បាស់លាស់។ ហើយខ្ញុំជឿជាក់ថា បើមិនមែនមនុស្សភាគច្រើន ក៏មានមនុស្សជាច្រើនមិនដឹងថាតើតាមពិតទៅជំនឿជាអ្វី ហេតុអ្វីបានជាត្រូវការជំនឿ តើអ្វីជារបៀបដឹងថាគេមានជំនឿ និងអ្វីជារបៀបទទួលបានជំនឿ។ ប្រសិនបើជំនឿគឺជាកុងតាក់ដែលអនុញ្ញាតឱ្យការចាក់ប្រេងតាំងហូរទៅ និងប្រោសស្ត្រីនេះឱ្យជា នោះយើងត្រូវពិនិត្យមើលយ៉ាងដិតដល់អំពីជំនឿ! យើងរកឃើញនិយមន័យនៃជំនឿរបស់យើងនៅក្នុងគម្ពីររ៉ូម ៤:១៨–២១។

*នៅពេលអស់សង្ឃឹម លោកជឿទាំងសង្ឃឹមថា លោកនឹងបានទៅជាឪពុកដល់សាសន៍ជាច្រើន ស្របតាមព្រះបន្ទូលដែលថ្លែងទុកមកថា «ពូជពង្សរបស់អ្នកនឹងបានដូច្នោះ»។ ជំនឿរបស់លោកមិនបានចុះខ្សោយឡើយ ទោះបើលោកមើលទៅរូបកាយរបស់លោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលមួយរយឆ្នាំទៅហើយ ហើយទោះបើផ្ទៃរបស់លោកយាយសារ៉ា ដែលរាប់ដូចជាស្លាប់ទៅហើយនោះក៏ដោយ។ លោកមិនបានសង្ស័យចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺលោកកាន់តែមានជំនឿខ្លាំងឡើង ហើយថ្វាយសិរីល្អដល់ព្រះ <u>ដោយជឿជាក់អស់ពីចិត្តថា</u> បើព្រះបានសន្យាធ្វើអ្វី នោះព្រះអង្គអាចនឹងសម្រេចបានមិនខាន។*

— រ៉ូម ៤:១៨-២១ (គកស១៦)

ចូរយើងមកឈ្វេងយល់ពីការកំណត់នៃរឿងនេះ។ លោកអប្រាហាំ និងអ្នកស្រីសារ៉ាមិនអាចមានកូនបានទេ។ ខ្ញុំមិនមែនមានន័យថាពួកគេមានបញ្ហាក្នុងការមានកូន ហើយគួរតែព្យាយាមបន្តទៀតនោះទេ។ ខ្ញុំមានន័យថាពួកគេមានអាយុជិត១០០ឆ្នាំ ហើយវាហួសអាយុមានកូនទៅហើយ។ រាងកាយរបស់ពួកគេមិនអាចមានកូនបានទេ។ វាមិនអាចទៅរួចទេ! ប៉ុន្តែ ព្រះជាម្ចាស់បានសន្យាប្រទានកូនដល់អប្រាហាំ ទោះបីជាតាមក្រឹត្យក្រមធម្មជាតិ វាមិនអាចទៅរួចជាដាច់ខាត។ ព្រះគម្ពីរចែងថា អប្រាហាំជឿជាក់ទាំងស្រុងថាព្រះជាម្ចាស់មានឫទ្ធានុភាពធ្វើអ្វីដែលទ្រង់មានបន្ទូល ទោះជាតាមភាពជាក់ស្តែងនៃធម្មជាតិបានចែងអំពីសាច់រឿងផ្សេងក៏ដោយ។

នេះគឺជានិយមន័យរបស់យើងអំពីជំនឿ៖ «ជឿជាក់ទាំងស្រុងថាព្រះជាម្ចាស់មានឫទ្ធានុភាពធ្វើតាមអ្វីដែលទ្រង់បានសន្យា»។ ខ្ញុំសូមនិយាយបែបនេះវិញ៖ «**ចិត្តអ្នកយល់ស្របនឹងស្ថានសួគ៌**»។ នោះមិនគ្រាន់តែយល់ស្របខាងផ្លូវចិត្តនឹងអ្វីដែលព្រះជាម្ចាស់មានបន្ទូលប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវបានបញ្ចុះបញ្ចូលឱ្យជឿយ៉ាងពេញលេញ។

## និយមន័យរបស់យើងថាតើជំនឿជាអ្វី៖

ខ្ញុំសូមនិយាយវាម្តងទៀតដើម្បីឱ្យប្រាកដថាយើងយល់។ ជំនឿ គឺការជឿយ៉ាងពេញលេញនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូល! វាគឺជាចិត្ត និងគំនិតរបស់យើងដែលត្រូវគ្នាជាមួយនឹងស្ថានសួគ៌ បញ្ចុះបញ្ចូលឱ្យជឿយ៉ាងពេញលេញ។

## ហេតុអ្វីបានជាត្រូវការជំនឿ?

ហេតុអ្វីបានជាព្រះជាម្ចាស់មិនអាចប្រោសអ្នករាល់គ្នានៅក្នុងមន្ទីរពេទ្យឱ្យជាសះស្បើយ ពេលទ្រង់ចង់ប្រោសឱ្យជា? ហេតុអ្វីបានជាទ្រង់មិនអាចបញ្ឈប់សង្គ្រាមបាន? ហេតុអ្វីបានជាទ្រង់មិនអាចបញ្ជូនទេវតាមកផ្សាយដំណឹងល្អដល់យើង? ខ្ញុំប្រាកដថាអ្នកធ្លាប់បានឮសំណួរទាំងអស់នេះពីមុនមក។ ចម្លើយគឺថាទ្រង់មិនអាចទេ។ វាមិនមែនមានន័យថាព្រះជាម្ចាស់មិនមានអំណាចដើម្បីធ្វើដូច្នេះទេ ប៉ុន្តែទ្រង់មិនមានដែនអំណាចគ្រប់គ្រងដើម្បីធ្វើដូច្នេះទេ។ ដើម្បីយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ យើងត្រូវមើលគម្ពីរហេប្រឺ ២:៦-៨។

*តែមានមនុស្សម្នាក់បានធ្វើបន្ទាល់ នៅកន្លែងណាមួយថា «តើមនុស្សជាអ្វី បានជាទ្រង់យកចិត្តទុកដាក់នឹងគេ ឬកូនមនុស្សបានជាទ្រង់ប្រោសដូច្នេះ ទ្រង់បានធ្វើឱ្យគេទាបជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ នឹងកេរ្តិ៍ឈ្មោះឱ្យ ទុកជាមកុដ ទ្រង់បានតាំងឡើងឱ្យត្រួតត្រាលើអស់ទាំងការនៃព្រះហស្តទ្រង់ ទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមជើងគេ» ហើយដែលទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នោះគឺមិនបានទុកអ្វី ដែលមិនចុះចូលសោះឡើយ តែសព្វថ្ងៃនេះ យើងមិនទាន់ឃើញគ្រប់ទាំងអស់ចុះចូលនៅឡើយទេ។*

— ហេប្រឺ ២:៦-៨

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ព្រះជាម្ចាស់បានផ្ដល់ឱ្យមនុស្សនូវដែនអំណាចគ្រប់គ្រងស្របច្បាប់ពេញលេញលើផែនដីទាំងមូល នៅពេលដែលទ្រង់ត្រូវមកនៅទីនេះ។ គ្មានអ្វីដែលមិនស្ថិតនៅក្រោមដែនអំណាចគ្រប់គ្រងរបស់ទ្រង់ទេ។ ទ្រង់បានគ្រប់គ្រងលើពិភពនេះដោយដែនអំណាចគ្រប់គ្រង និងសិទ្ធិអំណាចទាំងស្រុង។ សមត្ថភាពរបស់ទ្រង់ក្នុងការគ្រប់គ្រងជាមួយសិទ្ធិអំណាច ត្រូវបានគាំទ្រដោយរដ្ឋាភិបាលដែលបានកំណត់ឱ្យទ្រង់នៅទីនេះ។ សរុបមក ទ្រង់បានគ្រប់គ្រងដោយសិទ្ធិអំណាចដែលបានប្រគល់ឱ្យដោយព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់បានគ្រងមកុដនៃរដ្ឋាភិបាលនោះ ដែលតំណាងឱ្យសិរីរុងរឿងរបស់ព្រះជាម្ចាស់ ការចាក់ប្រេងតាំង និងតួនាទីដ៏មានកិត្តិយស ឬសិទ្ធិអំណាចដែលទ្រង់បានបង្កើត។

ពិតណាស់ ឥលូវនេះទ្រង់មិនបានគ្រងមកុដលោហៈពិតប្រាកដនោះទេ ប៉ុន្តែទ្រង់ពិតជាមានមកុដមួយមែន ក្នុងអត្ថន័យដែលមកុដនោះសំដៅលើ។ ដើម្បីទទួលបានការយល់យ៉ាងច្បាស់អំពីរឿងរ៉ាវនេះ សូមគិតទៅដល់ស្ដេចធម្មតាមួយអង្គ។ ទោះបីជាព្រះអង្គជាមនុស្សសាមញ្ញ ហើយមិនមានអំណាចពិតប្រាកដនៅក្នុងជាតិជាសាមញ្ញជនរបស់ទ្រង់ក៏ដោយ ទ្រង់គ្រងមកុដ ដែលមានន័យថា ទ្រង់មិនត្រឹមតែតំណាងឱ្យអង្គឯងប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់នគរ និងរដ្ឋាភិបាលទាំងមូល។ ព្រះបន្ទូលរបស់ព្រះអង្គមានសិទ្ធិអំណាចដោយសារតែពាក្យបន្ទូលទាំងនេះគាំទ្រដោយអំណាច និងធនធានធម្មជាតិទាំងអស់របស់រដ្ឋាភិបាល និងព្រះរាជ្យដែលទ្រង់តំណាង។

បើអ្នកគិតដល់តម្រួតបញ្ជាចរាចរណ៍ គាត់នឹងបញ្ឈប់រថយន្តសណ្ដោងរ៉ឺម៉កដ៏ធំមួយដោយនិយាយថា «ឈប់រថយន្តតាមច្បាប់កំណត់»។

មែនហើយ ឡានធុនធ្ងន់នេះមានទំហំធំជាងបុរសម្នាក់នោះខ្លាំងណាស់ ហើយគាត់តែម្នាក់ឯង មិនអាចទប់ទល់នឹងឡានបានទេ ប៉ុន្តែឡាននោះឈប់ មិនមែនដោយសារគាត់ទេ ប៉ុន្តែដោយសារផ្លាកសញ្ញាដែលគាត់ពាក់ ដែលតំណាងឱ្យរដ្ឋាភិបា

ល។ ក្នុងករណីនេះ រដ្ឋាភិបាលធំជាងបុរសដែលពាក់ផ្លាកសញ្ញាទៅទៀត។ ចំពោះអ្នកបើកបរឡានធុនធ្ងន់នេះវិញ គឺមិនមានអ្វីត្រូវខ្លាចបុរសនោះទេ ប៉ុន្តែមានការភ័យខ្លាចចំពោះរដ្ឋាភិបាលដែលបុរសម្នាក់នោះតំណាង ទើបធ្វើឱ្យអ្នកបើកបរនោះឈប់។

រឿងដូចគ្នានេះក៏មានពិតប្រាកដដែលនៅទីនេះ។ អដាំបានគ្រប់គ្រងលើអ្វីៗទាំងអស់ដែលត្រូវបានបង្កើតឡើងនៅក្នុងពិភពផែនដី។ ឫទ្ធានុភាព និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលបានតំណាងដោយមកុដនៃសិរីរុងរឿង និងកិត្តិយស បានផ្តល់ការធានាដល់មនុស្សថា ព្រះបន្ទូលទ្រង់បានធ្វើឡើងក្នុងនាមព្រះរាជ្យនៃព្រះជាម្ចាស់។

ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា នៅពេលដែលអដាំបាត់បង់សមត្ថភាពគ្រប់គ្រងលើផែនដីដោយប្រព្រឹត្តអំពើក្បត់ជាតិប្រឆាំងនឹងរាជរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ គាត់បានបាត់បង់មកុដរបស់គាត់ ឋានៈរបស់គាត់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ប៉ុន្តែគាត់មិនចុះចាញ់ក្នុងការទាមទារសិទ្ធិនៅលើផែនដីទេ។ បុរសរូបនេះនៅតែមានទំនួលខុសត្រូវលើផែនដី។ ព្រះជាម្ចាស់បានប្រទានវាដល់គាត់ដើម្បីគ្រប់គ្រង។ បើយើងត្រលប់ទៅអត្ថបទរបស់យើងជាភាសាហេប្រឺ យើងអាចឃើញរឿងនេះ។

*តែមានមនុស្សម្នាក់បានធ្វើបន្ទាល់ នៅកន្លែងណាមួយថា*
*«តើមនុស្សជាអ្វី បានជាទ្រង់យកចិត្តទុកដាក់នឹងគេ ឬកូនមនុស្សបានជាទ្រង់ប្រោសដូច្នេះ ទ្រង់បានធ្វើឱ្យគេទាបជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ នឹងកេរ្តិ៍ឈ្មោះឱ្យ ទុកជាមកុដ ទ្រង់បានតាំងឡើងឱ្យត្រួតត្រាលើអស់ទាំងការនៃព្រះហស្តទ្រង់ ទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមជើងគេ»*
*ហើយដែលទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នោះគឺមិនបានទុកអ្វី ដែល*<u>*មិន*</u>*ចុះចូលសោះឡើយ តែសព្វថ្ងៃនេះ យើងមិនទាន់ឃើញគ្រប់ទាំងអស់ចុះចូលនៅឡើយទេ។*

— ហេប្រឺ ២:៦-៨ (ពខប)

ទោះបីជាអត្ថបទនេះកំពុងនិយាយក្នុងពេលវេលាដែលអដាំ និងអេវ៉ាត្រូវបានបង្កើតឡើងក្ដី ក៏អត្ថបទបានបានចែងថា «នោះគឺមិនបានទុកអ្វី ដែលមិនចុះចូលសោះឡើយ»

*ផ្ទៃមេឃជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ តែព្រះអង្គប្រទានផែនដី**មកឱ្យមនុស្ស**លោក។*

— ទំនុកតម្កើង ១១៥:១៦ (គខប)

## មនុស្សបានបណ្ដេញព្រះជាម្ចាស់ចេញ

**នេះជាមូលហេតុដែលព្រះជាម្ចាស់ត្រូវប្រើមនុស្សដែលពោរពេញដោយព្រះវិញ្ញាណ ដើម្បីនាំបំណងព្រះហឫទ័យទ្រង់ចូលទៅក្នុងជីវិតមនុស្ស។**

ទោះបីជាមនុស្សមានដែនអំណាចគ្រប់គ្រងផ្លូវច្បាប់នៅលើផែនដីក៏ដោយ គេបានបាត់បង់សិទ្ធិអំណាចរបស់គេក្នុងការគ្រប់គ្រងខាងវិញ្ញាណ។ អ្វីដែលសំខាន់នោះ អដាំបានបណ្ដេញព្រះជាម្ចាស់ចេញពីកិច្ចការរបស់មនុស្សឱ្យត្រលប់ទៅកាន់សួនឧទ្យានវិញ។ ហើយនៅពេលមនុស្សធ្លាក់ក្នុងអំពើបាប ពិភពផែនដីបានប្រែជាល្អក់កករ និងប្រែប្រួលហើយ។ សេចក្ដីស្លាប់បានចូលក្នុងពិភពផែនដី ហើយតលូវនេះសាតាំងបានទាមទារសិទ្ធិឱ្យខ្លួនមានឥទ្ធិពលក្នុងកិច្ចការរបស់មនុស្ស។ ប៉ុន្តែទោះបីជាអ្វីៗទាំងអស់នេះបានកើតឡើងក៏ដោយ វាជាការចាំបាច់ដែលអ្នកត្រូវដឹងថាមនុស្សនៅតែជាអ្នកកាន់កាប់ផែនដីស្របច្បាប់។ ទោះស្ថិតក្នុងស្ថានភាពដួលរលំក៏មនុស្សនៅតែទទួលបន្ទុក។ ត្រូវហើយ គេលែងមានមកុដនៃរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ដើម្បីគាំទ្រគាត់ទៀតហើយ។ គេគ្មានសិទ្ធិគ្រប់គ្រងដោយឫទ្ធានុភាព និងសិរីរុងរឿងរបស់ព្រះជាម្ចាស់ទេ ហើយក៏បានបាត់បង់

មុខតំណែងកិត្តិយសផងដែរ។ ប៉ុន្តែគេនៅតែជាសត្វលោកតែមួយគត់ដែលមានសិទ្ធិស្របច្បាប់ក្នុងការគ្រប់គ្រងលើពិភពផែនដី។

នេះជាមូលហេតុដែលព្រះជាម្ចាស់ត្រូវប្រើមនុស្សដែលពោរពេញដោយព្រះវិញ្ញាណ ដើម្បីនាំបំណងព្រះហឫទ័យទ្រង់ចូលទៅក្នុងជីវិតមនុស្ស។ ដូចគ្នាដែរ សាតាំងប្រើអារក្សឱ្យមកបំផុសគំនិតមនុស្សដើម្បីធ្វើឱ្យប៉ះពាល់ដល់ពិភពផែនដីដើម្បីឆ្ពោះទៅរកផែនការរបស់វាសម្រាប់មនុស្ស។ គោលការណ៍នៃដែនអំណាចគ្រប់គ្រងរបស់មនុស្សនៅលើផែនដីនេះគឺសំខាន់ចំពោះការយល់ដឹងរបស់អ្នកអំពីច្បាប់នៃព្រះរាជ្យនៃព្រះជាម្ចាស់ ហើយជាពិសេសដឹងថាហេតុអ្វីបានជាតម្រូវឱ្យមានជំនឿដើម្បីឱ្យព្រះជាម្ចាស់ទទួលបានដែនអំណាចគ្រប់គ្រងស្របច្បាប់ក្នុងស្ថានភាពណាមួយ។

អ្នកអាចនិយាយថា «ប៉ុន្តែខ្ញុំបានគិតថាព្រះជាម្ចាស់ទ្រង់ជាម្ចាស់លើផែនដីនិងភាពពេញលេញនៅទីនោះ?» ពិតណាស់ ទ្រង់ជាម្ចាស់មែន។ ខ្ញុំសង្ឃឹមថាឧទាហរណ៍នេះនឹងជួយអ្នកឱ្យយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ។ ប្រសិនបើខ្ញុំជួលផ្ទះដែលខ្ញុំកាន់កាប់ឱ្យអ្នក ទោះបីខ្ញុំជាម្ចាស់ផ្ទះស្របច្បាប់ក៏ដោយ ខ្ញុំលះបង់សិទ្ធិស្របច្បាប់ក្នុងការចេញចូលរាល់ពេលណាដែលខ្ញុំចង់មកលេង។ នៅក្នុងការជួលភាគច្រើនមានឃ្លាមួយបញ្ជាក់ពីពេលវេលាម្ចាស់ផ្ទះជួលអាចចូលកន្លែងជួលដោយស្របច្បាប់ - ឧទាហរណ៍ ដើម្បីដោះស្រាយពេលមានអាសន្ន ឬជួសជុល - ហើយគេក៏ត្រូវការការជូនដំណឹងដែរ។ ប្រសិនបើខ្ញុំព្យាយាមចូលផ្ទះដោយខុសពីកិច្ចព្រមព្រៀងនេះ គេនឹងចាត់ទុកថាវាជាការគាស់ចូលហើយ ទោះបីខ្ញុំជាម្ចាស់កម្មសិទ្ធិក៏ដោយ។ ប្រសិនបើខ្ញុំបំពានច្បាប់ដូចមានចែងក្នុងកិច្ចសន្យាជួល នោះគេអាចបង្ខំខ្ញុំឱ្យចាកចេញដោយស្របច្បាប់ទោះខ្ញុំជាម្ចាស់ផ្ទះក៏ដោយ។

នេះបង្ហាញពីមូលហេតុដែលសាតាំងត្រូវឆ្លងកាត់អដាំដើម្បីចូលទៅកាន់កាប់ពិភពផែនដី។ មានតែអដាំទេដែលមានកូនសោ! សាតាំងត្រូវចូលតាមទ្វារ ហើយត្រូវ

អ្នកដែលកាន់កូនសោ ដោយស្របច្បាប់ប្រគល់កូនសោឱ្យ បើមិនដូច្នេះទេវានឹងត្រូវបណ្ដេញចេញដោយផ្លូវច្បាប់។

ដូចគ្នានេះដែរ ពេលអដាំបានបណ្ដេញរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ចេញពីពិភពផែនដី ព្រះជាម្ចាស់ត្រូវរកវិធីដើម្បីនាំរដ្ឋាភិបាលរបស់ទ្រង់ត្រលប់មកផែនដីវិញដោយស្របច្បាប់។ ជាថ្មីម្ដងទៀត ទ្រង់ត្រូវតែយាងមកតាមរយៈមនុស្ស។ ក្នុងករណីនេះនោះគឺជាបុរសម្នាក់ឈ្មោះអាប់រ៉ាម ជាអ្នកបានបើកទ្វារ។

> *ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖ «ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីញាតិសន្ដាន និងចាកចេញពីក្រុមគ្រួសារឪពុករបស់អ្នក តម្រង់ឆ្ពោះទៅស្រុកដែលយើងនឹងបង្ហាញអ្នក ។*
> *យើងនឹងឱ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក ហើយយើងនឹងឱ្យពរអ្នក។ យើងនឹងធ្វើឱ្យអ្នកមានឈ្មោះល្បី។ ដូច្នេះ ចូរធ្វើជាអ្នកផ្ដល់ពរដល់អ្នកដទៃចុះ! យើងនឹងឱ្យពរដល់ជនទាំងឡាយណាដែលឱ្យពរអ្នក យើងក៏នឹងដាក់បណ្ដាសាដល់ជនទាំងឡាយណា ដែលដាក់បណ្ដាសាអ្នកដែរ <u>ក្រុមគ្រួសារទាំងអស់នៅលើផែនដី នឹងបានទទួលពរដោយសារអ្នក</u>» ។*
>
> — លោកុប្បត្តិ ១២:១-៣ (គខប)

លោកអប្រាហាំត្រូវបានគេហៅថាជាឪពុកនៃជំនឿរបស់យើង ព្រោះគាត់គឺជាបុរសដែលបានបើកទ្វារនៃពិភពផែនដីដល់ព្រះជាម្ចាស់ ដែលគ្រប់ជាតិសាសន៍នៅលើផែនដីនឹងទទួលបានពរ។ ជាការពិតណាស់ នេះគឺជាការនិយាយអំពីព្រះយេស៊ូគ្រិស្ដ និងផែនការសង្គ្រោះរបស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិ។ ជំនឿរបស់អប្រាហាំបានបើកទ្វារផ្លូវច្បាប់ ដែលព្រះជាម្ចាស់បានបិទជាអចិន្ត្រៃយ៍ ដោយការធ្វើកិច្ចព្រមព្រៀងផ្លូវច្បាប់រវាងអប្រាហាំ និងទ្រង់ផ្ទាល់។ កិច្ចព្រមព្រៀងនេះក៏បានផ្សាភ្ជាប់នឹងពូជពង្សរបស់អប្រាហាំដែរ ហើយនេះជាន័យដែលមាននៅក្នុងគម្ពីរលោកុប្បត្តិ១២ ដែលព្រះ

គម្ពីរចែងថា «*<u>ក្រុមគ្រួសារទាំងអស់នៅលើផែនដី នឹងបានទទួលពរដោយសារអ្នក</u>*»។ «ទទួលបានពរដោយសារអ្នក» គឺសំដៅទៅលើព្រះយេស៊ូយាងមកតាមរយៈពូជពង្សរបស់អប្រាហាំ ហើយបានស្ដារឡើងវិញនូវអ្វីដែលអដាំបានបាត់បង់។

ដូច្នេះ ខ្ញុំសូមបកស្រាយនូវអ្វីដែលខ្ញុំកំពុងនិយាយ។ បុរស ឬស្ត្រីដែលមានដែនអំណាចគ្រប់គ្រងផ្លូវច្បាប់នៅក្នុងពិភពផែនដី ត្រូវតែស្ថិតក្នុងកិច្ចព្រមព្រៀងជាមួយស្ថានសួគ៌ ដើម្បីឱ្យស្ថានសួគ៌មានសិទ្ធិចូលទៅកាន់ពិភពក្រផែនដីដោយស្របច្បាប់។ គេបានហៅកិច្ចព្រមព្រៀងជាមួយស្ថានសួគ៌នេះថាជាជំនឿ។ នេះក៏ជាគោលការណ៍ដូចគ្នាដែលសាតាំងបានចូលទៅក្នុងពិភពផែនដីដោយស្របច្បាប់តាមរយៈបុរសម្នាក់ឈ្មោះអដាំដែលកាន់កូនសោ។

> *មារនាំព្រះអង្គ [ព្រះយេស៊ូ] ទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញនគរទាំងប៉ុន្មាននៅលើផែនដីឱ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឱ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឱ្យអ្នកណាក៏បាន ស្រេចតែនឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*
>
> — លូកា ៤:៥-៧ (គខប)

អ្នកអាចឃើញនៅក្នុងខគម្ពីរនេះ ដែលសាតាំងបានអះអាងថា អំណាច និងភាពរុងរឿង (ទ្រព្យសម្បត្តិ) នៃអាណាចក្រមនុស្ស ត្រូវបានប្រគល់ឱ្យវា ។ វាបានទាមទារសិទ្ធិអំណាចទាំងស្រុងលើផែនដី ដូចដែលវាទាក់ទងនឹងមនុស្សជាតិ។ ដូច្នេះ តើអ្នកណាបានផ្ដល់សិទ្ធិអំណាចនេះដល់វា? អ្នកដែលមានសិទ្ធិនោះគឺ អដាំ! ដូច្នេះ ព្រះជាម្ចាស់មិនអាចចេះតែចូលទៅក្នុងកិច្ចការរបស់មនុស្សដោយគ្មានច្រកចូលតាមផ្លូវច្បាប់

ទេ បើមិនដូច្នោះទេវានឹងខុសច្បាប់។ សាតាំងនឹងទាមទារដោយការលេងបន្លំ។ ទេ ព្រះជាម្ចាស់ត្រូវតែចូលតាមទ្វារដូចដែលសាតាំងបានធ្វើតាមរយៈបុរស ឬស្ត្រីលើផែនដី។

## ព្រះយេស៊ូមិនអាចប្រោសពួកគេឱ្យជាបាន - មេរៀនដ៏មានឥទ្ធិពលមួយត្រូវលាតត្រដាង

*ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតា គេមើលងាយព្យាការីតែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ»។* ***<u>នៅទីនោះព្រះអង្គពុំអាចធ្វើការអស្ចារ្យអ្វីឡើយ</u>*** *បានត្រឹមតែដាក់ព្រះហស្តលើអ្នកជំងឺខ្លះដើម្បីប្រោសគេឱ្យជាប៉ុណ្ណោះ។ ព្រះអង្គនឹកឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។*

— ម៉ាកុស ៦:៤-៦ (គខប)

ប្រសិនបើខ្ញុំសួរមនុស្សនៅតាមដងផ្លូវថា តើព្រះយេស៊ូអាចធ្វើអ្វីក៏បានមែនទេ ពួកគេប្រហែលជានិយាយថាទ្រង់អាចធ្វើបាន។ ប្រសិនបើខ្ញុំសួរថា តើមានកន្លែងណានៅក្នុងព្រះគម្ពីរដែលបញ្ជាក់ថាព្រះយេស៊ូបានព្យាយាម ប៉ុន្តែមិនអាចធ្វើការអស្ចារ្យ តើពួកគេនឹងនិយាយដូចម្តេច? ខ្ញុំសូមធានាថាពួកគេនឹងប្រាប់ខ្ញុំថា មិនមានកន្លែងបែបនេះនៅក្នុងព្រះគម្ពីរទេ។ ប៉ុន្តែអ្នកគ្រាន់តែបានអានគម្ពីរមួយប៉ុណ្ណោះ។ ព្រះយេស៊ូមិនអាចប្រោសពួកគេឱ្យជាបានទេ។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ខ្ញុំចង់ដឹងពីមូលហេតុ។ ចម្លើយគឺសាមញ្ញណាស់ ពោលគឺទ្រង់មិនអាច ហើយឥលូវនេះអ្នកដឹងពីមូលហេតុហើយ។ វាគឺដោយសារតែពួកគេគ្មានជំនឿ មានន័យថាគ្មានការព្រមព្រៀងជាមួយស្ថានសួគ៌ នោះស្ថានសួគ៌ក៏មិនមានដែនអំណាចគ្រប់គ្រងស្របច្បាប់ក្នុងស្ថានភាពនោះទេ។ ត្រូវប្រាកដថាអ្នកមានការយល់ដឹងច្បាស់លាស់អំពីអ្វីដែលយើងបានរកឃើញ។

## ស្ថានសួគ៌មិនមានដែនអំណាចគ្រប់គ្រងលើផែនដីទេ លុះត្រាតែចិត្តបុរស ឬស្ត្រីជឿជាក់យ៉ាងពេញលេញនូវអ្វីដែលស្ថានសួគ៌ចែង ដែលនេះហៅថា ជំនឿ។

ប្រសិនបើយើងត្រលប់ទៅសំណួរដែលខ្ញុំបានសួរនៅក្នុងផ្នែកដំបូងនៃជំពូកនេះអំពីការអធិស្ឋានដែលគ្មានការឆ្លើយតប នោះយើងអាចទទួលបានចម្លើយរបស់យើងឥលូវនេះ។ សូមចាំថា ខ្ញុំបានអធិប្បាយអំពីស្ថានភាពដែលអាចកើតមាន ដែលមនុស្សរាប់លាននាក់អាចអធិស្ឋានសម្រាប់នរណាម្នាក់ ហើយគេនឹងនៅតែស្លាប់។ ហេតុអ្វី? ជាថ្មីម្តងទៀត មូលហេតុចម្បងគឺគ្មានជំនឿ។ មនុស្សភាគច្រើនយល់ច្រឡំថាការអធិស្ឋានឮៗនោះជាការមានជំនឿហើយ។

> *ហើយកាលណាអធិស្ឋាន នោះកុំឱ្យពោលពាក្យឥតប្រយោជន៍ផ្ទួនៗ ដូចពួកសាសន៍ដទៃឡើយ ដ្បិតគេស្មានថា ព្រះទ្រង់នឹងស្តាប់គេ ដោយគេពោលពាក្យជាច្រើន ដូច្នេះ កុំឱ្យអ្នករាល់គ្នាធ្វើដូចគេឡើយ ដ្បិតព្រះវរបិតានៃអ្នកទ្រង់ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ មុនដែលអ្នកសូមផង។*
>
> — ម៉ាថាយ ៦:៧-៨ (ពខប)

មនុស្សជាច្រើនជឿថា មនុស្សអធិស្ឋានកាន់តែច្រើន នោះឱកាសកាន់តែច្រើនដែលព្រះជាម្ចាស់អាចស្តាប់ឮ និងអាចចូលមកជួយសង្គ្រោះ។ ខ្ញុំសង្ឃឹមថាយើងបានបញ្ជាក់គ្រប់គ្រាន់ហើយនៅពេលនេះ ដែលល្មមឱ្យអ្នកដឹងថា ការនេះមិនពិតទាំងស្រុង។ ជាដំបូង នៅពេលដែលយើងនិយាយថាគ្មានជំនឿ យើងកំពុងនិយាយអំពីមនុស្សម្នាក់ដែលត្រូវតែទទួលពីព្រះជាម្ចាស់ដោយមានជំនឿ។

នៅក្នុងរឿងរបស់យើងនៅក្នុងគម្ពីរម៉ាកុសជំពូកទី៦ អ្នកនឹងត្រូវយល់ស្របថាព្រះយេស៊ូមានជំនឿច្រើន ប៉ុន្តែទ្រង់នៅតែមិនអាចប្រោសពួកគេឱ្យជាបាន។ ដូច្នេះប្រសិនបើអ្នក និងខ្ញុំកំពុងនិយាយអំពីមិត្តមានជំងឺម្នាក់ ព្រមទាំងអ្នកអធិស្ឋានរាប់លាននាក់ ខ្ញុំនឹងសួរអ្នកថា «តើអ្នកជំងឺកំពុងនិយាយពាក្យអធិស្ឋានអ្វីខ្លះ?» អ្នកឃើញ

ទេ គ្មាននរណាម្នាក់មានសិទ្ធិអំណាចខាងវិញ្ញាណលើមនុស្សម្នាក់ទៀតបានទេ។ យើងអាចមានមនុស្ស ២០ ពាន់លាននាក់អធិស្ឋានសម្រាប់នរណាម្នាក់ ប៉ុន្តែប្រសិនបើមនុស្សនោះមិនមានជំនឿ ហើយនិយាយថាពួកគេនឹងស្លាប់ ពួកគេនឹងស្លាប់។

ម្តងទៀត សូមពិចារណាលើឧទាហរណ៍របស់យើងដែលទើបតែបានមើលនៅក្នុងគម្ពីរម៉ាកុស ជំពូក៦។ យើងដឹងថាព្រះយេស៊ូត្រូវមានជំនឿដើម្បីប្រោសឱ្យជា ប៉ុន្តែទ្រង់មិនអាចធ្វើអ្វីបានចំពោះមនុស្សដែលគ្មានជំនឿនៅក្នុងខ្លួនឡើយ។

មានមនុស្សជាច្រើនមករកខ្ញុំដោយប្រាប់ថា ជីដូន ឬជីតា ឬសាច់ញាតិរបស់ពួកគេឈឺ ហើយនិយាយថាពួកគេបានអធិស្ឋានឱ្យពួកគាត់ ប៉ុន្តែនៅតែមិនមានអ្វីកើតឡើង។ ខ្ញុំតែងតែសួរថា «តើជីដូនកំពុងនិយាយពាក្យអធិស្ឋានអ្វីខ្លះ? តើជីតាកំពុងនិយាយពាក្យអធិស្ឋានអ្វីខ្លះ? តើមានជំនឿក្នុងពាក្យនិយាយនោះទេ?» ឃើញទេ អ្នកមិនមានសិទ្ធិអំណាចខាងវិញ្ញាណលើអ្នកផ្សេងទេ។ អ្នកអាចធ្វើព័ន្ធកិច្ចចំពោះពួកគេបាន ប៉ុន្តែពួកគេត្រូវតែចូលរួមជាមួយការនោះដោយខ្លួនឯង។ ដូច្នេះអ្វីដែលខ្ញុំប្រាប់ពួកគេថា ពួកគេត្រូវតែធ្វើ ប្រសិនបើពួកគេចង់ឃើញព័ន្ធកិច្ចដ៏មានប្រសិទ្ធភាព គឺត្រូវផ្លាស់ប្តូររូបភាពជាមុនសិន។ ខ្ញុំកំពុងនិយាយអំពីរូបភាពដែលអ្នកជំងឺឃើញអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ចូរកុំផ្តល់ឱ្យពួកគេនូវសម្រង់សាសនាច្រើនពេក ផ្តល់ឱ្យពួកគេជារូបភាពវិញ។ ខ្ញុំសូមបង្ហាញអ្នកពីអ្វីដែលខ្ញុំកំពុងនិយាយ។

> *សិស្សរបស់លោកយ៉ូហានបានរៀបរាប់ជូនលោកនូវហេតុការណ៍ទាំងអស់នោះ។ លោកយ៉ូហានក៏ហៅសិស្សពីរនាក់មក រួចចាត់ឱ្យទៅទូលសួរព្រះយេស៊ូជាអម្ចាស់ថា៖ «តើលោកជាព្រះគ្រិស្តដែលត្រូវយាងមក ឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។ អ្នកទាំងពីរទៅដល់ ទូលសួរព្រះយេស៊ូថា៖ «លោកយ៉ូហានបាទីស្តចាត់ឱ្យយើងខ្ញុំមកសួរលោកថា តើលោកជាព្រះគ្រិស្តដែលត្រូវយាងមក ឬមួយក៏យើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។*

*នៅគ្រានោះ ព្រះយេស៊ូកំពុងប្រោសអ្នកជំងឺ មនុស្សពិការ និងមនុស្សដែលមានវិញ្ញាណអាក្រក់នៅក្នុងខ្លួនឱ្យជា។ ព្រះអង្គក៏បានប្រោសមនុស្សខ្វាក់ជាច្រើនឱ្យមើលឃើញដែរ។ ព្រះអង្គមានព្រះបន្ទូលទៅសិស្សទាំងពីរនាក់នោះថា៖ «ចូរអ្នកទៅជម្រាបលោកយ៉ូហាននូវហេតុការណ៍ ដែលអ្នករាល់គ្នាបានឃើញ និងបានឮ គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ មនុស្សថ្លង់ស្ដាប់ឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយគេនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។*

— លូកា ៧:១៨-២២ (គខប)

សូមកត់សម្គាល់ថា ព្រះយេស៊ូមិនបានសំដៅទៅលើបទគម្ពីរទេ។ ទ្រង់គួរមានបន្ទូលថា៖ «ចូរអ្នកទៅជម្រាបលោកយ៉ូហានពីបទគម្ពីរនេះ ឬពីបទគម្ពីរនោះចុះ»។ ប៉ុន្តែមិនមែនទេ ទ្រង់បានប្រាប់គេអំពីរឿងល្អៗទាំងអស់ដែលកើតឡើងដោយព្រះរាជ្យរបស់ព្រះជាម្ចាស់។ អ្នកនឹងធ្វើដូចគ្នា។ ចូរប្រាប់មិត្តភក្ដិរបស់អ្នកដែលមានជំងឺនូវរឿងមួយអំពីរបៀបដែលព្រះយេស៊ូបានប្រោសអ្នកផ្សេងឱ្យជា។ បើអាចធ្វើបាន ចូរប្រាប់ពួកគេនូវរឿងមួយអំពីមនុស្សម្នាក់ដែលបានជាសះស្បើយពីជំងឺដូចគ្នានឹងជំងឺកំពុងតែប៉ះពាល់ដល់រាងកាយរបស់ពួកគេ។ រូបភាពនេះនឹងជំរុញទឹកចិត្តពួកគេ និងនាំមកនូវក្ដីសង្ឃឹម។ ក្ដីសង្ឃឹមតែងតែនាំមកនូវរូបភាពមកជាមួយ ហើយនេះជារូបភាពដែលអ្នកចង់ឱ្យមិត្តអ្នកឃើញ ថាមានការប្រោសឱ្យជាពីជំងឺនោះ។

នៅពេលដែលមិត្តរបស់អ្នកឃើញថាវាអាចធ្វើឱ្យជាសះស្បើយបាន ពួកគេនឹងសួរអ្នកពីរបៀបដែលវាអាចទៅរួចបែបនេះ។ នេះគឺជាពេលដែលអ្នកបានទន្ទឹងរង់ចាំ។ ជំនួសឱ្យការអធិប្បាយទៅកាន់ពួកគេ ឥលូវនេះ ពួកគេកំពុងបើកចំហទទួលការណែនាំអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងគោលការណ៍នៃព្រះព្រះរាជ្យនៃព្រះ។ ទីមួយ អ្នកនឹងចង់នាំពួកគេចូលទៅក្នុងព្រះរាជ្យនៃព្រះ ប្រសិនបើពួកគេមិនបានកើតជាថ្មី។ ហើយទីពីរ អ្នកនឹងត្រូវចំណាយពេលវេលាខ្លះៗជាមួយពួកគេដើម្បីពន្យល់បទគម្ពីរ

ទាក់ទងនឹងការប្រោសឱ្យជា។ បើអាច សូមទុកឱ្យពួកគេនូវធនធានមួយចំនួន ដើម្បីពង្រឹងអ្វីដែលអ្នកបានប្រាប់ពួកគេ។

ឥលូវនេះយើងដឹងថាអ្វីជាជំនឿ (កិច្ចព្រមព្រៀងជាមួយស្ថានសួគ៌) ហើយនិងមូលហេតុដែលគេតម្រូវឱ្យមានជំនឿដោយស្របច្បាប់ ប៉ុន្តែយើងនៅតែត្រូវដឹងពីរបៀបទទួលបានជំនឿ និងរបៀបដឹងថាយើងស្ថិតក្នុងជំនឿហើយ។

## តើយើងទទួលបានជំនឿដោយរបៀបណា?

*ដូច្នេះ ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ត។*

— រ៉ូម ១០:១៧ (គខប)

តើជំនឿកើតឡើងដោយការឮព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច? តើមានដំណើរការអ្វីខ្លះ? តើគ្រាន់តែការស្តាប់ព្រះបន្ទូល ជាអ្វីដែលវាត្រូវការដើម្បីឱ្យជំនឿកើតឡើងនៅក្នុងវិញ្ញាណរបស់មនុស្សឬ? ដើម្បីយល់ពីរបៀបដែលសេចក្តីជំនឿកើតឡើង និងអ្វីដែលគម្ពីររ៉ូម ១០:១៧ កំពុងចែង យើងអាចមើលគម្ពីរម៉ាកុស ជំពូកទី៤។ ខ្ញុំតែងតែនិយាយថា ប្រសិនបើអ្នកបោះព្រះគម្ពីររបស់អ្នកឡើងទៅលើ វាគួរតែធ្លាក់មកវិញដោយបើកដល់គម្ពីរម៉ាកុស ជំពូកទី៤។ វាសំខាន់ណាស់! ព្រះយេស៊ូបានមានបន្ទូលនៅក្នុងគម្ពីរម៉ាកុស ៤:១៣ ថា បើអ្នកមិនយល់នូវអ្វីដែលទ្រង់កំពុងបង្រៀនក្នុងជំពូកនោះ នោះអ្នកនឹងមិនអាចយល់រឿងអប់រំផ្សេងៗក្នុងព្រះគម្ពីរបានឡើយ។ ខ្ញុំចង់និយាយថា វាសំខាន់ណាស់!

*ដូច្នេះ ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ត ។*
រ៉ូម ១០:១៧ (គខប)

ហេតុអ្វីជំពូកនេះសំខាន់ម្ល៉េះ? ព្រោះវាប្រាប់យើងពីរបៀបដែលស្ថានសួគ៌ទាក់ទងជាមួយពិភពផែនដី របៀបដែលស្ថានសួគ៌ទទួលបានដែនអំណាចគ្រប់គ្រង និងកន្លែងដែលកើតឡើង។ គ្មានអ្វីសំខាន់សម្រាប់ជីវិតរបស់អ្នកជាងការដឹងថាជំពូកទាំងមូលនេះកំពុងនិយាយអំពីអ្វីនោះទេ។

នៅក្នុងជំពូកនេះ ព្រះយេស៊ូប្រាប់យើងនូវប្រស្នាចំនួនបី ទាក់ទងនឹងរបៀបដែលជំនឿត្រូវបានបង្កើតនៅក្នុងវិញ្ញាណរបស់មនុស្ស ដូចដែលអ្នកបានដឹងតលូវនេះថា វាគឺជាតម្រូវការសម្រាប់ស្ថានសួគ៌ដើម្បីលុកលុយចូលផែនដីដោយស្របច្បាប់។ រឿងទាំងបីក្នុងជំពូកនេះ គឺប្រស្នាអំពីអ្នកព្រោះស្រូវ ប្រស្នាអំពីបុរសដែលព្រោះគ្រាប់ពូជ និងគ្រាប់ពូជល្អិត។ សូមចាប់ផ្ដើមដោយមើលរឿងទីពីរដែលព្រះយេស៊ូមានបន្ទូលក្នុងគម្ពីរម៉ាកុសជំពូកទី៤ ជារឿងរបស់បុរសដែលសាបព្រោះគ្រាប់ពូជ។

> *ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាបុរសម្នាក់ព្រោះស្រូវ នៅក្នុងស្រែរបស់ខ្លួន។ ទោះបីគាត់ដេកក្ដី ក្រោកក្ដី យប់ក្ដី ថ្ងៃក្ដី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ ដ្បិតដីធ្វើឱ្យពូជបង្កើតផលដោយខ្លួនឯង ដំបូងមានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ។ លុះស្រូវទុំ គេយកកណ្ដៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ»។*
>
> —ម៉ាកុស ៤:២៦-២៩ (គខប)

រឿងដំបូងដែលយើងត្រូវធ្វើគឺ ឱ្យនិយមន័យពាក្យរបស់យើង។ តើព្រះយេស៊ូកំពុងនិយាយអំពីគ្រាប់ពូជអ្វី ហើយអ្វីទៅជាដី? តាមពិត ព្រះយេស៊ូបង្ហាញន័យពាក្យទាំងពីរនេះ នៅផ្នែកខាងមុខនៃប្រស្នាអំពីអ្នកព្រោះស្រូវនេះ គឺនៅក្នុងជំពូកតែមួយ។ គ្រាប់ពូជគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដីគឺជាបេះដូងរបស់មនុស្ស ឬជាវិញ្ញាណរបស់មនុស្ស។

ដូច្នេះ ក្នុងរឿងអប់រំនេះ ព្រះយេស៊ូមានបន្ទូលថា បុរសម្នាក់សាបព្រោះព្រះបន្ទូលរបស់ព្រះជាម្ចាស់មកក្នុងចិត្តគាត់។ បន្ទាប់មក ដី ឬបេះដូងរបស់បុរសម្នាក់នោះក៏ចាប់ផ្តើមបង្កើតជំនឿ ឬកិច្ចព្រមព្រៀងជាមួយស្ថានសួគ៌។ ឥលូវនេះ វាជាដំណើរការ និងមុខងារធម្មជាតិនៃវិញ្ញាណរបស់អ្នក។ វានឹងរីកលូតលាស់ក្លាយជាអ្វីដែលអ្នកបានដាំនៅទីនោះ។ មុនពេលខ្ញុំនិយាយឆ្ពោះទៅមុខបន្តទៀត វាជារឿងសំខាន់ដែលអ្នកត្រូវចាំពីនិយមន័យរបស់យើងអំពីជំនឿ៖ បេះដូងរបស់បុរស ឬស្ត្រីដែលជឿជាក់យ៉ាងមុតមាំនូវអ្វីដែលស្ថានសួគ៌និយាយ។ ឥលូវនេះ រឿងដ៏លំបាកក្នុងការចងចាំនៅត្រង់នេះគឺ សេចក្តីព្រមព្រៀងជាមួយស្ថានសួគ៌ មិនមែនជារឿងដូចគ្នាទៅនឹងការយល់ស្របផ្លូវចិត្តជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះទេ។ ព្រះគម្ពីរចែងថា លោកអប្រាហាំជឿជាក់ទាំងស្រុង។

## ការជឿជាក់យ៉ាងពេញលេញ

ដើម្បីជួយអ្នកឱ្យទទួលបានរូបភាពច្បាស់លាស់ថាតើការជឿជាក់យ៉ាងពេញលេញមានរូបរាង និងអារម្មណ៍យ៉ាងដូចម្តេច និយាយទៅអីចេះ ខ្ញុំបានប្រាប់អ្នកឱ្យលោតពីលើកំពូលនៃអគារ Empire State ក្នុងទីក្រុងញូវយ៉ក។ ដើម្បីបញ្ចុះបញ្ចូលអ្នកឱ្យសាកល្បង ខ្ញុំបានប្រាប់អ្នកថា បើអ្នកលាដៃសន្ទឹងខ្លាំងល្មម អ្នកអាចហើរចុះមកផែនដីដោយសុវត្ថិភាព។ អ្នកនឹងសើចចំពោះមុខខ្ញុំ ព្រោះអ្នកដឹងថានឹងមានអ្វីកើតឡើងចំពោះអ្នក។ អ្នកជឿជាក់យ៉ាងពេញលេញពីលទ្ធផលនេះ។ នោះហើយគឺជាអារម្មណ៍ដែលមាន ពេលជឿជាក់យ៉ាងពេញលេញ។ អ្នកដឹងថាខ្លួនជឿជាក់យ៉ាងច្បាស់។ គឺមិនមានលទ្ធភាពផ្សេងទៀតទេ។ អ្នកនឹងស្លាប់ប្រសិនបើអ្នកលោត។

តោះមកមើលស្ថានភាពមួយទៀត និងមើលពីរបៀបដែលអ្នកធ្វើជាមួយវា។ ចូរសន្មតថាអ្នកមានដុំពកធំមួយដែលអាចមើលឃើញយ៉ាងច្បាស់នៅលើរាងកាយរបស់អ្នក ហើយគ្រូពេទ្យនិយាយថាអ្នកមានជីវិតរស់ប្រហែលមួយខែ ពោលគឺអ្នកមានជំងឺមហារីក។ តាមពិតទៅ វេជ្ជបណ្ឌិតនិយាយថា ទម្រង់នៃជំងឺមហារីករបស់អ្នកកម្រ

ណាស់ ដែលមិនមានអ្នកណាម្នាក់ធ្លាប់ធ្វើរោគវិនិច្ឆ័យឃើញរោគបែបនោះបានទេ។ ឥលូវនេះ ចូរសន្មតថាអ្នកដឹងពីអ្វីដែលគម្ពីរ ១ពេត្រុសទី ១:២៤ ចែង។

*ព្រះគ្រិស្តបានផ្ទុកបាបរបស់យើងក្នុងព្រះកាយរបស់ព្រះអង្គដែលជាប់លើឈើឆ្កាង ដើម្បីឱ្យយើងលែងជំពាក់ជំពិននឹងបាបតទៅមុខទៀត ហើយឱ្យយើងមានជីវិតដោយប្រព្រឹត្តតែអំពើសុចរិត។ បងប្អូនបានជាសះស្បើយដោយសារស្នាមរបួសរបស់ព្រះអង្គ។*

— ១ពេត្រុស ២:២៤ (គខប)

បទគម្ពីរនេះប្រាប់យើងនូវចម្លើយ ប៉ុន្តែអ្នកនិងខ្ញុំមានបញ្ហាធ្ងន់ធ្ងរមួយ។ យើងធំឡើងនៅក្នុងអាណាចក្រនៃសេចក្តីងងឹត ហើយភាពច្របូកច្របល់ និងសេចក្តីស្លាប់ស្ថិតនៅជុំវិញពួកយើង។ យើងបានធំឡើងក្នុងអាណាចក្រនៃភាពភ័យខ្លាចដោយបានជឿជាក់យ៉ាងពេញលេញនូវអ្វីដែលភាពភ័យខ្លាចនិយាយ។ ដូច្នេះ ក្នុងស្ថានភាពខាងលើ គេបង្រៀនយើងថា ជំងឺមហារីកអាចសម្លាប់មនុស្សបាន។ យើងមានភស្តុតាងនៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយដែលថានេះជាការពិត។ ដូច្នេះ តើយើងនឹងផ្លាស់ប្តូរនូវការយល់ស្របនេះដោយរបៀបណា? តើយើងអាចជឿជាក់យ៉ាងពេញលេញនូវអ្វីដែលព្រះមានបន្ទូលដោយរបៀបណា? ជាក់ស្តែង យើងមិនអាចធ្វើវាទៅបានដោយខ្លួនឯងទេ។ ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់មានព្រះជន្មគង់នៅ ហើយពោរពេញដោយឫទ្ធានុភាព ហើយដោយការដាក់វាចូលក្នុងវិញ្ញាណរបស់អ្នក នោះវិញ្ញាណរបស់អ្នកនិងព្រះបន្ទូល ចាប់ផ្តើមបង្កើតការព្រមព្រៀងជាមួយនឹងអ្វីដែលស្ថានសួគ៌បាននិយាយ។

## កិច្ចព្រមព្រៀងជាមួយស្ថានសួគ៌

*ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាបុរសម្នាក់ព្រោះស្រូវ នៅក្នុងស្រែរបស់ខ្លួន។ ទោះបីគាត់ដេកក្តី ក្រោកក្តី យប់*

*ក្តី ថ្ងៃក្តី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ ដ្បិតដីធ្វើឱ្យពូជបង្កើតផលដោយខ្លួនឯង ដំបូងមានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ។ លុះស្រូវទុំ គេយកកណ្តៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ»។*

— ម៉ាកុស ៤:២៦-២៩ (គខប)

ដី (ដួងចិត្តរបស់អ្នក) បង្កើតកិច្ចព្រមព្រៀងដោយខ្លួនឯង។ ចូរសម្គាល់ថាអ្នកមិនអាចអធិស្ឋានឱ្យមានជំនឿបានទេ។ វាជាមុខងាររបស់បេះដូងរបស់អ្នក និងព្រះបន្ទូល។ នៅពេលយើងក្រឡេកមើលអត្ថបទនេះ យើងអាចឃើញថាការព្រមព្រៀងនៃបេះដូងរបស់យើងជាមួយនឹងស្ថានសួគ៌គឺជាដំណើរការមួយ វាមិនកើតឡើងភ្លាមៗទេ។

ស្ថានភាពនេះប្រាប់យើងថា ដំបូងឡើយ ពេលចិត្តយើងទទួលព្រះបន្ទូល នោះជំនឿក៏ចាប់ផ្តើមដុះឡើង ដូចជាត្រួយ ឬពន្លកនៃគ្រាប់ពូជដែលទើបនឹងដាំដុះឡើង។ វាបន្តរីកលូតលាស់ក្លាយជាដើម ហើយបន្ទាប់មកវាបង្កើតជាក្បាល។ ក្បាលគឺជាកន្លែងដែលគ្រាប់ពូជ ឬផ្លែឈើចាប់ផ្តើមមានរូបរាងឡើង។ នៅដំណាក់កាលជីវិតរបស់រុក្ខជាតិនេះ អ្នកនៅតែមិនមានអ្វីបរិភោគទេ។ រុក្ខជាតិនេះនៅមិនទាន់បង្កើតបានផ្លែចាស់ ឬផ្លែទុំនៅឡើយទេ ប៉ុន្តែវាកំពុងលូតលាស់។

ដូច្នេះ វានៅជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅមិនទាន់មានការផ្លាស់ប្តូរដែលអាចមើលឃើញនៅឡើយទេនៅក្នុងពិភពធម្មជាតិ នៅពេលជំនឿកំពុងរីកលូតលាស់។ មិនទាន់មានការព្រមព្រៀងគ្នានៅឡើយទេ ប៉ុន្តែគេធានាថារុក្ខជាតិនេះកំពុងរីកលូតលាស់ ជំនឿកំពុងត្រូវគេបង្កើតឡើង ហើយកិច្ចព្រមព្រៀងនឹងកើតមានឡើង។ ព្រះយេស៊ូពន្យល់បន្តថា កាលណាគ្រាប់នៅក្នុងក្បាលចាស់ ឬទុំ នោះរដូវច្រូតបានមកដល់ហើយ នោះកិច្ចព្រមព្រៀងក៏មាននៅទីនោះ ហើយឥលូវនេះ ជំនឿក៏មាននៅទីនោះដែរ។

ដូច្នេះ នេះជាការយល់ឃើញ។ នៅពេលអ្នកដាំគ្រាប់ពូជនៅក្នុងដី តាមរយៈដំណើរការធំធាត់បែកមែកសាខា រុក្ខជាតិចាប់ផ្តើមរីកលូតលាស់ ប៉ុន្តែមិនទាន់មានផ្លែនៅឡើយទេ។ រុក្ខជាតិនៅបន្តលូតលាស់ដរាបណាវាស្ថិតនៅក្នុងបរិយាកាសត្រឹមត្រូវ ហើយពេលវាពេញវ័យ វានឹងដុះពន្លកផ្លែរបស់វាចេញមក។ ឧបមាថាអ្នកកំពុងដាំពោត។ ដើមពោតដុះពន្លកចេញជាស្នៀតពោត ប៉ុន្តែដំបូងវាគ្រាន់តែជាស្នៀតពោតដ៏តូចប៉ុណ្ណោះ ដែលគ្មានពោតទុំដែលអ្នកអាចបរិភោគបានទេ។ ប៉ុន្តែបន្ទាប់ពីមួយរដូវ គ្រាប់ពោត ក្លាយជាគ្រាប់ចាស់ទុំ។ ឥលូវមកចាប់ចំណុចនេះឱ្យបាន! នៅពេលគ្រាប់ពោតនៅនឹងស្នៀតពោតរីកធំប៉ុនគ្រាប់ពោតដែលត្រូវបានសាបព្រោះទៅក្នុងដី នោះមានការព្រមព្រៀងគ្នាហើយ។

## នៅពេលដែលគ្រាប់ពូជនៅក្នុងពន្លករបស់រុក្ខជាតិលូតលាស់ធំទៅ វានឹងមើលទៅដូចគ្នា ដូចគ្នាបេះបិទ ទៅនឹងគ្រាប់ពូជដែលត្រូវបានសាបព្រោះ។

ចូរដាំដំណាំពោត ហើយគ្រាប់ពូជទុំនៅក្នុងស្នៀតពោត នឹងត្រូវគ្នានឹងគ្រាប់ពូជដែលអ្នកបានដាំ។ ពួកវាគឺដូចគ្នា។ ពួកវាមើលទៅដូចគ្នា និងមានរសជាតិដូចគ្នា អ្នកមិនអាចបែកចែកពួកវាពីគ្នាបានទេ។

ដូច្នេះ ខ្ញុំសូមបកស្រាយនូវអ្វីដែលព្រះយេស៊ូកំពុងមានបន្ទូល។ នៅពេលដែលយើងឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ (រ៉ូម ១០:១៧) យើងពិតជាកំពុងសាបព្រោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលទៅក្នុងព្រលឹងវិញ្ញាណរបស់យើង ដួងចិត្តរបស់យើង។ ប្រសិនបើយើងរក្សាព្រះបន្ទូលនោះនៅក្នុងចិត្តរបស់យើង នោះវានឹងរីកចម្រើន ហើយមានភាពចាស់ទុំ។ ហើយនៅពេលដែលវាមានភាពចាស់ទុំ ចិត្តរបស់យើងនឹងជឿជាក់យ៉ាងពេញលេញនូវអ្វីដែលស្ថានសួគ៌បាននិយាយ។ ស្ថានសួគ៌ និងផែនដីត្រូវគ្នា ហើយឥលូវនេះស្ថានសួគ៌បានទទួលដែនអំណាចគ្រប់គ្រងស្របច្បាប់នៅក្នុងពិភពផែនដីហើយ តាមរយៈបុគ្គលដែលបានជឿជាក់យ៉ាងពេញលេញ។ គំនិត និងជំនឿ

របស់យើងពិតជាត្រូវគ្នានឹងអ្វីដែលស្ថានសួគ៌និយាយដោយទំនុកចិត្តខ្ពស់។ នេះមិនមែនជារឿងផ្លូវចិត្តទេ។ ឥលូវនេះ វាបានក្លាយជាអ្វីដែលយើងជឿជាក់យ៉ាងពិតប្រាកដ ដូចដែលយើងជឿថា បើយើងទម្លាក់ថ្ម នោះវានឹងធ្លាក់ចុះក្រោម។ ស្ថានសួគ៌សាបព្រោះព្រះបន្ទូលទៅក្នុងពិភពផែនដី ដែលជាទីវានឹងនាំមកនូវសេចក្តីព្រមព្រៀង និងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ប្រសិនបើស្ថានសួគ៌ប្រាប់ថាអ្នកត្រូវបានប្រោសឱ្យជាសះស្បើយហើយ នោះនៅពេលដែលព្រះបន្ទូលនោះរីកដុះដាលនៅក្នុងចិត្តរបស់អ្នកហើយ អ្វីដែលអ្នកនឹងឃើញគឺ អ្វីដែលស្ថានសួគ៌និយាយ។ គ្មានការភ័យខ្លាចទៀតទេ។ ពេលបិទភ្នែក អ្នកនឹងឃើញខ្លួនឯងជាសះស្បើយ! នេះជាមូលហេតុដែលគម្ពីរហេប្រឺ ១១:១ (ពខប) ចែងថា៖

> *រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថា នឹងបានដូចសង្ឃឹម ជាសម្គាល់ពីការដែលមើលមិនឃើញ។*

អ្នកប្រហែលជាមិនទាន់ឃើញវានៅក្នុងធម្មជាតិនៅឡើយទេ ប៉ុន្តែអ្នកបានឃើញវានៅក្នុងស្មារតីរបស់អ្នក ហើយវាប្រៀបដូចជាការពិតដូចដែលអ្នកកំពុងមានវានៅក្នុងដៃរបស់អ្នកដូច្នោះដែរ។ កិច្ចព្រមព្រៀងនោះត្រូវបានគេហៅថាជំនឿ ហើយជំនឿនោះនឹងនាំរូបភាពនោះឱ្យឆ្លងកាត់ទីនេះ ចូលទៅក្នុងពិភពផែនដី ក្នុងជីវិតរបស់អ្នក!

## ការចុចកុងតាក់

ប៉ុន្តែនៃ៎ នេះមិនមែនជាកន្លែងដែលគម្ពីរម៉ាកុសជំពូកបួនបញ្ចប់នោះទេ។ បន្ទាប់ពីចំណុចនេះបង្រៀនយើងពីរបៀបដែលចិត្តរបស់យើងចុះសម្រុងនឹងស្ថានសួគ៌ ហើយត្រូវមានជំនឿ វាផ្តល់ឱ្យយើងនូវការណែនាំអំពីរបៀបប្រមូលផលផងដែរ។

> *លុះស្រូវទុំ **គេយកកណ្តៀវមកច្រូត** ដ្បិតដល់រដូវចម្រូតហើយ។*
>
> — ម៉ាកុស ៤:២៩ (គខប)

សូមសម្គាល់ថា ទោះបីដួងចិត្តចុះសម្រុងនឹងស្ថានសួគ៌ក៏ដោយ ហើយក៏មានជំនឿទៀត ក៏មិនមានអ្វីកើតឡើងនៅឡើយដែរ។ ហេតុអ្វី? ដូចដែលយើងបាននិយាយរួចមកហើយថា អ្នកមានដែនអំណាចគ្រប់គ្រងស្របច្បាប់នៅទីនេះនៅក្នុងពិភពផែនដី។ តើអ្នកចាំការពិភាក្សារបស់យើងនៅក្នុងគម្ពីរលូកា ជំពូក៨ អំពីស្ត្រីដែលមានបញ្ហាធ្លាក់ឈាមទេ? តើអ្នកនៅចាំដែលព្រះយេស៊ូមានបន្ទូលថា «កូនស្រី ជំនឿរបស់កូនបានប្រោសកូនឱ្យបានជាសះស្បើយ» ឬទេ? ខ្ញុំបានប្រាប់អ្នកថា កូនស្រីនោះបានសន្និដ្ឋានដោយឈរនៅចំពោះមុខស្ថានសួគ៌យ៉ាងស្របច្បាប់ថា ដោយសារតែគាត់ជាកូនស្រីរបស់អប្រាហាំ គាត់មានសិទ្ធិស្របច្បាប់។

**អ្នកត្រូវតែបញ្ចេញអំណាចនៃព្រះរាជរបស់ព្រះជាម្ចាស់នៅទីនេះក្នុងពិភពផែនដី ព្រោះមានតែអ្នក ទាំងបុរស ឬស្ត្រីនៅលើផែនដីប៉ុណ្ណោះ ដែលអាចធ្វើវាបានដោយស្របច្បាប់។**

ខ្ញុំបានប្រៀបធៀបវាទៅនឹងខ្សែភ្លើងពីរោងចក្រអគ្គិសនីភ្ជាប់ទៅផ្ទះរបស់អ្នក។ វាមានថាមពល នៅទីនោះ និងអាចប្រើបាន ប៉ុន្តែអ្នកខ្លួនឯងនៅតែត្រូវបើកភ្លើងដោយផ្ទាល់។ នេះជារឿងដូចគ្នា។ នៅពេលដែលជំនឿត្រូវបានបង្កើតឡើង ថាមពលគឺអាចប្រើបាន ប៉ុន្តែគ្មានអ្វីកើតឡើងបានទេ ដោយសារតែអ្នកត្រូវបើកកុងតាក់សិន។ អ្នកត្រូវតែបញ្ចេញអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅទីនេះក្នុងពិភពផែនដី ព្រោះមានតែអ្នក ទាំងបុរស ឬស្ត្រីនៅលើផែនដីប៉ុណ្ណោះ ដែលអាចធ្វើវាបានដោយស្របច្បាប់។ គោលការណ៍នេះគឺជារបៀបដែលអ្នកត្រូវបានសង្គ្រោះ ដូចដែលបានរៀបរាប់នៅក្នុងគម្ពីររ៉ូម ១០:១០។

*ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿ នោះយើងនឹងទទួលការសង្គ្រោះ។*

— រ៉ូម ១០:១០ (គខប)

មនុស្សជឿលើព្រះបន្ទូលដោយចិត្ត ហើយត្រូវបានប្រោសឱ្យបានសុចរិត។ ប្រោសឱ្យបានសុចរិត គឺជាពាក្យច្បាប់ មានន័យថា ការគ្រប់គ្រងច្បាប់។ ដូច្នេះ នៅពេលដែលដួងចិត្តបុរស ឬស្ត្រីចុះសម្រុងនឹងស្ថានសួគ៌ នៅពេលដែលពួកគេជឿនូវអ្វីដែលស្ថានសួគ៌ថ្លែង នោះពួកគេត្រូវបានគេរាប់ជាអ្នកដែលមានដែនអំណាចគ្រប់គ្រងនៅចំពោះមុខស្ថានសួគ៌ និងផែនដី។ ឥលូវនេះ វាក្លាយជារឿងស្របច្បាប់សម្រាប់ស្ថានសួគ៌ហូរចូលទៅក្នុងជីវិតរបស់ពួកគេ និងឆ្លងកាត់ជីវិតរបស់ពួកគេ និងដើម្បីមានឥទ្ធិពលលើផែនដីក្នុងនាមព្រះរាជ្យរបស់ព្រះជាម្ចាស់។ ប៉ុន្តែអ្វីដែលចម្លែកនោះ បើទោះបីជាពេលនេះវាស្របច្បាប់ ហើយពួកគេមានជំនឿក៏ដោយ ក៏នៅតែមិនមានអ្វីកើតឡើងដែរ។ «ប៉ុន្តែហ្គារី ខ្ញុំគិតថាអ្នកបាននិយាយថា ប្រសិនបើខ្ញុំមានជំនឿ វាបានផ្តល់ឱ្យស្ថានសួគ៌នូវដែនអំណាចគ្រប់គ្រងស្របច្បាប់ត្រង់នេះ។» ត្រឹមត្រូវហើយ ប៉ុន្តែត្រូវមាននរណាម្នាក់ដោះលែងសិទ្ធិអំណាចរបស់ស្ថានសួគ៌ត្រង់នេះ នៅពេលដែលមានជំនឿកើតឡើង។ សូមក្រឡេកមើលបទគម្ពីររបស់យើងម្តងទៀត។

> *ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត **<u>ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ្រោះ</u>**។*
>
> — រ៉ូម ១០:១០ (គខប)

នៅពេលដែលអ្នកមានជំនឿ ឬត្រូវបានប្រោសឱ្យបានសុចរិត នោះឥលូវនេះវាស្របច្បាប់សម្រាប់ស្ថានសួគ៌ដើម្បីលុកលុយផែនដីហើយ ប៉ុន្តែសូមកត់សម្គាល់ថានោះខគម្ពីរចែងថា បើមាត់យើងប្រកាស នោះយើងនឹងទទួលការសង្គ្រោះ។ តើអ្នកឃើញផ្នែកទាំងពីរនោះទេ? ផ្នែកនៃស្ថានសួគ៌កំពុងនាំព្រះបន្ទូលចូលមកក្នុងចិត្តរបស់អ្នក ដែលជាកន្លែងបង្កើតកិច្ចព្រមព្រៀងនៅក្នុងពិភពផែនដី។ បន្ទាប់មក នៅពេលមានការព្រមព្រៀង ឬជំនឿហើយ អ្នកត្រូវធ្វើតាមកិច្ចព្រមព្រៀងនោះ ហើយបញ្ចេញសិទ្ធិអំណាចនៃស្ថានសួគ៌មកក្នុងស្ថានភាពរបស់អ្នក ដើម្បីទទួលបាននូវអ្វីដែលស្ថានសួគ៌

បានថ្លែង។ នៅក្នុងបទគម្ពីររបស់យើងនៅក្នុងគម្ពីរម៉ាកុស ៤:២៩ ចែងថានៅពេលរដូវច្រូតកាត់មកដល់ មនុស្ស (នៅលើផែនដី) បានប្រើកណ្ដៀវច្រូតកាត់។ គាត់គឺជាអ្នកដែលត្រូវធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលដែលមានជំនឿនៅទីនោះ ហើយគាត់ពិតជាទទួលបានការប្រមូលផលមែន។

## ការទទួលបាននៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

ខ្ញុំសូមត្រលប់ទៅនិយាយអំពីរឿងកណ្ដៀវនៅក្នុងគម្ពីរម៉ាកុសជំពូកបួនបន្តិចសិន។ ខ្ញុំជឿថា នៅពិតពក្រុមជំនុំភាគច្រើន គេមិនបានបង្រៀនពីរបៀបប្រើកណ្ដៀវទេ មានន័យថា ពួកគេមិនត្រូវបានបង្រៀនពីរបៀបប្រមូលផលអ្វីដែលពួកគេត្រូវការទេ។ ខ្ញុំក៏មិនដឹងរឿងនេះដែរ រហូតដល់ព្រះជាម្ចាស់បានចាប់ផ្ដើមបង្រៀនខ្ញុំពីរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់ដំណើរការ។ នេះជាដំណើររឿងបានកើតឡើងអំពីរបៀបនៃការបើកសម្ដែងដំបូងរបស់ខ្ញុំអំពីដំណើរការដ៏សំខាន់នេះនៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់។

គេបានអញ្ជើញខ្ញុំឱ្យអធិប្បាយនៅក្រុមជំនុំមួយនៅរដ្ឋអាត្លង់តា។ វាជាកម្មវិធីសម្រាប់រាត្រីថ្ងៃពុធ។ ហើយក្រុមជំនុំនៅទីនោះក៏មិនធំប៉ុន្មានដែរ ប៉ុន្តែវាមិនអីទេសម្រាប់ខ្ញុំ។ ខ្ញុំគ្រាន់តែចូលចិត្តបង្រៀនមនុស្សអំពីព្រះរាជ្យនៃព្រះជាម្ចាស់។ ពេលខ្ញុំទៅដល់ក្រុមជំនុំ ខ្ញុំបានឃើញថាវាចម្លែកដែលទ្វារត្រូវបានចាក់សោ ហើយគ្មានអ្នកណានៅទីនោះទេ។ ពេលនោះគឺត្រឹមដប់នាទីមុនពេលកម្មវិធីចាប់ផ្ដើម។ ខ្ញុំបានឮឡានដឹកទំនិញមួយមកពីក្រោយខ្ញុំ ហើយពេលខ្ញុំក្រឡេកមើលទៅ ខ្ញុំឃើញរថយន្តតឹកអាប់ចាស់មួយគ្រឿងបើកចូលពីក្រោយផ្លូវចូលក្រុមជំនុំនេះ។ ខ្ញុំមិនបានគិតអ្វីទាំងអស់យ៉ាងណាមិញ ខ្ញុំនៅកណ្ដាលទីក្រុងអាត្លង់តា។

ពេលខ្ញុំរង់ចាំ មានបុរសម្នាក់ដើរមកពីក្រោយអគារ ហើយណែនាំខ្លួនឯងថាជាគ្រូគង្វាល។ គាត់បាននិយាយថា គាត់សុំទោសដែលបានមកយឺត ប៉ុន្តែក៏ដោយសារឡានចាស់របស់គាត់បញ្ឆេះមិនឆេះសោះ។ គាត់បានប្រាប់ខ្ញុំថា គាត់ត្រូវតែបញ្ឆេះវា

ដោយរុញវាចុះពីលើជម្រាលភ្នំ ដោយសារខូចប្រអប់លេខ។ គាត់បានបន្តទៀតថា ពេលខ្លះវាមិនឆេះទាល់តែសោះ ហើយគាត់នឹងត្រូវបង្ខំចិត្តដើរចម្ងាយ៨គីឡូម៉ែត្រទៅក្រុមជំនុំ។ ខ្ញុំត្រូវទទួលស្គាល់ថា ខ្ញុំភ្ញាក់ផ្អើលបន្តិចចំពោះការសន្ទនានេះ។

គាត់បានបន្តពន្យល់ថា ដំបូងក្រុមជំនុំនេះគឺជាព័ន្ធកិច្ចផ្សព្វផ្សាយមួយ ហើយថាគាត់បានផ្តល់អាហារដល់មនុស្សរាប់ពាន់នាក់ជារៀងរាល់ខែ ដែលជាធម្មតាមានអាហារសរុបជាង ១០ ០០០ពេលក្នុងមួយខែ ពីទីតាំងមួយនោះ។ ពេលគ្រូគង្វាលកំពុងតែនិយាយ ខ្ញុំបានកើតទុក្ខក្រៀមក្រំ។ នេះជាបុរសរបស់ព្រះជាម្ចាស់ដែលចិញ្ចឹមមនុស្ស ១០ ០០០នាក់ក្នុងមួយខែ ហើយគាត់មិនទាំងមានឡានសមរម្យមួយផង? ខ្ញុំអាចដោះស្រាយវាបាន។ ខ្ញុំមានឡានថ្មីគួរសមមួយ ដែលទើបរត់បានចម្ងាយ ២០.០០០ ម៉ាយនៅផ្ទះ ដែលខ្ញុំនឹងប្រគល់វាឱ្យគាត់។ ខ្ញុំបានប្រាប់គាត់ពីផែនការរបស់ខ្ញុំ ហើយថាខ្ញុំនឹងបញ្ជូនបុគ្គលិករបស់ខ្ញុំម្នាក់ទៅអាត្លង់តា ជាមួយឡាននោះ។ ប្រាកដណាស់ គាត់ពិតជារំភើបមែនទែន។

ខ្ញុំបានចំណាយពេលយប់នោះដើម្បីបង្រៀនគាត់ និងក្រុមជំនុំតូចរបស់គាត់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់ដំណើរការទាក់ទងនឹងលុយកាក់។ ខ្ញុំបានដឹងថាវាសំខាន់ណាស់ដែលពួកគេចាប់ផ្តើមបង្ហាញថាតើព្រះរាជ្យនៃព្រះមានរូបរាងដូចម្តេចចំពោះអ្នកដែលត្រូវការវាយ៉ាងខ្លាំង។

ពេលទៅផ្ទះ ខ្ញុំរៀបចំឡានឱ្យគេបើកទៅអាត្លង់តា។ នៅពេលបុគ្គលិករបស់ខ្ញុំមកយកឡាន ខ្ញុំដឹងថាខ្ញុំកំពុងធ្វើប្រតិបត្តិការខាងវិញ្ញាណនៅស្ថានសួគ៌។ ខ្ញុំបានដឹងថាក្នុងពេលខ្ញុំបញ្ចេញរថយន្តនោះឱ្យចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំអាចជឿថាព្រះជាម្ចាស់នឹងត្រូវការយានយន្តនេះដូចដែលខ្ញុំត្រូវការវាផងដែរ។ ខ្ញុំមិនមែនជាអ្នកនិយមរឿងឡានអ្វីទេ មានន័យថាខ្ញុំមិនមែនជាអ្នកងប់ងល់នឹងជិះឡានទេ។ មានមនុស្សមួយចំនួនជាមនុស្សបែបនេះ ប៉ុន្តែខ្ញុំមិនមែនទេ។ ដូច្នេះ ខ្ញុំបានដាក់ដៃលើរថ

យន្តនោះ ពេលបុគ្គលិករបស់ខ្ញុំមកយករ៉ា ហើយខ្ញុំបាននិយាយថា «ឱព្រះវរបិតាអើយ ទូលបង្គំបានប្រគល់រថយន្តនេះឱ្យទៅក្នុងកិច្ចការនៅទីក្រុងអាត្លង់តាហើយ។ នៅពេលទូលបង្គំបញ្ចេញរថយន្តនេះ ទូលបង្គំបានសាបព្រោះវាជាគ្រាប់ពូជ ហើយជឿថាទូលបង្គំនឹងទទួលបាន ____________ »។ ខ្ញុំមិនអាចគិតពីឡានដែលខ្ញុំចង់បានទេ។ ដូច្នេះខ្ញុំបាននិយាយថា «ទូលបង្គំនឹងត្រលប់ទៅរកទ្រង់វិញត្រង់ចំណុចនេះ!»

មែនហើយ ក្នុងរយៈពេលពីរបីខែបន្ទាប់ ខ្ញុំពិតជាមិនបានគិតច្រើនអំពីឡានទេ ប៉ុន្តែនៅព្រឹកមួយ ខ្ញុំបានសួរឌ្រិនដាថាតើគាត់ចង់មានឡានប្រភេទណា។ បន្ទាប់ពីគិតមួយភ្លែត គាត់បាននិយាយថា យកល្អគឺឡានអាចបើកដំបូលទាំងស្រុងបាន។ ខ្ញុំក៏បានសួរគាត់ថាតើគាត់ចង់បានឡានបើកដំបូលប្រភេទណា ហើយយើងទាំងពីរនាក់មិនអាចគិតពីម៉ូដែលណាមួយដែលមានក្នុងពេលនេះបានឡើយ។ ដោយសារខ្ញុំគ្រោងនឹងទិញរថយន្តឱ្យឌ្រិនដា ខ្ញុំចង់ធ្វើឱ្យប្រាកដថាគាត់នឹងទទួលបានរថយន្តដែលគាត់ចូលចិត្ត។ ខ្ញុំបានប្រាប់គាត់ឱ្យពិនិត្យមើលតាមអ៊ីនធើណិត ឬមើលជុំវិញខ្លួន ហើយប្រាប់ខ្ញុំប្រសិនបើគាត់រកឃើញឡានមានបើកដំបូលទាំងស្រុងណាមួយដែលគាត់ចង់បាន។ យើងមិនបានប្រាប់អ្នកណាម្នាក់អំពីបំណងប្រាថ្នារបស់យើងសម្រាប់រថយន្តថ្មីនោះទេ ប៉ុន្តែទន្ទឹមនឹងនោះ យើងបានបើកភ្នែកចាំមើលរាល់ពេលយើងបើកឡានជុំវិញដោយស្វែងរករថយន្តដែលអាចទាក់ទាញការចាប់អារម្មណ៍យើង។

ថ្ងៃមួយ ពួកយើងបានចូលទៅភោជនីយដ្ឋានមួយក្នុងតំបន់ដើម្បីញ៉ាំអាហារថ្ងៃត្រង់ ហើយភ្លាមៗនោះឌ្រិនដា បានស្រែកថា «នោះវាហ្នឹងហើយ!» «ស្អីគេហ្នឹង?» ខ្ញុំបានសួរ។ «ឡានដែលខ្ញុំចូលចិត្តហ្នឹងណា៎» គាត់កំពុងចង្អុលទៅចំណតឡាន ដូច្នេះខ្ញុំបានបើកឡានជុំវិញចំណតនោះ ហើយឈប់ឡាននៅពីក្រោយឡាន BMW 6 Series Ci ប្រភេទបើកដំបូលទាំងស្រុងបាន ដែលជារថយន្តដ៏ស្រស់ស្អាតមួយយ៉ាងប្រាកដ។ ហើយខ្ញុំត្រូវបន្ថែមពាក្យមួយទៀតថា ជារថយន្តថ្លៃផងដែរ។ ខ្ញុំបានសរសើរគាត់ចំពោះចំណូលចិត្តរបស់គាត់ ហើយបានប្រាប់គាត់ថា វាជាឡានដ៏ស្រស់ស្អាត។

ឥលូវនេះ អ្នកត្រូវដឹងថា គ្រិនដានិងខ្ញុំមិនដើរលេងក្រៅ ហើយចំណាយប្រាក់ច្រើនសម្រាប់រថយន្តទេ។ ដូចខ្ញុំបាននិយាយ ខ្ញុំមិនមែនជាអ្នកនិយមរឿងឡានទេ។ ដោយសារខ្ញុំស្ថិតក្នុងផ្នែកហិរញ្ញវត្ថុ ខ្ញុំក៏បានដឹងដែរថាតើពួកវាធ្លាក់តម្លៃលឿនប៉ុនណា ហើយក៏ដឹងថាវាជាការល្អបំផុតក្នុងការទិញរថយន្តដែលមានអាយុពីមួយទៅពីរឆ្នាំ។ នោះគឺជាផែនការរបស់ខ្ញុំ។ ខ្ញុំនឹងរកមើលឡានមួយដែលត្រូវគេប្រើហើយតែនៅល្អ។

មួយសប្តាហ៍ក្រោយមក បុរសម្នាក់មកពីក្រុមជំនុំបានទូរសព្ទមកខ្ញុំ ហើយនិយាយពាក្យទាំងនេះថា «ខ្ញុំបានរកឃើញឡានរបស់គ្រិនដាហើយ!» ខ្ញុំមានការងឿងឆ្ងល់ជាខ្លាំង ព្រោះពួកយើងមិនបានប្រាប់នរណាម្នាក់អំពីរថយន្ត BMW ដែលយើងបានឃើញនៅថ្ងៃនោះនៅពេលអាហារថ្ងៃត្រង់ទេ។ ដូច្នេះខ្ញុំបានសួរគាត់ថាជារថយន្តប្រភេទអ្វី ហើយគាត់ថាជារថយន្ត BMW 6 Series Ci ប្រភេទបើកដំបូលទាំងស្រុងបាន។ គាត់បាននិយាយថា ពេលគាត់កំពុងបើកបរចុះឡើង គាត់បានឃើញវា ហើយព្រះអម្ចាស់បានប្រាប់គាត់ថា វាជារថយន្តរបស់គ្រិនដា។ «ហ្នឹងហើយ ឥលូវអ្នកទទួលបានចំណាប់អារម្មណ៍ខ្ញុំហើយ» ខ្ញុំបានប្រាប់គាត់។ រថយន្តនេះមានអាយុមួយឆ្នាំ ហើយស្ថិតក្នុងសភាពល្អ។ ខ្ញុំក៏បានបង់ប្រាក់ដើម្បីទិញវា ហើយគ្រិនដាក៏ទទួលបានឡានរបស់គាត់។

អីយ៉ា តើវាកើតឡើងដោយរបៀបណា?

តោះយើងមកប្រៀបធៀបរឿងនោះទៅនឹងអ្វីដែលយើងបានរៀនអំពីការមានជំនឿ និងការប្រើកណ្តៀវច្រូតកាត់។ ពេលដែលខ្ញុំប្រគល់ឡានរបស់ខ្ញុំទៅ ខ្ញុំមានជំនឿ។ ប៉ុន្តែនៅពេលដែលគ្រិនដាបាននិយាយខ្លាំងៗថា «គឺវានោះហើយ!» គឺប្រៀបបាននឹងគាត់កំពុងប្រើកណ្តៀវច្រូតកាត់នោះដែរ ហើយពីរបីថ្ងៃក្រោយមក រថយន្តក៏បានលេចឡើង។ ទោះបីជាខ្ញុំបានឮគាត់និយាយខ្លាំងៗថា «គឺវានោះហើយ!» ខ្ញុំមិនដែលចងភ្ជាប់

ប្រកាសរបស់គាត់ទៅនឹងគម្ពីរម៉ាកុសជំពូកបួន និងរឿងប្រេីកណ្ដៀរទេ។ ប៉ុន្តែរឿងបន្ទាប់នេះបានធ្វើវាឱ្យកាន់តែមានភាពច្បាស់លាស់។

## អំណាចនៃពាក្យសម្ដីរបស់អ្នក

ដូចខ្ញុំបាននិយាយ ខ្ញុំមានដី២៤ហិចតា ប្រហែល៩ហិចតាជាវាលភក់។ ខ្ញុំចូលចិត្តបរបាញ់នៅរដូវស្លឹកឈើជ្រុះ ហើយទោះបីជាខ្ញុំបានបរបាញ់សត្វប្រវឹកកាលពីនៅវិទ្យាល័យក៏ដោយ ខ្ញុំពិតជាមិនធ្លាប់ធ្វើការបរបាញ់សត្វប្រវឹកនៅក្នុងរដ្ឋអូហៃយ៉ូទេ។ ប៉ុន្តែនៅឆ្នាំនោះ វាលភក់ពោរពេញដោយទឹក ហើយសត្វប្រវឹកជាច្រើនហ្វូងនៅតែបន្តហើរចូលទៅក្នុងវាលនោះ។ ក្នុងមួយថ្ងៃៗប្រវឹករាប់រយក្បាលនឹងចូលមកដេកនៅពេលយប់។ ដូច្នេះ នៅយប់មួយ ខ្ញុំបានចាប់កាន់កាំភ្លើងខ្ញុំ ហើយចេញទៅក្រៅ ហើយចំណាយពេលវេលាដ៏ល្អនេះបាញ់ប្រវឹកពីរបីក្បាលមកធ្វើជាអាហារពេលល្ងាច។

នារដូវស្លឹកឈើជ្រុះនោះ ទាំងកូនប្រុសខ្ញុំ និងខ្ញុំរីករាយនឹងការបរបាញ់ប្រវឹកណាស់។ ទោះជាយ៉ាងណាក៏ដោយ រឿងមួយដែលខ្ញុំបានកត់សម្គាល់នោះគឺថា ភាគច្រើនខ្ញុំបាញ់បានសត្វប្រវឹកច្រើនជាងគេដោយប្រើកាំភ្លើងខ្លី។ នៅពេលបរបាញ់សត្វប្រវឹក ច្បាប់អនុញ្ញាតឱ្យអ្នកប្រើបានតែគ្រាប់កាំភ្លើងដែកទេ ដោយប្រឆាំងមិនឱ្យបាញ់ដោយប្រើគ្រាប់សំណឡើយ។ គ្រាប់សំណគឺធ្ងន់ជាង និងរក្សាចំងាយរបស់វាបានឆ្ងាយជាងការបាញ់ដោយគ្រាប់ដែក ដែលវាជាបញ្ហាក្នុងការបាញ់រយៈចម្ងាយឆ្ងាយនៅពេលបរបាញ់ប្រវឹក។

ប៉ុន្តែក្នុងអំឡុងពេលរដូវស្លឹកឈើជ្រុះនោះ នៅពេលដែលខ្ញុំកំពុងនិយាយជាមួយអ្នកប្រមាញ់ប្រវឹកពីរបីនាក់ ពួកគេបានប្រាប់ខ្ញុំអំពីកាំភ្លើងថ្មីដែលត្រូវបានរចនាឡើងសម្រាប់តែការបរបាញ់ប្រវឹកប៉ុណ្ណោះ។ ពួកគេអាចបាញ់បានទម្ងន់ធ្ងន់ជាងមុន និងអាចលាក់បាំងបានផងដែរ។ ខ្ញុំចាប់អារម្មណ៍ចង់ទិញជាខ្លាំង ប៉ុន្តែវាជាខែធ្នូទៅហើយ រដូវបរបាញ់ប្រវឹកបានបញ្ចប់ ហើយខ្ញុំក៏មិនបានគិតច្រើនអំពីវាទៀតដែរ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

នៅដើមខែមករា ខ្ញុំបានឈៀងចូលហាង Cabela's (ហាងលក់សម្ភារៈកីឡាក្នុងតំបន់របស់យើង) ដើម្បីទិញរបស់របរមួយចំនួន ហើយខ្ញុំនឹកឃើញកាំភ្លើងបាញ់ទាទាំងនោះ។ ខ្ញុំចង់ឃើញវា។ ដូច្នេះ ខ្ញុំបានដើរកាត់បញ្ជរកាំភ្លើងនៅផ្លូវចេញ ហើយខ្ញុំបានឃើញផ្នែកពេញលេញនៃកាំភ្លើងថ្មីនេះ ដែលមានជំនាញក្នុងការប្រមាញ់សត្វស្លាបទឹក។ ដោយមិនគិតច្រើន ខ្ញុំចាំថាខ្ញុំបានចង្អុលម្រាមដៃរបស់ខ្ញុំទៅកាំភ្លើងមួយដែលខ្ញុំគិតថាមើលទៅល្អបំផុត ហើយនិយាយខ្លាំងៗថា «អម្ចាស់ ទូលបង្គំនឹងយកមួយនេះ»។ ខ្ញុំមិនបានគិតអំពីវាពេលដែលខ្ញុំបាននិយាយវាទេ។ គឺវាចេញពីមាត់របស់ខ្ញុំតែម្តង។ រដូវបាញ់ទាមិនបានបើកម្តងទៀតទេរហូតដល់រដូវស្លឹកឈើជ្រុះឆ្នាំក្រោយ ដូច្នេះខ្ញុំមិនមានគម្រោងទិញកាំភ្លើងទេ រហូតដល់រដូវកាលកាន់តែខិតជិតមកដល់បន្តិច។

ពីរសប្តាហ៍ក្រោយមក គេបានអញ្ជើញខ្ញុំឱ្យមកអធិប្បាយនៅក្នុងសន្និបាតអាជីវកម្មមួយ។ ពេលខ្ញុំអធិប្បាយចប់ នាយកប្រតិបត្តិក៏ចេញមកអរគុណខ្ញុំ ហើយនិយាយថាពួកគេបានទិញកាដូមួយឱ្យខ្ញុំ។ ហើយអស្ចារ្យណាស់ គាត់បានយកកាំភ្លើងមួយចេញមក ដែលវាជាកាំភ្លើងម៉ូតតែមួយនឹងកាំភ្លើងដែលខ្ញុំបានចង្អុលបង្ហាញកាលពីពីរសប្តាហ៍មុននៅក្នុងហាង Cabela's ។ ជាការពិតណាស់ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអំណោយដ៏សប្បុរសបែបនេះ ប៉ុន្តែខ្ញុំដឹងថានេះមិនមែនជារឿងចៃដន្យនោះទេ។ ពេលនោះខ្ញុំបាននឹកឃើញអ្វីដែលខ្ញុំបាននិយាយពេលនៅហាង Cabela's ហើយបានដឹងពីអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំបានប្រើកណ្តៀវច្រូតកាត់!

*ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាបុរសម្នាក់ព្រោះស្រូវ នៅក្នុងស្រែរបស់ខ្លួន។ ទោះបីគាត់ដេកក្តី ក្រោកក្តី យប់ក្តី ថ្ងៃក្តី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ <u>ដ្បិតដីធ្វើឱ្យពូជបង្កើតផលដោយខ្លួនឯង</u> ដំបូងមានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ។ លុះស្រូវទុំ <u>គេយកកណ្តៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ</u>»។*

## បញ្ហាពាក់ទឹងដែនអំណាចគ្រប់គ្រង

— ម៉ាកុស ៩:២៦-២៩ (គខប)

ការយកកណ្ដៀវមកច្រូតនេះ បានបង្ហាញឱ្យឃើញពីគោលការណ៍ដូចគ្នាពាក់ព័ន្ធនឹងជំនឿដែលពួកយើងបានពិភាក្សាគ្នានៅក្នុងគម្ពីររ៉ូម ១០:១០។

*ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ្រោះ។*

— រ៉ូម ១០:១០ (គខប)

ខ្ញុំជឿដោយចេញពីចិត្ត ហើយគឺតាមរយៈមាត់របស់ខ្ញុំដែលខ្ញុំបានស្រាយព្រះរាជ្យនៃព្រះជាម្ចាស់ទៅក្នុងពិភពផែនដី។ ខ្ញុំធ្លាប់បានបរិច្ចាគកាំភ្លើងជាង៣០ដើមទៅគេ ប៉ុន្តែនេះជាលើកទីមួយហើយដែលខ្ញុំចាំថាបាននិយាយខ្លាំងៗថា «ខ្ញុំនឹងយកមួយនោះ»។ ប៉ុន្តែពេលខ្ញុំគិតអំពីរឿងនេះមួយនាទី មានពេលមួយទៀតដែលខ្ញុំបានធ្វើរឿងដដែលដូចគ្នានេះ ប៉ុន្តែនៅពេលនោះ ខ្ញុំមិនមានតម្រុយពីរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់ដំណើរការនោះទេ។

នៅពេលដែលឌ្រិនដានិងខ្ញុំបានផ្លាស់ទៅរស់នៅរដ្ឋអូហៃយ៉ូវិញ ពោលគឺពួកយើងមកពីអូក្លាហូម៉ា ដែលជាកន្លែងមានការបរបាញ់សត្វក្ងាន់ជាមួយនឹងកាំភ្លើងវែង។ ប៉ុន្តែនៅក្នុងរដ្ឋអូហៃយ៉ូ កាំភ្លើងវែងមិនស្របច្បាប់ទេ។ មានតែកាំភ្លើងស្នប់ដែលប្រើគ្រាប់សំណប៉ុណ្ណោះដែលគេបានអនុញ្ញាត។ អ្វីដែលខ្ញុំមាននៅពេលនោះគឺកាំភ្លើងកាណុងពីរ ខ្នាត២០រង្វាស់ (20-gauge double barrel) ដែលខ្ញុំបានព្យាយាមបាញ់បានសត្វក្ងាន់ពីរនៅឆ្នាំដំបូងដែលយើងផ្លាស់ទីនោះ។ ប៉ុន្តែខ្ញុំពិតជាចង់បានកាំភ្លើងបាញ់ល្អមួយដែលត្រូវបានរចនាឡើងជាពិសេសសម្រាប់បរបាញ់សត្វក្ងាន់។ ខ្ញុំចាំបានថាបន្ទាប់ពីរដូវបរបាញ់សត្វក្ងាន់ដំបូងនៅរដ្ឋអូហៃយ៉ូ ខ្ញុំបានអធិប្បាយទៅកាន់ឌ្រិនដា ថាខ្ញុំពិតជាចង់បានម៉ូដែល Remington 11-87 ខ្នាត១២រង្វាស់ជាមួយនឹងស្តុកសំយោគពណ៌ខ្មៅសម្រាប់ការបរបាញ់សត្វក្ងាន់។ បុណ្យណូអែលគឺនៅពីរបីសប្តាហ៍ក្រោយមក ហើយ

ខ្ញុំភ្ញាក់ផ្អើលនៅពេលដែលឪពុករបស់ខ្ញុំបានឱ្យកាដូខ្ញុំនូវកាំភ្លើងស្នប់ដូចគ្នានោះ សម្រាប់បុណ្យណូអែល។ ខ្ញុំមិនបានប្រាប់គាត់នូវតម្រូវការកាំភ្លើងស្នប់របស់ខ្ញុំទេ។ ខ្ញុំចាំថាបានគិតថា «អីយ៉ា នោះចម្លែកណាស់»។ ខ្ញុំបានប្រើកណ្ដៀវច្រូតកាត់ដោយមិនបានដឹងខ្លួន។

# ជំពូក ៩
# តើអ្នកចាំឬទេ?

កាលពីដំបូងៗ ពេលដែលខ្ញុំមិនទាន់ដឹងច្បាស់ពីរបៀបដែលព្រះរាជ្យព្រះជាម្ចាស់ដំណើរការ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអ្វីៗដែលខ្ញុំបានឃើញ។ មូលហេតុដ៏សំខាន់បំផុតនោះ គឺដោយសារតែខ្ញុំមិនដែលទទួលបានការបង្រៀនពីអ្វីៗទាំងនោះដែលខ្ញុំបានឃើញ។ ក៏ប៉ុន្តែដូចអ្វីដែលខ្ញុំបាននិយាយនៅក្នុងផ្នែកដំបូងនៃសៀវភៅនេះរួចមកហើយថា ព្រះជាម្ចាស់ហាក់ដូចជាប្រើប្រាស់ការប្រមាញ់សត្វក្ងាន់របស់ខ្ញុំសម្រាប់មេរៀនជាច្រើនដែលទ្រង់កំពុងបង្រៀនខ្ញុំ។ ជាការពិត ខ្ញុំគឺជាមនុស្សដ៏សាមញ្ញម្នាក់ ហើយខ្ញុំគិតថានោះគឺជារបៀបមួយដ៏ល្អដើម្បីទាក់ទាញចិត្តខ្ញុំ។ បន្ទាប់ពីខ្ញុំបានរៀនពីរបៀបសាបព្រោះគ្រាប់ពូជសម្រាប់សត្វក្ងាន់របស់ខ្ញុំ និងបានចាប់ផ្តើមប្រមូលផលជាធម្មតាក្នុងអំឡុងពេលប្រមាណជា៤០នាទីក្រោយពីខ្ញុំចេញទៅខាងក្រៅ ព្រះជាម្ចាស់បានចាប់ផ្តើមកែសម្រួលមេរៀនរបស់ខ្ញុំឱ្យចូលទៅក្នុងការយល់ដឹងកាន់តែអស្ចារ្យអំពីដំណើរការរបស់ព្រះរាជ្យ។

ពេលព្រះជាម្ចាស់បានបង្ហាញខ្ញុំពីរបៀបប្រមាញ់សត្វក្ងាន់ស្វែងបែកខ្នែងប្រាំមួយជាន់ដោយជំនឿ នោះខ្ញុំបានរស់នៅក្នុងទីក្រុងធុលសា រដ្ឋអូក្លាហូម៉ា។ ដូចជាអ្វីដែលខ្ញុំបានប្រាប់អ្នករួចមកហើយថា យើងបានរើផ្ទះទៅរដ្ឋអូហៃយ៉ូវិញក្នុងឆ្នាំបន្ទាប់ពីនោះ។ រដ្ឋអូហៃយ៉ូមានហ្វូងសត្វក្ងាន់ដ៏ធំ ហើយអ្នកទទួលបានការអនុញ្ញាតឱ្យប្រមាញ់ក្ងាន់បានពីរ ហើយក្នុងនោះអាចមានក្ងាន់ឈ្មោលតែមួយប៉ុណ្ណោះ។ ហេតុនេះហើយពេលខ្ញុំត្រលប់ទៅរដ្ឋអូហៃយ៉ូវិញ ខ្ញុំបានចាប់ផ្តើមសាបព្រោះពូជសម្រាប់សត្វក្ងាន់ពីរ គឺ

ឈ្មោលមួយ និងញីមួយក្នុងមួយឆ្នាំៗ។ ហើយវាប្រៀបដូចជាអ្វីដែលបានគ្រោងទុកដូច្នោះដែរ គឺខ្ញុំទទួលបានអ្វីដែលខ្ញុំសាបព្រោះនោះ។

ក៏ប៉ុន្តែរយៈពេលមួយឆ្នាំ ខ្ញុំបានសម្គាល់ឃើញពីអ្វីម្យ៉ាងដែលបានធ្វើឱ្យខ្ញុំមានចម្ងល់។ ខ្ញុំបានគិតថា «ទេ រឿងនេះមិនអាចកើតឡើងទៅរួចទេ។» ពេលបញ្ចប់រដូវកាលប្រមាញ់សត្វក្តាន់នោះខ្ញុំសម្គាល់ឃើញថាសត្វក្តាន់ចូលមកតាមលំដាប់លំដោយតាមអ្វីដែលខ្ញុំបានសរសេរទុកក្នុងកំណត់ត្រាពេលខ្ញុំបានសាបព្រោះគ្រាប់ពូជរបស់ខ្ញុំ។ ជាក់ស្តែងប្រសិនបើខ្ញុំសរសេរថា «បានក្តាន់ឈ្មោលមួយ និងក្តាន់ញីមួយ» នោះក្តាន់ឈ្មោលមកមុន ហើយក្តាន់ញីនឹងមកបន្ទាប់ពីនោះ។ ពេលខ្ញុំបានឆ្លុះបញ្ចាំងពីរដូវកាលពីរបីមុនៗនៅក្នុងរដ្ឋអូហៃយ៉ូ ខ្ញុំគិតថារឿងបែបនេះបានកើតឡើងរៀងរាល់ឆ្នាំ។ ខ្ញុំមិនសូវច្បាស់ប៉ុន្មានទេ ដោយសារខ្ញុំមិនដែលយកចិត្តទុកដាក់ខ្លាំងលើរឿងនោះ ក៏ប៉ុន្តែមានហេតុផលមួយចំនួនធ្វើឱ្យខ្ញុំឆ្ងល់ថាតើរឿងនេះកើតឡើងពិតមែនឬទេ។

ដូច្នេះហើយនៅឆ្នាំបន្ទាប់ ខ្ញុំដឹងមុនថាខ្ញុំត្រូវតែដឹងការពិតឱ្យបាន។ ខ្ញុំយល់ស្របថាវាគឺជាគំនិតដ៏លេលាមួយ ក៏ប៉ុន្តែខ្ញុំគិតថារឿងនេះហាក់ដូចជាមានដំណើរការតាមរបៀបដូច្នោះ ហើយខ្ញុំនឹងមិនដឹងការពិតទេរហូតទាល់តែខ្ញុំធ្វើការពិសោធមើលបន្តិចបន្តួច។ ហេតុដូច្នេះហើយនៅក្នុងឆ្នាំនោះ ខ្ញុំបានដាក់លំដាប់លំដោយបញ្ច្រាសគ្នាពេលដែលខ្ញុំសាបព្រោះគ្រាប់ពូជរបស់ខ្ញុំ។ លើកនេះខ្ញុំបានដាក់ក្តាន់ញីមុនក្នុងបញ្ជីរបស់ខ្ញុំ។ កាលពីមុនមកទល់ពេលនោះខ្ញុំតែងតែសរសេរក្តាន់ឈ្មោលមុននៅពេលដែលខ្ញុំសាបព្រោះគ្រាប់ពូជ។ វាច្បាស់ណាស់ខ្ញុំទទួលបានតាមលំដាប់លំដោយដែលខ្ញុំសរសេរពិតមែន។ ហេតុដូច្នេះហើយក្នុងឆ្នាំបន្ទាប់ខ្ញុំបានធ្វើដូច្នោះម្តងទៀត ហើយសត្វក្តាន់ក៏ចូលមកតាមលំដាប់លំដោយដែលខ្ញុំបានសរសេរទុកទៀត។ ខ្ញុំមិនធ្លាប់គិតសោះថារឿងបែបនោះអាចកើតឡើងទៅរួច។ ន័យរបស់ខ្ញុំគឺថា តើព្រះរាជ្យមានភាពជាក់លាក់ដូច្នោះឬ?

ដើម្បីឱ្យដឹងការពិតថារឿងបែបនេះពិតជាកើតឡើងពិតមែន ឬគ្រាន់តែជាការចៃដន្យ ខ្ញុំបានសម្រេចចិត្តស្វែងរកការពិតយ៉ាងពិតប្រាកដ ហើយធ្វើការពិសោធដែលមានភាពស៊ីជម្រៅជាងមុនបន្តិច។ ក្នុងឆ្នាំនោះខ្ញុំបានសាបព្រោះគ្រាប់ពូជយកសត្វក្ងាន់ដែលមានស្នែងបែកខ្នែងជាប្រាំពីរ។ ខ្ញុំដឹងថាសត្វក្ងាន់ធម្មតា ទូទៅមានស្នែងបែកខ្នែងចំនួនស្មើគ្នានៅលើស្នែងម្ខាងៗ ដូច្នេះហើយខ្ញុំបានរើសយកចំនួនសេស និងជាលេខជាក់លាក់ប្រាកដមួយ។ ដូច្នេះនោះហើយជាអ្វីដែលខ្រិនដា និងខ្ញុំបានសាបព្រោះគ្រាប់ពូជដើម្បីទទួលបាន តាមស្ដាប់ទៅវាប្រៀបដូចជារឿងចម្លែកមួយ។ យើងបានអធិស្ឋាន និងស្រាយគ្រាប់ពូជរបស់យើងដើម្បីទទួលបានក្ងាន់ដែលមានស្នែងបែកខ្នែងប្រាំពីរ។

## តើជំនឿមានភាពជាក់លាក់ប៉ុណ្ណា?

នៅទីបំផុតខែតុលាក៏ចូលមកដល់ ហើយរដូវកាលប្រមាញ់ក៏បានចាប់ផ្តើម។ ធម្មតាខ្ញុំមិនអាចទប់ចិត្តរង់ចាំឱ្យដល់ពេលយកធ្នូរបស់ខ្ញុំចូលទៅក្នុងព្រៃបានទេ ក៏ប៉ុន្តែខ្ញុំសម្គាល់ឃើញថាខ្ញុំមានអារម្មណ៍ប្លែកនៅពេលដែលរដូវកាលនោះបានចាប់ផ្តើម។ ខ្ញុំគ្មានអារម្មណ៍ចង់ចេញទៅក្រៅសោះ។ អារម្មណ៍នោះពិតជាមានឥទ្ធិពលខ្លាំងណាស់ ហើយខ្ញុំមិនទាន់ចង់ចេញទៅក្រៅនៅឡើយទេ វាហាក់ដូចជាចម្លែកមែន។ ពេលនោះខ្ញុំបានគិតថា ការខ្វះចំណង់ចង់ចេញទៅប្រមាញ់នេះនឹងកើតមានពេលរដូវកាលនោះកំពុងបន្ត រហូតដល់ពេលដែលស្លឹកឈើចាប់ផ្តើមជ្រុះ។ ក៏ប៉ុន្តែមិនដូច្នោះទេ ខ្ញុំមិនអាចពន្យល់ពីវាបានទេ ខ្ញុំគ្មានបំណងចង់ចេញទៅខាងក្រៅទេ គ្មានទាល់តែសោះ។ ខ្ញុំចាំបានខ្ញុំបានគិតថា «តើពេលដែលយើងចាស់ទៅ នឹងមានអារម្មណ៍បែបនេះកើតឡើងមែនឬទេ? អ្នកឈប់ធ្វើរឿងជាច្រើនមែនឬទេ?» ខ្ញុំចង់មានន័យថាខ្ញុំមិនអាចពន្យល់ពីអារម្មណ៍ចម្លែកដែលខ្ញុំមាននេះបានទេ។ វាហាក់ដូចជាខ្ញុំមិនខ្វល់អ្វីបន្តិចសោះពីការចេញទៅប្រមាញ់ម្តងទៀត។ ច្បាស់ណាស់ខែវិច្ឆិកាក៏ចូលមកដល់ ហើយខ្ញុំក៏ចាប់ផ្តើមបារម្ភបន្តិចបន្តួចដែរ។ ខ្ញុំបានខកខានពេលវេលាដ៏ស្រស់ស្អាតបំផុតនៅក្នុងព្រៃ ខ្ញុំអាចនិយាយបន្ថែមបានថាជាពេលវេលាដ៏កក់ក្ដៅបំផុត។ ក្រោយមកក៏ចូលមកដល់ពាក់ក

ណ្តាលខែវិច្ឆិកា ហើយខ្ញុំនៅតែគ្មានបំណងចង់ចេញទៅប្រមាញ់សត្វក្តាន់ទាល់តែសោះដដែល។ ខ្ញុំឆ្ងល់ថាតើខ្ញុំមិនចេញទៅក្រៅទាល់តែសោះមែនឬទេ គឺខ្ញុំមានអារម្មណ៍ដូច្នេះឯង។

ឪពុកម្តាយខ្រិនដាបានធ្វើដំណើរមកពីរដ្ឋអាល់បាម៉ា (Albama) ដើម្បីមកស្នាក់នៅជាមួយយើងរយៈពេលពីរថ្ងៃ។ ពេលយើងអង្គុយលេងនៅក្នុងបន្ទប់ទទួលភ្ញៀវភ្លាមៗខ្ញុំស្រាប់តែដឹងថាខ្ញុំត្រូវតែចេញទៅព្រៃនៅថ្ងៃបន្ទាប់។ វាប្រៀបដូចជាកុងតាក់ដែលគេបានបើកយ៉ាងនោះដែរ។ ខ្ញុំបានប្រាប់ពួកគាត់ទាំងអស់គ្នាថាខ្ញុំត្រូវតែចេញទៅនៅពេលព្រឹកដើម្បីប្រមាញ់ក្តាន់ឈ្មោលរបស់ខ្ញុំ។ ភ្លាមៗនោះខ្ញុំស្រាប់តែមានចិត្តរំភើបនិងក្តីសង្ឃឹមពេលខ្ញុំត្រៀបឧបករណ៍របស់ខ្ញុំជាស្រេចសម្រាប់ព្រឹកថ្ងៃបន្ទាប់។

ខ្ញុំដឹងថាក្តាន់ស្នែងបែកខ្នែងជាប្រាំពីររបស់ខ្ញុំនឹងនៅត្រង់នោះ។ ហើយក្រោយពីនោះខ្ញុំក៏បានយល់។ ក្តាន់ស្នែងបែកខ្នែងជាប្រាំពីរមិននៅទីនោះទេនៅខែតុលា ហើយក៏មិននៅទីនោះនៅមុនថ្ងៃនោះដែរ។ នោះមុខជាហេតុផលដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ហាក់មិនរវីរវល់នឹងការប្រមាញ់សត្វក្តាន់សោះ។ ខ្ញុំអាចស្រមៃឃើញថាវានឹងលំបាកប៉ុណ្ណាក្នុងការរង់ចាំរយៈពេលមួយខែកន្លះ ប្រសិនបើខ្ញុំគ្រាន់តែមើលទៅក្រៅតាមបង្អួចទាំងសង្ឃឹមថាខ្ញុំចេញទៅក្រៅជារៀងរាល់ថ្ងៃអស់រយៈពេលមួយខែកន្លះនោះ។ រឿងនោះនឹងធ្វើឱ្យខ្ញុំបាក់ទឹកចិត្ត។ មកដល់ត្រឹមនេះរឿងគ្រប់យ៉ាងគ្រាន់តែជាទ្រឹស្តីមួយប៉ុណ្ណោះ ក៏ប៉ុន្តែខ្ញុំនឹងធ្វើការសាកល្បងវាមើលនៅព្រឹកថ្ងៃបន្ទាប់។

ព្រឹកនោះពេលខ្ញុំក្រោកពីដំណេកទាំងមេឃនៅងងឹត ហើយខ្ញុំបានអធិស្ឋាននៅពេលយប់ អំពីរានប្រមាញ់លើដើមឈើមួយណាដែលខ្ញុំគួរតែតម្រង់ទៅរក។ នៅលើដីរបស់ខ្ញុំមានរានប្រមាញ់លើដើមឈើមួយចំនួន ហើយពេលខ្ញុំអធិស្ឋានអំពីវាខ្ញុំមានអារម្មណ៍ប្រាកដក្នុងចិត្តថាខ្ញុំត្រូវទៅរករានប្រម៉ាញ់នៅទំនាបបឹង។ យើងហៅវាថាជារានប្រមាញ់ទំនាបបឹងដោយសារតែវានៅជាប់នឹងទំនាបបឹងម្ខាងមានទំហំប្រមាណ

ជាងប្អូនហិកតា ជាមួយនឹងគុម្ពោធព្រៃនៅរានប្រមាញ់ម្ខាងទៀត។ ខ្ញុំដឹងថាជួនកាលសត្វក្ដាន់នឹងដើរតាមមាត់បឹងជុំវិញទំនាបបឹង។ រានប្រមាញ់នោះធ្លាប់នាំមកនូវជ័យជម្នះរួចមកហើយ ហើយខ្ញុំពិតជាសង្ឃឹមទាំងស្រុងថានឹងឃើញសត្វក្ដាន់ឈ្មោលរបស់ខ្ញុំនៅរានប្រមាញ់ទំនាបបឹងក្នុងថ្ងៃនោះ។

ពេលខ្ញុំធ្វើដំណើរទៅរានប្រមាញ់ ខ្ញុំបានរំឭកពីអ្វីដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំកាលពីមុនទាក់ទងនឹងព្រះរាជ្យរបស់ទ្រង់តាមរយៈការប្រមាញ់សត្វក្ដាន់ ហើយខ្ញុំមានអារម្មណ៍ថាទ្រង់កំពុងតែបង្រៀនខ្ញុំបន្ថែមទៀត។ ខ្ញុំរំភើបណាស់ក្នុងការចាំមើលលទ្ធផលពីការដកពិសោធរបស់ខ្ញុំ។

រស្មីអរុណោទ័យបានឈានចូលមកសន្សឹមៗ ហើយមានសំឡេង និងក្លិននាព្រឹកព្រហាមក្នុងរដូវស្លឹកឈើជ្រុះជាការស្វាគមន៍ដំណើរផ្លាស់ប្ដូរសម្រាប់ខ្ញុំ។ ខ្ញុំពិតជាខកពេលមែនហើយ។ ពេលវេលាពេលព្រឹកស្ទើរតែអស់ពេលមួយម៉ោងទៅហើយ ហើយហាក់ដូចជាគ្មានសញ្ញារបស់សត្វក្ដាន់សោះ។ ក៏ប៉ុន្តែខ្ញុំបានដឹងតាមរយៈការមើលតាមដានជើងរបស់សត្វក្ដាន់នៅលើដីរបស់ខ្ញុំ ថាសត្វក្ដាន់នឹងចូលមកក្នុងតំបន់នេះនៅពេលក្រោយក្នុងព្រឹកនោះ ដោយសារតែវាជាកន្លែងដ៏ល្អបំផុតសម្រាប់ជាទីដេកសម្រាក។ ទោះបីជាខ្ញុំបាននៅត្រង់រានប្រមាញ់ប្រមាណជាងមួយម៉ោងហើយក្ដី តែភ្លើងសញ្ញាអនុញ្ញាតឱ្យបាញ់ស្របច្បាប់ទើបតែបើកប្រមាញជា ៤០នាទីប៉ុណ្ណោះ។

ពេលខ្ញុំអង្គុយនៅទីនោះ ខ្ញុំបានឮសំឡេងបិទទ្វារឡាននៅឯផ្ទះ។ បន្ទាប់មកខ្ញុំក៏នឹកឃើញឳពុកម្ដាយខ្មែរនដាកំពុងតែត្រលប់ទៅរដ្ឋអាលបាម៉ាវិញ ហើយខ្ញុំក៏ចង់ទៅលាពួកគាត់។ ដូច្នេះខ្ញុំបានចុះពីរានប្រមាញ់យ៉ាងស្ងាក់ស្ទើរ ដោយគិតថាខ្ញុំនឹងត្រូវចេញមកក្រៅនៅថ្ងៃផ្សេងដើម្បីបានក្ដាន់ស្នែងបែកខ្នែកជាប្រាំពីររបស់ខ្ញុំ។

ពេលខ្ញុំទៅដល់ផ្ទះគ្រប់គ្នារៀបចំខ្លួនរួចរាល់ដើម្បីទទួលទានអាហារពេលព្រឹក។ ខ្ញុំតែងតែជាអ្នកចម្អិនអាហារពេលព្រឹកនៅក្នុងគ្រួសារ ជាអ្នកចម្អិនស្ទើរតែរាល់ថ្ងៃ

សម្រាប់ខ្រិនដា និងខ្លួនខ្ញុំ ក៏ដូចជានរណាក៏ដោយដែលនៅទីនេះ។ ដូច្នេះខ្ញុំចូលទៅចម្អិនអាហារពេលព្រឹកពេលឪពុកម្ដាយរបស់ខ្រិនដារៀបចំអីវ៉ាន់ដាក់ឡានរួចរាល់។ មិនខុសទេ ពួកគាត់បានសួរខ្ញុំពីក្ដាន់ឈ្មោលរបស់ខ្ញុំ ហើយខ្ញុំក៏ប្រាប់ពួកគាត់ថាខ្ញុំសម្រេចចិត្តបោះបង់ផែនការនោះចោល ដើម្បីឱ្យខ្ញុំអាចចំណាយពេលនៅព្រឹកនេះជាមួយពួកគាត់។ ពិតមែនហើយខ្ញុំរាងខកចិត្តបន្តិច។ ខ្ញុំរំពឹងថាពួកគាត់នឹងចេញទៅរាងថ្ងៃបន្តិចដើម្បីឱ្យខ្ញុំមានពេលទៅច្រកយកក្ដាន់របស់ខ្ញុំ។

ក៏ប៉ុន្តែនៅពេលដែលខ្ញុំកំពុងឈរចៀនពងទាក្រឡុកនៅលើចង្ក្រាន ខ្ញុំបានក្រឡេកមើលទៅក្រៅតាមបង្អួចផ្ទះបាយដែលនៅទល់មុខនឹងព្រៃឈើ និងទីវាលខាងក្រោយផ្ទះខ្ញុំ។ ខ្ញុំសម្លឹងទៅឃើញក្ដាន់ឈ្មោលមួយក្បាលកំពុងដេញក្ដាន់ញីឆ្លងកាត់ទីវាលខាងក្រោយតម្រង់ទៅមុំទំនាបបឹងត្រង់រានប្រមាញ់របស់ខ្ញុំតែម្ដង។ ខ្ញុំគ្រាន់តែដឹងថាខ្ញុំត្រូវតែចេញទៅចាប់ក្ដាន់ឈ្មោលរបស់ខ្ញុំ។ ខ្ញុំស្រាប់តែស្រែកយ៉ាងឮភ្លាមៗឱ្យនរណាម្នាក់មកចម្អិនម្ហូបជំនួសខ្ញុំ និងប្រាប់គេថាខ្ញុំទើបតែបានឃើញក្ដាន់ឈ្មោលរបស់ខ្ញុំ ហើយខ្ញុំនឹងទៅចាប់វា។ ខ្ញុំដឹងហើយថាខ្ញុំមិនមានពេលច្រើនទេ។

ខ្ញុំត្រូវតែរត់ជុំវិញដីរបស់ខ្ញុំពីទិសដៅផ្ទុយគ្នាដើម្បីជៀសវាងកុំឱ្យក្ដាន់មើលឃើញខ្ញុំ។ ខ្ញុំបានគិតថាវាមុខជាតម្រង់ចុះទៅតាមផ្លូវលំដែលរានប្រមាញ់របស់ខ្ញុំស្ថិតនៅពីលើ។ ខ្ញុំបានរត់យ៉ាងលឿនតាមដែលអាចធ្វើទៅបានជុំវិញទីវាល ហើយវាជាការល្អដែលខ្ញុំបានទៅដល់រានប្រមាញ់ដោយមិនបានឃើញក្ដាន់ណាមួយទាល់តែសោះ។ ក្រោយមកខ្ញុំបានដឹងថាខ្ញុំបានរត់ទៅដល់ទីនោះមុនវា ប្រសិនបើជាក់ស្ដែងពួកវាជ្រើសរើសរត់តាមផ្លូវលំរបស់ខ្ញុំ។ ខ្ញុំប្រញាប់ហក់ឡើងទៅលើរានប្រមាញ់ទាំងបេះដូងកំពុងលោតញាប់ ហើយញើសក៏ហូរសស្រាក់លើផ្ទៃមុខខ្ញុំផង។

ភ្លាមៗនោះពេលខ្ញុំអង្គុយចុះ ពួកវាក៏មកដល់។ ក្ដាន់ញីដើរចូលមកញាប់ជើងនៅពីក្រោមរានប្រមាញ់របស់ខ្ញុំតែម្ដង ហើយខ្ញុំក៏បានត្រៀមខ្លួនរួចជាស្រេចដោយខ្ញុំ

ដឹងថាក្ដាន់ឈ្មោលនៅពីក្រោយមិនឆ្ងាយប៉ុន្មានទេ។ ច្បាស់ណាស់ពួកវាពិតជាដើរចូលមកមែន។ ខ្ញុំគ្មានពេលបញ្ជាក់ទេថា វាពិតជាមានស្នែងបែកខ្នែងជាប្រាំពីរមែនឬទេ។ ខ្ញុំស្ទើរតែគ្មានពេលដើម្បីយកធ្នូខ្ញុំឡើងដើម្បីបាញ់។ ពេលខ្ញុំបាញ់ខ្ញុំដឹងថាខ្ញុំបាញ់ត្រូវក្ដាន់ឈ្មោលហើយ ក៏ប៉ុន្ដែបាញ់ត្រូវរាងទាបបន្ដិច ហើយក៏ធ្វើឱ្យខ្ញុំបារម្ភខ្លះដែរ។ ក្ដាន់ឈ្មោលលោតចូលទៅក្នុងគុម្ពោធព្រៃពេលត្រូវខ្ញុំបាញ់។ ខ្ញុំបានរង់ចាំនៅឯរានប្រមាញ់អស់ពេល២០នាទី ហើយទីបំផុតក៏ចុះពីលើដើមឈើទៅដោយចិត្តចង់ទៅរកមើលព្រួញដើម្បីឱ្យឃើញស្លាកស្នាមបាញ់ត្រូវ។ គួរឱ្យសោកស្ដាយវាមានឈាមតិចពេកនៅលើព្រួញ និងនៅលើដី។

ខ្ញុំអន់ចិត្តបន្ដិចចំពោះការបាញ់របស់ខ្ញុំ ក៏ប៉ុន្ដែខ្ញុំដឹងថាក្ដាន់មុខជាក្រាបចុះដេកក្នុងគុម្ពោធព្រៃនោះ ហើយខ្ញុំមិនចង់បង្ខំវាឱ្យចេញមកក្រៅនៅឡើយទេ។ ខ្ញុំធ្លាប់បាញ់ក្ដាន់ជាច្រើនមកហើយកាលពីមុនហើយឃើញមានឈាមតិច ហើយខ្ញុំដឹងថារឿងល្អបំផុតដែលត្រូវធ្វើគឺត្រូវទុកឱ្យវាអង្គុយចុះមួយសន្ទុះសិន។ ដូច្នេះហើយខ្ញុំដើរឡើងទៅវិញដើម្បីទទួលទានអាហារពេលព្រឹកឱ្យរួចរាល់ ហើយប្រាប់គ្រប់គ្នាពីរឿងនោះ ហើយបន្ទាប់មកប្រាប់កូនប្រុសៗរបស់ខ្ញុំថា ខ្ញុំត្រូវការឱ្យពួកគេដើរទៅទីវាលជាមួយខ្ញុំ ដើម្បីមើលថាតើយើងអាចរកក្ដាន់ឈ្មោលឃើញដែរឬទេ។ កាលនោះខ្ញុំសង្ឃឹមថាយើងនឹងរកឃើញក្ដាន់ឈ្មោលដែលត្រូវរបួសធ្ងន់ជាងអ្វីដែលបង្ហាញឱ្យឃើញនៅលើព្រួញ ហើយវាមុខជាបានងាប់បាត់ទៅហើយ។ ក៏ប៉ុន្ដែខ្ញុំបានដឹងថាវាតែងតែមានឱកាសណាមួយដែលខ្ញុំបានបាញ់ទៅទាបពេក ហើយក្ដាន់ឈ្មោលគ្រាន់តែរងរបួសតែប៉ុណ្ណោះ។

បន្ទាប់ពីចាំអស់ប្រហែលជាពីរម៉ោង ពួកយើងបានចេញទៅក្រៅ ហើយយើងទាំងបីនាក់បានបំបែកគ្នាពេញទីវាលនោះ។ ខ្ញុំលើកធ្នូឡើងហើយត្រៀមជាស្រេចក្នុងករណីដែលខ្ញុំត្រូវការវា។ ភ្លាមៗនោះ នៅទីវាលម្ខាងទៀតធីមបានធ្វើឱ្យក្ដាន់ឈ្មោល

លោតឡើង។ វាមិនបានឃើញខ្ញុំទេ ហើយវាកំពុងតែរត់តម្រង់មកខាងខ្ញុំ។ ពេលវាកំពុងរត់វាស្រាប់តែឃើញថម ហើយវាក៏ឈប់ដើម្បីគិតមើលថាត្រូវរត់ទៅផ្លូវណា។

ក្តាន់ឈ្មោលនៅចម្ងាយប្រមាណជា៦០ ទៅ៦៥ ម៉ែត្រពីខ្ញុំ វាឆ្ងាយពេកក្នុងការបាញ់ធ្នូឆ្លងកាត់ដោយប្រើធ្នូដែលមានកម្លាំងខ្សោយនៅថ្ងៃនោះ ក៏ប៉ុន្តែខ្ញុំបានដឹងថានោះគឺជាឱកាសតែមួយគត់ដែលខ្ញុំមាន។ ខ្ញុំរហ័សលើកធ្នូឡើង ហើយតម្រង់ទៅពីលើសត្វក្តាន់ និងបាញ់ព្រួញទៅ។ ពិតជាអស្ចារ្យណាស់ព្រួញបាញ់តម្រង់ទៅរកក្តាន់ឈ្មោល ហើយបាញ់ចំយ៉ាងត្រង់ចូលទៅចំណុចកណ្តាលត្រង់ករបស់វា។ វាក៏រត់យ៉ាងលឿនទៅក្រោមជម្រាលមើកលែងឃើញ។ ខ្ញុំស្រទ្បាំងកាំង។ ពិតជាអស្ចារ្យមែន យើងសន្សឹមៗដើរទៅតាមទិសដៅដែលក្តាន់បានរត់ទៅ ហើយក៏ឃើញវាដេកនៅខាងមុខប្រមាណជាជាង១០០ម៉ែត្រពីយើង។ ក្បាលវាងើយទៅលើតែវាមិនបានឃើញយើងទេ ដូច្នេះហើយយើងក៏សម្រេចចិត្តត្រលប់ទៅវិញ ហើយចាំមកម្តងទៀតនៅពេលក្រោយ។

**មែនហើយ ព្រះរាជ្យមានលក្ខណៈជាក់លាក់ដូច្នេះហើយ! គ្មាននរណាម្នាក់ធ្លាប់ប្រាប់ខ្ញុំថាព្រះរាជ្យធ្វើការយ៉ាងដូច្នេះទេ ថាព្រះរាជ្យជាក់លាក់យ៉ាងដូច្នេះ ហើយនឹងប្រាប់ថាយើងពិតជាមានសិទ្ធិអំណាចប្រភេទនោះឡើយ។**

និយាយទៅពេលក្រោយនោះគឺជាពេលក្រោយយូរទៀត ដោយសារខ្ញុំមានថ្ងៃដ៏រវល់កំពុងរង់ចាំខ្ញុំនៅក្រុមជំនុំ ហើយខ្ញុំមិនអាចត្រលប់ទៅផ្ទះវិញបានទេរហូតទាល់តែពេលយប់។ ធីម និងខ្ញុំបានយកពិលមួយ ហើយដើរចេញទៅកន្លែងដែលយើងឃើញក្តាន់ដេកនោះវិញ។ នៅទីនោះយើងក៏ឃើញវា វានៅប្រមាណជាពីរបីម៉ែត្រឆ្ងាយពីកន្លែងដែលវានៅពីមុន។ ខ្ញុំប្រញ៉ាប់មើលទៅស្នែង ហើយនៅចំពោះមុខខ្ញុំនោះគឺជាក្តាន់ឈ្មោលដែលមានស្នែងបែកខ្នែងជាប្រាំពីរ។ ខ្ញុំលម្លឹងមើលទៅក្តាន់នោះដោយ

ស្ងប់ស្ងៀង។ ធីម និងខ្ញុំបានអរព្រះគុណព្រះជាម្ចាស់សម្រាប់ក្ដាន់នោះ ហើយពេលដែលយើងកំពុងលើករាយកទៅផ្ទះយើងបាននិយាយគ្នាពីព្រះរាជ្យ និងអ្វីដែលយើងទើបតែបានឃើញនោះ។

មែនហើយ ព្រះរាជ្យមានលក្ខណៈជាក់លាក់យ៉ាងដូច្នេះហើយ! គ្មាននរណាម្នាក់ធ្លាប់ប្រាប់ខ្ញុំថាព្រះរាជ្យធ្វើការយ៉ាងដូច្នេះទេ ថាព្រះរាជ្យជាក់លាក់យ៉ាងដូច្នេះ ហើយនឹងប្រាប់ថាយើងពិតជាមានសិទ្ធិអំណាចប្រភេទនោះឡើយ។

## របកគំហើញមួយផ្សេងទៀត

ខ្ញុំនៅនឹកចាំអំពីការប្រមាញ់ក្ដាន់មួយទៀត ដែលខ្ញុំបានសាបព្រោះគ្រាប់ពូជដើម្បីបានសត្វក្ដាន់ឈ្មោលដែលទើបមានកំពកស្នែងមួយក្បាល។ ក្ដាន់ដែលទើបមានកំពកស្នែងគឺជាក្ដាន់ដែលមានអាយុមួយឆ្នាំ ដែលមានស្នែងយ៉ាងតូច។ ដោយសារតែស្នែងតូចនោះហើយទើបធ្វើឱ្យវាមើលពីចម្ងាយទៅដូចជាក្ដាន់ញី។ នេះដោយសារតែគេរាប់ក្ដាន់ដែលទើបមានកំពកស្នែងនេះថាជាក្ដាន់ញីនៅក្នុងរដ្ឋអូហៃយ៉ូ។ សូមចំណាំថាពួកវាមិនមែនជាកូនក្ដាន់ទេ។ ពួកវាមិនធំខ្លាំងដូចជាក្ដាន់ដែលធំពេញរូបរាងទេ ក៏ប៉ុន្ដែក៏ស្ទើរតែប្រហាក់ប្រហែលគ្នាដែរ។

ដូច្នេះនៅថ្ងៃធម្មតាមួយនេះ ខ្ញុំបានឡើងទៅលើរានប្រមាញ់របស់ខ្ញុំ ហើយមានហ្វូងក្ដាន់មួយហ្វូងចូលមក ប្រហែលជា៩ទៅ១០ក្បាល។ ពួកវានៅរាងឆ្ងាយពីកន្លែងដែលធ្នូខ្ញុំអាចបាញ់ទៅដល់បន្ដិច ក៏ប៉ុន្ដែពួកវាកំពុងតម្រង់មករកខ្ញុំសន្សឹមៗ។ ភ្លាមៗនោះអ្នកជិតខាងរបស់ខ្ញុំស្រាប់តែបញ្ឆេះឡានរបស់គាត់។ ដោយសារតែសំឡេងនោះហ្វូងសត្វទាំងមូលបាននាំគ្នាចាកចេញដោយរត់តម្រង់ទៅរកផ្លូវឆ្ងាយពីខ្ញុំ។ ខ្ញុំបានស្រែកឮៗថា «ក្ដាន់ដែលទើបមានកំពកស្នែងយើងបញ្ជាឱ្យឯងមកវិញ ហើយឈរនៅខាងក្រោមដើមឈើរបស់យើង»។ ហើយនេះជារូបភាពដែលខ្ញុំទទួលបាន។ វាគឺជាចម្ការពោតដែលគេប្រមូលផលរួចហើយ ហើយក្ដាន់ទាំងប្រាំបួនបានរត់ចេញទៅឆ្ងាយ

ពីខ្ញុំ។ នៅពេលខ្ញុំស្រែកមានក្តាន់មួយរត់ចេញពីហ្វូង ហើយនៅបន្តរត់ជារង្វង់ត្រលប់មកក្រោយវិញមកនៅក្រោមរានប្រមាញ់លើដើមឈើរបស់ខ្ញុំតែម្តង ហើយវាក៏ឈប់នៅទីនោះ! ខ្ញុំបានយកក្តាន់នោះមកផ្ទះ ហើយប្រាកដណាស់ថាវាគឺជាក្តាន់ដែលទើបមានកំពកស្នែងមួយក្បាល។

នេះគឺជារឿងរ៉ាវដែលខ្ញុំនៅតែបន្តមើលឃើញម្តងហើយម្តងទៀត។ ខ្ញុំនឹងពិតាក្សាបន្ថែមទៀតអំពីរបៀបដែលព្រះរាជ្យមានលក្ខណៈលម្អិត និងច្បាស់លាស់ប៉ុណ្ណានៅក្នុងសៀវភៅនេះក្នុងពេលក្រោយទៀត ក៏ប៉ុន្តែសម្រាប់ពេលនេះសូមគ្រាន់តែដឹងថាអ្វីម៉្យាងដ៏អស្ចារ្យកំពុងតែកើតមានឡើងនៅត្រង់នេះ។

ព្រះរាជ្យបានកែប្រែជីវិតយើង ហើយយើងមិនអាចឈប់ប្រាប់មនុស្សអំពីព្រះរាជ្យបានទេ។ យើងមានរឿងជាច្រើន ហើយយើងក៏បានឃើញរឿងជាច្រើនដែរ។ យើងបានឃើញមនុស្សស្លាប់ហើយរស់ឡើងវិញ សាច់ដែលដុះបានរលាយបាត់តែម្តង ក៏ដូចជារឿងអស្ចារ្យទាក់ទងនឹងហិរញ្ញវត្ថុ និងរឿងអស្ចារ្យជាច្រើននៃការជួយសង្គ្រោះ និងការណែនាំផ្លូវ។ ដោយមានការស្រេកឃ្លានក្នុងការប្រាប់ដល់មនុស្សអំពីដំណឹងល្អរបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ឌ្រិនដា និងខ្ញុំមានអារម្មណ៍ថាទទួលបានការដឹកនាំឱ្យចាប់ផ្តើមក្រុមជំនុំ Faith Life Church ក្នុងឆ្នាំ១៩៩៥ ដើម្បីជួយដល់មនុស្សឱ្យបានយល់ពីព្រះរាជ្យ។ បន្ទាប់មកព្រះជាម្ចាស់បានណែនាំយើងឱ្យចាប់ផ្តើមកម្មវិធី Faith Life Now ដែលជាព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់យើងក្នុងឆ្នាំ២០០៦ ដែលចាក់ផ្សាយព័ន្ធកិច្ចរបស់យើងតាមទូរទស្សន៍ទៅកាន់ពេលវេលាតាមតំបន់ទាំងអស់នៅលើពិភពលោកជារៀងរាល់ថ្ងៃ។ យើងបានដឹងថាមានមនុស្សគ្រប់ទីកន្លែងចង់ដឹងពីរបៀបរស់នៅក្នុងជីវភាពដែលមានសេរីភាព និងជ័យជម្នះស្របតាមព្រះរាជ្យនេះ។

## ព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការសម្រាប់មនុស្សគ្រប់គ្នា

ពេលខ្ញុំអង្គុយចុះដើម្បីសរសេរជំពូកនេះ នាពេលព្រឹកនេះខ្ញុំបានបើកមើលអ៊ីមែលរបស់ខ្ញុំ។ យើងបានទទួលអ៊ីមែលជារៀងរាល់ថ្ងៃពីមនុស្សជាច្រើនប្រាប់យើងពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់កំពុងផ្លាស់ប្តូរជីវិតរបស់ពួកគេផងដែរ។ ខ្ញុំបានគិតថាខ្ញុំនឹងឱ្យអ្នកក្លាយជាផ្នែកមួយនៅក្នុងថ្ងៃរបស់ខ្ញុំដូចដែលអ៊ីមែលនេះទើបតែបានផ្ញើចូលមកពីរបីនាទីមុននេះដែរ។

> តើខ្ញុំជានរណាទៅទើបធ្វើឱ្យទ្រង់ខ្វល់ខ្វាយពីខ្ញុំ? កាលពីរបីឆ្នាំមុនខ្ញុំបានចាប់ផ្តើមស្តាប់ការបង្រៀនរបស់លោកគ្រូ ហើយតាំងពីពេលនោះមកខ្ញុំបានឃើញការអស្ចារ្យជាច្រើន។ ខ្ញុំបានឃើញការព្យាបាល និងការអស្ចារ្យជាច្រើនក្នុងរឿងហិរញ្ញវត្ថុ។ ហើយក្នុងពេលនេះខ្ញុំពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលដែលខ្ញុំបានមើលជុំវិញខ្លួន ហើយបានឃើញសេចក្តីល្អរបស់ទ្រង់។ ខ្ញុំបានឃើញមនុស្សដែលមានភាពខ្វះខាត និងឃើញមានទ្វាបើកចំហសម្រាប់ដំណឹងល្អ និងសេចក្តីពិត។ ខ្ញុំបានឃើញទ្វារជាច្រើនបានបើកចំហចំពោះសេចក្តីពិត! ហើយអ្វីដែលធ្វើឱ្យខ្ញុំកាន់តែមានការភ្ញាក់ផ្អើលនោះ គឺខ្ញុំឃើញហិបរបស់ខ្ញុំពេញ។ ទ្រង់បានធ្វើឱ្យខ្ញុំមាន ដើម្បីខ្ញុំមានលទ្ធភាពអាចឱ្យ ដើម្បីឱ្យអ្នកដទៃបានឃើញទ្រង់! ខ្ញុំគឺជាអ្នកត្រួតពិនិត្យផ្ទះឯករាជ្យម្នាក់។ ខ្ញុំតែងផ្តល់ដំបូន្មានដល់អ្នកត្រួតពិនិត្យវ័យក្មេងជាច្រើនជាទៀងទាត់ ហើយខ្ញុំបានចាប់ផ្តើមក្រុមអាជីវកម្មជាគ្រិស្តបរិស័ទ ជាកន្លែងដែលយើងនិយាយគ្នាអំពីការត្រាស់ហៅឱ្យមានចិត្តសប្បុរស និងបង្កើតឱ្យមានជំនាន់ក្រោយ...ជាជំនាន់មួយដែលដឹងថាព្រះរាជ្យមិនមែនជាការប្រកួតប្រជែងទេ ក៏ប៉ុន្តែគឺជាភាពពេញបរិបូរហូរហៀរ។ នេះជាការពិតដែលការបង្រៀនរបស់លោកគ្រូបានផ្លាស់ប្តូរជីវិតខ្ញុំ ហើយឥលូវនេះការផ្លាស់ប្តូរបានបន្តទៅកាន់អ្នកដទៃទៀត ហើយដោយសារទ្រង់បានបង្កើតខ្ញុំ ឥលូវនេះអ្នកដទៃស្តាប់ និងមើលឃើញសិរីល្អ

របស់ទ្រង់ដែរ។ វាគ្មានអ្វីគួរឱ្យសរសើរខ្លួនឯងទេ ពេលមើលឃើញអ្វីដែលទ្រង់បានធ្វើ និងរបៀបដែលទ្រង់បន្តផ្គត់ផ្គង់។ ខ្ញុំសូមអរគុណចំពោះព័ន្ធកិច្ចរបស់លោកគ្រូ!

ដោយក្តីគោរព

B.F.

Knoxville, TN

យើងទទួលបានអ៊ីមែលប្រភេទនេះគ្រប់ពេល។ ក៏ប៉ុន្តែយើងក៏ទទួលបានសំណួរជាច្រើនអំពីដំណើរការរបស់ព្រះរាជ្យដែរ។ មនុស្សជាច្រើនសួរពីរបៀបប្រតិបត្តិនៅក្នុងព្រះរាជ្យ និងរបៀបមើលឃើញរឿងជាច្រើនដែលខ្រិនដា និងខ្ញុំបានឃើញ។ នោះហើយគឺជាគោលបំណងរបស់សៀវភៅនេះជាសៀវភៅទីបួននៅក្នុងស៊េរីសៀវភៅ «បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃព្រះរាជទាន» របស់ខ្ញុំ។ ប្រសិនបើអ្នកមានសៀវភៅផ្សេងទៀតរបស់ខ្ញុំនោះអ្នកដឹងហើយថាខ្ញុំបានចំណាយពេលមួយចំនួនរហូតមកដល់ត្រង់នេះ ដើម្បីរំឭកពីគំនិតសំខាន់ៗមួយចំនួនសម្រាប់មនុស្សគ្រប់គ្នាដែលចង់ប្រតិបត្តិនៅក្នុងព្រះរាជ្យត្រូវការដឹង។

ក៏ប៉ុន្តែឥលូវនេះខ្ញុំចង់ចូលទៅឱ្យកាន់តែស៊ីជម្រៅនៅក្នុងមុខងាររបស់ព្រះរាជ្យ ហើយដោយមានក្តីសង្ឃឹមក្នុងជួយអ្នកឱ្យយល់បន្ថែមទៀតអំពីរបៀបរស់នៅក្នុងព្រះរាជ្យឱ្យមានលទ្ធផលផ្សេងៗ។ ខ្ញុំចង់ចាប់ផ្តើមដោយការបង្ហាញពីអ្វីដែលខ្ញុំហៅថាជំហានជាមូលដ្ឋានទាំង៥ ដើម្បីទទួលបានព្រះរាជទាន (ការផ្គត់ផ្គង់) ដែលអ្នកត្រូវការពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំដែរ។

## ជំហានជាមូលដ្ឋានទាំងប្រាំដើម្បីទទួលបានព្រះរាជទានដែលអ្នកត្រូវការ

សូមចាប់ផ្តើមជាមួយនឹងរឿងនៅក្នុងគម្ពីរម៉ាកុស ៨:១៤-២១។

*ពួកសិស្សភ្លេចយកនំប៉័ងទៅជាមួយ។ ក្នុងទូកគេមាននំប៉័ងតែមួយដុំប៉ុណ្ណោះ។ ព្រះយេស៊ូមានព្រះបន្ទូលដាស់តឿនគេថា៖ «ចូរអ្នករាល់គ្នាប្រុងប្រយ័ត្ននឹងមេម្សៅរបស់ពួកផារីស៊ី ព្រមទាំងមេម្សៅរបស់ស្ដេចហេរ៉ូដ ឱ្យមែនទែន»។*

*ពួកសិស្សជជែកគ្នាថា៖ «លោកមានប្រសាសន៍ដូច្នេះ មកពីយើងគ្មាននំប៉័ងទេដឹង»។*

*ព្រះយេស៊ូជ្រាបគំនិតពួកគេ ក៏មានព្រះបន្ទូលថា៖ «__**ម្ដេចក៏ជជែកគ្នាអំពីរឿងគ្មាននំប៉័ងដូច្នេះ?**__ តើអ្នករាល់គ្នាពុំទាន់ស្ដាប់បាន ពុំទាន់យល់សេចក្ដីទេឬ? ឬមួយអ្នករាល់គ្នាមានចិត្តរឹងរូស? អ្នករាល់គ្នាមានភ្នែកតែមើលមិនឃើញ មានត្រចៀកតែស្ដាប់មិនឮឬ!។ __**តើអ្នករាល់គ្នាចាំឬទេ?**__ កាលខ្ញុំកាច់នំប៉័ងប្រាំដុំចែកឱ្យមនុស្សប្រាំពាន់នាក់ តើអ្នករាល់គ្នាប្រមូលនំប៉័ងដែលសល់បានប៉ុន្មានល្អី?»។*

*គេទូលព្រះអង្គថា៖ «ដប់ពីរល្អី»។*

*«ចុះកាលខ្ញុំកាច់នំប៉័ងប្រាំពីរដុំ ចែកឱ្យមនុស្សបួនពាន់នាក់ តើអ្នករាល់គ្នាប្រមូលបានប៉ុន្មានជាល?»។*

*គេទូលថា៖ «ប្រាំពីរជាល»។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នានៅតែពុំទាន់យល់ទៀតឬ?»។*

— ម៉ាកុស ៨:១៩-២១

និយាយជាទូទៅគឺព្រះយេស៊ូមានបន្ទូលថា «អ្នករាល់គ្នាអើយ តើអ្នកចាំឬទេ? យើងបានដោះស្រាយរឿងបែបនេះរួចមកហើយ ហើយអ្នកក៏បានឃើញរបៀបដែលយើងគ្រប់គ្រងទុកដាក់នំប៉័ងរួចមកហើយកាលពីពេលមុន»។ ក៏ប៉ុន្តែពួកសិស្សនៅតែមិនយល់អំពីរឿងនេះ។ ដូច្នេះហើយព្រះយេស៊ូប្រាប់ពួកគេឱ្យគិតឡើងវិញពីអ្វីដែលបានកើតឡើងពីពេលអតីតកាល។ ទ្រង់បានប្រទានសញ្ញាប្រាប់ផ្លូវមួយដ៏ច្បាស់លាស់។ «សូមត្រលប់ទៅគិតពីពេលចុងក្រោយដែលយើងបានដោះស្រាយជាមួយនឹង

ស្ថានភាពដូចគ្នានេះ នោះអ្នកនឹងរកឃើញចម្លើយ»។ ខ្ញុំសូមណែនាំឱ្យរឿងនេះក្លាយជាចម្លើយរបស់យើងដែរ។ ពិតមែនហើយ យើងឃើញថានំប៉័ង និងត្រីបានពុហុគុណឡើង នរណាៗក៏មើលឃើញរឿងនោះដែរ ក៏ប៉ុន្តែក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងចង់មើលឱ្យឃើញស៊ីជម្រៅជាងនេះ។ តើរឿងនោះកើតឡើងបានយ៉ាងដូចម្ដេច? ដូច្នេះសូមត្រលប់ចូលសាច់រឿងជាច្រើនដែលព្រះយេស៊ូបានយកមកធ្វើជាឯកសារយោង និងបានស្វែងរកសញ្ញាប្រាប់ផ្លូវផ្សេងៗ។

> *ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សិស្សនាំគ្នាចូលមកគាល់ព្រះយេស៊ូទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ថ្ងៃក៏ជិតលិចផង សូមប្រាប់អ្នកទាំងនេះឱ្យត្រលប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះ តាមភូមិជិតៗនេះ»។ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ!»។ គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីរយដួងទៅទិញម្ហូបអាហារឱ្យគេបរិភោគឬ?»។*
>
> *ព្រះអង្គមានព្រះបន្ទូលសួរគេថា៖«ទៅមើលមើល៍ អ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*
>
> *ព្រះយេស៊ូបង្គាប់ពួកសិស្សឱ្យប្រាប់បណ្ដាជន អង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉័ងប្រទានឱ្យពួកសិស្សដើម្បីឱ្យគេចែកបណ្ដាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឱ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំប៉័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំប៉័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

## តើអ្នកចាំឬទេ?

— ម៉ាកុស ៦:៣៥-៤៤

ខ្ញុំច្បាស់ក្នុងចិត្តថាពួកសិស្សមានការភ្ញាក់ផ្អើលជាខ្លាំង ក្នុងពេលសួរព្រះសុំឱ្យព្រះយេស៊ូបញ្ជូនមនុស្សឱ្យទៅរកម្ហូបនៅកន្លែងផ្សេង ព្រះយេស៊ូទម្លាក់រឿងនេះទៅឱ្យពួកគេវិញ ហើយមានបន្ទូលថា «អ្នករាល់គ្នាយកម្ហូបឱ្យគេបរិភោគចុះ»។ នៅក្នុងរឿងនេះ «ពួកគេ» មានលើស ៥.០០០នាក់ទៅទៀត។ ព្រះគម្ពីរចែងថាមានមនុស្ស ៥.០០០នាក់នៅទីនោះ ដូច្នេះខ្ញុំអាចសន្មត់ថាមានទាំងស្ត្រី និងក្មេងៗនៅទីនោះដែរ ដែលនាំឱ្យចំនួនពិតមានទៅដល់ ១៥.០០០ ទៅ ២០.០០០នាក់។ ខ្ញុំគិតថានរណាក៏យល់ស្របដែរថាមានមនុស្សជាច្រើនដែលត្រូវការអាហារ ជាពិសេសក្នុងពេលដែលគ្មានការដាស់តឿនសមស្របណាមួយ ឬការរៀបចំណាមួយត្រៀមទុកជាមុនឡើយ។

**ព្រះយេស៊ូចង់ឱ្យប្រាកដថាពួកគេនឹងដឹងពីរបៀបគ្រប់គ្រងនៅក្នុងជីវិតចេញពីទស្សនៈផ្សេងមួយ គឺជាទស្សនៈរបស់ព្រះរាជ្យ។**

ជាការពិតណាស់ ខ្ញុំជឿថាព្រះយេស៊ូសព្វព្រះហឫទ័យប្រទានអាហារដល់មនុស្ស ក៏ប៉ុន្តែខ្ញុំគិតថាទ្រង់ប្រហែលជាសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាលសិស្សរបស់ទ្រង់នៅក្នុងស្ថានភាពនេះជាងអ្វីៗទាំងអស់។ ខ្ញុំជឿថាហេតុនេះហើយបានជាទ្រង់មានបន្ទូលទៅពួកគេថា «អ្នករាល់គ្នាយកម្ហូបឱ្យគេបរិភោគចុះ»។ ពួកគេបានមើលឃើញព្រះយេស៊ូធ្វើការអស្ចារ្យជាច្រើន ក៏ប៉ុន្តែឥលូវនេះគឺជាពេលដែលពួកគេត្រូវធ្វើវិញម្តង។ នៅចុងបញ្ចប់ទ្រង់នឹងត្រូវចាកចេញក្នុងពេលឆាប់ៗនេះហើយ ហើយព្រះយេស៊ូចង់ឱ្យប្រាកដថាពួកគេនឹងដឹងពីរបៀបគ្រប់គ្រងនៅក្នុងជីវិតចេញពីទស្សនៈផ្សេងមួយគឺជាទស្សនៈរបស់ព្រះរាជ្យ។

## ជំហានទី ១៖ តើអ្នកមានអ្វីខ្លះ?

*ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំបុ័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*

កូនសោរសំខាន់គឺនៅត្រង់នេះ។ ព្រះយេស៊ូមិនបានមានបន្ទូលថា «ចូរធ្វើឱ្យដុំថ្មក្លាយជានំបុ័ងចុះ» នោះទេ។ ការធ្វើបែបនោះគឺខុសច្បាប់ខាងវិញ្ញាណ។ ផ្ទុយទៅវិញទ្រង់សុំពួកគេនូវអ្វីដែលពួកគេមានរួចទៅហើយ។ ទ្រង់ជ្រាប់ថាពួកគេមានត្រី និងនំបុ័ងមិនគ្រប់ដើម្បីឱ្យមនុស្សបរិភោគទេ ហើយការប្រាប់បែននោះមិនមែនជាចេតនានៃសំណើរបស់ទ្រង់ទេ។ ឥលូវងាកមកមើលពីគំនិតធម្មតាវិញ ទស្សនៈទាំងមូលនៃការប្រទានអាហារដល់អ្នកទាំងនោះស្តាប់ទៅដូចជាឆោតល្ងង់ណាស់។ សិស្សទាំងអស់បានដឹងដោយមិនចាំបាច់មើលទេថាគ្មានអាហារគ្រប់សម្រាប់មនុស្ស ២០.០០០នាក់បរិភោគទេ ទោះបីជាពួកគេងាកមើលទៅខាងណាក្តី។ តើអ្នកអាចស្រមៃបានទេពីអ្វីដែលពួកគេកំពុងគិតបានឬទេពេលព្រះយេស៊ូប្រាប់ពួកគេឱ្យចេញទៅមើលថាមាននំបុ័ង និងត្រីប៉ុន្មានកន្ទុយនៅទីនោះឱ្យប្រាកដ? ហើយត្រលប់មកប្រាប់ដំណឹងវិញថាអ្វីដែលពួកគេអាចរកបានគឺមានតែនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ? ពិតជាចម្លែកណាស់មែនទេ?

ខ្ញុំសូមបកស្រាយពីការសន្ទនានេះ។ ក្នុងនាមជាគ្រូគង្វាលម្នាក់ ខ្ញុំធ្លាប់បានជួយគ្រួសារជាច្រើននៅក្នុងកាលៈទេសៈលំបាកៗខាងផ្នែកហិរញ្ញវត្ថុក្នុងពេលអតីតកាល ប្រហែលជាតាមរយៈការជួយពួកគេបង់ប្រាក់កម្ចីទិញផ្ទះមួយខែ ឬថ្លៃផ្ទះជួល ក៏ដូចជាបង់ប្រាក់ថ្លៃវិកយបត្រផ្សេងៗ ឬជួយទិញគ្រឿងម្ហូបអាហារមួយចំនួន។ ក៏ប៉ុន្តែសូមសន្មតថាខ្ញុំបានដឹងថាចម្លើយពិត គឺមិនមែនជាការជួយពួកគេដោយទទេៗឡើយ ក៏ប៉ុន្តែផ្ទុយទៅវិញខ្ញុំដឹងថាចម្លើយពិតនោះគឺជាព្រះរាជ្យ។

ការសន្ទនានោះអាចនឹងស្តាប់ទៅមានលក្ខណៈដូច្នេះ «សួស្តីលោកគ្រូហ្គារី ខែនេះយើងគ្មានលុយគ្រប់គ្រាន់ទេ ហើយយើងជិតត្រូវគេបណ្តេញចេញពីផ្ទះរបស់យើងហើយ។ តើក្រុមជំនុំអាចជួយពួកយើងបានដែរឬទេ»? «ប្រាកដណាស់ ខ្ញុំអាចជួយអ្នកបាន ហើយនេះជាដំបូន្មានរបស់ខ្ញុំ អ្នកបង់ផ្តាច់ផ្ទះនោះតែម្តងទៅ ហើយអ្នកនឹងមិនបាច់បារម្ភពីការបង់ប្រាក់ទៀតនោះទេ»។ ពួកគេនឹងមើលមុខខ្ញុំ ហើយនិយាយថា « លោកគ្រូអើយ លោកគ្រូមិនដឹងទេ។ យើងគ្មានទាំងលុយបង់ប្រាក់ថ្លៃផ្ទះនៅខែក្រោយផង កុំថាឡើយតែប្រាក់បង់ផ្តាច់ផ្ទះនោះ»។ ខ្ញុំឆ្លើយតបថា «ខ្ញុំដឹង អ៊ីចឹងហើយបានជាខ្ញុំប្រាប់អ្នកឱ្យបង់ផ្តាច់យកផ្ទះនោះតែម្តងទៅ កុំឱ្យអ្នកត្រូវបង់ប្រាក់ថ្លៃផ្ទះតទៅទៀត»។

ហើយប្រសិនបើខ្ញុំសុំឱ្យពួកគេទៅមើលថាតើពួកគេមានលុយប៉ុន្មានជាក់ស្តែងដែលអាចយកមកប្រើប្រាស់ដើម្បីបង់ថ្លៃផ្ទះនោះ ពួកគេមុខជាគិតថាខ្ញុំនិយាយមិនដឹងអីជាមិនខានទេ។ ក៏ប៉ុន្តែប្រសិនបើដោយសារតែការស្តាប់បង្គាប់ខ្ញុំ ពួកគេពិតជាទៅរកមើលម្តងទៀត ហើយនឹងមកវិញហើយប្រាប់ខ្ញុំថា «យើងបានពិនិត្យមើលម្តងទៀតហើយលោកគ្រូ យើងរកបានទាំងអស់តែ២០ដុល្លារប៉ុណ្ណោះ ក៏ប៉ុន្តែចំនួនដែលត្រូវបង់កម្ចីទិញផ្ទះនោះគឺចំនួន ៣៦០.០០០ដុល្លារ»។ ខ្ញុំគិតថាអ្នកទទួលបានរូបភាពត្រង់នេះហើយ។ ពួកគេមុខជាគិតថាខ្ញុំឆ្កួតមិនខាន មែនឬទេ?

នេះហើយជាអារម្មណ៍របស់ពួកសិស្សនៅក្នុងថ្ងៃនោះ ពួកគេច្របូកច្របល់ទាំងអស់គ្នាតែម្តង។ តើនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយអាចឱ្យមនុស្ស ២០.០០០នាក់បរិភោគគ្រប់ឬ?

## អ្នកច្រូតផលអ្វីដែលអ្នកបានសាបព្រោះ

ជាការពិតណាស់ មុនពេលយើងចូលទៅកាន់តែស៊ីជម្រៅក្នុងរឿងនេះ ខ្ញុំត្រូវការចេញក្រៅសាច់រឿងបន្តិចដើម្បីបង្ហាញឱ្យឃើញច្បាប់របស់ព្រះរាជ្យមួយទៀតដែល

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ត្រូវលើកយកមកនិយាយក្នុងពេលបន្តិចទៀតនេះ។ នំប៉័ងពហុគុណចេញជានំប៉័ង ហើយត្រីពហុគុណចេញជាត្រី។ ដូច្នេះសូមសរសេរចំណុចនេះទុក។

## អ្នកត្រូវតែស្រាយអ្វីដែលអ្នកត្រូវការមួយចំនួនចូលទៅក្នុងព្រះរាជ្យដើម្បីឱ្យវាបានពហុគុណឡើង!

ខ្ញុំសូមចូលទៅកាន់ឧទាហរណ៍មួយទៀតនៅក្នុងព្រះគម្ពីរ ហើយខ្ញុំនឹងត្រលប់ចូលទៅក្នុងសាច់រឿងនៅក្នុងគម្ពីរម៉ាកុសជំពូកទី៦។ សូមមើលទៅគម្ពីរ ២ ពង្សាវតារក្សត្រ ៤:១-៧។

*មានស្ត្រីមេម៉ាយម្នាក់ជាភរិយារបស់បុរសមួយរូប ដែលជាសមាជិករបស់ក្រុមព្យាការី បានមកជួបលោកអេលីសេ ហើយអង្វរលោកថា៖ «ប្ដីរបស់នាងខ្ញុំ ជាអ្នកបម្រើរបស់លោកស្លាប់ផុតហើយ។ លោកក៏ជ្រាបដែរថា អ្នកបម្រើរបស់លោក គោរពកោតខ្លាចព្រះអម្ចាស់ណាស់។ ឥលូវនេះ ម្ចាស់បំណុលបានមកទាមទារយកកូនប្រុសទាំងពីរនាក់របស់នាងខ្ញុំ ទៅធ្វើជាបាវបម្រើរបស់គេ»។ លោកអេលីសេមានប្រសាសន៍ថា៖ **<u>«តើនាងចង់ឱ្យខ្ញុំធ្វើដូចម្ដេចចំពោះនាង? ចូរប្រាប់ខ្ញុំមកមើល នៅក្នុងផ្ទះនាងមានអ្វីខ្លះ?»។</u>***

*នាងឆ្លើយតបថា៖ «នៅក្នុងផ្ទះនាងខ្ញុំ គ្មានអ្វីក្រៅពីប្រេងមួយកូនដបប៉ុណ្ណោះ»។ លោកអេលីសេមានប្រសាសន៍ថា៖ «ចូរទៅខ្ចីដបទំនេរ ពីអ្នកជិតខាងឱ្យបានច្រើន គឺកុំខ្ចីតិចពេក។ ពេលមកដល់វិញ ត្រូវនាំគ្នាទាំងម្ដាយ ទាំងកូន ចូលទៅក្នុងផ្ទះ បិទទ្វារឱ្យជិត ហើយយកប្រេងចាក់ក្នុងដបទាំងនោះ។ ដបណាពេញត្រូវទុកដោយឡែក»។*

*នាងក៏ចាកចេញពីលោកទៅ ហើយនាំកូនចូលក្នុងផ្ទះបិទទ្វារជិត។ កូនទាំងពីរហុចដបមកឱ្យម្ដាយ រួចម្ដាយយកប្រេងមកចាក់ក្នុងដប។ ៦លុះដបទាំងអស់ពេញហើយ នាងប្រាប់កូនថា៖ «ហុចដបមួយទៀតមក!»។*

*កូនឆ្លើយថា៖ «អស់ដបហើយម៉ែ!»។ ពេលនោះ ប្រេងក៏ឈប់ហូរ។ នាងនាំដំណឹងនេះទៅជម្រាបអ្នកជំនិតរបស់ព្រះជាម្ចាស់ លោកមានប្រសាសន៍មកកាន់នាងថា៖ «ចូរយកប្រេងនេះទៅលក់សងបំណុលគេ រីឯប្រាក់ដែលនៅសល់ ចូរទុកចិញ្ចឹមជីវិតម្ដាយ និងកូនចុះ»។*

— ២ ពង្សាវតារក្សត្រ ៤:១-៧

សូមកត់សម្គាល់ថាព្យាការីមិនបាននិយាយថា «អ៊ីចឹង សូមចូលទៅរកមើលរបស់មានតម្លៃ ហើយមើលថាតើយើងមានអ្វីខ្លះ» គឺមិនដូច្នេះទេ គាត់បានដឹងពីវិធីមួយល្អជាងនេះដើម្បីដោះស្រាយបញ្ហានេះ។ គាត់និយាយថា «តើនាងចង់ឱ្យខ្ញុំធ្វើអ្វីចំពោះនាង»? ស្ត្រីនោះមុខជាច្របូកច្របល់បន្តិចហើយ ពេលដែលឆ្លើយតបទៅវិញថា «តើអាចធ្វើអ្វីចំពោះខ្ញុំបានទៅ? ខ្ញុំកំពុងត្រូវការលុយ!» ក៏ប៉ុន្តែគាត់មិនបានព្យាយាមនិយាយបង្អាប់ស្ត្រីនោះទេ។ គាត់បានសួរសំណួរមួយដ៏សំខាន់យ៉ាងខ្លាំង ដែលគាត់ដឹងថាវាដឹកនាំនាងទៅរកចម្លើយ។ វាគឺជាសំណួរតែមួយដូចគ្នាដែលនឹងដឹកនាំអ្នកទៅរកចម្លើយដែរ។

## <u>«តើនាងចង់ឱ្យខ្ញុំធ្វើដូចម្ដេចចំពោះនាង? ចូរប្រាប់ខ្ញុំមកមើល នៅក្នុងផ្ទះនាងមានអ្វីខ្លះ?»។</u>

### តើអ្នកមានអ្វីខ្លះ?

តើនៅក្នុងផ្ទះនាងមានអ្វីខ្លះ? ខ្ញុំជឿជាក់ថាគាត់តក់ស្លុតបន្តិចពេលឮសំណួរដោយសារតែគាត់បានប្រាប់រួចទៅហើយពីមូលហេតុដែលនាំឱ្យគាត់មកទីនោះ។

នាងតបថា៖ «នៅក្នុងផ្ទះនាងខ្ញុំ គ្មានអ្វីក្រៅពីប្រេងមួយកូនដបប៉ុណ្ណោះ»។

សូមសម្គាល់មើលអ្វីដែលគាត់បានបញ្ជាក់ «គ្មានអ្វីទាំងអស់» ក៏ប៉ុន្តែតើគាត់ពិតជាគ្មានអ្វីទាំងអស់មែនដែរឬទេ?

**ពេលដែលអ្នកថ្វាយទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ វាផ្លាស់ប្តូរការគ្រប់គ្រង ដោយការដាក់វានៅក្រោមការគ្រប់គ្រងស្របច្បាស់របស់ព្រះជាម្ចាស់ ដើម្បីឱ្យវាអាចពហុគុណបាន។**

ទេ អ្វីដែលគាត់បាននិយាយមិនត្រឹមត្រូវនោះទេ។ គាត់បាននិយាយថាគាត់មានប្រេងមួយកូនដប។ ត្រូវចំណុចតែម្តង! នោះហើយជាអ្វីដែលព្យាការីកំពុងរង់ចាំពីចម្លើយរបស់គាត់។

នោះក៏ជាសំណួរដែលអ្នកត្រូវសួរខ្លួនឯងដូចគ្នាដែរ។ ព្រះជាម្ចាស់គ្រាន់តែត្រូវការអ្វីម៉្យាងដែលស្ថិតក្រោមការគ្រប់គ្រងស្របច្បាប់របស់អ្នកដើម្បីទ្រង់ធ្វើការលើវា។

ដូច្នេះហើយសូមរំឭកពីជំហានទីមួយ។ អ្នកត្រូវតែថ្វាយអ្វីដែលអ្នកត្រូវការទៅព្រះជាម្ចាស់ខ្លះ។ ពេលដែលអ្នកថ្វាយទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ វាផ្លាស់ប្តូរការគ្រប់គ្រង គឺដាក់វានៅក្រោមការគ្រប់គ្រងស្របច្បាស់របស់ព្រះជាម្ចាស់ ដើម្បីឱ្យវាអាចពហុគុណបាន។ សូមចាំថាដើម្បីពហុគុណ អាចនឹងមិនមែនចង់និយាយអំពីអ្វីដែលយើងបានឃើញនៅក្នុងរឿងនេះទេ ដែលឃើញថានំប៉័ងរបស់អ្នកនឹងគ្រាន់តែពហុគុណឡើងដោយឯកឯងក្នុងទូចានដែលអ្នកបានដាក់វានោះទេ ទោះបីជាខ្ញុំធ្លាប់ឃើញរឿងប្រភេទនោះកើតឡើងហើយក៏ដោយ។ ក៏ប៉ុន្តែព្រះជាម្ចាស់នឹងបង្កើតផ្លូវមួយផ្ញើនំប៉័ងពហុគុណតាមរយៈអន្តរកម្មជាមួយនឹងអ្នកដទៃ។ នរណាម្នាក់នឹងមានចិត្តសប្បុរសចំពោះអ្នក ឬអ្នកទទួលបានការដំឡើងប្រាក់ខែ ឬក៏មានការសងប្រាក់ត្រលប់មកវិញដែលមិនបានរំពឹងទុកកើតឡើងផងដែរ។ មានរបៀបជាច្រើនដែលព្រះជាម្ចាស់អាចពហុគុណនំប៉័ងរបស់អ្នកត្រលប់ទៅឱ្យអ្នកវិញបាន។

## អ្នកអាចដាក់ឈ្មោះឱ្យលុយរបស់អ្នកបាន

ខ្ញុំលើកយកចំណុចដ៏សំខាន់មួយអំពីលុយមកនិយាយ។

## លុយអាចយកមកប្រើប្រាស់ជាគ្រាប់ពូជសម្រាប់អ្វីក៏បាន។

អ្នកដាក់ឈ្មោះឱ្យលុយជារៀងរាល់ថ្ងៃនៅក្នុងជីវិតអ្នក ពេលណាដែលអ្នកទិញរបស់អ្វីម្យ៉ាង។ ជាក់ស្តែងពេលដែលអ្នកនៅហាងទំនិញ ហើយអ្នកទិញនំប័ុង នោះគឺអ្នកបានប្តូរលុយរបស់អ្នកយកជានំប័ុង ឬនិយាយការពិតទៅអ្នកបានដាក់ឈ្មោះលុយរបស់អ្នកថា «នំប័ុង»។ សូមពិនិត្យមើលអ្វីដែលខ្ញុំចង់និយាយ។ ប្រសិនបើអ្នកត្រូវការនំប័ុង ពេលនេះអ្នកយល់ពីច្បាប់របស់ព្រះរាជ្យដែលមានឈ្មោះថាការសាបព្រោះ និងការច្រូតផល។ តាមរយៈការអនុវត្តច្បាប់នោះ អ្នកដឹងថាប្រសិនបើអ្នកសាបព្រោះនំប័ុង អ្នកនឹងទទួលបាននំប័ុង។ ក៏ប៉ុន្តែសន្មតថាអ្នកត្រូវការនំប័ុងតែអ្នកគ្មាននំប័ុងដើម្បីសាបព្រោះទេ។ សូមចាំថាលុយគឺជាប្រព័ន្ធនៃការដោះដូរមួយដ៏សាមញ្ញ។ យើងដាក់ឈ្មោះឱ្យវាជារៀងរាល់ថ្ងៃសម្រាប់អ្វីៗដែលយើងត្រូវការ រាប់តាំងពីទឹកដោះគោ និងថ្លៃជួលទៅដល់ស្បែកជើង និងអាហារផងដែរ។ ដូច្នេះហើយអ្នកអាចដាក់ឈ្មោះឱ្យលុយពេលដែលអ្នកឱ្យលុយក៏បានផងដែរ។

## អ្នកអាចដាក់ឈ្មោះឱ្យលុយរបស់អ្នកពេលដែលអ្នកឱ្យលុយ។

ក្រុមជំនុំ Faith Life Church នៅក្នុងទីក្រុង ញូវ អាល់បានី (New Albany) រដ្ឋអូហៃយ៉ូ គឺជាក្រុមជំនុំដែលឌ្រិនដា និងខ្ញុំបានចាប់ផ្តើមឡើងជាង២០ឆ្នាំមុន។ យើងបានសាងសង់មជ្ឈមណ្ឌល Now Center នៅក្នុងបរិវេណដែលក្រុមជំនុំ Faith Life Church តាំងនៅនៅក្នុងឆ្នាំ ២០០៨។ វាគឺជាគម្រោងមួយដ៏ធំមួយដែលត្រូវចំណាយលុយ ៦,៥លានដុល្លារនៅក្នុងពេលនោះ ជាគម្រោងដ៏ធំដែលត្រូវការមនុស្សប្រមាណជា ៥៥០នាក់ដើម្បីធ្វើវា។

ពិតណាស់ជាង១០ឆ្នាំមកនេះ អគាររបស់យើងបានពេញទៅហើយ។ យើងអាចទទួលមនុស្សបានប្រមាណជា ៣.០០០នាក់ប៉ុណ្ណោះនៅថ្ងៃចុងសប្តាហ៍។ ខ្ញុំអាចរៀបចំដំណើរការវេនថ្វាយបង្គំផ្ទាល់ត្រឹមតែបួនវេនប៉ុណ្ណោះជារៀងរាល់សប្តាហ៍។ ដូច្នេះ

ហើយទើបយើងសម្រេចចិត្តបន្ថែមចំនួនអគារពីលើអគារដែលយើងមានបច្ចុប្បន្ន នេះ។ កាលនោះវាគឺជាគម្រោងដែលនឹងមានតម្លៃ ១០លានដុល្លារ ហើយវានឹងជួយឱ្យយើងមានការរីកចម្រើនតាមរយៈការពង្រីកទំហំសាលប្រជុំ និងបន្ថែមទីធ្លាសម្រាប់កុមារ។ ក្នុងពេលជាមួយគ្នានោះដែរយើងបានដឹងថា ពេលវេលាដែលយើងត្រូវការដើម្បីរៃអង្គាសលុយ និងពេលវេលាដែលយើងត្រូវការដើម្បីសាងសង់អគារនោះនឹងជួបបញ្ហាមួយ។ នោះមានន័យថាយើងនឹងត្រូវការពេលវេលាពីរឆ្នាំកន្លះ ទុកជាពេលវេលារង់ចាំរហូតដល់ពេលដែលយើងអាចប្រើប្រាស់ទីធ្លាដែលយើងបន្ថែមនោះបាន។

ដោយការនឹកចាំពីរឿងនោះ យើងមានអារម្មណ៍ថាយើងគួរតែចាប់ផ្តើម និងឆ្ពោះទៅមុខក្នុងដំណើរការបន្ថែមចំនួនអគាររបស់យើង ក៏ប៉ុន្តែក្នុងពេលជាមួយគ្នានោះដែរយើងក៏ចាប់ផ្តើមរកមើលទីតាំងសម្រាប់បរិវេណក្រុមជំនុំយើង ដែលយើងមានអារម្មណ៍ថាយើងមានពេលសម្រាប់ដំណើរការនេះប្រមាណជា៦ខែ។ យើងជឿថាការធ្វើបែបនេះនឹងដកសម្ពាធខ្លះចេញពីបរិវេណក្រុមជំនុំដើម ខណៈដែលអនុញ្ញាតឱ្យក្រុមជំនុំមានការរីកចម្រើនក្នុងពេលតែមួយ។ ដូច្នេះហើយយើងបានបង្កើតក្រុមមួយដើម្បីចាប់ផ្តើមស្វែងរកទីតាំងសម្រាប់បរិវេណក្រុមជំនុំ។ យើងបានសិក្សាអំពីប្រជាជនយើង និងបានជ្រើសរើសតំបន់មួយនៅក្នុងទីប្រជុំជនមួយដែលយើងមានអារម្មណ៍ថាជាកន្លែងដ៏ល្អបំផុតនៅក្នុងទីក្រុងយើង។ យើងបានរកមើលហើយរកមើលទៀត ហើយស្ទើរតែដាក់ចិត្តពីរបីដងហើយថានឹងជ្រើសយកទីកន្លែងមួយចំនួនផ្សេងទៀត ក៏ប៉ុន្តែពេលយើងអង្គុយចុះដើម្បីធ្វើការមូលមតិគ្នាពិតប្រាកដថាគឺកន្លែងនោះហើយ យើងទាំងអស់គ្នាបែរជាមូលមតិគ្នាថាមានអ្វីម្យ៉ាងនៅតែមិនទាន់ត្រឹមត្រូវនៅឡើយ។ យើងទាំងអស់គ្នាមានអារម្មណ៍ថាយើងត្រូវការពិនិត្យមើលដួងចិត្តរបស់យើង។

ពេលវេលា៦ខែដើរទៅមុខយ៉ាងលឿន ហើយយើងឃើញថាបើប្រៀបធៀបទៅនឹងថ្ងៃទីមួយដែលយើងរក យើងនៅតែមិនទាន់ជិតរកបានកន្លែងសម្រាប់បរិវេណក្រុមជំនុំនៅឡើយ។ ខ្ញុំត្រូវទទួលស្គាល់ថាខ្ញុំខ្រិនដា និងខ្ញុំបានធ្លាក់ក្នុងការល្បួងឱ្យបាក់

ទឹកចិត្តបន្តិចក្នុងស្វែងរកនោះ។ យើងបានមើលគ្រប់ទាំងជម្រើសដែលយើងមាននៅក្នុងតំបន់ដែលយើងស្វែងរក ហើយនៅតែរកមិនបានអគារមួយណាដែលស័ក្តិសមពិតប្រាកដទេ។ ពិតមែនហើយយើងបានដាំគ្រាប់ពូជរបស់យើងតាំងពីដើមដំបូងនៃដំណើរនេះ ហើយយើងក៏ដឹងថាព្រះជាម្ចាស់មានអគារដ៏ល្អបំផុតសម្រាប់យើង តែយើងមិនបានរំពឹងថាវានឹងត្រូវចំណាយពេលយូរដល់ថ្នាក់នេះដើម្បីធ្វើឱ្យវាលេចចេញជារូបរាង។ ពាក្យណែនាំនៅទីនេះគឺ៖ ជួនកាលភាពល្អឥតខ្ចោះត្រូវការពេលវេលាយូរ!

ពេលនោះយើងបានរៀបចំកាលវិភាគដើម្បីចូលរួមក្នុងការកម្មវិធីរៃអង្គាសលុយតាមកម្មវិធីទូរទស្សន៍ ដើម្បីរៃអង្គាសលុយសម្រាប់បណ្ដាញទូរទស្សន៍ថ្មីមួយ។ ព្រឹត្តិការណ៍នោះមានរយៈពេលបីថ្ងៃ ដែលនឹងចាក់ផ្សាយផ្ទាល់ ក៏ដូចជាចាក់ផ្សាយនៅពេលព្រឹក និងពេលល្ងាចទាំងបីថ្ងៃតែម្ដង។ ខ្ញុំចាំបានថាកាលនោះគឺក្នុងថ្ងៃទីបី ហើយខ្ញុំអង្គុយនៅកន្លែងថតកម្មវិធីពេលដែលខ្ញុំឮព្រះជាម្ចាស់មានបន្ទូលមកខ្ញុំ។ ទ្រង់មានបន្ទូលថា «ចូរយកមូលប្បទានបត្រចំនួន ១០០.០០០ដុល្លារពីក្នុងព័ន្ធកិច្ច ហើយដាំគ្រាប់ពូជនោះទៅក្នុងកម្មវិធីឈោងចាប់តាមទូរទស្សន៍នេះដោយមានបំណងចង់បំបែករនាំងក្នុងការស្វែងបរិវេណក្រុមជនុំ។ ចូរយកមូលប្បទានបត្រនោះចូលទៅក្នុងវេនថ្វាយបង្គំនីមួយៗរបស់អ្នក ហើយសូមឱ្យក្រុមជំនុំទាំងមូលអធិស្ឋានសម្រាប់អំណោយនោះពេលដែលអ្នកប្រគល់វាចេញទៅ ហើយហៅការរកបរិវេណក្រុមជំនុំថាបានបញ្ចប់ហើយ!» ទ្រង់បន្តមានបន្ទូលដូច្នេះពេលដែលខ្ញុំអធិស្ឋានបណ្ដេញមារសាតាំង និងបញ្ជាឱ្យការច្របូកច្របល់ និងការពន្យារពេលបញ្ចប់ទៅ។ អ៊ីចឹងយើងក៏បានធ្វើរឿងនោះនៅចុងសប្ដាហ៍បន្ទាប់ក្នុងវេនថ្វាយបង្គំថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

នៅថ្ងៃបន្ទាប់ដែលជាថ្ងៃចន្ទ ក្រុមស្វែងរកទីតាំងក្រុមជំនុំរបស់ខ្ញុំបាននិយាយថា ភ្នាក់ងារអចលនទ្រព្យបានទូរសព្ទមក ហើយគាត់ទើបតែរកឃើញបរិវេណវិទ្យាល័យឯកជនមួយកន្លែង ដែលទើបដាក់លក់លើទីផ្សារ។ ពួកគេបានសម្រេចចិត្តទៅមើលកន្លែងនោះ។ ពេលពួកគេទៅមើលទីតាំងនោះ ពួកគេបានដឹងថាមានកម្មវិធីសិក្សាតាំង

ពីថ្នាក់ទី១ ដល់ទី១២ រួមមានទាំងថ្នាក់មត្តេយ្យសិក្សាផងដែរ។ វាមានតម្លៃទីផ្សារថ្លៃជាងចំនួនដែលយើងចង់ចំណាយសម្រាប់ទីតាំងក្រុមជំនុំច្រើនណាស់ ជាការពិតយើងកំពុងស្វែងរកជួលបរិវេណថ្មីដើម្បីសន្សំលុយទុកសម្រាប់ការសាងសង់បន្ថែមក្នុងបរិវេណក្រុមជំនុំដើម។ ទោះបីជាតម្លៃមិនមែនជាអ្វីដែលយើងអាចពិចារណាបានក៏ដោយ ឌ្រិនដា និងខ្ញុំបានសម្រេចចិត្តទៅមើលទីនោះនៅព្រឹកថ្ងៃអង្គារ។

អ្វីដែលយើងបានឃើញគឺបរិវេណសាលាដ៏អស្ចារ្យមានទំហំជាង ៨0.000 ម៉ែត្រការេ មានអគារបួន ទីលានរត់ប្រណាំងមួយ ក្លិបហាត់ប្រាណមួយ មានតារាងវាយតេន្នីសបួន និងអគារសិល្បៈដ៏ប្រណីតមួយ មានបន្ទប់ពិសោធវិទ្យាសាស្ត្រ ហើយនិយាយឱ្យច្បាស់ទៅគឺមានអ្វីគ្រប់យ៉ាងដែលកម្មវិធីសិក្សាពីថ្នាក់ទី១ ដល់ទី១២ត្រូវការ។ ផ្នែកដ៏អស្ចារ្យនៃរឿងនេះគឺនៅទីនេះមានបំពាក់គ្រឿងសង្ហារឹមពេញលេញ និងមានស្តុកទុកនូវសម្ភារៈបរិក្ខារជាច្រើន។ ឌ្រិនដា និងខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ក៏ប៉ុន្តែយើងអាចមើលឃើញថាយើងគ្មានផ្លូវទិញកន្លែងនេះទេ។

វាក៏ដល់ពេលល្ងាចដែលយើងត្រូវណាត់ជួបដៃគូរបស់យើងម្នាក់នៅយប់ថ្ងៃដដែលនោះ ដើម្បីជួបជុំគ្នា និងសួរសុខទុក្ខគ្នាធម្មតា។ យើងបានដូរកាលវិភាគសម្រាប់អាហារពេលល្ងាចមួយនេះប្រហែលជាបី ឬបួនដងកាលពីពីរខែមុនដោយសារតែយើងទាំងសងខាងមានការរវល់យ៉ាងខ្លាំង។ ក៏ប៉ុន្តែនៅយប់នោះយើងក៏អាចជួបគ្នាបាន។ ពេលយើងអង្គុយទទួលទានអាហារពេលល្ងាចនៅទីនោះ យើងបានចាប់ផ្តើមនិយាយគ្នាពីការបន្ថែមចំនួនអគារនៅក្នុងក្រុមជំនុំដើម។ ប្តីប្រពន្ធគាត់ទាំងពីរបានសួរយើងថាអ្វីៗមានដំណើរការទៅមុខបានលឿនប៉ុណ្ណាដែរ ហើយយើងបានប្រាប់ពួកគេអំពីការពន្យារពេលធំៗមួយចំនួនទាក់ទងនឹងការអនុញ្ញាតសាងសង់ និងគំរូប្លង់មេ ក៏ដូចជាបញ្ហាផ្សេងៗទៀតដែលយើងជួបប្រទះ។ យើងបានប្រាប់ពួកគាត់ថា មើលទៅយើងមុខជាបានចូលទៅក្នុងអគារសង់បន្ថែមនោះនៅចុងឆ្នាំ ២០២២ ឬក៏នៅរដូវផ្ការីកក្នុងឆ្នាំ២០២៣ អាស្រ័យទៅលើដំណើរការទៅមុខរបស់រឿងផ្សេងៗ។

ពួកគេបានសួរយើងភ្លាមៗថាតើយើងធ្លាប់គិតអំពីការបើកដំណើរការនៅក្នុងបរិវេណសាលាដែរឬទេ ហើយក៏ឆ្លើយថាធ្លាប់។ យើងបានពន្យល់ថាយើងបានព្យាយាមស្វែងរកយ៉ាងណាក្នុងរយៈពេល៦ខែមកនេះ ដោយរកមិនបានកន្លែងស័ក្តិសមមួយឡើយ។ បន្ទាប់មកយើងបានប្រាប់ពួកគាត់ពីសាលាមួយដ៏ល្អដែលយើងទើបតែទៅមើលកាលពីព្រឹកមិញនេះ ដោយប្រាប់ពួកគាត់ថាកន្លែងប្រភេទនោះគឺល្អឥតខ្ចោះតែម្តង ក៏ប៉ុន្តែគេដាក់វាលក់លើទីផ្សារតម្លៃរាប់លានឯណោះ។

ប្តីប្រពន្ធគាត់អង្គុយនៅទីនោះ ហើយដូចជាគ្មានភ្ញាក់ផ្អើលអ្វីសោះ ក៏ប៉ុន្តែបាននិយាយដោយសាមញ្ញថា «និយាយអីចឹង ប្រសិនបើអាចទទួលកន្លែងនោះដោយឥតគិតថ្លៃតើអ្នកគិតដូចម្តេចដែរ»? យើងពិតជាស្តាប់មិនយល់ទេភ្លាមៗនោះ ហើយពួកគេក៏សួរម្តងទៀតថា «ប្រសិនបើអាចទទួលកន្លែងនោះដោយឥតគិតថ្លៃតើអ្នកគិតដូចម្តេចដែរ»? ជាថ្មីម្តងទៀតយើងគិតថាពួកគាត់និយាយលេងទេ ក៏ប៉ុន្តែលើកនេះសុភាពបុរសម្នាក់នោះបាននិយាយថា «ឌ្រិនដា ប្រសិនបើអាចទទួលកន្លែងនោះដោយឥតគិតថ្លៃ តើអ្នកគិតដូចម្តេចដែរ»? «តើលោកចង់និយាយពីអ្វីទៅ?» យើងបានសួរគាត់។ ពួកគាត់ក៏និយាយថា «ពួកយើងនឹងសរសេរមូលប្បទានបត្រមួយឱ្យអ្នក!» យើងស្រឡាំងកាំងមួយស្របក់ពេលយើងអង្គុយនៅទីនោះ។ ក៏ប៉ុន្តែនិយាយដោយខ្លីទៅគឺពួកគេបានសរសេរមូលប្បទានបត្រពិតមែន។

ដូច្នេះគឺពីរថ្ងៃបន្ទាប់ពីយើងបានដាំគ្រាប់ពូជសម្រាប់ទីតាំងថ្មីរបស់យើង ព្រះជាម្ចាស់បានដឹកនាំយើងឱ្យរកឃើញទីតាំងដ៏ល្អឥតខ្ចោះនោះ។ ឥលូវនេះយើងជាម្ចាស់លើទីតាំងដែលមានតម្លៃ ១២លានដុល្លារដោយមិនចំណាយលុយ និងមិនជាប់ជំពាក់! តើនរណាទៅដែលធ្លាប់គិត ឬនិយាយដោយស្មោះទៅធ្លាប់សូម្បីតែស្រមៃពីរឿងនោះ? បន្ទាប់ពីឃើញរឿងនោះហើយឌ្រិនដា និងខ្ញុំយល់ស្របថាទោះបីជាយើងធ្លាប់ឃើញអ្វីៗទាំងអស់រួចមកហើយក៏ដោយ យើងត្រូវតែគិតឱ្យធំជាងមុន។ ព្រះជាម្ចាស់អាចធ្វើកិច្ចការជាច្រើនយ៉ាងអស្ចារ្យជាខ្លាំង!

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ខ្ញុំគិតថាវាមុខជាអារម្មណ៍តែមួយដែលពួកសិស្សទទួលបានក្រោយពីចែកម្ហូបទៅកាន់មនុស្ស ២០.០០០នាក់ ដោយមាននំបុ័ងតែប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ។ ខ្ញុំហ៊ាននិយាយថាពួកគេចូលដំណោកទាំងនិយាយថា «ពិតជាអស្ចារ្យមែនឃើញទេ»?

# ជំពូក ៥
# ការផ្ដល់អំណាចដល់
# ព្រះរាជទានរបស់អ្នក

យើងបានរៀនអំពីជំហានទីមួយដែលទាក់ទងជាមួយនឹងច្បាប់របស់ព្រះរាជ្យ សម្រាប់ព្រះរាជទានរបស់អ្នកនៅក្នុងជំពូកមុនរួចមកហើយ។

**អ្នកត្រូវតែស្រាយអ្វីដែលអ្នកត្រូវការមួយចំនួនចូលទៅក្នុងព្រះរាជ្យ ដើម្បីឱ្យវាពហុគុណឡើង!**

ខ្ញុំបានប្រាប់អ្នកក្នុងជំពូកមុនថាខ្ញុំនឹងឆ្លើយសំណួរពីរទាក់ទងនឹងសេចក្ដីថ្លែងមួយនេះ សំណួរទីមួយគឺ «តើពាក្យថាស្រាយអ្វីម្យ៉ាងចូលទៅក្នុងព្រះរាជ្យដើម្បីឱ្យវាពហុគុណឡើង មានន័យដូចម្ដេច»?

ជាថ្មីម្ដងទៀត សូមត្រលប់ទៅមើលរឿងរបស់យើងនៅក្នុងគម្ពីរម៉ាកុសជំពូកទី៦វិញ ដើម្បីទទួលបានការយល់ដឹងមួយចំនួន។

*ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សិស្សនាំគ្នាចូលមកគាល់ព្រះយេស៊ូទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ ថ្ងៃក៏ជិតលិចផងសូមប្រាប់អ្នកទាំងនេះឱ្យត្រលប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះ តាមភូមិជិតៗនេះ»។*

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ»។ គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីររយដួង ទៅទិញម្ហូបអាហារឱ្យគេបរិភោគឬ?»។*

*ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំបុ័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*

*ព្រះយេស៊ូបង្គាប់ពួកសិស្សឱ្យប្រាប់បណ្ដាជន អង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំបុ័ងប្រទានឱ្យពួកសិស្សដើម្បីឱ្យគេចែកបណ្ដាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឱ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំបុ័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំបុ័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

— ម៉ាកុស ៦:៣៥-៤៤

ខ្ញុំចង់ឱ្យអ្នកចំណាំចំណុចមួយចំនួននៅក្នុងរឿងនោះ ដែលអ្នកអាចនឹងមើលរំលង។ ពេលព្រះយេស៊ូមានព្រះបន្ទូលថា «ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ» ចម្លើយរបស់ពួកគេ និងការឆ្លើយតបរបស់ទ្រង់បង្ហាញយើងពីគន្លឹះដ៏សំខាន់បំផុតសម្រាប់ការយល់ដឹងរបស់យើងអំពីព្រះរាជ្យទាក់ទងទៅនឹងព្រះរាជទាន។ នៅពេលពួកគេឆ្លើយទៅទ្រង់ពួកគេបាននិយាយថា យើងត្រូវយកប្រាក់ពីររយដួងទៅទិញម្ហូបអាហារឱ្យគេបរិភោគ។ សូមចំណាំពីរបៀបដែលគំនិតរបស់គេផ្សារភ្ជាប់ការផ្គត់ផ្គង់ដែលពួកគេត្រូវការ ទៅនឹងកម្លាំងពលកម្មនៅពេលដែលពួកគេប្រឈមមុខនឹងបញ្ហានោះ។ ជាការពិតជាក់ស្ដែងយើងទាំងអស់គ្នាក៏ធ្វើដូចពួកគាត់ដែរ។ ក៏ប៉ុន្តែគំនិត

គិតអំពីការខិតខំប្រឹងប្រែងធ្វើការដើម្បីចិញ្ចឹមជីវិត មិនមែនជាផ្នែកមួយដែលស្ថិតនៅជាប់នឹងមនសិការរបស់មនុស្សស្រាប់ទេ។ វាបានចូលមកជាមួយនឹងការបរាជ័យរបស់អដាំ។ ខ្ញុំសូមនាំអ្នកត្រលប់ទៅមើលការបរាជ័យរបស់អដាំវិញ នៅត្រង់កន្លែងដែលយើងអាចមើលឃើញពីពេលដែលការខិតខំប្រឹងប្រែងធ្វើការនេះបានកើតមាន។

## គំនិតគិតអំពីការខិតខំប្រឹងប្រែងដើម្បីចិញ្ចឹមជីវិត

*ព្រះអង្គមានព្រះបន្ទូលមកលោកអដាំថា៖ «ដោយអ្នកបានស្តាប់តាមពាក្យប្រពន្ធ ហើយបរិភោគផ្លែឈើដែលយើងហាមប្រាមនោះ ដីនឹងត្រូវបណ្តាសាព្រោះតែអ្នក។ ដូច្នេះអ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃអស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើសរហូតដល់ថ្ងៃដែលអ្នកត្រលប់ទៅជាដីវិញ ដ្បិតអ្នកមានកំណើតមកពីដី។អ្នកកើតពីធូលីដី អ្នកត្រូវតែត្រលប់ទៅជាធូលីដីវិញ»។*

— លោកុប្បត្តិ ៣:១៧-១៩

ប្រសិនបើអ្នកនៅចាំបាន អដាំ និងអេវ៉ាត្រូវបានដាក់នៅលើផែនដីដើម្បីគ្រប់គ្រងលើផែនដី ជាតំណាងនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពួកគេគ្រប់គ្រងដោយសិទ្ធិអំណាចដែលបានប្រគល់មកឱ្យពួកគេ។ មារសាតាំងមានវត្តមាននៅលើផែនដីរួចមកហើយ វាបានស្អប់ពួកគេ ហើយច្រណែនពួកគេបន្ទាប់ពីពួកគេទទួលបានសិទ្ធិអំណាចនោះ។ ទោះបីជាអដាំ និងអេវ៉ាមានសិទ្ធិអំណាចលើវាទាំងស្រុងក៏ដោយ វានៅតែធ្វើយ៉ាងណាល្បួងពួកគេឱ្យជឿថាព្រះជាម្ចាស់មិននៅខាងពួកគេ ហើយជាព្រះមិនគួរឱ្យទុកចិត្តទេ។ វាបានផ្តល់អ្វីដែលមើលទៅហាក់ដូចជាអនាគតដែលមានភាពល្អប្រសើរជាងនេះដល់ពួកគេ ហេតុដូច្នេះហើយបានជាពួកគេសម្រេចចិត្តធ្វើតាមវាជំនួសព្រះជាម្ចាស់។ ដោយសារតែការបះបោររបស់ពួកគេ ពួកគេបាត់បង់តំណែងស្របច្បាប់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយជាពិសេសទៅទៀតពួកគេបានដេញព្រះជា

ម្ចាស់ចេញពីជីវិតរបស់ពួកគេ ដោយផ្ដល់ការគ្រប់គ្រងស្របច្បាប់លើផែនដីទាំងមូលទៅឱ្យមារសាតាំង ពេលដែលការគ្រប់គ្រងគឺជាកម្មសិទ្ធិរបស់មនុស្សពីដំបូងមក។ លោកប៉ូលហៅមារសាតាំងថាព្រះនៃលោកិយនេះនៅក្នុងគម្ពីរ ២ កូរិនថូស។

> *ជាអ្នកមិនជឿដែលត្រូវព្រះនៃលោកិយនេះធ្វើឱ្យចិត្តគំនិតរបស់គេទៅជាងងឹត មិនឱ្យគេឃើញពន្លឺរស្មីដ៏រុងរឿងនៃដំណឹងល្អរបស់ព្រះគ្រិស្តជាតំណាងរបស់ព្រះជាម្ចាស់នោះឡើយ។*
>
> — ២ កូរិនថូស ៤:៤

នៅពេលព្រះជាម្ចាស់បង្ហាញគាត់ឱ្យស្គាល់ពីកំហុស ទ្រង់មានបន្ទូលទៅអដាំថា «ដីនឹងត្រូវបណ្ដាសាព្រោះតែអ្នក។ ដូច្នេះអ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃអស់មួយជីវិត។» បន្ទាប់មកទ្រង់មានបន្ទូលបន្ថែមមួយឃ្លាទៀតថា « អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើស»។

ព្រះជាម្ចាស់មានបន្ទូលទៅអដាំដូច្នោះដោយសារតែការបះបោររបស់គាត់ ផែនដីនឹងមិនបង្កបង្កើនផលដូចគន្លងដែលធ្លាប់មានកាលពីអតីតកាលឡើយ។ ព្រះជាម្ចាស់មិនអាចកែប្រែរឿងនោះបានទេ ហើយអដាំត្រូវតែខំប្រឹងប្រែងដោយខ្លួនឯងពេញមួយជីវិតដោយបង្ហូរញើស និងកាប់គាស់យ៉ាងវេទនា។ សូមចាំថាអដាំគឺជាអ្នកធ្វើឱ្យផែនដីជាប់បណ្ដាសា មិនមែនព្រះជាម្ចាស់ឡើយ។ អដាំមានអំណាចគ្រប់គ្រងស្របច្បាប់លើផែនដី ហើយពេលដែលគាត់បះបោរប្រឆាំងនឹងព្រះជាម្ចាស់ នោះព្រះពររបស់ព្រះជាម្ចាស់ត្រូវដកចេញទាំងបង្ខំ។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់មានបន្ទូលទៅអដាំថា **«ដីនឹងត្រូវបណ្ដាសាព្រោះតែអ្នក»។** សួនច្បារដែលអដាំបានកើតមក និងរស់នៅដែលជាកន្លែងពោរពេញទៅដោយការផ្គត់ផ្គង់បានរលាយបាត់ហើយ។ មុនពេលអដាំបះបោរគាត់មិនដែលត្រូវគិត ឬបារម្ភអំពីការផ្គត់ផ្គង់នោះទេ គ្រប់ទីកន្លែងដែលគាត់មើលឃើញមានការផ្គត់ផ្គង់យ៉ាងពេញបរិបូរ។ ក៏ប៉ុន្តែឥលូវនេះគាត់ត្រូវស្វែង

រកការផ្គត់ផ្គង់ខ្លួនឯងតាមរយៈការកាប់គាស់យ៉ាងវេទនា និងការបង្ខូរញើស។ ខ្ញុំដាក់ឈ្មោះឱ្យវាថា ប្រព័ន្ធនៃការខិតខំប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើស។

## ឥលូវនេះតម្រូវឱ្យមានការខិតខំប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើសដើម្បីបង្កើតឱ្យមានការផ្គត់ផ្គង់!

មិនត្រឹមតែផែនដីប៉ុណ្ណោះទេដែលបានផ្លាស់ប្តូរ។ អដាំ និងមនុស្សជាតិគ្រប់រូបបានផ្លាស់ប្តូរ។ អដាំបានបាត់បង់អត្តសញ្ញាណ គោលបំណង និងការផ្គត់ផ្គង់របស់គាត់ ហើយឥលូវនេះគាត់បានក្លាយទៅជាទាសករដើម្បីត្រដររស់។ នេះក៏ជារបៀបដែលអ្នកហើយនឹងខ្ញុំបានធំធាត់ឡើងមកដែរ គឺស្ថិតនៅក្រោមប្រព័ន្ធនៃការខំប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើស។

ការសម្រេចចិត្តទាំងអស់ក្រោមប្រព័ន្ធនៃបណ្តាសាលោកិយនេះ គឺជាផ្នែកមួយនៃការត្រដររស់ ហើយជាធម្មតាមានមូលដ្ឋាននៅជុំវិញការរកលុយ ឬការដោះស្រាយជាមួយនឹងបញ្ហាលុយ។ ទីកន្លែង និងរបៀបដើម្បីរកលុយគ្រប់គ្រងលើគំនិត និងជីវិតរបស់យើង។ ពីដើម ព្រះជាម្ចាស់បានបង្កើតយើងមកឱ្យមានអត្តសញ្ញាណដែលមានលក្ខណៈពិសេសសម្រាប់គោលបំណង និងកិច្ចការរបស់យើងនៅលើផែនដី ប៉ុន្តែឥលូវអត្តសញ្ញាណនោះត្រូវបានលួច និងជំនួសមកវិញដោយតម្រូវការក្នុងការរកលុយដែលយើងត្រូវការដើម្បីត្រដររស់ យើងតែងតែស្វែងរកការផ្គត់ផ្គង់សម្រាប់ថ្ងៃបន្ទាប់ជានិច្ច។

**តាំងពីសម័យអដាំមក បុរស និងស្ត្រីបានធ្លាក់ជាទាសករដើម្បីត្រដររស់ ទាំងរត់តាមការផ្គត់ផ្គង់ ឬប្រមូលការផ្គត់ផ្គង់ទុកដោយសារតែការមានលុយគឺជាផ្លូវរត់គេចចេញពីការលំបាកតែមួយគត់។**

## ប្រព័ន្ធនៃភាពជាទាសករមួយ

មានការស្ទង់មតិថ្មីមួយដែលខ្ញុំបានឃើញ និយាយថាមនុស្សជាង៧០% នៅក្នុងសហរដ្ឋអាមេរិកមិនចូលចិត្តការងារដែលពួកគេធ្វើទេ។[5] អ្នកមុខជាឆ្ងល់ថា «ចុះហេតុអ្វីបានជាពួកគេទៅធ្វើការ ប្រសិនបើពួកគេមិនចូលចិត្តការងារ»? ចម្លើយដ៏សាមញ្ញនោះគឺ ពួកគេជាទាសកររបស់ប្រាក់ខែក្នុងខែបន្ទាប់ទៀត!

ស្ថិតនៅក្រោមបណ្តាសាលោកិយនៃការខិតខំប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ខូរញើស មនុស្សគ្រប់រូបសុបិនចង់ក្លាយជាមហាសេដ្ឋី សុបិនចង់រត់ចេញពីការលំបាកដែលគ្មានទីបញ្ចប់ និងសម្ពាធក្នុងការស្វែងរកការផ្គត់ផ្គង់។ មនុស្សជាច្រើនមានសុបិនចង់ត្រូវឆ្នោត សុបិនចង់ក្លាយជាអ្នកមានដើម្បីរស់នៅកន្លែងដែលពួកគេមានសេរីភាពធ្វើអ្វីដែលពួកគេចង់ធ្វើ ជំនួសឱ្យការធ្វើអ្វីដែលពួកគេត្រូវតែធ្វើ។ តាំងពីសម័យអដាំមក បុរស និងស្ត្រីបានធ្លាក់ជាទាសករដើម្បីត្រដររស់ ទាំងរត់តាមការផ្គត់ផ្គង់ ឬប្រមូលការផ្គត់ផ្គង់ទុក ដោយសារតែការមានលុយគឺជាផ្លូវរត់គេចចេញពីជីវិតបែបរត់ប្រណាំងកណ្តុរតែមួយគត់។

ខ្ញុំសូមលើកឧទាហរណ៍មួយអំពីរបៀបដែលប្រព័ន្ធនេះបានបណ្តុះបណ្តាលយើងទាំងអស់គ្នាអំពីរបៀបដែលយើងគិត។ ប្រសិនបើខ្ញុំប្រាប់អ្នកថា អ្នកត្រូវតែមានសេរីភាពពីបំណុលទាំងស្រុងក្នុងរយៈពេល១២ខែក្រោយនេះ អ្នកនឹងចាប់ផ្តើមគណនាពីរបៀបដើម្បីប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើសបន្ថែមទៀត ដើម្បីធ្វើឱ្យអ្វីដែលខ្ញុំប្រាប់នេះសម្រេចបាន។ អ្នកមុខជាគណនាពីរបៀបដែលអ្នកអាចធ្វើការពីរ ឬបីមុខ ហើយប្រសិនបើចាំបាច់គឺធ្វើអ្វីក៏ដោយឱ្យតែសម្រេចវាបាន។ ហើយអ្វីក៏ដោយឱ្យតែសម្រេចវាបាននោះគឺការប្រឹងប្រែងធ្វើការយ៉ាងវេទនា និងបង្ហូរញើសកាន់តែខ្លាំង។ ការប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើសគឺជាភាគបែងដែលរួមបញ្ចូលនៅ

[5] https://returntonow.net/2017/09/22/85-people-hate-jobs-gallup-poll-says

ក្នុងសុបិននីមួយៗ។ ប្រសិនបើអ្នកត្រូវការឡានថ្មី អ្នកនឹងយកតម្លៃឡានមកចែកនឹងកម្លាំងពលកម្ម និងតំណក់ញើសរបស់អ្នករួចនិយាយថា «ទេ យើងរកលុយទិញវាមិនបានទេ»។ «ផ្ទះធំជាងនេះមែនទេ? ទេយើងរកលុយទិញវាមិនបានទេ»។

## ព្រះជាម្ចាស់ទតឃើញលទ្ធភាពនៅក្នុងរឿងដែលមិនអាចទៅរួច

ស្ថិតនៅក្រោមប្រព័ន្ធនៃបណ្តាសាលោកិយ ការផ្អៀតចូលផ្សារវ៉លម៉ាត (Walmart) ហើយទិញនំប៉ុងបីហ្គីរមួយពេលកំពុងធ្វើដំណើរមកផ្ទះ បានចូលមកជំនួសសុបិនជាច្រើន។ ហើយប្រសិនបើគ្មានពេលវេលា ឬកម្លាំងពលកម្មគ្រប់គ្រាន់ដើម្បីសម្រេចសុបិនរបស់អ្នកទេ នោះអ្នកនឹងបោះបង់វាចោល ហើយប្រាប់ខ្លួនឯងឱ្យទទួលស្គាល់ថាអ្នកគួរតែនៅបន្តធ្វើការងារដែលអ្នកស្អប់នោះដូចជាអ្នកដទៃគ្រប់គ្នាធ្វើដែរទៅចុះ។ សម្រាប់មនុស្សមួយចំនួនធំ ជាធម្មតាសមីការនៃការប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើសមានពាក្យថាមិនអាចទៅរួចបន្ទាប់ពីសញ្ញាស្មើ។

នេះគឺជារបៀបដែលពួកសិស្សយល់ឃើញយ៉ាងពិតប្រាកដពីស្ថានភាពរបស់ពួកគេ «ឱ្យអាហារទៅមនុស្ស ២០.០០០នាក់បរិភោគឬ? មិនអាចទៅរួចទេ! វាត្រូវការចំណាយអស់ប្រាក់ឈ្នួលដល់ទៅ៦ខែឯណោះ!» នៅត្រង់នេះ ប្រាក់ឈ្នួលចង់សំដៅលើការប្រឹងប្រែងធ្វើការយ៉ាងវេទនា និងកម្លាំងពលកម្មបន្ថែមលើសពីអ្វីដែលអាចទៅរួចដើម្បីបំពេញតម្រូវការ។ ជាថ្មីម្តងទៀត គំនិតតែមួយរបស់ពួកគេទាក់ទងនឹងការទទួលបានការផ្គត់ផ្គង់ គឺទទួលបានតាមរយៈកម្លាំងពលកម្ម។ នេះគឺជារបៀបដែលអ្វីៗមានដំណើរការនៅលើផែនដីនេះ។ មនុស្សគ្រប់រូបដឹងពីការលំបាកទាំងនោះ ក៏ប៉ុន្តែព្រះយេស៊ូនឹងបង្ហាញពួកគេពីរបៀបថ្មីមួយក្នុងការរស់នៅ គឺព្រះរាជ្យថ្មីមួយជាមួយនឹងច្បាប់ថ្មីៗ។ ជាការពិតណាស់ ពិតជាមានវិធីគេចចេញពីប្រព័ន្ធនៃការប្រឹងប្រែងធ្វើការយ៉ាងវេទនា និងការបង្ហូរញើស។ ពិតជាមានវិធីអាចធ្វើបានប្រាកដមែន។

សូមត្រលប់ទៅរកពេលដែលពួកសិស្សនិយាយថា វាមិនអាចទៅរួចទេក្នុងការឱ្យអាហារទៅមហាជនបរិភោគ ហើយសូមមើលពីរបៀបដែលព្រះយេស៊ូឆ្លើយតប។ អ្នកគួរតែមានខ្សែដៃមួយធ្វើពីស្បែកដែលមានសរសេរពាក្យជាអក្សរកាត់ថា ធ្វើតាមអ្វីដែលព្រះយេស៊ូបានធ្វើ (DWJD) ដើម្បីកុំឱ្យអ្នកភ្លេចពីអ្វីដែលទ្រង់នឹងបង្ហាញយើងនាពេលបន្តិចទៀតនេះដូចជាពួកសិស្សបានភ្លេច។ ផ្ទុយពីការយល់ស្របជាមួយពួកសិស្សពីការវិនិច្ឆ័យរបស់ពួកគេចំពោះស្ថានភាពនោះ ព្រះយេស៊ូបែរជាគ្រប់គ្រងស្ថានការណ៍នោះដោយការបង្គាប់ពួកគេថា «ចូរចេញទៅមើលថាអ្នកមាននំប៉័ងប៉ុន្មានដុំ»? ពេលនោះពួកគេដឹងរួចទៅហើយមុនពេលដែលពួកគេទៅមើលទៅទៀត ថាពួកគេគ្មានគ្រប់គ្រាន់សម្រាប់ឱ្យទៅមហាជនទាំងមូលនោះបរិភោគទេ។ នោះហើយជាមូលហេតុដែលពួកគេមករកព្រះយេស៊ូតាំងពីដំបូង និងសុំឱ្យទ្រង់ប្រាប់មនុស្សទាំងនោះឱ្យទៅរកអាហារបរិភោគដោយខ្លួនឯង។ ក៏ប៉ុន្តែដោយសារតែការស្តាប់បង្គាប់ពួកគេបានទៅ និងមើលហើយត្រលប់មកវិញទាំងរាយការណ៍ផងថាមានតែនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ។

មានអ្វីមួយកើតឡើងនៅទីនេះដែលត្រូវតែពិនិត្យមើល នោះគឺមានរឿងសម្ងាត់មួយផ្សេងទៀត។ ក៏ប៉ុន្តែដើម្បីមើលឃើញរឿងនោះ ខ្ញុំចង់មើលទៅរឿងដូចគ្នាក៏ប៉ុន្តែមើលសាច់រឿងនៅក្នុងគម្ពីរម៉ាថាយវិញ។

> *ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សិស្សថា៖ «មិនបាច់ឱ្យគេត្រលប់ទៅវិញទេ ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ»។*
> *សិស្សទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងតែប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ»។*
> *ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរយកនំប៉័ង និងត្រីនោះមកឱ្យខ្ញុំ»។ បន្ទាប់មកព្រះអង្គប្រាប់បណ្តាជនឱ្យអង្គុយលើស្មៅ ព្រះអង្គយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើងលើ សរសើរតម្កើងព្រះជា*

*ម្ចាស់ ហើយកាច់នំបុ័ងប្រទានឱ្យពួកសិស្ស ពួកសិស្សក៏ចែកឱ្យបណ្តាជនបរិភោគ។ អ្នកទាំងនោះបានបរិភោគឆ្អែតគ្រប់ៗគ្នា ហើយពួកសិស្សប្រមូលនំបុ័ងដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ អស់អ្នកដែលបានបរិភោគនំបុ័ងមានប្រុសៗទាំងអស់ប្រមាណប្រាំពាន់នាក់ ឥតគិតស្រីៗ និងក្មេងៗផងទេ។*

— ម៉ាថាយ ១៤:១៦-២១

សូមសម្គាល់មើលនៅក្នុងខទី១៨ ពេលដែលព្រះយេស៊ូមានបន្ទូលឱ្យសិស្សយកនំបុ័ង និងត្រីមកថ្វាយទ្រង់។ ក្រោយមកចុងបញ្ចប់នៃខទី១៩ យើងឃើញថាទ្រង់បានប្រគល់នំបុ័ង និងត្រីទៅឱ្យពួកសិស្សវិញ។ មានរឿងអ្វីម៉្យាងកើតឡើងរវាងផ្នែកទាំងពីរនៃអត្ថបទគម្ពីរនោះ ដែលធ្វើឱ្យអ្នកចាប់អារម្មណ៍ និងជំរុញអ្នកឱ្យសួរសំណួរមួយថា «ហេតុអ្វីបានជាព្រះយេស៊ូប្រាប់ឱ្យពួកសិស្សយកនំបុ័ង និងត្រីមកថ្វាយទ្រង់ ប្រសិនបើទ្រង់គង់តែប្រគល់វាមកពួកគេវិញក្នុងពេលបន្តិចក្រោយមកដូច្នេះ»? ព្រះយេស៊ូមិនធ្វើអ្វីមួយតាមបែបសាសនាទេ ដូច្នេះមុខជាមានមូលហេតុមួយមិនខានទេ ទើបទ្រង់សួររកនំបុ័ង និងត្រីពីពួកសិស្ស។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងត្រូវតែដឹងថាមានអ្វីកើតឡើងពេលទ្រង់យកនំបុ័ង និងត្រីពីពួកសិស្ស។

***ព្រះអង្គយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើងលើ សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំបុ័ងប្រទានឱ្យពួកសិស្ស ពួកសិស្សក៏ចែកឱ្យបណ្តាជនបរិភោគ។***

ព្រះគម្ពីរចែងថាទ្រង់អរព្រះគុណ។ រឿងក្នុងអត្ថបទគម្ពីរផ្សេងចែងថាទ្រង់ប្រទានពរវា។ ក៏ប៉ុន្តែការចែងទាំងនោះមានន័យដូចម្តេច? ពាក្យក្រិកដែលប្រើសម្រាប់ពាក្យថាអរព្រះគុណ ឬប្រទានពរនៅទីនេះតាមព្យញ្ជនៈមានន័យថាប្រសិទ្ធពរអ្វីមួយ សុំការប្រទានពររបស់ព្រះជាម្ចាស់លើអ្វីមួយ ឬសុំព្រះជាម្ចាស់ប្រទានពរដល់អ្វីម៉្យាងសម្រាប់ឱ្យនរណាម្នាក់ប្រើប្រាស់។ និយាយឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ពាក្យថា

ប្រសិទ្ធពរអ្វីម្យ៉ាងមានន័យថាប្រកាសថាវាពិសិដ្ឋ វាបានឧទ្ទិសជាផ្លូវការថ្វាយទៅក្នុងគោលបំណងរបស់ព្រះជាម្ចាស់។

ហេតុដូច្នេះជាគោល ពេលព្រះយេស៊ូបានប្រទានពរដល់ត្រី និងនំប៉័ងរបស់ទាំងពីរមុខនោះបានបំបែកចេញពីការគ្រប់គ្រងរបស់អាណាចក្រផែនដី ចូលទៅក្នុងការគ្រប់គ្រងរបស់ស្ថានសួគ៌ទៅហើយ។

**នៅពេលទ្រង់មានបន្ទូលទៅកាន់នំប៉័ង និងត្រីពេលនោះនំប៉័ង និងត្រីបានផ្លាស់ប្ដូរព្រះរាជ្យទៅហើយ។**

## ការនាំយកអ្វីៗមកដាក់នៅក្រោមដែនអំណាចគ្រប់គ្រងមួយ

កាលពីមុន នំប៉័ង និងត្រីស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សនៅក្នុងអាណាចក្រផែនដី និងមិនស្ថិតនៅក្នុងសមត្ថភាពរបស់ព្រះជាម្ចាស់ដើម្បីធ្វើអ្វីម្យ៉ាងជាមួយនឹងរបស់ទាំងនោះទេ។ ក៏ប៉ុន្តែឥលូវនេះយើងឃើញថាតាមរយៈចិត្តសប្បុរសរបស់ក្មេងប្រុសម្នាក់ ដែលបានថ្វាយរបស់ទាំងនោះមកព្រះយេស៊ូ របស់ទាំងនោះក៏ទទួលបានការផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជ្យ។ យើងក៏ត្រូវតែដឹងដែរថាប្រសិនបើរបស់ទាំងនោះបានទុកនៅក្រោមការគ្រប់គ្រងរបស់អាណាចក្រផែនដីនោះទាំងនំប៉័ង និងត្រីមុខជាមិនអាចពហុគុណឡើងបានទេ។

ក្នុងនាមជាអ្នកវិទ្យាសាស្រ្តខាងវិញ្ញាណ យើងត្រូវតែយកចិត្តទុកយ៉ាងខ្លាំងចំពោះសេចក្ដីលម្អិត។ តើការផ្ទេរមួយនោះបានកើតឡើងនៅពេលណាឱ្យប្រាកដ? ពីដំបូងអ្នកអាចគិតថាការផ្លាស់ប្ដូរការគ្រប់គ្រងបានកើតឡើងនៅពេលដែលក្មេងប្រុសបានឱ្យនំប៉័ង និងត្រីទៅកាន់ពួកសិស្ស។ ជាការពិតទៅ នោះគឺជាផ្នែកមួយនៃដំណើរការនោះ ហើយក្មេងប្រុសម្នាក់នោះបានឱ្យដោយស្ម័គ្រចិត្ត ក៏ជាគន្លឹះដ៏សំខាន់មួយផងដែរដើម្បីរាប់ជាកត្តារួមបញ្ចូល។ ក៏ប៉ុន្តែការឱ្យនំប៉័ង និងត្រីទៅពួកសិស្សមិនមែនជាកន្លែងដែលការផ្ទេរពិតប្រាកដបានកើតឡើងទេ។ គឺពេលដែលព្រះយេស៊ូមានបន្ទូលទៅកាន់

វា ប្រទានពរវា ពេលនោះហើយជាពេលផ្ទេរពិតប្រាកដស្របច្បាប់មួយបានកើតឡើង។ ខ្ញុំទទួលស្គាល់ថាទោះបីជាព្រះយេស៊ូបានយកនំបុ័ង និងត្រីនោះ ហើយបានកាន់របស់ទាំងនោះនៅក្នុងព្រះហស្តទ្រង់ក៏ដោយ របស់ទាំងនោះនឹងមិនពហុគុណទេ លុះត្រាតែទ្រង់មានបន្ទូលទៅកាន់របស់ទាំងនោះជាមួយនឹងសេចក្ដីបង្គាប់ដ៏ជាក់លាក់មួយ។

សូមដាក់រឿងនោះជាទស្សនៈទៅក្នុងមេរៀនអំពីជំនឿរបស់យើង ដែលយើងបានរៀនមុននេះ។ យើងដឹងថាទោះបីជាដួងចិត្តយើងអាចមានជំនឿ ដែលជំនឿធ្វើឱ្យស្ថានសួគ៌ដណ្ដើមយកសិទ្ធិពីផែនដីដោយស្របច្បាប់ក៏ដោយ តែគ្មានអ្វីអាចកើតឡើងបានទេរហូតទាល់តែអ្នកដែលមានសិទ្ធិគ្រប់គ្រងស្របច្បាប់នៅលើផែនដីនេះ ស្រាយនូវសិទ្ធិអំណាចរបស់ស្ថានសួគ៌នៅទីនេះ។

*ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ្រោះ។*

— រ៉ូម ១០:១០

ទោះបីជាព្រះបន្ទូលរបស់ព្រះយេស៊ូមិនបានកត់ត្រាក្នុងព្រះគម្ពីរ អំពីអ្វីដែលទ្រង់មានបន្ទូលពេលទ្រង់ប្រទានពរដល់នំបុ័ង និងត្រី ប៉ុន្តែខ្ញុំប្រាកដណាស់ថាទ្រង់អាចនឹងមានបន្ទូលដូច្នេះថា «ព្រះបិតាអើយ កូនអរព្រះគុណទ្រង់សម្រាប់ការផ្គត់ផ្គង់ ហើយកូនទទួលយកនំបុ័ង និងត្រីនេះចូលទៅក្នុងព្រះរាជ្យរបស់ទ្រង់សម្រាប់សិរីល្អរបស់ទ្រង់ ។ ចូរឱ្យនំបុ័ង និងត្រីនេះពហុគុណឡើងក្នុងពេលឥលូវនេះ ដើម្បីឱ្យរបស់ទាំងនេះអាចប្រគល់ឱ្យទៅមហាជនដ៏ច្រើនសម្បើមនេះបរិភោគលើសពីអ្វីដែលពួកគេត្រូវការ ដើម្បីឱ្យពួកគេបានសម្រាក និងមានកម្លាំង ក៏ដូចជាបានឃើញសិរីល្អទ្រង់ផង»។ដូចដែលខ្ញុំបាននិយាយមកហើយ ជាការពិតណាស់ព្រះបន្ទូលទ្រង់មិនបានកត់ត្រាទុកទេ។ ក៏ប៉ុន្តែខ្ញុំច្បាស់ថាទ្រង់បង្គាប់ទៅនំបុ័ង និងត្រីបន្ទាប់ពីរបស់ទាំងនោះបានប្រគល់មកដល់

ព្រះហស្តទ្រង់។ តើខ្ញុំដឹងរឿងនោះដោយរបៀបណា? ដោយសារតែទ្រង់ជ្រាបរួចមកហើយពីផែនការ ហើយទ្រង់បានឱ្យពួកគេអង្គុយតាមក្រុមរួចទៅហើយ។

*ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សិស្សថា៖ «មិនបាច់ឱ្យគេត្រលប់ទៅវិញទេ ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ»។*

*សិស្សទូលព្រះអង្គថា៖ «យើងខ្ញុំមាននំបុ័ងតែប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ»។*

*ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរយកនំបុ័ង និងត្រីនោះមកឱ្យខ្ញុំ»។ បន្ទាប់មកព្រះអង្គប្រាប់បណ្ដាជនឱ្យអង្គុយលើស្មៅ ព្រះអង្គយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើងលើ សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំបុ័ងប្រទានឱ្យពួកសិស្ស ពួកសិស្សក៏ចែកឱ្យបណ្ដាជនបរិភោគ។*

— ម៉ាថាយ ១៤:១៦-១៩

សូមចំណាំថាទ្រង់បានបង្គាប់ពួកគេរួចទៅហើយឱ្យអង្គុយចុះនៅលើវាលស្មៅខាងមុខ មុនពេលទ្រង់ប្រទានពរដល់នំបុ័ង និងត្រី។ ទ្រង់ជ្រាបយ៉ាងច្បាស់ពីផែនការរបស់ទ្រង់។ ខ្ញុំប្រាកដណាស់ថាទ្រង់បានបង្គាប់ទៅនំបុ័ង និងត្រីបន្ទាប់ពីរបស់ទាំងនេះបានប្រគល់មកក្នុងព្រះហស្តទ្រង់។ សេចក្ដីបង្គាប់នៅពេលដែលអ្នកស្រោយគ្រាប់ពូជរបស់អ្នក គឺជាទិដ្ឋភាពមួយដ៏ចាំបាច់នៃការស្រោយគ្រាប់ពូជរបស់អ្នក។ តើខ្ញុំបាននិយាយថាចាំបាច់មែនឬទេ? ខ្ញុំពិតជាបាននិយាយមែន ដូច្នេះហើយសូមយកចិត្តទុកដាក់ត្រង់នេះ។ ខ្ញុំត្រូវការចំណាយពេលខ្លះនៅត្រង់ចំណុចនេះទាក់ទងនឹងការដាក់សេចក្ដីបង្គាប់លើអ្វីមួយពេលដែលអ្នកសាបព្រោះគ្រាប់ពូជ។

*ព្រះអង្គសួរគេទៀតថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថា ខ្ញុំជានរណាដែរ?»។*

*លោកស៊ីម៉ូនពេត្រុសទូលព្រះអង្គថា៖ «លោកជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ»។*

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «ស៊ីម៉ូនកូនលោកយ៉ូណាសអើយ អ្នកពិតជាមានសុភមង្គលមែន អ្នកដឹងសេចក្តីនេះមិនមែនដោយគំនិតប្រាជ្ញាខាងលោកិយទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខបានសម្តែងឱ្យអ្នកដឹង។ ខ្ញុំសុំប្រាប់អ្នកថាអ្នកឈ្មោះពេត្រុស ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ក្រុមជំនុំរបស់ខ្ញុំ។ មច្ចុរាជ ពុំមានអំណាចលើក្រុមជំនុំនេះបានឡើយ ខ្ញុំនឹងប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខឱ្យអ្នក។ អ្វីៗដែលអ្នកចង នៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នកស្រាយ នៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ»។*

— ម៉ាថាយ ១៦:១៥-១៩

អត្ថបទគម្ពីរនេះប្រាប់យើងយ៉ាងច្បាស់ថាសមត្ថភាពរបស់យើងក្នុងការគ្រប់គ្រងលើផែនដី ជាតំណាងព្រះរាជ្យរបស់ព្រះជាម្ចាស់ បានស្តារឡើងវិញរួចទៅហើយក្នុងពេលឥលូវនេះតាមរយៈព្រះយេស៊ូគ្រិស្ត។ យើងបានទទួលសិទ្ធិអំណាចដើម្បីចងវិញ្ញាណអាក្រក់ និងស្រាយបំណងចិត្តរបស់ស្ថានសួគ៌ទៅក្នុងផែនដី។ ឥលូវនេះខ្ញុំជឿ ឬយ៉ាងហោចណាស់ខ្ញុំសង្ឃឹមថាគ្រិស្តបរិស័ទជាច្រើន បានយល់ពីអត្ថន័យនៃការចងវិញ្ញាណអាក្រក់ហើយ។ និយាយដោយសាមញ្ញទៅ ការចងវិញ្ញាណអាក្រក់មានន័យថាបញ្ឈប់វាពីការបន្តធ្វើកិច្ចការតាមផែនការដ៏អាក្រក់របស់វា។ រឿងនោះអាចកើតឡើងបានតាមរយៈការដេញវិញ្ញានអាក្រក់ចេញពីមនុស្ស ការដាក់ដៃលើអ្នកជំងឺ និងធ្វើឱ្យពួកគេបានជាសះស្បើយ ឬការនិយាយដោយសាមញ្ញថា «ឈប់ភ្លាម នៅក្នុងព្រះ

**យើងបានទទួលសិទ្ធិអំណាចដើម្បីចងវិញ្ញាណអាក្រក់ និងស្រាយបំណងចិត្តរបស់ស្ថានសួគ៌ទៅក្នុងផែនដី។**

នាមព្រះយេស៊ូ!» អ្នកកំពុងយកសិទ្ធិអំណាចរបស់អ្នកនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ និងប្រើប្រាស់សិទ្ធិអំណាចនោះដើម្បីអនុវត្តជ័យជម្នះដែលព្រះយេស៊ូបានឈ្នះលើវិញ្ញាណអាក្រក់រួចទៅហើយ។

## ការប្រើប្រាស់សិទ្ធិអំណាចរបស់អ្នក

នៅក្នុងការសង្កេតរបស់ខ្ញុំ មានមនុស្សតិចតួចណាស់ដឹងពីរបៀបស្រាយស្ថានសួគ៌ឱ្យចូលមកក្នុងអាណាចក្រផែនដី។ ខ្ញុំបាននិយាយរួចមកហើយអំពីគម្ពីរ ១ យ៉ូហាន ៥:១៤-១៥ ទុកជាគំរូមួយសម្រាប់ការអធិស្ឋានប្រកបដោយប្រសិទ្ធភាព។

> *ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គគឺថា ប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*
>
> — ១ យ៉ូហាន ៥:១៤-១៥

ការជឿនៅក្នុងដួងចិត្តអ្នក ឬការមានជំនឿមិនមែនជាចុងបញ្ចប់ទេ។ ដូចដែលយើងបានឃើញរួចមកហើយ ពេលអ្នកជឿលើអ្វីដែលស្ថានសួគ៌ប្រាប់ នោះអ្នកត្រូវរាប់ទុកជាសុចរិត។ ឥលូវនេះស្ថានសួគ៌ហូរចូលមកក្នុងអាណាចក្រនៃផែនដីត្រូវរាប់ទុកថាជារឿងស្របច្បាប់ហើយ។ អ្នកនឹងអង្គុយជាមួយព្រះគ្រិស្តនៅស្ថានសួគ៌ នៅខាងស្ដាំដៃរបស់ព្រះបិតា។ ពាក្យសម្ដីរបស់អ្នកគឺជាបន្ទូលរបស់មហាក្សត្រ ហើយស្ថានសួគ៌នឹងមិនអាចត្រូវបានស្រាយឱ្យចូលមកទីនេះទេ លុះត្រាតែអ្នកនិយាយ! ពាក្យសម្ដីនេះអាចជាសេចក្ដីប្រកាស ឬកិច្ចព្រមព្រៀងមួយដែលបាននិយាយនៅក្នុងការអធិស្ឋាន ក៏ប៉ុន្តែកូនសោទៅកាន់ព្រះរាជ្យគឺស្ថិតនៅលើដៃអ្នក។ ព្រះជាម្ចាស់មិនអាចធ្វើវាបានដោយគ្មានអ្នកទេ!

ការចេះពីរបៀបឆ្លងកាត់សកម្មភាពអធិស្ឋានដែលធ្វើឱ្យអ្វីៗកើតឡើងមិនមែនជារឿងសំខាន់ទេ តែអ្វីដែលសំខាន់នោះគឺការចេះដាក់សេចក្តីបង្គាប់នៅពេលដែលអ្នកអធិស្ឋាន។ សូមចាំថា ប្រសិនបើអ្នកមិនស្រាយស្ថានសួគ៌នៅលើផែនដីនេះទេ ស្ថានសួគ៌មិនអាចស្រាយបានទេ។ ហេតុដូច្នេះហើយ ជាការចាំបាច់ណាស់ដែលយើងយល់ពីរបៀបដើម្បីស្រាយបំណងរបស់ស្ថានសួគ៌ចូលមកក្នុងជីវិតយើង និងចូលមកក្នុងពិតពលោករបស់យើង។

ឧទាហរណ៍ដ៏ល្អបំផុតមួយអំពីការបង្គាប់ មានបង្រៀននៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់។ មានកូនសោសំខាន់មួយចំនួននៅត្រង់នេះ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ដែលអ្នកត្រូវដឹង។ ទីមួយ នៅក្នុងអត្ថបទគម្ពីរថែងថាព្រះជាម្ចាស់ជ្រាបរួចទៅហើយពីអ្វីដែលអ្នកត្រូវការ ដូច្នេះហើយចូរឈប់សុំអង្វរទៅ។ ការអង្វរកមិនមែនជាជំនឿទេ ហើយវាបង្ហាញពីការមិនអើពើដែលមានជាប់ទាក់ទងនឹងរបៀបដែលព្រះរាជ្យមានដំណើរការ និងសិទ្ធិរបស់អ្នកក្នុងនាមជាប្រជាពលរដ្ឋម្នាក់នៅក្នុងព្រះរាជ្យ។ ការដាក់សេចក្តីបង្គាប់នៅក្នុងការអធិស្ឋានគឺជាការដាក់សំណើរមួយដ៏ពិតប្រាកដ។ ការដាក់សំណើរគឺជាបញ្ជីមួយដែលមានសេចក្តីលម្អិតយ៉ាងខ្លាំងពីអ្វីដែលអ្នកត្រូវការ។ វាមិនមែនជាការសុំវត្ថុទាំងនោះទេ តែវាជាការទាមទាររបស់ទាំងនោះ។

> *ពេលទូលទៅព្រះបិតា កុំពោលពាក្យច្រំដែលៗឥតប្រយោជន៍ ដូចសាសន៍ដទៃនោះឡើយ។ គេនឹកស្មានថា បើពោលពាក្យយ៉ាងច្រើនដូច្នេះ ព្រះរបស់គេនឹងស្តាប់គេ។ កុំធ្វើដូចគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត។ អ្នករាល់គ្នាត្រូវទូលព្រះអង្គដូចតទៅ៖ ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ! សូមសម្តែងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គឱ្យមនុស្សលោកស្គាល់ សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបាន*

*សម្រេចនៅលើផែនដីដូចនៅស្ថានបរមសុខដែរ។ សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។*

— ម៉ាថាយ ៦:៧-១១

ព្រះយេស៊ូផ្ដើមដោយមានបន្ទូលថា «ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខ (ជាទីគោរពដ៏ខ្ពង់ខ្ពស់ និងប្រកបដោយព្រះកិត្តិយស) អើយ! សូមសម្ដែងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ (ឆ្លុះបញ្ចាំងពីអំណាចត្រួតត្រា និងសិទ្ធិអំណាចរបស់ទ្រង់»។ ព្រះយេស៊ូកំពុងកំណត់ឋានៈស្របច្បាប់មួយរបស់សេចក្ដីអធិស្ឋាននៅក្នុងឃ្លាដំបូង។ សូមយកវាទៅប្រៀបធៀបជាមួយតាសានិយាយឃ្លាដំបូងនៅក្នុងបន្ទប់សវនាការ។

អាជ្ញាសាលាម្នាក់ក្រោកឈរឡើង ហើយមានប្រសាសន៍ថា «សូមក្រោកឈរឡើង។ តុលាការ (បន្ទាប់មកគាត់ប្រាប់ពីឈ្មោះតុលាការ)...»។ វាអាចជាតុលាការធម្មនុញ្ញស្រុកហ្វ្រេងឃ្លីន (Franklin County) ឬតុលាការមណ្ឌលមានយុត្តាធិការ (ដែនអំណាចគ្រប់គ្រង) បណ្ដឹងឧទ្ធរណ៍ ឬជានាយកដ្ឋានព្រហ្មទណ្ឌ ឬក៏ជាឈ្មោះណាមួយផ្សេង។ ក៏ប៉ុន្តែមានរឿងមួយចំនួនកើតឡើងនៅទីនោះក្នុងពេលចាប់ផ្ដើម។ អាជ្ញាសាលាមានប្រសាសន៍ថា «សូមក្រោកឈរឡើង» ជាការផ្ដល់កិត្តិយសដល់តុលាការ ក៏ដូចជាការផ្ដល់កិត្តិយសដល់ចៅក្រមដែលនឹងធ្វើជាអធិបតីនៅក្នុងអង្គតុលាការ។ ឈ្មោះរបស់តុលាការបានលើកឡើងដើម្បីបង្កើតនូវយុត្តាធិការដ៏ត្រឹមត្រូវមួយ ដើម្បីឱ្យអ្នកដឹងថាអ្នកស្ថិតនៅក្នុងអង្គសវនាការត្រឹមត្រូវដែលមានដែនអំណាចគ្រប់គ្រងលើរឿងក្ដីរបស់អ្នក។

សូមបន្តស្ដាប់អ្វីដែលអាជ្ញាសាលាមានប្រសាសន៍បន្ត «សូមក្រោកឈរឡើង។ តុលាការធម្មនុញ្ញស្រុកហ្វ្រេងឃ្លីនកំពុងបើកសវនាការ ដោយលោកឯកឧត្តមចៅក្រមស្មីត (Smith) ជាអធិបតី»។

ឃ្លាដំបូងដែលនិយាយថា **«ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ! សូមសម្ដែងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ»** គឺជាការកំណត់ឋានៈឱ្យ**នរណាម្នាក់**ដែលនឹងត្រូវគ្រប់គ្រងលើរឿងក្ដី និងប្រគល់សិទ្ធិឱ្យយើងនៅទីនោះ។ ទ្រង់គឺជាព្រះបិតាយើង ហើយយើងមានសិទ្ធិស្របច្បាប់ដើម្បីចូលទៅក្នុងតុលាការនេះ។ ឃ្លាដំបូងក៏ដាក់យុត្តាធិការ (ដែនអំណាចគ្រប់គ្រង) របស់តុលាការ ជាតុលាការនៃស្ថានសួគ៌ផងដែរ នៅក្នុងនាមជាតុលាការកំពូលបំផុតដែលមានគ្រប់ទាំងសិទ្ធិអំណាច។

បន្ទាប់មកសេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់មានយ៉ាងដូច្នេះថា **«សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេច»។**

ល្បះនេះកំពុងតែទាមទារសុំឱ្យតុលាការធ្វើការសម្រេចសេចក្ដី ស្របតាមច្បាស់របស់ព្រះរាជ្យ។ អ្នកត្រៀមនឹងធ្វើការសំណូមពរ ឬនាំយករឿងក្ដីមួយទៅកាន់តុលាការ ហើយអ្នកកំពុងសុំឱ្យចៅក្រមអនុវត្តនូវអ្វីដែលគាត់នឹងមានប្រសាសន៍ (ច្បាប់) ស្របតាមករណីមួយនេះ។ បន្ទាប់មកមានចែងថា **«នៅលើផែនដីដូចនៅស្ថានបរមសុខដែរ»។** ជាថ្មីម្ដងទៀត អ្នកកំពុងតែថ្លែងថា អ្នកចង់ឱ្យសេចក្ដីសម្រេចនេះនៅក្នុងស្ថានសួគ៌ ត្រូវយកមកអនុវត្តនៅលើផែនដីដូចនៅលើស្ថានសួគ៌ដែរ។ ទាំងអស់នេះជាអ្វីដែលបានបង្កើតឡើង និងបង្ហាញពីឋានៈរបស់អ្នក និងតុលាការ។ មិនទាន់មានសំណួរអ្វី ឬមានការបង្ហាញពីអ្វីនៅឡើយទេ ហើយអ្វីដែលនឹងចូលមកបន្ទាប់ពីនោះគឺការសំណូមពរ។

«សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ»។ សេចក្ដីថ្លែងត្រង់នេះមិនប្រាកដថានិយាយអំពីអាហារប៉ុណ្ណោះទេ លុះត្រាតែអាហារជាអ្វីដែលអ្នកពិតជាត្រូវការមែន។ ផ្ទុយទៅវិញវាប្រាប់អ្នកឱ្យជំនួសអាហារដោយអ្វីដែលជាតម្រូវការរបស់អ្នក។ សូមចាំថាការសន្ទនាទាំងមូលនេះបានចាប់ផ្ដើមនៅត្រង់កន្លែងដែលព្រះយេស៊ូកំពុងបង្ហាប់ពួកសិស្សទ្រង់ ពីរបៀបអធិស្ឋានដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ។ នេះគឺ

ជាកន្លែងដែលអ្នកធ្វើការសំណូមពរ ក៏ប៉ុន្តែដូចខ្ញុំបាននិយាយរួចមកហើយថា ពាក្យដែលល្អជាងនេះដែលត្រូវប្រើនៅទីនេះគឺការស្នើសុំ។ ជាការពិតណាស់ ការនិយាយទាំងពីរបែបនេះបានដូចគ្នា ហើយសំណូមពរជាអ្វីដែលមានចែងក្នុងគម្ពីរភីលីពជំពូក៤។ ក៏ប៉ុន្តែអ្វីដែលជាចំណុចសំខាន់ដែលខ្ញុំចង់ពន្យល់ឱ្យបានច្បាស់នោះគឺថាសំណូមពរ ត្រូវតែជាសំណូមពរលម្អិតមួយ។ ចំណុចដែលត្រូវចងចាំគឺសេចក្ដីលម្អិត។ អ្នកកំពុងដាក់សេចក្ដីបង្គាប់មួយនៅក្នុងសេចក្ដីអធិស្ឋាន វាត្រូវតែជាសេចក្ដីបង្គាប់ដែលលម្អិត និងច្បាស់លាស់។ គម្ពីរភីលីព ៤:៦-៧ ក៏ប្រាប់យើងដូច្នេះដែរ។

**ក៏ប៉ុន្តែគ្រិស្ដបរិស័ទភាគច្រើននឹងនិយាយយ៉ាងដូច្នេះថា «ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រទានអ្វីមកខ្ញុំក៏បានដែរ។ ដ្បិតទ្រង់ជ្រាបអ្វីៗដែលប្រសើរបំផុត»។ ខុស! ខុស! គឺខុសតែម្ដង!**

*សូមកុំខ្វាយខ្វល់នឹងអ្វីឡើយ ផ្ទុយទៅវិញក្នុងគ្រប់កាលៈទេសៈទាំងអស់ត្រូវទូលព្រះជាម្ចាស់ឱ្យជ្រាបពី<u>សំណូមពរ</u>របស់បងប្អូនដោយអធិស្ឋាន និងទូលទូលអង្វរទាំងអស់ព្រះគុណផង។ ធ្វើដូច្នេះសេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ដែលហួសពីការស្មានរបស់មនុស្ស និងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូនដែលរួមក្នុងអង្គព្រះគ្រិស្តយេស៊ូមិនខាន។*

— ភីលីព ៤:៦-៧

សូមចងចាំថាការអធិស្ឋាន និងការសំណូមពរគឺជារឿងផ្សេងគ្នា។ ពាក្យអធិស្ឋានរបស់យើងមានសំណូមពររបស់យើងនៅក្នុងនោះ ក៏ប៉ុន្តែការអធិស្ឋានគឺជាយានជំនិះដែលនាំយកសំណូមពរទៅកាន់ព្រះបិតា។ ជាថ្មីម្ដងទៀត សំណូមពរត្រូវតែលម្អិត និងច្បាស់លាស់។ ក៏ប៉ុន្តែគ្រិស្ដបរិស័ទភាគច្រើននឹងនិយាយយ៉ាងដូច្នេះថា «ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រទានអ្វីមកខ្ញុំក៏បានដែរ។ ដ្បិតទ្រង់ជ្រាបអ្វីៗដែលប្រសើរបំផុត»។ ខុស! ខុស! គឺខុសតែម្ដង!

## ព្រះជាម្ចាស់បានប្រទានកូនសោទៅកាន់ព្រះរាជ្យឱ្យអ្នករួចហើយ!

ប្រសិនបើអ្នកបានអានសៀវភៅរបស់ខ្ញុំច្រើន អ្នកនឹងឃើញរឿងលម្អិតរាប់មិនអស់អំពីព្រះរាជ្យ។ មានរឿងជាច្រើននៅក្នុងសៀវភៅនេះដែលខ្ញុំសង្ឃឹមថានឹងជួយឱ្យអ្នកឃើញថាព្រះរាជ្យមានលក្ខណៈលម្អិតយ៉ាងដូចម្តេច ហើយថាពាក្យសម្តីរបស់អ្នកត្រូវតែលម្អិតយ៉ាងដូចម្តេច។ ដើម្បីពន្យល់ពីអ្វីដែលខ្ញុំចង់និយាយ សូមឱ្យខ្ញុំប្រាប់អ្នកពីរឿងចាស់ៗមួយចំនួនដែលអ្នកប្រហែលជាធ្លាប់បានឮពីមុនមកហើយ។ ក៏ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវការចំណាយពេលច្រើនតាមដែលខ្ញុំត្រូវការដើម្បីឱ្យអ្នកទទួលបានការយល់ដឹងដ៏ល្អមួយអំពីព្រះរាជ្យ ថាតើមានលក្ខណៈច្បាស់លាស់ដូចម្តេច។ ខ្ញុំសូមបង្ហាញពីការរំឭកមួយចំនួនអំពីរឿងដែលខ្ញុំបាននិយាយ។

## ព្រះរាជ្យកំពុងធ្វើការ

អ្នកបានអានពីមុនរួចមកហើយពីរបៀបដែលឡានបានរបស់ខ្ញុំបានឆេះបន្ទាប់ពីខ្ញុំបាននិយាយឮៗថា «ព្រះអម្ចាស់អើយ វាជាការល្អបំផុតប្រសិនបើឡាននេះឆេះឥលូវនេះ»។ ជាការចៃដន្យណាស់មែនឬទេ? សូមបន្តទៅមុខទៀត។ ខ្ញុំបានប្រាប់អ្នកអំពីសត្វក្តាន់ ពីរបៀបដែលព្រះអម្ចាស់បានបង្ហាញប្រាប់ខ្ញុំពីរបៀបសាបព្រោះគ្រាប់ពូជដើម្បីបានវា និងប្រាប់ថាមិនដែលមានក្តាន់ដើរមកក្រោមរានប្រមាញ់របស់ខ្ញុំទេពេលដែលខ្ញុំមិនបានសាបព្រោះគ្រាប់ពូជ។ ក្តាន់ដ៏ត្រឹមត្រូវ ជាក្តាន់ដែលខ្ញុំសាបព្រោះដើម្បីវា បានចូលមករកខ្ញុំគ្រប់ពេលទាំងអស់។ បន្ទាប់មក ខ្ញុំបានបង្ហាញអ្នកពីរបៀបដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំថា សត្វក្តាន់ចូលមកតាមលំដាប់លំដោយដែលខ្ញុំបានសាបព្រោះសម្រាប់ពួកវា។ សាកគិតទៅមើល តើអ្នកធ្លាប់បានឮរឿងដូច្នេះពីមុនមកដែរឬទេ? ខ្ញុំដឹងថាខ្ញុំមិនធ្លាប់ឮទេ រហូតដល់ខ្ញុំបានឃើញរឿងនេះដោយផ្ទាល់ភ្នែក។ ព្រះរាជ្យមានភាពច្បាស់លាស់ពិតប្រាកដយ៉ាងខ្លាំង ដូចដែលខ្ញុំបានប្រាប់អ្នកអំពីការដកពិសោធអំពីក្តាន់ស្នែងបែកខ្នែងជាប្រាំពីរ និងជាប្រាំមួយដែលធីមបានសាបព្រោះដើម្បី

វា។ ខ្ញុំបានប្រាប់អ្នកពីរបៀបដែលព្រះជាម្ចាស់បង្រៀនខ្ញុំឱ្យនិយាយអមជាមួយនឹងសិទ្ធិអំណាច ហើយសត្វក្ដាន់ដែលកំពុងដើរចេញពីខ្ញុំក្នុងចម្ងាយប្រមាណជិត ២០០ម៉ែត្របានឈប់ដើរភ្លាមៗ ក្នុងពេលដែលខ្ញុំនិយាយ ហើយវាក៏ចូលមកឈរនៅពីក្រោមរានប្រមាញ់លើដើមឈើរបស់ខ្ញុំតែម្ដង។ ខ្ញុំបានប្រាប់អ្នកអំពីមាន់ទោដែលខ្ញុំបញ្ជារឱ្យវាឈប់ហើរ ហើយវាក៏ឈប់ភ្លាមៗក្នុងគន្លងហោះហើររបស់វា។

ខ្ញុំបានប្រាប់អ្នកអំពីកាំភ្លើងដែលខ្ញុំបានចង្អុលនៅក្នុងហាងលក់សម្ភារៈកីឡា ខណៈដែលខ្ញុំនិយាយថា «ខ្ញុំនឹងយកកាំភ្លើងមួយនោះ។» ហើយពីរបីសប្ដាហ៍ក្រោយមក មានគេឱ្យកាំភ្លើងមួយដើមនោះមកឱ្យខ្ញុំ។ ខ្ញុំក៏បានប្រាប់អ្នកដែរអំពីឡាន BMW 645Ci បើកដំបូលបានដែលឌ្រិនដាបានឃើញពីកន្លែងចតឡានទៅ ហើយគាត់និយាយថា «ឡានហ្នឹងហើយ»! យើងមិនដែលបានប្រាប់រឿងនេះទៅនរណាទេ ក៏ប៉ុន្តែពីរសប្ដាហ៍ក្រោយមកបុរសម្នាក់នៅក្រុមជំនុំបានទូរសព្ទមកខ្ញុំ ហើយនិយាយថា «ថ្ងៃនេះខ្ញុំបានឃើញឡានរបស់ឌ្រិនដា»។ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយសួរគាត់ថាតើគាត់កំពុងនិយាយពីអ្វី។ គាត់បន្តនិយាយថាគាត់បានបើកឡានតាមទីក្រុង គាត់ក៏បានឃើញឡាន BMW 645Ci បើកដំបូលដែលគេដាក់លក់ទាំងនៅល្អឥតខ្ចោះ ហើយពេលដែលគាត់ឃើញឡាននោះ ព្រះអម្ចាស់បានមានបន្ទូលមកគាត់ថានោះគឺជាឡានរបស់ឌ្រិនដា។ រឿងនោះធ្វើឱ្យខ្ញុំចាប់អារម្មណ៍ណាស់ វាគឺឡានតែមួយតែម្ដង!

ខ្ញុំនឹងនិយាយរឿងមួយប្រាប់ដល់អ្នកនៅក្នុងជំពូកទី៧ ពីរបៀបដែលខ្ញុំបានទទួលបានយន្តហោះតែមួយដែលខ្ញុំបានសាបព្រោះដើម្បីវា ពីប្រតពមួយដែលខ្ញុំមិនដែលរំពឹងទុកសោះ និងរបៀបដែលខ្ញុំមានលុយដើម្បីទិញវា។ ខ្ញុំមានរឿងរាប់មិនអស់ដែលបង្ហាញថាតើព្រះរាជ្យមានដំណើរការច្បាស់លាស់យ៉ាងដូចម្ដេច។

ខ្ញុំនៅចាំពីពេលខ្ញុំបាញ់បានក្ដាន់ស្នែងបែកខ្នែងជា២៦ដ៏ធំរបស់ខ្ញុំ។ គឺនៅក្នុងខែវិច្ឆិកានាថ្ងៃដែលមានអាកាសធាតុក្ដៅល្មម។ ខ្ញុំបានព្យួរវាទុកពេញមួយថ្ងៃ ហើយនៅ

ថ្ងៃបន្ទាប់ខ្ញុំបានយកវាទៅកន្លែងញាត់ស្បែកសត្វ ដើម្បីឱ្យគេញាត់ស្បែកឱ្យបានជារូបរាងក្បាលរបស់វាវិញ។ គាត់បានមើលទៅរោមរបស់វា ហើយបាននិយាយថា «ឱ្យខ្ញុំសុំទោសផងចុះ មើលទៅរោមរបស់វាដូចជាខូចទៅហើយដោយសារតែអាកាសធាតុក្តៅ។ ខ្ញុំគិតថាខ្ញុំញាត់ស្បែកវាមិនកើតទេ ក៏ប៉ុន្តែចាំខ្ញុំព្យាយាមសាកមើលសិន»។ ឥលូវនេះក្តាន់ជាជ័យត័ណ្ឌ ដែលខ្ញុំទើបតែច្រូតផលបានដោយជំនឿនោះ មិនអាចយកធ្វើជាក្តាន់ញាត់ស្បែកដ៏អស្ចារ្យសម្រាប់ដាក់លម្អក្នុងការិយាល័យខ្ញុំបានទេ។ ក្នុងពេលនោះដែរគាត់បានដើរចូលទៅក្នុងការិយាល័យ ដើម្បីយកបែបបទសម្រាប់ធ្វើការកុម្ម៉ង់មួយចេញមក។ ពេលគាត់ដើរចូលក្នុងការិយាល័យ ខ្ញុំបានដាក់ដៃលើក្តាន់ ហើយបានប្រកាសថារោមវានឹងមានសភាពឥតខ្ចោះ ហើយរូបក្តាន់ញាត់ស្បែកនឹងចេញជាលទ្ធផលមកយ៉ាងល្អឥតទាស់។ បន្ទាប់ពីនោះមកខ្ញុំបានត្រលប់មកវិញ។ ក្រោយពីចាំអស់មួយខែដើម្បីមកយកក្តាន់ញាត់ស្បែករបស់ខ្ញុំ ហើយអ្នកញាត់ស្បែកនោះបាននិយាយថា «តើអ្នកដឹងទេ ខ្ញុំបានប្រាប់អ្នកថារោមវាបានខូចទៅហើយ ក៏ប៉ុន្តែក្តាន់ញាត់ស្បែកនេះធ្វើចេញមកល្អឥតទាស់ ព្រោះរោមវានៅល្អគ្មានទាស់អ្វីទេ»។

ខ្ញុំអាចបន្តចំណាយពេលរាប់ម៉ោងដើម្បីប្រាប់រឿងដូចរឿងទាំងនេះ ក៏ប៉ុន្តែរឿងដែលសំខាន់បំផុតនោះគឺ តើអ្នកកំពុងតែនិយាយពីអ្វីដែរ? គ្រប់ពាក្យសម្តីដែលអ្នកនិយាយចេញទៅ គឺអ្នកកំពុងតែដាក់ដំណើរការច្បាប់ខាងវិញ្ញាណ! អ្នកមុខជាមិនបានដឹងរឿងនោះទេ។ ខ្ញុំដឹងថា ខ្ញុំក៏មិនបានដឹងពីមុនមកដែរតែវាគឺជាការពិត។ ព្រះរាជ្យមានលក្ខណៈជាក់លាក់យ៉ាងខ្លាំង។ ខ្ញុំសូមប្រាប់អ្នកនូវរឿងមួយទៀត ហើយអ្នកនឹងមើលឃើញរឿងជាច្រើនផ្សេងទៀតដែលនៅសេសសល់ក្នុងសៀវភៅនេះទាំងមូល ដែលនឹងបញ្ជាក់ពីអ្វីដែលខ្ញុំកំពុងតែនិយាយ។ អ្នកអាចមើលដឹងថាខ្ញុំមានចិត្តឆេះឆួលអំពីការពន្យល់អំពីរឿងនេះយ៉ាងខ្លាំង។

## ការដាក់ដំណើរការច្បាប់ខាងវិញ្ញាណ

រឿងនោះកើតឡើងក្នុងអំឡុងសន្និបាតស្ត្រីដែលឌ្រិនដារៀបចំឡើង។ យើងបានជួលឡាន Cadillac Escalade ដើម្បីឱ្យភ្ញៀវរបស់យើងម្នាក់ធ្វើដំណើរទៅមកក្នុងពេលដែលគាត់ស្នាក់នៅក្នុងទីក្រុង។ នៅចុងបញ្ចប់នៃសន្និបាត យើងនៅមិនទាន់ដល់ពេលប្រគល់ឡាន Escalade នោះត្រលប់ទៅវិញទេ គឺយើងនៅមានពេលរហូតដល់ព្រឹកស្អែក ដូច្នេះហើយឌ្រិនដា និងខ្ញុំបានសម្រេចចិត្តបើកវាយកទៅផ្ទះក្នុងពេលយប់នោះ ដើម្បីដឹងថាការបើកបរមានលក្ខណៈដូចម្តេច។ យើងមិនដែលបើកបរឡាន Escalade ពីមុនមកទេ។ ជាការពិតមែន ដូចជាអ្វីដែលអ្នកអាចស្រមៃដឹងថាឡាននោះបើកបរបានល្អណាស់។ ហើយយើងបានបើកវាទៅក្រុមជំនុំវិញក្នុងពេលព្រឹកថ្ងៃបន្ទាប់ ក្នុងពេលបើកវាយើងបាននិយាយគ្នា ហើយយល់ស្របគ្នាថាយើងចង់បានឡាននោះមួយ។ ឡានដែលយើងកំពុងបើកនោះជាឡានខ្លី ហើយជាឡានពណ៌សរលោងដូចគុជខ្យង។ យើងទាំងពីរនាក់បានយល់ស្របគ្នាថាយើងចូលចិត្តឡានខ្លីជាងឡានវែង ហើយយើងក៏ស្រលាញ់ឡានពណ៌សដូចគុជខ្យងដែរ។

ក្រោយពីនោះប្រហែលជាមួយខែបន្ទាប់ពីព្រឹត្តិការណ៍នោះ ពេលដែលខ្ញុំកំពុងដើរចេញក្រៅដើម្បីយកកាសែតរបស់ខ្ញុំ ទូរសព្ទខ្ញុំក៏រោទ៍ឡើង ខ្ញុំលើកទូរសព្ទហើយឮសំឡេងពីខ្សែម្ខាងទៀត ជាសំឡេងសមាជិកក្រុមជំនុំខ្ញុំ។ គាត់និយាយដោយធម្មតាថា «ខ្ញុំចង់ទិញឡាន Cadillac Escalade មួយគ្រឿងជូនលោកគ្រូ។ តើលោកគ្រូចង់បានពណ៌អ្វីដែរ»? ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ក៏ប៉ុន្តែខ្ញុំបានប្រាប់គាត់ថាខ្ញុំចូលចិត្តពណ៌សគុជខ្យង។ ក៏ប៉ុន្តែខ្ញុំភ្លេចប្រាប់គាត់ថាខ្ញុំចូលចិត្តឡានខ្លី។ មួយខែបន្ទាប់ពីនោះមក ខ្ញុំគិតថាគាត់អាចនឹងភ្លេចពីរឿងឡាន Escalade នោះទៅហើយ ប៉ុន្តែទូរសព្ទខ្ញុំក៏រោទ៍ឡើង ហើយគាត់បាននិយាយថាគាត់បានឡានមួយនោះហើយ។ ដូច្នេះយើងបានទៅជួបគាត់ ហើយអ្វីដែលគាត់មាននោះគឺឡាន Escalade ពណ៌សគុជខ្យងប្រភេទខ្លីយ៉ាងល្អឥតទាស់។ ពេលយើងដើរចូលទៅមើលវា គាត់ក៏បន្តនិយាយបែបនេះថា «ឱ្យខ្ញុំសុំ

ទោសផង ដែលឱ្យលោកគ្រូរង់ចាំយូរ ក៏ប៉ុន្តែខ្ញុំរកមិនបានឡានប្រភេទវែងទេ»។ គាត់មិនបានដឹងទេថាយើងមិនចង់បានឡានប្រភេទវែង។ គាត់ចូលចិត្តឡានប្រភេទវែង ហើយគិតថាយើងក៏ចង់បានដូចគាត់ដែរ ក៏ប៉ុន្តែគាត់រកបានតែឡានប្រភេទខ្លីតែប៉ុណ្ណោះ។ ជាថ្មីម្តងទៀតហើយដែលយើងទទួលបានយានជំនិះដូចអ្វីដែលយើងបាននិយាយ និងបានយល់ស្របគ្នា។

មានឧទាហរណ៍មួយដ៏អស្ចារ្យដែលខ្ញុំបានឃើញនៅក្នុងការធ្វើអាជីវកម្ម បានកើតឡើងអំឡុងពីរបីឆ្នាំចុងក្រោយនេះ។ ដូចដែលអ្នកដឹងរួចមកហើយ ឬអ្នកអាចមិនបានដឹងទេថាខ្ញុំនៅតែជាម្ចាស់ក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកហិរញ្ញវត្ថុមួយ។ មុនពេលដែលខ្ញុំចាប់ផ្តើមកិច្ចការជាគ្រូគង្វាល កាលពី២៥ឆ្នាំមុន ខ្ញុំមានការិយាល័យលំដាប់ថ្នាក់លេខ១ មួយក្នុងចំណោមការិយាល័យ ៥.០០០កន្លែង សម្រាប់ក្រុមហ៊ុនលក់មួយរបស់ខ្ញុំ។ ពេលដែលខ្ញុំចាប់ផ្តើមដំណើរការក្រុមជំនុំរបស់ខ្ញុំ ខ្ញុំបានដឹងហើយថាខ្ញុំនឹងរវល់ខ្លាំង ហើយខ្ញុំសន្មតថាខ្ញុំមុខជាមិនអាចរក្សាតំណែងក្នុងលំដាប់ថ្នាក់លេខ១នោះបានទេ ហើយខ្ញុំពិតជារក្សាវាមិនបានពិតមែន។ នៅក្នុងអាជីវកម្មរបស់ខ្ញុំ ក្រុមហ៊ុនលក់របស់យើងផ្តល់រង្វាន់លើកទឹកចិត្តជាដំណើរកម្សាន្ត ដើម្បីជារង្វាន់ដល់អ្នកលក់របស់ពួកគេសម្រាប់លទ្ធផលដែលទទួលបានក្នុងឆ្នាំនីមួយៗ។

មានក្រុមហ៊ុនលក់មួយដែលខ្ញុំបានប្រើប្រាស់ បានប្រគល់ប្រាក់រង្វាន់ ១០០.០០០ដុល្លារ ទៅកាន់ការិយាល័យកំពូលទាំង១០របស់ខ្លួន នៅក្នុងសន្និបាតប្រចាំឆ្នាំរបស់គេសម្រាប់អ្នកដែលរកចំណូលបានលើសពី ១០លានដុល្លារក្នុងបរិមាណសរុប។ ពួកគេក៏ចំណាយលើដំណើរកម្សាន្តដ៏ល្អមួយនៅក្នុងសន្និបាតប្រចាំឆ្នាំ សម្រាប់អ្នកដែលរកចំណូលបានលើសពីបីលានដុល្លារផងដែរ។ ជាធម្មតា ខ្ញុំធ្វើបានប្រមាណជា៩លានដុល្លារជារៀងរាល់ឆ្នាំជាមួយនឹងក្រុមហ៊ុនមួយនេះ ដូច្នេះហើយខ្ញុំទទួលបានដំណើរកម្សាន្តដែលឥតគិតថ្លៃនោះ ហើយមានន័យថាខ្ញុំនឹងត្រូវអង្គុយនៅទីនោះ និងមើលគេប្រគល់មូលប្បទានបត្រ ១០០.០០០ដុល្លារទៅកាន់អ្នកដែលស្ថិតក្នុងលំដាប់

កំពូលទាំង១០ជារៀងរាល់ឆ្នាំ។ ខ្ញុំមើលឃើញរឿងនេះអស់ពេល ១៨ឆ្នាំ! ត្រូវហើយគឺអស់ពេល ១៨ឆ្នាំ។ ខ្ញុំមិនដែលគិតថាខ្ញុំអាចឈានដល់គោលដៅមួយនោះទេ ខណៈពេលដែលខ្ញុំជាគ្រូគង្វាលនៅក្នុងក្រុមជំនុំ ហេតុដូច្នេះហើយខ្ញុំមិនដែលដាក់ជំនឿខ្ញុំនៅក្នុងទិសដៅមួយនោះឡើយ។

ក៏ប៉ុន្តែមានឆ្នាំមួយ ពេលខ្ញុំកំពុងអង្គុយនៅក្នុងសន្និបាតមើលទៅអ្នកស្ថិតក្នុងលំដាប់កំពូលទាំង១០ ទទួលបានមូលប្បទានបត្រ ១០០.០០០ដុល្លាររបស់គេ ព្រះជាម្ចាស់មានបន្ទូលមកខ្ញុំថា «យើងចង់ឱ្យអ្នកឡើងទៅទីនោះ។ យើងចង់ឱ្យមនុស្សនៅទីនេះមើលឃើញព្រះនាមយើង»។ និយាយការពិតទៅពេលនោះគឺខែមីនាទៅហើយ ហើយដូចដែលខ្ញុំបាននិយាយមកហើយថាយើងតែងទទួលបានប្រមាណ ៨លានដុល្លារក្នុងមួយឆ្នាំ អស់រយៈពេល១៨ឆ្នាំមកហើយសម្រាប់ក្រុមហ៊ុននេះ។ មើលតាមធម្មតា ខ្ញុំមើលមិនឃើញផ្លូវណាមួយដើម្បីសម្រេចគោលដៅនោះទេ ក៏ប៉ុន្តែខ្ញុំបានអធិស្ឋានអំពីវា ហើយត្រិនដា និងខ្ញុំបានសាបព្រោះដើម្បីឈានទៅដល់គោលដៅ ១០លានដុល្លារនោះ។ ព្រះអម្ចាស់បានបង្ហាញខ្ញុំពីការផ្លាស់ប្តូរដែលខ្ញុំអាចធ្វើបានទាក់ទងនឹងរបៀបដែលក្រុមហ៊ុនរបស់ខ្ញុំដំណើរការ ទាក់ទងនឹងការសាកសួរព័ត៌មានផ្សេងៗដែលបង្កើតឱ្យមានភាពខុសគ្នាដ៏ធំមួយ។ និយាយឱ្យខ្លីទៅគឺយើងចូលក្នុងលំដាប់កំពូលទាំង១០បានសម្រេច ហើយបានទទួលមូលប្បទានបត្រ ១០០.០០០ដុល្លារ។ ក៏ប៉ុន្តែត្រង់នេះគឺជាផ្នែកដែលខ្ញុំចង់ចែករំលែកជាមួយអ្នក នោះគឺយើងសម្រេចវាបានដោយការលក់តែមួយគត់!

ក្នុងឆ្នាំបន្ទាប់ ក្រុមហ៊ុននោះបានបង្កើនគោលដៅរហូតទៅដល់ ១២លានដុល្លារ ដើម្បីទទួលបានកម្រិតមូលប្បទានបត្រ ១០០.០០០ដុល្លារ។ ដូច្នេះហើយយើងបានសាបព្រោះគ្រាប់ពូជ ហើយក៏សម្រេចបានក្នុងឆ្នាំនោះផងដែរ។ ក៏ប៉ុន្តែដូចជាអ្នកទាយដឹង គឺយើងសម្រេចវាបានក្នុងការលក់មួយ។ ពីរឆ្នាំបន្ទាប់ពីនោះកម្មវិធីនោះក៏ត្រូវរំសាយ។ ក៏ប៉ុន្តែនៅឆ្នាំមុនក្នុងឆ្នាំ ២០១៩ ពួកគេចាប់ផ្តើមកម្មវិធីម្តងទៀតក្នុងកម្រិត

១០លានដុល្លារ។ យើងបានសាបព្រោះគ្រាប់ពូជទៀត ហើយក៏បានចូលក្នុងលំដាប់កំពូលទាំង១០ ហើយអ្នកមុខជាទាយត្រូវទៀតហើយ ជាថ្មីម្តងទៀតយើងសម្រេចវាបានក្នុងការលក់មួយ។ តើវាជាការចៃដន្យមែនទេ ដែលយើងធ្វើបានជារៀងរាល់ឆ្នាំដោយការលក់តែមួយ? ទេ គឺយើងបានសាបព្រោះដើម្បីឈានដល់ចំនួនអប្បបរមាដើម្បីបានចូលទៅក្នុងកម្រិតមូលប្បទានបត្រ ១០០.០០០ដុល្លារនោះ។ ហើយគឺជាអ្វីដែលយើងបានធ្វើយ៉ាងពិតប្រាកដ។ តើយើងមានបំណងចង់ធ្វើវាបានដោយការលក់តែមួយមែនឬទេ? ជាការពិតគឺមិនដូច្នោះទេ។ យើងបានខិតខំធ្វើវាពេញទំហឹងពេញមួយឆ្នាំ ហើយយើងមិនដឹងតើអ្វីៗនឹងក្លាយទៅជាយ៉ាងណាទេ រហូតដល់ថ្ងៃចុងក្រោយនៃខែនីមួយៗ។ ជាថ្មីម្តងទៀតនេះគឺជារូបភាពដ៏ល្អដ៏អស្ចារ្យអំពីរបៀបដែលអ្វីៗមានដំណើរការ។

## សារៈសំខាន់នៃការដាក់សេចក្តីបង្គាប់

នៅក្នុងសន្និបាតអំពីការផ្គត់ផ្គង់ក្នុងឆ្នាំនេះ ព្រះជាម្ចាស់មានបន្ទូលមកខ្ញុំ និងប្រាប់ខ្ញុំឱ្យបង្រៀនអំពីអ្វីដែលខ្រិនដា និងខ្ញុំបានរៀនអំពីការដាក់សេចក្តីបង្គាប់។ នេះគឺជាអ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធបានដាក់ឈ្មោះឱ្យវាថាជាសេចក្តីបង្គាប់។ ហេតុដូច្នេះហើយខ្ញុំបានចំណាយពេលខ្លះ បង្រៀនក្នុងដំណើរការសន្និបាតនោះ ដោយខ្ញុំដឹងថាមានមនុស្សមិនច្រើនទេដែលបានដឹងអំពីការធ្វើរឿងនេះ។ តាមវចនានុក្រម សេចក្តីបង្គាប់គឺជាសេចក្តីណែនាំដែលមានអំណាច ឬជាផ្លូវការ។ សូមចាំថាវាគ្មានន័យថាជាការអង្វរសុំសេចក្តីមេត្តាករុណាទេ មិនមែនជាសេចក្តីណែនាំដែលធ្វើឱ្យមានការទើសទាល់ចិត្តទេ។ មិនដូច្នោះទេវាគឺជាសេចក្តីណែនាំដែលមានអំណាច! ដូច្នេះសូមមើលទៅចំណុចនេះកាន់តែស៊ីជម្រៅបន្ថែម។ ប្រសិនបើខ្ញុំផ្តល់សេចក្តីបង្គាប់ខាងវិញ្ញាណ តើនរណាជាអ្នកបំពេញកិច្ចការនោះទៅ? ជាការពិត គឺមាននរណាម្នាក់ជាអ្នកធ្វើ សូមស្វែងរកមើលថាតើជានរណា។

*ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសិស្សថា៖ «ចូរមានជំនឿលើព្រះជាម្ចាស់ចុះ!។ ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា បើអ្នកណាម្នាក់និយាយទៅកាន់ភ្នំនេះថា "ចូរចេញពីទីនេះធ្លាក់ក្នុងសមុទ្រទៅ!" ហើយបើអ្នកនោះជឿជាក់ក្នុងចិត្តដោយឥតសង្ស័យថាពាក្យរបស់ខ្លួននឹងបានសម្រេច <u>នោះព្រះជាម្ចាស់នឹងប្រទានឱ្យបានសម្រេចតាមពាក្យគេមែន</u>។ ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយឱ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។»*

— ម៉ាកុស ១១:២២-២៤

មានរឿងពីរនៅក្នុងអត្ថបទគម្ពីរនេះដែលខ្ញុំចង់បង្ហាញ។ សូមចាំថាគម្ពីរចែងថា «បើនរណាម្នាក់និយាយថា»។ នៅត្រង់នេះយើងឃើញពីអ្វីដែលគ្រិនដា និងខ្ញុំបានរកឃើញ។ ពាក្យសម្ដីរបស់យើងស្រាយស្ពានសួគ៌មកលើអាណាចក្រផែនដីនេះ។ ទីពីរ ខ្ញុំចង់ផ្ដោតសំខាន់ទៅលើឃ្លានេះដែលមានចែងក្នុងអត្ថបទគម្ពីរនេះ។

***«ហើយបើអ្នកនោះជឿជាក់ក្នុងចិត្ត ដោយឥតសង្ស័យថាពាក្យរបស់ខ្លួននឹងបានសម្រេច នោះ<u>ព្រះជាម្ចាស់នឹងប្រទានឱ្យបានសម្រេចតាមពាក្យគេមែន</u>»។***

សូមចាំថាមានចែងថា «នឹងប្រទានឱ្យបានសម្រេចតាមពាក្យគេមែន»! មិនមែនសម្រាប់ព្រះជាម្ចាស់ទេ គឺសម្រាប់ពួកគេ គឺអ្នកដែលនិយាយនៅលើផែនដីនេះ។

ពិតជាអស្ចារ្យមែន! សូមបញ្ឈប់អ្វីៗទាំងអស់។ អ្នកត្រូវតែគិតអំពីរឿងនោះមួយភ្លែតសិន! សូមឱ្យវាចាក់ចូលទៅជ្រៅ នៅទីនេះគឺនិយាយអំពីអ្នក។

ដូច្នេះតើនរណាធ្វើកិច្ចការនេះសម្រាប់ពួកគេ? សូមមើលនៅក្នុងគម្ពីរហេប្រឺ ១:១៤ ដើម្បីស្វែងយល់។

*ទេវតាទាំងនោះសុទ្ធតែជាវិញ្ញាណដែលនៅបម្រើព្រះជាម្ចាស់ ព្រះអង្គចាត់ពួកលោកឱ្យមកបំពេញមុខងារ ជាប្រយោជន៍ដល់អស់អ្នកដែលត្រូវទទួលការសង្គ្រោះទុកជាមតិក!។*

សូមចំណាំថា មានពាក្យពីរផ្សេងគ្នាពណ៌នាអំពីទេវតានៅទីនេះ គឺពាក្យបំពេញមុខងារ និងបម្រើ។ បម្រើមានន័យថាបំពេញតួនាទី ឬបំពេញសេវាកម្មផ្សេងៗសម្រាប់នរណាម្នាក់ផ្សេងទៀត ហើយនៅក្នុងករណីនេះគឺបំពេញតួនាទី ឬបំពេញសេវាកម្មសម្រាប់អ្នក។ បំពេញមុខងារសំដៅលើមន្ត្រីជាន់ខ្ពស់ម្នាក់របស់រដ្ឋាភិបាល ដែលបានទទួលមុខងារគ្រប់គ្រងការបែងចែកសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល។ និយាយឱ្យងាយយល់ ទេវតាគឺជាតំណាងនៃដំណាក់ស្ថានសួគ៌ដែលមានអំណាចបំពេញតួនាទីក្នុងនាមព្រះរាជ្យរបស់ព្រះជាម្ចាស់ ក្នុងនាមរបស់អ្នក។ សូមចាំថាយើងមិនអាចបញ្ជាទេវតាទៅមកតាមចិត្តទេ ដោយសារតែទេវតាមិនស្ថិតក្រោមការគ្រប់គ្រងរបស់យើង ក៏ប៉ុន្តែយើងអាចដាក់សំណូមពរទៅដំណាក់នៃស្ថានសួគ៌ សម្រាប់អ្វីដែលយើងត្រូវការ នោះទេវតានឹងចេញទៅបំពេញមុខងាររបស់ពួកគេ។ ពិតជាអស្ចារ្យណាស់!

«តើខ្ញុំចាំបាច់ត្រូវនិយាយដែរមែនឬទេ? ខ្ញុំមិនដឹងសោះ»។ ឃ្លានេះពណ៌នាអំពីមេរៀនដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំនៅក្នុងរឿងខាងក្រោមនេះ។

មានឆ្នាំមួយនោះ ខ្ញុំបានសាបព្រោះគ្រាប់ពូជដើម្បីទទួលបានក្តាន់ដែលទើបមានកំពកស្នែងមួយ។ ក្នុងពេលដែលរឿងនោះកើតឡើង ខ្ញុំមានទំនុកចិត្តយ៉ាងខ្លាំងថានឹងទទួលបានក្តាន់នោះ។ ដូច្នេះហើយខ្ញុំបានចេញទៅក្រៅទាំងក្តីរំពឹងដូចសព្វដងថា ខ្ញុំនឹងទទួលបានក្តាន់ដែលទើបមានកំពកស្នែងរបស់ខ្ញុំក្នុងពេលបន្តិចខាងមុខ។ ពេលខ្ញុំអង្គុយនៅលើរានប្រមាញ់លើដើមឈើ ខ្ញុំបានឃើញក្តាន់ដែលទើបមានកំពកស្នែងយ៉ាងប្រាកដ វាកំពុងដើរកាត់ព្រៃឈើក៏ប៉ុន្តែវានៅឆ្ងាយពេកសម្រាប់ខ្ញុំក្នុងការដកធ្នូរបស់ខ្ញុំបាញ់វា។ ខ្ញុំបានព្យាយាមប្រាប់វាឱ្យចូលមករកខ្ញុំ ក៏ប៉ុន្តែគ្មានអ្វីកើតឡើងទេ។

ពេញមួយព្រឹកនោះ ខ្ញុំមិនបានឃើញក្ដាន់ផ្សេងពីនោះទេ។ ខ្ញុំបានចេញទៅក្រៅនៅព្រឹកបន្ទាប់ ហើយមិនទាំងឃើញមានក្ដាន់ណាមួយឡើយ។ ដល់ដំណាក់កាលនេះ ខ្ញុំដឹងភ្លាមថាមានអ្វីម្យ៉ាងមិនត្រឹមត្រូវ។

ពេលខ្ញុំកំពុងដើរចេញពីព្រៃនៅថ្ងៃទីពីរ ខ្ញុំបានចាប់ផ្ដើមអធិស្ឋានទៅព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីទទួលបានចម្លើយ។ ភ្លាមៗនោះ ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញខ្ញុំពីអ្វីដែលមិនត្រឹមត្រូវ។ ពេលដែលខ្ញុំសាបព្រោះគ្រាប់ពូជដើម្បីសត្វក្ដាន់នោះ ខ្ញុំបានសរសេរតាមធម្មតានៅលើមូលប្បទានបត្រសម្រាប់គ្រាប់ពូជរបស់ខ្ញុំ ហើយដាក់វាក្នុងស្រោមសំបុត្រ និងផ្ញើវាចេញទៅ។ ខ្ញុំមិនបានដាក់ដៃលើមូលប្បទានបត្រ និងអធិស្ឋានដូចដែលខ្ញុំតែងតែធ្វើពីមុនមកទេ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានរំឭកខ្ញុំអំពីរឿងត្រង់ពេលព្រះយេស៊ូវពហុគុណនំប៉័ង និងត្រី ហើយបានបង្ហាញប្រាប់ខ្ញុំថាព្រះយេស៊ូប្រទានពរដល់ពួកវាមុនពេលដែលពួកវាអាចពហុគុណបាន។ ខ្ញុំចាំបានថាខ្ញុំបានគិតថា *តើខ្ញុំត្រូវធ្វើដូច្នោះដែរឬ?* កាលពីមុនៗខ្ញុំតែងតែដាក់ដៃលើស្រោមសំបុត្រ និងបានអធិស្ឋានឱ្យស្រោមសំបុត្រនោះ ក៏ប៉ុន្តែក្នុងថ្ងៃដែលខ្ញុំផ្ញើស្រោមសំបុត្រនៅថ្ងៃនោះក្នុងឆ្នាំនោះ ខ្ញុំមានការរវល់យ៉ាងខ្លាំងទើបខ្ញុំភ្លេច។ ខ្ញុំបានគិតថា គ្រាន់តែសាបព្រោះគ្រាប់ពូជប៉ុណ្ណោះគឺជាអ្វីដែលនាំសត្វក្ដាន់ចូលមកក្នុងការគ្រប់គ្រងរបស់ព្រះរាជ្យ។

ជាការពិត ខ្ញុំមានការព្រួយបារម្ភក្នុងការកែតម្រូវកំហុសរបស់ខ្ញុំ និងសាកល្បងការយល់ដឹងថ្មីរបស់ខ្ញុំអំពីព្រះរាជ្យ ដើម្បីពិនិត្យមើលថាតើខ្ញុំធ្វើត្រឹមត្រូវដែរឬទេ។ ដូច្នេះខ្ញុំបានសាបព្រោះគ្រាប់ពូជជាថ្មីដើម្បីទទួលបានក្ដាន់ដែលទើបមានកំពកស្នែង ក៏ប៉ុន្តែលើកនេះខ្ញុំបានធ្វើឱ្យប្រាកដថាខ្ញុំបានអធិស្ឋានសម្រាប់វាមុនពេលខ្ញុំសាបព្រោះវា។ ពេលដែលខ្ញុំនិយាយថាខ្ញុំអធិស្ឋានឱ្យវា គឺដូចជាឧទាហរណ៍ដែលខ្ញុំប្រាប់អ្នកនៅទីនេះអំពីអ្វីដែលខ្ញុំនឹងនិយាយ «ព្រះបិតាអើយ ថ្ងៃនេះកូនទទួលក្ដាន់ដែលទើបមានកំពកស្នែងមួយក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ដូចដែលកូនបានសាបព្រោះគ្រាប់ពូជនេះ។ កូនប្រកាសថាកិច្ចការនេះបានសម្រេចស្របតាមគម្ពីរម៉ាកុស ១១:២៤ ហើយកូនអរព្រះ

គុណទ្រង់សម្រាប់កិច្ចការនេះ។ សូមព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំក្តាន់ដែលទើបមានកំពក ស្នែងនោះឱ្យចូលមកក្នុងគន្លងផ្លូវដែលអាចប្រមាញ់បានយ៉ាងល្អឥតខ្ចោះ នៅក្នុងព្រះ នាមព្រះយេស៊ូគ្រិស្ត អាម៉ែន»។ ដូចអ្នកអាចមើលឃើញហើយ គឺគ្មានពាក្យអ្វីក្បាច់ក្បូរ ច្រើនទេ ក៏ប៉ុន្តែខ្ញុំមិនបានសុំ ឬអង្វរសុំក្តាន់នោះទេ។ ខ្ញុំកំពុងប្រកាស និងបង្ហាញឱ្យ ទ្រង់ដឹងពីសំណូមពររបស់ខ្ញុំ។ នរណាម្នាក់ដែលជាកងទ័ពជួរមុខមិនត្រូវការសុំគ្រឿងចំ បាំងឡើយ ពួកគេគ្រាន់តែស្នើសុំវាតាមធម្មតា។ ឬអាចនិយាយបានថាពួកគេមានសិទ្ធិ ស្របច្បាប់ទទួលបានអ្វីដែលពួកគេត្រូវការ ដោយមិនចាំបាច់សុំ ហើយគ្រាន់តែ និយាយថា «សូមហុចគ្រឿងចម្បាំងមក»។

នៅព្រឹកបន្ទាប់ ខ្ញុំបានចេញទៅរានប្រមាញ់លើដើមឈើរបស់ខ្ញុំមុនពេល មេឃភ្លឺ ហើយពេលខ្ញុំចាប់ផ្តើមមើលឃើញដើមឈើរឡើងពណ៌ប្រផេះ ខ្ញុំបានឃើញ ក្តាន់មួយក្បាលកំពុងធ្វើដំណើរតម្រង់មករកខ្ញុំ។ វាងងឹតពេកមិនអាចបាញ់វាបាន ក៏ ប៉ុន្តែខ្ញុំបានឃើញសត្វក្តាន់ធ្វើដំណើរតម្រង់មកដើមឈើររបស់ខ្ញុំ។ ពេលក្តាន់ដើរមក ដល់ដើមឈើរបស់ខ្ញុំ វាក៏ឈប់ដើរ ហើយក្នុងអំឡុងពេល១៥នាទីបន្ទាប់ពីនោះ វាក៏ដើរ ឃឹតៗជុំវិញដើមឈើរបស់ខ្ញុំ។ អ្វីដែលខ្ញុំអាចនិយាយបាននោះគឺថា ខ្ញុំមានការភ្ញាក់ ផ្អើលយ៉ាងខ្លាំង។ ក្តាន់នោះនៅប្រមាណជា ២០ម៉ែត្រពីដើមឈើខ្ញុំ ហើយកំពុងដើរជុំ វិញវាមួយៗ។

ពេលពន្លឺថ្ងៃចាំងមកលើដើមឈើកាន់តែភ្លឺឡើង ខ្ញុំមើលឃើញថាវាមិនមែន ជាក្តាន់ដែលមានស្នែងទេ។ ជាក់ស្តែងវាមើលទៅដូចជាក្តាន់ញី ដោយសារតែខ្ញុំមើល មិនឃើញមានដែលទើបមានកំពកស្នែងនៅពីលើក្បាលក្តាន់។ មេឃនៅមិនទាន់ភ្លឺ ច្បាស់នៅឡើយទេ ក៏ប៉ុន្តែពេលនេះជាពេលដែលប្រមាញ់ស្របច្បាប់បានហើយ ដោយ ហេតុថារដ្ឋអូហៃយ៉ូមានច្បាប់អំពីម៉ោងប្រមាញ់នៅពេលព្រឹក។ ខ្ញុំបាននិយាយហើយ ថា ខ្ញុំមើលមិនដឹងថាជាក្តាន់ដែលទើបមានកំពកស្នែងទេ ក៏ប៉ុន្តែខ្ញុំក៏បានដឹងដែរថាក្នុង ករណីជាច្រើន កំពកស្នែងតូចគឺនៅបាំងពីក្រោមរោមវាបន្តិច។ ដោយសារតែក្តាន់មាន

អាកប្បកិរិយាចម្លែក វាបានធ្វើឱ្យខ្ញុំដឹងថាវាមុខជាក្តាន់របស់ខ្ញុំហើយ ដូច្នេះខ្ញុំក៏បាញ់ហើយក៏ត្រូវក្តាន់នោះដួលទៅ។ ពេលខ្ញុំទៅដល់កន្លែងក្តាន់នោះខ្ញុំពេញចិត្តណាស់ដែលបានឃើញកំពកខ្មែងរបស់វា ហើយខ្ញុំដឹងយ៉ាងប្រាកដថាវាជាក្តាន់ដែលទើបមានកំពកស្នែងរបស់ខ្ញុំ។ ខ្ញុំបានទុកក្តាន់នៅទីនោះសិន ដោយសារតែខ្ញុំនឹកឃើញថាខ្ញុំភ្លេចយកកាំបិតមកទៅហើយ ដូច្នេះខ្ញុំក៏ដើរត្រលប់ទៅផ្ទះ ហើយយកកាំបិតមួយមក។

ពេលខ្ញុំត្រលប់ទៅរកក្តាន់វិញ ខ្ញុំឃើញធីមដើរតម្រង់មករកខ្ញុំ។ គាត់សួរខ្ញុំថាមានឃើញអ្វីខ្លះទេ ហើយខ្ញុំក៏ប្រាប់គាត់ពីហេតុការណ៍កាលពីព្រឹកមិញនេះ។ ពេលយើងដើរទៅដល់កន្លែងដែលក្តាន់ដែលទើបមានកំពកស្នែងកំពុងដេក គាត់ក៏ប្រាប់ខ្ញុំថាគាត់ចេញក្រៅបីមកនេះ គាត់មិនដែលបានឃើញសូម្បីតែក្តាន់មួយ។ ធីមបានចេញមកក្រៅជាមួយខ្ញុំទាំងបីថ្ងៃ ពេលគាត់ប្រាប់ខ្ញុំដូច្នេះ ខ្ញុំដឹងភ្លាមថាមានបញ្ហាអ្វី។ ខ្ញុំចាំបានថ្ងៃដែលគាត់បានមកការិយាល័យរបស់ខ្ញុំ និងបានឱ្យមូលប្បទានបត្រមួយមកខ្ញុំទុកជាគ្រាប់ពូជសម្រាប់សត្វក្តាន់ ដែលគាត់បានសាបព្រោះទៅក្រុមជំនុំ។ ខ្ញុំចាំបានថាគាត់មិនបានអធិស្ឋានឱ្យគ្រាប់ពូជរបស់គាត់ទេ។ ខ្ញុំចំណាយពេលខ្លះ និងបានពន្យល់គាត់ពីអ្វីដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំ ទាក់ទងនឹងការអធិស្ឋានឱ្យគ្រាប់ពូជនៅពេលដែលយើងសាបព្រោះវា។

ក្នុងយប់នោះ ធីម និងខ្ញុំមានការងារត្រូវបំពេញនៅទីក្រុង កូឡុំបឺស (Columbus) ហើយពេលយើងត្រលប់មកផ្ទះវិញ យើងបានជិះកាត់ក្រុមជំនុំ។ ធីមបានសុំឱ្យខ្ញុំឈប់ឡានបន្តិច ហើយគាត់សាបព្រោះគ្រាប់ពូជជាថ្មីម្តងទៀត ហើយលើកនេះគាត់បានអធិស្ឋានឱ្យវាពេលដែលគាត់ថ្វាយវា។ ពេលយើងអង្គុយក្នុងការិយាល័យខ្ញុំគាត់បានឃើញគ្រាប់ពូជរបស់គាត់ ហើយនៅលើគ្រាប់ពូជនោះខ្ញុំថាគាត់បានសាបព្រោះដើម្បីបានក្តាន់ស្នែងបែកខ្នែងជា៦។ ខ្ញុំគិតថានោះគឺជាការប្រកាសដែលហាក់ដូចជារាងក្លាហាន និងមានភាពជាក់លាក់។

នៅព្រឹកបន្ទាប់ ធីមបានទៅរកដើមឈើដដែល ដែលខ្ញុំបានទៅកាលពីថ្ងៃមុន។ គាត់ទទួលបានបទពិសោធដូចនឹងខ្ញុំបានជួបនៅថ្ងៃមុននេះដែរ។ មុនពេលថ្ងៃរះបញ្ចេញពន្លឺ ក្តាន់ឈ្មោលមួយដើរតម្រង់មករកដើមឈើ ហើយគ្រាន់តែដើរជុំវិញដើមឈើ រហូតដល់ពេលបើកភ្លើងអនុញ្ញាតប្រមាញ់។ ធីមបានបាញ់ក្តាន់ ហើយមានអារម្មណ៍ថាគាត់បាញ់ត្រូវចំក្តាន់ល្អណាស់។ តែគួរឱ្យសោកស្តាយក្តាន់បានរត់បាត់មើលលែងឃើញ ហើយទោះបីជាយើងស្វែងរកវាអស់ពេលពីរម៉ោងហើយក្តី យើងនៅតែរកវាមិនឃើញ។ ពិតជាការអស្ចារ្យណាស់ ពេលក្រោយមកទៀតក្នុងថ្ងៃនោះមិត្តរបស់យើងដែលរស់នៅឆ្ងាយពីយើងជាង១គីឡូដីបានប្រាប់យើងថាអ្នកជិតខាងរបស់គាត់បានឃើញក្តាន់ស្នែងបែកខ្នែងជាប្រាំមួយដេកងាប់នៅលើផ្លូវដែលគាត់បើកឡានពេលក្រោកពីដំណេកព្រឹកមិញនេះ។ ក្តាន់នោះមានជាប់ព្រួញនៅនឹងខ្លួនវា។ ផ្ទះរបស់អ្នកជិតខាងម្នាក់នោះនៅចំទីតាំងដែលសត្វក្តាន់រត់ចេញពីព្រៃឈើលើដីរបស់យើងតែម្តង។ មិត្តរបស់យើងបានប្រាប់យើងថា អ្នកជិតខាងម្នាក់នោះមិនដឹងថានរណាបានបាញ់ក្តាន់នោះទេ ហើយគាត់ក៏កាប់សាច់វាដោយខ្លួនឯងនៅពេលព្រឹកនោះតែម្តង។ ខ្ញុំដឹងថារឿងនេះដូចជារញ៉េរញ៉ៃណាស់ ក៏ប៉ុន្តែទុកថាជាមេរៀនទៅចុះ។

## សូមអធិស្ឋានឱ្យគ្រាប់ពូជរបស់អ្នកពេលអ្នកថ្វាយវា ដូចព្រះយេស៊ូបានធ្វើដែរ។

យ៉ាងណាមិញ ធីមបានសាបព្រោះគ្រាប់ពូជថ្មី និងបានចេញទៅក្រៅ ហើយក៏ទទួលបានក្តាន់របស់គាត់នៅក្នុងសប្តាហ៍បន្ទាប់ពីនោះ។

## ពេលអ្នកនិយាយ សូមឱ្យមានភាពជាក់លាក់

ខ្ញុំដឹងថាក្តាន់ស្នែងបែកខ្នែងជាប្រាំមួយ ពិតជាជាក់លាក់ណាស់ ក៏ប៉ុន្តែពេលដែលយើងយល់ពីរឿងនេះ យើងដឹងថាព្រះរាជ្យគឺមានលក្ខណៈជាក់លាក់! សូមមើលទៅកាន់ឋានៈទុកជាឧទាហរណ៍។

> *លក្ខណៈដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដែលមនុស្សមើលពុំឃើញ គឺឫទ្ធានុភាពដែលនៅស្ថិតស្ថេរអស់កល្បជានិច្ចក្ដី ឬឋានៈរបស់ព្រះអង្គជាព្រះជាម្ចាស់ក្ដី ព្រះអង្គបានសម្ដែងឱ្យគេឃើញ តាំងពីកំណើតពិភពលោកមកម៉្លេះ នៅពេលណាដែលគេរិះគិតអំពីស្នាព្រះហស្ដរបស់ព្រះអង្គ។ ដូច្នេះ គេពុំអាចដោះសាខ្លួនបានឡើយ*
>
> — រ៉ូម ១:២០

ព្រះគម្ពីរចែងថាលក្ខណៈដ៏ល្អប្រសើរបំផុតរបស់ព្រះអង្គដែលមនុស្សមើលពុំឃើញ គឺមើលឃើញនៅក្នុងឋានៈរបស់ព្រះអង្គ។ ដូច្នេះខ្ញុំសូមសួរសំណួរមួយទៅកាន់អ្នកថា «តើឋានៈមានលក្ខណៈលម្អិតដូចម្ដេច»? គឺលម្អិតខ្លាំងក្រៃលែង! ប្រសិនបើខ្ញុំប្រាប់អ្នកថាខ្ញុំនឹងទិញឡានមួយ នោះសំណួរបន្ទាប់របស់អ្នកគឺ «តើឡានប្រភេទអ្វីដែរ»? មែនឬទេ? អ្នកមិនអាចមើលឃើញឡានមួយនៅក្នុងគំនិតរបស់អ្នកបានទេ ពេលដែលខ្ញុំជាអ្នកនិយាយថាឡាន។ អ្នកមើលឃើញ «ឡាន» ជាឡានមួយដែលជាក់លាក់បំផុត ជាឡានម៉ាក Ford ឬឡាន Chevy ឬជាឡានម៉ូឌែលណាមួយច្បាស់លាស់ជាមួយនឹងពណ៌ណាមួយច្បាស់លាស់។ គ្មានរូបភាពភ្ជាប់ជាមួយនឹងពាក្យថាឡានទេ តែវាតែងតែជាឡានណាមួយជាក់លាក់។ នេះជារបៀបដែលអ្នកត្រូវអនុវត្តនៅក្នុងការអធិស្ឋានក្នុងជីវិតអ្នកដែរ។

តើអ្នកធ្លាប់អានឯកសារផ្លូវច្បាប់ដែរឬទេ? ខ្ញុំប្រាកដចិត្តថាអ្នកធ្លាប់។ ឯកសារទាំងនោះមានលក្ខណៈលម្អិតយ៉ាងខ្លាំង។ ជាការពិតអ្វីដែលអ្នកស្រាយតាមរយៈពាក្យសម្ដីអ្នក ក៏មានភាពច្បាស់លាស់ដូច្នោះដែរ ទោះបីជាក្នុងពេលដែលអ្នកមិនចង់ឱ្យពាក្យសម្ដីអ្នកច្បាស់លាស់ក៏ដោយ។ សូមមើលរបៀបដែលព្រះយេស៊ូបានបំពេញព័ន្ធកិច្ច។ ទ្រង់យល់ពីសារៈសំខាន់នៃពាក្យសម្ដី៖

*កាលព្រះយេស៊ូយាងចុះពីលើភ្នំមកវិញ មានមហាជនជាច្រើននាំគ្នាដើរតាមព្រះអង្គ។ ពេលនោះ មានមនុស្សឃ្លង់ម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះអង្គទូលថា៖ «លោកម្ចាស់អើយ! ប្រសិនបើលោកមិនយល់ទាស់ទេ សូមប្រោសខ្ញុំប្របាទឱ្យជាស្អាតបរិសុទ្ធផង»។*

*ព្រះយេស៊ូលូកព្រះហស្តទៅពាល់គាត់ ទាំងមានព្រះបន្ទូលថា៖ «ខ្ញុំយល់ព្រមហើយ ចូរឱ្យបានជាស្អាតបរិសុទ្ធចុះ»។ រំពេចនោះ គាត់ក៏ជាស្អាតបរិសុទ្ធពីរោគឃ្លង់ភ្លាម។*

— ម៉ាថាយ ៨:១-៣

សូមចំណាំថាគ្មានអ្វីកើតឡើងទេ រហូតទាល់តែព្រះយេស៊ូមានបន្ទូលថា «ចូរឱ្យបានស្អាតបរិសុទ្ធចុះ»!

*កាលព្រះយេស៊ូ និងពួកសិស្សបានទៅដល់ត្រើយម្ខាង ក្នុងតំបន់គេរ៉ាស៊ីន មានបុរសអារក្សចូលពីរនាក់ចេញពីទីបញ្ចុះសព ដើរតម្រង់មករកព្រះអង្គ។ បុរសទាំងពីរនេះកាចណាស់ គ្មាននរណាហ៊ានដើរកាត់តាមនោះទេ។ អ្នកទាំងពីរស្រែកឡើងថា៖ «ព្រះបុត្រារបស់ព្រះជាម្ចាស់អើយ! តើព្រះអង្គចង់ធ្វើអ្វីយើងខ្ញុំ? ព្រះអង្គយាងមកទីនេះ ដើម្បីធ្វើទុក្ខទោសយើងខ្ញុំ មុនពេលកំណត់ឬ?»។*

*នៅឆ្ងាយពីនោះបន្តិច មានជ្រូកមួយហ្វូងធំកំពុងរកស៊ី។ ពួកអារក្សអង្វរព្រះយេស៊ូថា៖ «បើព្រះអង្គចង់ដេញយើងខ្ញុំ សូមបញ្ជូនយើងខ្ញុំឱ្យចូលទៅក្នុងជ្រូកមួយហ្វូងនេះទៅ»។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅអារក្សថា៖ «ទៅចុះ!»។ ពួកអារក្សក៏ចេញពីបុរសទាំងពីរ ចូលទៅក្នុងជ្រូក។ ពេលនោះ ហ្វូងជ្រូកបោលចុះតាមជម្រាលភ្នំ តម្រង់ទៅសមុទ្រ លង់ទឹកងាប់អស់ទៅ។*

— ម៉ាថាយ ៨:២៨-៣២

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

សូមចាំថាវិញ្ញាណអាក្រក់និយាយទៅព្រះយេស៊ូ ហើយមិនមែនកំពុងតែរត់គេចខ្លួនទេ! ពួកគេមានការសន្ទនាពិតប្រាកដមួយជាមួយគ្នា! វិញ្ញាណអាក្រក់ចាកចេញទៅនៅពេលព្រះយេស៊ូមានបន្ទូលថា «ទៅចុះ»! អ្នកជាអ្នកគ្រប់គ្រង អ្នកមានកូនសោ ប៉ុន្តែអ្នកត្រូវតែនិយាយចេញមក! សូមនិយាយអ្វីម៉្យាងចុះ។ បញ្ជាក់ជាថ្មីម្តងទៀត ព្រះរាជ្យគឺជាព្រះរាជ្យមួយដែលមានច្បាប់ និងមានលំហូរនៃសិទ្ធិអំណាចមួយដ៏ត្រឹមត្រូវ ដូច្នេះពាក្យសម្តីរបស់អ្នកមានសារៈសំខាន់!

**អ្នកជាអ្នកគ្រប់គ្រង អ្នកមានកូនសោ ក៏ប៉ុន្តែអ្នកត្រូវតែនិយាយចេញមក!**

មុនពេលយើងបន្តទៅមុខទៀត សូមរំឭកពីអ្វីដែលយើងបានរៀនរួចមកហើយ។ ពេលព្រះយេស៊ូប្រទានពរដល់នំបុ័ង និងត្រី របស់ទាំងពីរនោះបានផ្លាស់ប្តូរព្រះរាជ្យ។ ហើយអ្នកក៏ដូចព្រះយេស៊ូដែរ អ្នកចង់ដាក់សេចក្តីបង្គាប់ទៅគ្រាប់ពូជរបស់អ្នក នៅពេលដែលអ្នកថ្វាយវា។ តើអ្នករំពឹងចង់ឃើញអ្វី នៅពេលដែលអ្នកថ្វាយគ្រាប់ពូជរបស់អ្នកទៅ? គ្រប់គ្រាប់ពូជទាំងអស់មានរូបភាពមួយនៅជាប់ជាមួយវា។ រាល់ពាក្យសន្យាក៏មានរូបភាពមួយនៅជាមួយវាដែរ។ យើងនឹងនិយាយពីចំណុចនេះនៅពេលក្រោយ ក៏ប៉ុន្តែសម្រាប់សំណួរបន្ទាប់ដែលខ្ញុំចង់លើកឡើងនោះគឺ ទីកន្លែងដែលអ្នកគួរសាបព្រោះគ្រាប់ពូជរបស់អ្នក។

## តើអ្នកគួរសាបព្រោះគ្រាប់ពូជរបស់អ្នកនៅទីណា?

ជាដំបូង អ្នកមុខជាចង់សាបព្រោះចូលក្នុងកិច្ចការណាមួយរបស់ព្រះជាម្ចាស់នៅលើអាណាចក្រផែនដីនេះ។ សូមចាំថាខ្ញុំមិនមែនកំពុងនិយាយពីប្រភេទនៃការឱ្យទៅមនុស្សដែលខ្វះខាតដោយចិត្តសប្បុរស តាមរបៀបរស់នៅធម្មតារបស់អ្នកទេ។

*អ្នកដែលចែកទានដល់ជនទុគ៌តទុកដូចជាឱ្យព្រះអម្ចាស់ខ្ចី ព្រះអង្គនឹងប្រទានរង្វាន់ដល់អ្នកនោះវិញ។*

## ការផ្តល់អំណាចដល់ព្រះរាជទានរបស់អ្នក

— សុភាសិត ១៩:១៧

វាគឺជាការពិតពេលដែលអ្នកមានចិត្តសប្បុរស ព្រះជាម្ចាស់នឹងប្រទានរង្វាន់ដល់អ្នកវិញ!

*សូមចងចាំថា អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានផលតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិបូរ ក៏ច្រូតបានផលច្រើនបរិបូរដែរ។ ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់តាមតែខ្លួនសម្រេចចិត្ត ដោយមិននឹកស្ដាយ ឬទើសទ័លឡើយ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណាដែលធ្វើអំណោយដោយចិត្តរីករាយ។ ព្រះអង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន ដើម្បីឱ្យបងប្អូនមានអ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏ចាំបាច់នោះជានិច្ច ហើយថែមទាំងនៅសល់បរិបូរសម្រាប់ចែកទានផងដូចមានចែងទុកមកថា:*
*ព្រះអង្គចែក ព្រះអង្គប្រទានឱ្យអ្នកក្រសេចក្ដីសុចរិតរបស់ព្រះអង្គនៅស្ថិតស្ថេរហូតតរៀងទៅ។*
*ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» <u>ព្រះអង្គក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្ដីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក</u> និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ដោយយើងជួយគេ*
*ដ្បិតមុខងារប្រមូលប្រាក់នេះមិនត្រឹមតែជួយផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែមទាំងជួយគេឱ្យ<u>អរព្រះគុណព្រះជាម្ចាស់</u>កាន់តែច្រើនឡើងទៀតផង។ ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ <u>គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់</u> ព្រោះបងប្អូនសម្ដែងឱ្យគេឃើញថាបងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អរបស់ព្រះគ្រិស្តដែលបងប្អូនប្រកាស*

*ហើយបងប្អូនមានចិត្តទូលាយដោយយករបស់របរមកចែកជាមួយពួកគេ និងជាមួយមនុស្សទាំងអស់។ គេទូលអង្វរព្រះជាម្ចាស់ឱ្យបងប្អូនដោយចិត្តស្រលាញ់ ព្រោះតែព្រះគុណដ៏ច្រើនលើសលុបដែលព្រះជាម្ចាស់ប្រទានមកបងប្អូន។ សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គរកថ្លែងពុំបាន!*

— ២ កូរិនថូស ៩:៦-១៥

ជាការពិតណាស់ ព្រះជាម្ចាស់ប្រទានរង្វាន់ដល់អ្នកដែលមានចិត្តសប្បុរស។ ក៏ប៉ុន្តែប្រភេទនៃការឱ្យដែលខ្ញុំកំពុងនិយាយនេះ គឺអំពី**ការថ្វាយដែលមានគោលដៅ** ជាមួយនឹង**ការច្រូតផលដែលបានកំណត់ទុកជាមុន។** សូមចាំថាខ្ញុំនឹងដាក់ឈ្មោះឱ្យគ្រាប់ពូជរបស់ខ្ញុំ នៅក្នុងប្រភេទនៃការថ្វាយដែលខ្ញុំកំពុងនិយាយនេះ។ ការមានចិត្តសប្បុរសគឺជាសកម្មភាពនៃចិត្តមេត្តា ហើយជាធម្មតាខ្ញុំមិនដាក់ឈ្មោះឱ្យការថ្វាយដោយចិត្តសប្បុរសរបស់ខ្ញុំទេ ក៏ប៉ុន្តែផ្ទុយទៅវិញខ្ញុំប្រកាសពីអ្វីដែលយើងបានអាននៅក្នុងគម្ពីរ ២ កូរិនថូស ជំពូក ៩ ដែលប្រាប់ថាព្រះជាម្ចាស់នឹងប្រទានឱ្យខ្ញុំមានគ្រាប់ពូជដើម្បីអាចមានចិត្តសប្បុរសបាន ហើយនៅពេលដែលខ្ញុំបន្តមានចិត្តសប្បុរស ទ្រង់នឹងបង្កើនទ្រព្យសម្បត្តិរបស់ខ្ញុំបន្ថែមទៀតដើម្បីឱ្យខ្ញុំអាចបង្កើនការឱ្យទៅអ្នកដទៃបាន។

## ការថ្វាយដែលមានគោលដៅ

ខ្ញុំបានបញ្ជាក់រួចមកហើយថានៅពេលដែលខ្ញុំសាបព្រោះ ខ្ញុំបានចូលរួមសកម្មភាពដែលខ្ញុំឱ្យឈ្មោះថាការថ្វាយដោយមានគោលដៅ។ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ការថ្វាយប្រភេទនេះមានការច្រូតផលមួយដែលបានកំណត់ទុកជាមុន។ នេះគឺជាអ្វីដែលព្រះយេស៊ូបានធ្វើយ៉ាងពិតប្រាកដ នៅក្នុងម៉ាកុសជំពូក៦។ ទ្រង់ប្រឈរមុខជាមួយនឹងតម្រូវការដ៏ជាក់លាក់មួយ ហើយទ្រង់ត្រូវការចម្លើយមួយដែលមានភាពជាក់លាក់យ៉ាងខ្លាំង។ ទ្រង់ត្រូវការអាហារឱ្យមនុស្ស ២០.០០០នាក់បរិភោគ ដូច្នេះហើយទើបទ្រង់ត្រូវការគ្រាប់ពូជដ៏ជាក់លាក់ដើម្បីបំពេញកិច្ចការនោះ។ នៅក្នុងរឿងនោះ ទ្រង់

មិនបានសាបព្រោះគ្រាប់ពូជទេ គឺទ្រង់បានទទួលគ្រាប់ពូជ។ ហើយនោះមិនមែនជាការថ្វាយតាមចិត្តទេ គឺជាការថ្វាយអ្វីដែលអ្នកចង់បាន។ ពេលនោះទ្រង់ត្រូវការនរណាម្នាក់ដែលនឹងសាបព្រោះគ្រាប់ពូជជាក់លាក់មួយ ដើម្បីឱ្យវាបានពហុគុណនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ ហេតុនេះហើយទើបទ្រង់មានបន្ទូលថា «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។ នំបុ័ង និងត្រីគឺជាអ្វីដែលទ្រង់ត្រូវការក្នុងពេលនោះ ទ្រង់មិនត្រូវការអុស ឬអាវក្រៅទេ ក៏ប៉ុន្តែទ្រង់ពិតជាត្រូវការនំបុ័ង និងត្រីជាពិសេស។

សូមប្រាកដក្នុងចិត្តថាពេលអ្នកសាបព្រោះ គឺអ្នកកំពុងតែដាក់សេចក្តីបង្គាប់ដើម្បីបំពេញតាមតម្រូវការជាក់លាក់ដែលអ្នកត្រូវការ។ ពេលដែលខ្ញុំត្រូវការអ្វីម៉្យាងជាក់លាក់ ខ្ញុំតែងតែដំណើរការការថ្វាយប្រភេទនេះ ខ្ញុំច្បាស់លាស់ចំពោះអ្វីដែលខ្ញុំត្រូវការ ហើយខ្ញុំដាក់ឈ្មោះឱ្យគ្រាប់ពូជរបស់ខ្ញុំពេលដែលខ្ញុំសាបព្រោះវា។ ពេលដែលខ្ញុំថ្វាយ ខ្ញុំតែងតែថ្វាយតាមរយៈមូលប្បទានបត្រ ឬតាមអនឡាញ ដូច្នេះហើយគឺខ្ញុំបានសរសេរពីតម្រូវការរបស់ខ្ញុំយ៉ាងប្រាកដនៅលើមូលប្បទានបត្រ។ ឬប្រសិនបើខ្ញុំថ្វាយតាមអ៊ីនធឺណែត នោះខ្ញុំនឹងសរសេរកំណត់ចំណាំពីអ្វីដែលខ្ញុំថ្វាយដើម្បីទុកជាកំណត់ត្រារបស់ខ្ញុំ រួមទាំងសេចក្តីបង្គាប់ដែលខ្ញុំបានដាក់ភ្ជាប់នៅក្នុងការថ្វាយនោះ ក៏ដូចជាដាក់កាលបរិច្ឆេទ និងពេលវេលាដែលខ្ញុំបានថ្វាយផងដែរ។ សូមចាំថាអ្នកមិនរង់ចាំដើម្បីទទួលបាននូវអ្វីអ្នកអធិស្ឋាន ឬប្រកាសនៅក្នុងកាលបរិច្ឆេទមួយក្នុងថ្ងៃអនាគតទេ អ្នកទទួលបានរបស់ទាំងនោះនៅពេលដែលអ្នកអធិស្ឋានតែម្តង!

*ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយឱ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។*

— ម៉ាកុស ១១:២៤

ឥលូវនេះ ការថ្វាយដោយមានគោលដៅនេះបានសាបព្រោះរួចហើយ ទៅក្នុងបេសកកម្មរបស់ព្រះរាជ្យ នេះគឺជាអ្វីម្យ៉ាងដែលព្រះជាម្ចាស់កំពុងតែធ្វើនៅលើអាណាច្រកផែនដី។ ជាធម្មតា វាជាព័ន្ធកិច្ចមួយដែលព្រះជាម្ចាស់ប្រទានឱ្យបុរស ឬស្ត្រីម្នាក់មានបេសកកម្មដែលតម្រូវឱ្យពួកគេត្រូវការការឧបត្ថម្ភ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា ការធ្វើបែបនេះខុសគ្នាពីការជួយអ្នកក្រីក្រ ឬខ្វះខាតធម្មតាដែលជាកិច្ចការរបស់ព្រះជាម្ចាស់ដែរ ហើយជាការពិត ព្រះជាម្ចាស់បានបញ្ជាក់ច្បាស់លាស់ហើយពីរង្វាន់ដែលបានមកពីការថ្វាយប្រភេទនោះ។ សូមចាំថា យើងកំពុងនិយាយពីការថ្វាយដែលមានគោលដៅ។ ជាការពិតណាស់ អ្នកអាចសាបព្រោះគ្រាប់ពូជប្រភេទនេះទៅក្នុងក្រុមជំនុំតាមតំបន់របស់អ្នកបាន ហើយដាក់ស្លែងការថ្វាយដែលមានគោលដៅរបស់អ្នក គួរតែត្រូវថ្វាយទៅក្រុមជំនុំក្នុងតំបន់របស់អ្នក។

និយាយដល់ក្រុមជំនុំផ្ទះរបស់អ្នក តង្វាយមួយភាគដប់របស់អ្នកក៏ជាកម្មសិទ្ធិរបស់ក្រុមជំនុំក្នុងតំបន់របស់អ្នកដែរ។ មានមនុស្សជាច្រើនបានសួរខ្ញុំថា តើពួកគេអាចថ្វាយតង្វាយមួយភាគដប់មកក្នុងព័ន្ធកិច្ចរបស់យើងបានដែរឬទេ ដោយសារតែពួកគេគឺចូលរួមចំណែកក្នុងក្រុមជំនុំអនឡាញរបស់យើង។ ខ្ញុំប្រាប់ពួកគេថា «ប្រាកដជាបាន»។ ប៉ុន្តែខ្ញុំក៏លើកទឹកចិត្តពួកគេឱ្យស្វែងរកក្រុមជំនុំដ៏ល្អមួយក្នុងតំបន់របស់ពួកគេដែរ។ ក៏ប៉ុន្តែ ប្រសិនបើជាក្រុមជំនុំដើមផ្ទាល់ខ្លួនរបស់ពួកគេ នោះប្រាកដណាស់ពួកគេអាចថ្វាយតង្វាយមួយភាគដប់មកកាន់យើងបាន។ ទោះជាយ៉ាងណាក៏ដោយក្នុងនាមជាគ្រូគង្វាលម្នាក់ ខ្ញុំដឹងថាមនុស្សនឹងមានរីកចម្រើនកាន់តែរហ័ស និងកាន់តែរឹងមាំនៅពេលដែលពួកគេមានចំណែកនៅក្នុងក្រុមជំនុំក្នុងតំបន់ដ៏ល្អមួយ។ ម្យ៉ាងវិញទៀត ការក្លាយជាផ្នែកមួយនៃក្រុមជំនុំមួយដែលបង្រៀនពីការសង្ស័យ និងភាពគ្មានជំនឿ គឺមិនមែនជាក្រុមជំនុំដែលអ្នកចង់គាំទ្រ ឬចង់មានវត្តមាននៅទីនោះទេ។

ដូច្នេះ បន្ថែមពីលើការសាបព្រោះទៅក្នុងបេសកកម្មមួយ អ្នកចង់សាបព្រោះទៅកាន់ការយល់ស្របគ្នា សាបព្រោះទៅនរណាម្នាក់ ឬព័ន្ធកិច្ចណាមួយដែលយល់ពី

ជំនឿ និងអត្ថន័យរបស់ការយល់ស្របគ្នា។ សូមប្រុងប្រយ័ត្នចំពោះក្រុមមនុស្សដែលប្រាប់អ្នកថា «ពួកយើងនឹងធ្លាក់ចុះមិនខានប្រសិនបើអ្នកមិនសាបព្រោះ»។ នៅក្នុងការថ្លែងបែបនោះគឺគ្មានជំនឿទាល់តែសោះ។ ព្រះគម្ពីរចែងយ៉ាងច្បាស់ថា កុំសាបព្រោះក្នុងពេលដែលអ្នកស្ថិតក្រោមការបង្ខិតបង្ខំ។ ប្រសិនបើប្រជាជនរបស់ព្រះជាម្ចាស់មិនថាជាបុរស ឬស្ត្រីធ្វើឱ្យមានអារម្មណ៍ថាមានទោស ប្រសិនបើអ្នកមិនសាបព្រោះ ឬក៏ពួកគេដាក់សម្ពាធលើអ្នកឱ្យសាបព្រោះ រឿងដ៏ប្រសើរដែលអ្នកគួរតែធ្វើនោះ គឺទុកលុយរបស់អ្នកវិញចុះ។ ជំនឿមិនចាំបាច់ត្រូវមានការបង្ខំឱ្យដើរទៅមុខទេ។

ប្រសិនបើអ្នកចង់សាបព្រោះ ក៏ប៉ុន្តែគ្មានការដឹកនាំឱ្យថ្វាយទៅទីកន្លែងជាក់លាក់ណាមួយ ដូច្នេះសូមសាបព្រោះទៅក្នុងបេសកកម្មដែលអ្នកមានអារម្មណ៍ថាជាបេសកកម្មដែលបានបង្ហាញលទ្ធផល និងបង្រៀនពីជំនឿតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះ។ សូមកុំសាបព្រោះទៅក្នុងក្រុមជំនុំដែលប្រាប់ថាព្រះជាម្ចាស់សម្លាប់មនុស្ស ឬធ្វើឱ្យពួកគេមានជំងឺមហារីកដើម្បីបង្រៀនមេរៀនណាមួយទៅពួកគេ ឬអ្វីផ្សេងទៀតដែលស្តាប់ទៅគ្មានបានការ។ ប៉ុន្តែ សូមសាបព្រោះទៅក្នុងព័ន្ធកិច្ចដែលបង្រៀនព្រះបន្ទូលព្រះជាម្ចាស់។

ឥលូវនេះ សូមចាំថាត្រូវប្រកាស និងអធិស្ឋានឱ្យការសាបព្រោះរបស់អ្នកពេលអ្នកថ្វាយ។ ឌ្រិនដា និងខ្ញុំបានធ្វើដូច្នេះចាប់តាំងពីព្រះអម្ចាស់បានណែនាំខ្ញុំពីរបៀបទទួលបានក្កាន់របស់ខ្ញុំនៅក្នុងឆ្នាំដំបូង។ ជាការពិតណាស់ មានឆ្នាំមួយដែលខ្ញុំបានប្រាប់អ្នកនៅក្នុងជំពូកនេះ ពេលដែលខ្ញុំមិនបានប្រកាសពីគ្រាប់ពូជរបស់ខ្ញុំ ហើយអ្នកក៏ដឹងហើយថាគ្រាប់ពូជរបស់ខ្ញុំប្រែទៅជាបែបណា។ យើងបានអធិស្ឋានឱ្យគ្រាប់ពូជរបស់យើងជាទៀងទាត់អស់រយៈពេលជាច្រើនឆ្នាំ ដោយមិនបានគិតឱ្យច្បាស់អំពីវា ឬមិនទាំងបានដឹងថាវាជាផ្នែកមួយដ៏ចាំបាច់បំផុតនៃការសាបព្រោះផង។ ខ្ញុំបានសន្មតថាគ្រាន់តែថ្វាយតែអ្វីត្រូវថ្វាយគឺគ្រប់គ្រាន់តាមលក្ខខណ្ឌ ដើម្បីនាំយកការថ្វាយរបស់ខ្ញុំទៅក្រោមការគ្រប់គ្រងរបស់ព្រះរាជ្យហើយ ហើយតាមការពិតទៅគឺមិនដូច្នោះ

ទេ។ ក៏ប៉ុន្តែគ្មានសេចក្តីបង្គាប់ច្បាស់លាស់មួយ នាំឱ្យគ្មានការផ្តោតសំខាន់ និងគ្មានការច្រូតផលពិតប្រាកដ ហើយប្រសិនបើមិនដឹងពីការច្រូតផលពិតប្រាកដទេ នោះអ្នកនឹងខកខានមិនបានចូលរួមរដូវកាលច្រូតផលផងដែរ។

ខ្ញុំបានរៀនមេរៀនជាច្រើតាមរយៈការប្រមាញ់សត្វក្តាន់ ហើយក្នុងពេលដែលយើងបញ្ចប់ជំពូកនេះទាក់ទងនឹងរបៀបស្រាយជំនឿរបស់អ្នក ខ្ញុំចង់និយាយរឿងមួយបន្ថែមទៀត។

ប្រមាណជាពីរបីឆ្នាំបន្ទាប់ពីខ្ញុំបានរៀនពីរបៀបប្រមាញ់ដោយជំនឿ ជាពេលដែលមានហេតុផលមួយចំនួនបានធ្វើឱ្យខ្ញុំសម្រេចចិត្តថា ខ្ញុំនឹងមិនសាបព្រោះគ្រាប់ពូជទេនៅក្នុងឆ្នាំនោះ។ ខ្ញុំមិនបាននិយាយពីរឿងនោះប្រាប់ភរិយាខ្ញុំទេ ខ្ញុំគ្រាន់តែមិននិយាយអំពីការសាបព្រោះ ឬការអធិស្ឋានអំពីសត្វក្តាន់ក្នុងពេលដែលរដូវកាលអនុញ្ញាតឱ្យប្រើកាំភ្លើង កំពុងតែខិតជិតចូលមកដល់។ ខ្ញុំបានច្រូតផលជាសត្វក្តាន់របស់ខ្ញុំ ជាមួយនឹងរឿងរ៉ាវដ៏អស្ចារ្យជាច្រើនក្នុងអំឡុងពេលពីរឆ្នាំមុន ដោយរួមជាមួយនឹងអ្វីដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំ ប៉ុន្តែខ្ញុំគិតថាអ្វីៗទាំងអស់នោះគឺជារឿងថ្មីសម្រាប់ខ្ញុំ ហើយខ្ញុំគ្រាន់តែមានអារម្មណ៍ថា ខ្ញុំមានជំនឿថាបានក្តាន់ផ្ទាល់ខ្លួនរបស់ខ្ញុំនៅពេលនោះ ហើយមានអារម្មណ៍ថាខ្ញុំមិនត្រូវការឆ្លងកាត់ការដាក់សំណើរនៃការស្រាយជំនឿរបស់ខ្ញុំទេ។ ទោះជាយ៉ាងក្តី អ្នកអាចទាយដឹងហើយថាមានអ្វីកើតឡើង។

នៅព្រឹកដែលរដូវកាលប្រមាញ់បើក ខ្ញុំគិតថាខ្ញុំបានឃើញក្តាន់ឈ្មោលមួយកំពុងរត់នៅប្រមាណជាជិត៣០០ម៉ែត្រពីខ្ញុំ ហើយខ្ញុំគ្រាន់តែបានឃើញវាតែប៉ុណ្ណោះ។ រហូតមកដល់ពេលល្ងាចការប្រមាញ់របស់ខ្ញុំក៏មិនបានសម្រេចជាផ្លែផ្កាដែរ។ ពេលខ្ញុំត្រលប់មកផ្ទះវិញទាំងដៃទទេនៅល្ងាចនៃថ្ងៃបើកការប្រមាញ់នោះ មិត្តភក្តិម្នាក់របស់គ្រិនដាបានមកលេងផ្ទះយើង ចំពេលដែលខ្ញុំបានប្រាប់គាត់ថាការប្រមាញ់ដូចជាដំណើរការមិនល្អសោះ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនបានធ្វើតាមសេចក្តីណែនាំដែលព្រះជា

ម្ចាស់ប្រទានមកខ្ញុំទាក់ទងនឹងការប្រមាញ់សត្វក្តាន់របស់ខ្ញុំទេ។ គ្រិនដាបាននិយាយថា «អូនក៏ឆ្ងល់ពីរឿងនោះដែរ ពេលដែលបងចេញទៅក្រៅ»។ ពេលនោះហើយខ្ញុំទទួលស្គាល់កំហុសរបស់ខ្ញុំ និងសុំឱ្យពួកគាត់អធិស្ឋានពីរឿងនោះជាមួយខ្ញុំ។ ខ្ញុំបានសរសេរមូលប្បទានបត្រមួយសន្លឹកទុកជាគ្រាប់ពូជរបស់ខ្ញុំសម្រាប់សត្វក្តាន់ ទាំងមិនបានកត់ចំណាំថាជាក្តាន់ញីឬឈ្មោលអ្វីទេ។ យើងទាំងអស់គ្នាបានដាក់ដៃលើមូលប្បទានបត្រនោះ បានអធិស្ឋាន និងបានទទួលក្តាន់នោះដោយជំនឿ។

នៅថ្ងៃបន្ទាប់ ខ្ញុំមិនអាចចេញក្រៅនៅពេលព្រឹកបានទេ ដូច្នេះហើយខ្ញុំនឹងចេញក្រៅនៅពេលល្ងាច។ ខ្ញុំបានសម្លឹងមើលទៅដើមមេផល (Maple) មួយដើមធំនៅលើព្រំប្រទល់ដីរបស់ខ្ញុំ ដែលខ្ញុំគិតថាជាកន្លែងដែលនឹងក្លាយជារានប្រមាញ់ដ៏ល្អមួយ ហើយខ្ញុំក៏ដើរតម្រង់ទៅទីនោះ។ សម្រាប់ខែធ្នូនៅល្ងាចនោះ អាកាសធាតុដូចជារាងក្តៅបន្តិច ហើយបើតាមខ្ញុំចាំសីតុណ្ហភាពដូចជាជិតដល់២១អង្សារទៅហើយ ហើយក៏មានខ្យល់ធ្លាក់ផងដែរ។ ត្រឹមតែប្រមាណជាពីរបីនាទីបន្ទាប់ពីចាប់ផ្តើមការប្រមាញ់នៅពេលល្ងាច មានក្តាន់ញីមួយដ៏ធំចេញពីព្រៃមក ហើយដើរចេញទៅទីវាលដែលអាចមើលទៅឃើញពីលើដើមមេផល។ ក្តាន់ញីនោះកំពុងឈរនៅពីចំហៀងខ្ញុំ ដែលធ្វើឱ្យខ្ញុំអាចបាញ់វាចំត្រង់ឥតទាស់។ ពេលខ្ញុំពិនិត្យសភាពការ ខ្ញុំក៏ដឹងថាក្តាន់ញីនៅនោះចម្ងាយប្រមាណជា ៧០ម៉ែត្រពីខ្ញុំ ហើយខ្ញុំមិនសូវប្រាកដប៉ុន្មានទេអំពីរយៈចម្ងាយនោះ ដោយសារតែខ្ញុំប្រើកាំភ្លើងវែងប្រភេទ Bore 12-guage។ ក៏ប៉ុន្តែខ្ញុំបានតម្រង់ទៅរកគោលដៅយ៉ាងប្រុងប្រយ័ត្ន ហើយក្តាន់ញីនោះក៏ដួលនៅពេលដែលខ្ញុំបាញត្រូវ។ ខ្ញុំពិតជាមានចិត្តរំភើបយ៉ាងខ្លាំងដែលបាញ់បានក្តាន់មួយនោះ។ ខ្ញុំត្រលប់ទៅដល់ផ្ទះវិញមុនពេលមេឃងងឹត ហើយមិត្តរបស់គ្រិនដាបានត្រលប់មកលេងផ្ទះយើងម្តងទៀត ហើយទាំងអស់គ្នាមានអំណរសប្បាយនៅក្នុងច្បាប់របស់ព្រះរាជ្យ ខណៈពេលដែលខ្ញុំមានអារម្មណ៍ថាខ្ញុំបានទទួលមេរៀនមួយនៅក្នុងពេលនោះដែរ។

នៅក្នុងជំពូកនេះ យើងបានរំឭកពីគោលការណ៍ទីពីរនៃការទទួលពីព្រះរាជ្យ៖

## ជំហានទី ២៖ ការស្រោយគ្រាប់ពូជរបស់អ្នកទៅក្នុងព្រះរាជ្យព្រះជាម្ចាស់

យើងបានដឹងថា ពេលយើងសាបព្រោះគ្រាប់ពូជរបស់យើងទៅក្នុងបេសកកម្មរបស់ព្រះរាជ្យ គ្រាប់ពូជនោះនឹងផ្លាស់ប្តូរព្រះរាជ្យ។ យើងក៏បានរំឭកផងដែរពីរបៀបដែលយើងស្រោយគ្រាប់ពូជរបស់យើង ដោយពាក្យសម្តី និងដោយការដាក់សេចក្តីបង្គាប់។ ខាងក្រោមនេះគឺជាចំណុចមួយចំនួនផ្សេងទៀតដែលចង់ចងចាំពេលបន្តដំណើរទៅមុខទៀត។

១. យើងអាចដាក់ឈ្មោះឱ្យលុយបាន។
២. យើងអាចសាបព្រោះសម្រាប់គ្រាប់ពូជដ៏ជាក់លាក់មួយ។
៣. យើងមិនអាចដាក់ឈ្មោះឱ្យតង្វាយមួយភាគដប់បានទេ។
៤. ការថ្វាយមិនមែនជារូបមន្តទេ តែរូបមន្តគឺការថ្វាយដោយជំនឿ។
៥. ការថ្វាយជាក់លាក់ នាំមកនូវការច្រូតផលជាក់លាក់មួយ។

**យើងស្រោយគ្រាប់ពូជរបស់យើងដោយពាក្យសម្តីយើង។**

# ជំពូក ៦
# ជំនឿគឺជាកូនសោ

រយៈពេលពីរបីឆ្នាំក្រោយពីយើងបានចាប់ផ្ដើមក្រុមជំនុំមក ខ្ញុំបានបើកឡានត្រលប់មកផ្ទះ ហើយខ្ញុំបានឃើញភ្លើងចំណាំងផ្លាតរបស់ប៉ូលិសនៅពេលដែលខ្ញុំបើកជិតដល់ផ្លូវចូលមកកសិដ្ឋានចាស់របស់ខ្ញុំ។ គ្មានអ្វីថ្មីទេ ខ្ញុំបានសន្និដ្ឋានថា ប្រាកដជាប៉ូលិសបញ្ឈប់អ្នកបើកបរលើសល្បឿនកំណត់មិនខាន។ ដោយខ្ញុំប្រាកដក្នុងចិត្ត នោះខ្ញុំក៏បានបន្ថយល្បឿន ដោយបានឃើញរថយន្តមួយគ្រឿងនៅខាងមុខរថយន្តប៉ូលិសកំពុងចេញដំណើរទៅយឺតៗ បរចេញតាមផ្លូវបាត់ទៅ។ នៅពេលដែលខ្ញុំបានបើកមកដល់ទន្ទឹមរថយន្តប៉ូលិស និងបន្ថយល្បឿនហៀបនឹងបង្ហួសទៅ ខ្ញុំក៏ចាប់អារម្មណ៍នឹងរឿងម្យ៉ាង។ នៅចិញ្ចើមផ្លូវឯណោះ ខ្ញុំបានឃើញសត្វក្ដាន់ឈ្មោលដ៏ស្រស់ស្អាតមួយក្បាលដែលមានស្នែងបែកប្រាំបីខ្នែង។ ខ្ញុំដឹងច្បាស់ណាស់ថាមានរឿងអ្វីកើតឡើង។ ក្ដាន់ឈ្មោលនោះត្រូវរថយន្តដែលខ្ញុំទើបតែឃើញបើកចេញនោះបុក។

ខ្ញុំក៏បញ្ឈប់រថយន្តហួសសត្វក្ដាន់នោះបន្តិច រួចក៏បានដើរត្រលប់ទៅកាន់កន្លែងរថយន្តប៉ូលិសនោះ រួចក៏បានសួរមន្ត្រីប៉ូលិសថាតើគាត់នឹងធ្វើអ្វីជាមួយនឹងសត្វក្ដាន់ឈ្មោលនោះ។ ដោយសារតែខ្ញុំត្រូវបើកបរតែប្រមាណជិត៣៦០ម៉ែត្រប៉ុណ្ណោះ ហើយខ្ញុំត្រូវចិញ្ចឹមកូនទៀតនោះ ខ្ញុំក៏បានគិតថា ខ្ញុំនឹងសុំយកសត្វក្ដាន់ឈ្មោលនោះទៅផ្ទះ។ លោកមន្ត្រីប៉ូលិសហាក់ធូរចិត្តជាងមុនពេលបានឮថាមានគេចង់បានសត្វក្ដាន់ឈ្មោលនោះ។ គាត់ក៏បានកត់ត្រាឈ្មោះ និងអាសយដ្ឋានរបស់ខ្ញុំ រួចក៏បានភ្ជាប់ស្លាកសម្រាប់សត្វក្ដាន់ឈ្មោលនោះទុកឱ្យខ្ញុំ។

យើងហៀបនឹងលាគ្នាចេញទៅហើយ ស្រាប់តែគាត់បានប្រាប់ខ្ញុំថា ពួកគាត់តែងតែមានសត្វក្ដាន់ដែលត្រូវបានគេបុកបែបនេះ ហើយថា បើខ្ញុំចាប់អារម្មណ៍ នោះគាត់នឹងកត់ឈ្មោះខ្ញុំទុកក្នុងបញ្ជីក្រែងលោពួកគាត់មានសត្វដែលងាប់ដោយត្រូវគេបុកលើដងផ្លូវ ហើយគ្មាននរណាចង់បាន។ ខ្ញុំក៏គិតថា បែបនេះក៏ល្អម្យ៉ាងដែរ។ ពេលនោះទើបតែចូលដល់ដើមរដូវស្លឹកឈើជ្រុះ ហើយខ្ញុំមិនទាន់បានចេញទៅក្រៅដើម្បីបរបាញ់សត្វនៅឡើយ។ វាកើតឡើងមុនពេលដែលខ្ញុំចាប់ផ្ដើមបរបាញ់សត្វដោយការបាញ់ព្រួញ ហើយរដូវកាលបរបាញ់ដោយកាំភ្លើងមិនទាន់ចូលមកដល់ទេ គឺទាល់តែដល់សប្ដាហ៍ដំបូងនៃខែធ្នូឯណោះ ដូច្នេះ ខ្ញុំបានគិតថា បើបានសាច់ក្ដាន់ប្រាកដជាល្អហើយ។ និយាយទៅ មិនយូរប៉ុន្មានផង ផ្នែកនាយកដ្ឋានប៉ូលិសក៏បានទូរសព្ទមកខ្ញុំឱ្យយកក្ដាន់មួយទៀត។ ដូចនេះ មុនពេលរដូវបរបាញ់ដោយប្រើកាំភ្លើងបានចាប់ផ្ដើមនោះខ្ញុំបានត្លុះសាច់ក្ដាន់អស់បួនប្រាំក្បាលទៅហើយ។ ខ្ញុំចាំចំនួនពិតប្រាកដមិនច្បាស់លាស់ទេ តែខ្ញុំដឹងថា យ៉ាងហោចណាស់ក៏បួនក្បាលដែរ។ និយាយរួម ពេលរដូវបរបាញ់សត្វដោយកាំភ្លើងចូលមកដល់ នោះទូទឹកកករបស់ខ្ញុំពេញទៅហើយ។

អ្វីដែលគួរឱ្យចម្លែកនោះ ឌ្រិនដាបានចេញក្រៅក្រុងមួយសប្ដាហ៍សម្រាប់រដូវកាលបរបាញ់សត្វដោយកាំភ្លើង។ ខ្ញុំមិនបានចាំថាហេតុអ្វីបានជាគាត់ចេញទៅបាត់នោះទេ តែខ្ញុំដឹងថា វាជាការចម្លែកចំពោះយើងក្នុងការនៅឃ្លាតពីគ្នាអស់រយៈពេលមួយសប្ដាហ៍សម្រាប់ការបរបាញ់នោះ។ ដូចនេះ ខ្ញុំមិនបានអធិស្ឋានជាមួយគាត់សម្រាប់ការបរបាញ់សត្វក្ដាន់នោះទេ ហើយខ្ញុំថែមទាំងមិនបានសាបព្រោះគ្រាប់ពូជទៀតផង។ ប្រហែលមកពីខ្ញុំគិតថា ខ្ញុំមិនខ្វល់ថាខ្លួនរកសត្វក្ដាន់បានឬអត់នោះទេ ដ្បិតទូរទឹកកករបស់ខ្ញុំពេញទៅហើយ។ ប៉ុន្តែខ្ញុំបានចេញក្រៅ អ្នកប្រាកដជាដឹងច្បាស់ហើយ។ និយាយឱ្យខ្លី ក្នុងអំឡុងរដូវបរបាញ់ដោយកាំភ្លើងនោះ ខ្ញុំបានចេញក្រៅពេញមួយសប្ដាហ៍ ហើយមិនបានបាញ់សត្វអស់មួយគ្រាប់ទេ។ ពេលឌ្រិនដាមកដល់ផ្ទះវិញ

គាត់បានរំឮកខ្ញុំអំពីអ្វីដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំ ទាក់ទងនឹងការសាបព្រោះគ្រាប់ពូជ និងការអធិស្ឋានរួមគ្នាដើម្បីទទួលបានក្ដាន់។

និយាយទៅ ឆ្នាំបន្ទាប់មកទៀតក៏ចូលមកដល់ ហើយលើកនេះ ខ្ញុំមិនបានធ្វើឱ្យមានកំហុសដដែលៗទេ។ ទោះបីជាផ្នែកនាយកដ្ឋានប៉ូលិសបានហៅយើងឱ្យយកក្ដាន់ដែលស្លាប់នៅតាមផ្លូវប៉ុន្មានលើកក៏ដោយ ខ្ញុំគិតថា ខ្ញុំទទួលយកតែមួយក្បាលប៉ុណ្ណោះ ដោយខ្ញុំមានគម្រោងចង់បានសាច់ក្ដាន់ចេញពីការបរបាញ់ដោយខ្លួនឯងច្រើនជាង។ ម្ដងនេះ ឌ្រិនដា និងខ្ញុំ បានសាបព្រោះគ្រាប់ពូជរបស់យើង រួចក៏អធិស្ឋាននៅពេលដែលយើងបញ្ចេញគ្រាប់ពូជដើម្បីចាប់ក្ដាន់។ យើងមិនបានកំណត់ឱ្យជាក់លាក់អំពីទំហំនៃសត្វក្ដាន់ទេ គ្រាន់តែថាជាសត្វក្ដាន់។ ខ្ញុំមិនអាចចេញទៅនាពេលព្រឹកទេ តែខ្ញុំរំភើបចិត្តដែលបានចេញទៅនៅពេលល្ងាច។ តែគួរឱ្យសោកស្ដាយ ខ្ញុំមានតែប្រាប់អ្នកថា មិនបានសត្វក្ដាន់ទៀតហើយ។ ពេលខ្ញុំត្រលប់ទៅផ្ទះវិញនាល្ងាចនោះក្រោយអង្គុយនៅនឹងគល់ឈើ ខ្ញុំហាក់ច្របូកច្របល់ក្នុងចិត្ត។

ពេលខ្ញុំអង្គុយហូបអាហារពេលល្ងាច ស្រាប់តែទូរសព្ទក៏បានរោទិ៍ឡើង។ ផ្នែកនាយដ្ឋានប៉ូលិសបានប្រាប់ថាពួកគាត់មានសត្វស្លាប់មួយក្បាលនៅតាមដងផ្លូវ ក្រែងខ្ញុំចង់បាន។ ខ្ញុំក៏បានសួរពីកន្លែងសត្វស្លាប់នោះ ហើយពួកគាត់ក៏ប្រាប់ពីអាសយដ្ឋាននោះ។ ខ្ញុំស្ទើរតែមិនជឿសោះឡើយ។ «សូមលោកបញ្ជាក់អាសយដ្ឋានម្ដងទៀតទៅមើល៍?» ខ្ញុំបានសួរបញ្ជាក់។ គាត់បានបញ្ជាក់ពីអាសយដ្ឋាននោះម្ដងទៀត ហើយខ្ញុំបានដឹងថា នោះជាអាសយដ្ឋានរបស់ខ្ញុំសោះ! ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់។ ដូចនេះ ខ្ញុំបានអើតមើលតាមបង្អួច ហើយក៏ឃើញច្បាស់ថា មានភ្លើងចំណាំងក្រហមនៅចុងផ្លូវក្បែរផ្ទះខ្ញុំ ដូចនេះ ខ្ញុំក៏បានប្រាប់ពួកគាត់ថាខ្ញុំទៅដល់ឥលូវហើយ។ ផ្លូវចូលផ្ទះយើងមានចម្ងាយហួសពីផ្លូវធំតែ២៧០ម៉ែត្រប៉ុណ្ណោះ ហើយខ្ញុំចាំថា ខ្ញុំបានដើរក្នុងរយៈចម្ងាយប៉ុនហ្នឹងដោយស្ទើរតែមិនគួរឱ្យជឿ។ ពេលខ្ញុំទៅដល់កន្លែងសត្វក្ដាន់នោះ វាជាសត្វក្ដាន់ដ៏ធំមួយក្បាល ដែលស្ថិតក្នុងសភាពល្អឥតខ្ចោះ។ ខ្ញុំក៏បានបំពេញទម្រង់លិខិតរួច

ក៏អរគុណលោកមន្ត្រីប៉ូលិស ហើយក៏បានអូសក្ដាន់នោះដាក់ក្នុងជង្រុក។ ច្របូលច្របល់មែនទេ? ច្របូលច្របល់ក្នុងចិត្តណាស់! ខ្ញុំមិនបានគិតពីរឿងប្រមាញ់សត្វក្ដាន់ទៀតទេ រហូតដល់ខែកញ្ញា ឬខែតុលាឆ្នាំក្រោយឯណោះ។

## តើអ្វីជាប្រភពរបស់អ្នក?

ពេលនេះខ្ញុំមិនចាំថាពេលនោះស្ថិតក្នុងខែណានោះទេ ប៉ុន្តែពេលនោះខ្ញុំបានរត់ហាត់ប្រាណនៅជុំវិញសួនក្រោយផ្ទះរបស់ខ្ញុំ ដោយខ្ញុំបានហាត់ប្រាណបែបនេះម្ដងម្កាលដែរ។ នៅពេលខ្ញុំកំពុងរត់ហាត់ប្រាណ ខ្ញុំបានកំពុងអធិស្ឋានអំពីអ្វីដែលបានកើតឡើងក្នុងរយៈពេលពីរឆ្នាំចុងក្រោយ។ ខ្ញុំមិនបាននឹកចាំអ្វីទេ។ ស្រាប់តែរំពេចនោះ ក្នុងពេលកំពុងរត់ ខ្ញុំក៏នឹកឃើញពាក្យ «បញ្ជីប៉ូលិស» យ៉ាងច្បាស់។ ខ្ញុំបានគិតមួយសន្ទុះ។ តើព្រះជាម្ចាស់កំពុងព្យាយាមប្រាប់ខ្ញុំពីអ្វីមួយមែនទេ? បន្ទាប់មកខ្ញុំក៏បាននឹកឃើញ។ ខ្ញុំបានដឹងថា ទំនុកចិត្តរបស់ខ្ញុំមិនបានស្ថិតនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬព្រះរាជ្យរបស់ព្រះអង្គនោះទេ។ ទំនុកចិត្តរបស់ខ្ញុំស្ថិតនៅលើបញ្ជីរបស់ប៉ូលិសឯណោះវិញ! ខ្ញុំបានដឹងថា ប្រសិនបើខ្ញុំមិនបានសត្វក្ដាន់ផ្ទាល់ខ្លួនទេ នោះខាងនាយកដ្ឋានប៉ូលិសប្រាកដជាផ្ដល់សត្វឱ្យខ្ញុំទៀតហើយ។

បន្ទាប់មក ខ្ញុំក៏បានយល់ថាហេតុអ្វីបានជាឆ្នាំមុននោះខ្ញុំទទួលបានសត្វក្ដាន់នៅចុងផ្លូវ ជំនួសចុងកាំភ្លើងរបស់ខ្ញុំទៅវិញ។ ជំនឿរបស់ខ្ញុំស្ថិតនៅលើបញ្ជីប៉ូលិសឯណោះ។ នៅពេលដែលគ្រិនដា និងខ្ញុំបានសាបព្រោះសម្រាប់សត្វក្ដាន់ក្នុងឆ្នាំនោះ នោះសត្វក្ដាន់ក៏បានលេចឡើងទាន់ពេលវេលាជាលើកដំបូងសម្រាប់ឆ្នាំនោះ ប៉ុន្តែស្ថិតនៅកន្លែងត្រឹមត្រូវ ឬមិនត្រឹមត្រូវ? ខ្ញុំបានឈរនៅទីនោះទាំងអារម្មណ៍ស្ញប់ស្ញែង នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញដល់ខ្ញុំយ៉ាងច្បាស់ៗ។ ក្រោយមក ខ្ញុំក៏បានយល់ថា ក្ដាន់នោះបានបង្ហាញខ្លួននៅត្រង់កន្លែងដែលជំនឿរបស់ខ្ញុំស្ថិតនៅ ពោលគឺបញ្ជីប៉ូលិស។ នៅពេលដែលខ្ញុំបានភ្ញាក់ខ្លួនដឹងពីការនេះ ខ្ញុំក៏បានរត់ត្រង់សំដៅទៅផ្ទះ រួចក៏បានទូរសព្ទទៅនាយកដ្ឋានប៉ូលិស រួចក៏បានដកឈ្មោះរបស់ខ្ញុំចេញពីបញ្ជីនោះ។ ខ្ញុំ

បានរៀនសូត្រថា ផែនការបម្រុងរបស់អ្នកគឺជាផែនការពិតប្រាកដ! ចាប់តាំងពីឆ្នាំនោះមក ខ្ញុំមិនដែលបរាជ័យពេលបានឃើញសត្វក្តាន់បង្ហាញខ្លួនម្តងណាទេ។

ប៉ុន្តែចិត្តរបស់យើងមានភាពបោកបញ្ឆោតណាស់។ ទំនុកចិត្តរបស់យើងងាយនឹងវេទៅកាន់រឿងរ៉ាវដែលស្តាប់ទៅសមដំណើរ។ នេះជាអ្វីដែលយើងត្រូវតែដឹងច្បាស់ និងឃ្លាំមើលជានិច្ច។ ជំនឿមិនត្រូវការផែនការបម្រុងទេ។ ខ្ញុំនៅតែស្ញប់ស្ញែងដែលទោះបីជំនឿរបស់ខ្ញុំពិតជានៅក្នុងបញ្ជីប៉ូលីសក្តី ក៏សត្វក្តាន់បង្ហាញខ្លួននៅចុងផ្លូវនាថ្ងៃនោះ ហើយនេះបាននាំមកនូវគោលការណ៍ទីបីដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំ។

## ជំហានទី ៣៖ ចូរបញ្ចេញគ្រាប់ពូជរបស់អ្នកនៅពេលអ្នកស្ថិតក្នុងជំនឿ!

នេះជារឿងធំដុំមួយ ដូចយើងបានឃើញមុននេះនៅពេលដែលពួកសិស្សមិនអាចបណ្តេញអារក្សចេញពីក្មេងប្រុសដែលអារក្សសណ្ឋិត។ ព្រះយេស៊ូមានបន្ទូលថា នោះគឺដោយសារតែពួកគេមិនជឿ ឬខ្វះជំនឿ។ មុននេះយើងបានសិក្សាស្វែងយល់ថាអ្វីជាជំនឿ និងរបៀបដើម្បីទទួលបានជំនឿ ប៉ុន្តែវាជាការសំខាន់ណាស់ដែលអ្នករៀនវិនិច្ឆ័យខ្លួនឯងថាតើអ្នកមានជំនឿ ឬអត់។ ដូចនេះ ខ្ញុំសូមដាក់តេស្តសាកល្បងងាយៗមួយដល់អ្នក ដើម្បីឱ្យអ្នកអាចពិនិត្យមើលខ្លួនឯងថាអ្នកពិតជាមានជំនឿឬក៏អត់។ ចូរបិទភ្នែក ហើយមើលថាតើអ្នកបានឃើញអ្វីខ្លះ?

> *រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថា នឹងបានដូចសង្ឃឹម ជាសម្គាល់ពីការដែលមើលមិនឃើញ។*
>
> — ហេព្រើ ១១:១ (ពគប)

ជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថា នឹងបានដូចសង្ឃឹម។ ក្តីសង្ឃឹមពាំនាំនូវរូបភាពមកជាមួយ។ ប្រសិនបើខ្ញុំសន្យានឹងអ្នកថាឱ្យការ៉េមដើម នោះអ្នកនឹងនឹកឃើញដល់រូបភាពការ៉េមដើមក្នុងគំនិតភ្លាមៗ។ ប្រសិនបើអ្នកជឿថាខ្ញុំស្មោះត្រង់ដោយធ្វើតាម

ការផ្ដល់ជូន ហើយខ្ញុំមានមធ្យោបាយបង់ថ្លៃការ៉េមឱ្យ នោះអ្នកនឹងស្រមៃឃើញខ្លួនឯងកំពុងមានការ៉េមដើម រួមជាមួយភស្តុតាងនៃភាពជាក់ស្តែង និងអារម្មណ៍រំភើប។

ការនេះគឺដូចគ្នានឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ នៅពេលអ្នកជឿលើការសន្យារបស់ព្រះជាម្ចាស់ ហើយបានជឿទាំងស្រុង ព្រះជាម្ចាស់មានចេតនា និងមធ្យោបាយដើម្បីបំពេញតាមសេចក្ដីសន្យារបស់ទ្រង់ នោះអ្នកបានឃើញនូវរូបភាពខ្លួនឯងកំពុងនៅជាមួយសេចក្ដីសន្យានោះ។ ទោះបីជាពេលឥលូវនេះអ្នកអាចមិនមានវត្ថុដែលបានសន្យានោះក្ដី ក៏អ្នកនឹងប្រព្រឹត្តដូចអ្នកមានដែរ ពីព្រោះអ្នកកំពុងមានញ្ញាណថាអ្នកមានរបស់នោះនៅនឹងដៃ។ សេចក្ដីសន្យានៅមានសុពលភាព ចេតនានោះក៏នៅមានសុពលភាព ហើយរបស់នោះជារបស់អ្នក។ ដូច្នេះ ដោយបានជឿទាំងស្រុងអំពីចេតនា និងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ជំនឿគឺជាលក្ខណៈនៃសេចក្ដីសន្យាចំពោះអ្នក។ វាក៏ជាភស្តុតាងនៃអ្វីដែលដែលមិនទាន់បានឃើញផ្ទាល់នឹងភ្នែកដែរ។

**នៅពេលអ្នកជឿលើការសន្យារបស់ព្រះជាម្ចាស់ ហើយបានជឿទាំងស្រុងថាព្រះជាម្ចាស់មានចេតនា និងមធ្យោបាយដើម្បីបំពេញតាមសេចក្ដីសន្យារបស់ទ្រង់ នោះអ្នកបានឃើញនូវរូបភាពខ្លួនឯងកំពុងនៅជាមួយសេចក្ដីសន្យានោះ។**

អ្នកនៅតែត្រូវដាក់ទឹកប្រាក់ទៅក្រដាសសែក ដែលជាដំណើរការផ្លូវច្បាប់ដែលអនុវត្តចំពោះពិភពខាងវិញ្ញាណ ដូចការដែលវាបានធ្វើនៅក្នុងពិភពធម្មជាតិដែរ។ ដូចនេះ នៅពេលខ្ញុំនិយាយថា «ចូរបិទភ្នែក ហើយមើលថាតើអ្នកបានឃើញអ្វីខ្លះ?» នោះជាអ្វីដែលខ្ញុំកំពុងនិយាយក្នុងផ្នែកនេះ។ ប្រសិនបើអ្នកមើលមិនឃើញទេ នោះអ្នកមិនអាចក្រសោបយកវាបានទេ។ ខ្ញុំសូមនិយាយត្រង់ចំណុចនេះឱ្យងាយស្ដាប់បំផុត។ បើអ្នកបិទភ្នែក ហើយមិនបានមើលឃើញថាខ្លួនឯងកំពុងនៅជាមួយសេចក្ដីសន្យានោះទេ នោះអ្នកមិនស្ថិតក្នុងជំនឿទេ។ ប្រសិនបើអ្នកឈឺ ហើយពេលដែលអ្នកបិទភ្នែក

ទៅ អ្នកមើលឃើញខ្លួនឯងបានជា គឺខ្ញុំចង់មានន័យថា អ្នកមើលឃើញថាខ្លួនឯងបាន ជាដោយមិនមានសេចក្តីភ័យព្រួយ តែមានតែការធានាអះអាងយ៉ាងពេញទំហឹងថា អ្នកបានជាហើយ នោះហើយជាជំនឿ។ ប៉ុន្តែ ប្រសិនបើអ្នកបិទភ្នែក ហើយនៅតែមើលឃើញថាខ្លួនឯងកំពុងឈឺ កំពុងរង់ចាំឱ្យគេព្យាបាល នោះអ្នកមិនស្ថិតក្នុងជំនឿទេ។ ប្រសិនបើអ្នកត្រូវការលុយកាក់ ហើយអ្នកជឿលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ នោះអ្នកមិនមានការថប់បារម្ភរឿងលុយកាក់ទៀតទេ តែអ្នកមើលឃើញខ្លួនឯងថាកំពុងនៅជាមួយការផ្គត់ផ្គង់ដែលអ្នកត្រូវការ។

## ភាពភ័យខ្លាចមានលក្ខណៈផ្ទុយពីជំនឿ

ជំនឿមិនមានវត្តមាននៅក្នុងទំនុកចិត្តប្រភេទនេះទេ។ ប្រសិនបើអ្នកនៅតែខ្វល់ខ្វាយអំពីលទ្ធផល នោះអ្នកមិនមានជំនឿទេ។ ពាក់ព័ន្ធនឹងជំនឿ អ្នកត្រូវតែដឹងពីរបៀបប្រាប់ថាតើអ្នកស្ថិតក្នុងជំនឿឬក៏អត់។ អ្នកមិនចង់ធ្វើការសម្រេចចិត្តធំដុំថាតើអ្នកស្ថិតក្នុងជំនឿឬអត់នោះទេ ពីព្រោះថាប្រសិនបើអ្នកមិនស្ថិតក្នុងជំនឿទេ នោះអ្នកស្ថិតក្នុងភាពភ័យខ្លាចហើយ។ ភាពភ័យខ្លាចតែងតែមានការប្រុងប្រយ័ត្ន ហើយមិនជឿឡើយ។ ហេតុដូចនេះហើយទើបខ្ញុំបាននិយាយថា ត្រូវសាបព្រោះគ្រាប់ពូជរបស់អ្នកជានិច្ច នៅពេលអ្នកស្ថិតក្នុងជំនឿ។ អ្នកមិនចង់សាបព្រោះគ្រាប់ពូជនោះតាមរូបមន្តដោយគ្រាន់តែធ្វើតាមដំណើរនោះទេ ព្រោះថាការនោះនឹងមិនបង្កើតបានផលអ្វីនោះទេ។ អ្នកចង់មានទំនុកចិត្តអំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល ដើម្បីឱ្យអ្នកបានឃើញខ្លួនអ្នកផ្ទាល់ និងសេចក្តីសន្យានោះ នៅពេលដែលអ្នកបិទភ្នែក។ តាមពិតទៅ អ្នកមានវាស្រាប់ទៅហើយ អ្នកមានរបស់នោះហើយ វាជារបស់អ្នក ហើយសេចក្តីសុខសាន្តបានជំនួសនូវសេចក្តីខ្វល់ខ្វាយដែលអ្នកអាចមាន។

*សូមកុំខ្វល់ខ្វាយនឹងអ្វីឡើយ ផ្ទុយទៅវិញ ក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវទូលព្រះជាម្ចាស់ឱ្យជ្រាបពីសំណូមពររបស់បងប្អូន ដោយអធិស្ឋាន និងទូលអង្វរ ទាំងអរព្រះគុណព្រះអង្គផង។ ធ្វើដូច្នេះ សេចក្តីសុខសាន្តរបស់ព្រះជា*

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

*ម្ចាស់ដែលហួសពីការស្មានរបស់មនុស្ស នឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូន ដែលរួមក្នុងអង្គព្រះគ្រិស្តយេស៊ូមិនខាន។*

— ភីលីព ៤:៦-៧ (ពគប)

នៅពេលអ្នកស្ថិតក្នុងជំនឿ នោះក៏មានសេចក្តីសុខសាន្តមួយដែលមិនអាស្រ័យលើកាលៈទេសៈឡើយ តែវាអាស្រ័យលើព្រះបន្ទូលសន្យាវិញ។

ចំណុចបន្ទាប់នោះគឺ ភស្តុតាងនៃជំនឿរបស់អ្នកគឺជាសមត្ថភាពរបស់អ្នកដើម្បីការពារខ្លួនឯងនៅក្នុងទីជំនុំជម្រះផ្លូវច្បាប់ផ្នែកព្រលឹងវិញ្ញាណ។ ដោយសារតែជំនឿអាស្រ័យលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះអ្នកត្រូវតែដឹងពីមូលហេតុដែលអ្នកជឿ ដឹងពីអ្វីដែលអ្នកជឿ។ ឧបមាថា អ្នកកំពុងស្ថិតនៅក្នុងបន្ទប់សវនាការ ហើយអ្នកគឺជាមេធាវីការពារក្តី។ តំណាងអយ្យការបានថ្លែងថា កូនក្តីរបស់អ្នកកំពុងរស់នៅក្នុងផ្ទះរបស់កូនក្តីពួកគេដោយខុសច្បាប់ ហើយតំណាងអយ្យការក៏បានលើកឡើងថា ផ្ទះនោះក៏មិនមែនជាកម្មសិទ្ធិរបស់កូនក្តីអ្នកដែរ ប៉ុន្តែជារបស់កូនក្តីពួកគេ។ តើអ្នកនឹងធ្វើយ៉ាងណា? តើត្រូវពោលពាក្យសុំទោស ហើយប្រាប់ថា កូនក្តីរបស់អ្នកនឹងចាកចេញពីផ្ទះនោះភ្លាមៗឬ? ប្រសិនបើអ្នកមានលិខិតស្នាមចុះហត្ថលេខានៅក្នុងទ្រព្យកម្មសិទ្ធិរបស់អ្នក នោះភាពភ័យខ្លាចប្រាកដជាជំនួសដោយទំនុកចិត្ត ហើយអ្នកនឹងប្រាប់ចៅក្រមឱ្យបណ្តេញជនក្លែងបន្លំទាំងនោះចេញពីបន្ទប់សវនាការ។ នេះជារបៀបដែលជំនឿកើតឡើង។ ជំនឿស្គាល់នូវសេចក្តីពិត មានទំនុកចិត្ត ហើយលេចចេញមកស្ទើតែដូចភាពក្រអឺតក្រទម។ ដូចនេះ តើអ្នកអាចការពារជំហររបស់អ្នកបានទេ?

នៅថ្ងៃមួយ សារ៉ាបានមកក្រុមជំនុំរបស់យើង ដោយមិនបានដឹងថាខ្លួនឯងនៅឯណាឡើយ ដ្បិតគាត់គ្រាន់តែបើកបរចុះឡើងក្នុងក្រុងថ្មី។ គាត់ និងស្វាមីរបស់គាត់ត្រូវបានផ្ទេរទៅទីក្រុងកូឡុំប៊ីស ហើយពួកគាត់បានអធិស្ឋានរកក្រុមជំនុំ។ នៅពេលដែលពួកគាត់កំពុងបើកបរចុះឡើង ពួកគាត់ក៏បត់ចូលមកផ្លូវរបស់យើង ហើយបាន

គិតថា ពួកគាត់សាកល្បងសួរយើង។ ពួកគាត់មិនដែលចាកចេញពីផ្ទះទេ។ សារ៉ាមានជំងឺហឺតពេញមួយជីវិតទៅហើយ។ គាត់ធំធាត់ឡើងដោយចេញចូលមន្ទីពេទ្យរហូតហើយជំងឺនេះបានយាយីជីវិតរបស់គាត់ជាខ្លាំង។ គាត់បានរៀនពីរបៀបគេចចេញពីបរិស្ថានជាក់លាក់មួយចំនួនដែលបង្កឱ្យជំងឺហឺតរបស់គាត់កើនឡើងខ្លាំង ហើយគាត់តែងតែយកបំពង់ហឺតទៅគ្រប់ទីកន្លែងដែលគាត់ទៅ។

នៅឯក្រុមជំនុំ Faith Life Church គាត់បានរៀនសូត្រថា ការព្យាបាលគឺជាសិទ្ធិស្របច្បាប់របស់គាត់ និងបានរៀនពីរបៀបការពារខ្លួនឯងដោយផ្នែកវិញ្ញាណ។ នៅក្នុងកម្មវិធីមួយក្នុងពេលដែលគាត់កំពុងស្តាប់សមាជិករបស់យើងម្នាក់រៀបរាប់ពីរបៀបដែលពួកគេត្រូវបានប្រោសឱ្យជាពីជំងឺដែលយាយីជីវិត នោះគាត់ក៏បានធ្វើការសម្រេចចិត្ត។ ព្រះជាម្ចាស់ប្រព្រឹត្តចំពោះមនុស្សផ្សេងៗក្នុងរបៀបដូចគ្នា។ គាត់បានដកបំពង់ហឺតចេញពីកាបូបដៃ និងជំនួសដោយសន្លឹកកាតខគម្ពីរវិញ ដោយសន្លឹកកាតខគម្ពីរទាំងនោះសុទ្ធតែរៀបរាប់ពីសិទ្ធិស្របច្បាប់របស់គាត់ក្នុងការជាសះស្បើយ។ គាត់តែងតែអានខគម្ពីរទាំងនោះជារៀងរាល់ថ្ងៃ។ រាល់ពេលដែលគាត់មានអារម្មណ៍ថាជំងឺហឺតបានកំពុងវាយលុយគាត់ នោះគាត់តែងតែដកយកខគម្ពីរមួយមកអាន ជំនួសឱ្យបំពង់ហឺតនោះ ហើយគាត់មិនដែលរងការវាយលុយដោយជំងឺហឺតទៀតទេ!

មីងរបស់ខ្ញុំបានមកជួបខ្ញុំក្នុងកម្មវិធីជួបជុំគ្រួសារមួយ។ គាត់បានសុំឱ្យខ្ញុំអធិស្ឋានជូនគាត់ ដ្បិតគាត់មានជំងឺមហារីកសួត ហើយកំពុងតែរង់ចាំការវះកាត់សាច់ដុះក្នុងរយៈពេលមួយសប្តាហ៍កន្លះទៀត។ គាត់បាននិយាយបន្តដោយប្រាប់ខ្ញុំថា វេជ្ជបណ្ឌិតរបស់គាត់បានតាមដានមើលសាច់ដុះទំហំប៉ុនផ្លែទំពាំងបាយជូរដែលនៅក្នុងសួតរបស់គាត់នោះអស់រយៈពេលមួយឆ្នាំកន្លះទៅហើយ។ ទើបតែថ្មីៗនោះវាបានរីកធំជាងមុនយ៉ាងឆាប់រហ័ស ហើយលោកវេជ្ជបណ្ឌិតនោះបាននិយាយថា ត្រូវតែយកវះយកសាច់ដុះនោះចេញ។ ខ្ញុំបានឈរស្តាប់គាត់និយាយសាច់រឿងរបស់គាត់ ហើយខ្ញុំក៏បានឆ្លុះបញ្ចាំងពីជីវិតរបស់គាត់។ គាត់គឺជាអ្នកជក់បារីជាប់លាប់ពេញមួយជីវិតទៅ

ហើយ ហើយខ្ញុំបានដឹងថា គាត់មិនបានទៅក្រុមជំនុំអស់រយៈពេលជាច្រើនឆ្នាំ។ ខ្ញុំបានសន្យានឹងគាត់ថាខ្ញុំច្បាស់ជាអធិស្ឋានឱ្យគាត់ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា គាត់មិនទាន់បានត្រៀមខ្លួនរួចរាល់សម្រាប់ការអធិស្ឋានក្នុងពេលនោះទេ។ ខ្ញុំបានសួរគាត់ក្រែងលោគាត់ចង់អានអត្ថបទមួយចំនួនដែលខ្ញុំចង់ឱ្យគាត់អាន ពាក់ព័ន្ធនឹងការប្រោសគាត់ឱ្យជាសះស្បើយ មុនពេលដែលខ្ញុំអធិស្ឋាន។ ខ្ញុំបាននិយាយថា ខ្ញុំសប្បាយចិត្តនឹងអធិស្ឋានជូននៅព្រឹកថ្ងៃអាទិត្យ ក្រោយកម្មវិធីថ្វាយបង្គំចប់។ គាត់ក៏យល់ព្រម។

ខ្ញុំបានដឹងថា គាត់បានថ្វាយដួងចិត្តដល់ព្រះអម្ចាស់ជាច្រើនឆ្នាំកន្លងទៅ ប៉ុន្តែមិនបានរស់នៅថ្វាយព្រះអង្គទេ។ ខ្ញុំសង្ឃឹមថា ការទុកពេលវេលាខ្លះៗដើម្បីឆ្លុះបញ្ចាំងពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់អំពីការប្រោសឱ្យជា នឹងបានជួយជំរុញទឹកចិត្តអំពីជំនឿរបស់គាត់។ ខ្ញុំក៏បានដឹងដែរថា យើងមានឱកាសល្អច្រើនជាងក្នុងការមើលឃើញនូវលទ្ធផលវិជ្ជមាន ប្រសិនបើយើងអាចអធិស្ឋានដោយស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាយុត្តា និងក្តីសង្ឃឹមដែលយើងទុកចិត្ត។

ដូច្នេះ នៅថ្ងៃអាទិត្យបន្ទាប់នោះ មីងរបស់ខ្ញុំក៏បានមកក្រុមជំនុំដូចគាត់បាននិយាយមែន។ ក្រោយកម្មវិធីថ្វាយបង្គំចប់ ខ្ញុំក៏បានសុំឱ្យគាត់មកខាងមុខ ហើយពេលគាត់ក្រោយឈរ ខ្ញុំក៏បានសួរគាត់ថាតើគាត់បានអានអត្ថបទដែលខ្ញុំបានឱ្យគាត់ឬក៏អត់។ គាត់ថា គាត់បានអាន រួចខ្ញុំក៏សួរទៀតថា «តើមីងអាចដឹងបានដោយរបៀបណាថាមីងនឹងត្រូវបានប្រោសឱ្យជានៅពេលដែលខ្ញុំដាក់ដៃអធិស្ឋានលើមីង?» គាត់ក៏បានលើកឡើងពីខគម្ពីរមួយចំនួន ហើយគាត់ក៏បាននិយាយថា ទំនុកចិត្តរបស់គាត់ស្ថិតនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពេលនោះ ខ្ញុំបានដឹងថាគាត់បានត្រៀមខ្លួនរួចរាល់សម្រាប់សេចក្តីអធិស្ឋានហើយ ហើយខ្ញុំក៏បានដាក់ដៃលើគាត់ រួចអធិស្ឋានហើយបានប្រកាសថាគាត់បានជាសះស្បើយពីជំងឺមហារីក។ នៅពេលខ្ញុំអធិស្ឋានប្រេងតាំងរបស់ព្រះជាម្ចាស់ក៏បានសណ្ឋិតលើគាត់ ហើយគាត់ក៏បានដួលទៅលើឥដ្ឋ

ក្រោមឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ នៅពេលគាត់ក្រោកឡើង គាត់បានឧទានឡើងទាំងញ័រញាក់ថា «ខ្ញុំបានជាហើយ!»

នៅថ្ងៃអង្គារសប្ដាហ៍នោះ គាត់បានទៅធ្វើការវះកាត់យកសាច់ដុះចេញ ប៉ុន្តែនៅពេលពេទ្យពិនិត្យមើលខាងក្នុង មិនឃើញមានអ្វីដុះទេ។ គ្មានសាច់ដុះ សូម្បីតែស្នាមសន្លាក ឬស្លាកស្នាមដែលធ្លាប់មាន ក៏មិនឃើញនៅមានទៀតដែរ។

វាចម្លែកណាស់ដែលបានឃើញមនុស្សរស់នៅក្នុងរបៀបជីវិតរបស់គេ។ អ្នកប្រាកដជាគិតថា មីងរបស់ខ្ញុំប្រាកដជាដឹងគុណព្រះជាម្ចាស់ខ្លាំងណាស់ដែលព្រះអង្គប្រោសគាត់ឱ្យជា ហើយគិតថាមួយជីវិតរបស់គាត់ គាត់មិនដែលខកខានទៅក្រុមជំនុំនោះទេ។

ប៉ុន្តែ វាមិនមែនបែបហ្នឹងនោះទេ។ ខ្ញុំដូចជាបានឃើញគាត់មកចូលរួមកម្មវិធីថ្ងៃអាទិត្យតែម្ដងប៉ុណ្ណោះក្រោយថ្ងៃអាទិត្យនោះ។ រយៈពេលប្រាំមួយ ឬប្រាំពីរឆ្នាំក្រោយមក គាត់ក៏បានស្លាប់ដោយសារជំងឺមហារីកប្រភេទផ្សេងទៀត។ ប៉ុន្តែលើកនេះ គាត់មិនដែលសុំឱ្យខ្ញុំអធិស្ឋានឱ្យគាត់ទៀតទេ។

## ចូរក្រសោបពេលវេលានោះឱ្យជាប់ នៅពេលដែលអ្នកបញ្ចេញជំនឿ

រឿងមួយដែលខ្ញុំរំឭកមនុស្សម្នានោះគឺ តែងតែមានពេលវេលាសម្រាប់ពាក្យថា «អាម៉ែន» និង «មែនហើយ»។ ដោយសារតែការនេះ វាជារឿងសំខាន់ដែលអ្នកក្រសោបពេលវេលានៃការបញ្ចេញជំនឿរបស់អ្នកឱ្យជាប់។ ខ្ញុំសុំឱ្យអ្នកសរសេរទុកក្នុងសៀវភៅកំណត់ត្រារបស់អ្នក ឬក្រដាសកត់ត្រាណាមួយដើម្បីរំឭកខ្លួនឯង។ ខ្ញុំបានរំឭករឿងនេះពីមុនរួចហើយ ប៉ុន្តែខ្ញុំជឿថា វាជាការសំខាន់ខ្លាំងណាស់។ ខ្ញុំសូមសរសេរឧទាហរណ៍មួយដូចខាងក្រោម៖ «នៅម៉ោង ១:៣០ នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ខ្ញុំជឿថា ខ្ញុំទទួលបាន (ដាក់បញ្ចូលការទូលសុំជាក់លាក់មួយ) ស្របតាមគម្ពីរម៉ាកុស ១១:២៤ ហើយខ្ញុំជឿថា ខ្ញុំបានទទួលនៅពេលដែលខ្ញុំបានអធិស្ឋាន»។ អ្នកអាចកត់ចំណាំបន្ថែមទៀតនូវ

មនុស្សដែលឯកភាពនឹងអ្នក ចំនួនដែលអ្នកបានសាបព្រោះ និងអ្វីដែលព្រះជាម្ចាស់បានចាត់ចែងឱ្យអ្នកសាបព្រោះ។ នេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ប៉ុន្តែវាជាការសំខាន់ដែលអ្នកបានកត់ត្រាទុក ព្រោះថាអ្នកអាចតយុទ្ធនឹងការនោះបាន។

នៅពេលកាលៈទេសៈនានាល្បួងអ្នកឱ្យដកថយទាំងភាពភ័យខ្លាច នោះអ្នកអាចរំឭកខ្លួនឯងពីកាលបរិច្ឆេទ និងពេលវេលាដែលអ្នកទទួលបានការឆ្លើយតប។ នៅពេលសេចក្តីភ័យខ្លាចកើតឡើង ខ្ញុំតែងតែយកកំណត់ត្រានោះចេញមក ហើយអានដោយការប្រកាសឮៗ។ «ទេ សេចក្តីភ័យខ្លាចអើយ ឯងជាមេកុហក។ ខ្ញុំបានទទួលការឆ្លើយតបនៅថ្ងៃនេះ ពេលវេលានេះ ដោយស្របតាម (រួចដាក់បញ្ចូលនូវខគម្ពីរដែលអ្នកកំពុងរក្សាជំហរ)។ ពេលខ្លះ ខ្ញុំនឹងអានកំណត់ត្រានោះជាបីបួនដង ដើម្បីធ្វើឱ្យដួងចិត្តរបស់ខ្ញុំបានស្ងប់និងមានសន្តិភាព។ ចូរកុំអនុញ្ញាតឱ្យអ្វីដែលអាចបង្ហាញថាជាបរាជ័យដើម្បីបញ្ឆោតអ្នកចូលទៅក្នុងការចេញពីជំនឿរបស់អ្នកឡើយ។ តាមពិត គោលការណ៍នេះសំខាន់ណាស់នៅខណៈពេលដែលកូនៗរបស់ខ្ញុំកំពុងធំធាត់ ដែលពេលយើងមានការជួបជុំអធិស្ឋានជាលក្ខណៈគ្រួសារប្រចាំសប្តាហ៍ នោះយើងតែងមានកំណត់ត្រាគ្រួសារ ដែលយើងកត់ត្រាទុកនូវអ្វីដែលយើងបានអធិស្ឋាន និងអ្វីដែលយើងបានជឿថា យើងទទួលបាន។ យើងបានហៅសៀវភៅកំណត់ត្រានេះថាជា សៀវភៅសរសេរយ៉ាកុបជំពូក៤ (James 4 Notebook) របស់យើង។ តាមពិតទៅ បើអ្នកចង់បាន យើងក៏មានលក់សៀវភៅនេះនៅក្នុងព័ន្ធកិច្ចដែរ។

**តែងតែមានពេលវេលាសម្រាប់ពាក្យថា «អាម៉ែន» និង «មែនហើយ»។ ដោយសារតែការនេះ វាជារឿងសំខាន់ដែលអ្នកត្រសោបពេលវេលានៃការបញ្ចេញជំនឿរបស់អ្នកឱ្យជាប់។**

ពេលខ្លះ ក៏មានរឿងរ៉ាវផ្សេងៗដែលកំពុងកើតឡើងនៅក្នុងវិញ្ញាណ ដែលអ្នកមិនបានដឹង។ ព្រះជាម្ចាស់កំពុងធ្វើការរៀបចំចាត់ចែងគ្រប់យ៉ាង ប៉ុន្តែវាត្រូវការពេល

វេលា។ ប្រហែលជាមានចំណែកជាច្រើនដែលត្រូវផ្គុំឱ្យត្រូវ។ ឧទាហរណ៍ ប្រសិនបើព្រះជាម្ចាស់នឹងបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុ នោះទ្រង់ប្រហែលត្រូវមានបន្ទូលប្រាប់នរណាម្នាក់ឱ្យធ្វើកិច្ចការនេះ ឬនាំមកនូវឱកាសមួយដល់អ្នកដើម្បីទទួលបានប្រាក់ដែលអ្នកត្រូវការ។

> *លោកដានីយ៉ែលអើយ កុំភ័យខ្លាចអី! តាំងពីថ្ងៃដំបូងដែលលោកមានបំណងចង់យល់សេចក្តីទាំងនោះ ហើយបន្ទាបខ្លួននៅចំពោះព្រះភ័ក្ត្រព្រះរបស់លោក ទ្រង់ក៏ព្រះសណ្តាប់ឮពាក្យរបស់លោក ហេតុនេះបានជាខ្ញុំមកជួបលោក។ ទេវតាថែរក្សាចក្រភពពែរ្សបានតទល់នឹងខ្ញុំ អស់រយៈពេលម្ភៃមួយថ្ងៃ។ បន្ទាប់មក មហាទេវតាមីកែល ដែលជាមេដ៏សំខាន់របស់ពួកទេវតា បានមកជួយខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅទីនេះជាមួយស្តេចនានារបស់ជនជាតិពែរ្ស។ ខ្ញុំមកពន្យល់ប្រាប់លោកឱ្យដឹងអំពីហេតុការណ៍ ដែលនឹងកើតមានចំពោះប្រជាជនរបស់លោក ទៅអនាគត ដ្បិតមាននិមិត្តហេតុអស្ចារ្យមួយ សម្រាប់គ្រានោះដែរ។*
>
> — ដានីយ៉ែល ១០:១២-១៤ (គខប)

ចូរយើងក្រឡេកមើលរឿងនៅសាលាដែលខ្ញុំបានប្រាប់អ្នកកាលពីមុននេះ។ យើងបានរកមើលអគារផ្សេងៗ និងគិតគូររកជួលទីធ្លានៅក្នុងអគារមួយចំនួន ប៉ុន្តែយើងមិនមានចំណាប់អារម្មណ៍ក្នុងការចូលមកទីតាំងណាមួយក្នុងចំណោមអគារទាំងនោះទេ។ នៅពេលដែលយើងចាប់ផ្តើមស្វែងរកទីតាំងដំបូង យើងបានសាបព្រោះគ្រាប់ពូជសម្រាប់ព្រះជាម្ចាស់ ដើម្បីឱ្យទ្រង់បង្ហាញយើងពីកន្លែងដែលល្អឥតខ្ចោះ។ គ្រប់ពេលដែលពួកយើងរកបានទីតាំងមួយ និងពិចារណាចង់ជួលទីតាំងនោះ យើងមានអារម្មណ៍ថាមិនស្រួលក្នុងវិញ្ញាណរបស់យើង ហើយយើងស្ទើរតែបាក់ទឹកចិត្តផង។ យើងបានពិនិត្យរកមើលគ្រប់អគារនៅក្នុងតំបន់ដែលយើងចង់ដាក់ស្នាក់ការកណ្តាល ប៉ុន្តែមិនមានជម្រើសដែលយើងមានអារម្មណ៍ថាល្អនោះទេ។

គុណតម្លៃស្នូលរបស់យើងក្នុងនាមជាក្រុមជំនុំមាននូវបំណងប្រាថ្នាខ្លាំងក្លា ដើម្បីជួយអប់រំកុមារ និងថែរក្សាគ្រួសារ។ យើងបាននិយាយជាច្រើនដងមកហើយអំពីការបើកសាលានៅថ្ងៃណាមួយ ដោយមានថ្នាក់ថែទាំកុមារ កម្មវិធីកុមារតូច ព្រមទាំងកម្មវិធីជាច្រើនទៀតដើម្បីធ្វើព័ន្ធកិច្ចដល់សហគមន៍របស់ពួកយើង។ ទីធ្លាបច្ចុប្បន្នរបស់ពួកយើងពេញចំណុះទៅហើយ ដែលមិនអាចឱ្យយើងបំពេញតាមជម្រើសផ្សេងៗទៀតបាននោះទេ។

អ្នកប្រហែលជានឹងនិយាយថា មើលទៅព្រះរាជ្យរបស់ព្រះជាម្ចាស់មិនចូលមកទេ ប៉ុន្តែអ្នកត្រូវចាំថា យើងបានសាបព្រោះសម្រាប់ស្នាក់ការកណ្ដាលដ៏ល្អឥតខ្ចោះ។ តាមពិតនោះគឺថាព្រះជាម្ចាស់បានជ្រាបថា សាលាដែលយើងបានទិញនោះនឹងត្រូវរីបអូស។ ទ្រង់បានទតឃើញរូបភាពធំ។ ពេលយើងចាប់ផ្ដើមរកដំបូង ទីតាំងនោះមិនទំនេរទេ។

ក្រៅពីការបានដឹងថា សាលានោះនឹងក្លាយជាទីតាំងស្នាក់ការកណ្ដាលដ៏ល្អឥតខ្ចោះ នោះទ្រង់បានជ្រាបពីរបៀបដែលយើងនឹងអធិស្ឋានសម្រាប់អគារនោះ។ ប្ដីប្រពន្ធដែលបានទិញសាលាសម្រាប់យើងនោះស្ថិតក្នុងបញ្ជីប្រតិទិនរបស់ខ្ញុំ ដោយខ្ញុំបានអញ្ជើញពួកគាត់ពិសារអាហារពេលល្ងាចយ៉ាងហោចណាស់ក៏បានបួនលើកដែរ។ យោងតាមកាលៈទេសៈនានា យើងទាំងពីរបានលើកពេលជួបជុំពិសារអាហារពេលល្ងាចរហូតដល់រាត្រីដែលយើងបានជួបគ្នានោះ។ យើងទើបតែបានឃើញអគារនោះនៅវេលាព្រឹកនៃថ្ងៃតែមួយដែលយើងបានពិសារអាហារពេលល្ងាចជាមួយពួកគាត់។

ក៏មានអ្នកផ្សេងៗទៀតដែលចង់បានសាលានោះដែរ ប៉ុន្តែយើងបានទៅដល់មុនបន្តិច។ គ្រប់យ៉ាងស្ថិតក្នុងពេលវេលាដ៏ល្អឥតខ្ចោះ។ នៅពេលដែលយើងបានសាបព្រោះប្រាក់ ១០០.០០០ ដុល្លារ ពីរថ្ងៃមុនពេលដែលយើងបានពិសារអាហារពេលល្ងាចនោះ (ដោយមានការបង្ហាត់បង្ហាញពីព្រះវិញ្ញាណដ៏វិសុទ្ធ) ខ្ញុំជឿថា សាតាំងព្យាយាម

លាក់បាំងសាលានោះពីយើង ឬប្រើទិចនិកដើម្បីកុំឱ្យយើងបានសាលានោះ។ នៅពេលដែលព្រះជាម្ចាស់មានបន្ទូលប្រាប់ខ្ញុំឱ្យសាបព្រោះប្រាក់នោះ និងស្តីបន្ទោសសាតាំងដោយសាររារាំខានយើងក្នុងការស្វែងរកទីតាំងសាលា នោះខ្ញុំជឿថា ផែនការមួយចំនួនដែលវាបានជ្រៀតជ្រែកនោះក៏ត្រូវបានបញ្ឈប់។

ប្តីប្រពន្ធដែលបានផ្តល់ប្រាក់ដើម្បីទិញយកអចលទ្រព្យនេះក៏កំពុងរារែកក្នុងការសម្រេចចិត្តថាតើត្រូវជួយមិត្តម្នាក់ក្នុងការទិញអគារមួយកន្លែងឬយ៉ាងណា ដែលការជួយមិត្តនេះអាចប្រើប្រាស់ប្រាក់ដែលពួកគាត់បានប្រើប្រាស់សម្រាប់ការទិញអចលនទ្រព្យរបស់យើង។ បន្ទាប់ពីពួកគាត់បានស្តាប់ឮរឿងរ៉ាវរបស់យើងនៅរាត្រីនោះ ពួកគាត់បានពោលថា ពេលនោះពួកគាត់ទើបតែបានយល់ថាហេតុអ្វីបានជាពួកគាត់មិនមានសន្តិភាពក្នុងចិត្តក្នុងការជួយទំនុកបម្រុងមិត្តម្នាក់ឱ្យទិញអចលនទ្រព្យ។ ដូច្នេះចូរចងចាំថា នៅពេលអ្នកអធិស្ឋានដោយជំនឿ ដោយដឹងថាអ្នកទទួលបាននៅពេលដែលអ្នកអធិស្ឋាន ក៏នៅតែមានពេលវេលាក្នុងចន្លោះនៃពាក្យថា «អាម៉ែន» និង «មែនហើយ» ដែរ។ ដូច្នេះ ចូរមានចិត្តរឹងប៉ឹង និងអត់ធ្មត់។

## ចូរឈរមាំលើជំនឿរបស់អ្នក

*ប៉ុន្តែ ត្រូវឱ្យការស៊ូទ្រាំនេះបង្កើតចេញជាផលផ្លែដ៏ល្អគ្រប់លក្ខណៈ ដើម្បីឱ្យបងប្អូនបានគ្រប់លក្ខណៈ មានគុណសម្បត្តិល្អសព្វគ្រប់ ឥតខ្វះត្រង់ណាឡើយ។*

— យ៉ាកុប ១:៤ (គខប)

នេះជាមូលហេតុដែលខ្ញុំបានស្នើឱ្យមនុស្សគ្រប់គ្នាកត់ត្រាទុកនូវកាលបរិច្ឆេទ និងពេលវេលាដែលពួកគេបញ្ចេញជំនឿរបស់ខ្លួន ដ្បិតអ្នកត្រូវតែក្រោកឈរ។ នៅពេលដែលកូនស្រីរបស់ខ្ញុំកំពុងប្រឈមនឹងសាច់ដុះទម្ងន់ ៥,៨៩ គីឡូក្រាមនៅក្នុងពោះរបស់នាង នោះនាងក៏នឿយហត់នឹងបញ្ហាសុខភាពដែលដុំសាច់ដុះនេះបង្កឡើង៖ មានការរលាកតម្រងនោមឥតឈប់ឈរ ឈឺខ្នងឥតស្រាកស្រាន្ត និងបញ្ហាប្រព័ន្ធរំលាយ

អាហារ។ នាងបានសម្រេចចិត្តថា ប៉ុណ្ណឹងហើយហើយ ហើយនាងបានសម្រេចចិត្តចំណាយពេល៣០ថ្ងៃដើម្បីជញ្ជឹងគិតលើព្រះបន្ទូល និងសេចក្ដីសន្យារបស់ព្រះជាម្ចាស់ពាក់ព័ន្ធនឹងការប្រោសឱ្យជា។ នៅចុងរដូវកាលនៃការជញ្ជឹងគិតនោះ នាងបានសុំឱ្យម្ដាយរបស់នាង និងខ្ញុំដាក់ដៃអធិស្ឋានលើនាង ដ្បិតនាងជឿថានាងនឹងជាសះស្បើយ។ ដូចនេះក្រុមចាស់ទុំនៅក្រុមជំនុំ ព្រមទាំងម្ដាយរបស់នាង និងខ្ញុំបានដាក់ដៃអធិស្ឋានលើនាង និងជឿថានាងបានជាសះស្បើយដោយស្របតាមយ៉ាកុប ៥:១៤-១៦។

> *ក្នុងចំណោមបងប្អូន បើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ក្រុមជំនុំមក ដើម្បីឱ្យលោកទាំងនោះអធិស្ឋានឱ្យគាត់ និងលាបប្រេងឱ្យក្នុងព្រះនាមព្រះអម្ចាស់។ ពាក្យអធិស្ឋានដែលផុសចេញមកពីជំនឿ នឹងសង្គ្រោះអ្នកជំងឺនោះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឱ្យក្រោកឡើងវិញ ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើកលែងទោសឱ្យ។ ដូច្នេះ សូមបងប្អូនលន់តួបាបដល់គ្នាទៅវិញទៅមក ព្រមទាំងអធិស្ឋានឱ្យគ្នាទៅវិញទៅមកផង ដើម្បីឱ្យជាសះស្បើយ។ ពាក្យទូលអង្វររបស់មនុស្សសុចរិតមានប្រសិទ្ធភាពខ្លាំងណាស់។*
>
> — យ៉ាកុប ៥:១៤-១៦ (គខប)

នៅយប់នោះ នាងបានត្រលប់ទៅផ្ទះក្នុងរបៀបដូចគ្នាដែលនាងបានចូលមកដែរ។ សាច់ដុះនោះនៅតែមានដដែល។ ប៉ុន្តែនាងបានពោលថា «ខ្ញុំបានជាសះស្បើយ»។ នាងនៅបន្តជាប់នឹងការប្រកាសរបស់នាងអស់រយៈពេលពីរសប្ដាហ៍ដោយគ្មានការប្រែប្រួល ទោះបីជានាងកំពុងឈឺចាប់ខ្លាំងប៉ផុតដែលមិនធ្លាប់មានក្ដី។ នាងបានប្រាប់ខ្ញុំថាក្នុងអំឡុងរយៈពេលពីរសប្ដាហ៍ដែលនាងកំពុងមានការឈឺចាប់នោះ នាងបានប្រាប់សាតាំងថា «ឯងអាចព្យាយាមធ្វើឱ្យខ្ញុំឈឺចាប់បាន តែខ្ញុំបានជាសះស្បើយហើយ»។

ពីរសប្ដាហ៍ក្រោយមក នាងបានចូលគេងដោយសាច់ដុះនោះនៅមាននៅឡើយ ប៉ុន្តែនាងបានភ្ញាក់ឡើងដោយបានជាសះស្បើយទាំងស្រុង។ សាច់ដុះទម្ងន់

៥,៨៩គីឡូក្រាម និងទំហំ ២២ សង់ទីម៉ែត្រនោះក៏រលាយបាត់ពីចង្កេះនៅពេលនាងគេង ហើយខ្នងរបស់នាងដែលរលាក និងគ្រិចនោះ ក៏បានក្លាយជាសភាពឆ្អឹងខ្នងដ៏ល្អឥតខ្ចោះឡើងវិញ។

នៅពេលអ្នកមានទំនុកចិត្តពីព្រះបន្ទូលសន្យា ចូរកុំអនុញ្ញាតឱ្យសាតាំងបញ្ឆោតអ្នកចេញពីការប្រោសឱ្យជារបស់អ្នក ឬចេញពីព្រះបន្ទូលសន្យាដែលព្រះជាម្ចាស់បានប្រទានមកឱ្យអ្នក។

គ្រីស្ទីនបានមកក្រុមជំនុំរបស់យើងក្នុងនាមជាអ្នកមិនដែលទៅក្រុមជំនុំឡើយពីមុនមក។ វាថ្មីសម្រាប់នាង។ គ្រីស្ទីនបានពាក់ឧបករណ៍ជំនួយត្រចៀកអស់រយៈពេលពីរឆ្នាំមកហើយ ហើយក្នុងរយៈពេលនោះ គាត់បានបាត់បង់ញាណស្តាប់ឮអស់មួយចំណែកធំ។ ម្តាយរបស់គាត់ក៏មានជំងឺដូចគ្នា ហើយស្ទើរតែថ្លង់ទាំងស្រុង។

នៅពេលគ្រីស្ទីនបានចូលរួមក្នុងក្រុមជំនុំរបស់យើង គាត់បានថ្វាយដួងចិត្តទៅកាន់ព្រះអម្ចាស់ ហើយព្រះជាម្ចាស់បានផ្លាស់ប្តូរជីវិតរបស់គាត់យ៉ាងមហិមា។ គាត់រំភើបជាខ្លាំង ហើយចង់រៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ឱ្យបានច្រើនតាមតែអាចធ្វើបាន។ យើងក៏មានថ្នាក់ត្រួសត្រាយអ្នកជឿសម្រាប់អស់អ្នកដែលទើបមកក្រុមជំនុំថ្មីៗ ហើយគ្រីស្ទីនចង់ចូលរួមជាខ្លាំង។ ថ្នាក់ត្រួសត្រាយនោះបង្រៀននូវប្រធានបទផ្សេងៗ ប៉ុន្តែថ្ងៃដន្យអី ថ្នាក់រៀនដែលគ្រីស្ទីនកំពុងចូលរួមនោះកំពុងបង្រៀនអំពីការប្រោសឱ្យជា។ នៅចុងបញ្ចប់មេរៀន ក្រុមអ្នកដឹកនាំបានផ្តល់ការអធិស្ឋានដល់អ្នកដែលត្រូវការការប្រោសឱ្យជា។ គ្រីស្ទីនមានចិត្តរំភើបជាខ្លាំង ដោយគាត់បានដើរទៅមុខដើម្បីបានការអធិស្ឋាន។ នៅពេលគេកំពុងអធិស្ឋានឱ្យគាត់ ស្រាប់តែត្រចៀករបស់គាត់បានបើកមួយរំពេច។ គាត់អាចស្តាប់បានយ៉ាងច្បាស់ជាលើកដំបូង។

នៅពេលគាត់ហៀបនឹងចេញពីកម្មវិធីនៅថ្ងៃនោះ ខ្ញុំមានអារម្មណ៍ថា ត្រូវតែដាស់តឿនគាត់ពីការវាយប្រហាររបស់សាតាំង។ ប្រាកដណាស់ នៅព្រឹកបន្ទាប់គាត់បានប្រាប់ថា ត្រចៀករបស់គាត់ស្រាប់តែបានបិទវិញ ហើយគាត់ក៏ព្រួយបារម្ភជាខ្លាំង។ ប៉ុន្តែខ្ញុំបានប្រាប់គាត់ថា ការនេះនឹងកើតឡើង ហើយនៅពេលដែលវាបានកើតឡើង គាត់ត្រូវតែប្រកាសថា គាត់បានជាសះស្បើយហើយ និងត្រូវស្តីបន្ទោសសាតាំង។ គាត់ពិតជាបានធ្វើតាមអ្វីដែលខ្ញុំបានប្រាប់។ គាត់ចាប់ផ្តើមសរសើរតម្កើងព្រះជាម្ចាស់ និងប្រកាសថា គាត់បានជាសះស្បើយដោយគាត់បានអធិស្ឋានចងសត្រូវ។ ក្នុងរយៈពេលតែពីរបីនាទីក្រោយមក ត្រចៀករបស់គាត់ក៏បានបើកឡើង ហើយក៏បានបើករហូតចាប់តាំងពីពេលនោះមក ហើយបើគិតមកដល់ពេលនេះ គឺមានរយៈពេលបួនឆ្នាំមកហើយ។

**ជាថ្មីម្តងទៀត ការឈរយ៉ាងរឹងមាំនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាកូនសោបើកនូវសេរីភាពរបស់អ្នក។**

ជាថ្មីម្តងទៀត ការឈរយ៉ាងរឹងមាំនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាកូនសោបើកនូវសេរីភាពរបស់អ្នក។

## ខ្ញុំសូមនិយាយម្តងទៀតថា ចូរមានភាពជាក់លាក់

ពាក់ព័ន្ធនឹងការបញ្ចេញជំនឿរបស់អ្នក ខ្ញុំសូមរំឭកអ្នកម្តងទៀតថា ត្រូវតែមានភាពជាក់លាក់! រឿងនេះ គឺព្រះជាម្ចាស់ពិតជាចង់បង្ហាញខ្ញុំពីសារៈសំខាន់នៃពាក្យសម្តីរបស់ខ្ញុំ។ ខ្ញុំបានប្រាប់រាប់ឆ្នាំមកហើយ ប៉ុន្តែថ្ងៃនេះពាក្យនេះនៅតែមានអំណាចដូចមុននៅពេលដែលវាបានកើតឡើង។

ពេលនោះជារដូវបរបាញ់សត្វក្ងានដូចសព្វមួយដង ហើយខ្ញុំបានត្រៀមខ្លួនរួចរាល់ដើម្បីចូលក្នុងព្រៃ ខណៈដែលនៅមមាញឹកនឹងរឿងផ្សេងៗ។ នៅឆ្នាំនោះ ខ្ញុំបានសាបព្រោះគ្រាប់ពូជនូវសត្វក្ងានឈ្មោលចំនួនពីរក្បាល ដែលសត្វក្ងានឈ្មោលមួយ

ក្បាលមានស្នែងបែកបួនខ្នែង ឬមានស្នែងធំជាង ហើយសត្វក្តាន់ទីពីរ ជាសត្វក្តាន់ដែលទើបមានកំពកស្នែង។ ឌ្រិនដា និងខ្ញុំបានសាបព្រោះគ្រាប់ពូជដោយមានភាពស្របគ្នា និងដោយជំនឿ។ ខ្ញុំបានចេញទៅបរបាញ់ជាលើកដំបូងនៅពេលព្រឹកព្រលឹមទាំងដែលមិនទាន់ភ្លឺច្បាស់។ ដោយមេឃទើបតែប្រែជាក្រហមព្រឿងៗ ខ្ញុំបាញ់បានក្តាន់ឈ្មោលមួយក្បាលទៅហើយ នោះគឺជាសត្វក្តាន់ឈ្មោលដែលមានស្នែងបែកប្រាំបីខ្នែង។ ពេលវេលាសរុបដែលខ្ញុំបានចំណាយពេលក្នុងដើមឈើពួនរបស់ខ្ញុំនោះគឺតែដប់ប្រាំនាទីប៉ុណ្ណោះ! ខ្ញុំពិតជារំភើបណាស់! ដូច្នេះ នៅពេលដែលខ្ញុំបានចេញទៅក្រៅក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ដើម្បីយកសត្វក្តាន់ដែលទើបមានកំពកស្នែងនោះ ខ្ញុំមានទំនុកចិត្តណាស់។ ខ្ញុំក៏បានចេញទៅក្នុងពេលព្រឹកព្រលឹមម្តងទៀត ហើយប្រហែល ២០នាទី ខ្ញុំក៏ប្រទះឃើញសត្វក្តាន់ឈ្មោលមួយដែលមានមានស្នែងបែកប្រាំបីខ្នែងក្នុងចម្ងាយប្រហែល២៧០ម៉ែត្រកំពុងដើរសំដៅយ៉ាងត្រង់ទៅដើមឈើដែលខ្ញុំពួន។

នៅរដ្ឋអូហៃយ៉ូ អ្នកអាចត្រឹមបរបាញ់សត្វក្តាន់ឈ្មោលដែលមានស្នែងបានតែមួយក្បាលប៉ុណ្ណោះ។ ហើយសត្វក្តាន់ទីពីរត្រូវតែជាសត្វក្តាន់ញី ឬសត្វក្តាន់ដែលទើបមានកំពកស្នែង។ សត្វក្តាន់ដែលទើបមានកំពកស្នែងត្រូវរាប់ថាជាសត្វក្តាន់ញី ព្រោះអីស្នែងនោះតូចពេកដែលអ្នកមិនអាចមើលឃើញពីចម្ងាយ។ ដូច្នេះ នៅពេលដែលខ្ញុំបានឃើញក្តាន់ឈ្មោលកំពុងចូលមកកន្លែងខ្ញុំ ខ្ញុំបានសន្និដ្ឋានថាវានឹងរត់ចេញមុននឹងមកដល់ដើមឈើពួនចាំរបស់ខ្ញុំ ប៉ុន្តែវាមិនរត់ទេ។ វាបានដើរសំដៅមកដើមឈើពួនចាំរបស់ខ្ញុំ ហើយបានឈរនៅស្ងៀមទ្រឹងក្រោមកន្លែងខ្ញុំឈរប្រមាណជា២០វិនាទី។ ខ្ញុំមានតែឈរមើលប៉ុណ្ណោះព្រោះថាមិនស្របច្បាប់ទេបើបាញ់វានោះ។ បន្ទាប់ពីវាឈរអស់ប្រមាណជា២០វិនាទីហើយ វាស្រាប់តែដើរត្រលប់ទៅវិញ គឺទៅតាមផ្លូវដែលវាទើបនឹងមកនោះឯង។ គួរឱ្យភ្ញាក់ផ្អើលណាស់ វាបានដើរត្រលប់ទៅវិញប្រហែលជា ២៧០ម៉ែត្រតាមផ្លូវដដែលនោះ រួចក៏បាត់ស្រមោលទៅ។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង ហើយដូចជាវង្វេងវង្វាន់មិនដឹងទេ។

ពេលនោះ ខ្ញុំមិនដែលមានសត្វក្ដាន់ដែលចូលមកក្រោមកន្លែងខ្ញុំឈរបាញ់ ដែលសត្វនោះមិនមែនជាសត្វក្ដាន់ជាក់លាក់ដែលខ្ញុំបានសាបព្រោះគ្រាប់ពូជឡើយ។ ខ្ញុំច្របូកច្របល់ ហើយក៏បានចាប់ផ្ដើមអធិស្ឋានក្នុងវិញ្ញាណនៅពេលដែលខ្ញុំដើរសំដៅទៅផ្ទះវិញ។ «ព្រះអម្ចាស់អើយ ហេតុអ្វីបានជាសត្វក្ដាន់ឈ្មោលនោះនៅទីនោះ?» រំពេចនោះ ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលថា «ចូរឆែកមើលគ្រាប់ពូជរបស់អ្នកទៅ»។ ឆែកមើលគ្រាប់ពូជរបស់ខ្ញុំ? វង្វេងវង្វាន់អស់ហើយខ្ញុំ! ខ្ញុំដឹងថា ខ្ញុំបានសាបព្រោះសម្រាប់អ្វី។ យ៉ាងណាក្ដី ធនាគាដែលខ្ញុំបានប្រើប្រាស់នោះ បានផ្ញើក្រដាសកូពីចម្លងនៃសែកដែលបានលុបចោលប្រតិបត្តិការនោះមក ដោយមានការសរសេរបញ្ជាក់ជាប្រចាំខែ។ ខ្ញុំក៏បានទាញយកក្រដាសប្រយោគនោះមើល ហើយក៏ឃើញសែករបស់ខ្ញុំ។ នៅផ្នែកខាងក្រោមនៃសែកនោះ ខ្ញុំបានសរសេរថា សត្វក្ដាន់ចំនួនពីរដែលមានស្នែងបែកខ្នែងបួន ឬធំជាងនេះ សត្វក្ដាន់ដែលទើបមានកំពកស្នែង។ តើមានសត្វក្ដាន់ចំនួនប៉ុន្មានទៅ? អ្វីដែលខ្ញុំចង់សរសេរនោះគឺថា ខ្ញុំចង់បានសត្វក្ដាន់ឈ្មោលសរុបចំនួនពីរ ដោយមួយក្បាលជាសត្វក្ដាន់ឈ្មោលដែលមានស្នាមដៅចំនួនបួន ឬធំជាងនេះ ហើយមួយក្បាលទៀតជាសត្វក្ដាន់ដែលមានស្នាមប៉ោងត្រង់កន្លែងដុះស្នែង។ យ៉ាងណាក្ដី របៀបដែលខ្ញុំសរសេរបានបង្ហាញថា ខ្ញុំកំពុងសាបព្រោះសម្រាប់សត្វក្ដាន់ឈ្មោលដែលមានស្នែងបែកខ្នែងបួន ឬធំជាងនេះចំនួនពីរក្បាល និងសត្វក្ដាន់ដែលទើបមានកំពកស្នែងមួយក្បាល។ ខ្ញុំបានអង្គុយទាំងតាំងស្មារតី។ សត្វក្ដាន់ឈ្មោលទីពីរនោះមកដោយសារតែខ្ញុំបានសាបព្រោះគ្រាប់ពូជសម្រាប់សត្វនេះ។ នេះជាមូលហេតុដែលវាមកទីកន្លែងនោះ និងបានឈរនៅក្រោមដើមឈើពួនចាំរបស់ខ្ញុំ។ វាត្រូវតែនៅទីនោះ។

នៅពេលដែលខ្ញុំបាននឹកឃើញពីការនេះហើយ ខ្ញុំក៏ចាប់ផ្ដើមស្រែកឡើងស្រែករត់ពេញផ្ទះ។ ខ្ញុំរំភើបជាខ្លាំង ប៉ុន្តែក្នុងពេលដដែលនោះ ការណ៍នោះក៏បានបន្លាចខ្ញុំ។ តើប៉ុន្មានដងមកហើយដែលខ្ញុំបាននិយាយអ្វីមួយ ដែលតាមពិតខ្ញុំមិនចង់ឱ្យកើតឡើងបែបហ្នឹងសោះ តែអត្ថន័យនៃពាក្យដែលខ្ញុំនិយាយនោះបែរជាទៅបែបហ្នឹងនោះ?

ការនេះពិតជាស្តែងឱ្យឃើញក្នុងជីវិតពិតជាក់ស្តែងដូចអ្វីដែលគម្ពីរយ៉ាកុប ៣:៣-៤ ចែងអ៊ីចឹង។

> *សូមគិតពីសំពៅដែរ ទោះបីវាធំប៉ុនណា ហើយមានខ្យល់បក់មកខ្លាំងយ៉ាងណាក៏ដោយ ក៏អ្នកបើកសំពៅអាចបត់បែនបានតាមបំណងចិត្ត ដោយសារចង្កូតដ៏តូចមួយ។*
>
> — យ៉ាកុប ៣:៣-៤ (គខប)

គម្ពីរយ៉ាកុបកំពុងនិយាយប្រាប់ថាតើពាក្យពេចន៍របស់យើងមានអំណាចខ្លាំងប៉ុនណា។ វាច្បាស់ណាស់ថា បើពាក្យពេចន៍របស់យើងដែលកំពុងនិយាយពីរបស់ម្យ៉ាង តែតាមពិតទៅយើងចង់សំដៅលើអ្វីមួយផ្សេងទៀត នោះយើងនឹងឃើញថាជីវិតរបស់យើងដូចជាកប៉ាល់ដែលខូច ហើយមិនដឹងថាខ្លួនទៅដល់ទីនោះយ៉ាងដូចម្តេចឡើយ។

ដូច្នេះ ចូរចាំថា ព្រះរាជ្យនៃព្រះមានលក្ខណៈជាក់លាក់ ហើយពាក្យពេចន៍របស់អ្នកកំណត់នូវកន្លែងដែលអ្នកត្រូវទៅ និងរបៀបដែលអ្នកទៅដល់ទីនោះ!

## សារៈសំខាន់នៃការយល់ស្រប

យើងនៅតែនិយាយអំពីការបញ្ចេញគ្រាប់ពូជរបស់អ្នកនៅពេលដែលអ្នកស្ថិតក្នុងជំនឿ ហើយនេះជាអ្វីដែលអ្នកត្រូវតែចងចាំ។ ប្រសិនបើអ្នករៀបការរួច ចូរមានការយល់ស្របជាមួយប្តីប្រពន្ធរបស់អ្នក។ ប្រសិនបើអ្នកមិនមានប្តីឬប្រពន្ធទេ ខ្ញុំនឹងលើកឡើងនៅពេលបន្តិចទៀត ប៉ុន្តែឧបមាថាអ្នករៀបការហើយទៅចុះ។ សូមនិយាយម្តងទៀត ចូរមានការយល់ស្របជាមួយប្តីប្រពន្ធរបស់អ្នក។

ក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំដំបូងៗ ខ្ញុំមិនចូលចិត្តសុំឱ្យឌ្រិនដាឯកភាពនឹងខ្ញុំពាក់ព័ន្ធនឹងរឿងបរបាញ់សត្វឡើយ។ គឺដោយសារតែ បើខ្ញុំនិយាយរឿងទៅបរ

បាញ់ នោះខ្ញុំដឹងថាគាត់នឹងនិយាយពីរឿងរ៉ាវផ្សេងៗទៀតដូចជា រឿងសំរាមដែលត្រូវយកចេញ អំពូលភ្លើងត្រូវដូរ ហើយមានបញ្ជីការងារច្រើនទៀតដែលត្រូវធ្វើឱ្យហើយ។ ពេលនោះ គឺដោយសារតែខ្ញុំនៅមិនទាន់ពេញវ័យ និងអាត្មានិយម។ គាត់នៅផ្ទះជាមួយកូនៗពេញមួយថ្ងៃ ប៉ុន្តែដល់វេលាដែលខ្ញុំមកដល់ផ្ទះ ខ្ញុំក៏ចង់ចេញទៅព្រៃ។ ខ្ញុំគិតថាព្រះជាម្ចាស់មិនប្រទានពរដល់អាកប្បកិរិយាបែបនោះទេ។ មែនហើយ ខ្ញុំអាត្មានិយមណាស់។ មុនពេលខ្ញុំបានរៀនពីរបៀបបរបាញ់ដោយជំនឿ ខ្ញុំតែងតែចំណាយពេលច្រើនថ្ងៃបរបាញ់ដោយមិនជោគជ័យ។ វាគ្មានអ្វីចម្លែកទេដែលគាត់ខ្លាចរដូវបរបាញ់។

ប៉ុន្តែខ្ញុំបានរៀនទុកគាត់ជាទីមួយ។ ខ្ញុំត្រូវតែដឹងថា យើងស្ថិតក្នុងរឿងនេះរួមគ្នា ហើយយើងត្រូវការគ្នា។ នៅពេលខ្ញុំចាប់ផ្តើមទុកតម្រូវការរបស់គាត់ជារឿងទីមួយ នោះគាត់រឹតតែមានការយល់ស្របនឹងខ្ញុំកាន់តែច្រើនក្នុងការបរបាញ់សត្វក្តាន់។ ប៉ុន្តែគាត់ពិតជារីករាយជាពិសេសបើបានឃើញខ្ញុំប្រមាញ់សត្វក្តាន់បានជោគជ័យ។ ខ្ញុំត្រូវតែរៀនស្វែងយល់ថា ក្នុងនាមជាប្តីប្រពន្ធ យើងជាវិញ្ញាណតែមួយ ហើយគ្មានអ្វីមានអំណាចជាងពេលដែលយើងទាំងពីរធ្វើអ្វីមួយដោយមានការយល់ស្របគ្នានោះទេ។ វាមិនមែនគ្រាន់តែជាការប្រមាញ់សត្វក្តាន់ទេ។ ខ្ញុំបានដឹងថា ប្រសិនបើយើងដើររួមគ្នាជាធ្លុងមួយ នោះវាដំណើរការយ៉ាងល្អក្នុងគ្រប់ជ្រុងជ្រោយនៃជីវិត។

**ខ្ញុំត្រូវតែរៀនស្វែងយល់ថា ក្នុងនាមជាប្តីប្រពន្ធ យើងជាវិញ្ញាណតែមួយ ហើយគ្មានអ្វីមានអំណាចជាងពេលដែលយើងទាំងពីរធ្វើអ្វីមួយដោយមានការយល់ស្របគ្នានោះទេ។**

*រីឯបងប្អូនដែលជាស្វាមីក៏ដូច្នោះដែរ ម្នាក់ៗត្រូវរួមរស់ជាមួយភរិយារបស់ខ្លួនដោយយល់ថា ស្ត្រីៗជាមនុស្សទន់ខ្សោយជាងខ្លួន។ ត្រូវគោរពនាងទុកដូចជាអ្នកត្រូវរួមទទួលជីវិត ដែលព្រះជាម្ចាស់ប្រោសប្រណីប្រទានមកបងប្អូនជាមតិក ដើម្បីកុំឱ្យមានអ្វីមករារាំងការអធិស្ឋានរបស់បងប្អូនឡើយ។*

**ជំនឿគឺជាកូនសោ**

— ១ពេត្រុស ៣:៧ (គខប)

សូមចំណាំ បងប្អូនបុរសៗ ប្រសិនបើអ្នកមិនមានការគិតគូរដល់ភរិយារបស់ខ្លួនទេ នោះសេចក្តីអធិស្ឋានរបស់អ្នកនឹងត្រូវបានរារាំងមិនខាន! គិតគូរមានន័យថាអ្នកត្រូវចាត់ទុកនាងថាមានភាពស្មើគ្នា ដ្បិតអ្នកនៅជាមួយនាងក្នុងគ្រប់ការសម្រេចចិត្តនីមួយៗ។

មែនហើយ បើផ្នែកវិញ្ញាណ បុរសជាមេគ្រួសារ ប៉ុន្តែមិនមែនស្ថិតក្នុងទម្រង់បែបអ្នកផ្តាច់ការទេ តែជាអ្នកបម្រើវិញ ដោយលះបង់ជីវិតសម្រាប់នាង និងផ្តល់កិត្តិយសដល់នាង។

## ចុះបើប្តី/ប្រពន្ធរបស់អ្នកមិនមែនជាអ្នកជឿវិញ?

ខ្ញុំទទួលបានសារអ៊ីមែលដោយគេសួរថា តើគេត្រូវធ្វើអ្វីបើពួកគេរៀបការនឹងប្តី/ប្រពន្ធដែលមិនចង់បម្រើព្រះអម្ចាស់។ តើពួកគេអាចមានការយល់ស្របគ្នាយ៉ាងដូចម្តេចទៅ? ការយល់ដឹងរបស់អ្នកអំពីការយល់ស្របគ្នាគឺខុសហើយ។ ឧបមាថា អ្នករៀបការជាមួយបុរសម្នាក់ដែលមិនចង់បម្រើព្រះអម្ចាស់។ យ៉ាងណាក្តី អ្នកទាំងពីរឯកភាពគ្នាថា ត្រូវទិញរថយន្តថ្មី។ ដឹងថាម៉េចទេ? អ្នកមានការយល់ស្របគ្នាហើយ! ប្រសិនបើអ្នកទាំងពីរឯកភាពគ្នាថាអ្នកត្រូវការគ្រឿងទេស នោះអ្នកមានការយល់ស្របគ្នាហើយ។ ព្រះគម្ពីរចែងយ៉ាងច្បាស់ថា ប្រសិនបើម្នាក់ក្នុងចំណោមប្តីប្រពន្ធជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះព្រះរាជ្យរបស់ព្រះជាម្ចាស់មាននូវដែនអំណាចគ្រប់គ្រងស្របច្បាប់ដើម្បីធ្វើការនៅក្នុងគ្រួសារ!

*ដ្បិតប្តីដែលមិនជឿ នោះបានរាប់ជាស្អាតដោយសារប្រពន្ធ ហើយប្រពន្ធដែលមិនជឿក៏ដោយសារប្តីដែរ ពុំនោះ កូនចៅគេមិនស្អាតទេ តែឥលូវនេះ វាស្អាតហើយ។*

— ១កូរិនថូស ៧:១៤ (គខប)

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃព្រះរាជទាន

ខ្ញុំមិនជឿថា នេះជាការនិយាយថាប្ដី/ប្រពន្ធដែលមិនជឿត្រូវបានសង្គ្រោះដោយសារតែជំនឿរបស់ប្ដី/ប្រពន្ធខ្លួននោះទេ។ ខ្ញុំជឿថា បុគ្គលម្នាក់ៗត្រូវតែស្រែកហៅព្រះនាមរបស់ព្រះយេស៊ូគ្រិស្តដោយខ្លួនឯងផ្ទាល់។ យ៉ាងណាក្ដី ខ្ញុំជឿថា ប្រសិនបើប្ដី/ប្រពន្ធម្នាក់ជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះជំនឿរបស់ពួកគេបានស្អាង ឬនាំគ្រួសារទាំងមកស្ថិតមូលក្រោមព្រះពរនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ច្បាស់ណាស់ថាជារឿងពិតប្រាកដណាស់ដែលការបានរៀបការនឹងប្ដី/ប្រពន្ធដែលជឿជារឿងគាប់ប្រសើរជាង។ ហើយព្រះគម្ពីរបង្ហាញច្បាស់ៗដោយមានការលើកទឹកចិត្តដល់ប្ដីប្រពន្ធដែលជឿនូវសេចក្ដីពិតថា ជំនឿរបស់ពួកគេអាចយកឈ្នះលើប្ដី/ប្រពន្ធដែលមិនជឿឱ្យចូលក្នុងព្រះរាជ្យនៃព្រះជាម្ចាស់។

ប្រសិនបើអ្នកមិនទាន់រៀបការទេ មិនចាំបាច់ស្វែងរកបុគ្គលណាផ្សេងដើម្បីបានយល់ស្របនឹងអ្នកក្នុងសេចក្ដីអធិស្ឋានទេ។ អ្នកគ្រាន់តែជឿលើព្រះបន្ទូលព្រះជាម្ចាស់សម្រាប់ខ្លួនឯង និងឈរមើលព្រះរាជ្យនៃព្រះជាម្ចាស់ធ្វើការ!

ខណៈពេលដែលយើងកំពុងពិភាក្សាអំពីប្រធានបទស្ដីពីជំនឿ ខ្ញុំក៏ចង់ពិភាក្សានៅក្នុងជំពូកបន្ទាប់ ដែលសំណួរពិភាក្សានោះអាចជាសំណួរទូទៅបំផុតមួយដែលមានគេសួរខ្ញុំអំពីការសាបព្រោះ និងកំហុសដែលមនុស្សជាច្រើនបានបង្កឡើង។

# ជំពូក ៧
# ការព្រមាន៖ ចូររក្សាជំនឿដែលអ្នកមាន!

«ខ្ញុំនឹងចាប់ត្រីម៉ាលីនដែលមានទម្ងន់៥០៨គីឡូឱ្យបាន!» នេះជាអ្វីដែលសហការីម្នាក់របស់ខ្ញុំ ដែលនឹងធ្វើដំណើរទៅកោះម៉ៅអ៊ី នៅរដ្ឋហាវ៉ៃ បាននិយាយនៅក្នុងការិយាល័យរបស់ខ្ញុំ។ វាគឺជាការធ្វើដំណើរដែលបានបង់ថ្លៃចំណាយទាំងអស់រួចរាល់ហើយ ដែលយើងបានឈ្នះដោយសារផលិតកម្មរបស់យើងជាមួយអ្នកលក់ម្នាក់របស់យើង។ មុនពេលចេញដំណើរទៅកោះម៉ៅអ៊ី ពួកយើងទាំងបីនាក់បានសម្រេចចិត្តទៅស្ទូចត្រីម៉ាលីនពណ៌ខៀវ ដោយសារវាមិនមែនជារឿងអាថ៌កំបាំងអីទេ ដែលកោះម៉ៅអ៊ីត្រូវបានគេស្គាល់ថាជារដ្ឋធានីត្រីម៉ាលីនពណ៌ខៀវនៃពិភពលោក។ យើងបាននិយាយអំពីជំនឿជាច្រើនខែមុនពេលព្រឹត្តិការណ៍នេះបានកើតឡើង ហើយខ្ញុំកំពុងបង្រៀនក្រុមបុរសនេះអំពីរបៀបដែលជំនឿមានដំណើរការ។ សម្រាប់ដេន ជំនឿគឺជាអ្វីមួយថ្មីសម្រាប់គាត់ ហើយខ្ញុំចាំថា ខ្ញុំបានគិតថា នេះជាឱកាសដ៏ល្អមួយដើម្បីឱ្យគាត់ចេញទៅមើលកិច្ចការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយផ្ទាល់។ ដូច្នេះ ខ្ញុំក៏បាននិយាយទៅគាត់ថា «ហេ ដេន តើលោកដឹងទេថា វាអាចទៅរួចដែលយើងអាចដឹងដោយគ្មានការសង្ស័យថា លោកនឹងចាប់បានត្រីម៉ាលីនពណ៌ខៀវ ពេលយើងទៅហាវ៉ៃទេ?»។ អ្វីដែលខ្ញុំបាននិយាយនោះទទួលបានការចាប់អារម្មណ៍ពីគាត់ ហើយយើងបានចំណាយពេលជាច្រើនម៉ោងដើម្បីពិភាក្សាអំពីជំនឿមុនពេលយើងចាកចេញទៅកោះម៉ៅអ៊ី។ ដេនបានសាបព្រោះ

គ្រាប់ពូជរបស់គាត់ដូចដែលខ្ញុំបានបង្រៀនគាត់ ហើយរំភើបចិត្តណាស់ដែលបានដើរតាមសុបិនរបស់គាត់គឺ ចាប់ត្រីម៉ាលីនពណ៌ខៀវឱ្យបាន។

សហការីម្នាក់ទៀតរបស់ខ្ញុំគឺជាសមាជិកនៃក្រុមជំនុំរបស់ខ្ញុំ គាត់មានការយល់ដឹងយ៉ាងល្អអំពីរបៀបដែលជំនឿមានដំណើរការ ហើយធ្លាប់បានឃើញព្រះជាម្ចាស់ធ្វើរឿងអស្ចារ្យនៅក្នុងជីវិតរបស់គាត់។ គាត់ក៏បានសាបព្រោះគ្រាប់ពូជរបស់គាត់សម្រាប់ការចាប់ត្រីម៉ាលីន មិនគ្រាន់តែត្រីម៉ាលីនមួយណាក៏បានទេ ប៉ុន្តែ គាត់ចង់បានត្រីម៉ាលីនដែលមានទម្ងន់៩០៨គីឡូ។ ខ្ញុំចាំថា ខ្ញុំបានគិតថា «អីយ៉ា នេះជាត្រីដ៏ធំមួយ!» ខ្ញុំមានអារម្មណ៍ព្រួយបារម្ភអំពីទំហំដ៏ជាក់លាក់នៃត្រីម៉ាលីនដែលមិត្តរបស់ខ្ញុំកំពុងសាបព្រោះចង់បាន ប៉ុន្តែខ្ញុំមិនបាននិយាយអ្វីអំពីវាទៅគាត់នៅពេលនោះទេ។

ម្យ៉ាងវិញទៀត ដេនមិនបានសាបព្រោះសម្រាប់ទំហំត្រីដ៏ជាក់លាក់ណាមួយដែលគាត់ចង់បានទេ។ បាទ ដើម្បីធ្វើឱ្យដំណើរសាច់រឿងនេះបានខ្លីបន្តិច ដេនបានចាប់បានត្រីម៉ាលីនពណ៌ខៀវមួយដែលមានទម្ងន់៧៥គីឡូ ប៉ុន្តែសហការីម្នាក់ទៀតរបស់ខ្ញុំចាប់មិនបានត្រីម៉ាលីនទេ សូម្បីតែមួយក្បាល។ ចុះហេតុអ្វីបានជាដេនចាប់ត្រីម៉ាលីនរបស់គាត់បាន ប៉ុន្តែមិត្តម្នាក់ទៀតចាប់មិនបាន? នេះជាសំណួរដ៏ល្អមួយ ហើយមនុស្សភាគច្រើន សូម្បីតែគ្រិស្តបរិស័ទភាគច្រើនក៏នឹងតក់ស្លុតពេលសួរសំណួរបែបនោះដែរ។ ពួកគេនឹងសើចហើយនិយាយថា «សម្រាប់ការស្ទូចត្រី ពេលខ្លះអ្នកស្ទូចបានត្រី ហើយពេលខ្លះទៀតអ្នកស្ទូចមិនបានត្រីទេ» ។ ប៉ុន្តែ សម្រាប់ខ្ញុំវិញ ខ្ញុំបានរៀនថាព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាក់លាក់ និងអាចទុកចិត្តបាន។

> *ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្ដាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឱ្យគាត់*

*ចេញទូក ទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដាជនពីក្នុងទូកនោះ។*

*លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។*

*កស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។*

*គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។ ពេលលោកស៊ីម៉ូន-ពេត្រុសឃើញដូច្នោះ គាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងឱ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប»។*

*លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ រីឯលោកយ៉ាកុប និងលោកយ៉ូហានជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។*

— លូកា ៥:១-១០

លោកពេត្រុសបានរកឃើញរបៀបថ្មីក្នុងការនេសាទត្រី ដូចដែលខ្ញុំក៏បានរកឃើញរបៀបថ្មីក្នុងការបរបាញ់សត្វក្ដាន់ផងដែរ។ គាត់បានសាកល្បងនេសាទត្រី ប៉ុន្តែមិនបានត្រីទាល់តែសោះ រហូតទាល់តែព្រះយេស៊ូបានប្រាប់គាត់ថាត្រីនៅកន្លែងណានៅក្នុងទឹកជ្រៅ ទើបគាត់អាចចាប់វាបាន។ ពេលនោះគាត់ចាប់បានត្រីដ៏ច្រើនសន្ធឹកសន្ធាប់ រហូតដល់ថ្នាក់ទូកទាំងពីររបស់គាត់ស្ទើរតែលិចទៅហើយ។ ខ្ញុំប្រាប់មនុស្សថា៖

«អ្នកណាក៏អាចនេសាទត្រីបានដែរ ឱ្យតែព្រះយេស៊ូប្រាប់ពួកគេពីកន្លែង និងរបៀបដែលត្រូវនេសាទត្រីទាំងនោះ»។

ដូច្នេះ ទាក់ទងជាមួយមិត្តរបស់ខ្ញុំ ដែលចង់បានត្រីម៉ាលីនដ៏ធំ តែគាត់ចាប់វាមិនបាននោះ គឺថា វាជាការពិតណាស់ដែលថា អ្វីៗទាំងអស់អាចទៅរួចជាមួយព្រះជាម្ចាស់។ ក៏ប៉ុន្តែ ប្រសិនបើអ្នកសាបព្រោះគ្រាប់ពូជ ដោយជឿថាអ្នកនឹងចាប់បានត្រីម៉ាលីនពណិខៀវនៅក្នុងអាងងូតទឹករបស់អ្នក នោះអ្នកនឹងដឹងប្រាកដថាវាមិនអាចទៅរួចបានទេ។ ឥលូវនេះ ប្រសិនបើអ្នកចង់ចាប់ត្រីម៉ាលីនពណិខៀវ អ្នកអាចសាបព្រោះគ្រាប់ពូជមួយ ហើយព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំអ្នកទៅកន្លែងមួយដែលអ្នកអាចចាប់ត្រីម៉ាលីនបាន - គឺនៅក្នុងមហាសមុទ្រ បាទ ពិតណាស់ ប៉ុន្តែតើនៅក្នុងសមុទ្រមួយណាទៅ?

សូមចងចាំចំណុចនេះ៖ រាល់ការប្រមូលផលមានទីតាំងជាក់លាក់ និងមានពេលវេលាជាក់លាក់តែមួយគត់សម្រាប់ការប្រមូលផល! ប្រសិនបើអ្នកចង់សាបព្រោះសម្រាប់ត្រីម៉ាលីនពណិខៀវដែលជាប់កំណត់ត្រាពិភពលោក អ្នកមិនអាចគ្រាន់តែនិយាយថា «ខ្ញុំនឹងទៅសមុទ្រដើម្បីចាប់វា» បានទេ។ អ្នកនឹងត្រូវទៅតំបន់ដ៏ជាក់លាក់មួយនៅក្នុងមហាសមុទ្រ។ ហេតុអ្វី? ដោយសារតែត្រីម៉ាលីនពណិខៀវធ្វើចំណាកស្រុក និងមានផ្លូវជាក់លាក់ដែលពួកវាធ្វើដំណើរជារៀងរាល់ឆ្នាំ។ ហើយការចាប់ត្រីម៉ាលីនពណិខៀវដែលមានទម្ងន់៤០៨គីឡូ គឺជាការចាប់ត្រីដ៏កម្ររកបានផងដែរ។ ឧទាហរណ៍៖ ការប្រកួតនេសាទត្រីម៉ាលីនពណិខៀវនៅឆ្នេរត្បូងមរកត (Emerald Coast Blue Marlin Classic) នៅទីក្រុងមីរ៉ាម៉ា រដ្ឋផ្លរីដា បានមានដំណើរការអស់រយៈពេល១៧ឆ្នាំមកហើយ។ ត្រីម៉ាលីនពណិខៀវដ៏ធំបំផុតដែលមិនធ្លាប់ចាប់បានក្នុងអំឡុងពេលនោះមានទម្ងន់៥០៣គីឡូ។ តើវាអាចទៅរួចទេដែលយើងនឹងចាប់បានត្រីម៉ាលីនពណិខៀវទម្ងន់៤០៨គីឡូ ពេលយើងធ្វើដំណើរទៅកោះម៉ៅអ៊ី? ប្រហែលអាចទៅរួច ដោយសារមានកំណត់ត្រាត្រីម៉ាលីនពណិខៀវដែលគេចាប់បាននៅហាវ៉ៃ មានទម្ងន់៦២៥គីឡូ ប៉ុន្តែសូមសរសេរការនេះចុះ។

**ការព្រមាន៖ ចូររក្សាជំនឿដែលអ្នកមាន**

## កាលណាវត្ថុនៃជំនឿរបស់អ្នកកាន់តែជាក់លាក់ ឬកាន់តែខុសប្លែកពីគេ កាលនោះវាកាន់តែសំខាន់ក្នុងការយកចិត្តទុកដាក់លើទីតាំង វិធីសាស្ត្រ និង ពេលវេលា។

នៅថ្ងៃនោះ ប្រធានទូកនៅកោះម៉ៅអ៊ី បានប្រាប់យើងថាត្រីម៉ាលីនពណិខៀវនៅមិនទាន់មកដល់ទីនោះនៅឡើយទេ។ គាត់មានទូកពីរដែលចេញក្នុងមួយថ្ងៃប្រាំបីម៉ោង បួនខែមុននេះ ប៉ុន្តែចាប់បានតែត្រីម៉ាលីនឆ្នូតមួយក្បាលតែប៉ុណ្ណោះ។ ត្រីម៉ាលីនពណិខៀវនឹងត្រូវមកដល់នៅចុងខែនេះ។ ពិតណាស់ យើងចាប់បានត្រីម៉ាលីនមួយក្បាលដំបូងគេក្នុងរដូវកាលនេះ។ ប៉ុន្តែ ពេលដែលមិត្តរបស់ខ្ញុំបានធ្វើឱ្យគ្រាប់ពូជរបស់គាត់កាន់តែជាក់លាក់ ហើយជាពិសេសពេលគាត់ចង់បានត្រីម៉ាលីនដែលនឹងកត់ត្រាចូលក្នុងសៀវភៅកំណត់ត្រា នោះទីតាំង និងពេលវេលាកាន់តែមានសារៈសំខាន់ខ្លាំងជាងមុនក្នុងការប្រមូលផល។ ខ្ញុំខ្លួនឯងផ្ទាល់ក៏ជឿជាក់ថា នៅពេលនោះមិនមានត្រីម៉ាលីនដែលមានទំហំដូចគាត់ចង់បាននៅក្នុងតំបន់នោះទេ។ យើងក៏ត្រូវដឹងថា វាអាចទៅរួចដែលថា មិត្តរបស់ខ្ញុំពិតជាមិនមានជំនឿយ៉ាងមុតមាំថានឹងអាចចាប់បានត្រីម៉ាលីនដ៏ធំបែបនោះ។ ក៏ប៉ុន្តែ ប្រសិនបើគាត់ពិតជាប្រាកដក្នុងចិត្តថាគាត់ពិតជាចង់បានត្រីម៉ាលីនទម្ងន់៩០៨គីឡូនោះមែន នោះខ្ញុំក៏ដឹងច្បាស់ថា បើគាត់សាបព្រោះគ្រាប់ពូជរបស់គាត់ ហើយស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធអំពីទីកន្លែងដែលត្រូវចាប់វា និងស្តាប់ពីពេលវេលាដ៏ត្រឹមត្រូវដែលត្រូវចាប់វា នោះគាត់មុខជាចាប់បានត្រីម៉ាលីនពណិខៀវទម្ងន់៩០៨គីឡូរបស់គាត់ជាមិនខានទេ។

## ទីតាំង និងពេលវេលាពិតជាសំខាន់

ភាពជាក់លាក់ទាក់ទងនឹងទីតាំង និងពេលវេលានៃការប្រមូលផលគឺមានសារៈសំខាន់ដូចគ្នានឹងគ្រាប់ពូជជាក់លាក់ដែលអ្នកសាបព្រោះ។ អ្នកអាចបានឃើញពីដំណើរការនេះ ពេលដែលខ្ញុំបានធ្វើការពិសោធជាមួយសត្វក្ដាន់ឈ្មោល ដែលមាន

ស្នែងបែកខ្នែងប្រាំពីរ។ ខ្ញុំត្រូវរង់ចាំរហូតទាល់តែខ្ញុំទទួលបានការជំរុញចិត្តឱ្យចេញទៅក្រៅ ហើយក្នុងករណីនេះ ខ្ញុំបានរង់ចាំអស់រយៈពេលជាងមួយខែក្នុងរដូវបរបាញ់។ ហេតុអ្វី? ភាគច្រើនអាចទំនងជាដោយសារតែសត្វក្តាន់ដែលមានស្នែងបែកខ្នែងប្រាំពីរនេះមិនស្ថិតនៅក្នុងដីរបស់ខ្ញុំនៅឡើយទេ ឬប្រហែលដោយសារកត្តាផ្សេងទៀតដែលអាចរារាំងដល់ភាពជោគជ័យរបស់ខ្ញុំ ដូចជាអាកាសធាតុ និងទិសដៅខ្យល់ជាដើម។

ព្រះវិញ្ញាណដ៏វិសុទ្ធជ្រាបពីពេលវេលាសម្រាប់ការប្រមូលផលដ៏ជាក់លាក់នេះ ហើយទ្រង់បានដាក់ខ្ញុំនៅក្នុងជំហរដ៏ត្រឹមត្រូវ ក្នុងថ្ងៃដ៏ត្រឹមត្រូវ និងពេលវេលាដ៏ត្រឹមត្រូវដើម្បីប្រមូលផលសត្វក្តាន់ដ៏ជាក់លាក់មួយនោះ។

ខ្ញុំធ្លាប់ឮ និងឃើញកំហុសនេះជាញឹកញាប់។ «ហេ ហ្គារី ប្រសិនបើព្រះរាជ្យរបស់ព្រះជាម្ចាស់អាចនាំសត្វក្តាន់ចូលដូចអ្នកនិយាយមែននោះ ហេតុអ្វីអ្នកមិនចេញទៅសម្លាប់សត្វក្តាន់ដែលជាប់កំណត់ត្រាពិភពលោកដែលមានតម្លៃថ្លៃទៅ?» បាទ មិនអីទេ សំណួរនេះជាសំណួរដ៏ល្អ ហើយយើងត្រូវដោះស្រាយជាមួយវា។ ការនិយាយបែបនេះប្រៀបដូចជាអ៊ីមែលដែលខ្ញុំទទួលបានពីមនុស្សដែលចង់សងប្រាក់កម្ចីចំនួន ៥០០.០០០ដុល្លារ ហើយពួកគេប្រាប់ខ្ញុំថាពួកគេបានសាបព្រោះគ្រាប់ពូជដើម្បីសងវាក្នុងរយៈពេលប្រាំពីរថ្ងៃ។ នៅពេលដែលការនោះមិនបានកើតឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ ពួកគេបានធ្លាក់ទឹកចិត្ត ហើយសួរខ្ញុំថាហេតុអ្វីបានជាខ្ញុំមិនឃើញលុយនោះអ៊ីចឹង។ សំណួរទូទៅមួយទៀតដែលខ្ញុំបានឮគឺ «ហេតុអ្វីបានជាខ្ញុំមិនអាចសាបព្រោះគ្រាប់ពូជសម្រាប់ការឈ្នះឆ្នោត?»

**អនុញ្ញាតឱ្យខ្ញុំនិយាយពាក្យនេះម្តងទៀត ខ្ញុំគិតថាអ្នកត្រូវស្តាប់វាម្តងទៀត៖ ព្រះជាម្ចាស់មានផែនការ<u>របស់អ្នក</u>!**

ជាការប្រសើរណាស់ ខ្ញុំចង់ចាប់ផ្តើមនិយាយអំពីសំណួរដែលទាក់ទងជាមួយសត្វក្តាន់ជាប់កំណត់ត្រាជាមុនសិន។ បាទ សម្រាប់ខ្ញុំ ខ្ញុំជឿថាខ្ញុំអាចសម្លាប់សត្វក្តាន់

ជាប់កំណត់ត្រាដែលមានតម្លៃថ្លៃបាន ប្រសិនបើវាជាបំណងប្រាថ្នារបស់ខ្ញុំ ប៉ុន្តែវាមិនមែនជាបំណងប្រាថ្នាដែលខ្ញុំចង់បានទេ។ ជាធម្មតា ខ្ញុំបរបាញ់វាដើម្បីបានសាច់របស់វា ហើយខ្ញុំមិនមានការជំរុញចិត្តឱ្យបរបាញ់សត្វក្តាន់ដែលជាប់កំណត់ត្រានោះទេ។ ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលខ្ញុំមិនទទួលបានការជំរុញចិត្តឱ្យដេញតាមសត្វក្តាន់ជាប់កំណត់ត្រាពិតពលោក គឺដោយសារតែអ្វីដែលខ្ញុំទើបតែបានពន្យល់ដល់អ្នក៖ អ្នកនឹងមិនអាចចាប់បានត្រីបាឡែននៅក្នុងអាងងូតទឹករបស់អ្នកបានទេ។ សត្វក្តាន់ជាប់កំណត់ត្រាពិតពលោកមិនមាននៅក្នុងព្រៃដែលខ្ញុំបរបាញ់ទេ។ ប្រសិនបើខ្ញុំពិតជាចង់បានសត្វក្តាន់ប្រភេទនោះមែន នោះខ្ញុំដឹងថាខ្ញុំត្រូវទៅកន្លែងផ្សេងដើម្បីបរបាញ់។ ខ្ញុំប្រហែលជាត្រូវរៀនយុទ្ធសាស្ត្រថ្មីមួយចំនួនថែមទៀត ព្រោះថាសត្វក្តាន់ដែលជាប់កំណត់ត្រា ភាគច្រើនត្រូវបរបាញ់វានៅពេលយប់ ហើយវាមានទម្លាប់ពិសេសមួយចំនួនទៀត។ ខ្ញុំត្រូវធ្វើការស្រាវជ្រាវបន្ថែម ហើយអធិស្ឋានដើម្បីដឹងពីទីតាំងដែលអាចរកឃើញសត្វបែបនេះ។ ប៉ុន្តែ ខ្ញុំមិនចង់ពាក់ព័ន្ធជាមួយបញ្ហាទាំងអស់នោះទេ។ ខ្ញុំចូលចិត្តបរបាញ់នៅក្នុងព្រៃរបស់ខ្ញុំ។ ខ្ញុំចូលចិត្តដើរបរបាញ់ក្នុងទីធ្លាក្រោយផ្ទះរបស់ខ្ញុំ ហើយខ្ញុំបាញ់បានសត្វក្តាន់ល្អៗនៅក្នុងព្រៃផ្ទាល់ខ្លួនរបស់ខ្ញុំ។ ប៉ុន្តែដើម្បីឆ្លើយសំណួររបស់អ្នក ខ្ញុំជឿថាមនុស្សម្នាក់អាចមានជំនឿលើព្រះជាម្ចាស់សម្រាប់សត្វក្តាន់ប្រភេទនោះបាន ប៉ុន្តែត្រូវចាំពីអ្វីដែលខ្ញុំបាននិយាយកាលពីលើកមុន៖ កាលណាការប្រមូលផលកាន់តែប្លែក និងជាក់លាក់ នោះទីតាំង ពេលវេលា និងវិធីសាស្ត្រក៏កាន់តែសំខាន់ជាងមុនផងដែរ។

ជាធម្មតា ពេលដែលខ្ញុំទទួលបានអ៊ីមែលពីនរណាម្នាក់សួរខ្ញុំថា ហេតុអ្វីបានជាលុយមួយលានដុល្លារមិនចូលក្នុងកុងធានាគាររបស់ខ្ញុំក្នុងរយៈពេលប្រាំថ្ងៃ ខ្ញុំដឹងថាខ្ញុំប្រហែលជាមិនមែនកំពុងនិយាយជាមួយមនុស្សម្នាក់ដែលបានរៀនពីភាពខុសគ្នារវាងការមានជំនឿ និងការសន្មតនោះទេ។

វាដូចជាអ៊ីមែលមួយដែលខ្ញុំទទួលបានមួយថ្ងៃមុននេះ ដែលនិយាយថាពួកគេនឹងសាបព្រោះគ្រាប់ពូជក្នុងតម្លៃដប់លានដុល្លារក្នុងរយៈពេល៣០ថ្ងៃ ដែលពេលបច្ចុប្បន្ននេះពួកគេមិនមានសូម្បីតែម្ហូបអាហារ មិនបានបង់ថ្លៃផ្ទះជួលរបស់ពួកគេអស់រយៈពេលបីខែ ហើយក៏គ្មានការងារធ្វើផងដែរ។ ពួកគេកំពុងតែនៅក្រៅជំនឿដែលពួកគេបានអភិវឌ្ឍហើយ។

ដូច្នេះ ហ្គារី តើអ្នកនិយាយថាព្រះជាម្ចាស់មិនអាចផ្តល់ឱ្យនរណាម្នាក់ដប់លានដុល្លារបានទេ តើមែនទេ? ពិតណាស់ទ្រង់ពិតជាអាច។ អ្វីៗទាំងអស់គឺអាចទៅរួចជាមួយព្រះជាម្ចាស់។ សំណួរគឺមិនមែន «តើទ្រង់អាចទេ?» ប៉ុន្តែ «តើអ្នកមានជំនឿសម្រាប់ការនោះដែរឬទេ?» ប្រសិនបើជំនឿរបស់អ្នកមិនអាចនាំយកអាហារដែលអ្នកត្រូវការនៅថ្ងៃនេះផង នោះខ្ញុំក៏សង្ស័យថាអ្នកគ្មានជំនឿសម្រាប់ប្រាក់ដប់លានដុល្លារនៅពេលនេះក្នុងជីវិតរបស់អ្នកទេ។ ប៉ុន្តែអ្នកអាចទៅដល់ទីនោះបាន! អ្នកត្រូវចាប់ផ្តើមពីកន្លែងដែលអ្នកនៅ ហើយចាប់ផ្តើមរៀនពីរបៀបដែលជំនឿមានដំណើរការ ហើយពង្រីកសមត្ថភាពរបស់អ្នកក្នុងការគ្រប់គ្រងលើសពីអ្វីដែលអ្នកអាចគ្រប់គ្រងបាននាពេលបច្ចុប្បន្ននេះ។

## តើអ្នកអាចជឿថាអ្នកអាចឈ្នះឆ្នោតទេ?

ចុះចំណែកឆ្នោតវិញ តើវាយ៉ាងម៉េចដែរ?

អីយ៉ា តោះយើងនិយាយពីរឿងនេះវិញម្តង។ រង្វាន់ដែលទទួលបានពីឆ្នោតទាំងនេះកាន់តែកើនឡើងខ្ពស់ជាងមុនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ខ្ញុំចាំថាឆ្នាំមុនវាឡើងដល់ជិតមួយពាន់លានដុល្លារ! ខ្ញុំមិនដែលទិញសំបុត្រឆ្នោតទេក្នុងមួយជីវិតរបស់ខ្ញុំ ប៉ុន្តែលើកនេះពេលវាមានតម្លៃរហូតដល់មួយពាន់លានដុល្លារ ពួកយើងពីរបីនាក់នៅក្នុងការិយាល័យបាននិយាយថា «ហេ យ៉ាងហោចណាស់យើងទិញសំបុត្រពីរបីសន្លឹកទៅ»។ ខ្ញុំមិនបានគិតគូរវែងឆ្ងាយអីទេ ដូច្នេះខ្ញុំគ្រាន់តែគិតថា ខ្ញុំប្រហែលជា

អាចចាយលុយពីរបីដុល្លារដែរ។ ខ្ញុំដឹងហើយថា—ខ្ញុំមិនមានទំនុកចិត្តក្នុងការឈ្នះវាទេ—ប៉ុន្តែខ្ញុំគ្រាន់តែដាក់លុយពីរបីដុល្លារបស់ខ្ញុំនៅក្នុងធុងឆ្នោតនោះក៏បានដែរ។ ដូចមនុស្សភាគច្រើនធ្លាប់និយាយថា «នឹងមាននរណាម្នាក់ឈ្នះវាជាមិនខានទេ»។ ខ្ញុំក៏គិតផងដែរថា ទោះជានរណាឈ្នះបានមួយពាន់លានដុល្លារនេះក៏ដោយ ខ្ញុំមិនចង់ខកខានឱកាសយ៉ាងហោចណាស់បានដាក់ប្រាក់មួយដុល្លារដើម្បីផ្សងសំណាងទទួលបានវាដែរ។ មែនហើយ ខ្ញុំខ្មាសអៀនក្នុងការនិយាយថា ខ្ញុំពិតជាបានគិតយ៉ាងដូច្នោះមែន។

នៅយប់នោះ ព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់ខ្ញុំក្នុងសុបិនអំពីវា។ ទ្រង់បានមានបន្ទូលយ៉ាងសាមញ្ញក្នុងសុបិនរបស់ខ្ញុំថា «ការសន្យារបស់យើងទាំងអស់គឺជារបស់អ្នក!» «បាទ ព្រះអម្ចាស់ ខ្ញុំបានឮទ្រង់មានបន្ទូលយ៉ាងច្បាស់ណាស់។» «ទូលបង្គំយល់ហើយ។»។ ពិតមែនហើយ ទ្រង់បានកែតម្រង់ខ្ញុំ ប៉ុន្តែទ្រង់ក៏បានលើកទឹកចិត្តខ្ញុំផងដែរ។ ទ្រង់បានប្រាប់ខ្ញុំថា ខ្ញុំមិនត្រូវការឆ្នោតទេ ហើយប្រសិនបើខ្ញុំត្រូវការមួយពាន់លានដុល្លារមែន នោះទ្រង់នឹងផ្គត់ផ្គង់ឱ្យពេលដែលខ្ញុំត្រូវការ។ មានការសន្យាពីទ្រង់ជាង៧.០០០ ដែលខ្ញុំអាចទទួលបានយ៉ាងស្របច្បាប់ ហើយការសន្យាទាំងនោះវាលើសពីគ្រប់គ្រាន់ហើយ!

ឥលូវនេះ សូមត្រលប់ទៅឆ្លើយសំណួរដែលទាក់ទងជាមួយការសាបព្រោះដើម្បីឈ្នះឆ្នោត ឬការប្រកួតណាមួយវិញម្តង។ សម្រាប់ការទាំងនេះ អ្នកមិនមានដែនអំណាចគ្រប់គ្រងលើវាទេ។ ខ្ញុំអាចសាបព្រោះសម្រាប់សត្វក្ងាន់បាន ព្រោះសត្វក្ងាន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្ស។ ខ្ញុំមានដែនអំណាចគ្រប់គ្រងផ្លូវច្បាប់លើពួកវា។ ប៉ុន្តែ ខ្ញុំគ្មានដែនអំណាចគ្រប់គ្រងលើឆ្នោតទេ។ វាជាល្បែងនៃឱកាស។

## របៀបដឹងថាពេលណាអ្នកមិនមានជំនឿ

ការរៀនវិនិច្ឆ័យថាតើអ្នកមានជំនឿ ឬមិនមាន នឹងជួយអ្នកក្នុងការធ្វើការសម្រេចចិត្ត ហើយក៏ជួយអ្នកឱ្យដឹងថាពេលណាអ្នកមិនគួរធ្វើការសម្រេចចិត្ត

ប្រសិនបើអ្នកមានការភ័យខ្លាច។ ចូរចាំថា ពេលអ្នកមានជំនឿ អ្នកមានភាពជឿជាក់ មានការរំពឹងទុកថានឹងទទួលបាន និងពោរពេញដោយសន្តិភាព។ ខ្ញុំមិនមានទំនុកចិត្តទេ ពេលខ្ញុំចាប់ផ្តើមប្រមូលផលសត្វក្តាន់ឈ្មោលពានរង្វាន់ដំបូងរបស់ខ្ញុំ។ ខ្ញុំមិនមានជំនឿទេ។ តើអ្នកអាចប្រាប់បានទេថាពេលណាអ្នកមិនមានជំនឿ? ខ្ញុំសង្ឃឹមថាអ្នកអាចដឹងបាន។

ដូចដែលអ្នកបានដឹងហើយថាឌ្រិនដា និងខ្ញុំ ជាម្ចាស់ដីដ៏ស្រស់ស្អាតចំនួន ២៩ហិចតា ដែលមានព្រៃឈើ វាលតក់ និងវាលស្មៅ។ វាជាកន្លែងដ៏ល្អឥតខ្ចោះសម្រាប់បរបាញ់សត្វក្តាន់។ មានដំណាំដាំនៅជុំវិញដីរបស់យើង ហើយព្រៃឈើ និងវាលតក់គឺជាកន្លែងដែលទាក់ទាញសត្វក្តាន់ពីធម្មជាតិ។ ខ្ញុំបានសាងសង់ការិយាល័យរបស់ខ្ញុំនៅលើយានដ្ឋានរបស់យើង ដែលមានធ្នើសៀវភៅឈើ និងកន្លែងផ្តល់កម្តៅដល់បន្ទប់ដោយប្រើឧស្ម័ន។ វាប្រៀបដូចជារូងភ្នំសម្រាប់បុរស ដែលជាកន្លែងស្ងប់ស្ងាត់ កក់ក្តៅដែលខ្ញុំចូលចិត្តធ្វើការនៅទីនោះ។ អ្វីម្យ៉ាងដែលខ្វះនៅក្នុងបន្ទប់នោះគឺ រូបសត្វក្តាន់តាំងនៅលើតុរបស់ខ្ញុំ។ និយាយឱ្យត្រង់ទៅ ខ្ញុំមិនដែលចាប់អារម្មណ៍នឹងការបរបាញ់សត្វក្តាន់ដែលមានទំហំធំទេ ព្រោះខ្ញុំជាអ្នកប្រមាញ់ដើម្បីសាច់វាតែប៉ុណ្ណោះ ហើយខ្ញុំមិនដែលបាញ់បានសត្វក្តាន់ដែលមានទំហំធំល្មម ដើម្បីអាចយកវាទៅធ្វើជារូបតាំងបានដែរ។ ប៉ុន្តែ ពេលដែលខ្ញុំកាន់តែគិតអំពីរឿងនេះ ខ្ញុំក៏យល់ព្រមជាមួយឌ្រិនដា ព្រោះនាងជាអ្នកទទូចថា ខ្ញុំគួរបាញ់សត្វក្តាន់ធំជាងនេះ ដើម្បីយកវាធ្វើជារូបតាំងនៅក្នុងការិយាល័យរបស់ខ្ញុំ។

យើងបានរស់នៅលើដីរបស់យើងអស់រយៈពេលប្រាំឆ្នាំហើយ ពេលដែលយើងបានពិភាក្សាអំពីរឿងនេះ ហើយខ្ញុំមិនដែលឃើញសត្វក្តាន់ទំហំធំបែបនេះនៅលើដីរបស់ខ្ញុំទេ។ ខ្ញុំបានចេញទៅក្រៅគ្រប់រដូវកាលរបស់សត្វក្តាន់ ហើយបានបាញ់សត្វក្តាន់ដែលមានស្នែងបែកខ្នែងប្រាំបី ប៉ុន្តែមិនដែលបាញ់បានក្តាន់ដែលមានទំហំធំជាងនេះទេ។ ក៏ប៉ុន្តែឆ្នាំនោះ ខ្ញុំបានប្រាប់ឌ្រិនដាថា ខ្ញុំគិតថាខ្ញុំនឹងទៅរកសត្វក្តាន់ដែលមាន

ទំហំធំល្មម ដែលយើងអាចតាំងវាលើជញ្ជាំងបាន។ ជាថ្មីម្តងទៀត ខ្ញុំមិនដែលបានឃើញសត្វក្តាន់ធំនៅក្នុងព្រៃនោះទេ។ បង្អួចផ្ទះបាយរបស់យើងបែរមុខទៅព្រៃ និងទីវាល ប៉ុន្តែខ្ញុំមិនដែលបានឃើញវាទេ។

ប៉ុន្តែ ឌ្រិនដា និងខ្ញុំបានសាបព្រោះសម្រាប់សត្វក្តាន់ដ៏ធំមួយ។ ខ្ញុំបានសរសេរនៅលើសែកការសាបគ្រាប់ពូជរបស់ខ្ញុំថា ខ្ញុំកំពុងសាបព្រោះសម្រាប់សត្វក្តាន់ដែលមានស្នែងបែកខ្នែងចំនួន១០ ឬធំជាងនេះ។ យើងបានអធិស្ឋានលើសែកគ្រាប់ពូជនោះ ហើយខ្ញុំបានដាក់វានៅលើតុរបស់ខ្ញុំដើម្បីផ្ញើវាចេញទៅ។ ស្រោមសំបុត្រដាក់សែកនោះបាននៅទីនោះអស់រយៈពេលបីថ្ងៃ ហើយខ្ញុំនៅតែមិនអាចផ្ញើវាចេញទៅបានទេ។ ខ្ញុំបានដឹងថាខ្ញុំមិនមានជំនឿសម្រាប់សត្វក្តាន់ដែលមានស្នែងបែកខ្នែងចំនួន១០នោះទេ។ ខ្ញុំមានជំនឿសម្រាប់សត្វក្តាន់ដែលមានស្នែងបែកខ្នែងត្រឹមតែប្រាំបី ប្រាំមួយ ឬបួនប៉ុណ្ណោះពេញមួយថ្ងៃនោះ។ ប៉ុន្តែ ខ្ញុំមានបញ្ហាក្នុងការមើលឃើញសត្វក្តាន់ដ៏ធំ ជាមួយនឹងការធានានៃជំនឿដែលនិយាយថា «ខ្ញុំដឹង ខ្ញុំជឿជាក់ថា ខ្ញុំនឹងបាញ់បានសត្វក្តាន់ដែលមានស្នែងបែកខ្នែង១០ ឬធំជាងនេះពេលខ្ញុំចេញទៅក្រៅ»។ ខ្ញុំមានបទពិសោធគ្រប់គ្រាន់ជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលខ្ញុំអាចដឹងថា ខ្ញុំមិនមានជំនឿទេ។ ដូច្នេះ ខ្ញុំបានហែកសែកនោះចោល ហើយសរសេរសែកថ្មី ដែលនិយាយថា «សម្រាប់សត្វក្តាន់ដែលមានស្នែងបែកខ្នែងចំនួនបួន ឬធំជាងនេះ» ហើយក៏បានផ្ញើវាចេញទៅ។

**វាជារបស់អ្នកទាំងអស់ហើយ បងប្អូនអើយ គឺព្រះរាជ្យរបស់ព្រះជាម្ចាស់ទាំងមូល។ ព្រះជាម្ចាស់មិនអាចបន្ថែមអ្វីទៅលើអ្វីៗដែលទ្រង់បានប្រទានឱ្យអ្នករួចហើយនោះទេ។ អ្នកមានវា**

នៅយប់មុនពេលខ្ញុំចេញទៅក្រៅ ខ្ញុំបានប្រាប់ឌ្រិនដាពីអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំបានប្រាប់នាងថា៖ «ខ្ញុំមិនមានជំនឿសម្រាប់សត្វក្តាន់ដែលមានទំហំធំបែបនោះទេ»។ នាងបានមើលមកខ្ញុំ ហើយនិយាយថា «បងមានជំនឿសម្រាប់សត្វក្តាន់តូច តែខ្ញុំវិញ

ខ្ញុំមានជំនឿសម្រាប់សត្វក្តាន់ពានរង្វាន់។ ព្រះជាម្ចាស់អាចធ្វើកិច្ចការលើសពីអ្វីដែលបងសុំ ឬគិតទៅទៀត!»។

ពេលព្រឹកនោះមានសត្វកំប្រុក និងសត្វស្លាបនៅក្នុងព្រៃតាមធម្មតា ខណៈដែលក្លិនស្លឹកឈើជ្រុះបានធ្វើឱ្យខ្ញុំនឹកឃើញដល់ការប្រមាញ់សត្វក្តាន់ជាច្រើនដែលខ្ញុំធ្លាប់បានធ្វើពីមុនមក។ ខ្ញុំមិនបានអង្គុយនៅទីនោះយូរណាស់ណាទេ ប្រហែលជា២០នាទី ពេលដែលខ្ញុំបានឮសំឡេងសត្វក្តាន់ដើរកាត់ព្រៃ។ សត្វក្តាន់នោះកំពុងដើរតម្រង់មករកដើមឈើរបស់ខ្ញុំ ហើយខ្ញុំបានត្រៀមខ្លួនសម្រាប់ការបាញ់ប្រហារវា។ ពេលដែលសត្វក្តាន់នោះកាន់តែខិតជិតមកដល់ ខ្ញុំឃើញថាវាគឺជាសត្វក្តាន់មានស្នែងបែកខ្នែងចំនួនបួន ជាសត្វក្តាន់ដែលជាទូទៅខ្ញុំចង់បានវា ព្រោះសាច់ពួកវាញុំឆ្ងាញ់ខ្លាំងណាស់។ ពេលដែលសត្វក្តាន់នោះដើរមកដល់ចម្ងាយប្រហែល២៣ម៉ែត្រ ខ្ញុំក៏បាញ់ព្រួញខ្ញុំទៅ។ ខ្ញុំបានឃើញព្រួញរបស់ខ្ញុំបាញ់ចំក្រោយខ្នងរបស់វា ហើយខ្ញុំដឹងថា ខ្ញុំនឹងត្រូវដេញតាមវា។ សត្វក្តាន់នោះបានដើរកាត់ព្រៃ រួចលោតចូលក្នុងចម្ការពោតដែលនៅជាប់នឹងព្រៃនោះ ហើយខ្ញុំក៏មើលវាលែងឃើញ។ ខ្ញុំនៅតែអាចឮវារត់កាត់ចម្ការពោត ហើយដឹងថាវានៅមានកម្លាំងខ្លាំង ដែលខ្ញុំអាចត្រូវដេញតាមវារយៈពេលយូរបន្តទៀត។

ខ្ញុំបានរង់ចាំនៅលើដើមឈើប្រហែល២០នាទី ហើយបន្ទាប់មកក៏សម្រេចចិត្តចុះពីដើមឈើដើម្បីពិនិត្យមើលព្រួញរបស់ខ្ញុំ។ ប្រាកដណាស់ ខ្ញុំអាចប្រាប់បានថា ខ្ញុំពិតជាបាញ់ត្រូវសត្វក្តាន់នោះ ហើយខ្ញុំបានប្រទះឃើញដានស្នាមឈាម។ ពេលខ្ញុំដើរតាមដានឈាមនោះ ខ្ញុំទទួលបានការលើកទឹកចិត្ត ព្រោះវាមានឈាមល្អ។ ប៉ុន្តែបន្ទាប់ពីបានប្រហែល៨០ម៉ែត្រ មក ដានឈាមនោះបានស្ងួតអស់។ ខ្ញុំខំរកមើលហើយរកមើលទៀត ប៉ុន្តែរកមើលមិនឃើញដានឈាមមួយដំណក់ទៀតសោះ។ បន្ទាប់ពីបានរកមើលអស់រយៈពេលពីរម៉ោងក្រោយមក ខ្ញុំបានដឹងថាសត្វក្តាន់នោះបានរត់បាត់ហើយ។ ខ្ញុំមានការខកចិត្តយ៉ាងខ្លាំង។ ទីមួយ ខ្ញុំមិនដែលមានចិត្តចង់ធ្វើឱ្យសត្វក្តាន់រងរបួស ហើយបាត់វាទេ ទីពីរ ខ្ញុំខកចិត្តនឹងការបាញ់របស់ខ្ញុំ។

ខ្ញុំបានឈរនៅក្នុងចម្ការពោត ហើយក៏ចាប់ផ្តើមដើរត្រលប់ទៅផ្ទះវិញ ពេលនោះខ្ញុំក៏មានគំនិតមួយ។ *ខ្ញុំនៅតែមានឱកាស។ ខ្ញុំអាចជួបសត្វក្តាន់មួយនៅតាមផ្លូវទៅផ្ទះវិញ ពេលខ្ញុំឆ្លងកាត់វាលពោត និងបន្ទាប់មកឆ្លងកាត់តំបន់វាលស្មៅ។* ខ្ញុំបានដាក់ផ្លែព្រួញក្នុងស្នារបស់ខ្ញុំ។ ពេលខ្ញុំដើរយឺតៗតាមវាលស្មៅនៅក្នុងចម្ការពោត រំពេចនោះស្រាប់តែមានសត្វក្តាន់មួយក្បាលបានលោតមកចំមុខខ្ញុំ។ ដោយមិនដឹងថាខ្ញុំជាអ្វី សត្វក្តាន់នោះក៏ឈប់ ហើយងាកមើលក្រោយ។ ដោយសារខ្ញុំបានស្លៀកសម្លៀកបំពាក់បន្លំខ្លួនស្រដៀងស្លឹកឈើ សត្វក្តាន់ដែលខ្ញុំបានឃើញគឺជាសត្វក្តាន់ឈ្មោល វាស្ទាក់ស្ទើរ ព្រោះវាមិនអាចយល់ថាខ្ញុំជាអ្វីទេ។ រឿងនេះបានកើតឡើងក្នុងរយៈពេលតែមួយពព្រិចភ្នែកតែប៉ុណ្ណោះ។ ខ្ញុំអាចឃើញស្នែងរបស់វា ប៉ុន្តែខ្ញុំមិនអាចប្រាប់បានថាវាមានទំហំប៉ុនណា ឬមានស្នែងបែកខ្នែងប៉ុន្មានទេ។ ខ្ញុំដឹងថា ខ្ញុំមានពេលសម្រាកមួយវិនាទី ដើម្បីរៀបចំគំនិតរបស់ខ្ញុំអំពីសត្វក្តាន់នោះ។ វានៅឆ្ងាយលើសពីចម្ងាយស្នាធម្មតារបស់ខ្ញុំ ដែលមានចម្ងាយប្រហែល៥០ម៉ែត្រ ហើយវាឈរនៅពីមុខខ្ញុំ។ ខ្ញុំបានទាញស្នាឡើងយ៉ាងលឿន ហើយតម្រង់ទៅលើខ្នងរបស់វា ហើយក៏ប្រលែងព្រួញរបស់ខ្ញុំទៅ។ សត្វក្តាន់នោះបានដួលចុះភ្លាមៗ ពេលដែលព្រួញរបស់ខ្ញុំបានបាញ់ត្រូវចំវា។ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង។ តើការនេះជាការពិត មែនទេ?

ពេលខ្ញុំដើរទៅរកសត្វក្តាន់នោះ ខ្ញុំបាននិយាយដំបូងគេថា «ជំនឿរបស់ឌ្រិនដា!» សត្វក្តាន់នេះធំណាស់! ខ្ញុំបានរាប់មើលបានមានបែកខ្នែង២៦ ហើយវាក៏មានស្នែងធំដែរ។ ខ្ញុំមិនដែលឃើញសត្វក្តាន់ធំដល់កម្រិតនេះពីមុនមកទេ។ ជាការពិតណាស់ ខ្ញុំពិតជារំភើបដែលបាញ់បានក្តាន់មួយនោះ។ ដូចដែលអ្នកអាចទាយត្រូវហើយថា ឥលូវនេះសត្វក្តាន់នេះគឺនៅលើតុរបស់ខ្ញុំក្នុងការិយាល័យរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំចង់និយាយពីក្តាន់នេះបន្តិច។ តើវាបង្ហាញខ្លួនដោយរបៀបណា ឬដោយសារហេតុអ្វីទៅ?

ក្តាន់ដែលមានស្នែងបែកខ្នែងចំនួនបួនបានបង្ហាញខ្លួនឱ្យខ្ញុំឃើញទាន់ពេលវេលា ទោះបីជាខ្ញុំមិនបានបាញ់វាឱ្យដួលចុះក៏ដោយ។ ប៉ុន្តែឌ្រិនដាបាននិយាយថា នាង

ជឿថាខ្ញុំនឹងទទួលបានសត្វក្ដាន់ពានរង្វាន់មួយនេះ។ ឥលូវនេះ នាងមានប្រៀបជាងខ្ញុំ។ នាងមិនមែនជាអ្នកបរបាញ់សត្វក្ដាន់ដូចខ្ញុំទេ ហើយសម្រាប់នាង សត្វក្ដាន់ពានរង្វាន់គួរតែមានភាពងាយស្រួលក្នុងការបរបាញ់ដូចជាសត្វក្ដាន់ស្នែងបែកខ្នែងចំនួនបួនអីចឹងដែរ។ សម្រាប់នាង សត្វក្ដាន់ទាំងនោះទោះជាទំហំប៉ុនណាក៏ដោយ ក៏ពួកវានៅតែជាសត្វក្ដាន់ដូចតែគ្នាទេ។ ដោយសារតែនាងមិនមែនជាអ្នកបរបាញ់ នាងគ្មានរូបភាពប្រឆាំងនឹងជំនឿរបស់នាងទេ។ ខ្ញុំមិនដែលធ្លាប់ឃើញសត្វក្ដាន់ដែលមានស្នែងបែកខ្នែងប្រាំបីនៅលើដីរបស់ខ្ញុំទេ ប៉ុន្តែជំនឿរបស់នាងមិនផ្អែកលើអ្វីដែលមានលើដីរបស់ពួកយើងទេ។ នាងជឿថាព្រះជាម្ចាស់អាចនាំវាឱ្យមកដល់ដីរបស់ពួកយើងបាន។

ការបរបាញ់នេះបានកើតឡើងក្នុងរដូវបង្កាត់ពូជសត្វក្ដាន់ ហើយសត្វក្ដាន់អាចធ្វើដំណើររាប់សិបគីឡូម៉ែត្រដើម្បីស្វែងរកក្ដាន់ញីដែលជាដៃគូបង្កាត់ពូជរបស់វា។ ដូច្នេះ វាអាចមានឱកាសក្នុងការឃើញសត្វក្ដាន់ ដែលជាធម្មតាអ្នកមិនធ្លាប់ឃើញវានៅលើដីរបស់អ្នក ដូចក្នុងករណីខ្ញុំដែរ។

## ភាពជាដៃគូក្នុងជំនឿ

ជំនឿរបស់ឌ្រិនដា បាននាំសត្វក្ដាន់ដ៏ធំមួយក្បាលនេះមក ទោះបីជាខ្ញុំគ្មានជំនឿថានឹងបានសត្វក្ដាន់ពានរង្វាន់នេះក៏ដោយ។ ខ្ញុំចង់ឱ្យអ្នកអានវាម្ដងទៀត។ ខ្ញុំគ្មានជំនឿថានឹងបានសត្វក្ដាន់ពានរង្វាន់នេះទេ! ខ្ញុំដឹងថាអ្នកកំពុងតែគិតពីអ្វីនៅពេលនេះ។ «សូមផ្អាកបន្តិចសិន ហ្គារី។ ខ្ញុំរៀងច្រឡំបន្តិចហើយឥលូវនេះ។ ប្រសិនបើអ្នកគ្មានជំនឿថានឹងបានសត្វក្ដាន់នេះទេ ចុះហេតុអ្វីបានជាវាបានបង្ហាញខ្លួនឱ្យអ្នកឃើញ?» សូមអនុញ្ញាតឱ្យខ្ញុំពន្យល់អ្នក។

*ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្ដាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួន របស់គេ។ ព្រះ*

*យេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឱ្យគាត់ចេញទូក ទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដាជនពីក្នុងទូកនោះ។ លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថាៈ « ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ» ។ កស៊ីម៉ូនតបទៅព្រះយេស៊ូវិញថាៈ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ» ។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្តិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

— លូកា ៥:១-៧

ខ្ញុំដឹងថាយើងបានមើលរឿងនេះមុននេះរួចហើយ ប៉ុន្តែខ្ញុំចង់ចង្អុលបង្ហាញអ្វីមួយនៅទីនេះដែលនឹងឆ្លើយសំណួររបស់យើង។

*គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ **<u>គេបក់ដៃហៅមិត្តភក្តិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។</u>***

ខ្ញុំចង់សួរអ្នកសំណួរមួយ។ តើលោកយ៉ាកុប និងលោកយ៉ូហានបានប្រើជំនឿរបស់ពួកគេប៉ុនណាដែរ ដើម្បីបំពេញទូករបស់ពួកគេដោយត្រីដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ? ចម្លើយគឺគ្មានទេ! ប្រសិនបើអ្នកនៅចាំបាន ទូករបស់លោកពេត្រុស ក៏ដូចជាទូករបស់លោកយ៉ាកុប និងលោកយ៉ូហានបាននៅលើច្រាំង ហើយពួកគេកំពុងសម្អាតអួន ពេលដែលព្រះយេស៊ូបានយាងមក។ ព្រះយេស៊ូបានសុំទូករបស់លោកពេត្រុសយកទៅប្រើ ដើម្បីបង្រៀនពួកបណ្ដាជន ហើយបន្ទាប់មកបានប្រាប់លោកឱ្យទម្លាក់អួន

ក្នុងទឹកជ្រៅដើម្បីចាប់ត្រី។ លទ្ធផលគឺថាពេត្រុសចាប់បានត្រីដ៏ច្រើនសន្ធឹកសន្ធាប់ ដែលអួនរបស់គាត់ចាប់ផ្ដើមរហែក ហើយទូករបស់គាត់ក៏ចាប់ផ្ដើមលិច។ លោកពេត្រុសបានហៅដៃគូរបស់គាត់ដែលនៅមាត់ច្រាំងនោះឱ្យមកជួយយកត្រី។ ទូករបស់ពួកគេបានពេញដូចទូករបស់លោកពេត្រុសដែរ រហូតដល់ត្រីហៀរចេញក្រៅទូក។ សំណួរដែលខ្ញុំចង់សួរអ្នកគឺ «តើលោកយ៉ាកុប និងលោកយ៉ូហានបានប្រើជំនឿរបស់ពួកគេប៉ុនណាដែរ ដើម្បីឱ្យទូករបស់ពួកគេបានពោរពេញទៅដោយត្រី?» ចម្លើយគឺគ្មានទេ។ ចុះហេតុអ្វីបានជាទូករបស់ពួកគេចាប់បានត្រីសន្ធឹកសន្ធាប់ដូចលោកពេត្រុសដែរ? អត្ថបទគម្ពីរនេះបានឆ្លើយសំណួរនេះ វានិយាយថាពួកគេគឺជាដៃគូគ្នា។

**ខ្ញុំតែងតែនិយាយថា អាថិកំបាំងរបស់ព្រះជាម្ចាស់ត្រូវបានលាក់សម្រាប់អ្នក មិនមែនលាក់ពីអ្នកទេ! មារសាតាំងរស់នៅក្នុងភាពងងឹត ហើយវាមិនបានដឹងពីផែនការរបស់ព្រះជាម្ចាស់**

និយមន័យនៃពាក្យ «ដៃគូ» នៅក្នុងវចនានុក្រមអង់គ្លេសខូលីនគឺ៖ «បុគ្គលដែលចែករំលែក ឬជាប់ពាក់ព័ន្ធជាមួយមនុស្សម្នាក់ទៀតនៅក្នុងសកម្មភាព ឬកិច្ចខិតខំប្រឹងប្រែងណាមួយ។ ជាធម្មតា មានការចែករំលែកទាំងភាពប្រថុយប្រថាន និងប្រាក់ចំណេញផងដែរ។»

ភាពជាដៃគូ គឺជានីតិបុគ្គល និងភាគហ៊ុននៅក្នុងភាពប្រថុយប្រថាន ការចំណាយ និងប្រាក់ចំណេញនៃអាជីវកម្មមួយ។ ដូច្នេះ ពេលដែលលោកពេត្រុសធ្វើតាមព្រះយេស៊ូដោយជំនឿ គាត់ពិតជាបានឱ្យព្រះយេស៊ូខ្ចីលុយអាជីវកម្មក្នុងន័យផ្លូវច្បាប់ មិនមែនត្រឹមតែទូកនោះទេ។ តាមន័យបច្ចេកទេស លោកយ៉ាកុប និងលោកយ៉ូហានក៏ជាម្ចាស់មួយផ្នែកនៃទូកដែលលោកពេត្រុសបានអនុញ្ញាតឱ្យព្រះយេស៊ូប្រើដែរ ហើយដោយសារតែដូច្នេះហើយ ទើបទូកទាំងពីររបស់ពួកគេក៏ពេញដោយត្រីដូចគ្នាផងដែរ។ ដូច្នេះ តើជំនឿរបស់អ្នកណាដែលបានប្រមូលផលនោះ? តាមភាពជាក់ស្ដែង វាជាជំនឿរបស់លោកពេត្រុស។ គាត់គឺជាអ្នកដែលបាន

និយាយថា «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែបើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។

ដូច្នេះ លោកយ៉ាកុប និងលោកយ៉ូហានបានច្រូតផលដូចគ្នានឹងលោកពេត្រុសដែរ ទោះបីពួកគេមិនបានប្រើជំនឿរបស់ពួកគេនៅក្នុងស្ថានភាពនោះក៏ដោយ។ ដូច្នេះ វាក៏ដូចគ្នាជាមួយគ្រិនដាផងដែរ ។ យើងជាដៃគូ ហើយយើងជាមនុស្សតែមួយ។ ជំនឿរបស់នាងបាននាំសត្វក្តាន់នោះមកក្នុងថ្ងៃនោះ។ អ្នកអាចឃើញថាគំនិតនៃភាពជាដៃគូនេះគឺជាគោលការណ៍ខាងវិញ្ញាណដ៏មានឥទ្ធិពល ដូចដែលយើងទើបតែបានឃើញនៅក្នុងរឿងនេះអ៊ីចឹងដែរ។ លោកប៉ូលបាននិយាយអំពីគោលការណ៍នៃភាពជាដៃគូនេះនៅក្នុងសៀវភៅភីលីព។

> *ពេលណាខ្ញុំនឹកគិតដល់បងប្អូន ខ្ញុំតែងតែអរព្រះគុណព្រះជាម្ចាស់របស់ខ្ញុំជានិច្ច គឺគ្រប់ពេល ខ្ញុំទូលអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនទាំងអស់គ្នា ខ្ញុំទូលអង្វរដោយចិត្តរីករាយជាដរាប ព្រោះបងប្អូនរួមចំណែកក្នុងការផ្សាយដំណឹងល្អ តាំងពីថ្ងៃដំបូង រហូតមកទល់សព្វថ្ងៃ។ ខ្ញុំជឿជាក់ថា ព្រះអង្គដែលបានចាប់ផ្តើមធ្វើការល្អនៅក្នុងបងប្អូន ទ្រង់ក៏នឹងបង្ហើយការនេះរហូតដល់ថ្ងៃព្រះគ្រិស្តយេស៊ូយាងមក។*
>
> *ខ្ញុំមានចិត្តគំនិតបែបនេះចំពោះបងប្អូនទាំងអស់គ្នា ពិតជាត្រឹមត្រូវមែន ព្រោះចិត្តខ្ញុំនៅជាប់ជំពាក់នឹងបងប្អូនជានិច្ច ហើយទោះបីខ្ញុំនៅជាប់ឃុំឃាំងក្តី ឬពេលខ្ញុំនិយាយ និងពង្រឹងដំណឹងល្អក្តី បងប្អូនទាំងអស់គ្នា ក៏បានរួមចំណែកជាមួយខ្ញុំក្នុងកិច្ចការដែលព្រះជាម្ចាស់ប្រណីសន្តោសឱ្យខ្ញុំបំពេញនេះដែរ*។
>
> — ភីលីព ៣:១-៧

លោកប៉ូលនិយាយថា គាត់នឹកចាំពីក្រុមជំនុំនៅក្រុងភីលីពដោយចិត្តរីករាយដោយសារពួកគេបន្តសហការជាមួយកិច្ចការបម្រើការផ្សាយដំណឹងល្អរបស់គាត់។

គាត់បានបន្តថា ដោយសារតែភាពជាដៃគូរបស់ពួកគេ ឥលូវនេះពួកគេចូលរួមក្នុងព្រះគុណរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងកិច្ចការបម្រើរបស់គាត់។ ព្រះគុណគឺជាការពង្រឹងអំណាចរបស់ព្រះជាម្ចាស់ ឬសមត្ថភាពរបស់ព្រះជាម្ចាស់ ដែលមានលើលោកប៉ូល ដើម្បីសម្រេចកិច្ចការរបស់គាត់។ ក្រុមជំនុំនៅក្រុងភីលីពកំពុងចែករំលែកការចំណាយនៃកិច្ចការនេះ ហើយដូចលោកយ៉ាកុប និងលោកយ៉ូហានដែរ ពួកគេក៏បានចែករំលែកនៅក្នុងការចាក់ប្រេងតាំង និងព្រះគុណដែលមាននៅក្នុងកិច្ចការនោះដែរ។ សូមចូលទៅជំពូកទី៩ នោះអ្នកនឹងឃើញលទ្ធផលដ៏អស្ចារ្យនៃភាពជាដៃគូនេះ។

> *ទោះជាយ៉ាងណាក្តី បងប្អូនរួមជាមួយខ្ញុំក្នុងពេលខ្ញុំមានទុក្ខវេទនាដូច្នេះ ជាការប្រសើរណាស់។បងប្អូននៅក្រុងភីលីពអើយ បងប្អូនជ្រាបស្រាប់ហើយថា តាំងពីខ្ញុំបានចាប់ផ្ដើមផ្សព្វផ្សាយដំណឹងល្អ គឺតាំងពីខ្ញុំបានចាកចេញពីស្រុកម៉ាសេដូនមកនោះ ក្រៅពីបងប្អូន គ្មានក្រុមជំនុំណាបានជួយខ្ញុំ ក្នុងការចំណាយ ឬចំណូលឡើយ។ កាលខ្ញុំនៅក្រុងថេស្សាឡូនិក បងប្អូនបានផ្ញើប្រាក់ទៅជួយតាមសេចក្ដីត្រូវការរបស់ខ្ញុំដល់ទៅពីរបីលើក។ ត្រង់ណេះ មិនមែនមានន័យថាខ្ញុំប្រាថ្នាចង់បានជំនួយពីបងប្អូនទេ តែខ្ញុំចង់ឱ្យបងប្អូនបានទទួលព្រះពរដ៏បរិបូរ។ ខ្ញុំបានទទួលសព្វគ្រប់ទាំងអស់ហើយ ហើយខ្ញុំមានបរិបូរថែមទៀត ឥលូវនេះខ្ញុំមានរឹតតែច្រើន ដោយបានទទួលអំណោយពីបងប្អូនតាមរយៈលោកអេប៉ាប្រូឌីត។ អំណោយទាំងនេះប្រៀបបីដូចជាក្លិនក្រអូបឈ្ងុយឈ្ងប់ ជាយញ្ញបូជាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ និងយល់ព្រមទទួល។ <u>ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។</u>*
>
> — ភីលីព ៤:១៤-១៩

សូមយកចិត្តទុកដាក់ចំពោះអ្វីដែលលោកប៉ូលបាននិយាយទៅកាន់ក្រុមជំនុំនៅក្រុងភីលីព៖ «ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន»។

សូមកត់សម្គាល់ថា លោកប៉ូលមិនបាននិយាយថា៖ «ព្រះរបស់អ្នកនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ដោយសារបងប្អូនមានចិត្តសប្បុរសចំពោះខ្ញុំ»ទេ។ ទេ! គាត់បាននិយាយថា៖ «ឥលូវនេះ ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន!»។អ្នកឃើញទេ លោកភីលីពគឺជាដៃគូជាមួយលោកប៉ូល ហើយក្នុងនាមជាដៃគូ ពួកគេបានចែករំលែកនៅក្នុងព្រះគុណលើការចាត់តាំងរបស់លោកប៉ូល។ ឥលូវនេះ ដូចដែលលោកយ៉ាកុប និងលោកយ៉ូហានបានចាប់ត្រីទាំងអស់នោះបាន ដោយសារជំនឿរបស់លោកពេត្រុស លោកប៉ូលកំពុងប្រកាសថា សេចក្ដីត្រូវការគ្រប់យ៉ាងរបស់ពួកគេនឹងត្រូវបានបំពេញ ដោយសារជំនឿរបស់គាត់! ខ្ញុំសង្ឃឹមថាអ្នកអាចឃើញអត្ថប្រយោជន៍នៃគោលការណ៍មួយនេះ។

ឧបមាថាអ្នកត្រូវការឡានមួយ ហើយអ្នកជាដៃគូព័ន្ធកិច្ចជាមួយពួកយើង។

ឧបមាថាឡាននោះមានតម្លៃ ៣០.០០០ដុល្លារ។ ឥលូវនេះ ពេលដែលអ្នកសាបព្រោះចូលទៅក្នុង Garykeesee.com អ្នកនឹងយល់ថាភាពជាដៃគូមានន័យយ៉ាងដូចម្ដេច។ អ្នកបានចូលរួមនៅក្នុងការចាក់ប្រេងតាំង និងព្រះគុណរបស់ព្រះជាម្ចាស់លើព័ន្ធកិច្ចរបស់យើង។ ក្នុងនាមជាព័ន្ធកិច្ចមួយ យើងអាចយល់ព្រមយ៉ាងងាយស្រួលចំពោះទឹកប្រាក់ ៣០.០០០ដុល្លារ ព្រោះយើងបានឆ្លងកាត់តម្រូវការដែលមានចំនួនទឹកប្រាក់ ៣០.០០០ដុល្លារ យូរមកហើយ។ យើងអាចមានជំនឿយ៉ាងងាយស្រួលសម្រាប់ចំនួនទឹកប្រាក់ ៣០.០០០ដុល្លារ ដោយសារយើងចំណាយរាប់លានដុល្លារក្នុងមួយឆ្នាំពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ កាលពីពេលមុន ខ្ញុំអាចនៅចាំថា ខ្ញុំត្រូវប្រើជំនឿសម្រាប់ទឹកប្រាក់ ៣០.០០០ ដុល្លារ ហើយនៅពេលនោះចំនួនទឹកប្រាក់ប៉ុណ្ណឹងប្រៀបដូចជាភ្នំដ៏ធំមួយសម្រាប់ពួកយើងអ៊ីចឹងដែរ។ ដូច្នេះ ប្រសិនបើអ្នកសួរខ្ញុំថា តើខ្ញុំអាចជឿព្រះជាម្ចាស់សម្រាប់ទឹកប្រាក់ចំនួន ៣០.០០០ ដុល្លារទេ នោះចម្លើយរបស់ខ្ញុំគឺ ពិតប្រាកដណាស់»។ ដូច្នេះ ដូចលោកប៉ូលដែរ ពេលដែលយើងព្រមព្រៀងគ្នា ហើយយើងជាដៃគូជាមួយ

គ្នា ខ្ញុំអាចប្រកាសថា តម្រូវការរបស់អ្នកត្រូវបានបំពេញ មិនមែនដោយសារជំនឿរបស់អ្នកទេ ប៉ុន្តែដោយសារជំនឿរបស់ខ្ញុំ។

## ការជ្រើសរើសដៃគូយុទ្ធសាស្ត្រ

ដូច្នេះ ខ្ញុំចង់ចាប់ផ្ដើមដោយដាក់ច្បាប់មូលដ្ឋានមួយចំនួននៅទីនេះ ដោយសួរអ្នកនូវសំណួរមួយជាមុនសិន។ ប្រសិនបើអ្នកនឹងចាប់ផ្ដើមក្រុមហ៊ុនកុំព្យូទ័រមួយ តើអ្នកចង់បានមនុស្សម្នាក់ដែលទើបតែរៀនថ្នាក់វិទ្យាសាស្ត្រកុំព្យូទ័រឆ្នាំទី១ ដែលមិនមានលុយ ធ្វើជាដៃគូរបស់អ្នក ឬអ្នកចង់បានមនុស្សម្នាក់ដែលបានបង្កើតអាជីវកម្មកុំព្យូទ័រតម្លៃរាប់លានដុល្លារ ហើយមានលុយច្រើន ដែលអាចជួយដល់ការចាប់ផ្ដើមក្រុមហ៊ុនរបស់អ្នកបាន? ជាការពិតណាស់ អាចមានជម្រើសច្រើននៅទីនេះ ហើយខ្ញុំគ្រាន់តែចង់លើកនេះរឿងឡើងជាឧទាហរណ៍សម្រាប់អ្នកតែប៉ុណ្ណោះទេ។ ប៉ុន្តែ ខ្ញុំគិតថាជម្រើសដ៏ជាក់ស្តែងមួយ គឺអ្នកនឹងចង់បានមនុស្សម្នាក់ដែលមានបទពិសោធ មានកំណត់ត្រាច្បាស់លាស់ ហើយនឹងមិនដាច់ឃ៉ៃទេ!

ជាការពិតណាស់ វាដូចគ្នាដែរ ពេលដែលអ្នកចង់សាបព្រោះក្នុងភាពជាដៃគូជាមួយព័ន្ធកិច្ចណាមួយ។ សូមកុំភ័ន្តច្រឡំជាមួយអ្វីដែលខ្ញុំកំពុងនិយាយនៅពេលនេះជាមួយពេលដែលព្រះជាម្ចាស់ដឹកនាំអ្នកដោយផ្ទាល់ដើម្បីចាប់ដៃគូជាមួយនរណាម្នាក់។ ការដឹកនាំបែបនេះវាលើសពីអ្វីដែលខ្ញុំកំពុងនិយាយនៅពេលនេះ។ ជាច្រើនដង ព្រះជាម្ចាស់នឹងដឹកនាំអ្នកឱ្យធ្វើជាដៃគូជាមួយកិច្ចការរបស់ទ្រង់ ប៉ុន្តែពេលខ្លះអ្នកក៏ត្រូវជ្រើសរើសផងដែរ។ ខ្ញុំកំពុងតែនិយាយ ជាពិសេសនៅពេលនេះ អំពីការសាបព្រោះដែលជាជម្រើសដែលអ្នកចង់ធ្វើ ដោយសារអ្នកចង់សាបព្រោះព្រោះ ព្រោះអ្នកចង់ផ្លាស់ទីទៅកាន់កម្រិតបន្ទាប់ទៀត។ សម្រាប់ខ្ញុំ ខ្ញុំសាបព្រោះនៅក្នុងកិច្ចការដែលខ្ញុំមានចិត្តជឿជាក់ ក្នុងគោលបំណងពន្លឿនថវិកាដែលខ្ញុំត្រូវការក្នុងជីវិតរបស់ខ្ញុំ។ ច្បាប់មួយដែលខ្ញុំមិនដែលបំបែក គឺខ្ញុំតែងតែសាបព្រោះក្នុងកិច្ចការដែលយល់ពីជំនឿ និងការព្រមព្រៀង លុះត្រាតែខ្ញុំសាបព្រោះដល់ជនក្រីក្រ ឬអ្នកខ្វះខាត។ ជាការពិតណាស់

យើងមិនអាចរំពឹងថាអ្នកក្រ និងអ្នកខ្វះខាតអាចយល់ដឹងអំពីជំនឿនោះទេ។ យើងសាបព្រោះសេចក្ដីស្រលាញ់ដល់ជនក្រីក្រ និងអ្នកខ្វះខាត ហើយព្រះជាម្ចាស់នឹងតបសងមកយើងវិញ។ ជាថ្មីម្ដងទៀត ការសាបព្រោះដល់អ្នកក្រីក្រ គឺជាប្រភេទនៃការសាបព្រោះមួយទៀតខុសពីអ្វីដែលយើងកំពុងតែនិយាយនៅទីនេះ។ ចំណុចមួយទៀតដែលខ្ញុំនឹងរកមើលពេលខ្ញុំសាបព្រោះ គឺខ្ញុំស្វែងរកកិច្ចការរបស់ព្រះជាម្ចាស់ដែលមានផលដូចអ្វីដែលខ្ញុំកំពុងជឿព្រះជាម្ចាស់សម្រាប់ខ្លួនខ្ញុំផ្ទាល់។

ឧទាហរណ៍ ក្រុមហ៊ុនរបស់ខ្ញុំមានយន្តហោះពីរគ្រឿង។ មុនពេលដែលខ្ញុំទិញយន្តហោះមួយក្នុងចំណោមយន្តហោះទាំងពីរគ្រឿងនោះ ខ្ញុំបានសាបព្រោះក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ដែលជាព័ន្ធកិច្ចដែលខ្ញុំបានដឹងថាបានចំណាយលុយរាប់លានដុល្លារសម្រាប់យន្តហោះជាច្រើនកាលពីអតីតកាល។ ពេលដែលខ្ញុំនិយាយថាច្រើន ខ្ញុំចង់មានន័យថាវាពិតជាច្រើនពិតមែន ហើយយន្តហោះទាំងអស់នោះត្រូវបានទិញជាសាច់ប្រាក់សុទ្ធ។ មានលទ្ធផលជាផលផ្លែដែលបង្ហាញឡើងជាយន្តហោះ។ ខ្ញុំបានដឹងថា ពួកគេអាចយល់ស្របជាមួយខ្ញុំយ៉ាងងាយស្រួលសម្រាប់យន្តហោះមួយគ្រឿង ហើយពួកយើងមានជំនឿសម្រាប់ឱ្យវាកើតឡើង។ ខ្ញុំនឹងមិនចាប់ដៃគូជាមួយព័ន្ធកិច្ចណាដែលនិយាយថា យន្តហោះមានតម្លៃថ្លៃពេក ឬខ្ញុំមិនគួរធ្វើជាម្ចាស់វានោះទេ។ ព្រោះថាការនិយាយបែបនោះមិនមែនជាកិច្ចព្រមព្រៀងទេ។ ខ្ញុំចង់មានឯកភាពជាមួយព័ន្ធកិច្ចមួយ ដែលអាចយល់ថាខ្ញុំកំពុងតែនៅកន្លែងណា អាចយល់ពីខ្ញុំដែលកំពុងតែជឿព្រះជាម្ចាស់សម្រាប់យន្តហោះមួយដែលខ្ញុំចង់បាន ហើយក៏មានផលផ្លែដែលអាចបញ្ជាក់ថាពួកគេក៏ធ្លាប់ទទួលបានយន្តហោះពីព្រះជាម្ចាស់ផងដែរ។

ខ្ញុំធ្លាប់បានធ្វើជាអ្នកបើកបរយន្តហោះតាំងពីខ្ញុំមានអាយុ១៩ឆ្នាំ ហើយបានរៀនហោះហើរចេញពីផ្លូវក្រួសប្រវែងប្រហែលមួយគីឡូម៉ែត្រ នៅស្រុករបស់ខ្ញុំ។ ខ្ញុំបានជួលយន្តហោះគេជិះស្ទើរមួយជីវិតរបស់ខ្ញុំហើយ រហូតដល់ថ្ងៃមួយ ខ្ញុំបានគិតថា *ហេតុះវាយ៉ាងម៉េចដែរ? ប្រសិនបើខ្ញុំគ្រាន់តែសាបព្រោះគ្រាប់ពូជមួយ ហើយជឿព្រះជា*

*ម្ចាស់សម្រាប់យន្តហោះផ្ទាល់ខ្លួនរបស់ខ្ញុំ។* មែនហើយ ហើយវាជាអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំបានដឹងពីយន្តហោះដែលខ្ញុំនឹងសាបព្រោះ។ ដូច្នេះ ខ្ញុំបានសរសេរយន្តហោះដ៏ជាក់លាក់មួយនោះនៅលើសែករបស់ខ្ញុំ ហើយឌ្រិនដា និងខ្ញុំបានយល់ព្រមអំពីវា។ យើងបានផ្ញើសែកនោះទៅព័ន្ធកិច្ចមួយដែលខ្ញុំទើបតែបាននិយាយនៅខាងលើ។

ប្រហែលមួយខែបានកន្លងផុតទៅហើយ ហើយខ្ញុំបានទៅជួបគ្រូពេទ្យជាប្រចាំ។ ពេលដែលខ្ញុំកំពុងនិយាយជាមួយគ្រូពេទ្យនៅថ្ងៃនោះ គាត់បាននិយាយជាធម្មតាថា «តើអ្នកមានដឹងទេថាមាននរណាម្នាក់ចង់ទិញយន្តហោះដែរឬទេ?» ខ្ញុំមានការភ្ញាក់ផ្អើលបន្តិចចំពោះសំណួរមួយនោះ ព្រោះថាក្នុងមួយជីវិតរបស់ខ្ញុំមិនដែលមាននរណាធ្លាប់សួរខ្ញុំថា តើខ្ញុំចង់ទិញយន្តហោះដែរឬទេ? ដូច្នេះ ខ្ញុំបានសួរគាត់វិញថា តើយន្តហោះនោះប្រភេទអ្វីដែរ គាត់បានប្រាប់ខ្ញុំ ហើយវាជាយន្តហោះដែលខ្ញុំបានសាបព្រោះគ្រាប់ពូជសម្រាប់វា។ ពិតណាស់ វាបានធ្វើឱ្យខ្ញុំចាប់អារម្មណ៍។ ខ្ញុំបានទៅមើលយន្តហោះនោះ ទាក់ទងទៅម្ចាស់របស់វា ហើយគាត់បានយកខ្ញុំជិះយន្តហោះនោះ។ វាពិតជាល្អឥតខ្ចោះ។ តែមានតែបញ្ហាមួយគត់។ ពេលនោះខ្ញុំមិនទាន់មានលុយទិញវាទេ។ ប៉ុន្តែព្រះជាម្ចាស់មានផែនការសម្រាប់យន្តហោះខ្ញុំ។

អ្នកដឹងទេ នៅរដូវស្លឹកឈើជ្រុះឆ្នាំមុន ហើយឥលូវនេះជាខែមីនា ខ្ញុំបានទទួលផ្ទះមួយពីឪពុករបស់ខ្ញុំ ដែលខ្ញុំនឹងសាងសង់វាឡើងវិញជាអគារការិយាល័យនៅរដូវនិទាឃរដូវ។ បាទ ប៉ារបស់ខ្ញុំបានប្រាប់ខ្ញុំថាគាត់បានបិទទឹកមុនរដូវរងារួចហើយ ដូច្នេះខ្ញុំមិនបានទៅពិនិត្យមើលវាទេ។ ប៉ុន្មានថ្ងៃបន្ទាប់ពីខ្ញុំបានទៅមើលយន្តហោះ ប្អូនប្រុសខ្ញុំបានទូរសព្ទមកប្រាប់ខ្ញុំថា ផ្ទះរបស់ខ្ញុំខូចអស់ហើយ។ បន្ទាប់មក គាត់បានរៀបរាប់ប្រាប់ខ្ញុំថា ម្នាងសិលាទាំងអស់នៅក្នុងផ្ទះបានខូច ហើយភាគច្រើនវាធ្លាក់ចេញពីជញ្ជាំងហើយ។ តាមមើលទៅ ទឹកមិនបានបិទទេ ហើយវាបានកកនៅរដូវរងា។ ឥលូវនេះជាខែមីនា ហើយវាឡើងកម្ដៅខ្លាំង ទឹកចាប់ផ្តើមហូរចេញពីផ្ទះ ហើយគ្មានអ្នកណាបានដឹងទេ យ៉ាងហោចណាស់វាហូររយៈពេលពីពីរទៅបីសប្តាហ៍ដែរ។

អ្វីដែលប្អូនប្រុសខ្ញុំមិនបានដឹងនោះគឺថាខ្ញុំបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសំណង់មួយរួចហើយ ដើម្បីរុះរើជញ្ជាំង និងផ្នែកខាងក្រៅផ្ទះទាំងមូល។ នេះគឺជាផ្នែកមួយនៃដំណើរការសាងសង់ឡើងវិញ ដើម្បីបំប្លែងផ្ទះឱ្យទៅជាការិយាល័យថ្មីរបស់ខ្ញុំ។ ឥលូវនេះ ដល់ពេលការអស្ចារ្យចាប់ផ្ដើមកើតឡើងហើយ។ ក្រុមហ៊ុនធានារ៉ាប់រងបានបង់ប្រាក់សំណងសម្រាប់ការខូចខាតទឹក ហើយវាជាសាច់ប្រាក់ដែលខ្ញុំយកទៅចំណាយលើយន្តហោះរបស់ខ្ញុំ។ ខ្ញុំបានទិញយន្តហោះនោះដោយសាច់ប្រាក់សុទ្ធ!

ដូច្នេះសូមចាំថា ភាពជាដៃគូគឺជាគោលការណ៍ខាងវិញ្ញាណដ៏មានឥទ្ធិពលមួយ ដែលអ្នកគួរតែដឹង និងទាញយកប្រយោជន៍ពីវា។

យើងមកដល់ទីបញ្ចប់នៃការពិភាក្សារបស់យើងដែលទាក់ទងជាមួយការស្រាយគ្រាប់ពូជ ពេលអ្នកមានជំនឿហើយ។ ចុះឥលូវនេះ ប្រសិនបើអ្នកបានសាបព្រោះគ្រាប់ពូជហើយ តើនឹងមានអ្វីកើតឡើងបន្ទាប់ទៀត? សូមជឿខ្ញុំទៅ មនុស្សភាគច្រើនមិនបានដឹងទេ ដូចជាគ្រិស្តបរិស័ទជាច្រើនដែលបានសាបព្រោះហើយ តែមិនបានឃើញផលមកវិញ ឬផលពីការសាបព្រោះរបស់ពួកគេទេ។ តើបន្ទាប់មក វាជាពេលដែលអ្នកគ្រាន់តែអង្គុយផឹកទឹកក្រូចឆ្មារ រហូតទាល់តែការប្រមូលផលរបស់អ្នកបានមកដល់ឬ?

ទេ អ្នកមិនគួរធ្វើបែបនេះទេ! យើងនឹងពិភាក្សាអំពីអ្វីដែលអ្នកគួរធ្វើនៅក្នុងជំពូកបន្ទាប់។

# ជំពូក ៨

# អ្នកត្រូវការផែនការមួយ!

ពេលដែលប្រេដ និងឆារីធី បានមកដល់ក្រុមជំនុំរបស់យើងជាលើកដំបូង ខ្ញុំពិតជាមិនស្គាល់ពួកគេពិតមែន។ ខ្ញុំចាំបានថាធ្លាប់និយាយសួស្តីទៅកាន់ពួកគេ ហើយគ្រាន់តែនិយាយលេងជាមួយគាត់បន្តិចបន្តួចពីមួយពេលទៅមួយពេល។ លើកទីមួយដែលពួកគេធ្វើឱ្យខ្ញុំមានការចាប់អារម្មណ៍ខាងវិញ្ញាណលើពួកគេ គឺនៅក្នុងសន្និបាតស្ត្រីរបស់ខ្រិនដា។ សន្និបាតនោះចាប់ផ្តើមនៅយប់ថ្ងៃព្រហស្បត្តិ៍ និងបញ្ចប់នៅពេលរសៀលថ្ងៃសៅរ៍។ មានអ្នកចូលរួមជាច្រើនបានបន្តនៅរង់ចាំបន្ទាប់ពីនោះដើម្បីចូលរួមវេនថ្វាយបង្គំល្ងាចថ្ងៃសៅរ៍របស់យើង។ គឺនៅក្នុងវេនថ្វាយបង្គំនោះហើយដែលប្រេដ និងឆារីធីបានចូលមកបន្ទាប់ពីចប់វេនថ្វាយបង្គំនោះ អមជាមួយនឹងសំណូមពរមួយ។ ពួកគេចង់ចាប់ផ្តើមអាជីវកម្មមួយ និងបានសួរថាតើខ្ញុំនឹងទទួលយកគ្រាប់ពូជមួយចូលទៅក្នុងព័ន្ធកិច្ចរបស់យើង ហើយអធិស្ឋានឱ្យពួកគេសម្រាប់អាជីវកម្មនេះដែរឬទេ។

ក្រោយមកខ្ញុំបានដឹងថាឆារីធីបានជួលស្តង់មួយនៅក្នុងសន្និបាតស្ត្រី ដើម្បីលក់ផលិតផលថែរក្សាសក់ធ្វើដោយដៃរបស់គាត់ សម្រាប់សក់រួញរបស់ជនជាតិអាហ្វ្រិកអាមេរិក។ គាត់បានជួលតុនៅក្នុងសន្និបាតនោះដែលមានតម្លៃ១៥០ដុល្លារ ហើយគាត់លក់ផលិតផលបានចំនួន៣៥០ដុល្លារ ដែលធ្វើឱ្យគាត់រកចំណូលសរុបបាន ២០០ដុល្លារពីការលក់។

នៅក្នុងវេនថ្វាយបង្គំនាល្ងាចថ្ងៃសៅរ៍ ពួកគេទាំងពីរបានចូលមកដោយនាំយកលុយ២០០ដុល្លារនោះមក ហើយចង់សាបព្រោះចូលទៅក្នុងព័ន្ធកិច្ចរបស់យើង

ទុកជាគ្រាប់ពូជសម្រាប់ឱ្យអាជីវកម្មរបស់ពួកគេបានរីកចម្រើន។ ខ្ញុំបាននិយាយថា « ប្រាកដជាបាន» ហើយក៏បានអធិស្ឋាន។ ខ្ញុំមិនបានគិតច្រើនទេអំពីរឿងនោះ ក៏ប៉ុន្តែខ្ញុំអាចមើលឃើញចិត្តឆេះឆួលនៅក្នុងកែវភ្នែករបស់ពួកគេ ហើយខ្ញុំក៏អាចប្រាប់បានថាពួកគេមានជំនឿ ក្នុងពេលដែលពួកគេស្រាយគ្រាប់ពូជរបស់ពួកគេចេញទៅ។

នេះជាព័ត៌មានបន្តិចបន្តួចពីប្រេដ និងឆារីធី ក្នុងពេលនោះប្រេដគឺជាអ្នកគ្រប់គ្រងផ្នែកព័ត៌មានវិទ្យាឱ្យក្រុមហ៊ុនមួយ ហើយឆារីធីធ្វើការងារក្រៅម៉ោងដែលទទួលបានលុយ១០ដុល្លារក្នុងមួយម៉ោង គ្រាន់តែស្មើប្រាក់ខែជាមធ្យមរបស់គ្រួសារដែលរស់ពឹងលើការធ្វើការទទួលប្រាក់ខែតែប៉ុណ្ណោះ។ បន្ទាប់ពីសន្និបាតនោះបញ្ចប់ទៅពួកគេបាននៅបន្តលក់ផលិតផលរបស់ពួកគេទៅមិត្តភក្តិ និងលក់ផលិតផលខ្លះតាមអនឡាញ ក៏ប៉ុន្តែពួកគេបានទទួលស្គាល់ថាអាជីវកម្មរបស់ពួកគេមិនសូវជាមានដំណើរទៅមុខនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ព្រះជាម្ចាស់កំពុងតែធ្វើការនៅពីក្រោយដើម្បីរៀបចំការរីកចម្រើនរបស់ពួកគេក្នុងថ្ងៃអនាគត។

ប្រេងអូទ្រីសគឺជាគ្រឿងផ្សំដ៏ចាំបាច់នៅក្នុងរូបមន្តផលិតផលរបស់ពួកគេដែលពួកគេទិញវាមកពីកសិដ្ឋានអូទ្រីសមួយនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដែលក្រោយមកទៀតពួកគេបានដឹងថាម្ចាស់កសិដ្ឋានចង់លក់ក្រុមហ៊ុននោះ ហើយវាមានតម្លៃ៤០.០០០ដុល្លារ។ ឆារីធីដឹងថានេះគឺជាឱកាសដ៏ល្អមួយសម្រាប់ការរីកចម្រើនក្នុងថ្ងៃអនាគតរបស់ក្រុមហ៊ុនពួកគេ ក៏ប៉ុន្តែប្រេដ និងឆារីធីគ្មានលុយ៤០.០០០ដុល្លារនោះទេគឺគ្មានទាល់តែសោះ។ ពួកគេមានតែលុយល្មមទិញសំបុត្រយន្តហោះទៅមើលក្រុមហ៊ុននោះនៅរដ្ឋកាលីហ្វ័រញ៉ាប៉ុណ្ណោះ ពួកគេគ្មានលុយលើសពីនេះទៀតទេ។ ប្រេដបាននិយាយថាពេលដែលទៅកាន់តែជិតដល់រដ្ឋកាលីហ្វ័រញ៉ា គាត់កាន់តែភ័យ។ តើគាត់និយាយអ្វីទៅកាន់ម្ចាស់កសិដ្ឋានទៅបើពួកគេគ្មានលុយផង ហើយពួកគេទាំងពីរក៏បានសន្យាគ្នាថាពួកគេនឹងមិនខ្ចីលុយទៀតទេសម្រាប់អាជីវកម្មរបស់ពួកគេ? ពេលពួកគេទៅដល់កាលីហ្វ័រញ៉ា កសិករបាននាំពួកគេដើរមើលជុំវិញទីនោះ ក៏ប៉ុន្តែគាត់បាន

ប្រាប់ពួកគេថាគាត់រកឃើញអ្នកដែលចង់ទិញក្រុមហ៊ុនប្រេងនេះហើយ។ មើលទៅរឿងរ៉ាវហាក់ដូចជាមិនដំណើរការល្អទេ។ ក៏ប៉ុន្តែម្ចាស់កសិដ្ឋានបានសុំឱ្យប្រេដធ្វើកិច្ចការទាក់ទងនឹងព័តិមានវិទ្យាខ្លះៗឱ្យគាត់ ហើយប្រេដក៏បានទទួលយកការងារនោះ។

អំឡុងពេលនោះ ប្រេដ និងឆារីធីបានអភិវឌ្ឍទំនាក់ទនងមួយជាមួយនឹងម្ចាស់កសិដ្ឋាន ហើយថ្ងៃមួយម្ចាស់កសិដ្ឋានបាននិយាយថា គាត់សម្រេចចិត្តថាលក់អាជីវកម្មនោះទៅឱ្យពួកគេ។ ចុងក្រោយគាត់ក៏ទទួលយកការទូទាត់លុយសម្រាប់អាជីវកម្មនោះ ហើយប្រេដ និងឆារីធីក៏បានទទួលក្រុមហ៊ុនប្រេងអូទ្រីសមកជារបស់ពួកគេ។ គឺអំឡុងពេលនេះហើយដែលប្រេដ និងឆារីធីបានឮពីគម្រោងនៃការសាងសង់មួយដែលយើងកំពុងដាក់ដំណើរការនៅក្នុងក្រុមជំនុំ Faith Life Church ហើយមានអ្វីម្យ៉ាងស្រាប់ទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេពីខាងក្នុងមក។ ពួកគេបានមើលឃើញថាគ្រាប់ពូជដំបូងដែលពួកគេបានសាបព្រោះមុននេះ បានកែប្រែអាជីវកម្មរបស់ពួកគេទាំងស្រុង ហើយពេលនេះពួកគេដឹងថាវាជាពេលដែលត្រូវនាំអាជីវកម្មរបស់ពួកគេឡើងទៅមួយកម្រិតទៀតដោយប្រើគ្រាប់ពូជដ៏សំខាន់មួយ។ ជាថ្មីម្តងទៀតប្រេដ និងឆារីធីបានមកជួបខ្ញុំនៅខាងមុខក្រុមជំនុំ និងបានសាបព្រោះសម្រាប់អាជីវកម្មរបស់ពួកគេ ជាមួយនឹងគ្រាប់ពូជមួយ និងគោលដៅមួយដែលពួកគេបានសាបព្រោះដើម្បីវា។ ពួកគេមិនសាបព្រោះសម្រាប់លុយផ្ទាល់ខ្លួនរបស់ពួកគេទេ ក៏ប៉ុន្តែសម្រាប់គោលដៅ ១០០.០០០ដុល្លារដែលពួកគេចង់ប្រគល់មកក្នុងគម្រោងការសាងសង់។

និយាយរឿងដោយសង្ខេបទៅ មានការផ្លាស់ប្តូរដ៏ធំមួយបានកើតឡើងម្តងទៀតនៅក្នុងការផលិតផលិតផល ហើយព្រះជាម្ចាស់បានផ្តត់ផ្គង់នូវគ្រឿងផ្សំថ្មីមួយដែលបានផ្លាស់ប្តូរផលិតផលនោះ ដើម្បីឱ្យវាក្លាយទៅជាផលិតផលដ៏ល្អឥតទាស់សម្រាប់សក់រួញរបស់ជនជាតិអាហ្វ្រិកអាមេរិក។ ផលិតផលនោះបានលក់ចេញយ៉ាងឆាប់រហ័ស ហើយមិនយូរប៉ុន្មានពួកគេបានប្រគល់មូលប្បទានបត្រ ១០០.០០០ដុល្លារនោះមកក្នុងផែនការសាងសង់អគារ។ ឥលូវនេះពួកគេកំពុងគាំទ្រដល់គម្រោងជាច្រើន

នៅទូទាំងទ្វីបអាហ្វ្រិក ហើយលំហូរសាច់ប្រាក់របស់ពួកគេមានលើសពីខ្ទង់ ១.០០០.០០០ដុល្លារ។ រឿងរ៉ាវទាំងអស់នេះបានកើតឡើងក្នុងអំឡុងរយៈពេលបីឆ្នាំ។ នេះពិតជារឿងដ៏អស្ចារ្យមួយអំពីការចាកចេញពីចំណូល ១០ដុល្លារក្នុងមួយម៉ោង ឈានទៅដល់ចំណូលរាប់លាន ក្នុងរយៈពេលបីឆ្នាំ! ពិតជាអស្ចារ្យណាស់!

នេះគឺជារឿងមួយដ៏អស្ចារ្យ និងជាឧទាហរណ៍មួយដ៏ល្អឥតខ្ចោះពីរបៀបដែលព្រះជាម្ចាស់ ធ្វើការជាមួយអ្នកដើម្បីចាប់យកការផ្គត់ផ្គង់របស់អ្នក និងដើម្បីកសាងឥទ្ធិពលរបស់អ្នក។ រឿងទីមួយដែលលេចធ្លោជាងគេសម្រាប់ខ្ញុំ គឺដួងចិត្តរបស់ពួកគេចំពោះព្រះរាជ្យ និងគោលបំណងរបស់ក្រុមហ៊ុនរបស់ពួកគេ ដែលមានគោលបំណងគាំទ្រផ្នែកហិរញ្ញវត្ថុដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទីពីរគឺរបៀបដែលពួកគេធ្វើការជាមួយព្រះជាម្ចាស់ដើម្បីអភិវឌ្ឍរចនាសម្ពន្ធ ផលិតផល និងផែនការសម្រាប់ក្រុមហ៊ុនចេញពីមូលដ្ឋានដែលគ្មានអ្វីសោះ។ រឿងនេះគួរតែលើកទឹកចិត្តដល់នរណាម្នាក់ដែលចង់ធ្វើអ្វីម៉្យាងដ៏សំខាន់ ដែលរឿងនោះមិនត្រូវកំណត់ដោយចំនួនលុយដែលអ្នកមាន ឬកំណត់ដោយអ្វីដែលដែលអ្នកដឹងនៅពេលដែលអ្នកធ្វើការចាប់ផ្តើមទេ។ ព្រះជាម្ចាស់នឹងធ្វើការជាមួយអ្នកទាំងអស់គ្នា នៅក្នុងដំណើររបស់អ្នក។

រឿងនេះនាំខ្ញុំទៅកាន់គោលការណ៍ទី៩របស់ព្រះរាជ្យ ដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំ ហើយបន្ទាប់ពីអ្នកសាបព្រោះ និងស្រាយជំនឿរបស់អ្នក អ្នកត្រូវការស្តាប់ដើម្បីបានឮពីផែនការ។

## ជំហានទី ៩៖ បន្ទាប់ពីអ្នកសាបព្រោះ និងស្រាយជំនឿរបស់អ្នក អ្នកត្រូវការស្តាប់ដើម្បីបានឮពីផែនការ។

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ!»។*

*គេទូលព្រះអង្គថាៈ «តើយើងត្រូវយកប្រាក់ពីររយដួង ទៅទិញម្ហូបអាហារឱ្យគេបរិភោគឬ?»។*

*ព្រះអង្គមានព្រះបន្ទូលសួរគេថាៈ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។*

*កាលបានដឹងហើយ គេទូលព្រះអង្គថាៈ «យើងខ្ញុំមាននំបុ័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*

*ព្រះយេស៊ូបង្គាប់ពួកសិស្សឱ្យប្រាប់បណ្ដាជន អង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំបុ័ងប្រទានឱ្យពួកសិស្ស ដើម្បីឱ្យគេចែកបណ្ដាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឱ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំបុ័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំបុ័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

— ម៉ាកុស ៦:៣៧-៤៤

ព្រះយេស៊ូបានប្រទានផែនការមួយដល់ពួកសិស្សអំពី ការប្រតិបត្តិមុនពេលត្រី និងនំបុ័ងបានពហុគុណ។ ដូច្នេះហើយសូមប្រាកដថាអ្នកយល់ពីរឿងនេះ។ ពេលដែលអ្នកសាបព្រោះគ្រាប់ពូជរបស់អ្នកដោយជំនឿ អ្នកត្រូវការទទួលយកផែនការពីព្រះវិញ្ញាណដ៏វិសុទ្ធ។ វិធីដ៏ល្អបំផុតដើម្បីធ្វើរឿងនេះ គឺត្រូវចំណាយពេលអធិស្ឋាននៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ អ្នកមិនចង់ធ្វើការសម្រេចចិត្តណាមួយ ឬចាប់ផ្ដើមអ្វីមួយថ្មីដោយកម្លាំងផ្ទាល់ខ្លួនអ្នកទេ លុះត្រាតែអ្នកបានឮពីព្រះជាម្ចាស់។ នោះដោយសារតែមានហេតុផលមួយចំនួន។ ហេតុផលទីមួយ អ្នកនឹងព្យាយាមធ្វើរឿងនេះដោយកម្លាំងរបស់អ្នក ហើយគិតខ្លីពេក។ ទីពីរអ្នកមុខជាព្យាយាមកសាងផែនការមួយនៅជុំវិញ

រឿងរ៉ាវដែលអ្នកបានដឹងរួចមកហើយ នៅពេលដែលព្រះជាម្ចាស់សព្វព្រះហឫទ័យដឹកនាំអ្នកនៅក្នុងទិសដៅមួយថ្មី។ អ្នកបានព្យាយាមធ្វើអ្វីដែលអ្នកចេះ ហើយអ្នកត្រូវការគំនិតថ្មីស្រស់មួយ និងផែនការមួយដើម្បីផ្លាស់ប្តូរការច្រូតផលរបស់អ្នក។ ហេតុដូច្នេះហើយសូមចាំព្រះអម្ចាស់ប្រទានគំនិតថ្មីស្រស់ និងផែនការមួយមក។ វាអាចចេញមកពីទីណាក៏បាន។ អ្នកអាចនឹងឃើញវាតាមការផ្សាយពាណិជ្ជកម្មមួយ ជួបមនុស្សម្នាក់ ឬជាធម្មតាអាចនឹងមានសុបិនមួយដូចជាខ្ញុំធ្លាប់មាន។ ព្រះជាម្ចាស់នឹងទាក់យកចំណាប់អារម្មណ៍របស់អ្នក ហើយជួយឱ្យអ្នករៀបចំផែនការថ្មីមួយយ៉ាងច្បាស់លាស់។ ខ្ញុំសូមលើកឧទាហរណ៍មួយអំពីមូលហេតុដែលរឿងនេះគឺជារឿងដ៏សំខាន់។

**ពេលដែលអ្នកសាបព្រោះគ្រាប់ពូជរបស់អ្នកដោយជំនឿ អ្នកត្រូវការទទួលយកផែនការពីព្រះវិញ្ញាណដ៏វិសុទ្ធ។**

## អំណាចនៃផែនការ

ខ្ញុំប្រហែលជាបានលើកឧទាហរណ៍នេះនៅក្នុងសៀវភៅ «បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក» គ្រប់ក្បាល ក៏ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការលើកយកវាមកនិយាយម្តងទៀត។ បើខ្ញុំប្រាប់អ្នកថា ខ្ញុំអាចដោះស្រាយបញ្ហាហិរញ្ញវត្ថុទាំងអស់របស់អ្នកបាន ដោយការប្រាប់អ្នកតាមពាក្យសម្តីខ្លះៗនៅពេលបន្តិចទៀតនេះ ខ្ញុំប្រាកដណាស់ថាអ្នកនឹងអង្គុយចុះដើម្បីស្តាប់រឿងលម្អិត ដោយមានទាំងប៊ិចនៅក្នុងដៃផង។ ដូច្នេះសូមត្រៀមខ្លួនទទួលយកចម្លើយរបស់អ្នកនៅទីនេះ។ សូមរកចំណូលសរុបឱ្យបាន ១០លានដុល្លារក្នុងឆ្នាំនេះ។ មែនហើយ គឺខ្ញុំបាននិយាយថាសូមរកចំណូលសរុបឱ្យបាន១០លានដុល្លារមុនពេលឆ្នាំនេះបញ្ចប់ទៅ។ សម្រាប់មនុស្សភាគច្រើន ការធ្វើបែបនេះនឹងរៀបចំហិរញ្ញវត្ថុរបស់ពួកគេឱ្យស្ថិតនៅលើផ្លូវដ៏ល្អមួយឆ្ពោះទៅរកការរួចពីបំណុល។

តើមានរឿងអ្វីកើតឡើងទៅ? ខ្ញុំដូចជាមើលឃើញគេសើចខ្ទប់មាត់នៅត្រង់នោះមែនទេ? តើអ្នកកំពុងសើចមែនទេ? ពេលដែលខ្ញុំប្រាប់មនុស្សដែលកំពុងស្ដាប់ខ្ញុំឱ្យធ្វើដូច្នេះ ខ្ញុំបានឮសំណើចខ្ទប់មាត់នៅពេញសាលបន្ទប់ប្រជុំ។ បន្ទាប់មកខ្ញុំក៏សួរថាហេតុអ្វីបានជាពួកគេសើច។ ពួកគេសើចដោយសារតែសម្រាប់ពួកគេ វាគ្រាន់តែជារឿងកំប្លែងប៉ុណ្ណោះ វាជារឿងដែលមិនអាចទៅរួច។ បន្ទាប់មកខ្ញុំប្រាប់ពួកគេថាពេលខ្លះពេលដែលខ្ញុំដាក់គោលដៅចំណូលទាបជាងនេះសម្រាប់ពេលមួយឆ្នាំពួកគេនឹងឈប់សើច ហើយនឹងនិយាយថា «ខ្ញុំអាចធ្វើបាន»។

ដូច្នេះតើអ្នកនឹងឈប់សើចនៅត្រឹមណាដែរ ត្រឹម៦០០.០០០ដុល្លារក្នុងមួយឆ្នាំឬ? តើអ្នកមើលឃើញខ្លួនឯងនៅត្រឹមចំណូល ២០០.០០០ដុល្លារ ឬ១០០.០០០ដុល្លារក្នុងមួយឆ្នាំ? ប្រហែលជាចំនួនរបស់អ្នកតិចជាងនេះឆ្ងាយណាស់ ប្រហែលជាត្រឹម៥៥.០០០ដុល្លារក្នុងមួយឆ្នាំ។ ស្ថិតក្នុងចំនួនណាមួយរវាងចំនួន១០លានដុល្លារនិង០ដុល្លារ អ្នកមុខជារកឃើញចំនួនដែលអ្នកធ្វើឱ្យអ្នកនិយាយថា «ខ្ញុំគិតថាខ្ញុំអាចរកបាន» ហើយត្រង់នោះហើយជាបញ្ហា គឺវាស្ថិតនៅត្រង់កន្លែងដែលអ្នកនឹងនិយាយនោះតែម្ដង។ សូមយល់អំពីរឿងមួយនេះ គ្មាននរណាម្នាក់ព្យាយាមធ្វើអ្វីម៉្យាងដែលគេគិតថាវាមិនអាចទៅរួចសម្រាប់ពួកគេទេ។ ដូច្នេះហើយ ត្រង់នេះគឺជាបញ្ហា។ អ្នកជាប់ចំណង ឬមានដែនកំណត់ដោយសារតែកម្លាំងរបស់អ្នកខ្លួនឯង។

ឥលូវនេះខ្ញុំសូមបង្ហាញអ្នកពីអំណាចនៃផែនការមួយ។ ខ្ញុំសូមលើកយកសេចក្ដីថ្លែងដដែល ដែលនិយាយថាបញ្ហាហិរញ្ញវត្ថុទាំងអស់របស់អ្នកនឹងទទួលបានការដោះស្រាយ ប្រសិនបើអ្នករកចំណូលសរុបបាន១០លានដុល្លារក្នុងឆ្នាំនេះ។ ក៏ប៉ុន្តែលើកនេះខ្ញុំផ្ដល់ជូនអ្នកនូវកិច្ចសន្យាមួយដើម្បីឱ្យអ្នកអាចរកលុយបានមួយចំនួន។ ខ្ញុំចំណាយលុយឱ្យអ្នកចំនួន៥០០ដុល្លារ សម្រាប់ប្រអប់មួយដើម្បីយកបាល់មួយទៅដាក់ក្នុងនោះ ហើយយកស្កុតបិទវាឱ្យជាប់ និងសរសេរទុកចំណាំសម្រាប់ផ្ញើវាចេញទៅហើយបន្ទាប់មកសូមទុកវានៅម្ខាងសិន។ សូមឧបមាថាអ្នកអាចរៀបចំប្រអប់ទាំងនោះ

បាន១០០ប្រអប់ក្នុងរយៈពេលមួយម៉ោង ឬស្មើនឹងប្រាក់ចំណូល៥០.០០០ដុល្លារក្នុងពេលមួយម៉ោង។ ហើយក៏សូមឧបមាថាអ្នកធ្វើការ១០ម៉ោងថេរក្នុងពេលមួយថ្ងៃ ដែលរកប្រាក់ចំណូលបាន ៥០០.០០០ដុល្លារក្នុងមួយថ្ងៃ។ បើខ្ញុំនិយាយថាសូមរកលុយ១០លានដុល្លារ មុនពេលបញ្ចប់ឆ្នាំនេះ តើអ្នកនឹងឆ្លើយតបដូចម្ដេច? «ងាយស្រួលណាស់! បើដូច្នោះត្រូវចំណាយពេលធ្វើការត្រឹមតែ២០ថ្ងៃប៉ុណ្ណោះ»។ ដូច្នេះខ្ញុំសូមសួរអ្នកថា តើមានអ្វីបានផ្លាស់ប្ដូរទៅ។ គ្មានអ្វីផ្លាស់ប្ដូរទេលើកសែងតែឥលូវនេះអ្នកមានផែនការមួយ ហើយប្រសិនបើអ្នកដើរតាមវានោះជាមូលដ្ឋានវាធានាថាអ្នកនឹងសម្រេចបានតាមគោលដៅរបស់អ្នក ក្នុងការរកប្រាក់ចំណូលបាន១០លានដុល្លារក្នុងមួយឆ្នាំ។

តើអ្នកយល់ដែរឬទេ? ខ្ញុំទុកឱ្យអ្នកស្រមៃគិតមើលដោយខ្លួនឯង អ្នកប្រហែលជាមិនដែលគិតថាគោលដៅរបស់អ្នកអាចទៅរួចនោះទេ ហើយអ្នកប្រហែលជាធ្លាប់បានយល់ស្របជាមួយនឹងអ្វីក៏ដោយឱ្យតែអ្នកគិតថាវាអាចទៅរួច។ ក៏ប៉ុន្តែអ្នកមិនត្រូវការយោបល់របស់ខ្លួនអ្នកទេ អ្នកបានរស់នៅក្នុងពិភពលោកដែលមានដែនកំណត់អស់រយៈពេលជាយូរណាស់មកហើយ។ អ្នកមិនត្រូវការវាទេ គឺអ្នកត្រូវការព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីជួយដល់សុបិនរបស់អ្នក។

## ព្រះជាម្ចាស់មានផែនការមួយសម្រាប់អ្នក

ខ្ញុំបានប្រាប់អ្នកតាំងពីដំបូងនៅក្នុងសៀវភៅនេះ អំពីស្ថានភាពហិរញ្ញវត្ថុដ៏គួរឱ្យរន្ធត់របស់យើងរួចមកហើយ រួមទាំងការវាយប្រហារពីជំងឺភ័យស្លន់ស្លោ បញ្ហាផ្លូវចិត្តដែលខ្ញុំទទួលរងដោយសារតែបញ្ហាហិរញ្ញវត្ថុ។ ពេលដែលខ្ញុំចាប់ផ្ដើមរៀនពីរបៀបរស់នៅក្នុងជីវភាពស្របតាមព្រះរាជ្យ ខ្ញុំគ្មានទីពឹងទេក្រៅពីព្រះជាម្ចាស់។ ទ្រង់មានបន្ទូលមកខ្ញុំ និងប្រទានផែនការមួយមកខ្ញុំដើម្បីចាប់ផ្ដើមក្រុមហ៊ុន Forward Financial Group និងបង្ហាញមនុស្សពីរបៀបចាកចេញពីបំណុល។ ខ្ញុំពិតជាឆោតល្ងង់ណាស់! ខ្ញុំចាំបានថាខ្ញុំកំពុងអង្គុយក្នុងផ្ទះខ្ញុំនៅពេលនោះ ទាំងគិតអំពីអ្វីដែលទ្រង់កំពុងមានបន្ទូលឱ្យខ្ញុំធ្វើ ហើយនឹងមានការភ្ញាក់ផ្អើលចំពោះខ្លួនឯង « ព្រះអើយ ទូល

បង្គំសង្ឃឹមថាទ្រង់នឹងប្រាប់ទូលបង្គំពីរបៀបចេញពីបំណុលជាមុនសិន»។ ប៉ុន្តែទ្រង់បានតបមកខ្ញុំវិញថា ខ្ញុំនឹងដើរចេញពីបំណុលនៅពេលដែលខ្ញុំធ្វើតាមផែនការនេះ។

ពេលដែលខ្រិនដា និងខ្ញុំបានចាប់ផ្តើមដំណើរការផែនការដែលព្រះជាម្ចាស់ប្រទានមកយើង យើងគ្មានបរិក្ខា គ្មានកុំព្យូទ័រ ហើយគ្មានអ្វីៗទាំងអស់។ ក៏ប៉ុន្តែពេលដែលយើងឃើញផែនការនោះ ខ្ញុំបានដឹងរួចទៅហើយថាវានឹងដំណើរការ ខ្ញុំបានដឹងថាវាអាចទៅរួច។ ហើយពេលខ្ញុំនិយាយពីផែនការ ខ្ញុំសំដៅទៅលើយុទ្ធសាស្ត្រ និងសេចក្តីលម្អិតដែលទ្រង់បានបង្ហាញយើងទាក់ទងនឹងការចាប់ផ្តើមបើកដំណើរការផែនការនោះ។ ខ្ញុំអាចធ្វើវាបាន! ជាក់ស្តែងខ្ញុំចូលចិត្តធ្វើផែនការនោះ។

ដូចជានៅក្នុងករណីរបស់ប្រេដ និងឆារីធីដែរ ព្រះជាម្ចាស់ប្រទានការផ្គត់ផ្គង់នូវបរិក្ខារគ្រប់យ៉ាងដែលយើងត្រូវការសម្រាប់ការចាប់ផ្តើមដំបូង។ ពិតជាចម្លែកមែន មានថ្ងៃមួយឪពុករបស់ខ្ញុំដែលជាម្ចាស់ហាងលក់តីហ្សា ហើយគាត់មិនត្រូវការកុំព្យូទ័រទេ គាត់ស្រាប់តែប្រាប់ខ្ញុំថាគាត់ចង់ទិញកុំព្យូទ័រមួយគ្រឿង ហើយគាត់បានបបួលខ្ញុំទៅជាមួយគាត់។ ដូច្នេះហើយយើងបានទៅជាមួយគ្នា និងបានទិញកុំព្យូទ័រមួយគ្រឿងសម្រាប់គាត់ និងកម្មវិធី Word ដែលគាត់បាននិយាយថាខ្ញុំអាចប្រើកម្មវិធីនោះលើកកុំព្យូទ័របាន។ ខ្ញុំយល់ហើយ ខ្ញុំគ្មានចេះអ្វីសោះទាក់ទងនឹងកុំព្យូទ័រ។ គាត់រស់នៅឆ្ងាយពីខ្ញុំប្រមាណជាជាងមួយគីឡូដី ហើយខ្ញុំក៏បានចាប់ផ្តើមសាកល្បងរៀនប្រើកុំព្យូទ័រ និងកម្មវិធីនោះរហូតដល់ខ្ញុំអាចសរសេរបទបង្ហាញដ៏ល្អមួយសម្រាប់អតិថិជន អំពីរបៀបជម្រុះបំណុលរបស់ពួកគេ។ ព្រះជាម្ចាស់បានបង្កើតផ្លូវមួយសម្រាប់ខ្ញុំនៅពេលដែលខ្ញុំគ្មានលុយ។

ក្រុមហ៊ុនបានរីកចម្រើនឡើង ហើយខ្ញុំក៏ចាប់ផ្តើមជួលអ្នកតំណាងផ្នែកលក់ជាច្រើននាក់។ នៅពេលនោះយើងបានធ្វើការគណនាហិរញ្ញវត្ថុដោយដៃ ដើម្បីធ្វើការងារទាំងអស់ទាក់ទងនឹងគណិតវិទ្យាទៅលើផែនការរបស់គ្រួសារនីមួយៗ។ បន្ទាប់

ពីនោះមកយើងវាយបញ្ចូលទិន្នន័យនោះចូលទៅក្នុងគំរូឯកសារដែលខ្ញុំបានបង្កើតនៅក្នុងកម្មវិធីកុំព្យូទ័រ Word របស់ខ្ញុំដើម្បីយកមកព្រីនចេញសម្រាប់ប្រគល់ឱ្យអ្នកតំណាងរបស់យើង ហើយពួកគេនឹងយកវាត្រលប់ទៅផ្ទះរបស់អតិថិជនរបស់ពួកគេវិញ។ ពេលនោះម៉ាស៊ីនព្រីន Dot Matrix នឹងឮសូរសំឡេងដូចជាវាកំពុងតែច្រៀងពេញមួយថ្ងៃ (តើអ្នកនៅចាំពីសំឡេងនោះត្រូវទេ?) មិនយូរប៉ុន្មានលេខារបស់ខ្ញុំមិនអាចធ្វើការទាំងអស់នោះបានតែម្នាក់ឯង ហើយខ្ញុំត្រូវជួលមនុស្សម្នាក់ទៀតដើម្បីមកជួយវាយឯកសារ និងបោះពុម្ពឯកសាររបាយការណ៍របស់អតិថិជនទាំងនេះ។

ខ្ញុំបានដឹងថា ខ្ញុំត្រូវការវិធីមួយដែលប្រសើរជាងនេះដើម្បីធ្វើអាជីវកម្មនេះ។ ខ្ញុំត្រូវការកម្មវិធីកុំព្យូទ័រដែលអាចគណនារាល់សមីកាហិរញ្ញវត្ថុទាំងអស់ដែលត្រូវការនៅក្នុងករណីនីមួយៗរបស់អតិថិជន ក៏ដូចជាបោះពុម្ពវាចេញមកដែរ។ គ្រិនដា និងខ្ញុំបានសុំជំនួយពីព្រះជាម្ចាស់ និងសុំឱ្យទ្រង់ផ្គត់ផ្គង់ឱ្យយើងមានកម្មវិធីកុំព្យូទ័រដែលយើងមានលទ្ធភាពទិញវា ដើម្បីយកមកសរសេរកម្មវិធីទាំងមូលសម្រាប់ក្រុមហ៊ុនយើង។

ប្រមាណជាពីរខែបន្ទាប់ពីយើងអធិស្ឋាន ពេលដែលខ្ញុំកំពុងសួរសុខទុក្ខអតិថិជនរបស់ខ្ញុំតាមធម្មតា ពេលដែលអតិថិជនម្នាក់នោះបានសួរខ្ញុំបន្ទាប់ពីគាត់បានមើលឯកសារដែលខ្ញុំបានធ្វើសម្រាប់គាត់ «តើលោកធ្វើឯកសារនេះដោយដៃមែនទេ»? ខ្ញុំបាននិយាយថា «បាទ ក៏ប៉ុន្តែយើងពិតជាចង់ប្តូរពីការធ្វើដូច្នេះទៅប្រើកម្មវិធីកុំព្យូទ័រណាមួយ ដែលនឹងជួយធ្វើការងារនេះជំនួសយើងណាស់»។ គាត់បានមើលមកខ្ញុំហើយនឹងពន្យល់ខ្ញុំថាគាត់មានការងារពេញម៉ោងជាអ្នកសរសេរកម្មវិធីកុំព្យូទ័រ ក៏ប៉ុន្តែគាត់ពេញចិត្តនឹងជួយយើងតាមរយៈការសរសេរកម្មវិធីកុំព្យូទ័រមួយសម្រាប់យើងនៅពេលល្ងាច ដែលជាពេលវេលាផ្ទាល់ខ្លួនរបស់គាត់។ គាត់បានបង្ហាញយើងពីតម្លៃហើយគាត់នឹងអនុញ្ញាតឱ្យខ្ញុំទូទាត់ចំណាយនៅពេលដែលខ្ញុំអាចទូទាត់បាននៅឆ្នាំក្រោយ។

កម្មវិធីនោះបានផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាង និងបានអនុញ្ញាតឱ្យខ្ញុំជួលមនុស្សបន្ថែមទៀតបាន។ មិនយូរប៉ុន្មានយើងបានជួលអ្នកតំណាងដល់ទៅ៣០០នាក់ ដែលភាគច្រើនស្ថិតនៅក្នុងភាគខាងកើតនៃសហរដ្ឋអាមេរិក ដែលធ្វើឱ្យការិយាល័យរបស់យើងក្លាយជាការិយាល័យលេខមួយ ក្នុងចំណោមការិយាល័យ ៥.០០០កន្លែងសម្រាប់ក្រុមលក់មួយរបស់យើង។

តាមរយៈការចាប់ផ្តើមក្រុមហ៊ុនផ្ទាល់ខ្លួនរបស់យើង និងការដើរតាមព្រះវិញ្ញាណដ៏វិសុទ្ធ យើងបានចាកចេញពីបំណុលទាំងស្រុង ហើយរឿងក្រៅពីនោះខ្ញុំមិនចាំបាច់និយាយទៀតទេ ដោយសារតែអ្នកបានដឹងវាហើយ។ អ្វីដែលខ្ញុំចង់និយាយគឺថា ព្រះជាម្ចាស់នឹងប្រទានផែនការមួយដល់អ្នក ប្រសិនបើអ្នកសុំទ្រង់ ហើយទុកឱ្យទ្រង់ធ្វើវា។ ទ្រង់នឹងនាំអ្នកទៅកន្លែងជាច្រើនដែលអ្នកមិនដែលគិតថាអាចទៅរួច។

ដូច្នេះខ្ញុំសូមបញ្ជាក់ប្រាប់អ្នកថាអ្នកត្រូវការផែនការ។ ព្រះជាម្ចាស់មានផែនការសម្រាប់ភាគជោគជ័យរបស់អ្នក។ ជាក់ស្តែងទ្រង់មានផែនការជាច្រើនសម្រាប់ភាពជោគជ័យរបស់អ្នក។ គំនិត និងប្រាជ្ញារបស់ទ្រង់គ្មានទីបញ្ចប់ឡើយ។

> *យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុក សម្រាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្តល់សេចក្តីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនាទេ។ យើងនឹងផ្តល់សេចក្តីសង្ឃឹម និងអនាគតល្អឱ្យអ្នករាល់គ្នា នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។*
>
> — យេរេមា ២៩:១១

## តើអ្នកស្តាប់ឮពីផែនការរបស់ព្រះជាម្ចាស់ដោយរបៀបណា?

ដូច្នេះតើអ្នកស្តាប់ឮពីផែនការរបស់ព្រះជាម្ចាស់ដោយរបៀបណា? ដូចខ្ញុំបាននិយាយមកហើយ ការអធិស្ឋានក្នុងព្រះវិញ្ញាណគឺជាវិធីមួយដ៏ល្អបំផុតដើម្បីស្តាប់ឮ។ ខ្ញុំនឹងមិននិយាយពីការអធិស្ឋានក្នុងព្រះវិញ្ញាណក្នុងប្រវែងដ៏វែងនៅទីនេះទេ

ដោយសារតែសៀវភៅរបស់ខ្ញុំ *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃព្រះរាជទាន* និយាយអំពីការស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធលើសេចក្តីលម្អិតដ៏អស្ចារ្យ។ ទោះជាយ៉ាងណាក៏ដោយត្រូវធានាឱ្យមានកំណត់សម្គាល់សង្ខេបមួយ។

> *ប៉ុន្តែ សេចក្តីដែលយើងប្រៀនប្រដៅក្នុងចំណោមអ្នកដែលមានជំនឿគ្រប់លក្ខណៈហើយនោះ ក៏ជាប្រាជ្ញាម្យ៉ាងដែរ តែមិនមែនជាប្រាជ្ញារបស់មនុស្សលោក ឬជាប្រាជ្ញារបស់អ្នកគ្រប់គ្រងមនុស្សលោកនេះ ដែលនឹងត្រូវវិនាសសាបសូន្យទៅនោះទេ។ យើងប្រៀនប្រដៅអំពីប្រាជ្ញារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបង្កប់ន័យទុកតាមគម្រោងការដ៏លាក់កំបាំងរបស់ព្រះអង្គ តាំងពីមុនកំណើតពិភពលោកមកម៉្លេះ គឺព្រះអង្គបានគ្រោងទុកថានឹងប្រទានសិរីរុងរឿងមកយើង។ គ្មាននរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងមនុស្សលោកនេះ បានស្គាល់ប្រាជ្ញារបស់ព្រះអង្គទេ។ ប្រសិនបើគេពិតជាបានស្គាល់មែន គេមិនឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនោះឡើយ។*
>
> *ប៉ុន្តែ ដូចមានចែងទុកមកថា៖ <u>«អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្តាប់មិនឮ និងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់នោះព្រះជាម្ចាស់បានរៀបចំទុក សម្រាប់អស់អ្នកដែលស្រលាញ់ព្រះអង្គ»។ ព្រះជាម្ចាស់បានសម្តែងឱ្យយើងដឹងអំពីគម្រោងការដ៏លាក់កំបាំងនោះតាមរយៈព្រះវិញ្ញាណ</u> ដ្បិតព្រះវិញ្ញាណឈ្វេងយល់អ្វីៗទាំងអស់ សូម្បីតែជម្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ព្រះអង្គឈ្វេងយល់ដែរ។*
>
> *ចំពោះមនុស្សលោក គ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។ ចំពោះយើង យើងពុំបានទទួលវិញ្ញាណលោកីយ៍ទេ គឺយើងបានទទួលព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់ ដើម្បីឱ្យស្គាល់អ្វីៗដែលព្រះអង្គប្រោសប្រទានមកយើង។*

## អ្នកត្រូវការផែនការមួយ

— ១ កូរិនថូស ២:៦-១២

អ្វីៗដែលយើងមិនបានឮ មិនបានឃើញ ឬមិនបានគិតដូចដែលមានចែងនៅក្នុងអត្ថបទគម្ពីរនេះ គឺជារឿងដែលបង្ហាញឱ្យយើងឃើញតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ចំពោះខ្ញុំស្តាប់ទៅនេះដូចជាអត្ថប្រយោជន៍ដ៏អស្ចារ្យមួយ ខ្ញុំអាចប្រើប្រាស់អ្វីដែលព្រះវិញ្ញាណបង្ហាញឱ្យឃើញបាន។ ពេលអ្នកក្លាយជាគ្រិស្តបរិស័ទម្នាក់ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់ក្នុងអ្នក ហើយទ្រង់បានចាប់ផ្តើមដឹកនាំជីវិតរបស់អ្នក។

ក៏ប៉ុន្តែ មានមានកម្រិតនៃការរាស់ស្នង់មួយផ្សេងទៀតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះយេស៊ូបានប្រទានទៅក្រុមជំនុំ ដែលមានឈ្មោះថាការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះជាអ្វីដែលយើងឃើញកើតឡើងនៅក្នុងថ្ងៃបុណ្យទី៥០ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើពួកសិស្សនៅក្នុងបន្ទប់ជាន់ខាងលើ ដូចដែលទ្រង់បានយាងមកសណ្ឋិតលើព្រះយេស៊ូនៅឯទន្លេយ័រដាន់ដែរ។ នេះគឺជាពេលដែលព្រះយេស៊ូបានចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់។ នេះគឺជាពេលដែលអំណាចរបស់ព្រះជាម្ចាស់បានយាងមកសណ្ឋិតលើទ្រង់ ដើម្បីធ្វើជាសាក្សីម្នាក់របស់ព្រះរាជ្យ។ ពេលព្រះយេស៊ូនៅជាកុមារ ទ្រង់មិនបានធ្វើការអស្ចារ្យអ្វីទេ។ ទ្រង់មិនបានពហុគុណអាហាររបស់ក្រុមគ្រួសារទ្រង់ ឬយាងនៅលើទឹកនោះទេ។ ដើម្បីយល់ពីការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ អ្នកនឹងត្រូវយល់ថាមានភាពខុសគ្នារវាងការកើតជាថ្មី (នៅពេលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចូលមកនៅក្នុងអ្នក) និងការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធសិន (ពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់ក្នុងអ្នក)។

> *នៅល្ងាចថ្ងៃអាទិត្យនោះ ពួកសិស្សនៅក្នុងផ្ទះខ្ទាស់ទ្វារយ៉ាងជាប់ ព្រោះខ្លាចជនជាតិយូដា។ ស្រាប់តែព្រះយេស៊ូយាងមកឈរនៅកណ្តាលចំណោមពួកគេ មានព្រះបន្ទូលថា៖ «សូមឱ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត!»។ ព្រះអង្គមានព្រះបន្ទូលដូច្នេះ ទាំងបង្ហាញស្នាមរបួសនៅព្រះហស្ត និងនៅ*

*ត្រង់ឆ្អឹងជំនីរឱ្យគេឃើញផង។ ពួកសិស្សសប្បាយចិត្តជាខ្លាំង ដោយបានឃើញព្រះអម្ចាស់។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឱ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឱ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឱ្យទៅយ៉ាងនោះដែរ»។ <u>បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ ទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះវិញ្ញាណ!។</u>*

— យ៉ូហាន ២០:១៩-២២

ពួកសិស្សបានកើតជាថ្មីនៅត្រង់នោះ នៅត្រង់គម្ពីរយ៉ូហានជំពូកទី២០ ក៏ព្រះយេស៊ូមានបន្ទូលទៅពួកគេថាពួកគេនៅតែត្រូវរង់ចាំការជ្រមុជដោយព្រះវិញ្ញាណដ៏វិសុទ្ធនេះ ដែលនឹងធ្វើឱ្យពួកគេអាចក្លាយជាសាក្សីរបស់ព្រះរាជ្យនៃព្រះជាម្ចាស់។

*ក្រោយពេលរងទុក្ខលំបាករួចហើយ ព្រះយេស៊ូបានបង្ហាញព្រះអង្គ តាមរបៀបផ្សេងៗឱ្យសាវ័កទាំងនោះឃើញថាព្រះអង្គមានព្រះជន្មរស់ពិតប្រាកដមែន។ ព្រះអង្គបានឱ្យគេឃើញអស់រយៈពេលសែសិបថ្ងៃ ព្រមទាំងមានព្រះបន្ទូលអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ផង។ ពេលព្រះអង្គកំពុងសោយព្រះស្ងោយជាមួយក្រុមសាវ័ក ព្រះអង្គហាមគេមិនឱ្យចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ «គឺត្រូវរង់ចាំទទួលព្រះវិញ្ញាណតាមព្រះបន្ទូលសន្យារបស់ព្រះបិតា ដូចខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយថា លោកយ៉ូហានបានធ្វើពិធីជ្រមុជឱ្យគេក្នុងទឹក ប៉ុន្តែ នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ»។*

— កិច្ចការ ១:៣-៥

*ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ<u>មកសណ្ឋិតលើអ្នករាល់គ្នា</u>។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុង*

*ក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។*

— កិច្ចការ ១:៨

ការចាក់ប្រេងតាំងពីព្រះជាម្ចាស់នេះ នាំយកអំណាចរបស់ព្រះជាម្ចាស់មក ហើយនឹងជួយឱ្យអ្នកធ្វើកិច្ចការរបស់ទ្រង់។ សូមចំណាំថាព្រះវិញ្ញាណសណ្ឋិតលើអ្នក ហើយមិនមែននៅក្នុងអ្នកទេ។ អ្នកអាចនឹងត្រូវចងចាំដែរថា នៅថ្ងៃបុណ្យទី៥០ ពួកសិស្សទាំងអស់ដែលបានរង់ចាំនៅក្នុងទីក្រុងយេរូសាឡឹម នៅក្នុងបន្ទប់ជាន់ខាងលើបានទទួលការជ្រមុជដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ តើអ្វីទៅជាភស្តុតាងមួយអំពីហេតុការណ៍នេះ? នោះគឺពួកគេទាំងអស់គ្នាបាននិយាយភាសាចម្លែកអស្ចារ្យ។ ការនិយាយភាសាចម្លែកអស្ចារ្យមានកត់ត្រាទុកនៅក្នុងគម្ពីរ ១ កូរិនថូសជំពូក ១២ ដែលចាត់ចូលជាអំណោយទានខាងវិញ្ញាណទីប្រាំបួន ដែលបានប្រទានទៅឱ្យពួកជំនុំ។ អ្នកអាចនឹងនិយាយថាអំណោយទាននោះបានផុតរលត់ទៅហើយ ក៏ប៉ុន្តែខ្ញុំមិនយល់ស្រប ជាមួយអ្នកពេញទំហឹង។ ការជ្រមុជរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នាំមកជាមួយនូវអំណោយទានខាងវិញ្ញាណទាំងប្រាំបួន ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់ផ្តោតសំខាន់ទៅលើអំណោយទានតែមួយប៉ុណ្ណោះ នោះគឺការនិយាយភាសាចម្លែកអស្ចារ្យ។

**ការចាក់ប្រេងតាំងពីព្រះជាម្ចាស់ នាំយកអំណាចរបស់ព្រះជាម្ចាស់មក ហើយនឹងជួយឱ្យអ្នកធ្វើកិច្ចការរបស់ទ្រង់។**

ទីមួយ អំណោយទាននេះប្រហែលជាស្តាប់ទៅដូចជាគ្មានប្រយោជន៍សម្រាប់អ្នក ដោយសារតែអ្នកប្រហែលជាគិតថាអ្នកត្រូវការអំណោយទាននេះតែនៅពេលដែលអ្នកនិយាយទៅកាន់មនុស្សដែលនិយាយភាសាផ្សេង ហើយនឹងនៅពេលដែលអ្នកព្យាយាមអធិប្បាយដំណឹងល្អប៉ុណ្ណោះ។ ក៏ប៉ុន្តែការអាចនិយាយទៅកាន់មនុស្សជាច្រើន

ដោយប្រើភាសាមួយដែលអ្នកមិនចេះ គឺមិនមែនជាគោលបំណងរបស់អំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យទេ។ ខ្ញុំសូមបង្ហាញអ្នកពីមូលហេតុដែលវាគឺជាអំណោយទានដែលមិនអាចកាត់ថ្លៃបាន និងមូលហេតុដែលវាមានសារៈសំខាន់ចំពោះភាពចម្រុងចម្រើនរបស់អ្នក។

> *អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះនិយាយទៅកាន់ព្រះជាម្ចាស់ មិនមែននិយាយទៅកាន់មនុស្សទេ ដ្បិតគ្មាននរណាយល់ន័យ ព្រោះព្រះវិញ្ញាណនាំចិត្តអ្នកនោះឱ្យថ្លែងពីសេចក្ដីដ៏លាក់កំបាំង។ ផ្ទុយទៅវិញ អ្នកណាថ្លែងព្រះបន្ទូល អ្នកនោះនិយាយទៅកាន់មនុស្ស ដើម្បីជួយកសាង ដាស់តឿន និងលើកទឹកចិត្តគេ។ <u>អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះកសាងតែខ្លួនឯងប៉ុណ្ណោះ</u> រីឯអ្នកថ្លែងព្រះបន្ទូលវិញ កសាងក្រុមជំនុំ។ <u>ខ្ញុំចង់ឱ្យបងប្អូនចេះនិយាយភាសាចម្លែកអស្ចារ្យទាំងអស់គ្នា</u> ក៏ប៉ុន្តែ លើសពីនេះទៅទៀត ខ្ញុំចង់ឱ្យបងប្អូនចេះថ្លែងព្រះបន្ទូល។ អ្នកថ្លែងព្រះបន្ទូលសំខាន់ជាងអ្នកនិយាយភាសាចម្លែកអស្ចារ្យទៅទៀត លើកលែងតែអ្នកនិយាយនោះបកប្រែឱ្យគេយល់ ដើម្បីកសាងក្រុមជំនុំ ទើបសំខាន់។*
>
> — ១ កូនរិនថូស ១៤:២-៥

យើងត្រូវតែយល់ពីបរិបទនៃលិខិតរបស់លោកប៉ូលនៅទីនេះ។ គាត់កំពុងនិយាយពីរបៀបដែលការជួបជុំគ្នារបស់ក្រុមជំនុំមួយគួរតែប្រព្រឹត្តទៅ។ ជាមូលដ្ឋានគាត់កំពុងតែនិយាយថា ការនិយាយភាសាចម្លែកអស្ចារ្យគ្មានប្រយោជន៍អ្វីដល់អ្នកដែលបានស្ដាប់ឮនៅក្នុងវេនថ្វាយបង្គំទេ ក៏ព្រោះតែអ្នកដែលបានស្ដាប់ឮមិនយល់ពីអ្វីដែលគេកំពុងតែនិយាយ។ លោកប៉ូលនិយាយថា នៅក្នុងក្រុមជំនុំនឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងតាមរយៈការថ្លែងព្រះបន្ទូល ដោយសារតែការថ្លែងព្រះបន្ទូលនឹងធ្វើឡើងក្នុងភាសាធម្មតាដែលមនុស្សចេះស្ដាប់ ហើយនឹងមានប្រសិទ្ធភាពជាង។

ក៏ប៉ុន្តែពេលយើងនិយាយពីការអធិស្ឋានរៀងៗខ្លួនក្នុងភាសាចម្លែកអស្ចារ្យ វាពិតជាអស្ចារ្យណាស់ ហើយវាគឺជារឿងមួយផ្សេងទៀត។ ការនិយាយភាសាចម្លែកអស្ចារ្យមានអត្ថប្រយោជន៍ដ៏អស្ចារ្យចំពោះអ្នកដែលនិយាយភាសានេះ។ ព្រះគម្ពីរចែងថា ពួកគេកំពុងនិយាយពីអាថិកំបាំងជាច្រើនតាមរយៈវិញ្ញាណរបស់ពួកគេ។ អាថិកំបាំងទាំងនេះគឺជាអ្វីដែលអ្នកមិនដឹង និងជាអ្វីដែលអ្នកត្រូវការដឹង។ ទីពីរ លោកប៉ូលនិយាយថា អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យកសាងតែខ្លួនឯងប៉ុណ្ណោះ។ ពាក្យថាកសាងមានន័យថា នាំយកសេចក្ដីណែនាំមក។ ជាការពិតណាស់ ប្រសិនបើអ្នកត្រូវការដឹងពីអ្វីម្យ៉ាង នោះវាគឺជារឿងអាថិកំបាំងមួយសម្រាប់អ្នក នៅក្នុងពេលនោះ។ ក៏ប៉ុន្តែការនិយាយភាសាចម្លែកអស្ចារ្យនាំយកសេចក្ដីណែនាំទៅកាន់មនុស្សម្នាក់ដែលនិយាយភាសានោះ។ ប្រាកដណាស់ថាអ្នក និងខ្ញុំត្រូវការអំណោយទាននោះ ប្រសិនបើយើងត្រូវអភិវឌ្ឍផែនការផ្សេងៗដែលលើសពីអ្វីៗដែលបានដឹងរួចមកហើយ។ ដូចមានចែងក្នុងគម្ពីរ ១ កូរិនថូស ២:៩-១០ ថា៖

> *ប៉ុន្តែ ដូចមានចែងទុកមកថា៖ «អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្ដាប់មិនឮ និងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់នោះព្រះជាម្ចាស់បានរៀបចំទុក សម្រាប់អស់អ្នកដែលស្រលាញ់ព្រះអង្គ»។ ព្រះជាម្ចាស់បានសម្ដែងឱ្យយើងដឹងអំពីគម្រោងការដ៏លាក់កំបាំងនោះ តាមរយៈព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណឈ្វេងយល់អ្វីៗទាំងអស់ សូម្បីតែជម្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ព្រះអង្គឈ្វេងយល់ដែរ។*

ខ្ញុំត្រូវការជំនួយនោះ ហើយអ្នកក៏ត្រូវការវាដែរ។ សំណួរបន្ទាប់របស់អ្នកគឺ «ប្រសិនបើអ្នកនិយាយភាសាចម្លែកអស្ចារ្យ ហើយអ្នកមិនយល់ពីអ្វីដែលអ្នកកំពុងនិយាយ ដូច្នេះតើអ្នកទទួលបានប្រយោជន៍ពីអ្វីដែលអ្នកកំពុងនិយាយបានយ៉ាងដូចម្ដេច»? អាថិកំបាំងគឺនៅត្រង់នេះ។ ពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលតាមរយៈវិញ្ញាណជាមនុស្សរបស់អ្នក គំនិតរបស់អ្នកចាប់ផ្ដើមចាប់យកគំនិតមួយចំនួនដែល

កំពុងមានលំហូរឆ្លងកាត់អ្នក។ យើងហៅកិច្ចការនេះថាការបើកសម្តែង ហើយពាក្យនេះមានឫសគល់ចេញមកពីពាក្យថាបង្ហាញឱ្យឃើញ។ ហេតុដូច្នេះហើយ តាមរយៈការអធិស្ឋានក្នុងព្រះវិញ្ញាណ ក៏ដូចជានិយាយភាសាចម្លែកអស្ចារ្យដែលមានចែងក្នុងព្រះគម្ពីរ អ្នកមានសមត្ថភាពក្នុងចាប់យកគំនិត និងការគិតដែលមិនមែនជារបស់អ្នក។

ខ្ញុំដឹងថាអ្នកប្រហែលជាមានសំណួរច្រើនអំពីរឿងនេះ ដូច្នេះខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យអានសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃយុទ្ធសាស្ត្រ។* អ្នកនឹងរកឃើញចម្លើយទាំងអស់ក្នុងសៀវភៅនោះ។

## សូមផ្អាកសិន ហើយអធិស្ឋានដើម្បីទទួលបានយុទ្ធសាស្ត្រ

ពេលនេះ សូមគ្រាន់តែយល់ថាពេលដែលអ្នកសាបព្រោះគ្រាប់ពូជរបស់អ្នកដោយជំនឿ ជំហានបន្ទាប់គឺត្រូវឈប់សិន និងអធិស្ឋានក្នុងព្រះវិញ្ញាណដ៏វិសុទ្ធមួយរយៈសិន ដោយសារតែអ្នកត្រូវការផែនការមួយ។ នេះគឺជាអ្វីដែល ខាឡា បានធ្វើ។

ខាឡា និងចូត បានរស់នៅតាមជីវភាពធម្មតារបស់ជនជាតិអាមេរិក ដោយចំណាប្រាក់ខែមួយខែៗមិនគ្រប់ដល់ពេលទទួលប្រាក់ខែខែថ្មី ហើយនឹងធ្លាក់ខ្លួនកាន់តែជ្រៅចូលទៅក្នុងបំណុល។ ថ្ងៃមួយខាឡាបានឃើញកម្មវិធី *ការដោះស្រាយបញ្ហារឿងលុយ (Fixing the Money Thing)* តាមទូរទស្សន៍ ហើយគាត់បានដឹងថាគាត់ត្រូវការរៀបចំហិរញ្ញវត្ថុរបស់ពួកគាត់ឱ្យមានលំដាប់លំដោយ។ ខ្ញុំអាចចាំពីអ៊ីមែលដែលខាឡាបានផ្ញើមកខ្ញុំបាន។ ក្នុងពេលនោះ គាត់បាននិយាយថាពួកគេគ្មានផែនការហិរញ្ញវត្ថុទេ។ ពួកគេមើលមិនទាំងឃើញពីផែនការក្នុងរយៈពេលពីរខែទៅមុខទៀតផង ពួកគេមានលុយតិចតួចណាស់។ រាល់ការខ្វះខាតរបស់ពួកគេទាំងប៉ុន្មាន ត្រូវយកកាតក្រេឌីតមកដោះស្រាយ។

គាត់បានដឹងថាពួកគាត់ត្រូវការរួចពីបំណុល ក៏ប៉ុន្តែមិនដឹងធ្វើដូចម្តេច? គាត់និងប្តីគាត់បានសាបព្រោះគ្រាប់ពូជសម្រាប់គំនិតអាជីវកម្មមួយ បន្ទាប់ពីបានអានសៀវភៅរបស់ខ្ញុំ ហើយពួកគេបានសាបព្រោះយ៉ាងជាក់លាក់សម្រាប់អាជីវកម្មមួយដែលខាឡាអាចធ្វើវានៅផ្ទះបាន។ ចូតមានការងាររវល់ច្រើនណាស់ទៅហើយ ក្នុងនាមជាគ្រូបង្រៀននៅសាលារដ្ឋមួយ ដូច្នេះហើយទើបខាឡាស្វែងរកមើលថាតើគាត់អាចធ្វើអ្វីបានខ្លះដើម្បីជួយគ្នា។ រៀងរាល់ព្រឹកបន្ទាប់ពីពួកគេបានសាបព្រោះគ្រាប់ពូជសម្រាប់គំនិតមួយរួចមក ខាឡាតែងមានពេលវេលាស្ងប់ស្ងាត់ជាមួយព្រះអម្ចាស់ ដោយរង់ចាំស្តាប់ការណែនាំមួយចំនួនពីព្រះវិញ្ញាណដ៏វិសុទ្ធ។

នៅព្រឹកមួយ គាត់បានឮពាក្យថាកូនឆ្កែ ចេញពីជម្រៅចិត្តរបស់គាត់។ ដំបូងគាត់ហាក់ដូចជាច្របូកច្របល់បន្តិច។ កូចឆ្កែឬ? ត្រូវចិញ្ចឹមកូនឆ្កែឬ? ពួកគេធ្លាប់មានឆ្កែមួយក្បាល ក៏ប៉ុន្តែការចញ្ចឹមកូនឆ្កែគឺជាអ្វីដែលគាត់មិនដែលគិតដល់ពីមុនមកទេ។ ពេលចូតត្រលប់មកផ្ទះវិញក្នុងពេលល្ងាចនោះ គាត់ចង់ប្រាប់ចូតពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ ដូចអ្វីដែលរំពឹងទុក ចូតមានចម្ងល់បន្តិចបន្តួចដែរពីផែនការនោះ ក៏ប៉ុន្តែគាត់បានលើកទឹកចិត្តខាឡាឱ្យស្វែងរកមើលអ្វីដែលអាចទៅរួច។ មិនយូរប៉ុន្មានចូតនិងខាឡាបានទិញកូនឆ្កែ Goldendoodle ញីពីរក្បាល និងបានចាប់ផ្តើមអាជីវកម្មកូនឆ្កែតូចរបស់ពួកគេ។ ជាការពិតណាស់ ដំបូងពួកគេត្រូវការចិញ្ចឹមកូនឆ្កែសិន ហើយបន្ទាប់មកចាប់ផ្តើមដំណើរការបង្កាត់ពូជវា។

ពួកគេជួបការបរាជ័យមួយចំនួនក្នុងដំណើរការនេះ ក៏ប៉ុន្តែនៅក្នុងឆ្នាំដំបូងឆ្កែរបស់ពួកគេមានកូន ហើយមានដល់ទៅ១៣ក្បាល។ ឆ្កែមួយក្បាលៗលក់បានតម្លៃប្រមាណ ១.៥០០ដុល្លារ ហើយខាឡាបាននិយាយទាំងទឹកភ្នែក ពេលគាត់ដឹងថាគាត់ស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធបានត្រឹមត្រូវ ពេលដែលគាត់ឮពាក្យថាកូនឆ្កែ។ នៅក្នុងឆ្នាំតែមួយនោះ ចូតទទួលបានការឡើងតំណែងជានាយកសាលារដ្ឋនោះ។

អាជីវកម្មកូនឆ្កែរបស់ពួកគេបន្តរីកចម្រើនឡើង ហើយមកទល់ពេលនោះពួកគេមានកូនឆ្កែជាង៣០០ក្បាល ហើយតម្លៃក៏កើនឡើងទៅដល់ប្រមាណជា ២.៥០០ ដុល្លារក្នុងមួយក្បាល។ ជីវិតហិរញ្ញវត្ថុរបស់ពួកគេបានផ្លាស់ប្តូរ១៨០ដឺក្រេតែម្តង! ពួកគេបានទិញផ្ទះកាលពីឆ្នាំមុន ហើយឥលូវនេះពួកគេសងបំណុលរួចទាំងស្រុង។ ពួកគេបានធ្វើដំណើរទៅក្រៅប្រទេសក្នុងដំណើរកម្សាន្តដ៏អស្ចារ្យជាច្រើន និងបានឃើញព្រះជាម្ចាស់ធ្វើកិច្ចការជាច្រើនក្នុងក្រុមគ្រួសាររបស់ពួកគេ ដែលធ្វើឱ្យខាឡាត្រូវតែប្រាប់មនុស្សជាច្រើនអំពីព្រះរាជ្យរបស់ទ្រង់។ គាត់ទើបតែចេញសៀវភៅដំបូងរបស់គាត់ ដែលមានចំណងជើងថា *ផែនការដើម្បីចម្រុងចម្រើន៖ របៀបដែលព្រះជាម្ចាស់ប្រទានឱ្យយើងមានសេរីភាពផ្នែកហិរញ្ញវត្ថុតាមរយៈកូនឆ្កែ (Plans to Prosper: How God Gave Us Financial Freedom Through Puppies)*។

ថូត និងខាឡាកំពុងរស់នៅក្នុងជីវភាពស្របតាមព្រះរាជ្យ ជាជីវភាពដែលទាក់ទាញការចាប់អារម្មណ៍ពីមនុស្សជាច្រើន និងធ្វើឱ្យពួកគេឈប់ ហើយគិតអំពីព្រះជាម្ចាស់។ ព្យាការីអេសាយបាននិយាយអំពីពេលវេលានៃក្រុមជំនុំ នៅក្នុងគម្ពីរអេសាយជំពូក៦១ ជាកន្លែងដែលគាត់បានប្រាប់យើងពីអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យធ្វើនៅក្នុងជីវិតយើង ក្នុងពេលដែលយើងរស់នៅលើផែនដីនេះ។

> *ពេលនោះ គេនឹងប្រដូចអ្នកក្រុងយេរូសាឡឹម ទៅនឹងដើមឈើសក្ការៈនៃព្រះដ៏សុចរិត ជាសួនឧទ្យានរបស់ព្រះអម្ចាស់ដើម្បីបង្ហាញភាពថ្កុំថ្កើងរបស់ព្រះអង្គ។*
>
> — អេសាយ ៦១:៣

ដើមឈើសក្ការៈគឺជាដើមឈើដ៏រឹងមាំ ហើយទូទៅតែងមានទំហំធំដែរ។ ព្រះគម្ពីរចែងថាជីវិតយើងនឹងក្លាយទៅដូចជាដើមឈើសក្ការៈ ជាយុថ្កា នៅស្ថិតស្ថេរ និងមិនរង្គើរ។ ផលផ្លែនៃដើមឈើនេះនឹងជាសេចក្តីសុចរិត ដែលនិយាយដោយសាមញ្ញមានន័យថាមនុស្សនឹងមើលឃើញថាជីវិតគួរតែមានរូបភាពបែបណា គឺស្របតាមអ្វី

ដែលព្រះជាម្ចាស់មានបន្ទូលថាត្រឹមត្រូវ។ យើងគឺជាឧទ្យានរបស់ព្រះអម្ចាស់ មានន័យថាព្រះជាម្ចាស់នឹងដាក់យើងនៅកន្លែងដែលទ្រង់ទតឃើញថាស័ក្តិសម ដាក់យើងទាំងអស់គ្នានៅកន្លែងផ្សេងៗពីគ្នា មានមុខរបរផ្សេងៗ និងវប្បធម៌ផ្សេងៗពីគ្នា ដើម្បីបង្ហាញភាពចំរុះថ្កើងរបស់ព្រះអង្គ។ ព្រះជាម្ចាស់ចង់ទាក់ទាញការចាប់អារម្មណ៍ពីមនុស្សជាច្រើនជាមួយអ្នក! ទ្រង់សព្វព្រះហឫទ័យឱ្យមនុស្សមើលឃើញផលផ្លែដ៏ល្អនៅក្នុងជីវិតស្របតាមរបៀបរបស់ទ្រង់។ ដូចជាដើមឈើហូបផ្លែមួយដើមធ្វើឱ្យអ្នកដើរចូលទៅរកវា ដោយសារតែផ្លែឈើដ៏មានរសជាតិឈ្ងុយឆ្ងាញ់របស់វាដូច្នោះដែរ ព្រះជាម្ចាស់សព្វព្រះទ័យឱ្យជីវិតអ្នកមើលទៅប្រៀបដូចជាស្ថានសួគ៌នៅលើស្ថានមនុស្សលោក។

ដូច្នេះតើថូត និងខាឡាធ្វើវាបានយ៉ាងដូចម្តេចទៅ? ជាការពិតណាស់ វាជាការងារដ៏លំបាកក្នុងការចិញ្ចឹមកូនឆ្កែទាំងនោះ ក៏ប៉ុន្តែវាស័ក្តិសមនឹងតម្លៃថ្នូរនឹងសេរីភាព។ សេរីភាពទាំងអស់នោះបានចាប់ផ្តើមឡើងតាមរយៈការស្តាប់ឮផែនការ ជាព្រះបន្ទូលមកពីព្រះជាម្ចាស់។ គាត់បានឮតែពាក្យសាមញ្ញមួយថា «កូនឆ្កែ»! ក៏ប៉ុន្តែនោះជាពាក្យតែមួយគត់ដែលគាត់ត្រូវការ។ ព្រះជាម្ចាស់នឹងមានបន្ទូលមកអ្នកដូចគ្នា។ ទ្រង់នឹងនាំអ្នកទៅរកវាលស្មៅខៀវខ្ចី និងកន្លែងស្ងាត់ក្បែរមាត់ទឹកដូចមានចែងក្នុងគម្ពីរទំនុកតម្កើងជំពូក ២៣។

ក៏ប៉ុន្តែដូចដែលអ្នកគិតស្រមៃមែន គ្រាន់តែការស្តាប់ឮពីផែនការមិនគ្រប់គ្រាន់ទេ។ ខ្ញុំនឹងធ្វើការពិភាក្សាពីជំហានទី៥ នៅក្នុងជំពូកបន្ទាប់ ហើយជំពូកនោះអាចជាជំពូកដ៏សំខាន់បំផុតក្នុងចំណោមជំពូកទាំងអស់ ព្រោះជំហានទី៥ គឺជាកន្លែងដែលមនុស្សភាគច្រើនបរាជ័យ។ ក៏ប៉ុន្តែអ្នកបរាជ័យមិនមែនជាអ្នកទេ អ្នកនឹងដើរនៅក្នុងសេចក្តីល្អរបស់ព្រះជាម្ចាស់ គឺដូចជានៅក្នុងរឿងជាច្រើនដែលអ្នកបានអានក្នុងសៀវភៅនេះដែរ! តើអ្នកត្រៀមខ្លួនហើយឬនៅ? សូមបន្តទៅជំហានទី៥។

# ជំពូក ៩
# ដល់ពេលចេញទៅហើយ!

កសិករគ្រប់រូបដឹងថាគ្រប់រដូវចម្រូតនីមួយៗមាននូវពេលវេលាច្បាស់លាស់ និងពិសេសផ្សារភ្ជាប់នឹងចម្រូតនេះ។ ការដឹងពីរដូវកាលចម្រូតបានត្រឹមត្រូវសម្រាប់ដំណាំជាក់លាក់មួយគឺជារឿងខុសគ្នារវាងជោគជ័យ និងបរាជ័យ។ និយាយឱ្យច្បាស់ទៅ៖ អ្នកអាចខកខានក្នុងការប្រមូលផល។ ដូចនេះ វាជាប្រធានបទដ៏ធំ និងសំខាន់មួយ។ តើអ្នកធ្លាប់ចូលហាងលក់ទំនិញ ដោយឃើញនូវផ្លែប៉ោមក្រហមដ៏ទាក់ទាញទេ ហើយគិតថា *អូហ៎ ផ្លែប៉ោមនេះទំនងណាស់* ប៉ុន្តែពេលអ្នកទៅដល់ផ្ទះ ហើយក្រោយត្លក់មួយម៉ាត់ទៅក៏គិតវិញថា *ងាប់ហើយ អត់ជាតិសោះហ្នឹង?* នេះហើយគឺជាបញ្ហានៃពេលវេលា។

**គោលគំនិតចំណែកទ្វេដង ការមានច្រើនបរិបូហូរហៀរ អាចមើលទៅហាក់ដូចជាមិនអាចនឹងស្រមើស្រមៃទៅរួចបានក្នុងពេលតលូវនេះទេបើធៀបនឹងកន្លែងដែលអ្នកមើលឃើញខ្លួនអ្នក ក្នុងជីវិតរបស់អ្នកនៅពេលនេះឡើយ។ ក៏ប៉ុន្តែទីនេះគឺជាកន្លែងដែលអ្នកត្រូវតែចាប់ផ្តើមដំណើរទៅរកសេរីភាពរបស់អ្នក - នៅក្នុងការគិតរបស់អ្នក។**

ខ្ញុំមិនអាចប្រាប់អ្នកថាតើមានបញ្ហាហិរញ្ញវត្ថុចំនួនប៉ុន្មានដែលខ្ញុំធ្លាប់បានឮ និងបានដោះស្រាយនោះទេ ពោលគឺមនុស្សបានត្រឹមតែមានគំនិត ហើយក៏បានខក

ខាននឹងពេលកំណត់។ ខគម្ពីរដែលខ្ញុំពេញចិត្តទាក់ទងនឹងពេលកំណត់នោះគឺ គម្ពីរម៉ាថាយ ១៣:៤៤។

> *«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជា**កំណប់**ដែលគេកប់ទុកនៅក្នុងស្រែមួយ។ មានបុរសម្នាក់រកកំណប់នោះឃើញ ហើយកប់ទុកវិញ។ គាត់មានចិត្តត្រេកអរជាខ្លាំង ក៏ចេញទៅលក់ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាត់មាន យកប្រាក់ទិញដីស្រែនោះ។*

នៅក្នុងសាច់រឿងនេះ បុរសនោះមានភាពឈ្លាសវៃគ្រប់គ្រាន់ដែលបានដឹងពីការនោះក្នុងនាទីនោះ គាត់មិនមានសមត្ថភាពធ្វើជាម្ចាស់លើកំណប់នោះទេ។ គាត់ត្រូវតែចេញទៅ ហើយរៀបចំចាត់ចែងក្នុងការទិញយកវា។

ជាឧទាហរណ៍ នៅពេលកាឡុបឮពាក្យថា កូនឆ្កែ គឺមិនមែនមានន័យថា គាត់បានដាក់ផ្សាយពាណិជ្ជកម្មលក់កូនឆ្កែនោះទេ។ គាត់មិនទាន់មានកូនឆ្កែនៅឡើយទេ។ គឺនៅមានការរៀបចំច្រើនណាស់។ ដំបូង ពួកគេត្រូវតែទិញឆ្កែញីពីរក្បាលសិន។ ពួកគេត្រូវសង់កន្លែង ធ្វើជារោងសម្រាប់ពួកគេ និងត្រូវគ្រោងទុកសម្រាប់កូនឆ្កែដែលនឹងកើតមក។ ពួកគេក៏ត្រូវរៀនស្វែងយល់ពីបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងតម្រូវការនៃការចាក់វ៉ាក់សាំងសម្រាប់កូនឆ្កែដែលកូនឆ្កែទាំងនោះត្រូវមាន ប្រសិនបើអ្នកចង់លក់ឆ្កែទាំងនោះ។

បើនិយាយត្រួសៗទៅ ក៏នៅមានបញ្ហាពាក់ព័ន្ធនឹងរឿងលិខិតអនុញ្ញាត ការធ្វើទីផ្សារ ធនាគារ និងការបង់ពន្ធនានា។ រឿងទាំងនេះចាំបាច់ត្រូវមើលឱ្យគ្រប់សព្វមុនពេលអ្នកឈានជើងចូលដល់រដ្ឋូវចម្រូតនៃគំនិតអាជីវកម្មរបស់អ្នក។

ឧបមាថា អ្នកបានឆ្លើរចរាល់នូវជំហានសំខាន់ៗដែលគួរឆ្លើរចរាល់ហើយ តែរឿងលំបាកៗនៅខាងមុខនៅតែមាន។ អ្នកត្រូវតែបោះជើងឈានចូលក្នុងនិមិត្តដែលព្រះជាម្ចាស់បានមានបន្ទូលមកកាន់អ្នក។ មែនហើយ គំនិតនោះប្រាកដជាធំជាងគំនិតរបស់អ្នក ហើយប្រហែលជាមាននូវភាពភ័យខ្លាចមួយចំនួនកើតឡើងក្នុងពេលឈាន

ជើងចេញផងដែរ។ ប៉ុន្តែសេចក្តីភ័យខ្លាចនោះជាអ្នកពីមុនទេ។ ត្រូវចងចាំថា ពេលនេះអ្នកជាមនុស្សថ្មីហើយ។

នៅពេលព្រះជាម្ចាស់មានបន្ទូលមកខ្ញុំពាក់ព័ន្ធនឹងការចាប់ផ្តើមអាជីវកម្មរបស់ខ្ញុំ ខ្ញុំពិតជាអល់អែកណាស់។ ខ្ញុំចាប់ផ្តើមធ្វើពីនេះពីនោះគ្រប់មុខ។ ទោះបីជាព្រះជាម្ចាស់បានមានបន្ទូលប្រាប់ខ្ញុំក្នុងសុបិនថាឱ្យខ្ញុំឈានជើងចេញ ហើយខ្ញុំបានធ្វើរឿងចាំបាច់ដែលត្រូវធ្វើរួចរាល់ហើយក៏ដោយ ក៏ខ្ញុំនៅតែអន្ទះសាអំពីអាជីវកម្មនេះដដែល។ ពេលនេះ គ្រប់យ៉ាងដែលធ្លាប់តែត្រូវពឹងផ្អែកលើខ្ញុំ ក៏បានបោះជំហានចេញផុតទៅ ហើយធ្វើវាដោយខ្លួនឯង។ តើអ្នកធ្លាប់មានមិត្តភក្តិ ឬស្គាល់នរណាម្នាក់ដែលតែងតែនិយាយអំពីអ្វីដែលពួកគេនឹងធ្វើ តែមិនដែលធ្វើវាទេ? ខ្ញុំស្គាល់មនុស្សដូចពួកគេនេះច្រើនណាស់! នៅចាំទេ ខ្ញុំបានបណ្តុះបណ្តាលដល់អ្នកធ្វើការផ្នែកលក់ជាង៣០ឆ្នាំហើយ។

នៅពេលដែលខ្ញុំចាប់បើកដំណើរការអាជីវកម្មរបស់ខ្ញុំ ខ្ញុំគ្មានទទួលបានការចាត់ចែងណាទេ។ ខ្ញុំរស់នៅយ៉ាងតឹងរឹងលើបេសកកម្មនោះ ហើយខ្ញុំជាអ្នករ៉ាប់រងលើអ្វីៗគ្រប់យ៉ាងតែម្នាក់ឯង។ ប៉ុន្តែរបស់មួយដែលខ្ញុំមាននោះគឺ ចិត្តឆេះឆួល។ នៅពេលដែលព្រះជាម្ចាស់បានដឹកនាំខ្ញុំឱ្យចាប់ផ្តើមក្រុមហ៊ុនមួយ ដើម្បីជួយមនុស្សដែលវណ្ឌកនឹងបំណុល នោះខ្ញុំមានការតាំងចិត្តជាខ្លាំង។ ខ្ញុំធ្លាប់រងទុក្ខញាំញីនឹងបញ្ហាវិបត្តិហិរញ្ញវត្ថុស្ទើរពេញមួយជីវិតទៅហើយ ហើយពេលនេះទើបខ្ញុំរកឃើញចម្លើយ នោះគឺព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលខ្ញុំចង់ប្រាប់ដល់អ្នកទាំងអស់គ្នាក្នុងពេលនេះឯង។ ទីពីរនៅពេលដែលព្រះជាម្ចាស់ជួយខ្ញុំក្នុងការដាក់បញ្ចូលនូវផែនការដែលទ្រង់បានបង្ហាញដល់ខ្ញុំពីរបៀបសរសេរផែនការសម្រាប់គ្រួសារដើម្បីចាកចេញពីបំណុលក្នុងរយៈពេលប្រាំទៅប្រាំពីរឆ្នាំ ដោយរាប់បញ្ចូលទាំងបំណុលផ្ទះ និងដោយគ្មានការផ្លាស់ប្តូរគម្រោងថវិការបស់ពួកគេ នោះខ្ញុំមានចិត្តឆេះឆួលលើសអ្វីៗទាំងអស់។ ខ្ញុំបានដឹងថា ខ្ញុំមានចំណុចពិសេសមួយក្នុងទីផ្សារហិរញ្ញវត្ថុ ហើយខ្ញុំក៏មានសាច់រឿងដែលត្រូវប្រាប់ដែរ។

ប៉ុន្តែជាថ្មីម្តងទៀត ខ្ញុំត្រូវតែមាននូវគម្រូពិសេសដែលមានលក្ខណៈល្អឯក មុននឹងខ្ញុំបើកនូវកុងតាក់នោះ។

ច្បាស់ណាស់ថា តែងតែមាននូវរឿងរ៉ាវដែលអ្នករៀនសូត្របណ្តើរៗក្នុងពេលអនុវត្តវា ប៉ុន្តែនៅពេលដែលអ្នកលោតទៅ នោះអ្នកគួរតែមាននូវគម្រោងជាមូលដ្ឋានដែលបានអភិវឌ្ឍរួចរាល់។ ប៉ុន្តែមិនថាឱកាសនោះធំប៉ុនណានោះទេ ផលិតផល ឬប្រាក់ឈ្នួលដ៏មានសក្តានុពល តែងតែកើតមាននៅថ្ងៃនេះ ហើយថ្ងៃនេះគឺជាថ្ងៃដែលអ្នកត្រូវតែឈានជើងចូលក្នុងផែនការនោះហើយ។

និយាយទៅ ចំណុចនេះគឺជាបញ្ហាពិតប្រាកដដែលខ្ញុំចង់លើកឡើង អ្វីដែលខ្ញុំជឿនោះគឺជាមូលហេតុចម្បងដែលមនុស្សជាច្រើនឈោងចាប់គោលដៅរបស់ពួកគេសូម្បីតែក្រោយពេលដែលពួកគេបានឮពីព្រះជាម្ចាស់អំពីការចង្អុលបង្ហាញ និងចម្លើយសម្រាប់បញ្ហាហិរញ្ញវត្ថុរបស់ពួកគេរួចហើយក្តី។

## ការបង្អែបង្អង់!

ការបង្អែបង្អង់អាចឈរលើមូលដ្ឋាននៃភាពអសុវត្ថិភាព ភាពភ័យខ្លាច ឬក៏គ្រាន់តែជាភាពខ្ជិលក៏ថាបានដែរ។ ប៉ុន្តែរឿងមួយដែលច្បាស់លាស់នោះគឺ វាងាយស្រួលនឹងធ្វើទេ! ខ្ញុំបានអានអត្ថបទសិក្សាខាងក្រោមទាក់ទិននឹងទម្លាប់របស់សិស្សបញ្ចប់ការសិក្សាពាក់ព័ន្ធនឹងការបង្អែបង្អង់។

*ជេននីបោសសម្អាតផ្ទះអាផាតមិនរបស់នាង។ ខាធីដោះស្រាយរូបផ្គុំគណិតវិទ្យា។ ម៉ាត់ផែកមើលពិន្ទុកីឡា ហើយខាមិនវិញកំពុងតែធ្វើបច្ចុប្បន្នភាពលើទំព័រហ្វេសប៊ុករបស់នាង។ ពួកគេទាំងអស់គ្នាជានិស្សិតចិត្តវិទ្យាដែលកំពុងតែទម្លាក់ចោលការងារផ្សេងៗដែលពួកគេគួរតែកំពុងធ្វើនាពេលនេះ។ នេះចាត់ទុកថាកំពុងតែមានការបង្អែបង្អង់យ៉ាងប្រាកដណាស់។*

*វាជាទម្លាប់ដ៏តានតឹងមួយក្នុងការបញ្ឈប់ ជាពិសេសនោះគឺសម័យបច្ចុប្បន្ននេះឯង នៅពេលដែលអ៊ិនធើណិតបណ្តែតបណ្តោយឱ្យសិស្សគេចផុតពីពេលសិក្សាដែលមានគោលវិន័យដោយគ្រាន់តែចុចកុំព្យូទ័រមួយឃ្លីកប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវមួយនៅឆ្នាំ២០០៧នៅសាកលវិទ្យាល័យកាល់ហ្គារីដោយបណ្ឌិតចិត្តវិទ្យា លោក ភា ស្ទីល ដោយការស្រាវជ្រាវនេះបង្ហាញថា មាននិស្សិតសាកលវិទ្យាល័យចំនួន ៨០ ទៅ ៩០ ភាគរយមានការបង្អែបង្អង់ គឺច្បាស់ណាស់ថាពួកគេបង្អែបង្អង់ក្នុងការធ្វើកិច្ចការមេរៀនរបស់ខ្លួន។*[6]

និយាយរួម ខ្ញុំហ៊ានសន្និដ្ឋានថា ការនេះមិនមែនពិតតែសម្រាប់សិស្សនិស្សិតនោះទេ។ មានការរំខានដ៏ខ្លាំងក្លាណាស់។ ការលើកទូរសព្ទ ឬបើកអ៊ីមែលគឺជាការស៊ីពេលវេលាយ៉ាងពិតប្រាកដ។ ប៉ុន្តែការបង្អែបង្អង់មានចំណែកដែលមាននូវកលល្បិច និងកិច្ចការរបស់អារក្សដែលអ្នកគួរតែដឹង។ ដើម្បីបង្ហាញឱ្យឃើញ និងបំភ្លឺលើប្រធានបទដ៏គ្រោះថ្នាក់នេះ (មែនហើយ ខ្ញុំហៅថាជាប្រធានបទដ៏គ្រោះថ្នាក់) នោះខ្ញុំចង់មើលខគម្ពីរ ១កូរិនថូស ២:៦-៨។

*ប៉ុន្តែ សេចក្តីដែលយើងប្រៀនប្រដៅក្នុងចំណោមអ្នកដែលមានជំនឿគ្រប់លក្ខណៈហើយនោះ ក៏ជាប្រាជ្ញាម្យ៉ាងដែរ តែមិនមែនជាប្រាជ្ញារបស់មនុស្សលោក ឬជាប្រាជ្ញារបស់អ្នកគ្រប់គ្រងមនុស្សលោកនេះ ដែលនឹងត្រូវវិនាសសាបសូន្យទៅនោះទេ។ យើងប្រៀនប្រដៅអំពីប្រាជ្ញារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបង្កប់ន័យទុកតាមគម្រោងការដ៏លាក់កំបាំងរបស់ព្រះអង្គ តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ គឺព្រះអង្គបានគ្រោងទុកថានឹងប្រទានសិរីរុងរឿងមកយើង។ <u>**គ្មាននរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងមនុស្សលោកនេះ បាន**</u>*

[6] https://www.apa.org/gradpsych/2010/01/procrastination

*<u>ស្គាល់ប្រាជ្ញារបស់ព្រះអង្គទេ។ ប្រសិនបើគេពិតជាបានស្គាល់មែន គេមិនឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនោះឡើយ</u>។*

— ១កូរិនថូស ២:៦-៨ (គខប)

អ្នកគួរតែសរសេរខគម្ពីរនេះទុកនៅត្រង់ណាមួយហើយ។ សាតាំងនឹងប្តូរវិធី ប្រសិនបើវាដឹងពីអ្វីដែលអ្នកកំពុងតែធ្វើ! ហេតុនេះហើយទើបព្រះជាម្ចាស់មានបន្ទូលជាប្រស្នា។ នេះជាមូលហេតុដែលព្រះជាម្ចាស់រង់ចាំរហូតដល់ពាក់កណ្តាលអាធ្រាត មុននឹងទ្រង់បង្ហាញចម្លើយរបស់អ្នក។ អ្នកត្រូវតែដឹង និងចងចាំថា យើងមានសត្រូវម្នាក់។ សត្រូវរបស់អ្នកមិនមែនគ្រាន់តែជាតួអង្គន័យធៀបដែលមាននូវរនាស់ និងស្លៀកសម្លៀកបំពាក់ពណ៌ក្រហមនោះទេ។ ព្រះគម្ពីរចែងយ៉ាងច្បាស់ថា៖

*ត្រូវភ្ញាក់ខ្លួន ហើយប្រុងស្មារតីជានិច្ច! ដ្បិតមារជាសត្រូវនឹងបងប្អូន កំពុងតែក្រវែលជុំវិញបងប្អូន ដូចសិង្ហក្រវែល ទាំងគ្រហឹម រកត្របាក់ស៊ីអ្នកណាម្នាក់។*

— ១ពេត្រុស ៥:៨ (គខប)

ច្បាស់ណាស់ថា វាមិនអាចចេះតែត្របាក់នរណាម្នាក់បានទេ តែវាចង់ទាញអ្នកចេញពីដែនអំណាចគ្រប់គ្រងនៃស្ថានសួគ៌ឱ្យធ្លាក់ចូលក្នុងការត្រួតត្រាស្របច្បាប់របស់វា ដើម្បីសម្លាប់ លួច និងបំផ្លាញ។ ព្រះគម្ពីរចែងថា «មារជាសត្រូវ!» ល្បិចកលមួយក្នុងចំណោមល្បិចកលនានារបស់សាតាំងគឺដើម្បីបញ្ឆោតអ្នកឱ្យធ្លាក់ចូលក្នុងភាពស្កប់ចិត្ត ចូលក្នុងកន្លែងនៃការបង្អែបង្អង់។ ការនេះនឹងផ្តល់ពេលវេលាឱ្យវាអាចដឹងថាអ្នក និងព្រះជាម្ចាស់កំពុងបំពេញភារកិច្ចអ្វី។

**ការបង្អែបង្អង់អាចមានគ្រោះថ្នាក់ដល់ស្លាប់!**

ខ្ញុំនៅចាំពីការយល់សប្តិក្នុងរាត្រីមួយ។ រូបភាពដែលខ្ញុំបានឃើញនោះគឺនៅពេលយប់ ហើយពន្លឺដែលចាំងចេញពីបន្ទប់គេងរបស់ខ្ញុំនោះបានចាំងចេញមកលើទីធ្លាវាលស្មៅ រហូតដល់ពន្លឺនោះបានរលត់ក្នុងភាពងងឹតទៅ។ នៅត្រង់កន្លែងដែលពន្លឺ

រលត់បាត់ទៅនោះ  គឺនៅក្នុងស្រមោលនោះ ខ្ញុំបានឃើញអារក្សពីរនាក់កំពុងឈរបែរមុខមករកបង្អួចរបស់ខ្ញុំដោយមានកាន់សៀវភៅសរសេរក្នុងដៃផង។ ខ្ញុំបានដឹងច្បាស់ថា ពួកគេត្រូវបានបញ្ជូនមកដើម្បីស្វែងរកការបើទ្វារស្របច្បាប់ចូលក្នុងផ្ទះរបស់ខ្ញុំ។ ពួកគេកំពុងកត់ចំណាំ កំពុងសម្លឹងមើលកន្លែងដែលមានភាពខ្សោយ ដែលពួកគេអាចចឹងព្យាយាមបញ្ឈប់កិច្ចការរបស់ព្រះជាម្ចាស់។

ការបង្អែបង្អង់អាចមានគ្រោះថ្នាក់ដល់ស្លាប់! ស្លាប់ទៅដូចជាធ្ងន់ធ្ងរណាស់មែនទេ? ស្តាប់ទៅ វាផ្ទុយនឹងអ្វីដែលបានប្រាប់អ្នកអំពីការល្បួងនៃការបង្អែបង្អង់។ សំឡេងរបស់វាពោរពេញដោយកលល្បិច និងការលួងលោម «បើអ្នកធ្វើវានៅពេលក្រោយ វានឹងមិនថ្វីនោះទេ»។ អ្នកនៅតែអាចធ្វើបាននៅពេលក្រោយជានិច្ច។ ប៉ុន្តែតើវាពិតដែរឬទេ? ខ្ញុំសូមចែកចាយអំពីរឿងរ៉ាវមួយដែលនឹងបង្ហាញឱ្យអ្នកបានឃើញថាតើការបង្អែបង្អង់អាចមានភាពគ្រោះថ្នាក់យ៉ាងណា។

> *រីឯជនភីលីស្ទីននោះវិញ  ក៏ដើរចូលមករកដាវីឌដែរ  ដោយមានម្នាក់កាន់ខែលដើរពីមុខ។ ពេលជនភីលីស្ទីនក្រឡេកមើលមកដាវីឌ វាមើលងាយ ព្រោះឃើញដាវីឌនៅក្មេង  មានថ្ពាល់ក្រហម  និងមានទឹកមុខស្រស់ល្អ។ ជនភីលីស្ទីននោះជេរដាវីឌថា៖ «<u>**តើអញជាឆ្កែឬ បានជាឯងកាន់ដំបងមកវាយអញដូច្នេះ**</u>?»។ វាក៏យកនាមព្រះរបស់វាមកដាក់បណ្ដាសាដាវីឌ។  វាពោលមកកាន់ដាវីឌថា៖  «មកជិតអញមក៏! អញនឹងយកសាច់ឯងឱ្យត្មាត និងសត្វសាហាវស៊ី!»*
>
> — ១សាំយ៉ូអែល ១៧:៤១-៤៤ (គខប)

> *ពេលនោះ ជនភីលីស្ទីនដើរតម្រង់ចូលមករកដាវីឌ ដាវីឌក៏រត់យ៉ាងលឿនទៅតទល់នឹងវា។  ដាវីឌលូកដៃក្នុងកូនថង់យ៉ាងរហ័ស  យកក្រួសមួយគ្រាប់មកដាក់នឹងខ្សែដង្ហក់   បាញ់ចំថ្ងាសជនភីលីស្ទីននោះ។  គ្រាប់ក្រួសផ្ទុះចូលក្នុងថ្ងាសរបស់ជនភីលីស្ទីន វាក៏ដួលផ្កាប់មុខ។*

— ១សាំយ៉ូអែល ១៧:៤៨-៤៩ (គខប)

សាច់រឿងរបស់ដាវីឌនិងកូលីយ៉ាតគឺជាសាច់រឿងដ៏អស្ចារ្យមួយ។ ជាតិសាសន៍អ៊ីស្រាអែលទាំងមូលមានភាពភ័យខ្លាចនៅពេលដែលពួកគេបានលើពីការស្រែកសង្សកដាក់របស់កូលីយ៉ាត។ ប៉ុន្តែដាវីឌពោលថា គាត់នឹងវាយជាមួយកូលីយ៉ាតដោយលក្ខខណ្ឌតែមួយប៉ុណ្ណោះ៖ គាត់អាចជ្រើសរើសអាវុធផ្ទាល់ខ្លួនបាន នោះគឺដង្ហក់ដែលគាត់ធ្លាប់ប្រើរាប់ឆ្នាំមកហើយក្នុងពេលដែលខ្លួនមើលថែការពារហ្វូងចៀម។ នៅពេលដាវីឌចូលទៅជិតកូលីយ៉ាត នោះកូលីយ៉ាតហាក់មានការភាន់ច្រឡំ ហើយក៏ស្រែកថា «<u>តើអញជាឆ្កែឬ បានជាឯងកាន់ដំបងមកវាយអញដូច្នេះ?</u>» អ្វីដែលកូលីយ៉ាតគិតនោះគឺថា ដំបងនោះគឺជាឈើច្រត់របស់ដាវីឌប៉ុណ្ណោះ។ កូលីយ៉ាតមិនបានឃើញដង្ហក់ដែលសៀតនៅនឹងចង្កេះរបស់ដាវីឌឡើយ។ ទេ ដាវីឌកំពុងតែប្រើប្រាស់ដំបងនោះជាឧបករណ៍បញ្ឆោត ដោយទាញចំណាប់អារម្មណ៍កូលីយ៉ាតលើដំបងនេះ ជំនួសឱ្យដង្ហក់នោះ។ នៅពេលដែលកូលីយ៉ាតឆ្ពោះសំដៅទៅរកដាវីឌ នោះដាវីឌក៏រត់សំដៅទៅកូលីយ៉ាង។ នេះក៏ជាវិធីសាស្ត្រមួយទៀតដែលដាវីឌប្រើដែរ។ គាត់ដឹងថា វារឹតតែធ្វើឱ្យកូលីយ៉ាតពិបាកនឹងមើលឃើញដង្ហក់ប្រសិនបើគាត់រត់សំដៅទៅកូលីយ៉ាតភ្លាមៗ។

**នេះគឺជាអ្វីដែលសាតាំងចង់ធ្វើចំពោះអ្នក។ វាចង់យកផែនការរបស់អ្នកធ្វើជាឈ្លើយរបស់វា។**

ប៉ុន្តែចុះបើដាវីឌបានបញ្ចេញលក្ខណៈដូចដែលមនុស្សភាគច្រើនធ្វើវិញនោះ? គឺមានតែដើរចូលក្នុងជម្លោះទាំងអារម្មណ៍ភ័យខ្លាច នោះពួកគេមានការបង្អែបង្អង់ហើយ។ ចុះប្រសិនបើដាវីឌរាំជុំវិញកូលីយ៉ាតរហូតដល់គាត់មានអារម្មណ៍ថាខ្លួនត្រៀមខ្លួនរួចរាល់ដើម្បីប្រតិបត្តិការនោះ? ខ្ញុំជឿថា កូលីយ៉ាតប្រាកដជានឹងបានឃើញដង្ហក់នោះមិនខាន ដោយបានដឹងនូវយុទ្ធសាស្ត្ររបស់ដាវីឌ ហើយនឹងបានប៉ះប៉ូវតាមភាព

ជាក់ស្តែងនោះមិនខាន។ សង្គ្រាមនោះប្រាកដជាត្រូវចាញ់ ហើយជាតិសាសន៍អីស្រាអែលទាំងមូលក៏ត្រូវធ្វើជាឈ្លើយ។

នេះគឺជាអ្វីដែលសាតាំងចង់ធ្វើចំពោះអ្នក។ វាចង់យកផែនការរបស់អ្នកធ្វើជាឈ្លើយរបស់វា។ ប្រសិនបើវាអាចធ្វើឱ្យអ្នកផ្អាកបាន ដោយរង់ចាំរហូតដល់អ្នកមានអារម្មណ៍ថាអ្នកបានត្រៀមលក្ខណៈរួចរាល់ នោះវានឹងមានពេលវេលាដើម្បីផ្លាស់ប្តូរកលល្បិចរបស់ខ្លួនដើម្បីរាំងផែនការរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នក។ ដូច្នេះ តើការបង្អែបង្អង់មានគ្រោះថ្នាក់ដែរឬទេ? ប្រាកដណាស់! ខ្ញុំប្រាកដណាស់ថា វាបានធ្វើឱ្យអ្នកខាតបង់អស់ប្រាក់រាប់ពាន់ដុល្លាររួចមកហើយនៅក្នុងជីវិតរបស់អ្នក។ នៅក្នុងករណីរបស់ដាវីឌ វាអាចធ្វើឱ្យខាតបង់អស់ជីវិតរាប់ពាន់នាក់ទៀតផង។

នេះហើយជាមូលហេតុដែលអ្នកគួរតែឈានជើងចេញដោយទំនុកចិត្ត នៅពេលដែលអ្នកដឹងពីពេលវេលា ហើយមានផែនការរបស់អ្នក។ ខ្ញុំជឿថា អ្នកនឹងមានការបង្ហាញតម្រុយពីព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីជួយអ្នកឱ្យដឹងថាតើពេលណាដែលការនោះដល់ពេលដែលត្រូវឈានជើងចេញ។ ប៉ុន្តែដោយសារតែមានការបង្រៀនខុសឆ្គង នោះក៏មានមនុស្សជាច្រើនស្ទាក់ស្ទើរ ឬឈានជើងចេញទៅ ហើយបន្ទាប់មក ពោលគឺនៅពេលដែលពួកគេរកឃើញមានភាពរកាំរកូស នោះពួកគេក៏ដកថយ ហើយគិតថាពួកគេច្បាស់ជាបានបាត់បង់ព្រះជាម្ចាស់មិនខាន។

## ចូរកុំភ័យខ្លាចនូវភាពរកាំរកូស

មនុស្សម្នាបានប្រាប់ខ្ញុំថា នៅពេលដែលពួកគេឈានជើងចេញទៅ នោះអ្វីៗអាក្រក់ និងប្រទូសភាពក៏កើតមានឡើង។ និយាយទៅ អ្នកមានការបំពាក់បំប៉នឱ្យចេះដោះស្រាយរឿងអាក្រក់ៗដោយគ្មានការភ័យខ្លាចរួចទៅហើយ។ សត្រូវទើបតែបានទាញបិទនូវផែនការនៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់អ្នក ហើយវាកំពុងតែបញ្ចេញប្រតិកម្មដើម្បីបិទវាទាំងស្រុង។ វាមិនអាចបញ្ឈប់ផែនការរបស់អ្នកនាពេលឥលូវនេះបានទេ។ វា

យឺតពេលហើយ។ ប៉ុន្តែប្រសិនបបើវាអាចធ្វើឱ្យអ្នកមានការសង្ស័យចំពោះព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលបានដឹកនាំអ្នកមកដល់ត្រង់ចំណុចនេះ នោះភាពភ័យខ្លាចនឹងនាំអ្នក រុញច្រានអ្នកត្រលប់ទៅវិញ។ វាចង់បង្កចលាចលមួយដែលធ្វើឱ្យអ្នកចុះចាញ់។ ប៉ុន្តែពេលនេះ អ្នកត្រូវតែឈរឱ្យកាន់តែរឹងមាំជាងពេលណាៗទាំងអស់ ហើយអ្នកត្រូវប្រើប្រាស់សិទ្ធិអំណាចដើម្បីគ្រប់គ្រងលើវា។ ចូរកុំខ្លាចក្នុងការនិយាយថា «ទេ អ្នកនឹងមិនធ្វើបែបហ្នឹងឡើយ» ឬ «ខ្ញុំនឹងបិទវិញ្ញាណនៃភាពតានតឹងច្រឡំដែលកំពុងតែព្យាយាមធ្វើទុក្ខទោសដាក់ខ្ញុំ។ ខ្ញុំដឹងពីអ្វីដែលព្រះអម្ចាស់មានបន្ទូលឱ្យធ្វើ ហើយខ្ញុំកំពុងតែធ្វើវានៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ សាតាំងអើយ ឆាប់ថយចេញទៅ!»

ជាអកុសល គ្រិស្តបរិស័ទដែលមិនមានការបង្ហឹកបង្ហឺនភាគច្រើននាពេលសព្វថ្ងៃនេះ មានប្រតិកម្មចំពោះការវាយបករបស់សាតាំងដោយភាពភ្ញាក់ផ្អើល។ ពួកគេជឿថា ដោយសារតែព្រះជាម្ចាស់បានមានបន្ទូលមកកាន់ពួកគេ និងបានប្រទានផែនការរបស់ទ្រង់មកកាន់ពួកគេ នោះអ្វីៗនឹងដំណើរការទៅមុខយ៉ាងរលូន និងឆាប់រហ័សដោយគ្មានការភ្ញាក់ផ្អើលអ្វីឡើយ។

ឥលូវនេះ ចូរកុំយល់ច្រឡំចំពោះអ្វីដែលខ្ញុំកំពុងនិយាយ។ យើងមានសិទ្ធិអំណាចពេញលេញលើវិញ្ញាណអាក្រក់ ប៉ុន្តែយើងមិនមានសិទ្ធិអំណាចពេញលេញលើមនុស្សឡើយ។ ត្រូវកត់ចំណាំទុកថា ទោះបីជាខ្ញុំស្ថិតនៅក្រោមដែនអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្តី ក៏មានមនុស្សជាច្រើនដែលនៅជុំវិញខ្ញុំមិនស្ថិតក្រោមដែនអំណាចគ្រប់គ្រងរបស់ទ្រង់ ហើយពួកគេនឹងជាប់ជាឈ្លើយនៃពាក្យចចាមអារ៉ាម និងភាពតានតឹងច្រឡំ។ ពួកគេអាចវិនិច្ឆ័យខុសចំពោះកត្តាជំរុញចិត្តរបស់ខ្ញុំ ឬនាំមកនូវការបៀតបៀនចំពោះខ្ញុំ។

ប៉ុន្តែពួកគេមិនអាចបញ្ឈប់ផែនការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធឡើយ!!! សត្រូវនឹងនៅបន្តចូលមកដោយភាពឃឹតយ៉ាវ និងខ្វះការប្រឹងប្រែង។ ព្រះជាម្ចាស់មកមុនពួក

គេ ហើយទ្រង់នឹងដឹកនាំអ្នកទៅកាន់ជ័យជម្នះ ប្រសិនបើអ្នកនៅរក្សាជំហររឹងមាំនៅក្នុងជំនឿ និងបដិសេធមិនសម្របសម្រួល។

ជំហានដែលកំពុងឈានជើងចេញ ជាជំហានដែលនឹងមានភាពក្លាហានកាន់តែខ្លាំង ជាជំនឿដើម្បីឈានជើងចេញទៅ។ ជំនឿនាំអ្នកឱ្យមកដល់ត្រឹមនេះ ប៉ុន្តែពេលនេះវានឹងទាមទារនូវភាពក្លាហានដើម្បីឈានជើងចេញទៅ។ ខ្ញុំគិតថា បញ្ហានោះគឺថាមនុស្សមានការយល់ច្រឡំចំពោះសាច់រឿងសមុទ្រក្រហម និងសាច់រឿងទន្លេយ័រដាន់។

នៅក្នុងរឿងសមុទ្រក្រហម ប្រជាជនអ៊ីស្រាអែលត្រូវបានដោះលែងឱ្យចេញពីស្រុកអេស៊ីប ហើយបានធ្វើដំណើរទៅកាន់សមុទ្រក្រហម ជាកន្លែងដែលសមុទ្រ និងភ្នំនៅហ៊ុំព័ទ្ធពួកគេជុំជិត ខណៈពេលដែលស្ដេចផារ៉ោនបានផ្លាស់ប្ដូរគំនិតរបស់ទ្រង់ ហើយក៏បានចេញតាមប្រកិតពីក្រោយពួកគេ។ មើលទៅពួកគេគ្មានផ្លូវរត់គេចឡើយ។ ប៉ុន្តែលោកម៉ូសេបានលើកឈើច្រត់ (សិទ្ធិអំណាច) របស់គាត់ឡើង ហើយទឹកសមុទ្រក្រហមក៏ញែកជាពីរ។ ពួកគេដើរឆ្លងកាត់លើដីស្ងួត ហើយកងទ័ពរបស់ស្ដេចផារ៉ោនក៏ព្យាយាមតាមពីក្រោយ។ ប៉ុន្តែនៅពេលដែលកងទ័ពរបស់ស្ដេចផារ៉ោនដើរឆ្លងតាមនោះសមុទ្រក៏បានលេបត្របាក់ពួកគេ ដោយសម្លាប់ពួកគេទាំងអស់។ ពេលនេះ អ៊ីស្រាអែលបានមានសេរីភាពរួចខ្លួនពីអេស៊ីប និងបានរួចខ្លួនពីរបបទាសភាពហើយ។ នេះជាស្នាព្រះហស្តដ៏មានព្រះចេស្ដាអំពីការរំដោះ ហើយយើងគ្រប់គ្នាចូលចិត្តច្រៀងអំពីការរំដោះរបស់ព្រះជាម្ចាស់។

សេចក្ដីសន្យារបស់ពួកគេនោះ គឺជាទឹកដីកាណានដែលនៅចំពោះមុខពួកគេ។ វាជាទឹកដីនៃដូនតារបស់ពួកគេ ហើយបានប្រទានការសន្យាមកឱ្យគ្រាប់ពូជរបស់អប្រាហាំ។ នៅពេលដែលពួកគេធ្វើដំណើរឆ្លងកាត់វាលខ្សាច់ នោះពាក្យរបស់ម៉ូសេបានដក់ជាប់នឹងត្រចៀករបស់ពួកគេ។ វាជាទឹកដីដែលសម្បូរទៅដោយទឹកដោះ និងទឹកឃ្មុំ។ ស្ដាប់ទៅដូចជាល្អពេកហើយក្នុងការឱ្យប្រជាជនជឿថាពិត ដោយព្រោះថាពេញ

មួយជីវិតរបស់ប្រជារាស្ត្រទាំងនេះស្គាល់តែការធ្វើជាទាសករប៉ុណ្ណោះ។ ប៉ុន្តែនៅមានបញ្ហាមួយត្រង់នេះ។ ទឹកដីនោះមានជាតិសាសន៍ផ្សេងកំពុងកាន់កាប់រួចហើយ។ នៅពេលដែលពួកគេចូលទៅជិតទន្លេយ័រដាន់ ម៉ូសេក៏សម្រេចចិត្តបញ្ជូនអ្នកស៊ើបការណ៍ទៅពិនិត្យមើលផ្លូវដ៏ល្អបំផុតសម្រាប់ឱ្យពួកគេធ្វើដំណើរទៅនៅពេលដែលពួកគេឆ្លងទន្លេទៅកាន់ទឹកដីថ្មី និងឱ្យពួកអ្នកស៊ើបការណ៍នាំមកវិញនូវភោគផលនៃទឹកដីថ្មីនោះដើម្បីបង្ហាញជាភស្តុតាងដល់ប្រជាជនថា វាជាទឹកដីល្អដែលពេញដោយសក្តានុពល។

ប៉ុន្តែអ្នកស៊ើបការណ៍បាននាំមកវិញនូវរឿងមួយដែលធ្វើឱ្យប្រជាជនអ៊ីស្រាអែលចង់ត្រលប់ទៅអេស៊ីបវិញ។ ទឹកដីនោះមានសុទ្ធតែក្រុងនានាដែលហ៊ុំព័ទ្ធដោយជញ្ជាំង ហើយមនុស្សនៅទីនោះធំជាង និងខ្ពស់ជាងសាសន៍អ៊ីស្រាអែលច្រើនណាស់។ សាសន៍អ៊ីស្រាអែលយំខ្សឹកខ្សួលដោយការបាក់ទឹកចិត្ត ហើយបែរទៅរកព្រះជាម្ចាស់ និងលោកម៉ូសេ ដោយគិតថា ខ្លួនត្រូវបានកុហក។ ដោយសារតែការមិនជឿរបស់ពួកគេនោះព្រះជាម្ចាស់មិនបានដឹកនាំពួកគេឱ្យចូលក្នុងទឹកដីសន្យាឡើយ ដ្បិតទ្រង់ជ្រាបថា ដោយគ្មានជំនឿ នោះពួកគេនឹងត្រូវវិនាស។ មនុស្សជំនាន់នោះបានរស់នៅ និងស្លាប់នៅក្នុងវាលរហោស្ថានរហូតដល់គ្មានមនុស្សណាម្នាក់ក្នុងជំនាន់នោះនៅសេសសល់។

ពេលនេះ ព្រះជាម្ចាស់បានបញ្ជាឱ្យលោកយ៉ូស្វេដឹកនាំពួកគេឆ្លងទៅទីសន្យានោះ។ ប៉ុន្តែម្តងទៀត នៅពេលដែលពួកគេចូលមកកាន់ទន្លេយ័រដាន់ នោះក៏មានបញ្ហាមួយកើតឡើង។ ទន្លេកំពុងតែស្ថិតក្នុងស្ថានភាពជំនន់ ហើយប្រជាជនមិនអាចឆ្លងកាត់ទឹកដែលកំពុងហូរយ៉ាងលឿននោះទេ។ ប៉ុន្តែព្រះជាម្ចាស់ក៏បានញែកទឹកជាពីរម្តងទៀត ហើយប្រជាជនអ៊ីស្រាអែលក៏បានដើរឆ្លងកាត់ដីស្ងួត ម្តងនេះមិនមែនកើតឡើងដោយសារជម្លោះ ដូចកាលដែលពួកគេចាកចេញពីអេស៊ីបនោះទេ ប៉ុន្តែពួកគេកំពុងចូលក្នុងជម្លោះនៅពេលដែលពួកគេហៀបចាប់យកព្រះបន្ទូលសន្យារបស់ពួកគេ។

នេះជាអ្វីដែលអ្នកត្រូវដឹង។ វាតែងតែអាចមានរឿងរ៉ាវ ឬបញ្ហាកើតឡើងដែលត្រូវដោះស្រាយនៅពេលដែលអ្នកឈានជើងចេញ ប៉ុន្តែចូរកុំភ័យខ្លាចឱ្យសោះ។ ព្រះជា

ម្ចាស់នឹងជួយអ្នក ហើយការពារអ្នកនៅពេលដែលអ្នកធ្វើវា។ ចូរចងចាំជានិច្ចថា នៅខាងក្រោយបញ្ហានោះគឺមាននូវព្រះបន្ទូលសន្យាហើយ។ សូមកុំភ្លេចពាក្យនេះឱ្យសោះ។

តាមពិត ខ្ញុំនឹងនិយាយអ្វីមួយនៅត្រង់នេះដែលនឹងធ្វើឱ្យអ្នកភ្ញាក់ផ្អើល។ ត្រូវតែប្រុងប្រៀបខ្លួនចំពោះបញ្ហាជានិច្ច។ ទេ ខ្ញុំមិននិយាយអំពីការស្វែងរកឱកាសទេ។ ឃើញទេ មនុស្សចំណាយប្រាក់ច្រើនណាស់ដើម្បីបោសសម្អាត ឬដោះស្រាយបញ្ហា។ អាជីវកម្មតែងតែជាចម្លើយចំពោះបញ្ហារបស់នរណាម្នាក់។ ជាឧទាហរណ៍ មនុស្សជួបនឹងបញ្ហាមួយ ពោលគឺពួកគេស្រេកឃ្លាន ដូច្នេះក៏មាននរណាម្នាក់ចាប់ផ្ដើមបើកហាងទំនិញនៅផ្លូវក្រោមដី។ ខ្ញុំជឿជាក់ថា អ្នកក៏ប្រហែលជាធ្លាប់ហូបនំសាំងវិចក្រោមដីដែរ ប៉ុន្តែអ្នកមិនបានយកបញ្ហានេះមកធ្វើជាផ្នត់គំនិតអាជីវកម្មទេ។ ប៉ុន្តែថ្ងៃនេះ ផ្លូវក្រោមដីមាននូវហាងទំនិញរាប់ពាន់នៅជុំវិញពិភពលោក ព្រោះថាពួកគេកំពុងដោះស្រាយបញ្ហារបស់នរណាម្នាក់។ ហើយអ្នកនឹងពោលថា «ខ្ញុំគួរតែបានធ្វើអាជីវកម្មនេះ» ហើយអ្នកពិតជាគួរតែបានធ្វើវាមែន។ ប៉ុន្តែអ្នកត្រូវតែគិតខុសផ្សេងពីគេ។

សព្វថ្ងៃនេះ ឌ្រិនដា និងខ្ញុំជាសេដ្ឋីទៅហើយ គឺមិនមែនដោយសារតែយើងវៃឆ្លាត ឬមានរូបរាងស្អាតបាតអ្វីទេ។ យើងគ្រាន់តែបានរៀនពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ ហើយព្រះជាម្ចាស់បានបង្ហាញដល់យើងនូវរបៀបដោះស្រាយបញ្ហាដែលយើងមាន។ បន្ទាប់មក ព្រះជាម្ចាស់បានបង្ហាញយើងពីរបៀបជួយអ្នកដទៃក្នុងការដោះស្រាយបញ្ហា។ វាមិនពិបាកណាស់ណានោះទេ!

## ទីកន្លែងនៃការរៀបចំ

ដូច្នេះ ក្រោយពេលដែលអ្នកសាបព្រោះក្នុងជំនឿរួច ហើយក្រោយពេលដែលអ្នកមាននូវផែនការ ចូរកុំគ្រាន់តែលោតចេញទៅដោយគ្មានការត្រិះរិះពិចារណាឡើយ។ សូមចងចាំខគម្ពីរក្នុងគម្ពីរជំពូក១៣។

*មួយទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជាកំណប់កប់ទុកក្នុងចំការ ដែលកាលណាមនុស្សម្នាក់បានឃើញ នោះក៏លាក់ទុក រួចចេញទៅ លក់របស់ទ្រព្យខ្លួនទាំងអស់ដោយអំណរ ដើម្បីនឹងទិញចំការនោះ។*

— ម៉ាថាយ ១៣:៤៤ (គខប)

ព្រះជាម្ចាស់តែងតែត្រាស់ហៅអ្នកទៅកន្លែងមួយដែលមានការរៀបចំជាមុន។ ដូច្នេះ ទោះបីជាអ្នកបានឮពីព្រះជាម្ចាស់ ហើយទ្រង់បានប្រទាននូវគំនិតមួយមកអ្នក ដែលគំនិតនោះជាការចាប់ផ្តើមនូវអាជីវកម្មដ៏អស្ចារ្យថ្មីមួយក្តី ចូរមានភាពប្រាកដអំពីពេលវេលាកំណត់។ ព្រះជាម្ចាស់តែងតែបើកបង្ហាញនូវកំណប់ដើម្បីជំរុញចិត្តអ្នកឆ្ពោះទៅកាន់ការរៀបចំជាមុនសិន។ សូមកត់សម្គាល់ថា ខ្ញុំមិនបានពោលថាព្រះជាម្ចាស់ប្រទានកំណប់មកអ្នកនោះទេ។ ខ្ញុំបាននិយាយថាទ្រង់បើកបង្ហាញអំពីកំណប់ ពោលគឺចម្លើយ។ មានមនុស្សជាច្រើនណាស់ដែលបានអានច្រឡំពីការបើកបង្ហាញអំពីកំណប់ ថាជាពេលដែលត្រូវចាប់យកកំណប់នោះ ដោយពួកគេទទួលបានលទ្ធផលយ៉ាងអាក្រក់។ ព្រះជាម្ចាស់នឹងតែងតែដឹកនាំអ្នកចូលក្នុងកន្លែងបណ្តុះបណ្តាល និងការរៀបមុនពេលដែលទ្រង់បញ្ជូនអ្នកឱ្យចេញទៅយកកំណប់នោះ។

ខ្ញុំដឹងថា ក្នុងករណីរបស់ខ្ញុំដែលក្នុងនាមខ្ញុំជាយុវជនវ័យក្មេងម្នាក់ ព្រះជាម្ចាស់បានប្រទាននូវនិមិត្តមួយឱ្យខ្ញុំឃើញខ្លួនឯងកំពុងឈរ ហើយក៏កំពុងកាន់ព្រះគម្ពីរនៅនឹងដៃ។ ក្នុងកំឡុងពេលកំពុងឈរនោះ ខ្ញុំមិនត្រឹមតែបានឃើញថាខ្ញុំកំពុងអធិប្បាយចេញពីព្រះគម្ពីរនោះទេ តែក៏បានមើលឃើញនូវបន្ទប់មួយ ហើយបានឃើញមនុស្សម្នាដែលខ្ញុំកំពុងអធិប្បាយទៅកាន់។ នៅពេលដែលខ្ញុំបានឃើញនិមិត្តនោះ ស្រាប់តែមានសំឡេងមួយបានបន្លឺមកកាន់ខ្ញុំថា «យើងកំពុងត្រាស់ហៅអ្នកឱ្យអធិប្បាយព្រះបន្ទូលរបស់យើង»។ ខ្ញុំបានឮសំឡេងនោះចំនួនបីលើក រួចនិមិត្តនោះក៏បានរលុបបាត់ទៅវិញ។ ពេលនោះខ្ញុំមានអាយុ១៩ឆ្នាំ។ ខ្ញុំកំពុងតែជួយលក់នៅហាងតីស្យូរបស់ប៉ាខ្ញុំ ហើយខ្ញុំពិតជាមិនដឹងថាតើនិមិត្តនោះមានន័យយ៉ាងណាសោះឡើយ។

ខ្ញុំបានដឹងថា ខ្ញុំត្រូវបានត្រាស់ហៅឱ្យអធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែរបៀប ឬកន្លែងដែលនឹងកើតឡើងនោះ ខ្ញុំមិនបានដឹងនៅឡើយទេ។

នៅក្នុងលក្ខណៈជាក់ស្តែង ខ្ញុំត្រូវបានប្រាស់ហៅឱ្យមានការត្រៀមបម្រុង។ គឺមិនយូរប៉ុន្មានក្រោយពេលដែលព្រះជាម្ចាស់បានប្រទានការបើកសម្ដែងនោះមក ទ្រង់បានប្រាប់ខ្ញុំឱ្យទៅសាលាព្រះគម្ពីរ ហើយបន្ទាប់មកក៏ទៅសាលាព្រះគម្ពីរ ORU ។ នៅទីនោះហើយដែលខ្ញុំបានជួបសេចក្ដីស្រលាញ់នៃជីវិតរបស់ខ្ញុំ នោះគឺឌ្រិនដា។ យើងក៏បានបន្តពីសាលាព្រះគម្ពីរ ORU មកបើកអាជីវកម្មមួយ ដែលជាផែនការដែលខ្ញុំមិនបានយល់ឡើយនាពេលនោះ។ ទ្រង់ប្រើប្រាស់ពេលវេលានោះដើម្បីបង្វឹកបង្វឺនខ្ញុំនៅក្នុងផ្នែកហិរញ្ញវត្ថុនៃជីវិត ដើម្បីបង្វឹកបង្វឺនខ្ញុំក្នុងច្បាប់ និងគោលការណ៍នៃព្រះរាជ្យរបស់ទ្រង់ ដែលវាបានក្លាយជាគ្រឹះនៃព័ន្ធកិច្ចរបស់ខ្ញុំ។ ទ្រង់ក៏បានប្រើប្រាស់ពេលវេលានោះដើម្បីជួយខ្ញុំឱ្យរីកធំធាត់នៅក្នុងការមានទំនុកចិត្តលើខ្លួនឯង ដោយសារខ្ញុំមានការភ័យខ្លាចក្នុងការនិយាយទៅកាន់មនុស្សម្នានៅពេលដែលខ្ញុំមានវ័យក្មេងជាង។

អាជីវកម្មនោះមិនបានចាប់ផ្តើមរហូតដល់ថ្ងៃទី១ខែកញ្ញា ឆ្នាំ១៩៩៥ ទើបព្រះជាម្ចាស់បានដឹកនាំយើងឱ្យបើកដំណើរការក្រុមជំនុំរបស់យើងដែលស្ថិតនៅជាន់ក្រោមនៃស្ថានីយ៍វិទ្យុគ្រិស្តបរិស័ទក្នុងតំបន់។ កម្មវិធីរបស់យើងដំបូងធ្វើឡើងនៅពេលព្រលប់ ហើយខ្ញុំក៏បានឈរនៅទីនោះ ខ្ញុំក៏បានឃើញរូបភាពដូចគ្នាបិះបិតទៅនឹងនិមិត្តដែលព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំកាលពី២១ឆ្នាំកន្លងទៅ។

ដូចនេះ ដើម្បីយល់ថា នៅពេលដែលអ្នកបានឮពីនិមិត្ត ទទួលបានការដឹកនាំ ឬទទួលនូវគំនិត ដែលជាធម្មតាមិនមានន័យថាត្រូវបោះជំហាននាពេលនោះទេ។ ព្រះជាម្ចាស់នឹងប្រាប់អ្នកនៅពេលដែលអ្នកបោះជំហានចេញទៅក្នុងរបៀបដូចគ្នាដែលទ្រង់ប្រទានផែនការមកឱ្យអ្នក។ ទ្រង់នឹងមានបន្ទូលមកកាន់អ្នក ហើយអ្នកនឹងដឹងពីផែនការនោះ។

នៅក្នុងករណីរបស់ខ្ញុំ យើងកំពុងចូលរួមក្នុងក្រុមជំនុំតូចមួយដែលនៅក្បែរផ្ទះរបស់យើងក្នុងឆ្នាំ១៩៩៥ ហើយនៅក្នុងកម្មវិធីរាត្រីថ្ងៃអាទិត្យ ព្រះជាម្ចាស់បានចាប់ផ្ដើមដោះស្រាយនឹងខ្ញុំ។ ខ្ញុំមិនអាំចស្ដាប់លើអ្វីដែលគ្រូគង្វាលកំពុងនិយាយទេ ដ្បិតអីព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់កំពុងស្ថិតក្នុងខ្ញុំយ៉ាងខ្លាំងក្លា។ ខ្ញុំបានដឹងថា នោះជាពេលដែលត្រូវបោះជំហានចេញទៅហើយ! ហើយអ្នកក៏នឹងត្រូវធ្វើដែរ។

ខ្រិនដា និងខ្ញុំពិតជាពេញចិត្តជាខ្លាំងក្នុងការមើលឃើញអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានធ្វើ ប៉ុន្តែចិត្តឆេះឆួលរបស់យើងស្ថិតនៅលើគ្រប់យ៉ាងដែលទ្រង់កំពុងធ្វើ!!! យើងបានប្ដេជ្ញាថាយើងនឹងអធិប្បាយ និងបង្រៀនសារអំពីព្រះរាជ្យអស់មួយជីវិតរបស់យើង។ គ្មានអ្វីដែលធ្វើឱ្យយើងរំជួលចិត្តជាងការដែលបានឃើញមុខមនុស្សពេញដោយពន្លឺប្រកបដោយការបើកបង្ហាញ នៅពេលដែលយើងបង្រៀននោះទេ។ យើងដឹងថាការនោះមានន័យដូចម្ដេច។ នោះពួកគេកំពុងតែស្ដាប់ឮចម្លើយហើយ។

យើងដឹងថា ព្រះរាជ្យក៏ជាចម្លើយរបស់អ្នកផងដែរ! ដូច្នេះ តើអ្វីជាគោលការណ៍ទីប្រាំដែលព្រះជាម្ចាស់បានបង្រៀនដល់ខ្ញុំនោះ?

## ជំហានទី ៥៖ នៅពេលអ្នកដឹងពីពេលវេលា វិធីសាស្ត្រ និងទីកន្លែង ចូរកុំបង្អែបង្អង់ឱ្យសោះ! ទីពីរ ចូរកុំភ្ញាក់ផ្អើលដោយសារការកាំរភូសឡើយ!

អ្នកនិងព្រះជាម្ចាស់អាចបំពេញការងារចប់សព្វគ្រប់ ចូរកុំមានចិត្តសង្ស័យឡើយ! ចូរគ្រាន់តែចងចាំថា ព្រះជាម្ចាស់មានបំណងព្រះហឫទ័យចង់ឱ្យអ្នកបានចម្រុងចម្រើន។

*អ្នកស្ងួនភ្ងាអើយ ខ្ញុំប្រាថ្នាចង់ឱ្យអ្នកបានចម្រើនឡើងគ្រប់ជំពូក ហើយឱ្យបានសុខសប្បាយខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចម្រើនឡើងដែរ*

— ៣យ៉ូហាន ២ (ពគប)

ចូរកុំអនុញ្ញាតឱ្យនរណាម្នាក់ប្រាប់អ្នកថា វាមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងសេចក្តីប្រសើរបំផុតរបស់ទ្រង់សម្រាប់អ្នកដើម្បីឱ្យមានសុខភាពល្អ និងមានភាពចម្រុងចម្រើនក្នុងជីវិតឡើយ! នេះជាអ្វីដែលសាតាំងបានលួចពីពិតពផែនដី និងជាអ្វីដែលព្រះជាម្ចាស់បានស្តារអ្នកនៅក្នុងព្រះយេស៊ូគ្រិស្ត។ សាសនាបានបង្រៀនមនុស្សនូវសេចក្តីកុហកអំពីព្រះជាម្ចាស់។ ពេលខ្លះ មនុស្សម្នាត្រូវការដកចេញនូវរឿងប្រឌិតមុនពេលដែលពួកគេរៀនអំពីសេចក្តីពិត។ ថ្ងៃមួយ ខ្ញុំបានទទួលនូវអ៊ីមែលខាងក្រោមនេះ ដែលវាបង្ហាញពីភាពចាំបាច់ដើម្បីស្អាងគំនិតរបស់អ្នកឱ្យថ្មីឡើងដើម្បីមកដឹងពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល។

*សួស្តីលោកហ្គារី*

*ខ្ញុំឈ្មោះអានីត។ ខ្ញុំបានធំធាត់ឡើងនៅក្នុងគ្រួសាររបស់គ្រូគង្វាលនិកាយបាទីស្ទ ដែលខ្ញុំត្រូវបានសង្គ្រោះតាំងពីនៅកុមារភាពមកម្ល៉េះ ហើយខ្ញុំបានស្រលាញ់ព្រះយេស៊ូជាពន់ពេក។ ក្នុងវ័យជំទង់ ខ្ញុំបានទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណ និងបានចាប់ផ្តើមយល់ពីការថ្វាយបង្គំដ៏ពិត ការប្រោសឱ្យជាការរំដោះ អំណោយទានខាងវិញ្ញាណ និងសេចក្តីពិតផ្សេងៗទៀតអំពីព្រះរាជ្យនៃព្រះជាម្ចាស់។ ខ្ញុំបានរៀនអំពីគោលការណ៍មូលដ្ឋាននៃការសាបព្រោះ និងការច្រូតកាត់តាមរយៈគ្រូបង្រៀនជាច្រើននៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ ប៉ុន្តែខ្ញុំមិនបានដឹងថាខ្ញុំខ្លួនឯងមានបញ្ហាពិតប្រាកដមួយក្នុងការជឿថា គ្រិស្តបរិស័ទ ជាពិសេសគ្រូគង្វាល និងមនុស្សបម្រើក្នុងព័ន្ធកិច្ច គួរតែស្វែងរកការចម្រុងចម្រើនលើសពីការត្រឹមមានតម្រូវការជាមូលដ្ឋានរបស់ពួកគេ រហូតដល់ស្វាមីរបស់ខ្ញុំ គឺលោកចន «បានពើបប្រទះ» នឹងការបង្រៀនរបស់អ្នក។ យើងបានរកឃើញថា យើងទាំងពីរពិតជាមិនបានយល់ពីរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់ធ្វើការសោះ។*

យើងស្ថិតនៅក្នុងក្រុមបម្រើព័ន្ធកិច្ច ហើយយើងស្មោះត្រង់នឹងតង្វាយមួយភាគដប់ណាស់។ យើងក៏ជាអ្នកដែលផ្តល់ឱ្យដ៏មានចិត្តសប្បុរសដែរ ហើយថែមទាំងបានបង្រៀនពីគោលការណ៍នៃការសាបព្រោះ និងការច្រូតកាត់ទៀតផង។ ប៉ុន្តែយើងមានអារម្មណ៍ថាយើងបានរស់នៅក្នុងជីវិតដ៏មានផាសុកភាព ហើយនោះជាអ្វីដែលយើងគួររំពឹងចង់បាន។ មកដល់ត្រឹមឆ្នាំ២០០៣ គឺនៅពេលដែលយើងជួបនឹងបញ្ហាភ្លើងឆេះនៅឯផែរបស់យើង ដែលជាកន្លែងដែលយើងបានធ្វើជំនួញ និងបានដាក់ជាទីស្នាក់ការកណ្តាល។ បន្ទាប់មកក៏មានព្រឹត្តិការណ៍មួយចំនួនទៀតដែលបានផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាង។ ចនបានចាប់ផ្តើមមានបញ្ហាបេះដូងជាប្រចាំ ដោយជាក់ស្តែងទៅគាត់ត្រូវតែធ្វើការវះកាត់បេះដូងចំហ។ នៅពេលនោះ យើងមិនមានបណ្ណធានាសុខភាពទេ ហើយយើងក៏ចាប់ផ្តើមរងការចំណាយថ្លៃមន្ទីរពេទ្យយ៉ាងច្រើន។ ភាពមិនអាចធ្វើការបានរបស់គាត់រឹតតែធ្វើឱ្យស្ថានភាពកាន់តែយ៉ាប់យ៉ឺនជាងមុនទៅទៀត។ ហើយក្រោយមក ការសម្រេចចិត្តដែលធ្វើឡើងដោយយើងក៏បណ្តាលឱ្យមានបញ្ហាហិរញ្ញវត្ថុកាន់តែខ្លាំងជាងមុន។ នៅឆ្នាំ២០១៥ បែបផែនជីវិតធម្មតារបស់យើងក៏បានផ្លាស់ប្តូរពីភាពល្អប្រសើរ មកជាមនុស្សដែលកំពុងវណ្ឌកនឹងបំណុល ដោយរាប់បញ្ចូលទាំងពន្ធទៀតផង។

យើងធ្លាប់តែមានចិត្តសប្បុរស ព្រោះយើងចូលចិត្តផ្តល់ឱ្យ ហើយជឿលើការសាបព្រោះ និងការច្រូតកាត់។ យើងបានខិតចំស្វែងរកព្រះអម្ចាស់ច្រើនជាងពេលណាៗទាំងអស់ដើម្បីចម្លើយ។ បន្ទាប់មក ចនក៏បានពើបប្រទះនឹងការបង្រៀនរបស់អ្នកនៅលើប៉ុស្តិ៍ទូរទស្សន៍។ ប៉ុន្តែពីរបីថ្ងៃក្រោយមក គាត់ក៏បានឃើញកម្មវិធីរបស់អ្នកម្តងទៀត ហើយពេលនោះគាត់ប្រឹងស្តាប់ឥតឈប់ឡើយ។ ទីបំផុត គាត់បានកម្មង់ធនធានបង្រៀនគ្រប់យ៉ាងដែលអ្នកមានលក់ក្នុងពេលនោះ! យើងបានរស់នៅជាមួយនឹងធនធានទាំងនោះអស់រយៈពេល

*ពីរឆ្នាំ មុនពេលដែលយើងទាំងពីរអាចបោះចោលនូវជំនឿផ្លូតៗថា វាជាភាពខុសឆ្គងក្នុងការបានមានគ្រប់គ្រាន់ និងលើសពីគ្រប់គ្រាន់ទៅទៀត។*

*នៅថ្ងៃមួយ យើងកំពុងតែមើលឌីវីឌីមួយ គឺប្រហែលជាលើកទីដប់ហើយ ដែលត្រង់ចំណុចនោះអ្នកបានបង្រៀនពីគម្ពីរម៉ាថាយជំពូក១៧ អំពីព្រះយេស៊ូកំពុងមានបន្ទូលប្រាប់ពេត្រុសឱ្យនេសាទត្រី និងប្រើប្រាស់កាក់នៅក្នុងមាត់របស់គេឱ្យទៅបង់ពន្ធ ដោយសាច់រឿងមានផ្សារភ្ជាប់នឹងការបង្ហាញឱ្យដឹងនៅក្នុងគម្ពីរ ២ពង្សាវតារក្សត្រជំពូក៤ ស្តីពីស្ត្រីម្នាក់ដែលបានប្រើប្រាស់អ្វីដែលគាត់មាននៅក្នុងផ្ទះរបស់ខ្លួន។*

*រំពេចនោះ ខ្ញុំក៏នឹកចាំថា កាលពីពីរបីឆ្នាំមុន មានមិត្តម្នាក់បានឱ្យកាក់មាសមកយើងជាការដោះដូរនឹងកិច្ចការមួយចំនួនដែលយើងបានធ្វើសម្រាប់ពួកគេ។ វាមិនគ្រប់គ្រាន់សម្រាប់ដោះបំណុលទេ ប៉ុន្តែវាមិនមែនជា «អ្វីមួយ» ដែលយើងមាននៅក្នុងផ្ទះរបស់យើងដែលយើងអាចសាបព្រោះនោះទេ! យើងបានសាបព្រោះកាក់នោះចូលទៅក្នុងព័ន្ធកិច្ចរបស់អ្នក និងបានក្លាយជាដៃគូផ្ទៃក្នុង និងឃ្លាំមើលអ្វីដែលព្រះជាម្ចាស់អាចនឹងធ្វើបន្ទាប់ទៀត។*

*ក្នុងរយៈពេលពីរបីខែបន្ទាប់ យើងបានបន្តពឹងផ្អែកលើសេចក្តីបង្រៀនរបស់អ្នក ហើយយើងជួបការរាំងស្ទះក្នុងការគេចចេញពីបញ្ហាលុយកាក់ ក្នុងពេលកំពុងបង់ថ្លៃបំណុល។ ស្រាប់តែនៅរាត្រីមួយ ខ្ញុំបានសុបិនឃើញថា ព្រះជាម្ចាស់បានបង្ហាញឱ្យខ្ញុំឃើញនូវទឹកប្រាក់ដ៏ច្រើនកំពុងមកកាន់យើង។ ក្នុងអំឡុងពេលនៃសប្តាហ៍បន្ទាប់ពីនោះមក យើងបានឃើញព្រះពរផ្នែកហិរញ្ញវត្ថុតិចតួចកំពុងធ្លាក់ចុះមក។ យើងក៏បន្តអធិស្ឋាន និងថ្វាយកាន់តែច្រើន ដូចដែលព្រះជាម្ចាស់បានណែនាំ ហើយយើងក៏បានប្រកាសពីសេចក្តីពិត*

*របស់ព្រះជាម្ចាស់ និងបានស្ដាប់ដើម្បីធ្វើឱ្យប្រាកដថា យើងបានស្ដាប់បង្គាប់គ្រប់យ៉ាងដែលយើងបានជឿថាទ្រង់កំពុងមានបន្ទូលឱ្យយើងធ្វើ។*

*បន្ទាប់មក ក៏មានស្ថានការណ៍មួយបានកើតឡើងបញ្ច្រាសពីការនោះដែលមើលទៅហាក់ដូចជាសឹងតែមិនអាចកើតឡើងឡើយ។ យើងបានឃើញការចាក់បំពេញនៃក្ដីសុបិន្តកើតឡើងបន្ទាប់ពីនោះយ៉ាងរហ័ស។ ចំនួនប្រាក់ដែលយើងទទួលបាននោះគឺមានចំនួនច្រើនជាង និងលើសលប់ជាងអ្វីដែលយើងត្រូវការដើម្បីបង់ថ្លៃបំណុលដែលយើងជំពាក់ទៅទៀត។ ពេលនេះយើងរួចផុតទុក្ខពីបំណុលហើយ។ ពេលនេះយើងកំពុងស្វែងរកយុទ្ធសាស្ត្រពីរបៀបដែលត្រូវបណ្ដាក់ទុនប្រកបដោយភាពឈ្លាសវៃ និងរស់នៅក្នុងជីវិតបែបចំណែកមួយទ្វេជាពីរ ដើម្បីឱ្យយើងអាចផ្ដល់ឱ្យដោយភាពសប្បុរស និងតែងតែបន្តធ្វើក្នុងគ្រប់ឱកាសទាំងអស់។*

ចន និងអានីត

យើងបានទទួលនូវសារអ៊ីមែលបែបនេះគ្រប់ពេលដែលមនុស្សម្នាបានរៀនសូត្រពីសេចក្ដីពិតអំពីព្រះជាម្ចាស់ និងព្រះរាជ្យរបស់ទ្រង់ ហើយមានការដឹងខ្លួនថាពួកគេត្រូវបានកុហកដោយសាសនា។

ខ្ញុំរកឃើញថា នៅពេលដែលគំនិតរបស់ខ្ញុំបានស្អាងឱ្យថ្មីមករកសេចក្ដីល្អរបស់ព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់ នោះខ្ញុំអាចរីកចម្រើននៅក្នុងការបើកបង្ហាញដែលខ្ញុំត្រូវការដើម្បីឱ្យមានសេរីភាព។ សូមចាំថា មិនត្រូវសង្ស័យចំពោះព្រះជាម្ចាស់ឡើយ។ ប្រសិនបើមានស្ថានភាពមួយនៅក្នុងជីវិតរបស់អ្នក ដែលប្រហែលជាមានសភាពបែបបរាជ័យលើផ្នែកនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នោះ ចូរធ្វើអ្វីដែលពួកសិស្សបាន

**ទ្រង់នឹងមានបន្ទូលមកកាន់អ្នក ហើយជួយអ្នកឱ្យបានសិក្សាស្វែងយល់ពីរបៀបដែលព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ដំណើរការ។**

ធ្វើ។ ពួកគេមិនបានសួរព្រះយេស៊ូ «ព្រះយេស៊ូ ហេតុអ្វីបានជាទ្រង់មិនបណ្ដេញវិញ្ញាណអាក្រក់នោះចេញ?» ទេ ពួកគេបានសួរថា «ហេតុអ្វីបានជាយើងមិនអាចបណ្ដេញវិញ្ញាណអាក្រក់នោះចេញ?» ពួកគេដឹងថា សៀគ្វីខ្លីនោះត្រូវតែនៅខាងគេ ហើយពួកគេសុំឱ្យព្រះយេស៊ូជួយឱ្យពួកគេយល់។ ប្រសិនបើអ្នកមិនបានឃើញអ្វីដែលព្រះគម្ពីរចែងថាជារបស់អ្នកនៅក្នុងជីវិតរបស់អ្នក នោះចូរទូលសុំព្រះជាម្ចាស់ឱ្យទ្រង់បង្ហាញពីមូលហេតុ! ទ្រង់នឹងមានបន្ទូលមកកាន់អ្នក ហើយជួយអ្នកឱ្យបានសិក្សាស្វែងយល់ពីរបៀបដែលព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ដំណើរការ។

ទើបតែម្សិលមិញនេះ អ្នកជំនួញម្នាក់ក្នុងក្រុមជំនុំរបស់ខ្ញុំបានឮដំណឹងពីធនាគាររបស់គាត់ថា ប្រាក់ជំនួយសហព័ន្ធដែលត្រូវទទួលតាមការសន្យាដំបូងរបស់គាត់នោះត្រូវបានបដិសេធ។

គាត់បានស្មានទុកជាមុនអំពីប្រាក់នោះរួចទៅហើយ ហើយក៏បានរៀបចំផែនការសម្រាប់វាដែរ។ ដោយគ្មានជំនួយ គាត់នឹងត្រូវបញ្ឈប់បុគ្គលិករបស់គាត់ហើយ។ នៅពេលដែលគាត់សួរខាងធនាគារថាហេតុអ្វីបានជាប្រាក់នោះត្រូវបានបដិសេធ នោះពួកគេមិនអាចឆ្លើយថាមកពីមូលហេតុអ្វីបានឡើយ។ ដោយសារតែគាត់បានគិតថាគាត់មានប្រាក់ច្រើនកំពុងតែធ្លាក់ចូលមក នោះគាត់ក៏បានធ្វើមុនមួយជំហាន និងបានបណ្ដាក់ទុនប្រាក់ដែលគាត់មាននោះទៅលើសម្ភារៈផ្គត់ផ្គង់ដែលគាត់ត្រូវការចាំបាច់។ ប៉ុន្តែពេលនេះ ដោយសារតែប្រាក់នោះមិនធ្លាក់មក នោះគាត់ក៏អស់ប្រាក់ពីខ្លួន ហើយមិនដឹងថាត្រូវធ្វើអ្វី។ របស់តែមួយដែលគាត់នៅសល់នោះគឺ កាតអំណោយនៅក្នុងកាបូបរបស់គាត់ ដែលមាននរណាម្នាក់បានផ្ដល់វាឱ្យគាត់។ ភ្លាមៗនោះ គាត់ក៏បានបើករថយន្តទៅក្រុមជំនុំជាមួយនឹងគាត់នោះ ដោយសារគាត់បានដឹងថា គាត់ត្រូវសាបព្រោះនូវអ្វីដែលគាត់មាន និងបានជឿថាព្រះជាម្ចាស់ត្រូវតែជួយគាត់ក្នុងរដូវកាលដ៏លំបាកនេះ។ នៅក្នុងម៉ោងដែលគាត់បានទម្លាក់កាតអំណោយនោះនៅក្នុងក្រុមជំនុំ

សម្រាប់ធ្វើជាគ្រាប់ពូជ នោះខាងធនាគារក៏បានទូរសព្ទមកគាត់ និងបានពោលថា ពួកគេសុំទោស គឺដោយសារមានកំហុសកើតឡើង។ ពួកគេកំពុងតែផ្ញើប្រាក់មកហើយ។

## អ្នកមានចំណែកដែលត្រូវធ្វើ

មុននឹងបញ្ចប់មេរៀនជំពូកនេះ ខ្ញុំសូមបញ្ចេញនូវពាក្យពេចន៍ចុងក្រោយពាក់ព័ន្ធនឹងការចាប់យកប្រាក់ដែលអ្នកត្រូវការ។ ខ្ញុំបានរកឃើញថា ប្រជារាស្រ្តជាច្រើនរបស់ព្រះជាម្ចាស់មាននូវដួងចិត្តក្នុងការថ្វាយ មានដួងចិត្តសម្រាប់មនុស្ស ប៉ុន្តែគ្មានប្រាក់។ ខ្ញុំជឿថា មូលហេតុចម្បងដែលមនុស្សបរាជ័យក្នុងការមើលឃើញនូវការឱ្យផលត្រលប់មកវិញនូវអ្វីដែលពួកគេបានថ្វាយនោះ គឺជាការយល់ឃើញខុសឆ្គងនៃអ្វីដែលគួរតែបានកើតឡើងក្រោយពេលដែលពួកគេបានថ្វាយ។ មានគ្រិស្តបរិស័ទជាច្រើនបានជឿទាំងខុសថា ព្រះជាម្ចាស់នឹងគ្រាន់តែនាំយកនូវប្រាក់ដែលពួកគេជឿថាបានប៉ុណ្ណោះ។ ប៉ុន្តែការនេះមិនអាចទៅរួចទេ ព្រោះថាព្រះជាម្ចាស់មិនមានប្រាក់ទេ។ ប្រាក់ទាំងអស់សុទ្ធតែនៅក្នុងពិភពផែនដី ហើយវាគ្រាន់តែជាផលិតផលជួញដូរ (ការទិញ ឬការលក់អ្វីមួយ) ប៉ុណ្ណោះ។

ដូច្នេះ នៅពេលដែលយើងថ្វាយ ប្រសិនបើយើងយល់នូវទិដ្ឋភាពនៃដំណើរការនេះ នោះយើងត្រូវតែស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់ការបង្ហាញប្រាប់ពីផែនការការចង្អុលបង្ហាញ ឬគំនិតមួយដែលយើងអាចបង្កើត ឬចាប់យកនូវទ្រព្យសម្បត្តិនៅក្នុងទីផ្សារបាន។ ការនេះមិនមែនមានន័យថាអ្នកត្រូវតែមានអាជីវកម្មក្នុងពេលមួយពព្រិចភ្នែកឡើយ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធនឹងដឹកនាំនាំទៅកន្លែងណាមួយនៅក្នុងទីផ្សារដើម្បីដាក់នូវទុនសកម្មរបស់អ្នក។ ទុនសកម្មគឺជាអ្វីមួយដែលមានសមត្ថភាពដើម្បីចាប់យក ឬបង្កើតសាច់ប្រាក់នៅក្នុងទីផ្សារ។ ព្រះជាម្ចាស់នឹងដឹកនាំជំហានរបស់អ្នក និងមាននូវផែនការដែលអ្នកត្រូវធ្វើតាម។ សម្រាប់មនុស្សភាគច្រើន ខ្ញុំជឿថាទុនសកម្មដ៏ល្អបំផុត លឿនបំផុត និងពេញនិយមបំផុតនោះគឺអាជីវកម្ម។ នៅពេលដែលខ្ញុំនិយាយថាអាជីវកម្ម ខ្ញុំមិនបានដកចេញនូវការធ្វើការក្រោមការ ឬស្ថិតក្នុងការសហការ

ទេ ប៉ុន្តែជាទុនសកម្មនោះត្រូវតែមានទំហំធំល្មមក្នុងការចាប់យកត្រូវដែលអ្នកត្រូវការ។ វាអាចជាអាជីវកម្មរបស់អ្នក ឬរបស់នរណាម្នាក់។

ប៉ុន្តែនៅពេលដែលនិយាយពីរឿងទុនសកម្មនេះ នៅក្នុងបទពិសោធរបស់ខ្ញុំ មនុស្សភាគច្រើនធ្វើការស្ទូចត្រីបាឡែននៅក្នុងអាងងូតទឹក។ ខ្ញុំសូមពន្យល់ចុះ។ ឧបមាថា មនុស្សម្នាក់មានការងារធ្វើនៅក្នុងហាងទំនិញក្នុងតំបន់ដោយទទួលបានប្រាក់ ១០ ដុល្លារក្នុងមួយម៉ោង។ ប៉ុន្តែពេលនេះ ពួកគេបានសម្រេចចិត្តសងបំណុលផ្ទះក្នុងតម្លៃ ១៥០.០០០ដុល្លារ ហើយចង់ប្រើប្រាស់ច្បាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់ដើម្បីសម្រេចការនេះ។ ហ្នឹងហើយ ស្តាប់ទៅល្អដែរ។

បន្ទាប់មក ពួកគេបានឮពីការសាបព្រោះ និងការច្រូតកាត់ ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយពួកគេសាបព្រោះ និងជឿថាអាចបង់ថ្លៃផ្ទះនោះ។ ជាថ្មីម្តងទៀត ស្តាប់ទៅល្អហើយ។ ប៉ុន្តែដោយសារមូលហេតុមួយចំនួន ពួកគេគិតថា ប្រាក់នោះនឹងលេចចេញមក។ ពួកគេដឹងថា ការងាររបស់ពួកគេមិនមានលទ្ធភាពដើម្បីអាចចាប់យកប្រាក់ឱ្យបានគ្រប់គ្រាន់ដើម្បីបង់ផ្ទះនោះឡើយ ដូច្នេះពួកគេបានដាក់ក្តីសង្ឃឹមទាំងមូលរបស់ខ្លួនទៅលើព្រះអម្ចាស់ (ហើយវាជាការល្អហើយ)។ ប៉ុន្តែនៅពេលដែលខ្ញុំនិយាយថា «ដាក់ក្តីសង្ឃឹមទៅលើព្រះអម្ចាស់» អ្នកត្រូវតែយល់ថា អ្វីដែលខ្ញុំកំពុងនិយាយនោះគឺថា យើងកំពុងដាក់ក្តីសង្ឃឹមរបស់ខ្លួននៅលើព្រះអម្ចាស់ ដើម្បីដើម្បីឱ្យទ្រង់ប្រទាននូវប្រាជ្ញា និងការណែនាំដល់យើងដើម្បីចាប់យកនូវប្រាក់នោះ។ ហើយការនេះអាចមានន័យថា មានពាក់ព័ន្ធនឹងការផ្លាស់ប្តូរមួយចំនួន។

ឃើញទេ អ្វីដែលមនុស្សមិនបានដឹងនោះគឺថា ព្រះជាម្ចាស់អាចត្រូវដឹកនាំពួកគេទៅកាន់បឹងថ្មីមួយដើម្បីចាប់ត្រីបាឡែន មិនមែនចាប់ត្រីបាឡែននៅក្នុងអាងងូតទឹកក្នុងផ្ទះរបស់គេទេ។ ឃើញទេ ក្នុងអាងងូតទឹករបស់អ្នកមិនមានត្រីបាឡែនទេ! ការបង់ថ្លៃផ្ទះក្នុងតម្លៃ ១៥០.០០០ដុល្លារ ដែលរកចំណូលបាន១០ដុល្លារក្នុងមួយម៉ោង គឺជា

រឿងពិបាកធ្វើណាស់។ ប៉ុន្តែព្រះជាម្ចាស់ពិតជាជ្រាបថាតើត្រីនោះនៅត្រង់ណា ហើយអាចណែនាំអ្នកទៅកាន់កន្លែងត្រឹមត្រូវ និងវិធីសាស្ត្រចាប់ត្រីដែលអ្នកត្រូវការដើម្បីឈោងចាប់គោលដៅរបស់អ្នក។ តើអ្នកនៅចាំពីសាច់រឿងរបស់ពេត្រុស និងការចាប់ត្រីបានយ៉ាងច្រើននោះទេ? ពេត្រុសបានចុះទៅនេសាទពេញមួយយប់ ហើយរកត្រីមិនបានសោះ ប៉ុន្តែព្រះយេស៊ូបានប្រាប់គាត់ពីកន្លែងដែលត្រូវនេសាទ ហើយក្រោយមកទូករបស់ពេត្រុសមិនអាចផ្ទុកត្រីទាំងអស់បានទេ។ ឃើញភាពខុសគ្នាទេ? ព្រះបន្ទូលនៃការណែនាំ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។ ឃើញទេ ពេត្រុសកំពុងនេសាទត្រីនៅកន្លែងមិនត្រឹមត្រូវ ប៉ុន្តែព្រះយេស៊ូបានប្រាប់ថាត្រូវធ្វើអ្វី ហើយភាពជោគជ័យរបស់គាត់ក៏បានផ្លាស់ប្ដូរ។

នៅពេលឌ្រិនដា និងខ្ញុំបានស្ថិតក្នុងបំណុលយ៉ាងធ្ងន់ធ្ងរ យើងត្រូវតែរៀនស្ដាប់ព្រះជាម្ចាស់ និងដើរតាមទ្រង់ទៅកាន់បឹងដែលកាន់តែធំជាងមុនដើម្បីចាប់ត្រីដែលយើងត្រូវការ។ ការណែនាំរបស់ព្រះជាម្ចាស់បានបន្តនាំយើងមកដល់ទឹកដែលមានជម្រៅកាន់តែជ្រៅទៅៗ។ និយាយដោយត្រង់ទៅ ព្រះជាម្ចាស់បានដឹកនាំយើងមកដល់ចម្ងាយដ៏ឆ្ងាយ រហូតដល់យើងមិនអាចមើលឃើញដីគោកទៀតទេ ដែលជាកន្លែងដ៏គួរឱ្យភ័យខ្លាច ដ្បិតយើងមិនដែលមកដល់ទីនេះទេពីមុនមក ហើយរឹតតែគួរឱ្យខ្លាចនោះគឺនៅពេលដែលមានព្យុះបោកបក់មក។

ដោយសារតែមនុស្សភាគច្រើនកំពុងរង់ចាំព្រះជាម្ចាស់ដើម្បីឱ្យប្រាក់ធ្លាក់មក ពួកគេមិនដែលរៀនស្ដាប់អ្វីមួយដែលចម្លែកចំពោះពួកគេ និងការដឹកនាំទៅកាន់កន្លែងថ្មី និងគួរឱ្យខ្លាចដែលពួកគេមិនដែលបានទៅដល់ពីមុនឡើយ។ មនុស្សភាគច្រើនបានត្រឹមតែធ្វើអ្វីដែលពួកគេស្គាល់ អ្វីដែលពួកគេបានដឹងរួចហើយប៉ុណ្ណោះ។ ប៉ុន្តែត្រីបាឡែនមិននៅក្នុងអាងងូតទឹករបស់អ្នកទេ។ អ្នកត្រូវតែចេញទៅខាងក្រៅទៅកាន់ទឹកជ្រៅ។

ដូច្នេះ ចូរចាំទុកថា យើងមិនត្រូវអង្គុយស្ងៀមឈឹងនៅពេលយើងសាបព្រោះនោះទេ។ នៅពេលដែលយើងសាបព្រោះ យើងអាចឈោងចាប់ព្រះបន្ទូលរបស់ព្រះជា

ម្ចាស់ និងដឹងថា ព្រះជាម្ចាស់នឹងដឹកនាំយើងទៅកាន់ទីប្រមូលផល។ ប៉ុន្តែយើងត្រូវតែស្តាប់ដើម្បីបានការណែនាំ ដើរតាមការណែនាំនោះ ហើយបន្ទាប់មក ត្រូវមានសំណាញ់ដើម្បីចាប់ត្រីបាឡែននៅពេលដែលយើងទៅដល់ទីនោះ។

មានមនុស្សជាច្រើនដែលពិតជាបានបោះជំហាននានាដើម្បីប្តូរបឹងនេសាទ ប៉ុន្តែបានបរាជ័យក្នុងការផ្លាស់ប្តូរវិធីសាស្ត្រដែលបានប្រើដើម្បីចាប់ត្រីនៅក្នុងទីប្រមូលផលរបស់ខ្លួន។ ផ្លែសន្ទូចសម្រាប់ត្រីកន្ត្រប់នឹងមិនអាចស្ទូចយកត្រីបាឡែនបានឡើយ។ (និយាយទៅ ខ្ញុំមិនមែនកំពុងបង្ហាញថា យើងគួរតែចាប់ត្រីបាឡែនមួយមុខទេ។ ខ្ញុំគ្រាន់តែប្រើឧទាហរណ៍នេះដោយផ្អែកលើទំហំរបស់វាប៉ុណ្ណោះ។)

**យើងត្រូវតែធ្វើការជាមួយព្រះជាម្ចាស់ រៀបចំសម្រាប់ការប្រមូលផល ហើយធ្វើនូវអ្វីដែលជាផ្នែករបស់យើងដើម្បីចាប់យកគ្រប់ទាំងឱកាសដែលព្រះជាម្ចាស់បានដាក់នៅចំពោះមុខយើង។**

នៅពេលដែលអ្នកនៅកន្លែងត្រឹមត្រូវ វិធីសាស្ត្ររបស់អ្នកត្រូវតែអាចដោះស្រាយសម្រាប់ទម្ងន់ធ្ងន់ជាង និងសម្ពាធខ្លាំងជាងមុន ដែលជាការតម្រូវសម្រាប់ការប្រមូលផលធំជាងមុន។ ការទាំងអស់នេះទាមទារពេលវេលាដើម្បីសម្រេចបាន។ មានពេលជាច្រើន ព្រះជាម្ចាស់ជ្រាបថា យើងមិនអាចមានលទ្ធភាពនេសាទយកត្រីបាឡែនដែលយើងកំពុងនេសាទទេ នៅពេលដែលយើងយល់ស្របថានឹងនេសាទយកវា។ ប៉ុន្តែព្រះជាម្ចាស់នឹងបង្វឹកបង្វឹនយើង ហើយយើងអាចប្រាកដថា យើងនឹងច្បាស់ជាធ្វើការចាប់ត្រីនោះមកច្រាំង ប្រសិនបើយើងមិនរសាយចិត្ត។

ដូចនេះ សូមរំឭកឡើងវិញថា យើងត្រូវឈប់គិតរឿងប្រាក់ដែលបានមកដោយការអស្ចារ្យ ឬអ្វីដែលខ្ញុំហៅថាជាគំនិតបែបប្រអប់សារ (បោះបីជាព្រះជាម្ចាស់ធ្វើ

នូវរឿងអស្ចារ្យមួយចំនួនក្តី)។ ផ្ទុយទៅវិញ យើងត្រូវតែធ្វើការជាមួយព្រះជាម្ចាស់ រៀបចំសម្រាប់ការប្រមូលផល ហើយធ្វើនូវអ្វីដែលជាតួនាទីរបស់យើង ដើម្បីចាប់យកគ្រប់ទាំងឱកាសដែលព្រះជាម្ចាស់បានដាក់នៅពីមុខយើង។

ឫទ្ធានុភាពនៃការផ្គត់ផ្គង់ត្រូវបានដាក់នៅក្នុងដៃទាំងទ្វេរបស់អ្នកហើយ។ ទេ ខ្ញុំមិនមែនកំពុងនិយាយអំពីចំណងសៀវភៅរបស់ខ្ញុំទេ។ ខ្ញុំកំពុងនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានរាប់អ្នកបញ្ចូល។ ដូចនេះ ចូរតាមយកវាឱ្យបាន ហើយត្រូវតែយកឈ្នះកិច្ចការជាច្រើនដើម្បីព្រះគ្រិស្ត ដោយភាពជោគជ័យរបស់អ្នក និងធ្វើជាគំរូក្នុងអំឡុងពេលនៃការធ្វើកិច្ចការនេះ។

ខ្ញុំទើបតែបានឃើញសារអ៊ីមែលមួយលោតមក ហើយខ្ញុំក៏បានគិតថា វាជាការរំឭកដ៏ល្អសម្រាប់ការបិទបញ្ចប់មេរៀននេះ។

> *នៅពាក់កណ្តាលនៃការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក អាជីវកម្មរបស់យើងមានបំណុលត្រឹមតែ ៥.០០០ដុល្លារ និងបានដោះបំណុលអស់ ៨.០០០ដុល្លារ! យ៉ាងណា នៅមានច្រើនទៀត!! យើងកំពុងពិនិត្យមើលហិរញ្ញវត្ថុក្រុមហ៊ុនរបស់យើង ហើយក៏បានដឹងថា ត្រឹមថ្ងៃនេះ ចំណូលសុទ្ធនៃអាជីវកម្មរបស់យើងសម្រាប់ឆ្នាំ ២០២០ បានរ៉ាដាច់លើសចំណូលសុទ្ធនៃក្រុមហ៊ុនទាំងមូលរបស់យើងក្នុងឆ្នាំ២០១៩! យើងកំពុងចម្រុងចម្រើនលើសអ្វីដែលយើងអាចសុំ ឬគិតទុក (អេភេសូ ៣:២០) ទៅទៀត ខណៈដែលបណ្តាសាលោកិយលើសេដ្ឋកិច្ចពិភពលោកកំពុងបរាជ័យ! យើងពិតជារំភើបចំពោះអ្វីដែលព្រះជាម្ចាស់កំពុងតែធ្វើ។ ទ្រង់ពិតជាទៀងត្រង់ចំពោះព្រះបន្ទូលរបស់ព្រះអង្គណាស់!!*
>
> *សូមអរគុណ ពិតជាអរគុណណាស់លោកហ្គារី និងអ្នកស្រីឌ្រិនដា គ្រួសាររបស់ពួកគាត់ និងបុគ្គលិក ព្រមទាំងដៃគូរបស់ពួកគាត់ដែលបានពាំនាំនូវ*

*ព្រះបន្ទូលរបស់ព្រះជាម្ចាស់មកចូលក្នុងជីវិតរបស់យើង! យើងបានរស់នៅក្នុងភាពក្រីក្រ និងភាពអត់ឃ្លានអស់រយៈពេល១៧ឆ្នាំ ពោលគឺដូចលោកហ្គារី និងអ្នកស្រីខ្រិនដាក្នុងរយៈពេល៩ឆ្នាំនោះដែរ រហូតដល់គ្រូគង្វាលរបស់យើងចាប់ផ្តើមសាបព្រោះនូវការគោលការណ៍ ការដោះស្រាយរឿងរ៉ាវពាក់ព័ន្ធនឹងលុយកាក់ នៅក្នុងកម្មវិធីរាត្រីថ្ងៃពុធនៅឯក្រុមជំនុំ។ យើងខ្ញុំសូមថ្លែងអំណរគុណម្តងទៀត សូមព្រះប្រទានពរ!*

អ្នកក៏អាចប្រាប់រឿងរ៉ាវរបស់អ្នកមកកាន់ខ្ញុំតាមគេហទំព័រ Garykeesee.com ដែរ។ មានអ្នកផ្សេងទៀតដែលត្រូវការស្តាប់ឮថាតើព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងធ្វើការនៅក្នុងជីវិតរបស់អ្នកអស្ចារ្យយ៉ាងណា។

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក
## អំណាចនៃព្រះរាជទាន

រស់ដោយវេទនា...

ឬអាចមានក្តីស្រមៃធំ?

ជាខ្ញុំបម្រើនៃបំណុល...

ឬកំពុងតែសម្រេចនូវគោលបំណងដែលព្រះជាម្ចាស់បានរៀបចំសម្រាប់អ្នក?

តើចំណុចមួយណាខាងលើដែលស្តាប់ទៅ បង្ហាញពីអ្នក?

តើអ្វីនឹងបង្កើតឱ្យមានភាពខុសប្លែកនៅក្នុងជីវិតអ្នក?

*គឺព្រះរាជទាន (ការផ្គត់ផ្គង់)។*

យើងគ្រប់គ្នាសុទ្ធតែអាចយល់ស្របថា ការមានការផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់អ្វីៗដែលយើងត្រូវការនៅក្នុងជីវិត គឺជាការចាំបាច់។

ប៉ុន្តែតើអ្នកពិតជាយល់ពីអំណាចនៃព្រះរាជទានដែរឬទេ?

លោកគ្រូ ហ្គារី ឃីស៊ី ចង់បង្ហាញឱ្យអ្នកយល់។

នៅក្នុងសៀវភៅទីបួននៃសៀវភៅជាស៊េរី "បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក" លោកគ្រូហ្គារីលាតត្រដាងនូវសមាសធាតុដ៏សំខាន់បំផុតនៃជោគជ័យរបស់លោក និងជោគជ័យរបស់អ្នកដទៃ និងអាថ៌កំបាំងដ៏សំខាន់មួយទៀតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់៖ អំណាចនៃព្រះរាជទាន!

សូមរៀន៖

- ជំហានមូលដ្ឋានទាំងប្រាំដែលអ្នកអាចឈាន ដើម្បីទទួលបានការផ្គត់ផ្គង់ដែលអ្នកត្រូវការ។
- សារៈសំខាន់នៃជំនឿ និងរបៀបដែលអ្នកអាចដឹងនៅពេលណាដែលអ្នកមិនមានជំនឿ។
- របៀបដែលការបង្អែបង្អង់អាចមានគ្រោះថ្នាក់ដល់ស្លាប់។
- ប្រសិនបើអ្នកអាចជឿថាអ្នកអាចឈ្នះឆ្នោត (ពិតមែន ចំណុចនេះមាននៅក្នុងសៀវភៅនេះ)។
- និងច្រើនថែមទៀត!

សូមចូលរួមជាមួយលោកគ្រូហ្គារីនៅក្នុងដំណើរដែលបើកភ្នែកយើង និងរកឱ្យឃើញរបៀបអនុវត្តអំណាចនៃព្រះរាជទាននៅក្នុងជីវិតរបស់អ្នក!



លោកគ្រូ ហ្គារី ឃីស៊ីជាអ្នកនិពន្ធ វាគ្មិន សហគ្រិន អ្នកជំនាញហិរញ្ញវត្ថុ និងគ្រូគង្វាលដែលមានចិត្តឆេះឆួលជួយមនុស្សឱ្យយកឈ្នះនៅក្នុងជីវិត ជាពិសេសនៅលើផ្នែកជំនឿ ក្រុមគ្រួសារ និងហិរញ្ញវត្ថុ។ លោកគ្រូហ្គារី និងភរិយា គឺអ្នកគ្រូឌ្រិនដា បានបង្កើតអាជីវកម្មដ៏ជោគជ័យមួយចំនួន និងជាស្ថាបនិកនៃ Faith Life Now ដែលបង្កើតកម្មវិធីទូរទស្សន៍ពីរគឺ *ការដោះស្រាយរឿងលុយកាក់* និង *ឌ្រិនដា* សន្និបាតទូទាំងពិភពលោក និងធនធានអនុវត្តជាច្រើន។ លោកទាំងពីរក៏ជាគ្រូគង្វាលនៃក្រុមជំនុំ Faith Life Church ក្បែរទីក្រុងកូឡំបឹស រដ្ឋអូហៃយ៉ូ។

ប្រអប់សំបុត្រលេខ 779, New ALBANY, OH 43054
1.888.391.LIFE | garykeesee.com